# អាថ៌កំបាំងខាងវិញ្ញាណ
## របស់
# លោកគ្រូ ហ៊័ដសិន ថេល័រ

# The Spiritual Secret of Hudson Taylor

Dr. and Mrs. Howard Taylor

ផ្លូវពិត
plovpit.com

អាថ៌កំបាំងខាងវិញ្ញាណរបស់លោកគ្រូ Hudson Taylor

The Spiritual Secret of Hudson Taylor

Hudson Taylor’s Spiritual Secret written by Dr. and Mrs. Howard Taylor

First published in 1932 now in the public domain

Khmer Translation based on Modernized English Text ©2024 Nathan Wells

All rights reserved.

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៤

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក

ជំនួយការបកប្រែ៖ លោកគ្រូ យូ អន និងលោក ឈាង បូរ៉ា

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ហុង សម្កស, លោក ឡង់ គីមឡុង, លោក ស៊ូ ទិត្យ, លោក ឯក សត្យា

សូមថ្លែងអំណរគុណចំពោះ៖ លោកស្រី ឡូញ ស្រីរ័ត្ន, លោកស្រី ថាវ ប៊ុននី និងកញ្ញា រិន ខារីសា

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វើល ណាថាន និងលោក ខែម បូឡុង

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

plovpitshop.com

បោះពុម្ពលើកទី១ ចំនួន ៣.០០០ក្បាល ២០២៤ នៃគ.ស.

ISBN-978-9924-566-15-1

# មាតិកា


បុព្វកថា .......... ៧

១ អាថ៌កំបាំងដ៏បើកចំហ .......... ១១

២ ការលូតលាស់ខាងព្រលឹងវិញ្ញាណនៅឆ្នាំដំបូងៗ.......... ១៥

៣ ជំហានដំបូងនៃសេចក្តីជំនឿ.......... ២១

៤ ជំហានបន្ថែមទៀតនៅក្នុងសេចក្តីជំនឿ .......... ៣១

៥ សេចក្តីជំនឿដែលបានសាកល្បង និងធ្វើឲ្យរឹងមាំឡើង.......... ៤៣

៦ មិត្តភាព និងអ្វីលើសពីនេះទៅទៀត.......... ៥៧

៧ មាគ៌ានៃព្រះជាម្ចាស់ «គ្រប់លក្ខណ៍».......... ៧៣

៨ អំណរនៃចម្រូត .......... ៨៥

៩ ឆ្នាំអាថ៌កំបាំង.......... ៩៧

១០ មនុស្សដែលប្ដេជ្ញាចុះចូលចំពោះព្រះជាម្ចាស់ .......... ១០៥

១១ មនុស្សដែលព្រះជាម្ចាស់បានបញ្ជូនទៅ .......... ១០៩

១២ ភាពបន្ទាន់ខាងឯព្រលឹងវិញ្ញាណ.......... ១១៩

១៣ ពេលវេលាដ៏ខ្មៅងងឹត.......... ១៣៧

១៤ ជីវិតដែលបានផ្លាស់ប្រែ.......... ១៤៧

១៥ មិនស្រេកទៀតទេ .......... ១៥៩

១៦ ភាពបរិបូរណ៍ហូរហៀរ.......... ១៧៧

១៧ ព្រះពរកាន់តែបរិបូរណ៍ហូរហៀរ.......... ១៩៩

១៨ ប្រភពទឹកនៅតែបន្តបង្ហូរមក ........................................................ ២២៥

សេចក្តីបន្ថែម ........................................................................................ ២២៩

គម្រោងកាលប្បវត្តិ.....................................................................................២៣៧



លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេង
ដោយគ្រាន់តែចូលទៅកាន់គេហទំព័រ៖
hudsontaylorkhmer.com

# បុព្វកថា

សៀវភៅនេះបានរៀបរៀងជាពិសេសសម្រាប់អ្នកអានដែលមិនទាន់ដឹងច្បាស់អំពីជីវិតរបស់លោកគ្រូ ហ៉ាដសិន ថេល័រ (Hudson Taylor)។ សម្រាប់លោកអ្នកដែលបានដឹងច្រើនអំពីជីវប្រវត្តិរបស់លោកគ្រូ តាមរយៈអ្នកនិពន្ធនានា ឬសៀវភៅថ្មីៗរបស់លោកគ្រូ ម៉ាហ្សល ប្រ៊ូមហាល (Marshall Broomhall) នឹងមិនរកឃើញព័ត៌មានថ្មីច្រើនទេនៅក្នុងសៀវភៅនេះ។ ទោះជាយ៉ាងនេះក្ដី មានមនុស្សជាច្រើន ជាពិសេសនៅលោកខាងលិច ដែលមិនសូវស្គាល់លោកគ្រូ  ហ៉ាដសិន ថេល័រ មានពេលតិចដើម្បីអាន ហើយប្រហែលជាពួកគាត់មិនចង់អានសៀវភៅពីរភាគអំពីលោក ប៉ុន្តែនៅតែមានបំណងចង់មានបទពិសោធន៍ដូចទៅនឹងសេចក្ដីអំណរ និងកម្លាំងខាងក្នុងដែលលោកគ្រូ ហ៉ាដសិន ថេល័រ បានពិសោធន៍ដែរ។

អ្នកនិពន្ធមានបំណងចែករំលែកបទពិសោធន៍របស់ឪពុកជាទីស្រឡាញ់របស់ពួកគេជាមួយអស់អ្នកដែលរវល់ច្រើន ហើយចង់អរគុណចំពោះព្រះពរដែលបាននាំមកជីវិតរបស់ពួកគេតាមរយៈចរិតលក្ខណៈរបស់ឪពុកគាត់ និងអ្វីដែលគាត់បានរកឃើញនៅក្នុងព្រះ ក៏ដូចជាកិច្ចការដែលប្រកបដោយផលផ្លែរបស់គាត់ផងដែរ។

— លោក ហូវត ថេល័រ និងលោកស្រី ជីរលដាញ ថេល័រ (Howard and Geraldine Taylor)

ទីក្រុង ហ្វីឡាដែលហ្វៀ (Philadelphia) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៣២

ព្រះជាម្ចាស់ប្រើប្រាស់មនុស្ស ដើម្បីសម្រេចផែនការរបស់ទ្រង់។ ក្រុមជំនុំកំពុងតែស្វែងរកមធ្យោបាយដែលល្អប្រសើរ ប៉ុន្តែព្រះជាម្ចាស់ស្វែងរកមនុស្សដែលល្អប្រសើរវិញ។ អ្វី

ដែលក្រុមជំនុំត្រូវការសព្វថ្ងៃ គឺមិនមែនជារចនាសម្ព័ន្ធដែលល្អជាង អង្គការចាត់តាំងថ្មី ឬការឆ្នៃប្រឌិតថ្មីៗនោះទេ ប៉ុន្តែជាអស់អ្នកដែលព្រះវិញ្ញាណបរិសុទ្ធអាចប្រើប្រាស់បាន ជាអស់អ្នកដែលអធិស្ឋានអស់ពីចិត្ត និងឥតឈប់ឈរ ហើយនិងអស់អ្នកមានអំណាចនៅក្នុងការអធិស្ឋាន។ ព្រះវិញ្ញាណបរិសុទ្ធមិនបានយាងមកសណ្ឋិតលើម៉ាស៊ីននោះឡើយ ប៉ុន្តែសណ្ឋិតលើពួកមនុស្សវិញ។ ទ្រង់មិនបានប្រទានពរដល់គម្រោងទាំងឡាយទេ តែប្រទានពរដល់មនុស្ស—គឺអស់អ្នកដែលអធិស្ឋាន។

ព្រះរាជកិច្ចដ៏សំខាន់ លំបាក និងគង់នៅគឺជាការហ្វឹកហ្វឺនសាវ័កទាំងដប់ពីររបស់ព្រះគ្រីស្ទ។ ព្រះជាម្ចាស់មិនត្រូវការអស់អ្នកដែលមានទេពកោសល្យច្រើន រៀនបានខ្ពង់ខ្ពស់ ឬក៏មានសមត្ថភាពលេចធ្លោក្នុងការអធិប្បាយឡើយ ប៉ុន្តែផ្ទុយទៅវិញត្រូវការអស់អ្នកប្រកាន់យកភាពបរិសុទ្ធ ស្មោះត្រង់ មានសេចក្តីស្រឡាញ់ មានការប្តេជ្ញាចិត្ត និងស្មោះស្ម័គ្រចំពោះទ្រង់។ បុគ្គលបែបនេះអាចបង្កើតមនុស្សជំនាន់មួយថ្វាយព្រះ ដោយការអធិប្បាយឥតឈប់ឈរតាមរយៈការបង្រៀនដ៏បរិសុទ្ធ និងជាគំរូល្អនៅក្នុងព្រះវិហារ និងនៅខាងក្រៅផងដែរ។

— លោក អ៊ី. អិម បោនស៍ (E. M. Bounds)

លោក ជេ. ហ័ដសិន ថេល័រ (J. Hudson Taylor) គឺជាអ្នកស្ថាបនិកអង្គការបេសកកម្មចិនដីគោក (China Inland Mission)។ លោកគឺជាគ្រូពេទ្យម្នាក់ដែលពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងសេចក្តីជំនឿ។ គាត់បានចុះចាញ់ទាំងស្រុងចំពោះព្រះជាម្ចាស់ និងការត្រាស់ហៅរបស់ទ្រង់ ដែលបានបង្ហាញអំពីការលះចោលខ្លួនឯងដ៏អស្ចារ្យ និងមានចិត្តពេញដោយការក្តួលអាណិត ព្រមទាំងមានអំណាចដ៏អស្ចារ្យនៅក្នុងការអធិស្ឋានគួរឲ្យកត់សម្គាល់ផងដែរ។ លោកគ្រូ ហ័ដសិន មានទេពកោសល្យដ៏អស្ចារ្យនៅក្នុងការរៀបចំ មានគំនិតផ្តួចផ្តើមយ៉ាងស្វាហាប់ ការតស៊ូដោយឥតនឿយហត់ និងឥទ្ធិពលគួរឲ្យភ្ញាក់ផ្អើលលើមនុស្សម្នាទាំងឡាយ ប៉ុន្តែគាត់នៅតែរក្សាភាពដូចជាកូនក្មេងដែលបន្ទាបខ្លួន។

— លោកសាស្ត្រាចារ្យ វ៉ាំនែក (Professor Warneck)

គ្មានអ្នកណាស័ក្តិសមជាងគាត់ សម្រាប់រៀបចំកិច្ចការដ៏លំបាកនៅក្នុងការកសាង គ្រប់គ្រងបេសកកម្មអន្តរនិកាយ និងអន្តរជាតិដ៏ធំមួយនៅក្នុងប្រទេសចិនដែលមានប្រជាជនយ៉ាងសម្បើមនោះទេ។ អង្គការបេសកកម្មនៅចិនដីគោកត្រូវបានបង្កើតឡើងនៅក្នុងចិត្តគំនិតរបស់គាត់ ហើយការខិតខំប្រឹងប្រែងរបស់គាត់បានជំរុញឲ្យគ្រប់ផ្នែកទាំងអស់រីកចម្រើន។ អង្គការបេសកកម្មចិនដីគោកនេះមានប្រភពពីការសន្ទនា និងទំនាក់ទំនងជាមួយព្រះយ៉ាងជ្រាលជ្រៅ និងភាពមិនអាចថ្លែងបានរបស់គាត់ជាមួយព្រះជាម្ចាស់ ហើយវាបន្សល់ទុកជាកេរ្តិ៍ដំណែលរបស់គាត់។

— លោក អេច. ហ្គ្រេតថែន ហ្គីនណេស ឌី.ឌី. (H. Grattan Guinness, D.D.)

ជំពូកទី១

# អាថ៌កំបាំងដ៏បើកចំហ

*ចូរកុំផ្អកកង្វល់តែម្នាក់ឯងអំពីអ្វីឡើយ*
*ក្តីបារម្ភតែមួយគឺធំពេកហើយសម្រាប់ឯង។*
*ចូរទុកឲ្យយើងធ្វើការ ដោយសារកិច្ចការនេះជារបស់យើងតែម្នាក់ប៉ុណ្ណោះ*
*ការងាររបស់ឯងធ្វើគឺត្រូវសម្រាកនៅក្នុងយើង។*

លោកគ្រូ ហ៉ដសិន ថេល័រ មិនមែនជាឥសីនោះទេ។ គាត់ចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងកិច្ចការជាច្រើន ជាមេគ្រួសារ និងមានទំនួលខុសត្រូវសំខាន់ៗជាច្រើនត្រូវរែកពុនផងដែរ។ និស្ស័យដែលអាចធ្វើបានពីកំណើតរបស់គាត់បានដឹកនាំគាត់ទៅកាន់ជីវិតមួយពេញ ដែលអាចបន្តផ្លាស់ប្តូរនៅជុំវិញក្រុមមនុស្សពីគ្រប់មជ្ឈដ្ឋាន។ លោកគ្រូ ហ៉ដសិន ថេល័រ មិនមានកម្លាំងខ្លាំងក្លា ក៏មិនបានកើតមកដោយមានលក្ខណៈជាពិសេស ដើម្បីនឹងរែកពុននូវបន្ទុកទាំងឡាយរបស់លោកីយ៍នោះទេ។ គាត់មានមាឌតូច និងមិនរឹងមាំទេ គាត់តែងតែជួប និងការលំបាកនៅក្នុងការប្រើកាយសម្បទារបស់គាត់។ ក្រៅពីការចិញ្ចឹមដោយឪពុកម្តាយដែលគោរពកោតខ្លាចព្រះ មានអត្ថប្រយោជន៍មួយនៅក្នុងចំណោមអត្ថប្រយោជន៍ជាច្រើន ដែលលោកបានឆ្លងកាត់រហូតដល់ធំដឹងក្តីនៅវ័យត្រឹមតែដប់ប្រាំមួយឆ្នាំ ដើម្បីធ្វើការផ្គត់ផ្គង់ចិញ្ចឹមខ្លួនឯង។ ការនេះបានធ្វើឲ្យគាត់ក្លាយជាបុគ្គលម្នាក់ ដែលឧស្សាហ៍ព្យាយាមក្នុងការងារ និងជាវេជ្ជបណ្ឌិតស្ទាត់ជំនាញម្នាក់។ គាត់អាចមើលថែទាំទារក ចម្អិនអាហារ គ្រប់គ្រងហិរញ្ញវត្ថុ និងកម្សាន្តចិត្តដល់អស់អ្នកដែលមានទុក្ខព្រួយយ៉ាងមានប្រសិទ្ធភាព ដូចដែលគាត់អាចផ្តួចផ្តើមគំនិតដ៏សំខាន់ៗ

និងផ្ដល់ការណែនាំខាងឯព្រលឹងវិញ្ញាណដល់មនុស្សទាំងឡាយនៅលើពិភពលោកនេះ។

លើសពីនេះទៅទៀត គាត់បានពិសោធន៍នឹងសេចក្ដីសន្យារបស់ព្រះជាម្ចាស់ និងបានបង្ហាញថាការរស់នៅប្រកបដោយភាពខ្ជាប់ខ្ជួនខាងព្រលឹងវិញ្ញាណនៅកម្រិតខ្ពស់បំផុត គឺអាចធ្វើទៅបាន។ គាត់បានយកជ័យជំនះលើឧបសគ្គដែលមនុស្សតិចណាស់ធ្លាប់បានឆ្លងកាត់ និងបានបន្សល់ទុកនូវកិច្ចការ ដែលនៅតែរីកចម្រើនទៅមុខ និងនៅតែបន្តមានឥទ្ធិពលរហូតពី១១០ឆ្នាំ ក្រោយពីមរណៈភាពរបស់គាត់។ ជីវិតរបស់គាត់បានរួមចំណែកយ៉ាងធំធេងនៅលើទឹកដីប្រទេសចិនសម្រាប់ដំណឹងល្អ ដោយបាននាំព្រលឹងបាត់បង់រាប់ម៉ឺនថ្វាយដល់ព្រះគ្រីស្ទនៅក្នុងបណ្ដាខេត្តដែលដំណឹងល្អមិនដែលបានទៅដល់កាលពីមុន។ គាត់បានឧបត្ថម្ភបេសកជនចំនួនមួយម៉ឺនពីរពាន់នាក់ ដែលបានពឹងផ្អែកព្រះជាម្ចាស់សម្រាប់តម្រូវការផ្សេងៗរបស់ពួកគេដោយមិនមានការធានាថាបានប្រាក់ខែទៀងទាត់។ បេសកកម្មរបស់គាត់មិនដែលធ្លាប់ស្វែងរកជំនួយខាងហិរញ្ញវត្ថុនោះទេ ប៉ុន្តែក៏មិនធ្លាប់ជំពាក់បំណុលគេដែរ មិនបានរើសនរណាម្នាក់ឲ្យធ្វើការ។ ហើយថ្មីៗនេះក៏បានបញ្ជូនអ្នកធ្វើការថ្មីចំនួនពីររយនាក់ទៅកាន់ប្រទេសចិន គ្រប់ទាំងអស់បានប្រទានមកតាមរយៈការអធិស្ឋាន។ នេះគឺជាការជំរុញដែលអំពាវនាវឲ្យយើងត្រាប់តាមជំនឿ និងការលះបង់របស់លោកគ្រូ ហ័ដសិន ថេល័រ។

យើងប្រហែលជាសួរថា តើមានអ្វីជាអាថ៌កំបាំង ដើម្បីមានជីវិតបែបនេះ។ លោកគ្រូហ័ដសិន ថេល័រ មានអាថ៌កំបាំងជាច្រើន ដោយសារគាត់បានរីកចម្រើនក្នុងព្រះជាម្ចាស់ឥតឈប់ឈរ ប៉ុន្តែអាថ៌កំបាំងទាំងនោះបានរួមគ្នាមកជាអាថ៌កំបាំងមួយដ៏សាមញ្ញ តែមានលក្ខណៈជ្រាលជ្រៅ៖ ដោយយកចេញពីភាពបរិបូរណ៍នៃព្រះគ្រីស្ទចំពោះគ្រប់តម្រូវការទាំងអស់ មិនថាខាងសម្ភារៈក្ដី ឬខាងព្រលឹងវិញ្ញាណក្ដី។ ការស្វែងយល់អំពីរបៀបដែលគាត់បានធ្វើការនេះ និងការទទួលយកអាកប្បកិរិយា និងវិធីសាស្ត្រសាមញ្ញនឹងជាក់ស្ដែងចំពោះអ្វីៗខាងព្រលឹងវិញ្ញាណនឹងដោះស្រាយបញ្ហារបស់យើង ព្រមទាំងជួយសម្រាលបន្ទុករបស់យើងផងដែរ ដែលអនុញ្ញាតឲ្យយើងក្លាយជាអ្វីទាំងអស់ទៅតាមព្រះហឫទ័យរបស់ព្រះអម្ចាស់។ យើងមានបំណងចិត្តចង់បាន និងត្រូវការអាថ៌កំបាំងរបស់លោកគ្រូ ហ័ដសិន ថេល័រ ព្រមទាំងភាពជោគជ័យរបស់គាត់ ហើយយើងអាចទទួលបានវា ដោយសារតែយើងមានព្រះគម្ពីររបស់លោកគ្រូ ហ័ដសិន ថេល័រ និងព្រះ

ជាម្ចាស់របស់គាត់។

«ចូរនឹកចាំពីពួកអ្នកនាំមុខ ដែលបានផ្សាយព្រះបន្ទូលមកអ្នករាល់គ្នា ត្រូវតែត្រាប់តាមសេចក្តីជំនឿរបស់អ្នកទាំងនោះ ទាំងពិចារណាមើលចុងបំផុតនៃកិរិយាគេផង» (ហេព្រើរ ១៣:៧)។

ជំពូកទី២

# ការលួតលាស់ខាងព្រលឹងវិញ្ញាណនៅឆ្នាំដំបូង។

*ចូរសម្លឹងទៅមើលព្រះយេស៊ូវ*
*សម្លឹងទៅព្រះភក្ត្រដ៏អស្ចារ្យរបស់ទ្រង់*
*ហើយរបស់នៅលើផែនដីនឹងកាន់តែក្លាយទៅជាភាពស្រអាប់*
*នៅក្នុងពន្លឺនៃសិរីល្អ និងព្រះគុណរបស់ទ្រង់។*
*— អ្នកស្រី អេច. លែមម៉ែល (H. Lemmel)*

រឿងរ៉ាវទាំងអស់បានចាប់ផ្ដើមពីពេលដែលគាត់បានសំងំរកមើលអ្វីដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងសៀវភៅរបស់ឪពុករបស់គាត់ តាមចរិតលក្ខណៈរបស់ក្មេងប្រុស។ ម្ដាយរបស់គាត់មិនបាននៅផ្ទះទេ ហើយគាត់បានចាប់ផ្ដើមនឹកម្ដាយគាត់ណាស់។ គាត់មានអារម្មណ៍ថា ផ្ទះនៅល្ហល្ហេវ ដូច្នេះគាត់ក៏បានយកសៀវភៅរឿងមួយក្បាលដែលគាត់បាន

រកឃើញទៅអង្គុយអាននៅកន្លៀតជញ្ជាំងឃ្លាំងចាស់ ដែលគាត់ចូលចិត្តទៅអង្គុយរាល់ដង ដោយមានគម្រោងនឹងអានវាឲ្យបានយូរតាមតែចិត្តគាត់ចង់អាន។

អ្នកម្ដាយបានស្ដាយក្ដីបារម្ភយ៉ាងពិសេសសម្រាប់កូនប្រុសតែមួយរបស់គាត់ នៅឆ្ងាយពីផ្ទះរាប់សិបគីឡូម៉ែត្រ។ នៅរសៀលថ្ងៃសៅរ៍នោះ គាត់បានចាកចេញពីមិត្តរបស់នាងដើម្បីអធិស្ឋានតែម្នាក់ឯង ដើម្បីសុំឲ្យព្រះជាម្ចាស់ឲ្យសង្គ្រោះកូនប្រុសរបស់គាត់។ គាត់បានចំណាយពេលជាច្រើនម៉ោងលុតជង្គង់ រហូតដល់នៅទីបំផុតគាត់មានអារម្មណ៍ថាមានសេចក្ដីអំណរ ហើយដែលការអធិស្ឋានរបស់គាត់ត្រូវបានព្រះសណ្ដាប់ និងបានឆ្លើយតបដែរ។

នៅខណៈដែលគាត់កំពុងអានកូនសៀវភៅដែលគាត់បានរើស ក្មេងប្រុសរូបនេះបានជក់ចិត្តនឹងសាច់រឿង ជាពិសេសនៅពេលគាត់បានជាប់ចិត្តនឹងឃ្លាថា៖ «កិច្ចការដែលព្រះគ្រីស្ទបានបញ្ចប់»។ តើអ្នកណាអាចពន្យល់ពីអាថ៌កំបាំងអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធបាន? សេចក្ដីពិតដែលគាត់ធ្លាប់ស្គាល់យូរមកហើយ ទោះជាត្រូវបានមើលរំលងក៏ដោយ ក៏បានលេចឡើងម្ដងទៀតនៅក្នុងគំនិត និងដួងចិត្តរបស់គាត់។

គាត់បានសួរថា៖ «ហេតុអ្វីបានជាអ្នកនិពន្ធប្រើពាក្យទាំងនោះ? ហេតុអ្វីគាត់មិននិយាយថា៖ «ដង្វាយធួននឹងបាប ឬកិច្ចការផ្សះផ្សារបស់ព្រះគ្រីស្ទ?» ភ្លាមៗនោះ ឃ្លាថា៖ «ខ្ញុំបានសម្រេចសព្វគ្រប់អស់ហើយ» បានបញ្ចេញពន្លឺដូចជាបានសរសេរជាអក្សរនៃពន្លឺ។ បានបញ្ចប់? តើអ្វីត្រូវបានបញ្ចប់?

ចិត្តរបស់គាត់បានឆ្លើយថា៖ «ដង្វាយធួនបាបដែលពេញលេញ និងល្អឥតខ្ចោះ។ អ្នកជំនួសដ៏អស្ចារ្យបានសងបំណុលជំនួសយើង។ "ព្រះគ្រីស្ទបានសុគតជំនួសអំពើបាបយើង" ហើយ "មិនគ្រាន់តែសម្រាប់អំពើបាបរបស់យើងនោះទេ ប៉ុន្តែសម្រាប់អំពើបាបរបស់លោកីយ៍ទាំងមូលផងដែរ"»។

នោះគំនិតក៏លេចឡើងយ៉ាងច្បាស់គួរឲ្យភ្ញាក់ផ្អើលថា «ប្រសិនបើកិច្ចការទាំងស្រុងបានសម្រេចសព្វគ្រប់អស់ហើយ ហើយបំណុលទាំងអស់បានសងរួចរាល់ តើនៅសល់អ្វីឲ្យខ្ញុំត្រូវធ្វើទៀត?»។

ចម្លើយតែមួយបានដក់ជាប់ក្នុងព្រលឹងរបស់គាត់គឺថា៖ «ខ្ញុំគ្មានអ្វីត្រូវធ្វើទៀតទេនៅលើលោកីយ៍នេះ ក្រៅពីលុតជង្គង់ ទទួលយកព្រះអង្គសង្គ្រោះនេះ និងសេចក្ដីសង្គ្រោះ

របស់ទ្រង់ ព្រមទាំងសរសើរតម្កើងទ្រង់ជារៀងរហូត»។

ពេលនោះ ការសង្ស័យ និងការភ័យខ្លាចបានរលាយទៅអស់ នៅពេលដែលសេចក្ដីពិតនៃបទពិសោធន៍ដ៏អស្ចារ្យ ដែលយើងហៅថា ការប្រែចិត្តនោះ បានចាក់បំពេញគាត់ដោយសេចក្ដីសុខសាន្ត និងសេចក្ដីអំណរ។ គាត់បានទទួលជីវិតថ្មីតាមរយៈការទទួលជឿយ៉ាងសាមញ្ញលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលព្រះអង្គបានប្រទានដល់អស់អ្នកណាដែលបានទទួលយកទ្រង់ដោយអំណាច ដើម្បីត្រឡប់ជាកូនព្រះ។ ជីវិតថ្មីនេះ បាននាំមកនូវការផ្លាស់ប្ដូរដ៏សម្បើមណាស់។

ដោយអន្ទះសានៅក្នុងការចែកចាយសេចក្ដីអំណរថ្មីជាមួយម្ដាយរបស់គាត់ គាត់បានចេញទៅទទួលម្ដាយគាត់មុន នៅពេលដែលម្ដាយរបស់គាត់ត្រឡប់មកផ្ទះវិញ។ ម្ដាយគាត់និយាយទាំងឱបកូនប្រុសថា៖ «ម៉ែដឹង កូនប្រុសរបស់ម៉ែ ម៉ែដឹងថា ទ្រង់បានប្រទានអំណាចដល់អស់អ្នកណាដែលបានទទួលទ្រង់ឲ្យបាន»។ «អស់រយៈពេលពីរសប្ដាហ៍មកនេះ ម្ដាយមានការអបអរចំពោះដំណឹងល្អដែលកូនត្រូវតែចែកចាយជាមួយម្ដាយ»។

មិនយូរប៉ុន្មាន មានការភ្ញាក់ផ្អើលផ្សេងទៀតបានរង់ចាំគាត់ នៅពេលដែលគាត់រើសបានសៀវភៅកំណត់ត្រាមួយក្បាល ដែលគាត់បានគិតថាជារបស់គាត់។ គាត់បានឃើញសេចក្ដីផ្ដើមមួយនៅក្នុងការសរសេររបស់បងស្រីគាត់ ដោយបានលើកឡើងថា នាងនឹងអធិស្ឋានជារៀងរាល់ថ្ងៃរហូតដល់ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់នាង ដោយការបំផ្លាស់បំប្រែចិត្តប្អូនប្រុសតែម្នាក់របស់នាង។ នារីវ័យក្មេងម្នាក់នេះបានធ្វើការសម្រេចចិត្តបែបនេះកាលពីមួយខែមុន។

លោកគ្រូ ហ៊ុដសិន ថេល័រ បានសរសេរថា ការដែលបានធំដឹងក្ដីនៅក្នុងមជ្ឈដ្ឋានបែបនោះ ហើយបានសង្គ្រោះនៅក្នុងស្ថានភាពទាំងនោះ វាហាក់បីដូចជាធម្មតាសម្រាប់គាត់តាំងពីដើមដំបូងនៃជីវិតជាគ្រីស្ទបរិស័ទរបស់គាត់នៅក្នុងការជឿថា សេចក្ដីសន្យានៅក្នុងព្រះគម្ពីរគឺជារឿងពិតជាក់ណាស់ ហើយការអធិស្ឋានគឺពិតជាការសំខាន់មួយនៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ណាស់ មិនថាសម្រាប់ខ្លួនឯងក្ដី ឬស្វែងរកព្រះពររបស់ទ្រង់សម្រាប់អស់អ្នកណាក្ដី។

ឥឡូវនេះ ប្អូនប្រុស និងបងស្រីបានបង្កើតចំណងថ្មីមួយ បើទោះបីពួកគេនៅវ័យក្មេងៗក៏ដោយ ដោយគាត់មានវ័យត្រឹមតែដប់ប្រាំពីរឆ្នាំ ពួកគេបានចាប់ផ្ដើមធ្វើអ្វីគ្រប់យ៉ាង

ដែលពួកគេអាចធ្វើបាន ដើម្បីនាំអ្នកដទៃទៅកាន់ព្រះគ្រីស្ទ។ ការលះបង់នេះ គឺជាហេតុផលនៅក្នុងការរីកចម្រើនខាងព្រលឹងវិញ្ញាណយ៉ាងឆាប់រហ័សរបស់ពួកគេ។ ចាប់តាំងពីដំបូង ពួកគេបានចែកចាយពីសេចក្តីមេត្តាករុណាដ៏ជ្រាលជ្រៅរបស់ព្រះជាម្ចាស់ដល់អស់អ្នកដែលបានបាត់បង់។ ពួកគេមិនគ្រាន់តែធ្វើការងារសង្គមនោះទេ ពួកគេក៏រស់នៅដើម្បីអ្នកដទៃ ដោយផ្តោតសំខាន់លើការសង្គ្រោះព្រលឹងដែលបាត់បង់ថ្វាយព្រះដែរ។ ការស្វែងរកនេះមិនបានកើតចេញពីអារម្មណ៍នៃភាពខ្ពង់ខ្ពស់ណាមួយនោះទេ ប៉ុន្តែកើតចេញពីសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ និងផ្ទាល់ខ្លួនសម្រាប់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

សេចក្តីស្រឡាញ់កាន់តែចម្រើនឡើងជារៀងរាល់ថ្ងៃ ដោយបណ្តាលឲ្យមានសេចក្តីទុក្ខព្រួយយ៉ាងធំ នៅពេលបរាជ័យនៅរបៀបដូចគ្នា  និងបាត់បង់អារម្មណ៍រីករាយចំពោះព្រះវត្តមានទ្រង់។ ដូចគ្រីស្ទបរិស័ទក្មេងៗជាច្រើនទៀតដែរ លោកគ្រូ ហ័ដសិន ថេល័រ ធ្លាប់មានបទពិសោធន៍នៃជីវិតដែលឡើងខ្ពស់ និងធ្លាក់ចុះ ហើយបានដឹងថា ការធ្វេសប្រហែសចំពោះការអធិស្ឋាន និងមិនបានបំប៉នដោយព្រះបន្ទូលព្រះជាម្ចាស់នឹងនាំទៅរកភាពត្រជាក់ល្ហឹមខាងព្រលឹងវិញ្ញាណ។ ទោះជាយ៉ាងណា អ្វីដែលធ្វើឲ្យបទពិសោធន៍របស់លោកគ្រូ ហ័ដសិន ថេល័រ ដំបូងៗដាច់ពីគ្នា គឺការមិនអាចពេញចិត្តជាមួយនឹងគ្រប់យ៉ាងដែល តិចជាងអ្វីដែលល្អបំផុត—សេចក្តីអំណរពិត និងជាប់លាប់នៃព្រះវត្តមានរបស់ព្រះ។ បើគ្មានសេចក្តីទាំងនេះ គឺដូចជារស់នៅដោយគ្មានពន្លឺព្រះអាទិត្យ ឬធ្វើការដោយគ្មានកម្លាំង។ ការដែលគាត់មានអារម្មណ៍ដឹងពីសេចក្តីអំណររបស់ព្រះអម្ចាស់នៅថ្ងៃនោះ គឺយើងអាចឃើញច្បាស់អំពីការចងចាំទាំងនេះ៖ គាត់បានចំណាយពេលរសៀលដែលទំនេរ ដើម្បីអធិស្ឋាន ដែលមានការជំរុញដោយបំណងចិត្តដ៏ជ្រាលជ្រៅ។ ដូច្នេះ គាត់បានចូលទៅក្នុងបន្ទប់របស់គាត់ ដើម្បីចំណាយពេលផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់។

ខ្ញុំចាំច្បាស់ណាស់នូវអារម្មណ៍ដែលពេញដោយសេចក្តីអំណរ និងការចាក់បង្ហូរព្រលឹងរបស់ខ្ញុំទៅព្រះជាម្ចាស់ ដោយបង្ហាញម្តងហើយម្តងទៀតពីការស្រឡាញ់ដោយដឹងគុណចំពោះទ្រង់ ដែលធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់ខ្ញុំ ហើយបានសង្គ្រោះខ្ញុំ នៅពេលខ្ញុំបាត់ក្តីសង្ឃឹម និងបំណងប្រាថ្នាទាំងអស់សម្រាប់សេចក្តីសង្គ្រោះ។ ខ្ញុំបានសុំឲ្យព្រះអង្គប្រទានកិច្ចការខ្លះដល់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចធ្វើថ្វាយដល់ទ្រង់ ដើម្បីជារបៀបមួយនៅក្នុងការបង្ហាញពីសេចក្តីស្រឡាញ់ និងការដឹងគុណរបស់ខ្ញុំចំពោះទ្រង់។

ខ្ញុំចាំយ៉ាងច្បាស់អំពីរបៀបដែលខ្ញុំបានថ្វាយខ្លួនខ្ញុំ ជីវិតខ្ញុំ មិត្តភក្តិរបស់ខ្ញុំ អ្វីគ្រប់យ៉ាងដែលខ្ញុំមាននៅលើអាសនា។ ខ្ញុំមានអារម្មណ៍ដឹងពីភាពញាប់ញ័រយ៉ាងជ្រាលជ្រៅ ដែលខ្ញុំដឹងថា តង្វាយរបស់ខ្ញុំត្រូវបានទ្រង់ទទួលយកហើយ។ ព្រះវត្តមានរបស់ព្រះបានក្លាយជាការពិត និងព្រះពរដែលមិនគួរឲ្យជឿ ហើយខ្ញុំចាំបានពីការក្រាបចុះនៅចំពោះព្រះភក្ត្រទ្រង់ដោយស្ងប់ស្ងៃង និងអំណរដែលមិនអាចពណ៌នាបាន។ ខ្ញុំមិនដឹងថា ព្រះចង់ឲ្យខ្ញុំបម្រើកិច្ចការអ្វីទេ ប៉ុន្តែខ្ញុំដឹងច្បាស់ថា ខ្ញុំមិនមែនជាកម្មសិទ្ធរបស់ខ្លួន ខ្ញុំបានកាន់ខ្លួនខ្ញុំជាប់ នៅក្នុងការមានឥទ្ធិពលលើខ្លួនឯងនោះទេ ហើយវាក៏មិនដែលរលាយបាត់ឡើយ។

យើងបានយល់ច្រលំ ប្រសិនបើយើងជឿថាក្មេងៗវ័យជំទង់ គឺនៅក្មេងពេកសម្រាប់ការទទួលបានបទពិសោធន៍ជ្រាលជ្រៅខាងព្រលឹងវិញ្ញាណដូចនេះ។ គ្មានអ្វីធំជាងនេះសម្រាប់ការលះបង់នៅពេលវេលាណាមួយផ្សេងទៀតនៅក្នុងជីវិត បើពួកគេបានថ្វាយជីវិតរបស់ខ្លួនគឺមានន័យថា ពួកគេក៏បានបើកចំហចិត្តសម្រាប់សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដែរ។

ជំពូកទី៣

# ជំហានដំបូងនៃសេចក្តីជំនឿ

*ហើយតែងតែគង់នៅក្បែរគាត់គ្រប់កន្លែងដែលគាត់ទៅ*
*ព្រះគ្រីស្ទដែលមើលមិនឃើញនឹងធ្វើការ*
*ដូច្នេះ គាត់អាចពឹងផ្អែកលើព្រះហស្តទ្រង់ ហើយពោលថា*
*«ឱព្រះអម្ចាស់អើយ! តើទ្រង់អនុញ្ញាតឲ្យទូលបង្គំដៃរឬទេ?» ។*
*— លោក អេច. ដឹបបលយូ. ឡុងហ្វិឡូ (H. W. Longfellow)*

ការត្រាស់ហៅនេះមិនបានមកកាន់មនុស្សគ្រប់លក្ខណ៍នោះទេ។ គាត់គ្រាន់តែជាក្មេងប្រុសធម្មតាម្នាក់ ដែលរស់នឹងជីវិតរបស់គាត់ មិនថាជាអ្នកធ្វើការនៅតុទទួលភ្ញៀវនៅធនាគារ ឬជួយធ្វើការនៅក្នុងហាងរបស់ឪពុកគាត់ ដោយប្រឈមមុខនឹងការល្បួងជាច្រើន។ ការរក្សាអាទិភាពជាចម្បង និងការលៃពេលអធិស្ឋានបានក្លាយជារឿងកាន់តែលំបាកឡើងៗ នៅពេលជីដូនមួយដ៏រពឹសរបស់គាត់ត្រូវចូលមកគេងនៅក្នុងបន្ទប់ជាមួយគាត់។ ទោះជាយ៉ាងណាមិញ បើគ្មានការអធិស្ឋាន នោះនឹងកើតមានភាពបរាជ័យ និងអារម្មណ៍មិនស្រួលក្នុងចិត្តដែលមិនអាចជៀសបាន។ ព្រលឹងដែលធ្វេសប្រហែសមិនអាចរកឃើញសេចក្តីអំណរក្នុងព្រះជាម្ចាស់បាននោះទេ។ ហើយលោកគ្រូ ហ៉ដសិន

ថេល័រ ត្រូវតែដឹងថា គ្មានអ្វីអាចមកជំនួសភាពពេញលេញនៃព្រលឹងវិញ្ញាណដែលស្មោះត្រង់បានឡើយ។

«ទូលបង្គំបានឃើញទ្រង់ ទូលបង្គំបានស្វែងរកទ្រង់ ទូលបង្គំបានទ្រង់ហើយ ហើយទូលបង្គំត្រូវការទ្រង់» បានតែងឡើងដោយអ្នកដែលស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់ ហើយដែលក្មេងមកពីទីក្រុង ប៊ើនស្លីយ៍ (Barnsley)។ ទោះបីគ្រាន់តែជាការចាប់ផ្ដើមក៏ដោយ ក៏ក្មេងប្រុសរូបនេះ មានអារម្មណ៍ដឹងអំពីការឃ្លាន និងការស្រេកព្រះបន្ទូលមកពីព្រះជាម្ចាស់ដែរ ដែលព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានគាត់ឲ្យមានសេចក្ដីអំណរក្នុងការស្ដាប់ចិត្ត។ នៅក្នុងឃ្លាថា៖ «ព្រលឹងទូលបង្គំស្រេករកទ្រង់» បានបញ្ជាក់អំពីបំណងព្រះហឫទ័យរបស់ស្ដេច ដាវីឌ (ទំនុកតម្កើង ៦៣:១)។ «ព្រលឹងទូលបង្គំនឹងបានឆ្អែត» (ទំនុកតម្កើង ៦៣:៥) ហើយនៅខបន្ទាប់ដូចគ្នា «ព្រលឹងទូលបង្គំតាមទ្រង់ប្រកិត» (ទំនុកតម្កើង ៦៣:៥)។

នៅក្នុងអំឡុងពេលដ៏លំបាកជាក់លាក់មួយដែលពេញដោយភាពបរាជ័យ ការទន្ទឹងរង់ចាំ និងព្រះពរដ៏ជ្រាលជ្រៅ លោកគ្រូ ហ័ដសិន ថេល័រ បានទទួលបទពិសោធន៍នៃការប៉ះពាល់ចិត្តរបស់ព្រះជាម្ចាស់នៅក្នុងរបៀបថ្មីមួយ។ គាត់បានយល់ភ្លាមៗដោយគ្មាននរណាម្នាក់និយាយប្រាប់គាត់ឡើយ។

គាត់បានឈានដល់ចំណុចមួយដែលគាត់ដឹងថា មានតែព្រះជាម្ចាស់ប៉ុណ្ណោះទើបអាចជួយសង្គ្រោះគាត់បាន ដោយដឹងថា គាត់ត្រូវការជំនួយ និងអំណាចនៃសេចក្ដីសង្គ្រោះរបស់ទ្រង់។ ប្រសិនបើព្រះជាម្ចាស់នឹងធ្វើការជំនួសគាត់ រំដោះគាត់ពីអំណាចនៃអំពើបាប ហើយប្រទានឲ្យគាត់នូវជ័យជម្នះតាមរយៈព្រះគ្រីស្ទ នោះគាត់នឹងបោះបង់ចោលគ្រប់ទាំងមហិច្ឆតារបស់លោកីយ៍ចោល និងចេញទៅទីណា ធ្វើអ្វីគ្រប់យ៉ាង សុខចិត្តរងទុក្ខគ្រប់បែបយ៉ាង តាមបំណងព្រះហឫទ័យរបស់ព្រះ ទាំងអស់សម្រាប់បុព្វហេតុរបស់ទ្រង់ និងចុះចូលទាំងស្រុងចំពោះបំណងព្រះហឫទ័យរបស់ទ្រង់។ នេះគឺជាការអង្វរដោយចេញពីចិត្តចំពោះព្រះជាម្ចាស់ ដើម្បីបន្សុទ្ធគាត់ និងការពារគាត់កុំឲ្យធ្លាក់ចូលទៅក្នុងអំពើបាប។

ខ្ញុំនឹងមិនដែលភ្លេចពីអារម្មណ៍ដែលធ្វើឲ្យខ្ញុំជ្រួលច្របល់ទេ នៅពេលដែលខ្ញុំបានសរសេរអំពីរឿងនោះជាច្រើននៅពេលក្រោយមក។ មិនមានពាក្យអ្វីអាចថ្លែងឲ្យអស់បានឡើយ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងស្ថិតនៅក្នុងព្រះវត្តមានរបស់ព្រះ ដោយធ្វើការតាំង

សេចក្តីសញ្ញាជាមួយទ្រង់ដ៏មានគ្រប់ទាំងព្រះចេស្តា។ ខ្ញុំស្ទើរតែចង់ដកពាក្យសន្យារបស់ខ្ញុំមកវិញ ប៉ុន្តែមានអារម្មណ៍ថា ត្រូវបង្ខំឲ្យរក្សាវា ដូចជាមានអ្វីបានប្រាប់ខ្ញុំថា៖ «សេចក្តីអធិស្ឋានរបស់ឯងត្រូវបានព្រះសណ្តាប់ឮហើយ លក្ខខណ្ឌរបស់ឯងត្រូវបានអនុញ្ញាតឲ្យហើយ»។ តាំងពីពេលនោះមក ខ្ញុំតែងតែជឿជាក់ថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យខ្ញុំទៅប្រទេសចិន។

ប្រទេសចិន ជាប្រទេសដ៏ធំមួយដែលគាត់បានស្គាល់តាំងពីក្មេងតាមរយៈការអធិស្ឋានរបស់ឪពុករបស់គាត់  និងជាប្រទេសដែលគាត់ត្រូវបានចាត់តាំងពីមុនកំណើតរបស់គាត់មកម៉្លេះ ហើយសេចក្តីតម្រូវការ និងភាពងងឹតរបស់ប្រទេសចិនជាញឹកញាប់ត្រូវបានហៅគាត់ពីចម្ងាយ—តើនោះគឺគោលបំណងដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់គាត់មែនឬ? ការត្រាស់ហៅរបស់គាត់ច្បាស់ណាស់ វាហាក់ដូចជាសំឡេងមួយបាននិយាយមកកាន់គាត់ គឺព្រះបន្ទូលបានមកនៅក្នុងសភាពស្ងៀមស្ងាត់ថា៖ «ចូរចេញទៅប្រទេសចិន ដើម្បីយើងចុះ»។

ចាប់ពីពេលនោះមក ជីវិតគាត់មានគោលបំណង និងការអធិស្ឋានតែមួយរួមគ្នា ដោយសារតែលោកគ្រូ ហ៊ុដសិន ថេល័រ បានស្តាប់បង្គាប់តាមនិមិត្តរបស់ស្ថានសួគ៌។ សម្រាប់គាត់ ការស្តាប់បង្គាប់តាមបំណងព្រះហឫទ័យព្រះជាម្ចាស់គឺជាការពិតជាក់ស្តែងណាស់។ ភ្លាមៗនោះ គាត់បានចាប់ផ្តើមរៀបចំជីវិតមួយដែលនឹងទាមទារឲ្យមានការស៊ូទ្រាំខាងរូបកាយផងដែរ។ គាត់ធ្វើលំហាត់ប្រាណនៅខាងក្រៅកាន់តែច្រើនឡើង បានផ្លាស់ប្តូរគ្រែរោមសត្វដ៏ទន់របស់គាត់ទៅជាពូកដ៏រឹង ហើយគាត់ប្រុងប្រយ័ត្នថា មិនបណ្តោយខ្លួនឲ្យបរិភោគច្រើនពេកតាមតែចិត្ត នៅពេលដែលគាត់ទទួលទាននោះទេ។ ជំនួសឲ្យការទៅថ្វាយបង្គំនៅព្រះវិហារពីរដងនៅថ្ងៃអាទិត្យ គាត់បានចំណាយពេលល្ងាចទៅសួរសុខទុក្ខនៅតំបន់ដែលក្រីក្របំផុតនៃទីក្រុង ចុះចែកខិត្តប័ណ្ណ និងប្រជុំនៅតាមផ្ទះខ្ទមតូចៗ។ គាត់ក្លាយជាម្នាក់ដែលគេស្គាល់ និងស្វាគមន៍នៅក្នុងផ្ទះបាយ ផ្ទះស្នាក់ដែលមានមនុស្សច្រើនកុះករ ហើយថែមទាំងអាចចែកចាយព្រះរាជសារដ៏មានន័យនៅទីលានប្រណាំងសេះដោយពាក្យដែលប្រកបដោយអាកប្បកិរិយារាក់ទាក់ និងសប្បុរស។ គ្រប់សកម្មភាពទាំងនេះបាននាំឲ្យគាត់ឲ្យសិក្សាព្រះគម្ពីរ និងអធិស្ឋានបន្ថែមទៀត ពីព្រោះគាត់បានដឹងយ៉ាងឆាប់រហ័សថា មានតែមួយអង្គតែប៉ុណ្ណោះដែលពិតជាអាចបង្រៀន

យើងឲ្យក្លាយទៅជា "អ្នកនេសាទមនុស្ស" បាន។

គាត់បានចាប់ផ្ដើមរៀនភាសាចិនដោយសេចក្ដីក្លៀវក្លា។ សៀវភៅវេយ្យាករណ៍មួយក្បាលមានតម្លៃមិនក្រោមជាងម្ភៃដុល្លារ (ដែលប្រហែលស្មើនឹង ៧៥០ ដុល្លារ បច្ចុប្បន្ន) ហើយវចនានុក្រមមួយក្បាលក៏មិនក្រោមចិតសិបប្រាំដុល្លារ (ដែលប្រហែល ៣.៣៥០ ដុល្លារ បច្ចុប្បន្ន) ដែរ។ គាត់មិនអាចមានសមត្ថភាពទិញរបស់ទាំងពីរមុខនេះទេ។ ទោះជាយ៉ាងណា តាមរយៈការប្រើប្រាស់កណ្ឌគម្ពីរដំណឹងល្អលូកាជាភាសាចិន គាត់អាចឲ្យដឹងពីអត្ថន័យអក្សរជាងប្រាំមួយរយតួដោយធ្វើការប្រៀបធៀបខគម្ពីរខ្លីៗនឹងការបកប្រែជាភាសាអង់គ្លេសដោយប្រុងប្រយ័ត្ន។ គាត់បានចងចាំតួអក្សរទាំងនោះ និងបានបង្កើតវចនានុក្រមផ្ទាល់ខ្លួនរបស់គាត់ស្របពេលដែលគាត់បន្តការសិក្សាផ្សេងទៀត។

ឥឡូវ ខ្ញុំក្រោកពីដំណេកនៅម៉ោងប្រាំព្រឹក ហើយត្រូវចូលគេងពីព្រលប់។ ខ្ញុំត្រូវតែរៀនសូត្រ ប្រសិនបើខ្ញុំមានគម្រោងទៅប្រទេសចិន។ ខ្ញុំបានធ្វើការសម្រេចចិត្តថានឹងទៅ ហើយកំពុងរៀបចំគ្រប់វិធីដែលខ្ញុំអាចធ្វើបាន។ ខ្ញុំមានគម្រោងពង្រឹងភាសាឡាតាំងរបស់ខ្ញុំឲ្យពូកែឡើង រៀនភាសាក្រិក និងមូលដ្ឋាននៃភាសាហេព្រើរ ព្រមទាំងប្រមូលព័ត៌មានច្រើនបំផុតតាមដែលខ្ញុំអាចធ្វើបាន។ ខ្ញុំត្រូវការការអធិស្ឋានរបស់លោកអ្នក។

គាត់បានចំណាយពេលបីបួនឆ្នាំធ្វើការជាមួយឪពុករបស់គាត់ជាអ្នកចែកចាយថ្នាំពេទ្យ បានធ្វើឲ្យគាត់មានបំណងសិក្សាផ្នែកវេជ្ជសាស្ត្រ ហើយនៅពេលគាត់មានឱកាសធ្វើជាជំនួយការវេជ្ជបណ្ឌិតកំពូលម្នាក់នៅទីក្រុង ហ្វូល (Hull City) គាត់បានចាប់យកឱកាសនោះយ៉ាងឆាប់រហ័ស។ ការនេះតម្រូវឲ្យគាត់ត្រូវចាកចេញពីគ្រួសាររបស់គាត់ ប៉ុន្តែគាត់នៅតែរស់នៅក្នុងភាពសុខស្រួល និងស្រស់ស្រាយ ដំបូងគាត់រស់នៅផ្ទះរបស់វេជ្ជបណ្ឌិត បន្ទាប់មកផ្ទះរបស់ម្ដាយមីងរបស់គាត់ដែលត្រូវជាបងស្រីរបស់ម្ដាយគាត់។

នេះពិតជាបានក្លាយជាទិដ្ឋភាពមួយនៃជីវិតថ្មីរបស់គាត់ ដែលដឹកនាំឲ្យគាត់គិតដោយហ្មត់ចត់។ លោកវេជ្ជបណ្ឌិត ហាតឌីយ៍ (Dr. Hardey) បានផ្ដល់ប្រាក់ខែឲ្យគាត់ ដែលល្មមគ្រប់គ្រាន់សម្រាប់ចាយវាយលើការចំណាយផ្ទាល់ខ្លួន។ ប៉ុន្តែ លោកគ្រូ ហ័ដសិន ថេល័រ បានថ្វាយជាកាតព្វកិច្ច និងឯកសិទ្ធិ មួយភាគដប់នៃអ្វីៗទាំងអស់ដែលបានមកគាត់សម្រាប់កិច្ចការរបស់ព្រះជាម្ចាស់។ គាត់បានចំណាយពេលរាល់ថ្ងៃអាទិត្យ ដើម្បីផ្សាយដំណឹងល្អនៅផ្នែកមួយនៃទីក្រុងដែលត្រូវការជំនួយយ៉ាងខ្លាំងទាំងខាងសម្ភារៈ

និងព្រលឹងវិញ្ញាណ។ ការនេះធ្វើឲ្យគាត់ឆ្ងល់ថា ហេតុអ្វីគាត់មិនចំណាយពេលឲ្យតិចជាងនេះសម្រាប់ខ្លួនគាត់ ហើយរីករាយនឹងការឲ្យអ្នកដទៃច្រើនជាងនេះ។

លើសពីដីទំនេរនៃជាយក្រុង ផ្ទះខ្ទមពីរជួរបានសង់នៅតាមប្រឡាយទឹកដ៏ចង្អៀតមួយ ហៅថា “ឌ្រេនសាយដ៍” (Drainside) ដែលល្បីថាមិនមែនជាសង្កាត់ដែលគួរឲ្យចង់រស់នៅនោះទេ។ ប្រឡាយទឹកនេះ ជាប្រឡាយទឹកដ៏ជ្រៅមួយ ដែលអ្នកស្រុកបោះចោលសំរាមចូល នៅពេលណាដែលទឹកជោរឡើងសំរាមត្រូវបានហូរទៅជាមួយ—សម្រាប់ទីក្រុង ហួល វាជាទីក្រុងកំពង់ផែសមុទ្រ។ ផ្ទះខ្ទមទាំងនេះមានសណ្ឋានភាពដូចជាគ្រាប់សណ្ដែកនៅក្នុងស្រោមផ្លែ លាតសន្ធឹងនៅតាមបណ្ដោយប្រឡាយទឹកប្រហែលប្រាំបីរយម៉ែត្រ ដែលនៅតាមផ្ទះខ្ទមនីមួយៗមានទ្វារមួយ និងបង្អួចពីរ។ លោកគ្រូ ហ៉ដសិន ថេល័រ បានផ្លាស់ទៅរស់នៅបន្ទប់ជួលមួយក្នុងចំណោមផ្ទះតូចៗទាំងនេះ ដោយបានចាកចេញពីភាពសុខស្រួលនៅផ្ទះរបស់ម្ដាយមីងរបស់គាត់នៅផ្លូវ ឆាលឡូត (Charlotte Street)។ ម្ចាស់ផ្ទះស្រីរបស់គាត់ លោកស្រី ហ្វីនច្ឆ (Mrs. Finch) គឺជាគ្រីស្ទបរិស័ទស្មោះត្រង់ម្នាក់មានភាពរីករាយដែលបានការធ្វើជាម្ចាស់ផ្ទះ “លោកវេជ្ជបណ្ឌិតវ័យក្មេង” ម្នាក់នេះ។ គាត់បានប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការធ្វើឲ្យបន្ទប់ស្អាត និងកក់ក្ដៅ ដោយបោសសម្អាតឡកម្ដៅនៅទល់មុខបង្អួច ហើយធ្វើការរៀបចំគ្រែឲ្យនៅជ្រុងឆ្ងាយបំផុតពីច្រកចូល។ មានគ្រឿងសង្ហារិមធម្មតាៗ៖ តុទទេមួយ និងកៅអីមួយគូរ។ បន្ទប់នោះ មានទំហំត្រឹមតែ បីកៀសប្រាំ (៣.៥គុណ៣.៥) ម៉ែត្របួនជ្រុង ដូច្នេះមិនត្រូវការអ្វីច្រើនទេ។ វានៅជាន់ផ្ទាល់ដីដែលមានទ្វារមួយបើកឃើញដល់ផ្ទះបាយ។ តាមបង្អួច គេអាចមើលឃើញ ភោជនីយដ្ឋាន ម្ចាស់ដៃ (The Founder's Arms) ដែលជាហាងស្រាដ៏ស្រើបស្រាល ដែលមានភ្លើងជួយបំភ្លឺនៅពេលរាត្រីដ៏ខ្មៅងងឹត នៅពេលដែលពន្លឺរបស់វាបានចាំងនៅលើភក់ និងទឹកនៃប្រឡាយ។

នៅចុងខែវិច្ឆិកា នៅពេលដែលលោកគ្រូ ហ៉ដសិន ថេល័រ បានចូលមកនៅឌ្រេនសាយដ៍ ប្រហែលជាមើលទៅដូចជាក្រៀមក្រំបន្តិច។ គាត់បានរស់នៅតែម្នាក់ឯង ដែលមានន័យថាគាត់នឹងទិញម្ហូបអាហារតិចតួចសម្រាប់គាត់ បន្ទាប់ពី ត្រឡប់ពីគ្លីនិកវិញ ហើយគាត់កម្របានអង្គុយហូបបាយបានត្រង់មាត់ណាស់។ គាត់បានដើរទៅណាមកណាតែម្នាក់ឯង បានចំណាយពេលល្ងាចៗតែម្នាក់ឯង ហើយជារៀងរាល់ថ្ងៃអាទិត្យគាត់បានចូល

រួមធ្វើកិច្ចការជាច្រើនម៉ោងនៅក្នុងតំបន់របស់គាត់ ឬជាមួយមនុស្សដែលបានមកលេងកំពង់ផែ ហាមបើរ ឌកឃ៍ (Humber Dock)។

ខ្ញុំមានគោលបំណង ដើម្បីឲ្យទម្លាប់នឹងការលំបាក និងដើម្បីសន្សំលុយ សម្រាប់ជួយដល់ពួកអ្នកដែលខ្ញុំបានផ្សាយដំណឹងល្អជាមួយ។ ខ្ញុំបានដឹងយ៉ាងឆាប់រហ័សថា ខ្ញុំអាចរស់នៅដោយចំណាយតិចជាងខ្ញុំបានគិតទៅទៀត។ ខ្ញុំបានឈប់ប្រើ ប៊ឺរ ទឹកដោះគោ និងរបស់ទាន់សម័យជាច្រើន ហើយរកឃើញថា របបអាហារភាគច្រើនជាស្រូវសាលី និងអង្ករជាមួយម្ហូបមួយចំនួនទៀតត្រូវការលុយតិចណាស់។ ការនេះបានអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់ពីរភាគបីនៃប្រាក់ខែរបស់ខ្ញុំសម្រាប់គោលបំណងផ្សេងៗទៀត។ ខ្ញុំបានឃើញថា កាលណាខ្ញុំបានចំណាយកាន់តែតិចលើខ្លួនឯង កាលនោះខ្ញុំអាចឲ្យទៅអ្នកដទៃកាន់តែច្រើន ហើយខ្ញុំនឹងកាន់តែមានអារម្មណ៍រីករាយ និងមានព្រះពរច្រើនឡើងៗ។

ព្រះជាម្ចាស់មិនបានជំពាក់នរណាម្នាក់សោះ ហើយនៅក្នុងភាពឯការបស់គាត់ នោះលោកគ្រូ ហ័ដសិន ថេល័រ បានរកឃើញអំពីអ្វីដែលទ្រង់អាចបំពេញសម្រាប់នរណាម្នាក់ដែលពិតជាឆេះឆួលនៅក្នុងការស្វែងរកព្រះអង្គមែន។ ចំពោះគ្រីស្ទបរិស័ទដែលធ្វើខ្លួនរំភើយៗបច្ចុប្បន្ន តើវាមិនសំខាន់ទេឬអីនៅក្នុងការចងចាំថា វាពិតជាត្រូវចេញថ្លៃអ្វីមួយ ដើម្បីក្លាយជាម្នាក់ដែលព្រះជាម្ចាស់អាចប្រើប្រាស់បាន? លោកអ្នកមិនអាចអភិវឌ្ឍបុគ្គលិកលក្ខណៈឲ្យដូចជាព្រះគ្រីស្ទដោយឥតគិតថ្លៃបានឡើយ លោកអ្នកមិនធ្វើកិច្ចការដូចជាព្រះគ្រីស្ទដោយមិនបង់ថ្លៃដ៏ថ្លៃបានទេ។ “តើលោកអ្នកផឹកពីពែងដែលខ្ញុំបានផឹក ឬបានទទួលបុណ្យជ្រមុជទឹកដែលខ្ញុំបានជ្រមុជដែរឬទេ?”។

ប្រទេសចិនកំពុងទទួលបានចំណាប់អារម្មណ៍ពីសាធារណៈជនជាច្រើននៅពេលនេះ ដោយសារមានព្រឹត្តិការណ៍សំខាន់ៗរបស់ការប្រឆាំងបះបោររបស់ពួកថៃភីង (Taiping Rebellion)។ មនុស្សច្រើនកំពុងអធិស្ឋាន ហើយចិត្តមនុស្សរាប់សិបនាក់ទៀតកំពុងតែព្រួយបារម្ភចំពោះការផ្សាយដំណឹងល្អ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅពេលដែលការខកចិត្ត និងការបរាជ័យរបស់ការផ្តួចផ្តើមគំនិតនៃការសន្យាបានកើតឡើង នោះមនុស្សភាគច្រើនបានឈប់ជួយ និងយកចិត្តទុកដាក់ជាមិនខាន។ ការប្រជុំគ្នាអធិស្ឋានថយចុះ អ្នកបំរុងធ្វើជាបេសកជនបានជ្រើសរើសអាជីពផ្សេងទៀត ហើយការបរិច្ចាគក៏បានថយចុះយ៉ាងខ្លាំងដោយអង្គការមួយចំនួនត្រូវបានរំសាយចោល។ ប៉ុន្តែ មានបុគ្គលមួយ

ចំនួនតូចប៉ុណ្ណោះដែលព្រះអម្ចាស់អាចពឹងពាក់បាន—ប្រហែលជាពួកអ្នកក្រ និងពួកអ្នកទន់ខ្សោយ ពួកអ្នកដែលគេមិនស្គាល់ ហើយមិនសំខាន់សោះ ប៉ុន្តែដោយសារព្រះគុណ នោះគេមានឆន្ទៈចេញទៅគ្រប់ទីកន្លែង ដើម្បីបំពេញបំណងព្រះហឫទ័យទ្រង់។

នៅផ្ទះដ៏ស្ងាត់របស់គាត់នៅខ្រេនសាយដ៍មានមនុស្សម្នាក់បែបនេះបានរស់នៅ។ ដោយមិនគិតអំពីដែនកំណត់របស់គាត់ លោកគ្រូ ហ៍ដសិន ថេល័រ ពិតជាចង់មានបុគ្គលិកលក្ខណៈ និងជីវិតដូចជាព្រះគ្រីស្ទយ៉ាងខ្លាំងមែន។ នៅពេលដែលឧបសគ្គនីមួយៗដែលអាចជៀសវាងបាន ចូលមកចំពោះមុខគាត់ គាត់បានជ្រើសរើសការលះបង់ខ្លួនឯង និងផ្ទុកឈើឆ្កាងដោយចេតនា តែមិនមែនដោយសារគាត់បានគិតថា គាត់នឹងទទួលបានគុណសម្បត្តិសម្រាប់ការនោះទេ ប៉ុន្តែដោយសាមញ្ញគឺថា គាត់ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ ផ្នត់គំនិតនេះបានអនុញ្ញាតឲ្យគាត់មានការបើកចំហចិត្តសម្រាប់ព្រះពរទាំងឡាយ។

«មើល អញបានបើកទ្វារចំហនៅមុខឯង គ្មានអ្នកណាអាចនឹងបិទបានទេ ពីព្រោះទោះបើឯងមានអំណាចតែបន្តិចក៏ដោយ គង់តែបានកាន់តាមពាក្យអញដែរ ហើយមិនបានលះបង់ឈ្មោះអញទេ» (វិវរណៈ ៣:៨)។

ទ្វារធំ និងមានប្រសិទ្ធភាពត្រូវបានបើកចំហ ប៉ុន្តែមានពួកសត្រូវជាច្រើន។ នៅពេលនេះពួកសត្រូវប្រាកដជាបានក្រោកឈរប្រឆាំងនឹងដំណើររីកចម្រើនរបស់លោកគ្រូ ហ៍ដសិនថេល័រ។ គាត់បានចាប់ផ្ដើមដំណាក់កាលដែលបង្កើតផលផ្លែខ្លាំងបំផុតនៅក្នុងជីវិតរបស់គាត់ ដែលពេញដោយព្រះពរសម្រាប់ខ្លួនគាត់ផ្ទាល់ និងអ្នកដទៃទៀត។ តើវាមិនច្បាស់ទេឬអី ដែលការល្បួងនឹងខិតចូលមកដល់? ដោយឯកា និងចង់បានក្តីស្រឡាញ់ខ្លាំងនិងការអាណិតអាសូរផង គាត់ក៏បានរស់ដោយរកជីវិតដែលបដិសេធខ្លួនឯង ដែលការនោះមិនងាយស្រួលដល់បុរសវ័យក្មេងនៅក្នុងការទ្រាំទ្រទេ។ វាគឺជាឱកាសដ៏ល្អឥតខ្ចោះសម្រាប់អារក្សសាតាំង ដែលម្ដងម្កាលវាត្រូវបានអនុញ្ញាតឲ្យបង្កបញ្ហា ដូច្នេះសូម្បីតែការនេះក៏អាចនាំទៅរកអ្វីដែលវិជ្ជមានដែរ។

នៅពេលដែលគាត់គ្រាន់តែរស់នៅខ្រេនសាយដ៍បានតែពីរបីសប្ដាហ៍ ការវាយប្រហារដ៏គួរឲ្យខ្លាចបានកើតឡើង ហើយគាត់ហាក់បីដូចជាបានបាត់បង់នារី ដែលគាត់បានស្រឡាញ់ខ្លាំងជារៀងរហូត។ រយៈពេលពីរឆ្នាំពេញ គាត់មានសេចក្ដីសង្ឃឹម និងបាន

ទន្ទឹងរង់ចាំ។ តែភាពមិនប្រាកដប្រជានៃអនាគតនោះបានជំរុញឲ្យការចង់បានវត្ថុមានរបស់នាង និងភាពជាដៃគូរបស់នាង ដើម្បីឆ្លងគ្រប់កាលៈទេសៈទាំងអស់កើតឡើងកាន់តែខ្លាំងឡើងៗ។ ប៉ុន្តែ ឥឡូវនេះ ក្តីសុបិនត្រូវបានរលាយបាត់អស់ហើយ។ ដោយឃើញថា នាងមិនអាចបញ្ឈប់ការបញ្ចុះបញ្ចូលរបស់មិត្តរបស់នាងពីគោលបំណងនៃបេសកកម្មរបស់គាត់ អ្នកគ្រូតន្ត្រីវ័យក្មេង—ដែលមានមុខស្រទន់ និងសម្លេងពីរោះរូបនេះ—ចុងក្រោយបានបញ្ជាក់ឲ្យឃើញច្បាស់ណាស់ថា នាងមិនបានត្រៀមខ្លួនដើម្បីចេញទៅប្រទេសចិនទេ។ ឪពុករបស់នាងបានប្រឆាំងដាច់ខាតចំពោះរឿងនេះ ហើយនាងក៏មិនមានអារម្មណ៍ថា នាងស័ក្តិសមនឹងជីវិតបែបនេះនោះទេ។ នេះមានន័យតែមួយគត់ បើទោះបីបេះដូងរបស់គាត់ស្ទើរតែខ្ទេចខ្ទាំក៏ដោយ។

មេល្បួងបានទទូចថា៖ «តើវាសមតម្លៃដែរឬទេ? ហេតុអ្វីឯងត្រូវតែទៅប្រទេសចិន? ហេតុអ្វីត្រូវធ្វើការ និងរងទុក្ខពេញមួយជីវិតរបស់ឯងសម្រាប់កាតព្វកិច្ចដ៏ល្អឥតខ្ចោះធ្វើអី? បោះបង់វាចោលទៅ ទាន់ឯងនៅមានឱកាសឈ្នះចិត្តនាង។ គ្រាន់តែរស់នៅធម្មតាៗដូចអ្នកដទៃ ហើយបម្រើព្រះនៅផ្ទះទៅបានហើយ។ ទាន់ឯងនៅអាចឈ្នះចិត្តនាងបាន»។

ក្តីស្រឡាញ់បានអង្វរយ៉ាងខ្លាំងនៅខណៈពេលនៃការសង្ស័យនេះ។ ខ្មាំងសត្រូវធ្វើឲ្យបុរសវ័យក្មេងម្នាក់នេះបានជ្រួលច្របល់ ពីព្រោះគាត់ត្រូវបានស្លឹកដោយទុក្ខសោកហើយ។ ជាជាងការស្វែងរកការកំសាន្តចិត្តពីព្រះជាម្ចាស់ គាត់បានទុកការឈឺចាប់នៅខាងក្នុង ហើយរស់នៅក្នុងភាពក្រៀមក្រំរបស់គាត់។ ប៉ុន្តែ គាត់មិនត្រូវបានបោះបង់ចោលឡើយ។

នៅថ្ងៃបន្ទាប់ នៅក្នុងបន្ទប់វះកាត់តែម្នាក់ឯង ខ្ញុំទទួលបទពិសោធនៃអារម្មណ៍ដ៏រំជួលចិត្តដ៏ជ្រាលជ្រៅមួយ។ ខ្ញុំមានអារម្មណ៍ដ៏ស្រទន់ និងបន្ទាបខ្លួន ហើយបានទទួលការបើកសម្តែងដ៏អស្ចារ្យមួយអំពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ឱព្រះអម្ចាស់អើយ ទ្រង់មិនបានមើលងាយចំពោះ «ចិត្តខ្ទេចខ្ទាំ ហើយទន់ទាបឡើយ» (ទំនុកតម្កើង ៥១:១៧) ប៉ុន្តែទ្រង់បានឆ្លើយតបសេចក្តីអង្វររបស់ទូលបង្គំសម្រាប់ព្រះពរដោយស្មោះត្រង់ និងទៀងត្រង់វិញ។

មែនហើយ ព្រះអង្គបានបន្ទាបទូលបង្គំចុះ ហើយបង្ហាញទូលបង្គំថាទូលបង្គំជាអ្នកណា ដោយបើកសម្តែងអង្គទ្រង់ថាជាអ្នកជំនួយដែលពឹងពាក់បាននៅក្នុងគ្រាអាសន្ន។ បើទោះបីជា ទ្រង់អនុញ្ញាតទូលបង្គំឲ្យដឹងអំពីការសាកល្បងរបស់ទូលបង្គំក៏ដោយ ក៏ទ្រង់

បានចម្រើនកម្លាំងទូលបង្គំឲ្យច្រៀងថា៖ «គង់តែខ្ញុំនឹងរីករាយ ដោយសារព្រះយេហូវ៉ា ខ្ញុំនឹងអរសប្បាយក្នុងព្រះដ៏ជួយសង្គ្រោះខ្ញុំដែរ» (ហាបាគុក ៣:១៨)។

ពេលនេះ ខ្ញុំរីករាយនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះសង្គ្រោះរបស់ខ្ញុំណាស់ ហើយអាចអរព្រះគុណទ្រង់សម្រាប់គ្រប់យ៉ាង ទោះបីជានៅអតីតកាលដែលឈឺចាប់បំផុត ហើយទុកចិត្តទ្រង់ដោយគ្មានការភ័យខ្លាចចំពោះអនាគតសោះ។

ជំពូកទី៤

# ជំហានបន្ថែមទៀត នៅក្នុងសេចក្តីជំនឿ

*អស់អ្នកណាដែលទុកចិត្តដល់សេចក្តីស្រឡាញ់ដែលមិនប្រែប្រួលរបស់ព្រះជាម្ចាស់ អ្នកនោះនឹងត្រូវសង់នៅលើថ្មដារដែលមិនត្រូវរង្គោះរង្គើឡើយ។*

*— លោក នូម៉ាក់ (Mr. Neumark)*

លោកគ្រូ ហ័ដសិន ថេល័រ បានពោលថា៖ «ខ្ញុំមិនដែលធ្វើការលះបង់សោះ» នៅឆ្នាំក្រោយៗរបស់គាត់ ដោយឆ្លុះបញ្ចាំងទៅលើជីវិតមួយរបស់គាត់ ដែលប្រាកដជាមានចំណែកចំពោះការលះបង់នោះមែន។ អ្វីដែលគាត់បាននិយាយ គឺជាការពិត ដោយសារតែរង្វាន់ដែលគាត់ទទួលពីព្រះ គឺពិតប្រាកដ និងយូរអង្វែង ដែលធ្វើឲ្យគាត់បានដឹងថាការលះបង់តែងតែនាំទៅរកប្រយោជន៍ នៅពេលដែលគាត់បានចូលរួមដោយស្មោះត្រង់ចំពោះព្រះជាម្ចាស់។ នេះគឺជាភស្តុតាងនៅអំឡុងរដូវរងានៅខ្រែនសាយដ៏។ មិនគ្រាន់តែផ្នែកខាងក្រៅប៉ុណ្ណោះទេ ប៉ុន្តែនៅផ្នែកខាងក្នុងផងដែរ ដោយគាត់បានធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយបានលះបង់អ្វីដែលហាក់ដូចជាល្អបំផុត និងភាពខ្ពង់ខ្ពស់បំផុតរបស់គាត់—អ្នកដែលជាទីស្រឡាញ់ដែលបានច្របាច់បញ្ចូលទៅក្នុងជីវិតរបស់គាត់—ដើម្បីដើរតាមព្រះគ្រីស្ទដោយគ្មានការបង្អាក់។ ការលះបង់គឺធំដុំ ប៉ុន្តែរង្វាន់

គឺធំជាងនេះឆ្ងាយណាស់។

គាត់ប្រាប់យើងពីអារម្មណ៍ដែលគាត់មានថា ជារៀងរាល់ថ្ងៃគាត់មានសេចក្ដីអំណរដែលមិនអាចថ្លែងបានពេញមួយថ្ងៃ ការភ្លក់បទពិសោធន៍នៃភាពរីករាយមានភាពងាយស្រួលដោយសារព្រះជាម្ចាស់ ព្រះអម្ចាស់នៃខ្ញុំ ដែលគង់នៅយ៉ាងត្រចះត្រចង់ មានព្រះជន្មរស់នៅក្នុងសេចក្ដីពិត ហើយអ្វីគ្រប់យ៉ាងដែលខ្ញុំធ្វើគឺជាការបម្រើដោយសេចក្ដីអំណរ។

សំបុត្រនានាផ្សេងទៀតរបស់គាត់បានប្រើការបង្ហាញពីទឹកចិត្តថ្មី ដោយផ្ដោតលើខ្លួនឯងតិចជាងមុន ហើយផ្ដោតសំខាន់លើគោលបំណងបេសកកម្មរបស់គាត់ចាប់ពីចំណុចនេះតទៅ។ ប្រទេសចិនបានក្លាយជាទីផ្ដោតសំខាន់មួយនៅក្នុងគំនិតទាំងអស់របស់គាត់ ហើយគាត់មានការបារម្ភកាន់តែខ្លាំងសម្រាប់ដំណាក់កាលខាងព្រលឹងវិញ្ញាណសម្រាប់អស់អ្នកដែលគ្មានព្រះគ្រីស្ទ។

ជូនចំពោះអ្នកម្ដាយជាទីស្រឡាញ់ សូមកុំឲ្យអ្វីមកបង្អាក់អ្នកម្ដាយឡើយ។ គាត់បានសរសេរថា កិច្ចការខាងបេសកកម្ម គឺពិតជាកិច្ចការដ៏ខ្ពង់ខ្ពស់បំផុតដែលមនុស្សណាម្នាក់អាចទទួលខុសត្រូវ។ យើងមិនព្រងើយកន្តើយចំពោះការបង្កើតទំនាក់ទំនងធម្មជាតិ ប៉ុន្តែតើយើងមិនគួរនឹងរីករាយទេឬអី នៅពេលយើងមានអ្វីមួយនៅក្នុងការលះបង់សម្រាប់ព្រះសង្គ្រោះនៃយើង?

សូមបន្តអធិស្ឋានសម្រាប់កូន។ បើទោះបី កូនមានភាពសុខស្រួលនឹងរឿងសម្ភារៈ ហើយមានអារម្មណ៍រីករាយ នឹងដឹងគុណ ក៏កូននៅតែត្រូវការអធិស្ឋានរបស់ម៉ាក់ដែរ។ ឱ! អ្នកម្ដាយអើយ! កូនមិនអាចបង្ហាញពីបំណងប្រាថ្នាដ៏ជ្រាលជ្រៅបាន ដែលកូនត្រូវតែធ្វើជាបេសកជនម្នាក់ ហើយនាំដំណឹងល្អទៅមនុស្សក្រខ្សត់ មនុស្សកំពុងស្លាប់នៅក្នុងអំពើបាប ដើម្បីលះបង់ខ្លួនកូនចំពោះព្រះអង្គដែលបានសុគតជំនួសកូន។ សូមសញ្ជឹងគិតបន្តិច អ្នកម្ដាយអើយ! មនុស្សចំនួនដប់ពីរលាននាក់—ចំនួននោះច្រើនលើសលប់ពិបាកនៅក្នុងការស្រមៃ—ជារៀងរាល់ឆ្នាំនៅក្នុងប្រទេសចិន ដោយបានស្លាប់ដោយមិនបានស្គាល់ព្រះ ឬក៏ក្ដីសង្ឃឹមសោះ។ សូមមើលទៅកាន់បណ្ដាជននេះដោយក្ដីអាណិតអាសូរ។ ព្រះជាម្ចាស់បានបង្ហាញនូវក្ដីមេត្តាដល់យើង សូមឲ្យយើងបានបង្ហាញក្ដីមេត្តាករុណានោះដល់ពួកគេដូចគ្នាដែរ។

ពេលនេះមកដល់ចុងបញ្ចប់នៃសំបុត្រនេះហើយ។ តើអ្នកម្ដាយមិនគួរតែនឹងលះបង់អ្វី

គ្រប់យ៉ាងដើម្បីព្រះគ្រីស្ទ ដែលបានសុគតជំនួសអ្នកម្តាយដែរទេឬអី? បាទ! អ្នកម្តាយកូនដឹងថាអ្នកម្តាយនឹងលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីព្រះគ្រីស្ទ។ សូមឲ្យព្រះគង់នៅជាមួយអ្នកម្តាយ និងកម្សាន្តចិត្តអ្នកម្តាយចុះ។ តើកូនគួរតែចាកចេញឲ្យឆាប់បំផុតមែនទេ នៅពេលដែលកូនសន្សំលុយគ្រប់ដើម្បីចេញទៅប្រទេសចិន? កូនមានអារម្មណ៍ថាកូនមិនអាចរស់នៅបានទេ ប្រសិនបើយើងមិនបានធ្វើរឿងអ្វីមួយសម្រាប់ប្រទេសចិន។

គាត់ពិតជាចង់ចាកចេញទៅភ្លាមៗណាស់ ប៉ុន្តែមានហេតុផលជាច្រើនដែលរារាំងគាត់ពីការធ្វើបែបនោះ។ គាត់បានជួបការលំបាក និងមានជ័យជម្នះជាច្រើនដែលមានតែព្រះជាម្ចាស់ទេដែលបានដឹងថាវាបានកើតឡើងនៅបន្ទប់តូចមួយនៅខ្រេនសាយដ៍។

នៅរដូវរងានោះ គាត់បានសរសេរថា ខ្ញុំបានគិតពិចារណាយ៉ាងខ្លាំង ហើយសម្រេចចិត្តថា ការចេញទៅប្រទេសចិននៅរដូវរងានោះហាក់បីដូចជាធ្ងន់ធ្ងរណាស់សម្រាប់ខ្ញុំ ការនៅឆ្ងាយពីជំនួយរបស់មនុស្ស ដោយត្រូវការពឹងផ្អែកការរស់នៅទាំងស្រុងដោយពឹងលើព្រះជាម្ចាស់នៅក្នុងការការពារ ផ្គត់ផ្គង់ និងផ្តល់ជំនួយគ្រប់បែបយ៉ាងជាជាងពឹងផ្អែកពីជំនួយរបស់មនុស្ស។ ខ្ញុំបានគិតថា មនុស្សម្នាក់នឹងត្រូវការជំនួយខាងសាច់ដុំព្រលឹងវិញ្ញាណកាន់តែខ្លាំងសម្រាប់ការងារបែបនេះ។ ប្រសិនបើយើងមានជំនឿ នោះយើងមិនមានចម្ងល់ទេដែលថា ព្រះជាម្ចាស់នឹងមិនធ្វើឲ្យយើងបរាជ័យឡើយ។ តែនឹងមានរឿងអ្វីកើតឡើង ប្រសិនបើសេចក្តីជំនឿរបស់ខ្ញុំបែរជាមិនគ្រប់គ្រាន់? នៅពេលនោះ ខ្ញុំមិនទាន់បានយល់នៅឡើយទេ ដែលសូម្បីតែយើងមិនជឿ ក៏ទ្រង់នៅតែស្មោះត្រង់ ទ្រង់មិនអាចបដិសេធអង្គទ្រង់ផ្ទាល់បានឡើយ។ ដូច្នេះ បញ្ហាពិតនៅក្នុងគំនិតរបស់ខ្ញុំមិនមែនថា តើទ្រង់ស្មោះត្រង់ ឬយ៉ាងណានោះទេ ប៉ុន្តែថាសេចក្តីជំនឿរបស់ខ្ញុំខ្លាំងគ្រប់គ្រាន់ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៅក្នុងការចាប់ផ្តើមគម្រោងដែលនៅមុខខ្ញុំ ឬយ៉ាងណា។

"នៅពេលដែលខ្ញុំទៅដល់ប្រទេសចិន" ខ្ញុំគិតថា៖ "ខ្ញុំមិនបានស្នើសុំពីនរណាម្នាក់សម្រាប់រឿងអ្វីនោះទេ។ ខ្ញុំនឹងពឹងពាក់លើព្រះជាម្ចាស់តែមួយប៉ុណ្ណោះ។ វាជាការសំខាន់ណាស់នៅក្នុងការរៀនអំពីរបៀបជំរុញអ្នកដទៃតាមរយៈព្រះជាម្ចាស់ដោយការអធិស្ឋានតែមួយមុខគត់ជាមុនសិន មុននឹងចាកចេញពីប្រទេសអង់គ្លេស"។

គាត់មានឆន្ទៈនៅក្នុងការលះបង់អ្វីគ្រប់យ៉ាងសម្រាប់ការនេះ។ ប្រហែលជាមានការវិនិច្ឆ័យដ៏មិនសូវល្អ ប្រហែលជាវាស្រួចស្រាវខ្លាំងបំផុតក៏មិនដឹង ប៉ុន្តែព្រះទ្រង់បានជ្រាប

និងបានជួបគាត់យ៉ាងអស្ចារ្យ។ «ដើម្បីផ្លាស់ប្រែមនុស្ស តាមរយៈព្រះជាម្ចាស់ដោយការអធិស្ឋានតែមួយមុខគត់»—វាគឺជាមហិច្ឆតាដ៏ធំក្នុងការទទួលបានបទពិសោធន៍ក្នុងសិរីល្អនៃព្រះ នៅរដូវរងាដ៏ឯកានោះនៅឌ្រេនសាយដ៍។

នៅទីក្រុងហ្វល ចៅហ្វាយដ៏ចេះគិតគូររបស់ខ្ញុំបានសួរខ្ញុំ សូមឲ្យខ្ញុំប្រាប់គាត់ឲ្យដឹងនៅពេលដែលប្រាក់ខែរបស់ខ្ញុំដល់ពេលកំណត់ត្រូវបើក។ ខ្ញុំបានសម្រេចចិត្តថាមិនរម្លឹកគាត់ដោយផ្ទាល់នោះទេ ប៉ុន្តែអធិស្ឋានសុំឲ្យព្រះជាម្ចាស់រម្លឹកគាត់ ដោយសង្ឃឹមថានឹងជួយពង្រឹងសេចក្ដីជំនឿរបស់ខ្ញុំដោយការទទួលបានការឆ្លើយតបចំពោះការអធិស្ឋានរបស់ខ្ញុំអំពីប្រាក់ខែនោះ។

នៅពេលដែលជិតដល់ពេលបើកប្រាក់ខែមួយភាគបួន ខ្ញុំបានអធិស្ឋានយ៉ាងច្រើនអំពីការនេះតាមធម្មតា។ ពេលវេលាកំណត់បានមកដល់ហើយ ប៉ុន្តែលោកវេជ្ជបណ្ឌិតហាតឌីយ៍ នៅតែមិនទាន់រម្លឹកអ្វីបន្តិចសោះ។ ខ្ញុំនៅតែបន្តអធិស្ឋាន។ ប៉ុន្មានថ្ងៃកន្លងផុតទៅហើយ តែគាត់នៅតែមិនចាំដដែល។ ចុងក្រោយ ខ្ញុំបានធ្វើការលើគណនីប្រចាំសប្ដាហ៍របស់ខ្ញុំនៅយប់ថ្ងៃសៅរ៍ ខ្ញុំបានដឹងថា ខ្ញុំនៅសល់លុយតែកន្លះកាក់មកុដ ("half a crown" គឺជាប្រភេទលុយប្រទេសអង់គ្លេស ដែលប្រហែលពីរម៉ឺនរៀលបច្ចុប្បន្ន) នេះទេ។ ទោះជាយ៉ាងនេះក្ដី ខ្ញុំមិនដែលធ្លាប់ជួបការខ្វះខាតអ្វីឡើយពីមុនមក ដូច្នេះខ្ញុំនៅតែបន្តអធិស្ឋាន។

ថ្ងៃអាទិត្យនោះពិតជារីករាយណាស់។ ចិត្តរបស់ខ្ញុំពេញដោយព្រះពរដូចធម្មតា។ ខ្ញុំបានទៅព្រះវិហារនៅពេលព្រឹក ហើយនៅពេលរសៀល និងពេលល្ងាចខ្ញុំបានចំណាយពេលផ្សាយដំណឹងល្អនៅតាមផ្ទះបន្ទប់ជួល ដែលធម្មតាខ្ញុំបានទៅសួរសុខទុក្ខនៅតំបន់ក្រីក្របំផុតនៃទីក្រុង។ វាហាក់បីដូចជាមានអារម្មណ៍ថាដូចស្ថានសួគ៌បានចាប់ផ្ដើមនៅលើផែនដី ហើយគ្រប់យ៉ាងដែលខ្ញុំអាចប្រាថ្នា គឺសមត្ថភាពខ្លាំងជាងនេះនៅក្នុងការស្គាល់សេចក្ដីអំណរ មិនមែនជាបទពិសោធន៍ពិតជាងបទពិសោធន៍ដែលខ្ញុំមានរួចទៅហើយនោះឡើយ។

បន្ទាប់ពីបញ្ចប់ការបម្រើចុងក្រោយរបស់ខ្ញុំនៅម៉ោងដប់យប់នោះ  បុរសក្រីក្រម្នាក់បានសុំឲ្យខ្ញុំអធិស្ឋានឲ្យប្រពន្ធគាត់ដែលកំពុងជិតស្លាប់។ ខ្ញុំបានយល់ព្រមដោយឥតស្ទាក់ស្ទើរ ហើយនៅតាមផ្លូវ ខ្ញុំបានសួរថា ហេតុអ្វីមិនអញ្ជើញសម្ដេចសង្ឃទៅ ដោយ

សម្គាល់លើការសង្កត់សម្លេង គាត់ជាជនជាតិអៀរឡង់ (Irish)។ គាត់បានពន្យល់ថា បានអញ្ជើញហើយ តែសម្ដេចសង្ឃនឹងអញ្ជើញមកលុះត្រាតែមានប្រាក់ដប់ប្រាំបីផែនស៍ (ប្រហែលបួនម៉ឺនបីពាន់រៀលបច្ចុប្បន្ន) ដែលគាត់មិនមានលទ្ធភាពអញ្ជើញនោះទេ ដោយសារតែគ្រួសាររបស់គាត់កំពុងតែអត់ឃ្លាន។ បន្ទាប់មកការនោះ បានធ្វើឲ្យខ្ញុំភ្ញាក់ព្រើតថា លុយទាំងអស់ដែលខ្ញុំមានគឺតែកន្លះកាក់មកុដ (ប្រហែលពីរម៉ឺនរៀលបច្ចុប្បន្ន) តែប៉ុណ្ណោះ ជាងនេះទៅទៀតខ្ញុំមានតែទុកសម្រាប់ទឹកបបររាវមួយចានសម្រាប់អាហារពេលល្ងាច ហើយលុយនេះគ្រប់គ្រាន់សម្រាប់អាហារពេលព្រឹកប៉ុណ្ណោះ ប៉ុន្តែប្រាកដជាគ្មានអ្វីនឹងបរិភោគនៅយប់ថ្ងៃបន្ទាប់ទេ។

ភ្លាមៗនោះ មិនដឹងយ៉ាងម៉េចសេចក្ដីអំណរនៅក្នុងចិត្តខ្ញុំត្រូវបានបញ្ចប់។ ជាជាងការបន្ទោសខ្លួនឯង ខ្ញុំបានចាប់ផ្ដើមបន្ទោសបុរសក្រីក្រនោះ ដោយប្រាប់គាត់ថា វាពិតជាខុសណាស់នៅក្នុងការបណ្ដោយឲ្យរឿងរ៉ាវអាក្រក់ដូចដែលគាត់បានពណ៌នា ហើយគាត់គួរតែស្វែងរកជំនួយពីមន្ត្រីឲ្យមកជួយ។ គាត់បានឆ្លើយថា គាត់បានព្យាយាមហើយ ហើយគេបានប្រាប់គាត់ឲ្យមកនៅម៉ោងដប់មួយនៅព្រឹកបន្ទាប់ ប៉ុន្តែគាត់ខ្លាចថាប្រពន្ធរបស់គាត់មិនអាចរស់ឆ្លងផុតយប់នេះបានទេ។

ខ្ញុំបានគិតថា៖ «អាហ៍!» «ប្រសិនបើខ្ញុំមានប្រាក់ពីរស្លែលលីង (two shillings) និងប្រាំមួយផែន (sixpence) មិនមែនប្រាក់កន្លះកាក់មកុដនេះ (half-crown) ខ្ញុំនឹងឲ្យមួយស្លែលលីង (one shilling ប្រហែលប្រាំបួនពាន់រៀលបច្ចុប្បន្ន) ដល់អ្នកក្រីក្រទាំងនេះនោះមុខជារីករាយប៉ុណ្ណាទៅ!»។ ប៉ុន្តែ ខ្ញុំមិនដែលគិតថា ត្រូវចែកប្រាក់កាក់មកុដជាមួយអ្នកណាទេ។ ខ្ញុំបានដឹងតិចតួចថា ការពិតគឺខ្ញុំអាចទុកចិត្តព្រះជាម្ចាស់ជាមួយប្រាក់មួយស្លែលលីង និងប្រាំមួយផែន ប៉ុន្តែមិនបានជាស្រេចនៅក្នុងការទុកចិត្តទ្រង់ដោយគ្មានលុយមួយកាក់នៅក្នុងហោប៉ៅរបស់ខ្ញុំទេ។

អ្នកនាំផ្លូវរបស់ខ្ញុំបាននាំខ្ញុំឆ្លងកាត់ទីធ្លា ហើយខ្ញុំដើរតាមគាត់ដោយមានអារម្មណ៍ភ័យបន្តិច។ ខ្ញុំធ្លាប់ទៅទីនោះពីមុន ជាកន្លែងដែលខ្ញុំត្រូវបានគេប្រព្រឹត្តយ៉ាងឃោរឃៅកាលខ្ញុំបានទៅសួរសុខទុក្ខលើកមុន។ គាត់បាននាំខ្ញុំឡើងជណ្ដើររយីករយាកទៅក្នុងបន្ទប់ទ្រុឌទ្រោម ហើយខ្ញុំមានការតក់ស្លុតដោយបានឃើញរូបស្ថានភាពនៅខាងមុខខ្ញុំ។ មានក្មេងៗបួន ឬប្រាំនាក់កំពុងឈរនៅជុំវិញ ដែលថ្ពាល់ និងថ្ពាសផតរបស់ពួកគេ

កំពុងបង្ហាញយ៉ាងច្បាស់ពីសញ្ញានៃការអត់ឃ្លានរ៉ាំរ៉ៃ ហើយម្ដាយដ៏កំសត់ដែលនឿយហត់ ព្រមទាំងទារកទើបនឹងកើតរបស់នាងកំពុងដេកលើគ្រែ—ដែលអាយុតិចជាងមួយថ្ងៃកន្លះ—កំពុងយំង៉ាង៉ានៅក្បែរនាង។

ខ្ញុំបានគិតថា៖ «អាហ៍!» «ប្រសិនបើខ្ញុំមានប្រាក់ពីរស្លេលលីង និងប្រាំមួយផេន មិនមែនប្រាក់កន្លះកាក់មកុដ ខ្ញុំនឹងពេញចិត្តឲ្យប្រាក់ពួកគេមួយស្លេលលីង និងប្រាំមួយផេន (ប្រហែលមួយម៉ឺនរៀលបច្ចុប្បន្ន)»។ ប៉ុន្តែ ការសង្ស័យដ៏គួរឲ្យភ័យខ្លាចនៅតែបានបញ្ឈប់ខ្ញុំពីចិត្តចង់ជួយសម្រាលការឈឺចាប់របស់ពួកគេ ទោះបីជាវាត្រូវលះបង់អ្វីគ្រប់យ៉ាងដែលខ្ញុំមានក៏ដោយ។

វាប្រហែលជាមិនហាក់បីដូចជាចម្លែកនោះទេដែល ខ្ញុំមិនបានផ្ដល់ការកំសាន្តចិត្តច្រើនដល់អស់អ្នកដែលមានសំណាងមិនល្អ ព្រោះខ្ញុំក៏ត្រូវការកំសាន្តចិត្តដែរ។ យ៉ាងណាក៏ដោយ ក៏ខ្ញុំបានចាប់ផ្ដើមប្រាប់ពួកគេថាមិនគួរបាត់បង់ក្ដីសង្ឃឹមឡើយ។ ទោះបីជាស្ថានភាពរបស់ពួកគេធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ពួកគេមានព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដ៏សប្បុរស និងប្រកបដោយសេចក្ដីស្រឡាញ់សម្រាប់ពឹងផ្អែកលើបានដែរ។ ប៉ុន្តែ នៅក្នុងខ្លួនខ្ញុំ មានសម្លេងមួយបានស្រែកថា «ឱមនុស្សកំពុតអើយ! ឯងបាននិយាយដល់អ្នកមិនជឿទាំងនេះអំពីព្រះវរបិតាដ៏សប្បុរស និងប្រកបដោយសេចក្ដីស្រឡាញ់ដែលគង់នៅស្ថានសួគ៌ តែឯងមិនបានត្រៀមខ្លួនជាស្រេចក្នុងការទុកចិត្តទ្រង់ ដោយលះបង់ប្រាក់កន្លះកាក់មកុដនោះផង»។

ខ្ញុំស្ទើរតែអួលដើមករទៅហើយ។ ខ្ញុំនឹងធ្វើការព្រមព្រៀងដោយរីករាយដោយបញ្ញាចិត្តរបស់ខ្ញុំ ប្រសិនបើខ្ញុំមានប្រាក់ពីរហ្វ្លូរិន (florin) និងប្រាំមួយផេន (ប្រហែលមួយម៉ឺនរៀលបច្ចុប្បន្ន) ។ ខ្ញុំនឹងឲ្យប្រាក់ពីរហ្វ្លូរិន ហើយទុកអ្វីដែលនៅសល់។ ប៉ុន្តែ ខ្ញុំមិនត្រៀមខ្លួនជាស្រេចនៅក្នុងការទុកចិត្តលើព្រះតែមួយមុខ ដោយគ្មានប្រាក់ប្រាំមួយផេន (ប្រហែលមួយម៉ឺនប្រាំពីរពាន់ប្រាំរយរៀលបច្ចុប្បន្ន) នោះទេ។

ខ្ញុំមិនអាចនិយាយទៅរួចទេក្នុងស្ថានភាពទាំងនេះ ប៉ុន្តែចម្លែកណាស់ ខ្ញុំបានគិតថាការអធិស្ឋាននឹងងាយស្រួលទៅវិញ។ មុនពេលនេះ ខ្ញុំមានបទពិសោធន៍ថា ការអធិស្ឋានគួរឲ្យរីករាយ ហើយមិនដែលនឿយហត់នោះឡើយ ហើយខ្ញុំងាយស្រួលពោលពាក្យក្នុងការអធិស្ឋាន។ ខ្ញុំមានអារម្មណ៍ថា អ្វីដែលខ្ញុំត្រូវធ្វើគឺលុតជង្គង់ ហើយអធិស្ឋាន ហើយ

នោះនឹងនាំមកនូវភាពធូរស្រាលទាំងពួកគេ និងខ្ញុំដែរ។ ខ្ញុំនិយាយទៅកាន់បុរសនោះថា៖ «អ្នកបានសុំឲ្យខ្ញុំមក ហើយអធិស្ឋានជាមួយប្រពន្ធរបស់អ្នក» ។ «តោះសូមយើងអធិស្ឋាន»។ ហើយខ្ញុំក៏លុតជង្គង់ចុះ។

នៅពេលដែលខ្ញុំបានចាប់ផ្ដើមនិយាយថា៖ «ឱព្រះវរបិតាគង់នៅស្ថានសួគ៌អើយ!» នោះបញ្ញាចិត្តរបស់ខ្ញុំបានសួរថា «តើឯងកំពុងចំអកដល់ព្រះជាម្ចាស់មែនទេ? តើឯងនៅហ៊ានលុតជង្គង់ ហើយហៅទ្រង់ថា ព្រះវរបិតាដោយមានប្រាក់កន្លះកាក់មកុដនៅក្នុងហោប៉ៅនោះឬអី?»។

គ្រានៃវិបត្តិដែលខ្ញុំមិនធ្លាប់ជួបពីមុនមកបានកើតមកលើខ្ញុំហើយ។ ខ្ញុំមិនដឹងថា តើខ្ញុំបានឆ្លងផុតការអធិស្ឋាននោះដោយរបៀបណា ហើយថាតើពាក្យដែលខ្ញុំបានពោលចេញទៅស្ដាប់យល់ដែរឬអត់ទេ។ ប៉ុន្តែ ខ្ញុំបានក្រោកឡើងពីការលុតជង្គង់ដោយសេចក្ដីទុក្ខព្រួយយ៉ាងខ្លាំង។

ឪពុកដែលពេញដោយក្ដីទុក្ខព្រួយបានបែរមកខ្ញុំ ហើយនិយាយថា៖ «លោកគ្រូបានឃើញហើយពីស្ថានភាពដ៏គួរឲ្យភ័យបារម្ភដែលយើងកំពុងស្ថិតនៅក្នុង។ សូមជួយពួកយើងផង ប្រសិនបើលោកគ្រូអាចធ្វើបាន ដើម្បីជាសិរីល្អរបស់ព្រះ!»។ នៅខណៈនោះឃ្លាថា៖ «ចូរឲ្យដល់អស់អ្នកណាដែលសុំឯង» បានចូលមកក្នុងគំនិតខ្ញុំ ហើយព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអំណាច។

ខ្ញុំបានលូកដៃចូលហោប៉ៅរបស់ខ្ញុំ ហើយទាញយកប្រាក់កន្លះកាក់មកុដ រួចបានប្រគល់វាទៅឲ្យបុរសនោះទៅ។ ខ្ញុំបានពន្យល់ថា ថ្វីដ្បិតតែវានឹងហាក់បីដូចជាងាយស្រួលសម្រាប់ខ្ញុំនៅក្នុងការជួយពួកគេ ព្រោះខ្ញុំមើលទៅដូចជាអ្នកមាន តែខ្ញុំតាមពិតទៅកំពុងតែប្រគល់អ្វីៗគ្រប់យ៉ាងដែលខ្ញុំមានទៅឲ្យពួកគេអស់ហើយ។ ប៉ុន្តែ ខ្ញុំបានសង្កត់ធ្ងន់ថា ពាក្យនាំសាររបស់ខ្ញុំគឺពិតប្រាកដ៖ ព្រះជាម្ចាស់ពិតជាព្រះវរបិតាមួយអង្គ ហើយយើងអាចទុកចិត្តបាន។ សេចក្ដីអំណរនោះបានត្រឡប់មកកាន់ដួងចិត្តរបស់ខ្ញុំយ៉ាងពេញទំហឹង។ ខ្ញុំអាចនិយាយ និងមានអារម្មណ៍គ្រប់យ៉ាងនៅខណៈនោះ ហើយឧបសគ្គណាមួយចំពោះព្រះពរត្រូវបានដកចេញ ដោយសង្ឃឹមជារៀងរហូត។

មិនត្រឹមតែជីវិតរបស់ស្ត្រីដ៏កំសត់នោះទេដែលត្រូវបានសង្គ្រោះ តែជីវិតរបស់ខ្ញុំក៏ត្រូវបានសង្គ្រោះផងដែរ នៅពេលដែលខ្ញុំបានដឹងច្បាស់។ ជីវិតរបស់ខ្ញុំអាចក្លាយជាខូច ក្នុងនាម

ជីវិតជាគ្រីស្ទបរិស័ទប្រសិនបើព្រះគុណរបស់ព្រះជាម្ចាស់មិនបានទទួលជ័យជម្នះសោះ ហើយបើខ្ញុំមិនបានស្ដាប់បង្គាប់តាមការដឹកនាំរបស់ព្រះវិញ្ញាណរបស់ព្រះនៅខណៈនោះ។

ខ្ញុំចាំយ៉ាងច្បាស់ថា នៅពេលដែលខ្ញុំបានដើរត្រឡប់មកផ្ទះវិញនៅយប់នោះ មានអារម្មណ៍ថា ចិត្តរបស់ខ្ញុំស្រាលដូចហោប៉ៅទទេរបស់ខ្ញុំអញ្ចឹង។ ផ្លូវស្ងាត់ និងទទេស្អាតរណ្ដំជាមួយការសរសើរ ដែលខ្ញុំមិនអាចទប់បាន។ នៅពេលដែលខ្ញុំបានហូបបបររាវដ៏សាមញ្ញរបស់ខ្ញុំមុនពេលចូលគេង ខ្ញុំនឹងមិនដូរវាជាមួយពិធីជប់លៀងដ៏ប្រណិតបំផុតនោះទេ។ ខណៈពេលដែលខ្ញុំកំពុងអធិស្ឋាននៅចំហៀងគ្រែរបស់ខ្ញុំ ខ្ញុំបាននឹកដល់ព្រះជាម្ចាស់នូវព្រះបន្ទូលផ្ទាល់របស់ទ្រង់ថា៖ «អ្នកណាដែលមានចិត្តអាណិត ចែកដល់ពួកទាល់ក្រ នោះឈ្មោះថាថ្វាយឲ្យព្រះយេហូវ៉ាខ្ចី» (សុភាសិត ១៩:១៧)។ ហើយខ្ញុំសុំឲ្យទ្រង់សងប្រាក់កម្ចីរបស់ខ្ញុំយ៉ាងឆាប់រហ័ស បើមិនដូច្នេះ ខ្ញុំនឹងគ្មានអ្វីសម្រាប់បរិភោគនៅថ្ងៃបន្ទាប់ឡើយ។ ដោយមានសេចក្ដីសុខសាន្តក្នុងចិត្តខ្ញុំ និងនៅជុំវិញខ្លួនខ្ញុំ ខ្ញុំបានសម្រាកដោយភាពរីករាយនៅយប់នោះ។

នៅព្រឹកបន្ទាប់ ចានបបររបស់ខ្ញុំនៅទីនោះដដែលសម្រាប់ជាអាហារពេលព្រឹក ហើយអ្នករត់សំបុត្របានគោះទ្វារ មុនពេលខ្ញុំបរិភោគរួច។ ជាធម្មតា ខ្ញុំមិនបានទទួលសំបុត្រនៅថ្ងៃច័ន្ទនោះទេ ព្រោះឪពុកម្ដាយរបស់ខ្ញុំ និងមិត្តភក្តិភាគច្រើនមិនបានផ្ញើសំបុត្រមកនៅថ្ងៃសៅរ៍ឡើយ។ ដូច្នេះ វាធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើល នៅពេលម្ចាស់ផ្ទះបានដើរចូលមកជាមួយសំបុត្រមួយច្បាប់ ឬកញ្ចប់មួយនៅក្នុងដៃសើមរបស់គាត់ដែលគ្របដោយអៀមចុងភៅការពារប្រឡាក់របស់គាត់។ ខ្ញុំបានមើលសំបុត្រ តែមិនចំណាំអក្សរសរសេរដៃនោះទេ។ អក្សរសរសេរដៃនោះទាំងមើលមិនស្គាល់ ឬបន្លំ ហើយតែមប្រៃសណីយ៍ក៏ខ្ញុំអានមិនដាច់ទៀតផង។ ខ្ញុំមិនដឹងថាអ្នកណាជាអ្នកផ្ញើ ឬក៏មកពីណានោះទេ។ នៅពេលដែលខ្ញុំបើកស្រោមសំបុត្រ ខ្ញុំឃើញក្រដាសទទេ មានតែក្រដាសទទេមួយសន្លឹក។ នៅក្នុងក្រដាស ខ្ញុំបានឃើញស្រោមដៃក្មេងមួយគូ ហើយនៅពេលដែលខ្ញុំបានបើកវាដោយការភ្ញាក់ផ្អើល ប្រាក់កន្លះផោន (half a sovereign ប្រហែលមួយរយម៉ឺនរៀលបច្ចុប្បន្ន) បានធ្លាក់ទៅលើដី។

«ខ្ញុំបានបន្លឺឡើងថា៖ «សរសើរព្រះអម្ចាស់ ប្រាក់ ៤០០% បានត្រឡប់មកវិញក្រោយដាក់ទុនបានដប់ពីរម៉ោង! អ្នកជំនួញនៃទីក្រុង ហ្វូល នឹងរីករាយណាស់ ប្រសិនបើពួក

គេអាចឲ្យប្រាក់របស់គេខ្ចីបានអត្រាការប្រាក់បែបនេះ!»។ ពេលនោះ ខ្ញុំបានសម្រេចចិត្តថាដាក់ប្រាក់សន្សំ ឬប្រាក់ចំណូលទៅក្នុងធនាគារដែលមិនបរាជ័យ ទោះបីមួយណាក៏បាន ដែលជាការសម្រេចចិត្តដែលខ្ញុំមិនស្ដាយក្រោយ។

ខ្ញុំមិនអាចប្រាប់លោកអ្នកថា ខ្ញុំបានគិតអំពីឧប្បត្តិហេតុនេះញឹកញាប់ប៉ុណ្ណា ឬវាបានជួយខ្ញុំច្រើនប៉ុណ្ណា នៅពេលដែលមានរឿងរ៉ាវលំបាក។ ប្រសិនបើយើងនៅតែស្មោះត្រង់ជាមួយព្រះជាម្ចាស់នៅក្នុងរឿងតូចតាច នោះយើងនឹងទទួលបានបទពិសោធន៍ និងកម្លាំងដែលនឹងជួយយើងអំឡុងឧបសគ្គកាន់តែលំបាកនៅក្នុងជីវិតរបស់យើងជាមិនខាន។

នេះមិនមែនជាចុងបញ្ចប់នៃសាច់រឿងទេ ឬក៏ជាចម្លើយតែមួយគត់ចំពោះការអធិស្ឋានដែលនឹងបញ្ជាក់ពីសេចក្ដីជំនឿរបស់ លោកគ្រូ ហ៉ដសិន ថេល័រ នៅពេលនោះដែរ។

ការជួយសង្គ្រោះដែលគួរឲ្យកត់សម្គាល់ និងពេញដោយព្រះគុណនេះបាននាំសេចក្ដីអំណរដ៏ធំដល់ខ្ញុំ ហើយបានបញ្ជាក់យ៉ាងច្បាស់អំពីសេចក្ដីជំនឿរបស់ខ្ញុំ។ ប៉ុន្តែ ដប់ស្ដែលលីង (ten shillings ប្រហែលមួយរយម៉ឺនរៀលបច្ចុប្បន្ន) សូម្បីតែប្រើដោយសន្សំសំចៃក៏មិនបានយូរដែរ ហើយវានៅតែមានសារៈសំខាន់នៅក្នុងការបន្តការអធិស្ឋានថា លោកវេជ្ជបណ្ឌិត ហាតដីយ៍ នឹងចាំហើយនឹងសងប្រាក់ចំនួនដ៏ច្រើនដែលគាត់នៅតែជំពាក់ខ្ញុំ។ ថ្វីបើការអធិស្ឋានរបស់ខ្ញុំហាក់បីដូចជាមិនទទួលការឆ្លើយតប ហើយពីរសប្ដាហ៍បានកន្លងផុតទៅ ខ្ញុំបានត្រឡប់មកក្នុងស្ថានភាពដដែលដូចយប់ថ្ងៃអាទិត្យដែលគួរឲ្យកត់សម្គាល់។ គ្រប់ពេលទាំងអស់ ខ្ញុំបានបន្តអធិស្ឋានដោយស្មោះត្រង់សុំព្រះជាម្ចាស់ឲ្យរម្លឹកវេជ្ជបណ្ឌិត ហាតដីយ៍ ឲ្យបើកប្រាក់ខែឲ្យខ្ញុំ។

ប្រាកដណាស់ ការខ្វះខាតលុយកាក់មិនបានធ្វើឲ្យខ្ញុំក្រៀមក្រំនោះទេ។ ខ្ញុំអាចទទួលបានប្រាក់ពេលណាក៏បានដោយគ្រាន់តែទារ។ សំណួរសំខាន់នៅគំនិតរបស់ខ្ញុំគឺថា៖ «តើខ្ញុំអាចទៅប្រទេសចិន ឬក៏ការខ្វះសេចក្ដីជំនឿរបស់ខ្ញុំ និងការទំនាក់ទំនងជាមួយព្រះជាម្ចាស់បានក្លាយជាឧបសគ្គដ៏ធ្ងន់ធ្ងរដែលខ្ញុំមិនអាចចាប់ផ្ដើមការបម្រើដ៏មានតម្លៃខ្ពស់នេះបានមែនទេ?»។

នៅពេលចុងអាទិត្យបានខិតជិតមកដល់ ខ្ញុំមានអារម្មណ៍ពិតជាអាម៉ាស់ជាខ្លាំង។ ខ្ញុំត្រូវតែគិតឲ្យកាន់តែច្រើនជាជាងខ្លួនឯង។ ម្ចាស់ផ្ទះដែលជាគ្រីស្ទបរិស័ទរបស់ខ្ញុំរំពឹងថានឹងទទួលបានថ្លៃឈ្នួលនៅយប់ថ្ងៃសៅរ៍ដែលខ្ញុំបានដឹងថា គាត់ពិតជាត្រូវការវាណាស់។

តើខ្ញុំមិនគួរពិភាក្សារឿងប្រាក់ខែរបស់ខ្ញុំដើម្បីជាប្រយោជន៍ដល់គាត់ទេឬអី? ប៉ុន្តែ ការធ្វើដូច្នេះមានន័យថា ខ្ញុំត្រូវទទួលស្គាល់ខ្លួនឯងថា ខ្ញុំមិនសមនឹងទទួលគម្រោងបេសកកម្មបានទេ។ ខ្ញុំបានចំណាយពេលស្ទើរតែទាំងអស់នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ នៅពេលណាដែលខ្ញុំមិនធ្វើការ ដោយអធិស្ឋានយ៉ាងញឹកញាប់ទៅកាន់ព្រះ។ ប៉ុន្តែ ព្រឹកថ្ងៃសៅរ៍បានមកដល់ ខ្ញុំនៅតែស្ថិតនៅក្នុងស្ថានភាពដដែល។ ការអង្វរដ៏ខ្លាំងរបស់ខ្ញុំគឺសម្រាប់ការដឹកនាំ ថាតើត្រូវបន្តការរង់ចាំសម្រាប់ឱកាសល្អឬយ៉ាងណា។ តាមដែលខ្ញុំអាចប្រាប់បាន ខ្ញុំមានអារម្មណ៍យ៉ាងប្រាកដថា ការរង់ចាំនោះគឺជាជម្រើសដ៏ត្រឹមត្រូវ ហើយថាតាមរបៀបណាមួយព្រះនឹងអន្តរាគមន៍ជំនួសខ្ញុំ។ ដូច្នេះ ខ្ញុំបានរង់ចាំ ឥឡូវនេះចិត្តរបស់ខ្ញុំពេញដោយសេចក្តីសុខសាន្ត ហើយមិនមែនជាបន្ទុកទៀតទេ។

នៅម៉ោងប្រហែលប្រាំរសៀលថ្ងៃសៅរ៍នោះ បន្ទាប់ពីលោកវេជ្ជបណ្ឌិត ហាតឌីយ៍ បានបញ្ចប់ការសរសេរវេជ្ជបញ្ជារបស់គាត់ ហើយបានបំពេញជុំចុងក្រោយរបស់គាត់ចប់សព្វគ្រប់នៅថ្ងៃនោះហើយ នោះគាត់ក៏បានផ្អែកទៅកៅអីផ្អែករបស់គាត់ដូចធម្មតា ហើយបានចាប់ផ្តើមនិយាយអំពីរឿងសាសនា។ គាត់គឺជាបុរសម្នាក់មានសេចក្តីជំនឿយ៉ាងមុតមាំចំពោះព្រះ ហើយយើងមានពេលវេលានៅជាមួយគ្នាដោយអំណរ។ នៅខណៈនោះ ខ្ញុំកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ទៅខ្ទះដែលខ្ញុំកំពុងដាំទឹកគ្រឿងផ្សំដែលត្រូវការយកចិត្តទុកដាក់ដិតដល់។ ជាសំណាងល្អសម្រាប់ខ្ញុំ ព្រោះខ្ញុំជាប់រវល់ រំពេចនោះគាត់បានពោលឡើងដោយគ្មានការជាប់ទាក់ទងច្បាស់ទៅនឹងសកម្មភាពមុនរបស់ពួកយើងថា៖

«និយាយអញ្ចឹង ហ័ដសិន តើមិនត្រូវដល់ពេលត្រូវពេលបើកប្រាក់របស់ឯងម្តងទៀតហើយឬអី?»។

ខ្ញុំអាចត្រឹមតែស្រមៃថាខ្ញុំមានអារម្មណ៍បែបណា។ ខ្ញុំត្រូវលេបទឹកមាត់ពីរបីដងមុននឹងឆ្លើយតប។ នៅខណៈដែលខ្ញុំកំពុងកូរខ្ទះ និងបែរមុខចេញពីលោកវេជ្ជបណ្ឌិត ខ្ញុំបានប្រាប់គាត់ដោយចិត្តត្រជាក់ថា ប្រាក់ខែខ្ញុំត្រូវហួសពេលបើកមួយរយៈហើយ។ នៅខណៈនោះ ខ្ញុំមានអារម្មណ៍ថាអរព្រះគុណព្រះជាម្ចាស់យ៉ាងខ្លាំង! ព្រះអង្គប្រាកដជាបានឮការអធិស្ឋានរបស់ខ្ញុំ ហើយបានរម្លឹកគាត់ឲ្យគាត់គិតអំពីប្រាក់នោះនៅអំឡុងដែលខ្ញុំត្រូវការវាខ្លាំង ដោយមិនចាំបាច់ឲ្យខ្ញុំនិយាយ ឬឲ្យតម្រុយអ្វីទាំងអស់។

គាត់បានឆ្លើយថា៖ «អូហ៍ ឲ្យខ្ញុំសុំទោសផង ខ្ញុំភ្លេចឲ្យឈឹង។ ឯងដឹងហើយថាខ្ញុំរវល់

ប៉ុណ្ណា។ ខ្ញុំចង់ឲ្យខ្ញុំចាំឲ្យបានឆាប់ជាងនេះ ព្រោះកាលពីរសៀលនេះខ្ញុំបានផ្ញើលុយខ្ញុំទាំងអស់នៅធនាគារហើយ។ បើមិនដូច្នេះ ខ្ញុំនឹងបើកលុយឲ្យអ្នកភ្លាមៗហើយ»។

ខ្ញុំមិនអាចពណ៌នាអំពីអារម្មណ៍ជិនឆ្អន់ដែលខ្ញុំបានមាន ដោយសារតែឃ្លាដ៏គួរឲ្យភ្ញាក់ផ្អើលនោះ។ ខ្ញុំមិនដឹងថាត្រូវធ្វើបែបណាទេ។ ជាសំណាងល្អ ទឹកក្នុងខ្ទះនោះបានពុះរួចរាល់ធ្វើឲ្យខ្ញុំមានហេតុផលល្អនៅក្នុងការប្រញាប់ចេញពីបន្ទប់។ ខ្ញុំបានធូរចិត្តពេលចេញផុតពីមុខពីមាត់គាត់ រហូតដល់លោកវេជ្ជបណ្ឌិត ហាតឌីយ៍ បានត្រឡប់ទៅផ្ទះរបស់គាត់ ហើយខ្ញុំពិតជាអរគុណជាខ្លាំង ដែលគាត់មិនបានកត់សម្គាល់ពីអារម្មណ៍របស់ខ្ញុំ។

ភ្លាមៗនោះ នៅពេលដែលគាត់បានចាកចេញទៅ ខ្ញុំត្រូវទៅរកកន្លែងស្ងប់ស្ងាត់ ហើយអធិស្ឋានទៅព្រះអម្ចាស់រហូតខ្ញុំទទួលមិនត្រឹមតែការស្ងប់ចិត្ត ប៉ុន្តែការដឹងគុណ និងសេចក្តីអំណរដែរ។ ខ្ញុំជឿថា ព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងអ្វីៗទាំងអស់ ហើយទ្រង់នឹងមិនធ្វើឲ្យខ្ញុំខកបំណងនោះទេ។ ខ្ញុំបានព្យាយាមយល់អំពីបំណងព្រះហឫទ័យទ្រង់តាំងពីព្រលឹមតាមដែលខ្ញុំអាចដឹងបាន ខ្ញុំបានទទួលការណែនាំឲ្យរង់ចាំដោយអត់ធ្មត់។ ពេលនេះ ខ្ញុំបានទុកចិត្តថា ព្រះនឹងធ្វើការជំនួសខ្ញុំក្នុងរបៀបផ្សេងទៀត។

ល្ងាចនោះ ខ្ញុំបានចំណាយពេលអានព្រះគម្ពីរ និងរៀបចំមេរៀនសម្រាប់ការចែកចាយនៅផ្ទះផ្សេងៗនៅថ្ងៃបន្ទាប់ ដូចខ្ញុំធម្មតាបានធ្វើនៅរាល់ថ្ងៃសៅរ៍។ ខ្ញុំបានរង់ចាំយូរជាងធម្មតាបន្តិច។ ចុងក្រោយ នៅម៉ោងប្រហែលដប់ដោយគ្មានអ្វីមករំខាន ខ្ញុំបានពាក់អាវក្រៅ ហើយត្រៀមខ្លួនជាស្រេចនឹងត្រឡប់ទៅផ្ទះ។ ខ្ញុំសប្បាយចិត្តដែលដឹងថា ខ្ញុំត្រូវចាក់សោសាគួរចូលផ្ទះដោយខ្លួនឯង ដោយសារតែម្ចាស់ផ្ទះខ្ញុំបានចូលគេងពីព្រលប់។ គ្មាននរណាជួយទេសម្រាប់យប់នោះ។ ប៉ុន្តែ ប្រហែលជានៅថ្ងៃច័ន្ទ ព្រះនឹងជួយអន្តរាគមន៍ ហើយខ្ញុំអាចបង់នូវប្រាក់ជួលផ្ទះដែលខ្ញុំជំពាក់គាត់នៅដើមសប្តាហ៍ក្រោយ។

គ្រាន់តែខ្ញុំបម្រុងនឹងពន្លត់ភ្លើងចង្កៀង នោះខ្ញុំក៏បានឮសំរឹបជើងលោកវេជ្ជបណ្ឌិតនៅសួនច្បារដែលនៅចន្លោះផ្ទះ និងការិយាល័យរបស់គាត់។ គាត់បានសើចដោយអស់ពីចិត្តចំពោះខ្លួនឯងដោយរីករាយ។ គាត់បានចូលមកក្នុងការិយាល័យ បានសុំសៀវភៅបញ្ជីកត់ត្រា ហើយបានពោលថា៖ នោះពិតជាចម្លែកណាស់ អ្នកជំងឺអ្នកមានស្តុកស្តម្ភបំផុតម្នាក់ទើបតែមកបង់ថ្លៃព្យាបាលរបស់គាត់។ វាពិតជាចម្លែកខ្លាំងមែន! ខ្ញុំមិនបានគិតថាអ្វីដែលបានកើតឡើងនោះមានការទាក់ទងនឹងស្ថានភាពរបស់ខ្ញុំ ទោះបើមិនអញ្ជឹងទេ

នោះខ្ញុំនឹងមានអារម្មណ៍ឆ្គងៗ។ ប៉ុន្តែ ក្នុងនាមជាអ្នកសង្កេតការណ៍ម្នាក់ ខ្ញុំគិតថាវាគួរឲ្យអស់សំណើច ដែលមានអ្នកស្គុកស្គម្ភដល់ម្លឹងមកទូទាត់វិក្កយបត្រក្រោយម៉ោងដប់យប់ គាត់អាចគ្រាន់តែបង់ប្រាក់បានយ៉ាងងាយដោយសែកមួយសន្លឹកជាការស្រេច។ វាហាក់បីដូចជាគាត់មិនអាចស្ងប់ចិត្តដោយមិនទាន់បានបង់ប្រាក់រួច ហើយមានអារម្មណ៍ថា ត្រូវបានបង្ខំឲ្យមកពេលយប់ថ្មើរនេះ ដើម្បីបង់ប្រាក់។

លោកវេជ្ជបណ្ឌិត ហាតឌីយ៍ បានទទួលគណនីនៅក្នុងសៀវភៅបញ្ជីរួចរាល់ ហើយបម្រុងនឹងចាកចេញ រំពេចនោះ គាត់បានងាកមក ហើយហុចក្រដាសប្រាក់មួយចំនួនដែលគាត់ទើបតែបានទទួល និងធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើល និងអរគុណជាខ្លាំង ព្រោះគាត់បាននិយាយថា៖

«និយាយអញ្ចឹង ហ៍ដសិន ឯងទទួលក្រដាសប្រាក់ទាំងនេះទៅ។ ខ្ញុំគ្មានក្រដាសប្រាក់រាយទេ ប៉ុន្តែខ្ញុំអាចឲ្យប្រាក់ដែលនៅសល់នៅសប្តាហ៍ក្រោយ»។

ជាថ្មីម្តងទៀត ខ្ញុំបានត្រឡប់ទៅបន្ទប់តូចរបស់ខ្ញុំ ហើយសរសើរព្រះអម្ចាស់ដោយអំណរ ដោយគ្មានអ្នកណាដឹងអំពីអារម្មណ៍របស់ខ្ញុំ។ បន្ទាប់ពីអ្វីៗបានកើតឡើង ខ្ញុំប្រហែលជាអាចទៅប្រទេសចិនបាន។

ជំពូកទី៥

# សេចក្តីជំនឿដែលបានសាកល្បង និងធ្វើឲ្យរឹងមាំឡើង

*ចិត្តខ្ញុំបានស្ងប់ដោយសារព្រះវរបិតារបស់ខ្ញុំ ទ្រង់ជ្រាបគ្រប់ទាំងអស់៖*
*គ្មានអ្វីអាចធ្វើឲ្យសេចក្តីជំនឿមួយនេះស្រអាប់បានទេ។*
*ទ្រង់ប្រទានអ្វីដែលគាប់ប្រសើរបំផុតដល់អស់អ្នកណា*
*ដែលទុកចិត្តទ្រង់ឲ្យជ្រើសរើសផ្លូវដែលគេដើរ។*

“នៅទីបំផុត ខ្ញុំនឹងទៅប្រទេសចិន!” ប៉ុន្តែ មានឧបសគ្គជាច្រើននៅតែកើតឡើង។ ដើម្បីទទួលបានជីវិតដែលបង្កើតផលផ្លែដ៏ពិត យើងត្រូវចាក់ឫសយ៉ាងជ្រៅ និងយ៉ាងពិសេសនៅក្នុងព្រះជាម្ចាស់។

លោកគ្រូ ហ៊័ដសិន ថេល័រ បានទៅទីក្រុងឡុងដ៍ (London) បន្ទាប់ពីទីក្រុងហ្វូល និងបានចូលជានិស្សិតពេទ្យនៅក្នុងចំណោមមន្ទីរពេទ្យដ៏ធំមួយ។ គាត់បានពឹងផ្អែកទាំង

ស្រុងលើព្រះអម្ចាស់តែមួយប៉ុណ្ណោះសម្រាប់ការផ្គត់ផ្គង់ ទោះបីជាឪពុក និងសមាគមន៍របស់គាត់ ដែលនៅទីបំផុត បានបញ្ជូនគាត់ទៅប្រទេសចិនស្នើផ្តល់ជំនួយខាងហិរញ្ញវត្ថុដល់គាត់ក្តី ក៏គាត់ចង់បន្តបញ្ជាក់ថា យើងអាចទុកចិត្តលើការសន្យារបស់ព្រះបាន។ នៅពេលដែលគាត់បានបដិសេធសំណើដ៏សប្បុរសរបស់ឪពុកគាត់ គ្រួសារ សមាគមន៍របស់គាត់បានសន្មតថា ការចំណាយរបស់គាត់មានគ្រប់គ្រាន់ហើយមើលទៅ។ សមាគមន៍បានបង់ថ្លៃសិក្សាឲ្យគាត់នៅមន្ទីរពេទ្យឡុនដុន (London Hospital) ហើយពូរបស់គាត់ម្នាក់នៅសូហូ (Soho) បានផ្តល់កន្លែងឲ្យគាត់ស្នាក់នៅពីរបីសប្តាហ៍។ ទោះជាយ៉ាងណាក្រៅពីរឿងនេះ មានតែការទុកចិត្តរបស់គាត់នៅក្នុងភាពស្មោះត្រង់របស់ព្រះទេ ទើបអាចជួយការពារគាត់មិនឲ្យប្រឈមមុខនឹងភាពក្រខ្សត់នៅក្នុងទីក្រុងដ៏ធំនេះបាន។ មុនពេលចាកចេញពីទីក្រុងហួល គាត់ក៏បានសរសេរសំបុត្រទៅម្តាយរបស់គាត់។

ខ្ញុំពិតជាកំពុងតែបង្ហាញថាកណ្ឌគម្ពីរ អេសាយ ២៦:៣ «ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះ ឲ្យមានសេចក្តីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់» គឺជាការពិត។ ចិត្តគំនិតរបស់ខ្ញុំបានស្ងប់ណាស់ ស្ងប់ជាងពេលណាទាំងអស់ ស្ងប់ជាងកាលដែលខ្ញុំមានមួយរយផោន (one hundred pounds ប្រហែល $៦000 ដុល្លារ បច្ចុប្បន្ន) នៅក្នុងហោប៉ៅរបស់ខ្ញុំទៅទៀត។ សូមឲ្យទ្រង់រក្សាខ្ញុំនៅបែបនេះ គ្រាន់តែពឹងផ្អែកលើទ្រង់សម្រាប់គ្រប់ទាំងព្រះពរ ទាំងខាងសម្ភារៈ និងខាងព្រលឹងវិញ្ញាណ។

មកដល់ប្អូនស្រីរបស់គាត់ អាមីលៀ (Amelia)៖

មិនទាន់មានឱកាសស័ក្តិសមនឹងខ្ញុំនៅឡើយទេនៅទីក្រុងឡុងដ៍ ប៉ុន្តែខ្ញុំមិនបារម្ភទេ ព្រោះព្រះទ្រង់ «នៅតែដដែលមិនថាម្សិលមិញ ថ្ងៃនេះ និងរហូតតទៅ»។ សេចក្តីស្រឡាញ់របស់ទ្រង់មិនដែលផុតឡើយ ព្រះបន្ទូលរបស់ទ្រង់នៅតែដដែល ហើយអំណាចរបស់ទ្រង់ក៏មិនដែលផ្លាស់ប្រែដែរ ដូច្នេះដួងចិត្តដែលទុកចិត្តក្នុងទ្រង់ស្ថិតនៅក្នុង «សេចក្តីសុខពេញខ្នាត»។ ខ្ញុំដឹងថា ទ្រង់ល្បងលខ្ញុំ ដើម្បីធ្វើឲ្យសេចក្តីជំនឿរបស់ខ្ញុំបានរឹងមាំឡើង ហើយអ្វីទាំងអស់នោះកើតមកពីសេចក្តីស្រឡាញ់។ ប្រសិនបើការនេះថ្វាយសិរីល្អដល់ទ្រង់ នោះខ្ញុំបានស្កប់ចិត្តហើយ។

លោកគ្រូ ហ័ដសិន ថេល័រ មានទំនុកចិត្តទាំងស្រុងសម្រាប់ពេលអនាគតទាំងជិត និង

ឆ្ងាយ។ ប្រសិនបើទំនុកចិត្តនោះបរាជ័យ គាត់បានគិតថា វាប្រសើរជាងក្នុងការដឹងអំពីវានៅក្នុងទីក្រុងឡុងដ៍ជាជាងនៅក្នុងប្រទេសចិន។ គាត់មានចេតនាជ្រើសរើសការកាត់ផ្ដាច់ប្រភពផ្គត់ផ្គង់ដែលអាចមានសក្ដានុពលរបស់គាត់ចោល។ គាត់បានដឹងថា គាត់ត្រូវការជំនឿរឹងមាំជាងនេះ ដើម្បីទុកចិត្តលើភាពស្មោះត្រង់របស់ព្រះដ៏មានព្រះជន្មគង់នៅ និងបទពិសោធន៍ច្រើនជាងនេះក្នុងការពឹងផ្អែកលើទ្រង់គ្រប់កាលៈទេសៈទាំងអស់។ មិនថាគាត់រស់នៅសុខស្រួល ឬមិនសុខស្រួលនៅទីក្រុងឡុងដ៍ មិនថាគាត់មានប្រាក់មូលនិធិ ឬមិនមាននោះទេ វាមិនសូវសំខាន់ជាងការទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅ គឺថាអ្វីៗទាំងអស់អាស្រ័យលើទ្រង់។ នៅពេលមានឱកាសផ្សេងដើម្បីសាកល្បងចំណេះដឹងរបស់គាត់នោះ គាត់មិនស្ទាក់ស្ទើរឡើយ ទោះបីគាត់បានដឹងថា វានឹងជាការល្បងលដ៏លំបាកក៏ដោយ។ ការសម្រេចចិត្តរបស់គាត់នឹងត្រូវដឹកនាំដោយព្រះជាម្ចាស់។ ចម្លើយដ៏ច្បាស់សម្រាប់ការអធិស្ឋានរបស់គាត់នៅទីក្រុងឡុងដ៍ បានចម្រើនសេចក្ដីជំនឿរបស់គាត់ឡើង និងបានជាការរៀបចំដ៏ល្អឥតខ្ចោះសម្រាប់ព្រឹត្តិការណ៍ដែលនឹកស្មានមិនដល់ ដែលធ្វើឲ្យការចេញដំណើរទៅប្រទេសចិនកាន់តែខិតចូលមកដល់នៅឆ្នាំក្រោយ។ លោកគ្រូ ហ៍ដសិន បានរៀបរាប់ពីបទពិសោធន៍យ៉ាងសង្ខេបនៅក្នុងការក្រឡេកមើលទៅអតីតកាលរបស់គាត់។ វាសមល្មមក្នុងការនិយាយថា ភាពឯកា និងទុក្ខលំបាក ដែលគាត់បានជួបប្រទះជាការល្បងនៃការស៊ូទ្រាំក្នុងការរស់ដោយសារតែនំប៉័ងពណ៌ត្នោត និងផ្លែប៉ោមអស់ជាច្រើនខែ ដោយដើរជាងដប់បីគីឡូម៉ែត្រទៅមន្ទីរពេទ្យ និងត្រឡប់មកវិញជារៀងរាល់ថ្ងៃ។ ហើយភាពមិនច្បាស់លាស់អំពីទំនាក់ទំនងរបស់គាត់ជាមួយអង្គការតែមួយគត់ ដែលមានបំណងបញ្ជូនគាត់ទៅប្រទេសចិន ទោះបីនៅមានវ័យក្មេងនៅឡើយក្ដី ទាំងគ្មានការបណ្ដុះបណ្ដាលនៅសាកលវិទ្យាល័យ តែលោកបានទទួលការដុសខាត់ឲ្យក្លាយជាមនុស្សម្នាក់ដែលមានសេចក្ដីជំនឿល្អ។

លោកគ្រូ ហ៍ដសិន ថេល័រ មានអាយុត្រឹមម្ភៃមួយឆ្នាំប៉ុណ្ណោះ នៅពេលដែលគាត់បានទទួលបានឱកាសដែលស្មានមិនដល់ ដើម្បីចុះសំពៅទៅទីក្រុង សៀងហៃ (Shanghai) ភ្លាមៗនៅតែអាចរកសំពៅបាន ស្របពេលដែលសមាគមន៍ផ្សាយដំណឹងល្អដល់ប្រទេសចិន (Chinese Evangelisation Society) បានស្នើសុំគាត់ឲ្យជួយបម្រើការងារ។ ការបះបោរប្រឆាំងរបស់ក្រុមថៃភីង បានឈានដល់កម្រិតកំពូលនៃយុទ្ធនារបស់ពួកគេ។

ដោយទីក្រុង ណាងគីង (Nanking ណានជីងបច្ចុប្បន្ន) ជាបន្ទាយដ៏រឹងមាំរបស់ពួកគេ កងកម្លាំងដែលបានអះអាងថាជាគ្រីស្ទបរិស័ទបានដណ្ដើមយកខេត្តភាគកណ្ដាល និងភាគខាងជើង ហើយជិតដណ្ដើមយកក្រុង ប៉ិគីង (Peking ប៉េកាំងបច្ចុប្បន្ន)។ អ្នកដឹកនាំរបស់ពួកគេបានសរសេរទៅកាន់បេសកជនជនជាតិអាមេរិកម្នាក់ដែលគាត់ទុកចិត្តថា៖ «សូមជួយបញ្ជូនគ្រូមកខ្ញុំឲ្យបានច្រើន ដើម្បីជួយផ្សាយអំពីសេចក្ដីពិត។ នៅពេលដែលបេសកកម្មរបស់ខ្ញុំជោគជ័យ ខ្ញុំនឹងផ្សព្វផ្សាយគោលលទ្ធិ (ការបង្រៀន) ទូទាំងអាណាចក្រទាំងមូល ដូច្នេះ គ្រប់គ្នានឹងត្រឡប់ទៅព្រះអម្ចាស់ ហើយថ្វាយបង្គំព្រះពិតតែមួយអង្គប៉ុណ្ណោះ។ នេះ គឺជាបំណងចិត្តរបស់ខ្ញុំ»។

សរុបមក ភ្លាមៗវាហាក់បីដូចជាប្រទេសចិននឹងបើកទទួលពួកអ្នកផ្សាយដំណឹងល្អ។ គ្រីស្ទបរិស័ទ គ្រប់ទីកន្លែងមានអារម្មណ៍រំជើបរំជួលយ៉ាងខ្លាំង។ ការចាត់សកម្មភាពភ្លាមៗចាំបាច់នៅក្នុងការឆ្លើយតបទៅនឹងវិបត្តិដ៏សំខាន់នេះ ហើយមួយរយៈនោះការបរិច្ចាគបានហូរចូលទៅក្នុងមូលនិធិយ៉ាងច្រើន។ នៅក្នុងចំណោមអ្នកផ្ដួចផ្ដើមសមាគមន៍ព្រះគម្ពីរចក្រភពអង់គ្លេស និងបរទេស (British and Foreign Bible Society) មានគម្រោងប្រារព្ធពិធីបុណ្យខួបហាសិបឆ្នាំរបស់ពួកគេ ដោយបោះពុម្ពព្រះគម្ពីរសញ្ញាថ្មីជាភាសាចិនចំនួនមួយលានក្បាល។ អង្គការដែលលោកគ្រូ ហ័ដសិន បាននិយាយជាមួយបានសម្រេចចិត្តបញ្ជូនបុរសពីរនាក់ទៅទីក្រុង សៀងហៃ ដើម្បីធ្វើការនៅលើទឹកដីប្រទេសចិន។ ម្នាក់គឺជាវេជ្ជបណ្ឌិតជនជាតិស្កុតឡែន (a Scottish doctor) មិនអាចចាកចេញទៅភ្លាមៗបានទេ ប៉ុន្តែពួកគេរំពឹងចង់បានបុរសវ័យក្មេងជាងនេះ ដើម្បីទៅផ្ដល់ដំណឹងក្នុងរយៈពេលខ្លី បើទោះបីជា វាមានន័យថា ត្រូវបោះបង់សញ្ញាបត្រខាងវេជ្ជសាស្ត្រ និងការវះកាត់ដែលគាត់កំពុងសិក្សាក្ដី។

លោកគ្រូ ហ័ដសិន ថេល័រ បានពិចារណាយ៉ាងល្អិតល្អន់លើការសម្រេចចិត្តនេះ និងតាមធម្មតា គាត់ស្វែងរកដំបូន្មាន និងការអធិស្ឋានពីឪពុកម្ដាយរបស់គាត់។ បន្ទាប់ពីប្រជុំជាមួយលេខាធិការម្នាក់របស់សមាគមន៍ផ្សាយដំណឹងល្អដល់ប្រទេសចិន នោះគាត់បានសរសេរសំបុត្រទៅម្ដាយរបស់គាត់ថា៖

«លោក ប៊ើដ (Bird) បានជួយដោះស្រាយការលំបាកជាច្រើនដែលខ្ញុំបានជួប ហើយខ្ញុំគិតថា វានឹងជារឿងវៃឆ្លាតនៅក្នុងការធ្វើតាមដំបូន្មាន និងភ្លាមៗដាក់ពាក្យទៅគណៈ

កម្មការ។ ខ្ញុំនឹងរង់ចាំការឆ្លើយតបរបស់អ្នកម្តាយ និងពឹងផ្អែកលើការអធិស្ឋានរបស់អ្នកម្តាយ។ ប្រសិនបើពួកគេយល់ព្រមឲ្យខ្ញុំចាកចេញភ្លាមៗ តើអ្នកម្តាយគិតថា ខ្ញុំគួរតែមកផ្ទះវិញ មុនពេលខ្ញុំចេញដំណើរដែរឬទេ? ខ្ញុំពិតជាចង់ជួបអ្នកម្តាយម្តងទៀត ហើយខ្ញុំដឹងថា អ្នកម្តាយក៏ចង់ជួបខ្ញុំដែរ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា វានឹងងាយស្រួលជាងសម្រាប់យើង បើយើងមិនបានជួបគ្នា ជាជាងជួបគ្នាម្តងទៀត ហើយត្រូវនិយាយពាក្យថាលាម្តងទៀត។ ប៉ុន្តែ មិនមែនលាគ្នារហូតទេ!

បន្តិចទៀត៖ វានឹងកន្លងផុតហើយ! ហេតុអ្វីយើងគួរតែជៀសវាងការប្រឈមនឹងទុក្ខលំបាកដែលព្រះយេស៊ូវដែលបានសន្យា? អូហ៍ សូមដើរតាមជំហានរបស់ទ្រង់ឲ្យបានឆាប់ ដោយចាត់ទុកគ្រប់អ្វីផ្សេងទៀតថា ដូចជាឥតបានការ មិនអាចប្រៀបផ្ទឹមនឹងទ្រង់បានទេ៖ បន្ទាប់មក ស្នាមញញឹមទ្រង់នឹងលើសពីការប៉ះប៉ូវចំពោះការរងទុក្ខនៃរយៈពេលដ៏ខ្លីនេះទៅទៀត!។

ខ្ញុំមិនដឹងថាត្រូវសរសេរអ្វីទៀតនោះទេ ប៉ុន្តែខ្ញុំសង្ឃឹមថា នឹងបានឮពីអ្នកម្តាយឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ សូមអធិស្ឋានឲ្យច្រើនសម្រាប់ខ្ញុំ។ វាជាការងាយនៅក្នុងការនិយាយអំពីការបោះបង់ចោលអ្វីគ្រប់យ៉ាង ដើម្បីព្រះគ្រីស្ទ ប៉ុន្តែវាពិបាកនៅពេលដែលជួបការសាកល្បងជាក់ស្តែង យើងអាចយកឈ្នះទៅបាន លុះត្រាតែយើង “ពេញលេញក្នុងទ្រង់” នៅក្នុងទ្រង់។ សូមព្រះគង់នៅជាមួយអ្នកម្តាយ ព្រមទាំងប្រទានពរ អ្នកម្តាយជាទីស្រឡាញ់របស់ខ្ញុំ សូមឲ្យទ្រង់ជួយអ្នកម្តាយបានយល់ច្បាស់ថា ព្រះគ្រីស្ទទ្រង់មានតម្លៃប៉ុណ្ណា ដូច្នេះអ្នកម្តាយនឹងមិនប្រាថ្នាអ្វីផ្សេងក្រៅពី “ចង់ស្គាល់ទ្រង់”... សូម្បីតែ “រួមក្នុងការរងទុក្ខលំបាករបស់ទ្រង់ទៀតផង”»។

ហើយគាត់ក៏បានសរសេរទៅកាន់បងស្រីរបស់គាត់ថា៖

“ប្អូនស្រី អាម៉ាលៀ សូមអធិស្ឋានទៅព្រះអង្គដែលបានសន្យាថា នឹងប្រទានគ្រប់ទាំងតម្រូវការរបស់យើង សូមទ្រង់គង់នៅជាមួយខ្ញុំនៅក្នុងពេលវេលាដ៏លំបាក និងអន្ទះសានេះ។

នៅពេលយើងពិចារណាអំពីសេចក្តីស្រឡាញ់ដែលមានកម្រិតរបស់យើង ការបម្រើដែលមិនបានបង្កើតផលផ្លែ និងការរីកចម្រើនបន្តិចបន្តួចរបស់យើងធ្វើឆ្ពោះទៅកាន់ភាពល្អឥតខ្ចោះ វាពិតជាស្រស់ស្រោយយ៉ាងសម្បើមនៅក្នុងការបែរទៅរកទ្រង់ ដើម្បីជ្រមុជខ្លួន

យើងម្តងទៀតនៅក្នុង "ក្បាលទឹកមួយបើកឡើង ដើម្បីជំរះអំពើបាប និងសេចក្តីសៅហ្មង" (សាការី ១៣:១)។ ហើយដើម្បីរម្លឹកថា "ព្រះបានទទួលយើងនៅក្នុងព្រះរាជបុត្រាស្ងួនភ្ញារបស់ទ្រង់" ដែលជាប្រាជ្ញាញាណ សេចក្តីសុចរិត ការញែកជាបរិសុទ្ធ និងការប្រោសលោះរបស់យើងមកពីព្រះជាម្ចាស់។ អូហ៍ សេចក្តីពោរពេញនៃព្រះគ្រីស្ទ សេចក្តីពោរពេញនៃព្រះគ្រីស្ទ (អេភេសូរ ១:៦; ៤:១៣)"។

នៅពេលដែលលោកគ្រូ ហ័ដសិន ថេល័រ បានទៅដល់ច្រាំងសមុទ្រប្រទេសចិនដំបូងនៅឆ្នាំ ១៨៥៤ បន្ទាប់ពីធ្វើដំណើរប្រកបគ្រោះថ្នាក់អស់រយៈពេលប្រាំខែ ប្រទេសចិនបានបង្កឲ្យមានបញ្ហាប្រឈមកាន់តែលំបាកកើតឡើង ចំពោះអ្នកផ្សាយដំណឹងល្អជាងសព្វថ្ងៃនេះទៅទៀត។ មានតែកំពង់ផែ សៀងហៃ និងកំពង់ផែសន្ធិសញ្ញាបួន (Treaty Ports) ផ្សេងទៀតប៉ុណ្ណោះ បើកឲ្យជនបរទេសរស់នៅ ហើយគ្មានវត្តមានបេសកជនប្រូតេស្តង់សូម្បីតែម្នាក់នៅលើទឹកដី ដែលនៅឆ្ងាយពីឆ្នេរសមុទ្រនោះ។ សង្គ្រាមស៊ីវិលបានចាប់ផ្តើម ហើយចលនាថៃភីងក៏បានចាប់ផ្តើមបាត់បង់លក្ខណៈដើមរបស់វាដែរ។ ចលនានោះបានក្លាយជាចលនានយោបាយពុករលួយ ដែលធ្វើឲ្យប្រទេសជោគជាំដោយឈាម និងទុក្ខវេទនាក្រៃលែងអស់រយៈពេល១១ឆ្នាំ។ ជំនួសឲ្យការអាចទៅដល់ទីក្រុង ណាងគីង និងផ្សាយដំណឹងល្អនៅជនបទ លោកគ្រូ ហ័ដសិន ថេល័រ បានជួបការលំបាកសូម្បីតែតាំងជំហរខ្លួនឯងនៅក្នុងទីក្រុង សៀងហៃ ហើយអាចត្រឹមតែធ្វើដំណើរចូលទៅជនបទដោយប្រថុយប្រថានប៉ុណ្ណោះ។

ជាច្រើនឆ្នាំក្រោយមក នៅពេលគាត់ទទួលខុសត្រូវដឹកនាំបេសកជនជាច្រើននាក់ វាច្បាស់ណាស់ដែលបញ្ហាប្រឈមនៅពេលដំបូងៗទាំងនោះសុទ្ធតែជារឿងចាំបាច់។ គាត់កំពុងត្រួសត្រាយផ្លូវមួយក្នុងប្រទេសចិនសម្រាប់មនុស្សរាប់រយនាក់ដែលនឹងដើរតាមក្រោយ ទោះបីនៅពេលនោះគាត់ផ្ទាល់ ឬអ្នកផ្សេងទៀតមិនដឹងឡើយក៏ដោយ។ គាត់បានស្គាល់គ្រប់ទាំងបន្ទុក និងទ្រាំទ្រនឹងការល្បួងល បទពិសោធន៍ទាំងនោះអាចបង្កើតភាពពិតប្រាកដ។ ដូចជាដែកត្រូវប្រែក្លាយទៅជាដែកថែប ចិត្តរបស់គាត់កាន់តែចេះស៊ូទ្រាំ និងអត់ធ្មត់ជាងអ្នកផ្សេងដោយការស្រឡាញ់ និងរងទុក្ខច្រើនជាង។ គាត់ជាមនុស្សម្នាក់ដែលលើកទឹកចិត្តដល់មនុស្សរាប់ពាន់នាក់ឲ្យជឿជាក់ទាំងស្រុងដូចជាក្មេងៗ ដែលយើងត្រូវរៀនមេរៀនកាន់តែជ្រៅអំពីព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះវរបិតា។

ហេតុដូច្នេះ ការលំបាកត្រូវបានអនុញ្ញាតឲ្យនៅជុំវិញខ្លួនគាត់ ជាពិសេសនៅពេលដំបូងៗ នៅពេលដែលចាប់អារម្មណ៍ គឺជាអ្វីជ្រាលជ្រៅបំផុត និងយូរអង្វែងបំផុត ការលំបាកទាំងប៉ុន្មានបានអមមកជាមួយនឹងការរំដោះជាច្រើន ដែលបានប្រែការទាំងអស់នោះឲ្យទៅជាព្រះពរពេញមួយជីវិត។

ទីក្រុង សៀងហៃ បានស្ថិតនៅក្នុងភ្លើងសង្គ្រាម។ “ពួកឈ្មួតក្បាលក្រហម” (Red Turbans) គឺជាក្រុមឧទ្ទាមដែលបានកាន់កាប់ទីក្រុងកំណើតនៅជិតកន្លែងតាំងលំនៅរបស់ជនបរទេស (Foreign Settlement)។ កងទ័ពរដ្ឋាភិបាលប្រហែលបួនម៉ឺន ទៅប្រាំម៉ឺននាក់បានបោះជំរុំនៅក្បែរនោះ។ ជាញឹកញាប់ មានការប្រយុទ្ធគ្នាបានកើតឡើង ហើយជារឿយៗកងជីវពលបរទេសត្រូវការពារលំនៅឋានដែលនៅទីនោះ។ តម្លៃទំនិញបានហក់ឡើងដោយសារតែគ្រោះទុរភិក្ស ហើយទាំងទីក្រុង និងលំនៅឋានមានភាពចង្អៀតយ៉ាងខ្លាំង ពិបាកក្នុងការស្វែងរកកន្លែងស្នាក់នៅ។ អរគុណដល់លោកវេជ្ជបណ្ឌិត ឡក់ហាដ (Dr. Lockhart) មកពីក្រុមបេសកកម្មទីក្រុងឡុងដ៍ (London Mission) ដែលបានផ្តល់ទីជម្រកបណ្តោះអាសន្នសម្រាប់អ្នកដែលមកដល់ថ្មី។ ទោះជាយ៉ាងនេះក្តី គាត់ក៏អាចមើលឃើញការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាតាមបង្អួចរបស់គាត់ ហើយធ្វើដំណើរទៅណាក៏ឃើញមានការរងទុក្ខដែលមិនធ្លាប់ឃើញពីមុនមក។

លោកគ្រូ ហ៉ាដសិន ថេល័រ រងាខ្លាំងនៅពេលដែលគាត់បានមកដល់ទីក្រុង សៀងហៃជាលើកដំបូង ហើយដោយសារតែធ្យូងមានតម្លៃហាសិបដុល្លារ (ប្រហែលពីរពាន់សាមសិបដុល្លារ បច្ចុប្បន្ន) ក្នុងមួយតោន ដូច្នេះការធ្វើឲ្យផ្ទះបានកក់ក្តៅ គឺមិនអាចធ្វើទៅរួចនោះទេ។ គាត់មិនបារម្ភអំពីការរស់នៅដោយគ្មានរបស់ទំនើប ហើយរីករាយចំពោះទីជម្រកនៅលើដី ប៉ុន្តែគាត់នៅតែប្រឈមនឹងភាពរងាញ័រមាត់ និងភាពសើម។

មិនយូរប៉ុន្មានបន្ទាប់ពីគាត់បានមកដល់ គាត់បានលើកឡើងថា ស្ថានភាពពិតជាលំបាកណាស់។ លោកវេជ្ជបណ្ឌិត ឡក់ហាដ បានទទួលឲ្យគាត់ស្នាក់នៅជាបណ្តោះអាសន្ន ដោយសារតែគាត់មិនអាចរកផ្ទះស្នាក់នៅបាន។ គ្មាននរណាម្នាក់អាចតាំងទីលំនៅនៅទីក្រុងឡើយ ព្រោះតែមានការប្រយុទ្ធគ្នាកំពុងតែកើតឡើងពេលនោះ ហើយផ្ទះសំបែងកំពុងតែរង្គោះរង្គើដោយសារកាណុងកាំភ្លើងដែលគេបាញ់នៅពេលដែលគាត់កំពុងតែសរសេរ។

«វាគឺរងាខ្លាំងណាស់ ដែលពិបាកនឹងធ្វើការគិត ឬសូម្បីតែកាន់ប៊ិកសរសេរ។ អ្នកម្តាយនឹងបានទទួលសំបុត្ររបស់កូនតាមរយៈលោក ភៀស (Mr. Pearse) កូនកំពុងតែច្របូកច្របល់ខ្លាំងណាស់។ កូននឹងមិនទទួលបានសំបុត្រតបមកវិញក្នុងរយៈពេលបួនខែ ហើយមានបេសកជនដែលមានសន្តានចិត្តល្អមួយក្រុម បានស្វាគមន៍កូនយ៉ាងកក់ក្តៅ រហូតបានធ្វើឲ្យកូនក្រែងចិត្តនឹងពួកគាត់។ ព្រះយេស៊ូវនឹងដឹកនាំកូនឲ្យត្រូវចំទិសដៅ។ កូនស្រឡាញ់ជនជាតិចិនកាន់តែខ្លាំងឡើងហើយឥឡូវនេះ។ កូនសង្ឃឹមថា កូននឹងក្លាយជាប្រយោជន៍សម្រាប់ពួកគេ!»

គាត់បានសរសេរអំពីថ្ងៃអាទិត្យដំបូងនៅក្នុងប្រទេសចិនថាៈ

«កូនបានចូលរួមថ្វាយបង្គំពីរវេននៅឯក្រុមបេសកកម្មទីក្រុងឡុងដ៍ ហើយបន្ទាប់មកនៅពេលរសៀល កូនបានចូលទៅក្នុងទីក្រុងជាមួយលោកគ្រូ វ៉ាយលី (Mr. Wylie)។ អ្នកម្តាយមុខជាមិនធ្លាប់ឃើញទីក្រុងមួយស្ថិតនៅក្រោមការឡោមព័ទ្ធទេ…ខ្ញុំសង្ឃឹមថាអ្នកម្តាយនឹងមិនជួបរឿងបែបនេះទេ! យើងបានដើរជុំវិញកំផែងបន្តិច ហើយវាជារឿងគួរឲ្យក្រៀមក្រំ ដែលឃើញផ្ទះសម្បែងជាច្រើនខ្ទង់ត្រូវបានបំផ្លាញ។ គេបានដុតផ្ទះសម្បែងបំផ្ទុះខ្ទេចខ្ទីជាបំណែកៗ ស្ថិតក្នុងសភាពពុកផុយ! ហើយវាជារឿងដ៏គួរឲ្យរន្ធត់ខ្លាំងណាស់ក្នុងការពិចារណាអំពីសេចក្តីទុក្ខវេទនារបស់មនុស្សដែលធ្លាប់បានរស់នៅទីនោះ ដ្បិតគេបានបង្ខំឲ្យចេញពីផ្ទះសម្បែង និងទីជម្រករបស់ពួកគេនៅក្នុងពេលដ៏លំបាកនេះ។

ចំពេលដែលយើងបានទៅដល់ច្រកខាងជើង (North Gate) ពួកគេកំពុងប្រយុទ្ធគ្នាយ៉ាងសាហាវនៅខាងក្រៅទីក្រុង។ មានគេបានទាញមនុស្សស្លាប់ម្នាក់ចូលមក ម្នាក់ទៀតរបួសចំទ្រូង ហើយខ្ញុំបានពិនិត្យបុរសទីបី ដែលហាក់បីដូចជាមានការឈឺចាប់យ៉ាងក្រៃលែង ដោយសារគ្រាប់កាំភ្លើងបានបាញ់ចំដៃរបស់គាត់ធ្លាយឆ្អឹង។ នៅឆ្ងាយបន្តិច យើងបានឃើញបុរសមួយចំនួនបានអូសកាណុងកាំភ្លើងតូចមួយដើម ដែលពួកគេដណ្តើមបាន ហើយនៅពីក្រោយពួកគេ អ្នកខ្លះទៀតបានអូសអ្នកទោសដ៏កម្សត់ប្រាំនាក់ ដោយទាញសក់របស់ពួកគេអូសចូលមកខាងក្នុង។ ពួកអ្នកទោសដ៏កម្សត់ទាំងនោះបានអង្វរពួកយើងយ៉ាងក្រៀមក្រំឲ្យជួយសង្គ្រោះពួកគេ ស្របពេលដែលពួកគេត្រូវអូសចូលមកក្នុងយ៉ាងប្រញាប់ប្រញាល់ ប៉ុន្តែគួរឲ្យសោកស្តាយណាស់ ពួកយើងមិនអាចធ្វើអ្វីទាំងអស់។ ពួកគេប្រហែលជាត្រូវប្រហារជីវិតភ្លាមៗ។ គិតដល់រឿងនេះ ពិតជាគួរឲ្យតក់ស្លុតណាស់»។

ការឈឺចុកចាប់របស់អ្នកដែលនៅជុំវិញខ្លួនគាត់អាចនឹងធ្វើឲ្យគាត់ជ្រួលច្របល់ក្នុងចិត្ត បើសិនគ្មានកម្លាំង ដែលគាត់ទទួលបានពីព្រះអង្គ ដែលរងការឈឺចាប់ខ្លាំងបំផុតនោះទេ ជាពិសេសខណៈដែលគាត់អាចធ្វើអ្វីបានតិចតួច ឬមិនអាចធ្វើអ្វីបានទាល់តែសោះ ក្នុងការជួយដល់ពួកគេ។

«ខ្ញុំយល់ច្បាស់ថា ពេលនៅឆ្ងាយពីផ្ទះវាមានអារម្មណ៍យ៉ាងណា នៅក្នុងសង្គ្រាម មិនអាចយល់ ឬក៏ទំនាក់ទំនងជាមួយមនុស្សណាបាន។ ខ្ញុំមានការប៉ះពាល់ចិត្តយ៉ាងខ្លាំងដោយការរងទុក្ខវេទនា និងភាពអសមត្ថភាពទាំងស្រុងរបស់ខ្ញុំផ្ទាល់នៅក្នុងការជួយពួកគេ ឬសូម្បីតែដឹកនាំគេទៅឯព្រះយេស៊ូវ។ សាតាំងធ្វើឲ្យចិត្តខ្ញុំជ្រួលច្របល់ដូចជាទឹកជំនន់ ប៉ុន្តែមានព្រះជាម្ចាស់អាចតតាំងនឹងវាបាន។ ព្រះយេស៊ូវគង់នៅទីនេះ បើទោះបើជាមនុស្សភាគច្រើនមិនស្គាល់ទ្រង់ ហើយមនុស្សជាច្រើនអាចព្រងើយកន្តើយចំពោះទ្រង់ក៏ដោយ ក៏ទ្រង់មានព្រះជន្មគង់នៅ និងមានតម្លៃចំពោះអស់អ្នកដែលជាកម្មសិទ្ធិរបស់ទ្រង់ដែរ។

លោកគ្រូ ហ៊ដសិន ថេល័រ បានប្រឈមមុខនឹងទុក្ខលំបាកជាលើកដំបូង នៅពេលដែលគាត់បានជួបការលំបាកក្នុងការបំពេញកាតព្វកិច្ចខាងហិរញ្ញវត្ថុរបស់គាត់។ គាត់បានរស់នៅយ៉ាងសន្សំសំចៃនៅផ្ទះ ប៉ុន្តែឥឡូវនេះត្រូវប្រឈមនឹងការចំណាយដែលមិនអាចជៀសបាន ដែលលើសពីប្រាក់ចំណូលរបស់គាត់។ ការរស់នៅជាមួយអ្នកដែលមានប្រាក់ចំណូលច្រើនជាងគាត់ គាត់ត្រូវតែបង់ថ្លៃជួលបន្ទប់សំណាក់ដូចពួកគេដែរ ដែលបានធ្វើឲ្យប្រាក់ឧបត្ថម្ភរបស់គាត់ត្រូវអស់យ៉ាងឆាប់រហ័ស។ ក្នុងនាមជាម្នាក់ដែលធ្លាប់តែសន្សំសំចៃសម្រាប់បេសកកម្មបរទេស គាត់បានស្គាល់ពីតម្លៃនៃប្រាក់រួមចំណែកបានមកពីការរកយ៉ាងលំបាករបស់អ្នកក្រ ហើយមានអារម្មណ៍ថា ពិបាកចិត្តដែលត្រូវប្រើប្រាស់ប្រាក់បេសកជនក្នុងចំនួនច្រើនបែបនេះ។ សំបុត្រដែលគាត់បានផ្ញើទៅសមាគមន៍បានទទួលការឆ្លើយតបដែលមិនជាគាប់ចិត្ត ហើយបើទោះបីជាគាត់បានរង់ចាំអស់ជាច្រើនខែសម្រាប់ការណែនាំក្តី ជាញឹកញាប់គាត់មិនបានទទួលបានចម្លើយសម្រាប់សំណួរបន្ទាន់របស់គាត់ទេ។ គណៈកម្មការនៅទីក្រុង ឡុងដ៍ ដែលនៅកន្លែងឆ្ងាយពីគាត់ ហើយមមាញឹកនឹងរឿងផ្ទាល់ខ្លួនរបស់ពួកគេ ហើយពិបាកនឹងយល់ពីស្ថានភាពរបស់គាត់។ ទោះបីជាមានការខិតខំប្រឹងប្រែងពីសំណាក់លោកគ្រូ ហ៊ដសិន ថេល័រ ដើម្បីបញ្ជាក់រឿងរ៉ាវនានាក៏ដោយ ក៏គាត់នៅបន្តរងទុក្ខពីភាពមិនច្បាស់លាស់ និងវិបត្តិខាងហិរញ្ញវត្ថុដែរ។

ប្រាក់ដុល្លារ សៀងហៃ (Shanghai dollar) ពីមុនមានតម្លៃប្រហែលហាសិបសេន មាស (ប្រហែលជាស្មើនឹង $២៧,១៧ ដុល្លារ បច្ចុប្បន្ន) បានឡើងថ្លៃទ្វេដង ហើយនៅតែបន្តឡើងថ្លៃ ប៉ុន្តែទិញមិនបានច្រើនបន្ថែមទេ។ ដោយបានបង្ខំឲ្យចំណាយលើសប្រាក់ខែរបស់គាត់សម្រាប់តម្រូវការចាំបាច់ គាត់បានប្រើលិខិតឥណទានបន្ទាន់មួយ ដែលគ្មានការធានាថាការចំណាយរបស់គាត់នឹងត្រូវបានរ៉ាប់រងនោះឡើយ។ គាត់សម្រាន្តមិនលក់អស់ជាច្រើនយប់ ដោយសារស្ថានភាពលំបាកនៃទំនួលខុសត្រូវខាងហិរញ្ញវត្ថុនេះ។

នៅពេលដែលកម្តៅនារដូវក្តៅកាន់តែកើនឡើង បញ្ហាក៏មានកាន់តែច្រើនឡើងដូចគ្នាដែរ។ លោកគ្រូ ហ័ដសិន ថេល័រ បានដឹងដោយប្រយោលថា លោកវេជ្ជបណ្ឌិតជនជាតិស្កុតឡេនដែលលោកគ្រូរំពឹងថា គាត់នឹងមកចូលរួមជាមួយគាត់ បានចាកចេញពីប្រទេសអង់គ្លេសជាមួយក្រុមគ្រួសារគាត់ហើយ។ គ្មាននរណាម្នាក់បានប្រាប់គាត់ឲ្យរៀបចំផ្ទះសម្បែងសម្រាប់ពួកគេទេ ហើយនៅពេលដែលពេលវេលាចេះតែកន្លងផុតទៅ ច្បាស់ណាស់ថា គាត់ត្រូវតែធ្វើអ្វីមួយដើម្បីការពារពួកគេពីការគ្មានផ្ទះស្នាក់នៅ។ វាជារឿងដ៏លំបាកមួយ  ដោយមិនមានការអនុញ្ញាតឲ្យចំណាយលុយ គាត់បានជួលបន្ទប់មួយសម្រាប់មនុស្សប្រាំនាក់ស្នាក់នៅ។ គាត់ក៏បានស្វែងរកក្នុងក្រុង និងលំនៅឋានយ៉ាងនឿយហត់ នៅក្រោមកម្តៅក្តៅខ្លាំងនាខែសីហា ដើម្បីរកផ្ទះតែគ្មានផ្ទះទំនេរឲ្យជួលទេ ដោយសារមិនមានប្រាក់គ្រប់គ្រាន់នៅក្នុងការធ្វើដំណើរ។ មិត្តភក្តិរបស់គាត់នៅសៀងហៃបានផ្តល់ដំបូន្មានឲ្យគាត់ថា ឲ្យទិញដី ហើយសាងសង់ភ្លាមៗ។ ប៉ុន្តែ គាត់មិនអាចចែកចាយពីទុក្ខលំបាកខាងហិរញ្ញវត្ថុ ឬក៏បញ្ហានៃការគ្រប់គ្រងរបស់សមាគមន៍របស់គាត់ ដែលបានលេចលឺនៅក្នុងសហគមន៍ទៅហើយនោះក្តី។ ដូច្នេះ គាត់បានលាក់ទុកបញ្ហានោះតែម្នាក់ឯងតាមដែលគាត់អាចធ្វើបាន ហើយបានព្យាយាមទុកចិត្តលើព្រះជាម្ចាស់ ដើម្បីទ្រាំទ្របន្ទុកទាំងនោះ។

អស់អ្នកណាដែលពិតជាពឹងអាងលើព្រះអម្ចាស់តែងនិយាយថា៖ “អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្តីស្លាប់ក៏ដោយគង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ ព្រនង់ ហើយនឹងដំបងរបស់ទ្រង់កំសាន្តចិត្តទូលបង្គំ” (ទំនុកតម្កើង ២៣:៤)។ ប៉ុន្តែ ដូចដែលសាវ័ក ពេត្រុស បានលើកឡើងថា ខ្ញុំមានទំនោរនឹងឈប់ទុកចិត្ត ហើយចាប់ផ្តើមចាប់អារម្មណ៍ទៅលើបញ្ហានៅជុំវិញខ្លួនខ្ញុំ។ អូហ៍ តើខ្ញុំ

កាន់តែចង់ឲ្យមានស្ថេរភាពជាងនេះឬយ៉ាងណា! ថ្មីៗនេះ ខ្ញុំបានអានព្រះគម្ពីរ និងឆ្លុះបញ្ចាំងទៅលើព្រះបន្ទូលសន្យាជាច្រើន ហើយកាន់តែមានតម្លៃ។ ដំបូង ក្តីបំណងចង់រៀនភាសាឲ្យបានឆាប់ចេះរបស់ខ្ញុំបានបណ្តាលព្រលឹងវិញ្ញាណរបស់ខ្ញុំស្រទន់។ ទោះជាយ៉ាងណា ព្រះគុណដែលមិនអាចកាត់ថ្លៃបានរបស់ព្រះអម្ចាស់ បានធ្វើឲ្យជីវិតរបស់ខ្ញុំកាន់តែភ្លឺស្វាងឡើងដោយព្រះវត្តមានទ្រង់»។

ហើយគាត់បានសរសេរបន្ថែមទៅប្អូនស្រីរបស់គាត់ថា៖

«បងបានព្យាយាមគិតស្ទើរតែផ្ទុះខួរក្បាល ដើម្បីរកផ្ទះមួយខ្នង ប៉ុន្តែគ្មានលទ្ធផលទាល់តែសោះ។ ហេតុដូច្នេះបានជា បងបានប្តូរទៅរកការអធិស្ឋានវិញ ទាំងបានផ្ទេរទុក្ខកង្វល់ទាំងឡាយទៅព្រះអម្ចាស់ ហើយឥឡូវនេះបងមានអារម្មណ៍ថា បានស្ងប់ចិត្តទាំងស្រុងហើយ។ ទ្រង់នឹងផ្គត់ផ្គង់ ព្រមទាំងដឹកនាំបង ហើយនឹងគ្រប់ទាំងការសម្រេចចិត្តដ៏លំបាកៗផ្សេងទៀត»។

វាស្ទើរតែមិនគួរឲ្យជឿថាជាការពិត នៅពេលដែលលោកគ្រូ ហ័ដសិន ថេល័រ បានរកឃើញផ្ទះកន្លែងមួយ ដែលគាត់អាចជួលបានត្រឹមតែរយៈពេលពីរថ្ងៃ បន្ទាប់ពីគាត់បានសរសេរសំបុត្រខាងលើ។ មុនពេលដាច់ខែ គាត់រកបានផ្ទះមួយធំល្មមសម្រាប់មិត្តរួមការងារដែលនឹងមកធ្វើការជាមួយគាត់។ ផ្ទះនោះមានបន្ទប់ប្រាំនៅជាន់លើ និងបន្ទប់ប្រាំពីរនៅជាន់ក្រោម វាពិតជាលំនៅឋានដ៏ធំទូលាយណាស់។ ថ្វីដ្បិតតែ វាជាផ្ទះឈើបែបចិនបុរាណដែលសភាពទ្រុឌទ្រោមបន្តិចក្តី តែទីតាំងរបស់វាល្អ ស្ថិតនៅកណ្តាលទីប្រជុំជន ហើយនៅជិតច្រកទ្វារក្រុងខាងជើង។ ដូច្នេះ ប្រាំមួយខែក្រោយការមកដល់ប្រទេសចិន គាត់បានតាំងលំនៅរបស់គាត់នៅទីនោះ។ ទោះបីជាតំបន់នោះមានគ្រោះថ្នាក់ខ្លាំង ហើយលោកគ្រូរបស់គាត់នឹងមិនហ៊ានទៅជាមួយក្តី ក៏គាត់បានជួលគ្រីស្ទបរិស័ទម្នាក់ពីទីក្រុងសៀងហៃ ដែលជាបុរសម្នាក់ដែលមានការអប់រំ ដើម្បីឲ្យជួយគាត់នៅក្នុងការប្រើសំនៀងភាសាក្នុងតំបន់។

ការរស់នៅក្នុងចំណោមជនជាតិចិននៅកន្លែងរបស់គាត់អាចឲ្យគាត់បើកការប្រជុំរាល់ថ្ងៃ ហើយអាចធ្វើកិច្ចការពេទ្យជាច្រើន ដោយមានជំនួយពីមិត្តរួមការងារថ្មី បានធ្វើឲ្យគាត់មានសេចក្តីអំណរយ៉ាងខ្លាំង។ ទោះជាយ៉ាងណាក្តី ទីតាំងនោះបានក្លាយទៅជាកន្លែងមានគ្រោះថ្នាក់ខ្លាំងលើសពីអ្វីដែលគាត់បានរំពឹងទុក។ វាស្ថិតនៅហួសពីដែន

ការពារសុវត្ថិភាពរបស់លំនៅឋាន និងកងកាំភ្លើងធំរបស់អធិរាជនៅច្រកទ្វារខាងជើង អាចបាញ់ដល់ ដោយការនេះបានបង្ហាញឲ្យឃើញថា ហេតុអ្វីផ្ទះនោះនៅទំនេរ។ អស់រយៈពេលជិតបីខែ បេសកជនវ័យក្មេងមួយរូបនេះបានរង់ចាំដោយសង្ឃឹមថា ស្ថានភាពនឹងបានប្រសើរឡើង។ ប៉ុន្តែ នៅទីបំផុត អ្វីៗកាន់តែអាក្រក់ទៅៗ។ គាត់បានប្រឈមនឹងគ្រោះថ្នាក់ដល់ជីវិតម្តងហើយម្តងទៀត ហើយត្រូវតែបង្ខំចិត្តមើលអំពើដ៏អាក្រក់ៗសាហាវព្រៃផ្សៃជារៀងរាល់ថ្ងៃ។ នៅពេលគេដុតអគារនៅជាប់នោះ ដើម្បីបង្ខំជនបរទេសឲ្យចេញ គាត់គ្មានជម្រើសអ្វីផ្សេងទៀតទេ ក្រៅពីត្រូវត្រឡប់ទៅសមាគមន៍បេសកកម្មក្រុងឡុងដ៍វិញ។ នៅទីនោះ គាត់បានរកកន្លែងសុវត្ថិភាពមួយនៅពេលដែលគ្រួសាររបស់លោកគ្រូផាកឃើស៍ (Parkers) បានមកដល់។

មិត្តជិតស្និទ្ធបំផុតរបស់លោកគ្រូ ហ័ដសិន ថេល័រ នៅប្រទេសចិនបានរស់នៅក្នុងផ្ទះតូចមួយដែលជារបស់សមាគមន៍បេសកកម្មក្រុងឡុងដ៍នៅជិតកន្លែងរបស់លោកវេជ្ជបណ្ឌិត ឡក់ហាដ។ ជាធម្មតា គាត់រីករាយនឹងធ្វើការជាមួយនឹងពួកគេ ជាពិសេសនៅពេលពួកគេបានអបអរនឹងកំណើតកូនដំបូងរបស់ពួកគាត់។ ទោះបីជាយ៉ាងណាលោកគ្រូ ហ័ដសិន បានកាន់ទុក្ខចំពោះការបាត់បង់របស់មិត្តគាត់ ខណៈដែលគ្រួសារបានបាក់បែក បន្ទាប់ពីមរណៈភាពរបស់ម្តាយកូននោះ ហើយឪពុកបានយកកូនទៅឲ្យមិត្តរួមការងារជួយមើលថែ។ ដំបូង គាត់មិនបានដឹងទេថា ផ្ទះនៅទទេដែលពេញដោយអនុស្សាវរីយ៍នេះ បានប៉ះពាល់ដល់ស្ថានភាពរបស់គាត់យ៉ាងណាឡើយ។ ដោយប្រឈមនឹងតម្រូវការរើផ្ទះដ៏គ្រោះថ្នាក់របស់គាត់នៅជិតច្រកទ្វារខាងជើង លោកគ្រូ ហ័ដសិនបានរកឃើញលំនៅឋាន ប៊ើឌិន (Burdon residence) ដែលគេដាក់សម្រាប់ជួល។ ជាមួយនឹងការមកដល់ដ៏ឆាប់របស់គ្រួសាររបស់លោកវេជ្ជបណ្ឌិត ផាកឃើ គាត់ក៏បានសម្រេចចិត្តទទួលខុសត្រូវក្នុងការជួលផ្ទះសម្រាប់ពួកគាត់។ ការនេះបានធ្វើឲ្យគាត់នៅសល់ប្រាក់ត្រឹមតែបីដុល្លារ (ប្រហែល $១២៦ ដុល្លារ បច្ចុប្បន្ន) ប៉ុណ្ណោះ ប៉ុន្តែត្រូវដល់ពេលត្រូវស្វាគមន៍មិត្តរួមការងាររបស់គាត់ ដោយមានទាំងទារកដែលបានកើតអំឡុងពេលធ្វើដំណើរតាមឆ្នេរសមុទ្រផងដែរ។

ដើម្បីជួយស្តារស្ថានការណ៍ គាត់បានចែកផ្ទះរបស់គាត់ពាក់កណ្តាលដោយស្ម័គ្រចិត្តដើម្បីជួលទៅក្រុមគ្រួសារបេសកជននៅក្នុងគ្រាលំបាកនេះ។ យ៉ាងណាមិញ ការបែងចែក

នេះបានធ្វើឲ្យនៅសល់ត្រឹមតែបីបន្ទប់សម្រាប់គ្រួសារលោកវេជ្ជបណ្ឌិត ផាកឃើ និងខ្លួនគាត់ផ្ទាល់។ ដោយសារមិនមានលុយគ្រប់គ្រាន់ គាត់មិនអាចដាក់គ្រឿងសង្ហារិមឲ្យពួកគេបានត្រឹមត្រូវនោះទេ ហើយរបស់របរដែលគាត់មាន ក៏មិនគ្រប់គ្រាន់សម្រាប់មនុស្សប្រាំមួយនាក់ដែរ។ ប៉ុន្តែ នេះគ្រាន់តែជាការចាប់ផ្ដើមនៃបញ្ហារបស់ពួកគេតែប៉ុណ្ណោះ។ លោកវេជ្ជបណ្ឌិត ផាកឃើ នៅសល់ប្រាក់ត្រឹមតែបីបួនដុល្លារតែប៉ុណ្ណោះ ក្រោយពីការធ្វើដំណើរដ៏វែងឆ្ងាយតាមកប៉ាល់ ហើយបានពឹងផ្អែកទៅលើលិខិតឥណទានមកពីសមាគមន៍ដែលមិនបានមកដល់ដៃទាល់តែសោះ ដោយសារបញ្ហាមួយចំនួន។ ប្រាក់ទាំងនោះត្រូវផ្ញើមកមុនពេលដែលគ្រួសារលោកវេជ្ជបណ្ឌិតបានចាកចេញពីប្រទេសអង់គ្លេស ប៉ុន្តែជាច្រើនខែបានកន្លងផុតទៅហើយ គ្មានដំណឹងអំពីវាទាល់តែសោះ។ ដោយសារមិនបានត្រៀមខ្លួនសម្រាប់រដូវរងាដ៏អាក្រក់ គ្រួសារនេះពិតជាត្រូវការសំលៀកបំពាក់ និងពូកយ៉ាងខ្លាំង។ វាពិបាកនឹងយល់ណាស់ថា តើពួកគេបានរស់ដោយរបៀបណានៅអំឡុងពេលប៉ុន្មានខែដ៏លំបាកនោះ ហើយពួកគេអាចត្រឹមតែទាយពីសហគមន៍បរទេសប៉ុណ្ណោះ។

លោកវេជ្ជបណ្ឌិត និងលោកស្រី ផាកឃើ (Dr. and Mrs. Parker) នៅតែបន្តការងារបេសកកម្មរបស់ពួកគាត់ ដោយមិនគិតពីឱកាសគួរឲ្យចាប់អារម្មណ៍នានាសម្រាប់អាជីពផ្នែកវេជ្ជសាស្ត្រនៅទីក្រុងសៀងហៃឡើយ។ គាត់បានចូលរួមយ៉ាងជាប់លាប់ជាមួយមិត្តរួមការងារវ័យក្មេងរបស់គាត់ក្នុងការផ្សាយដំណឹងល្អនៅទីក្រុង និងភូមិក្បែរៗនោះ។ នៅផ្ទះ ពួកគេបានចំណាយពេលនៅក្នុងការសិក្សាយ៉ាងឧស្សាហ៍ព្យាយាមនៅកន្លែងដ៏មមាញឹករបស់ពួកគេ។ ប៉ុន្តែ បទពិសោធន៍ទាំងនេះ បានបង្រៀនលោកគ្រូ ហ៉ដសិន ថេល័រ នូវមេរៀនដ៏មានតម្លៃអំពីរបៀបមិនគួរប្រព្រឹត្តនឹងអស់អ្នកដែលពឹងផ្អែកលើលោកអ្នក។ សមាជិកគណៈកម្មការនៅទីក្រុងឡុងដ៍ ដែលភាគច្រើនជាមិត្តជិតស្និទ្ធបានចែករំលែកការប្រកបខាងព្រលឹងវិញ្ញាណដែលគួរឲ្យចងចាំនៅទីក្រុង ថូថិនហាម (Tottenham) និងកន្លែងផ្សេងៗទៀត។ សូម្បីតែនៅពេលដែលគាត់បានដឹងច្បាស់បំផុតពីកំហុសរបស់ពួកគេ លោកគ្រូ ហ៉ដសិន មានអារម្មណ៍ថា នឹកបរិយាកាសនៃការអធិស្ឋាន និងសេចក្ដីស្រឡាញ់របស់ពួកគេសម្រាប់ព្រះគម្ពីរ។ គាត់នៅតែមានអារម្មណ៍ថាខ្វះអ្វីម៉្យាង ហើយគាត់ត្រូវតែរកឲ្យឃើញនូវអ្វីដែលជាការដឹកនាំនាពេលអនាគតរបស់គាត់ ទាំងការអនុវត្តន៍ជាក់ស្ដែង និងខាងព្រលឹងវិញ្ញាណ។ ដូចជាលោក យ៉ូសែប កាល

ពីដើម សេចក្ដីក្រលំបាកបានប៉ះពាល់គាត់យ៉ាងខ្លាំង ប៉ុន្តែការទ្រាំទ្ររបស់គាត់បាននាំមកនូវការធូរស្បើយដល់មនុស្សជាច្រើន។

គាត់បានសរសេរមកប្អូនស្រីរបស់គាត់ និងអ្នកឆ្លើយឆ្លងព័ត៌មានដ៏ស្និទ្ធស្នាលថា៖ «ប្អូនស្រីបានសួរថា តើបងអាចឆ្លងផុតបញ្ហាទាំងឡាយរបស់បងបានដោយរបៀបណា។ នេះគឺជារបៀបដែលបងធ្វើ៖ បងបានថ្វាយវាទៅព្រះអម្ចាស់។ ចាប់តាំងពីបងបានសរសេរសំបុត្រខាងលើ បងបានអានព្រះគម្ពីរនៅពេលល្ងាច—ទំនុកតម្កើងជំពូក៧២ដល់៧៤។ សូមអានខគម្ពីរទាំងនោះ ហើយមើលថាអាចយកមកអនុវត្តបានច្រើនប៉ុណ្ណា។ បងមិនប្រាកដថាហេតុអ្វី ប៉ុន្តែជាញឹកញាប់ បងកម្រអានព្រះគម្ពីរដោយហូរទឹកភ្នែកនៃសេចក្ដីអំណរ និងដោយអរព្រះគុណ។

បងយល់ថា តាំងពីបងបានមកដល់ ការធ្វើជាបងតាមពិតទៅបានដឹកនាំទៅរកអ្វីដែលកាន់តែប្រសើរឡើង និងរីកចម្រើនជាងស្ថានភាពណាៗទាំងអស់ ហើយទោះបីជាញឹកញាប់វាពិបាក ហើយមិនមែនជាអ្វីដែលបងចង់បានក្តី។ សម្រាប់ការទុកចិត្តកាន់តែខ្លាំងលើប្រាជ្ញា និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់»។

ជំពូកទី៦

# មិត្តភាព និងអ្វីលើសពីនេះទៅទៀត

*សេចក្តីស្រឡាញ់ដែលបន្ទាបខ្លួនទទួលបន្ទុកបងប្អូនរបស់ខ្លួន ជារបៀបដែលគាត់បានធំដឹងក្តី និងឃើញសេចក្តីទុក្ខព្រួយរលាយអស់! សេចក្តីស្រឡាញ់ដែលមិនដែលស្វែងរកការតបស្នង និងរង្វាន់នឹងមើលឃើញព្រះភក្ត្រនៃសេចក្តីស្រឡាញ់ដ៏ល្អឥតខ្ចោះរបស់ព្រះ!*
*— លោក អេហ្វ. ដឺបបលយូ. មេយ័រស— F.W.H. Meyers*

ក្នុងពេលពីរឆ្នាំដំបូងរបស់គាត់នៅប្រទេសចិន អ្វីដែលគួរឲ្យភ្ញាក់ផ្អើលបំផុតនៃកំណត់ត្រារបស់លោកគ្រូ ហ័ដសិន ថេល័រ គឺការប្តេជ្ញាចិត្តរបស់គាត់ចំពោះការត្រួសត្រាយផ្លូវក្នុងការផ្សាយដំណឹងល្អ។ លោកអ្នកអាចនឹងគិតថា ជាមួយនឹងការរៀនភាសា ការស៊ូទ្រាំនឹងសង្គ្រាម និងការប្រឈមមុខនឹងឧបសគ្គផ្សេងទៀតរាប់មិនអស់ គាត់នឹងមិនប្រថុយប្រថានចូលទៅតំបន់ខាងក្នុងជាញឹកញាប់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏អំឡុងពេលនោះ គាត់បានធ្វើដំណើរផ្សាយដំណឹងល្អយ៉ាងហោចណាស់ដប់ដង ដែលនោះគឺគួរឲ្យកត់សម្គាល់ចំពោះភាពក្លាហាន និងការតស៊ូព្យាយាមរបស់ពួកគេ។

ភាគខាងជើង ខាងត្បូង និងខាងលិចនៃទីក្រុងសៀងហៃ ជាតំបន់មួយមានប្រជាជនច្រើនអាចចូលទៅដល់បានដោយសារផ្លូវទឹកដ៏ច្រើន។ សំពៅបានផ្តល់ទីជម្រកនៅពេល

យប់ និងការធ្វើដំណើរនៅពេលថ្ងៃ ដោយធ្វើឲ្យអ្នកដំណើរមិនចាំបាច់ពឹងផ្អែកលើផ្ទះសំណាក់ចិនទេ។ ទូកមានការរៀបចំការចម្អិនម្ហូប ដើម្បីផ្ដល់អាហារដល់គ្រួសារនាយដើរទូក និង "ពួកភ្ញៀវ" ដែលពួកគេអាចធ្វើឲ្យប្រសើរឡើងដោយការផ្គត់ផ្គង់របស់ពួកគេ។ គ្រែធ្វើពីក្ដារឈើ ហើយបង្អួចតូចៗភាគច្រើននៅរាបស្មើនឹងបាតទូក។ ជាញឹកញាប់ ទោះបីគេមិនអាចក្រោកឈរបានត្រង់ខ្លួន ក៏គេអាចដេក ឬអង្គុយនៅលើគ្រែរបស់ពួកគេបានដែរ។ បើទោះបីជាមានភាពមិនសុខស្រួលរាប់មិនអស់ក្ដី ក៏ទូកនោះអាចនាំឲ្យមនុស្សចូលទៅក្រុង ស្រុក និងភូមិនានា ដែលតែងតែជាទស្សនីយភាពនៅពេលគេធ្វើដំណើរយ៉ាងយឺតៗនៅតាមនោះ។

ការនេះបានបង្ខំឲ្យលោកគ្រូ ហ៍ដសិន ថេល័រ ដូចដែលព្រះអម្ចាស់បានធ្វើដាក់គ្រូរបស់គាត់បានបំពេញដែរ។ គាត់មានអារម្មណ៍ថាវាជាកាតព្វកិច្ចនៅក្នុងចិត្តរបស់គាត់៖ «ខ្ញុំត្រូវតែធ្វើកិច្ចការរបស់ព្រះដែលបានបញ្ជូនខ្ញុំឲ្យមក» «ខ្ញុំក៏ត្រូវប្រាប់ដំណឹងល្អពីនគរព្រះដល់ស្រុកផ្សេងផងដែរ» «ខ្ញុំមានចៀមផ្សេងទៀត ហើយខ្ញុំត្រូវតែនាំពួកគេមកដែរ»។ ការគ្រាន់តែចេញទៅផ្សាយដំណឹងល្អតាមផ្លូវ និងច្រកនានានៃទីក្រុងសៀងហៃមិនគ្រប់គ្រាន់ទេ។ អ្នកខ្លះបានធ្វើការនោះដល់កម្រិតមួយហើយ។ គាត់មានអារម្មណ៍ថា គាត់មានទំនួលខុសត្រូវយ៉ាងជ្រាលជ្រៅចំពោះអស់អ្នកដែលនៅកាន់តែឆ្ងាយ អស់អ្នកដែលមិនដែលឮអំពីសេចក្ដីសង្គ្រោះ ហើយក៏នឹងមិនដែលឮលុះត្រាតែមាននរណាម្នាក់នាំសេចក្ដីពិតទៅកាន់ពួកគេតាមរយៈពួកអ្នកនាំសាររបស់ព្រះគ្រីស្ទ។ ហេតុដូច្នេះហើយ គ្មានអ្វីអាចបញ្ឈប់គាត់ឡើយ មិនថារដូវរងា កម្ដៅនារដូវក្ដៅ ឬក៏ស្ថានភាពគ្រោះថ្នាក់នៃសង្គ្រាម ដែលអាចនឹងគម្រាមកំហែងជីវិតរបស់ជនជាតិអឺរ៉ុបគ្រប់ពេល ឬក៏រារាំងមិនឲ្យគាត់ត្រឡប់មកវិញទៅក្នុងទីក្រុងសៀងហៃក៏ដោយ។

នៅពេលដែលគាត់បញ្ចប់ការធ្វើដំណើរមួយ ភ្លាមៗគាត់ក៏ចាប់ផ្ដើមរៀបចំសម្រាប់ការធ្វើដំណើរបន្ទាប់ទៀត។ បន្ទាប់ពីពេលដែលគាត់បានផ្ដោតលើការសិក្សា អ្នកដែលស្ដាប់គាត់អាចយល់ទាំងភាសាចិន និងគ្រាមភាសារបស់គាត់។ គាត់ធ្វើដំណើរយ៉ាងញឹកញាប់ ដែលគាត់បានបញ្ចប់ការធ្វើដំណើរដប់ដងនៅក្នុងរយៈពេលដប់ប្រាំខែ។ មុនពេលដែលលោកវេជ្ជបណ្ឌិត ផាកឃើ បានមកដល់ គាត់បានធ្វើដំណើរជាច្រើនដងដល់ដប់ប្រាំម៉ៃល៍ (ប្រហែលម្ភៃបួនគីឡូម៉ែត្រ) ពីទីក្រុង សៀងហៃ ហើយនៅបីខែដំបូងនៃភាពជាដៃ

គូរបស់ពួកគាត់ ពួកគាត់បានចែកចាយព្រះគម្ពីរសញ្ញាថ្មីមួយម៉ឺនប្រាំបីពាន់ក្បាល ផ្នែកខ្លះនៃខគម្ពីរ និងសៀវភៅពន្យល់នានា ព្រមទាំងខិតប័ណ្ណជាងពីរពាន់យ៉ាងប្រុងប្រយ័ត្នដល់អ្នកដែលអាចអានអក្សរបាន។ ដោយសារតែមនុស្សភាគច្រើនមិនចេះអក្សរ ការនេះតម្រូវឲ្យពួកគាត់ត្រូវទៅច្រើនកន្លែង និងពន្យល់ខ្លឹមសាររបស់សៀវភៅទៅកាន់ក្រុមដែលតែងតែផ្លាស់។ ចាប់ផ្ដើមនៅរដូវរងា ពួកគេបានធ្វើដំណើរចំនួនបួនដងពីខែមករាដល់ខែមីនា ទោះបីជាសីតុណ្ហភាពត្រជាក់ខ្លាំង និងបានបន្តនៅខែមេសា ឧសភា មិថុនា សីហា និងកញ្ញា។ ការចំណាយពេលពេញមួយថ្ងៃនៅក្នុងចំណោមហ្វូងមនុស្ស និងដេកនៅក្នុងទូក ដែលត្រូវតែបិទជិត ដើម្បីផ្ដល់សុវត្ថិភាពនៅពេលយប់ពីពួកចោរទន្លេបានធ្វើឲ្យពួកគេពិបាកគេចផុតពីកម្ដៅដ៏ខ្លាំង។ ប៉ុន្តែ គ្មានអ្វីមួយឡើយដែលអាចបង្អាក់ទឹកចិត្តអ្នកផ្សាយដំណឹងល្អវ័យក្មេងដែលបានតាំងចិត្តនោះទេ។

ការធ្វើដំណើរពិតជាមានគ្រោះថ្នាក់ណាស់ ហើយគាត់មានអារម្មណ៍ឯកោណាស់នៅពេលគាត់បានធ្វើដំណើរម្នាក់ឯង។ ការដាច់ចេញពីជនបរទេសផ្សេងទៀត និងការស្ថិតក្នុងចំណោមមហាជនដែលមិនរាក់ទាក់ គាត់នៅតែបានបន្តបេសកកម្មរបស់គាត់ដោយស្ងៀមស្ងាត់ដែរ ដោយប្រើឧបករណ៍ពេទ្យរបស់គាត់យ៉ាងមានប្រសិទ្ធភាព ដើម្បីយកឈ្នះការទុកចិត្តរបស់បណ្ដាជន។ ចិត្តរបស់គាត់បានកាន់តែដឹងច្បាស់ពីការរស់និងស្លាប់ «ដោយគ្មានព្រះគ្រីស្ទ» ហើយទស្សនៈរបស់គាត់កាន់តែទូលាយទៅៗ។ ពីកម្ពស់ភ្នំដែលមានប្រាសាទ និងវត្តបុរាណ គាត់បានឃើញទីក្រុងនានា និងផ្ទះនៅក្នុងភូមិនានារបស់មនុស្សរាប់លាននាក់ ដែលមិនដែលឮអំពីព្រះនាមតែមួយគត់ «ដែលយើងត្រូវតែបានសង្គ្រោះ» តាមរយៈនាមនោះ។ គំនិតដ៏ជ្រាលជ្រៅ និងយូរអង្វែងបានញាប់ញ័រឡើងនៅក្នុងចិត្តគាត់។

សង្គ្រាមស៊ីវិលបានឡើងដល់ចំណុចកំពូល ហើយកងកម្លាំងរបស់រដ្ឋាភិបាលដណ្ដើមបានទីក្រុងសៀងហៃ។ នៅក្នុងអំឡុងពេលនោះ លោកគ្រូ ហ៉ដសិន ថេល័រ និងបេសកជនចាស់ៗកំពុងធ្វើដំណើរឆ្ពោះទៅកាន់បឹងស៊ូចូវ (Soochow)។ ពួកគេមិនបានធ្វើដំណើរទៅយូរឡើយ នៅពេលពួកគេបានឃើញផ្សែងចេញពីអណ្ដាតភ្លើងដ៏សម្បើមពីកំពូលភ្នំ ដែលការនោះបានបង្ហាញថា ទីក្រុងសៀងហៃកំពុងតែឆេះហើយ។ ដោយបារម្ភអំពីគ្រួសាររបស់ពួកគាត់ដែលមានទីលំនៅនៅទីនោះ ពួកគាត់ក៏ប្រញាប់ប្រញាល់ត្រឡប់

ទៅវិញ។ ការភ័យខ្លាចរបស់ពួកគាត់បានកើនឡើង នៅពេលពួកគាត់បានរត់ជួបនឹងក្រុមអ្នកបះបោរដែលរត់គេចខ្លួន ដើម្បីស្វែងរកការការពារ ដែលក្រុមបេសកជនមិនអាចផ្តល់ឲ្យពួកគេបាន។ ក្រុមអ្នកបះបោរដែលត្រូវបានចាប់ខ្លួនដោយកងទ័ពត្រូវបានគេប្រហារជីវិតនៅចំពោះមុខពួកគាត់។ នៅពេលពួកគាត់បានធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់ដោយមានការភ័យខ្លាចកាន់តែខ្លាំង ពួកគេបានឃើញភស្តុតាងដ៏គួរឲ្យខ្លាចនៃមហន្តរាយដែលបានកើតឡើង។ ប៉ុន្តែលំនៅដ្ឋានរបស់ពួកគាត់នៅដដែល ដូចមុនពេលដែលក្រុមពួកគាត់បានចាកចេញទៅ។ ពួកចក្រព័ទ្ធនិយម ដែលឈ្លក់វង្វេងនឹងជ័យជម្នះ មិនអើពើនឹងពួកជនជាតិបរទេសឡើយ។

លោកគ្រូ ហ័ដសិន ថេល័រ បានសរសេរថា  ទីក្រុងសៀងហៃមានសន្តិភាព ហើយឥឡូវនេះ ប៉ុន្តែវាជាសន្តិភាពមរណៈ។ យ៉ាងហោចណាស់ មនុស្សពីរពាន់នាក់បានស្លាប់ ហើយជនរងគ្រោះមួយចំនួនបានរងការធ្វើទារុណកម្មដែលអាក្រក់លើសពីភាពសាហាវព្រៃផ្សៃបំផុតនៅក្នុងការស៊ើបអង្កេតយ៉ាងម៉ឺងម៉ាត់ និងសាហាវពីពួកកាតូលិកនូឆ្នាំ១៥៤២ (Inquisition)។ ទីក្រុងត្រូវបានគរដោយគំនរបាក់បែកជាមូលដ្ឋាន ហើយវាគួរឲ្យសង្វេគណាស់ដែលឃើញអ្នកដែលនៅរស់រានមានជីវិតកំពុងតែវេទនា។

លោកគ្រូ  ហ័ដសិន ថេល័រ និងអ្នករួមការងាររបស់គាត់ដែលបានធូរស្បើយពីរឿងអាក្រក់បំផុតដែលបានផុតហើយ ពួកគេបានលះបង់ខ្លួនក្នុងការមើលថែរក្សាមនុស្សដែលមានតម្រូវការខាងសាច់ឈាម និងព្រលឹងវិញ្ញាណ នៅពេលដែលពួកគាត់បានរង់ចាំការឆ្លើយតបពីគណៈកម្មការរបស់ពួកគេសម្រាប់សំណើការងារអចិន្ត្រៃយ៍បន្ថែមទៀត។ ពួកគាត់ប្រាថ្នាចង់ឲ្យខ្លួនមានប្រយោជន៍ ហើយក៏បានរៀបចំ និងអធិស្ឋានយ៉ាងយកចិត្តទុកដាក់អំពីគំនិតរបស់ខ្លួន។ ទោះបីជាយ៉ាងណា ការឆ្លើយតបដ៏សំខាន់ដែលហាក់បីដូចជាកំណត់អនាគតរបស់ពួកគាត់បានចំណាយពេលយូរ ដើម្បីនឹងមកដល់។

នៅខណៈពេលនោះ កម្តៅនៅរដូវក្តៅបានកំពុងគ្របដណ្តប់លើកន្លែងស្នាក់នៅដែលពេញដោយអ្នកផ្សេងទៀត ហើយការឆៀងចូលដ៏ខ្លីមកកាន់ទីក្រុង នីងប៉ូ បានបង្ហាញពីឱកាសដ៏គួរឲ្យចាប់អារម្មណ៍។ ពួកបេសកជននៅទីនោះបានដឹងពីតម្រូវការរបស់មន្ទីរពេទ្យមួយ ដើម្បីពង្រឹងប្រសិទ្ធភាពអង្គការរបស់ខ្លួន ហើយបានអញ្ជើញលោកវេជ្ជបណ្ឌិតផាកឃើ យ៉ាងកក់ក្តៅឲ្យមកដឹកនាំការផ្តួចផ្តើមនេះ ដោយពួកគេបានសន្យាថា នឹងផ្តល់

ការគាំទ្រយ៉ាងពេញលេញ។ នៅត្រង់ចំណុចនេះ នៅក្នុងពេលកំពុងរង់ចាំការឆ្លើយតបរបស់គណៈកម្មការ ពួកគេបានដឹងថា ពួកគេនឹងត្រូវរើចេញពីផ្ទះដែលពួកគេនៅរួមគ្នាជាមួយគ្រួសារផ្សេងឆាប់ៗនេះ ព្រោះវានឹងត្រូវទុកសម្រាប់សមាជិករបស់បេសកកម្មដែលវាជាកម្មសិទ្ធរបស់ពួកគេ។ មិត្តរួមផ្ទះរបស់ពួកគេកំពុងរើចេញ ប៉ុន្តែពួកគេមិនអាចមានលទ្ធភាពសាងសង់ ឬក៏រកបន្ទប់សម្រាប់ជួលនៅក្នុងសហគមន៍ ឬទីក្រុងក្នុងប្រទេសចិនឡើយ។ ដោយការរង់ចាំការឆ្លើយតបអស់រយៈពេលយ៉ាងយូរពីគណៈកម្មការប្រែជាមិនអនុគ្រោះ—ពួកគេមិនមានឆន្ទៈក្នុងការផ្ដល់មូលនិធិក្នុងការសាងសង់អគារនៅតំបន់កំពង់ផែទេ ហើយចង់បញ្ជូនអ្នកធ្វើការរបស់ពួកគេទៅកាន់ដីគោកវិញ ដោយគ្មានការផ្ដល់ភ្លាមៗនូវការរៀបចំការរស់នៅឡើយ—ជម្រើសគឺមានកម្រិត។ លោកវេជ្ជបណ្ឌិត និងលោកស្រីផាកឃើ បានសម្រេចចិត្តផ្លាស់ទៅទីក្រុង នីងប៉ូ ហើយមិត្តរួមការងាររបស់ពួកគាត់បានប្រឈមមុខនៅភាពមិនប្រាកដប្រជាដ៏ធំ។ ដោយមិត្តរបស់គាត់លែងនៅ និងផ្ទះរបស់គាត់ក៏លែងមាន ព្រមទាំងគ្មានកន្លែងស្នាក់នៅទំនេរទាំងជនបរទេស ឬផ្នែកដើមនៃទីក្រុង តើគាត់អាចស្នាក់នៅទីក្រុងសៀងហៃ ដើម្បីបន្តការងាររបស់គាត់ដោយរបៀបណា?

គាត់ពិតជាមានការច្របូកច្របល់យ៉ាងខ្លាំងកាលពីដំបូង ប៉ុន្តែគំនិតថ្មីមួយបានលេចឡើងចេញពីការលំបាកទាំងនេះ។ គាត់បានបរាជ័យក្នុងការស្វែងរកកន្លែងមួយសម្រាប់ជួលធ្វើជាផ្ទះ។  បញ្ហាផ្ទះសម្បែងនៅទីក្រុងសៀងហៃកាន់តែធ្ងន់ធ្ងរដោយមានលំហូរចូលនៃប្រជាជនថ្មី។ ប្រសិនបើគាត់មិនអាចរកផ្ទះមួយខ្នងនៅលើគោកបាន ហេតុអ្វីមិនព្រមរស់នៅលើទឹកដូចជនជាតិចិនជាច្រើននាក់ទៀត? គំនិតនេះស្របគ្នាល្អជាមួយនឹងគម្រោងរបស់គាត់ក្នុងការស្លៀកពាក់សំលៀកបំពាក់ជនជាតិចិន ដើម្បីឲ្យគាត់ធ្វើការបានកាន់តែប្រសើរឡើង។ គ្រប់យ៉ាងបានចាប់ផ្ដើមសមហេតុផលជាងមុនហើយ។ គាត់នឹងយករបស់របរគាត់ទៅកាន់ទីក្រុងនីងប៉ូ នៅពេលដែលគាត់បានទៅជាមួយគ្រួសារលោកវេជ្ជបណ្ឌិត ផាកឃើ ហើយត្រឡប់មកវិញ ដើម្បីចូលរួមយ៉ាងពេញលេញជាមួយប្រជាជនដែលគាត់បានលះបង់សម្រាប់ពួកគេ។

ដំណើររបស់គាត់មិនងាយស្រួលដូចអ្វីដែលគាត់បានគិតនោះទេ។ នៅសម័យនោះ ការស្លៀកសំលៀកបំពាក់ចិនមានន័យថា លោកអ្នកត្រូវតែកោរក្បាលផ្នែកខាងមុខ ហើយទុកសក់ឲ្យវែងមួយជួរដូចជាកន្ទុយសេះ។ គ្មានបេសកជន ឬជនបរទេសណាធ្វើតាមទម្លាប់

នេះទេ។ សម្រាប់ការធ្វើដំណើរម្ដងម្កាល បេសកជន ឬជនបរទេសខ្លះអាចពាក់ឈុតចិន ពីលើសំលៀកបំពាក់ធម្មតា ប៉ុន្តែការបោះបង់ចោលទាំងស្រុងនូវសំលៀកបំពាក់អឺរ៉ុប សម្រាប់ប្រពៃណីជនជាតិដើម គឺជាបញ្ហាមួយផ្សេងទៀត។ លោកគ្រូ ហ័ដសិន ថេល័រ បានដឹងបន្ទាប់ពីចំណាយពេលមួយឆ្នាំកន្លះនៅក្នុងប្រទេសចិនថា ការផ្លាស់ប្តូរបែបនេះ នឹងនាំទៅរកការផ្ដាច់ខ្លួនពីសង្គមបរទេស។ យ៉ាងណាក៏ដោយ គាត់កាន់តែមានជំនឿថា តាមទស្សនៈទូលំទូលាយ វាជារឿងដ៏ឈ្លាសវៃដែលត្រូវធ្វើ ទោះបីជាគាត់បានតស៊ូជាមួយការសម្រេចចិត្តនេះមួយរយៈក៏ដោយ។

គាត់ចង់ឈោងចាប់ប្រជាជនចិន។ ក្នុងការធ្វើដំណើរថ្មីរបស់គាត់ម្នាក់ឯងរយៈពេល ២៥ថ្ងៃ ដែលគាត់បានធ្វើដំណើរ២០០ ម៉ៃល៍ (ប្រហែល៣២១គីឡូម៉ែត្រ) ទៅតាមដងទន្លេយ៉ាងជី បានបង្ហាញគាត់ថា គាត់អាចសម្រេចបានក្នុងការផ្សាយដំណឹងល្អត្រាច់ចរកាន់តែច្រើន លើសជាងមនុស្សភាគច្រើនបានជឿ។ គាត់បានទៅដល់ក្រុង៥៨ ដែលមាន៥១ក្រុងមិនដែលបានប្រទះនឹងដំណឹងល្អពីមុនមកសោះ។ ទោះជាយ៉ាងណាក៏ដោយ ភាពអស់កម្លាំង និងភាពតានតឹងចំពោះការធ្វើដំណើរ ភាគច្រើនកើតពីការស្លៀកសំលៀកបំពាក់អឺរ៉ុប—ជារូបភាពចម្លែកសម្រាប់អស់អ្នកដែលមិនធ្លាប់ឃើញវាពីមុនមក។ រូបរាងរបស់គាត់ជាញឹកញាប់បានបង្វែរអារម្មណ៍បណ្ដាជនចេញពីសាររបស់គាត់ នៅពេលដែលវាហាក់បីដូចជាមិនមានសេចក្តីថ្លៃថ្នូរ និងកំប្លែងចំពោះមហាជនក្នុងស្រុក។ ចុងក្រោយ គាត់បានដឹងថា ការស្លៀកពាក់សមរម្យតាមទស្សនៈជនជាតិចិន គឺជារឿងសំខាន់ជាង ប្រសិនបើគាត់មានបំណងភ្ជាប់ទំនាក់ទំនងជាមួយពួកគេ ជាជាងការរក្សាការអនុញ្ញាតពីសហគមន៍បរទេសនៅកំពង់ផែ។ ក្រោយពីការអធិស្ឋាន និងទទួលបានការដឹកនាំដ៏ច្រើនចេញពីព្រះគម្ពីរ គាត់ក៏បានធ្វើការសម្រេចចិត្ត។ នៅពេលដែលគ្រួសារលោកវេជ្ជបណ្ឌិត ផាកឃើ បានរៀបចំចាកចេញទៅទីក្រុង នីងប៉ូ សំលៀកបំពាក់បែបចិនរបស់លោកគ្រូ ហ័ដសិន ថេល័រ ក៏បានត្រៀមរួចរាល់ផងដែរ ដោយរង់ចាំតែពេលវេលាដ៏សំខាន់ នៅពេលដែលគាត់នឹងអនុញ្ញាតឲ្យជាងកាត់សក់ផ្លាស់ប្តូររូបរាងរបស់គាត់។

គាត់បានទៅទន្លេនៅល្ងាចមួយនៃខែសីហា ដើម្បីរៀបចំទូកសម្រាប់ការធ្វើដំណើរដំបូងរបស់គ្រួសារលោក ផាកឃើ។ នៅអំឡុងការធ្វើដំណើររបស់គាត់ ជនជាតិចិនប្លែកមុខម្នាក់បានចូលមកជិតគាត់ ដោយសួរសំណួរដែលមិននឹកស្មានដល់ថា តើគាត់កំពុងស្វែងរក

ផ្ទះសម្រាប់ជួលមែនទេ។ គាត់បានសួរថា តើផ្ទះតូចមួយខ្នងនៅក្នុងក្រុងនឹងល្មមសម្រាប់គាត់ឬទេ ដោយរម្លឹកថា ផ្ទះមួយខ្នងនៅជិតទ្វារក្រុងខាងត្បូងសង់ជិតរួចហើយ។ តែម្ចាស់ផ្ទះអស់ប្រាក់សាងសង់បន្ត ហើយក៏មិនអាចបង្ហើយការសាងសង់បានដែរ។ ប្រសិនបើផ្ទះសមល្មម  នោះមិនចាំបាច់កក់ប្រាក់ជាមុនទេ ហើយវាប្រហែលជាទំនេរសម្រាប់ការជួលប្រាំមួយខែដោយបង់ថ្លៃជួលជាមុន។

លោកគ្រូ ហ៊ុដសិន ថេល័រ ហាក់បីដូចជានៅក្នុងយល់សប្តិ នៅពេលដែលគាត់បានដើរតាមទៅភាគត្បូងនៃទីក្រុង ហើយបានរកឃើញផ្ទះតូចល្មមដែលស្អាត និងថ្មី មានពីរបន្ទប់នៅខាងលើ ពីរបន្ទប់នៅជាន់ក្រោម ហើយមានបន្ទប់មួយទៀតនៅទល់មុខសួនច្បារសម្រាប់ពួកអ្នកបម្រើ—ជាអ្វីដែលគាត់ពិតជាត្រូវការនៅកន្លែងដែលគាត់ចូលចិត្ត។ រឿងសំខាន់នៅក្នុងការបង់ប្រាក់នៅយប់នោះ គឺដើម្បីការពារផ្ទះមិនឲ្យអ្នកផ្សេងជួលអាចនឹងកាន់តែងាយស្រួលមែជាងពិពណ៌នា។ បន្ទាប់មក គាត់បានដឹងថា គាត់គិតមិនខុសទេ! ការងាររបស់គាត់នៅទីក្រុងសៀងហៃមិនទាន់បានចប់សព្វគ្រប់ទេ។ ព្រះបានឆ្លើយតបការអធិស្ឋានរបស់គាត់ ហើយការដឹកនាំដែលគាត់ប្រាថ្នា និងទន្ទឹងរង់ចាំបានប្រទានមកហើយ។

យប់នោះ គាត់បានធ្វើការសម្រេចដែលបានជះឥទ្ធិពលដ៏សម្បើមនៅការរីករាលដាលនូវជំនឿគ្រីស្ទបរិស័ទនៅក្នុងតំបន់ដីគោកប្រទេសចិន។ បន្ទាប់ពីជាងកាត់សក់បានកាត់សក់រួច បេសកជនវ័យក្មេងបានប្តូរសក់របស់គាត់ទៅជាពណ៌ខ្មៅ ដើម្បីពាក់សក់ក្រងវែងដែលនឹងត្រូវជំនួសសក់គាត់ជាបណ្តោះអាសន្ន។ នៅព្រឹកបន្ទាប់ គាត់បានស្លៀកសំលៀកបំពាក់រលុងដែលមិនធ្លាប់មានឲ្យល្អបំផុតតាមដែលគាត់អាច ហើយនោះគឺជាលើកដំបូងដែលគាត់បានស្លៀកពាក់ឈុតចិន និងស្បែកជើងក្រណាត់រលើបរបស់និស្សិត ឬក៏គ្រូបង្រៀន។

បន្ទាប់ពីនោះ អ្វីគ្រប់យ៉ាងបានឈានដល់កម្រិតថ្មីមួយ។ តាមផ្លូវត្រឡប់ទៅទីក្រុងសៀងហៃវិញ គាត់មើលទៅមិនអាចសម្គាល់ថា ជាជនជាតិបរទេសនោះទេ រហូតដល់គាត់ចាប់ផ្តើមបង្រៀន ចែកសៀវភៅ ឬក៏ព្យាបាលពួកអ្នកជំងឺ ទើបគេស្គាល់ថាជាជនជាតិបរទេស។ បន្ទាប់មក ស្ត្រី និងក្មេងៗបានចូលមកជិតកាន់តែបើកចំហ ហើយមហាជនកាន់តែស្ងប់ចិត្តជាងមុន។ បើទោះបីជា ការខ្វះការគោរពខ្លះដែលជាធម្មតាបង្ហាញដល់

ជនជាតិអឺរ៉ុប សេរីភាពដែលរូបរាងថ្មីបានផ្ដល់លើសពីនេះ ដោយអនុញ្ញាតឲ្យគាត់កាន់តែចុះចំណោមយ៉ាងងាយស្រួលជាមួយអ្នកក្នុងស្រុក។ គាត់ទទួលបានការអនុញ្ញាតឲ្យចូលទៅក្នុងផ្ទះរបស់គេដែលមិនធ្លាប់មានពីមុនមក ហើយអាចចូលរួមនៅសន្ទនាស្ងាត់ៗជាមួយអ្នកដែលបានបង្ហាញការចាប់អារម្មណ៍ផងដែរ។ ដោយដឹងគុណចំពោះប្រយោជន៍ទាំងនេះ គាត់បានសរសេរទៅផ្ទះដោយសរសើរពីសំលៀកបំពាក់ដែលគាត់បានសម្រេបខ្លួនជាមួយ ដោយនិយាយថា៖ «វាច្បាស់ណាស់នឹងក្លាយជាអត្ថប្រយោជន៍ចម្បងរបស់យើងនៅក្នុងតំបន់ដីគោក»។

ចិត្តរបស់គាត់បានពោរឡើងដោយបំណងចង់បាន «តំបន់ខាងក្នុងដែលឆ្ងាយពីសមុទ្រ»។ បន្ទាប់ពីពីរបីសប្ដាហ៍នៅផ្ទះថ្មីគាត់នៅទ្វារក្រុងត្បូង គាត់ទទួលបានបទពិសោធន៍ភាពស្រស់ស្រាយខាងព្រលឹងវិញ្ញាណដែលគួរឲ្យកត់សម្គាល់។

គាត់បានសរសេរសំបុត្រទៅឲ្យលោកវេជ្ជបណ្ឌិត ផាកឃើ ដែលនៅទីក្រុងនីងប៉ូ នៅដើមខែតុលាថា៖ ខ្ញុំក៏មិននៅតែម្នាក់ឯងដែរ។ ខ្ញុំមានអារម្មណ៍ថា ព្រះវត្តមានព្រះគង់នៅជាមួយខ្ញុំច្រើនជាងខ្ញុំធ្លាប់មានអារម្មណ៍ពីមុន ហើយមានអារម្មណ៍ទាញទំនោរខ្លាំងឆ្ពោះទៅកាន់ការអធិស្ឋាន និងការយកចិត្តទុកដាក់ ដែលពិតជាមានព្រះពរ និងចាំបាច់ណាស់។

បើទោះបីជា នៅកន្លែងផ្ទាល់ខ្លួនបានស្វាគមន៍គាត់ ហើយមានឱកាសជាច្រើននៅជុំវិញគាត់ ក៏លោកគ្រូ ហ៍ដសិន ថេល័រ បានធ្វើដំណើរម្ដងទៀតទៅតំបន់ៗដែលមិនធ្លាប់ទៅពីមុន។ គ្រូបង្រៀនជាគ្រីស្ទបរិស័ទរបស់គាត់បានស្នាក់នៅ ដើម្បីថែរក្សាអ្នកជិតខាងដែលចង់ដឹងចង់ឃើញច្រើននៅទីក្រុងសៀងហៃ ខណៈពេលដែលបេសកជនដទៃទៀតបានធ្វើការងារយ៉ាងមានប្រសិទ្ធភាពនៅក្នុងមជ្ឈមណ្ឌលដ៏សំខាន់នោះ។ វាប្រហែលជាមើលទៅមិនមែនជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការធ្វើដំណើរផ្លូវឆ្ងាយ ដើម្បីផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះនោះទេ ប៉ុន្តែវាជាការគ្រាប់តាមការបង្រៀន និងគំរូរបស់ព្រះអម្ចាស់នៅក្នុងការផ្សាយព្រះបន្ទូលព្រះ។ បើគ្មាននរណាម្នាក់ប្រើវិធីសាស្ត្រនេះទេ តើមនុស្សនៅកន្លែងដាច់ស្រយាលនឹងឮ ឬរៀនបានដោយរបៀបណា?

សេចក្ដីអំណរ និងសេចក្ដីទុក្ខព្រួយបានលាយឡំគ្នានៅក្នុងថ្ងៃបន្ទាប់។ គាត់បានជោគជ័យនៅក្នុងការធ្វើដំណើរនេះ ប៉ុន្តែវាក៏បានធ្វើឲ្យគាត់ធ្លាក់ចូលទៅក្នុងបញ្ហាដែរ។ ទិសដៅរបស់គាត់គឺកោះដ៏ធំមួយនៅសុងមីង ដែលមានប្រជាជនចំនួនជាងមួយលាននាក់

ហើយគ្មានបេសកជនប្រូតេស្តង់នៅទីនោះសូម្បីតែម្នាក់។ លោកគ្រូ ហ៉ាដសិន ថេល័រ បានមកសុងមីងជាមួយលោក ប៉័រដឺន កាលពីឆ្នាំមុន ប៉ុន្តែពេលនេះគាត់បានជួបនឹងការទទួលដ៏ខុសពីមុន។ គ្រាន់តែគាត់មកដល់ភ្លាមៗ មនុស្សម្នាចង់ឲ្យគាត់ស្នាក់នៅទីនោះ ដោយសារគាត់ស្លៀកពាក់ដូចពួកគេដែរ នោះគាត់មិនបានមើលទៅដូចជាជនជាតិបរទេសនោះទេ។ ពួកគេចាប់អារម្មណ៍ទាំងថ្នាំនៅខាងក្នុងប្រអប់របស់គាត់ ទាំងការបង្រៀនរបស់គាត់។ ពួកគេបានដឹងថា គាត់ត្រូវការបន្ទប់នៅជាន់លើមួយបន្ទប់ ដើម្បីកុំឲ្យសើម នោះពួកគេបាននិយាយថា៖

«សូមឲ្យគាត់ស្នាក់នៅក្នុងវិហារទៅ បើសិនគ្មានបន្ទប់នៅជាន់លើទំនេរនោះទេ»។

ភ្លាមៗនោះ ម្ចាស់ផ្ទះម្នាក់ដែលមានបន្ទប់ជាន់លើបានលេចមក ហើយក្នុងអំឡុងពេលមកដល់បីថ្ងៃ លោកគ្រូ ហ៉ាដសិន ថេល័រ ជាលើកដំបូងដែលគាត់មានផ្ទះនៅ «ចិនដីគោក»។

ការនេះគឺពិតជាអស្ចារ្យណាស់ ហើយការឆ្លើយតបទៅនឹងសាររបស់គាត់ពិតជាគួរឲ្យចាប់អារម្មណ៍ដូចគ្នា។ អ្នកជិតខាងបានមកស្តាប់ការប្រជុំគ្នាជារៀងរាល់ថ្ងៃ ហើយលំហូរនៃអ្នកមកសួរសុខទុក្ខមានជាបន្តបន្ទាប់ ថែមទាំងអ្នកជំងឺហាក់បីដូចជាគ្មានទីបញ្ចប់។ ប្រាំមួយសប្តាហ៍នៃកិច្ចការដែលពេញដោយអំណរនេះ បានបង្កឲ្យមានការប្រឆាំងខ្លះៗពីសហគមន៍វេជ្ជសាស្ត្រសហគមន៍ ប៉ុន្តែក៏មានការនាំឲ្យមានក្រុមអ្នកចង់ស្គាល់ព្រះបន្ទូលច្បាស់លាស់មួយក្រុមដែរ។ ក្នុងចំណោមពួកគេ មានជាងដែកម្នាក់ឈ្មោះ ចាង និងអ្នកជំនួញមានកេរ្តិ៍ឈ្មោះម្នាក់ ដែលព្រះអម្ចាស់បានប៉ះពាល់ចិត្តពួកគេ។ លោក វ៉ាំ ដែលជាអ្នកប្រែចិត្តជឿដំបូង និងអ្នកបម្រើដែលជាគ្រីស្ទបរិស័ទផ្សេងទៀតបាននៅជាមួយគាត់ ដើម្បីធ្វើឲ្យប្រាកដថា ក្រុមតូចនៅតែមានការចូលរួមបានល្អ នៅពេលដែលលោកគ្រូ ហ៉ាដសិន ថេល័រ ត្រូវត្រឡប់ទៅទីក្រុងសៀងហៃ ដើម្បីរកសម្ភារៈផ្គត់ផ្គង់បន្ថែមទៀត។

បន្ទាប់មក ការខកចិត្តក៏បានកើតឡើង ដែលឈឺចាប់ដោយនឹកស្មានមិនដល់។ គាត់មិនដឹងថា មានឈុតឆាកល្បិចកលបានកើតឡើងនៅសុងមីងឡើយ។ មន្ត្រីជាន់ខ្ពស់ម្នាក់បាន ទទួលអន្ទោកអន្ទោលពីវេជ្ជបណ្ឌិត និង ឱសថការី បានសម្រេចចិត្តកម្ចាត់អ្នកណាដែលគេឃើញថា ជាគូប្រជែងរបស់ពួកគេ បើទោះបីជាបេសកជនវ័យក្មេងនោះមិនដែលយកប្រាក់ពីការព្យាបាលរបស់គាត់ក៏ដោយ។ នៅពេលដែលគាត់បានមកដល់កុងស៊ុល

អង់គ្លេស ពួកគេបានបញ្ជាឲ្យគាត់ចាកចេញពីកោះ ដោយព្រងើយកន្តើយនឹងសំណើស្នាក់នៅទីនោះរបស់គាត់ ដែលជាកន្លែងហាក់បីដូចជាមានសន្តិភាព និងការរាក់ទាក់។ ខាងកុងស៊ុល បានរម្លឹកគាត់ថា តាមសន្ធិសញ្ញាអង់គ្លេស ជនបរទេសត្រូវបានអនុញ្ញាតឲ្យស្នាក់នៅតាមកំពង់ផែតែប៉ុណ្ណោះ ហើយស្នាក់នៅកន្លែងផ្សេងទៀតនឹងត្រូវពិន័យ ៥០០ ដុល្លារ (ប្រហែល $១៩,៣៤៨.៣៩ ដុល្លារ បច្ចុប្បន្ន) គាត់ត្រូវរើផ្ទះ និងទ្រព្យសម្បត្តិរបស់គាត់ទៅទីក្រុងសៀងហៃវិញ ហើយត្រូវប្រយ័ត្នមិនឲ្យល្មើសច្បាប់ម្តងទៀត បើទោះបីជាបូជាចារ្យជនជាតិបារាំងបានរស់នៅក្នុងសុងមីង ក្រោមការការពាររបស់សន្ធិសញ្ញាបន្ថែមក៏ដោយ។ សន្ធិសញ្ញានេះបានបញ្ជាក់ថា អភ័យឯកសិទ្ធិ ដែលបានផ្តល់ទៅជនជាតិដទៃទៀតគួរតែអនុវត្តចំពោះជនជាតិអង់គ្លេសផងដែរ បើតាមដែលលោកគ្រូ ហ័ដសិន ថេល័របានដឹង។ គាត់អាចស្វែងរកបណ្តឹងឧទ្ធរណ៍ខ្ពស់ជាងនេះ ប៉ុន្តែសម្រាប់ពេលនេះគាត់ត្រូវតែស្តាប់តាមការសម្រេចចិត្តរបស់កុងស៊ុល។

គាត់បានសរសេរសំបុត្រដែលខូចចិត្តទៅផ្ទះនៅល្ងាចនោះ ដោយចង់ដឹងអំពីវាសនារបស់ពួកអ្នកចង់ស្គាល់ព្រះបន្ទូលវ័យក្មេងមានលោកចាង លោកសុង និងអ្នកផ្សេងទៀត។ តើពួកគេមិនដូចជាកូនបង្កើតរបស់គាត់ក្នុងសេចក្តីជំនឿទេមែនទេ? តើឲ្យគាត់បោះបង់ចោលពួកគេដោយគ្មានជំនួយ និងមានការយល់ដឹងតិចតួចអំពីផ្លូវរបស់ព្រះជាម្ចាស់បានដោយរបៀបណាទៅ? យ៉ាងណាក៏ព្រះជាម្ចាស់បានអនុញ្ញាតឲ្យការនេះបានកើតឡើងដែរ។ កិច្ចការទាំងនេះជារបស់ទ្រង់ ហើយព្រះអង្គក៏មិនធ្វើឲ្យគេបរាជ័យ ឬក៏មិនបោះបង់ពួកគេដែរ។

ជាងដែកបាននិយាយនៅល្ងាចចុងក្រោយដែលពួកគេជួបគ្នាថា៖ «ខ្ញុំពិតជាសោកស្តាយណាស់ នៅពេលដែលខ្ញុំមិនអាចចូលរួមប្រជុំគ្នាជាមួយអ្នករាល់គ្នាទៀតទេ»។

មិត្តសម្លាញ់របស់គាត់បានឆ្លើយថា៖ «ឯងនឹងថ្វាយបង្គំព្រះនៅផ្ទះ។ សូមបិទហាងរបស់ឯងនៅថ្ងៃអាទិត្យ ព្រោះព្រះជាម្ចាស់មានព្រះវត្តមាននៅទីនេះ មិនថាខ្ញុំនៅឬអត់ទេ។ សូមរកនរណាម្នាក់ ដើម្បីអានព្រះបន្ទូលឲ្យឯងស្តាប់ ហើយសូមអញ្ជើញអ្នកជិតខាងរបស់ឯងមកស្តាប់ព្រះបន្ទូលដែរ»។

លោកសុង បាននិយាយថា៖ «ខ្ញុំគ្រាន់តែដឹងបន្តិចបន្តួចប៉ុណ្ណោះ ហើយនៅពេលដែលខ្ញុំអាន ខ្ញុំមិនចេះអក្សរគ្រប់តួទេ។ ខ្ញុំមានទុក្ខព្រួយយ៉ាងខ្លាំង ដែលឯងត្រូវតែចាកចេញពី

ពួកយើង ប៉ុន្តែខ្ញុំអរគុណព្រះ ដែលទ្រង់បាននាំឯងមកទីនេះ។ ដែលអំពើបាបដ៏ធ្ងន់ទាំងអស់របស់ខ្ញុំបានផ្ទេរទៅលើព្រះយេស៊ូវ ហើយទ្រង់ក៏បានប្រទានខ្ញុំនូវសេចក្ដីអំណរ និងសេចក្ដីសុខសាន្តជារៀងរាល់ថ្ងៃដែរ»។

ដោយមានការជឿងឆ្ងល់ និងខកចិត្ត បេសកជនវ័យក្មេង អាចត្រឹមតែរង់ចាំការដឹកនាំរបស់ព្រះជាម្ចាស់ទាក់ទងទៅនឹងជំហានបន្ទាប់របស់គាត់។

គាត់បានសរសេរទៅកាន់ឪពុកម្ដាយរបស់គាត់ថា៖ «សូមអធិស្ឋានសម្រាប់កូនផង។ កូនត្រូវការព្រះគុណបន្ថែមទៀត ហើយកូនក៏មិនទាន់បំពេញសក្ដានុពលរបស់កូនទេ។ អូហ៎ ដើម្បីឲ្យកូនមានអារម្មណ៍ដូចជាអ្វីព្រះអម្ចាស់យេស៊ូវគ្រីស្ទបានធ្វើ នៅពេលដែលទ្រង់មានព្រះបន្ទូលថា៖ «ខ្ញុំស៊ូប្ដូរជីវិតខ្ញុំនឹងចៀមខ្ញុំ»។ កូនមិនចង់ធ្វើដូចជាអ្នកស៊ីឈ្នួលដែលរត់ចេញពេលឃើញគ្រោះថ្នាក់ ក៏មិនចង់ស្វែងរកគ្រោះថ្នាក់ដោយមិនប្រយ័ត្នប្រយែងនោះឡើយ នៅពេលដែលកូនអាចសម្រេចបានការងារជាច្រើនដោយមានសុវត្ថិភាព។ កូនចង់ស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ហើយមានភាពក្លាហានក្នុងការធ្វើវា បើទោះបីជាត្រូវចាកចេញពីប្រទេសរបស់កូនក៏ដោយ។ «ឥឡូវនេះ ខ្ញុំមានចិត្តតប់ប្រមល់ តើត្រូវឲ្យខ្ញុំទូលដូចម្ដេច? ឱព្រះវរបិតាអើយ សូមតម្កើងព្រះនាមទ្រង់ឡើង» (យ៉ូហាន ១២:២៧, ២៨)។ សូមអធិស្ឋានសម្រាប់កូនផង ដើម្បីឲ្យកូនអាចប្រតិបត្តិតាមព្រះគ្រីស្ទនៅក្នុងសេចក្ដីពិតមិនគ្រាន់តែមាត់ ប៉ុន្តែថែមទាំងទង្វើផងដែរ។

ដោយមិនដឹងពីដួងចិត្តដែលតប់ប្រមល់ នោះមានមនុស្សម្នាក់ទៀតដែលខ្លាំងជាងជ្រាលជ្រៅជាង ហើយមានបទពិសោធន៍ជាងក្នុងរបៀបរបស់ព្រះជាម្ចាស់ ហើយបានជួបបញ្ហាដូចគ្នា។ បុរសម្នាក់នេះ ថែមទាំងព្រួយបារម្ភចំពោះមនុស្សរាប់លាននាក់វិនាសនៅចិនដីគោក។ គាត់បានដកពិសោធន៍នឹងការផ្សាយដំណឹងល្អតាមការធ្វើដំណើរ ហើយបានរកឃើញឱកាសដែលអាចនាំមកនូវជោគជ័យសម្រាប់កិច្ចការនេះ។ បើទោះបីជាមិនអាចទៅដល់ទីក្រុងណានគីង ហើយត្រូវបង្ខំឲ្យរស់នៅលើទូក ព្រមទាំងត្រឡប់ទៅឆ្នេរយ៉ាងយឺតៗ លោក វីលលៀម ប៊ើនស៍ (William Burns) ដែលជាគ្រូគង្វាល និងអ្នកផ្សាយដំណឹងល្អ ដែលព្រះជាម្ចាស់បានប្រើគួរឲ្យកត់សម្គាល់អំឡុងពេលនៃការរីកផុលផុសខាងឯវិញ្ញាណនៅឆ្នាំ ១៨៣៩ នៅក្នុងប្រទេសស្កុតឡែន និងកាណាដា បានចូលមកជិតទីក្រុងសៀងហៃ។ ទីនេះហើយដែលគាត់បានជួបលោកគ្រូ ហ៉ដសិន ថេល័រ

ក្នុងពេលដែលគាត់ត្រូវការជំនួយ។ មិនយូរប៉ុន្មាន ពួកគាត់បានស្គាល់ពីដួងចិត្តគ្នាទៅវិញទៅមក ទោះបីជាអាយុពួកគាត់ខុសគ្នាច្រើនក៏ដោយ។ ដូចជាសាវ័ក ប៉ុល និងសាវ័កធីម៉ូថេ ដែលពួកគាត់កាន់តែមានភាពស្និទ្ធស្នាលគ្នា ហើយពេលវេលានៅរដូវរងានោះបានរាប់ជាការចាប់ផ្ដើមនៃមិត្តភាព ដែលមិនត្រឹមតែតម្រង់ជីវិតជាបេសកជនរបស់លោកគ្រូ ហ័ដសិន ថេល័រ នោះទេ ប៉ុន្តែក៏បានបង្កើតចរិតលក្ខណៈនៃភាពសំខាន់របស់បេសកកម្ម ដែលនឹងលាតត្រដាងនៅក្រោមការដឹកនាំរបស់គាត់។

ពេលនេះ ទូកពីរបានធ្វើដំណើរជាមួយគ្នាតាមផ្លូវទឹកពីទីក្រុងសៀងហៃទៅកាន់ដីគោក។ បេសកជនម្នាក់ៗធ្វើដំណើរអមជាមួយបេសកជនជនជាតិចិនម្នាក់ និងអ្នកជួយម្នាក់ ហើយពួកគេបានធ្វើការថ្វាយបង្គំជាប្រចាំថ្ងៃនៅលើទូក ដោយប្រែវាឲ្យទៅជាការថ្វាយបង្គំតូចមួយ។ លោក ប៊ើនស៍ បានអភិវឌ្ឍន៍វិធីសាស្ត្ររបស់គាត់ផ្ទាល់ទៅលើកិច្ចការនេះ ដែលមិត្តរបស់គាត់បានសម្របនឹងវាដោយរីករាយ។ ពួកគាត់បានជ្រើសយកមជ្ឈមណ្ឌលមួយ ហើយស្នាក់នៅទីនោះពីរ ឬបីសប្ដាហ៍។ រាល់ព្រឹក ពួកគាត់បានចាកចេញពីព្រលឹមដោយមានគម្រោងមួយច្បាស់លាស់ ពេលខ្លះការធ្វើការជាមួយគ្នា ហើយពេលខ្លះទៀតក៏ត្រូវចេញទៅតំបន់ផ្សេងៗរៀងៗខ្លួន។ លោក ប៊ើនស៍ មានចំណង់ចំណូលចិត្តថាការចាប់ផ្ដើមដោយស្ងាត់ៗនៅជាយក្រុង ដែលមានជនជាតិបរទេសកម្របានរកឃើញ ហើយបន្ទាប់មកចាប់ផ្ដើមរំកិលឆ្ពោះទៅកាន់តំបន់នានាៗដែលកាន់តែអ៊ូអរ។ ពួកគាត់បានចំណាយពេលបីបួនថ្ងៃបង្រៀននៅតំបន់ជាយក្រុង ដោយរំកិលបន្តិចម្ដងឆ្ពោះទៅកាន់ផ្លូវនានា និងទីផ្សារដែលមានមនុស្សកុះករ រហូតដល់ពួកគាត់អាចដើរគ្រប់ទីកន្លែងដោយមិនធ្វើឲ្យម្ចាស់ហាងក្នុងស្រុកមិនសប្បាយចិត្ត ឬធ្វើឲ្យខូចទំនិញរបស់ពួកគេឡើយ។ បន្ទាប់មក ពួកគាត់នឹងទៅតាមវិហារ សាលារៀន និងហាងទាំងឡាយដោយត្រឡប់មកវិញយ៉ាងទៀងទាត់ ដើម្បីរកកន្លែងល្អដ៏បំផុតក្នុងការអធិប្បាយ។ ដោយប្រកាសប្រាប់ពួកគេអំពីការត្រឡប់មកវិញលើកក្រោយរបស់ពួកគាត់នៅគ្រប់ការប្រជុំគ្នានីមួយៗ ជាញឹកញាប់ ពួកគេបានឃើញមនុស្សដដែលៗ ហើយបានអញ្ជើញអ្នកស្ដាប់ដែលចាប់អារម្មណ៍ត្រឡប់ទៅកាន់ទូក ដើម្បីពិភាក្សាគ្នាបន្ថែមទៀត។

ពេលវេលាកន្លងផុតទៅ លោក ប៊ើនស៍ បានកត់សម្គាល់ឃើញថា បើទោះបីជា លោកគ្រូ ហ័ដសិន ថេល័រ នៅក្មេងជាង ហើយមានបទពិសោធន៍តិចជាងក៏ដោយ ក៏គាត់បាន

ទាក់ទាញអ្នកស្ដាប់ដែលយកចិត្តទុកដាក់កាន់តែច្រើន ហើយពួកគេក៏បានអញ្ជើញ លោកគ្រូ ហ៉ាដសិន ចូលផ្ទះពួកគេផងដែរ ខណៈពេលដែលគាត់ត្រូវបានគេស្នើសុំឲ្យរង់ចាំនៅខាងក្រៅ។ ហ្វូងមនុស្សឆ្គុងឆាំងឡូឡាតែងតែប្រមូលផ្ដុំគ្នានៅជុំវិញគ្រូអធិប្បាយដែលពាក់សំលៀកបំពាក់បរទេស ចំណែកអ្នកដែលចង់ស្ដាប់ដោយគ្មានការរំខាន បានដើរតាមសម្លាញ់ដែលមិនសូវមានគេកត់សម្គាល់នោះ។ លោក ប៊ើនស៍ ចែករំលែកលទ្ធផលនៅក្នុងសំបុត្រដូចខាងក្រោម៖

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៨៥៦

ថ្ងៃនេះ ជាថ្ងៃទី៤១ហើយ តាំងពីខ្ញុំបានចាកចេញពីទីក្រុងសៀងហៃក្នុងការធ្វើដំណើរនាពេលថ្មីៗនេះ។ ខ្ញុំកំពុងតែធ្វើដំណើរជាមួយបេសកជនដ៏ប្រសើរជនជាតិអង់គ្លេសម្នាក់មានឈ្មោះថា ហ៉ាដសិន មកពីសមាគមន៍ផ្សាយដំណឹងល្អចិន។ យើងបានទទួលសេចក្ដីសប្បុរសដ៏ច្រើន ហើយនៅពេលខ្លះជំនួយដ៏សំខាន់បានជួយយើងនៅក្នុងកិច្ចការដែលយើងបានធ្វើ។

ខ្ញុំត្រូវតែប្រាប់រឿងរ៉ាវម្ដងទៀត ដែលជារឿងរ៉ាវដែលខ្ញុំបានប្រាប់ពីរបីដងរួចមកហើយ។ កាលពីបួនសប្ដាហ៍មុន នៅថ្ងៃទី ២៩ ខែ ធ្នូ ខ្ញុំបានស្លៀកសំលៀកបំពាក់ចិន ដែលខ្ញុំកំពុងតែស្លៀកនាពេលថ្មីៗនេះ។ លោក ហ៉ាដសិន បានធ្វើការផ្លាស់ប្ដូរនេះប៉ុន្មានខែមុន ហើយខ្ញុំសម្គាល់ឃើញថា គាត់បានជួបការរំខានកាន់តែតិចទៅៗពីពួកបណ្ដាជន នៅពេលដែលគាត់កំពុងបង្រៀន។ ហេតុដូច្នេះហើយ ខ្ញុំបានសម្រេចចិត្តថា ការផ្លាស់ប្ដូរនេះគឺជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការធ្វើតាមគំរូរបស់គាត់។

ទោះបីវានឹងលំបាកសម្រាប់នរណាម្នាក់នៅក្នុងការបង្កើតកន្លែងជាក់លាក់មួយនៅក្នុងពេលនេះ យើងមានវាលចម្រូតធំណាស់នៅក្នុងតំបន់នេះ។ មនុស្សម្នាស្ដាប់ដោយយកចិត្តទុកដាក់ ប៉ុន្តែយើងក៏ត្រូវការអំណាចមកពីព្រះជាម្ចាស់ដែរនៅក្នុងការបញ្ចុះបញ្ចូល និងផ្លាស់ប្ដូរពួកគេ។ តើអ្នកគ្រប់គ្នានៅ ឃីលស៊ីធ បានអធិស្ឋានឲ្យពួកយើងដែរទេ?  ឬក៏អ្នកគ្រប់គ្នាកំពុងតែព្យាយាមស្វែងរកឆន្ទៈនោះដើម្បីអធិស្ឋានមែនទេ? សេចក្ដីត្រូវការ គឺពិតជាបន្ទាន់ណាស់ ហើយមានហេតុផល និងកម្លាំងជំរុញចិត្តខ្លាំង ដើម្បីអធិស្ឋានក្នុងស្ថានភាពនេះ! ចម្រូត គឺពិតជាធំណាស់នៅទីនេះ ហើយមិនមានអ្នកចម្រូតច្រើនទេ ពួកគេក៏មិនបានត្រៀមខ្លួនបានល្អដែរ ហើយថែមទាំងខ្វះខាតខាងព្រះគុណ ដែលត្រូវការសម្រាប់

ធ្វើកិច្ចការនេះទៀតផង។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះគុណអាចឲ្យឧបករណ៍ខ្សោយមួយចំនួនសម្រេចបានរឿងរ៉ាវដ៏អស្ចារ្យ ដែលធំជាងអ្វីដែលយើងអាចស្រមៃបានដែរ។

ជីវិតរបស់លោកគ្រូ វីលៀម បើនស៍ បាននៅវិលវល់ជុំវិញការអធិស្ឋាន ហើយគាត់បានចម្អែតដោយព្រះបន្ទូលព្រះជារៀងរាល់ថ្ងៃ។

នៅក្នុងកំណត់ត្រាជីវប្រវត្តិរបស់គាត់បានសរសេរថា  គាត់គឺបុគ្គលម្នាក់ដែលមានចំណេះដឹងខាងព្រះបន្ទូល ហើយការបង្រៀនដ៏មានអំណាចបំផុតរបស់គាត់បានមកអំពីរបៀប ដែលគាត់បានអនុវត្តន៍ "ដាវរបស់ព្រះវិញ្ញាណ" ទៅកាន់បញ្ញាចិត្ត និងដួងចិត្តរបស់មនុស្ស។ ពេលខ្លះ ការអំពាវនាវដ៏ស្មោះត្រង់របស់គាត់ វាហាក់បីដូចជាការស្ដាប់នូវជំពូកថ្មីនៃព្រះគម្ពីរដែលបានលើកឡើងដោយហោរាដែលនៅរស់អញ្ចឹង។ ពេញមួយជីវិតរបស់គាត់ គឺពិតជាបានលះបង់ចំពោះការអធិស្ឋាន ហើយព័ន្ធកិច្ចរបស់គាត់មានពេញទៅដោយការតយុទ្ធជាបន្តបន្ទាប់នៅក្នុងការអធិស្ឋានដែរ។ នៅក្នុងការសិក្សាព្រះបន្ទូលរបស់គាត់ ជួនកាលគាត់បានរកឃើញចំណេះដឹងព្រះគម្ពីរដ៏មានតម្លៃជាច្រើន ដែលបានក្លាយជាផ្នែកដ៏នៅយូរអង្វែងនៃសម្បត្តិខាងព្រលឹងវិញ្ញាណរបស់នរណាម្នាក់។

ចរិតលក្ខណៈថ្លៃថ្នូរ មានមន្តស្នេហ៍ និងប្រកបដោយប្រាជ្ញា ធ្វើឲ្យគាត់ក្លាយជាគូកនដ៏សក្តិសម។ គាត់ចូលចិត្តតន្ត្រីថ្វាយបង្គំ។ រឿងនិទានខ្លីៗជាច្រើនរបស់គាត់បានបន្ថែមភាពស្រស់ស្អាតដល់គូកនរបស់គាត់ ហើយគាត់បានចែករំលែកនូវបទពិសោធន៍របស់គាត់ដោយសប្បុរស ដើម្បីជាប្រយោជន៍អ្នកដទៃដែរ។ ដោយពេញមួយជីវិត និងប្រវត្តិរបស់គាត់ មិត្តភាពរបស់បុរសរូបនេះ គឺជាអំណោយទានមកពីព្រះជាម្ចាស់ ហើយជាព្រះពរដល់លោកគ្រូ ហ័ដសិន ថេល័រ យ៉ាងខ្លាំងនៅពេលនោះ។ នៅក្រោមឥទ្ធិពលពីគាត់ លោកគ្រូ ហ័ដសិន បានចម្រើនឡើង និងពង្រីកការយល់តម្លៃខាងព្រលឹងវិញ្ញាណដែលប៉ះពាល់យ៉ាងជ្រាលជ្រៅពេញមួយជីវិតរបស់គាត់។ លោកគ្រូ វីលលៀម បើនស៍ គឺមានប្រយោជន៍ច្រើនសម្រាប់គាត់លើសពីការចូលរៀននៅសាកលវិទ្យាល័យដែលមានប្រយោជន៍ទាំងអស់ ពីព្រោះគាត់បានបង្ហាញការពិតជាក់ស្ដែងគ្រប់យ៉ាង ដែលលោកគ្រូ ហ័ដសិន ថេល័រ ត្រូវរៀន និងត្រូវក្លាយខ្លួននៅក្នុងប្រទេសចិនតែម្ដង។

ពួកគាត់បានធ្វើការជាមួយគ្នាយ៉ាងរីករាយអស់រយៈពេលប្រាំពីរខែ ដោយចាប់ផ្ដើមពីតំបន់ក្នុងក្រុងសៀងហៃ បន្ទាប់មកធ្វើដំណើរឆ្ពោះទៅនៅជុំវិញទីក្រុង សាចូវ ដ៏ធំ។ ពួក

គាត់បានទទួលការត្រាស់ហៅដោយគ្មានការព្រៀងទុកទៅកាន់កំពង់ផែភាគខាងត្បូងនេះ ហើយទទួលបានឯកសិទ្ធិក្នុងការធ្វើជាបេសកជននៅតំបន់ដែលដ៏លំបាក ប៉ុន្តែឥឡូវបានបង្កើតផលផ្លែ។ ការស្លៀកសំលៀកបំពាក់ចិនគឺមានសារៈសំខាន់ណាស់ក្នុងការរស់នៅទីក្រុងជនជាតិដើម ហើយបានបង្កើតមិត្តភក្តិជាមួយអ្នកជិតខាងដែលមានការឆុងឆាំង។ បួនខែក្រោយមក ដោយសារភាពជោគជ័យក្នុងកិច្ចការខាងវេជ្ជសាស្ត្រ ព្រមទាំងបានយកឈ្នះលើឧបសគ្គដំបូងៗរបស់ពួកគាត់ ពួកគាត់អាចជួលអគារទាំងមូល ដែលកាលពីដំបូងពួកគាត់បានជួលត្រឹមតែមួយបន្ទប់ប៉ុណ្ណោះ។

ក្រោយមក ដោយមានការស្នើសុំពីលោកគ្រូ ប៉ើនស៍ មិត្តសម្លាញ់វ័យក្មេងរបស់គាត់បានយល់ព្រមត្រឡប់ទៅទីក្រុងសៀងហៃវិញ ដើម្បីយកសម្ភារៈពេទ្យរបស់គាត់ ដែលគាត់បានទុកនៅទីនោះដើម្បីរក្សាសុវត្ថិភាព។ លោកគ្រូ ហ័ដសិន ថេល័រ មានការស្ទាក់ស្ទើរនៅក្នុងការចាកចេញ ព្រោះគាត់មានអារម្មណ៍ថា ដូចជាការបែកគ្នាដ៏យូរកំពុងតែលេចហើយ ថែមទាំងធ្វើឲ្យគាត់មានការទុក្ខព្រួយចំពោះការទុកឲ្យលោកគ្រូ ប៉ើនស៍ នៅតែម្នាក់ឯង ដើម្បីទ្រាំទ្រនឹងកំដៅដ៏ក្តៅបំផុតនៅក្នុងរដូវក្តៅ ដូចជាវានឹងបញ្ចប់ភាពជាដៃគូរបស់ពួកគាត់ ដែលពិតមានសារៈសំខាន់នៅក្នុងជីវិតរបស់គាត់អញ្ចឹង។

ខ្ញុំចងចាំយ៉ាងច្បាស់នូវប៉ុន្មានខែយ៉ាងរីករាយនោះថា ជាសេចក្តីអំណរ និងសេចក្តីសុខសាន្តដែលមិនអាចថ្លែងបាន។ ខ្ញុំមិនដែលមានឪពុកខាងសេចក្តីជំនឿដូចលោកគ្រូ ប៉ើនស៍ នោះឡើយ ហើយខ្ញុំក៏មិនដែលធ្លាប់មានគូកនដែលបរិសុទ្ធ និងពេញដោយអំណរបែបនេះឡើយ។ សេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះបន្ទូលគឺជាសេចក្តីអំណរ និងជីវិតបរិសុទ្ធ ហើយគោរពកោតខ្លាចដល់ព្រះជាម្ចាស់ ព្រមទាំងការទាក់ទងនឹងព្រះជាម្ចាស់ដែលឥតឈប់ឈររបស់គាត់បានបំពេញសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅនៃដួងចិត្តរបស់ខ្ញុំ។

ថ្នាំ និងឧបករណ៍ពេទ្យពិតជាចាំបាច់ណាស់ ព្រោះលោកគ្រូ ប៉ើនស៍ មានការឆេះឆួលក្នុងការងារមន្ទីរពេទ្យជាន់ខ្ពស់ជាខ្លាំង។ ហេតុដូច្នេះហើយ លោកគ្រូ ហ័ដសិន ថេល័រ ក៏បានចេញដំណើរតាមទូកទៅទីក្រុងសៀងហៃ ប៉ុន្តែការមកដល់ធ្វើឲ្យគាត់ដឹងថា សម្ភារៈបរិក្ខារពេទ្យរបស់គាត់ត្រូវបានបំផ្លាញដោយសារភ្លើងដោយចៃដន្យ។ មុនពេលគាត់អាចទទួលបានសម្ភារៈថ្មី គាត់ទទួលដំណឹងដ៏ក្រៀមក្រំ ដែលមិត្តសម្លាញ់ និងជាទីគោរពរបស់គាត់ត្រូវបានអាជ្ញាធរចិនចាប់ខ្លួន និងអមដំណើរនៅក្នុងការធ្វើដំណើរសាមសិបមួយថ្ងៃ

របស់គាត់ទៅទីក្រុងកានតុន។ ដំណឹងនោះបានបណ្ដាលឲ្យគាត់មានភាពតក់ស្លុត និងការឈឺចាប់ ជាពិសេសដោយសារតែពួកគេត្រូវបានហាមមិនឲ្យត្រឡប់ទៅទីក្រុង សាតូវិញទេ ហើយផ្លូវដែលហាក់ដូចជាមានភាពជាក់ច្បាស់ ឥឡូវត្រូវបានវង្វេងដោយភាពមិនពិតប្រាកដប្រជាទៅវិញ។

ប៉ុន្តែបើគ្មានការល្បងលដ៏ធំនឹកស្មានមិនដល់នេះ លោកគ្រូ ហ័ដសិន ថេល័រ នឹងមិនអាចរកឃើញកិច្ចការពេញមួយជីវិតដែលរង់ចាំគាត់បានទេ។ គាត់ប្រហែលជាមិនអាចទទួលបាននៃសេចក្ដីស្រឡាញ់លើសពីសេចក្ដីស្រឡាញ់របស់មនុស្សឯទៀតឡើយ ដែលបានក្លាយជាសេចក្ដីអំណរ និងព្រះពរដ៏ធំបំផុតរបស់គាត់។

ជំពូកទី៧

# មាគ៌ានៃព្រះជាម្ចាស់ «គ្រប់លក្ខណ៍»

*ឱព្រះអម្ចាស់អើយ យើងសូមអរព្រះគុណព្រះអង្គ សម្រាប់ថ្ងៃនានានៃដំណើរទៅរកព្រះអង្គ នៅពេលដែលប្រភពទឹកវាលខ្សាច់ស្ងួត ហើយពួកយើងក៏បានយល់ជាលើកដំបូងពីជម្រៅនៃសេចក្តីស្រឡាញ់ដែលអាចបំពេញតម្រូវការរបស់យើង។*

បញ្ហាដែលទាក់ទងនឹងនយោបាយដែលកំពុងកើតឡើង ហើយសំបុត្រដដែលបានពាំនាំដំណឹងពីការចាប់ខ្លួនលោកគ្រូ ប៊ើនស៍ ក៏បានប្រកាសពីការចាប់ផ្តើមនៃការប្រយុទ្ធគ្នារវាងប្រទេសអង់គ្លេស និងប្រទេសចិនផងដែរ។ ពេលដែលលោកគ្រូ ហ៉ដសិន ថេល័រ នៅក្នុងទីក្រុងនីងប៉ូ គាត់បានដឹងអំពីការដែលកងទ័ពអង់គ្លេសបានទម្លាក់គ្រាប់បែកនៅក្រុងកានតុន (Canton) សង្គ្រាមក៏បានចាប់ផ្តើមឡើង ហើយក៏អូសបន្លាយបន្តអស់រយៈពេលបួនឆ្នាំ។ ដំបូងគាត់ព្រួយបារម្ភដល់លោកគ្រូ ប៊ើនស៍ តែគាត់ក៏ធូរទ្រូងឡើងវិញដែលលោកគ្រូ ប៊ើនស៍ មិនបាននៅក្នុងក្រុងសាតូវ (Swatow) ទៀតទេ ព្រោះនៅទីនោះលោកគ្រូ ប៊ើនស៍ អាចនឹងត្រូវប្រឈមជាមួយក្រុមមនុស្សដែលពេញដោយកំហឹងនៅភាគខាងត្បូង។

គាត់បានសរសេរផ្ញើរទៅប្អូនស្រីរបស់គាត់នៅខែវិច្ឆិកាថា គាត់ត្រូវឃាត់ខ្លួននៅទីក្រុង

នីងប៉ូ ដោយសារស្ថានភាពផ្សេងៗ ហើយពេលនេះ ការរំខាននៅភាគខាងត្បូងបានក្លាយជាហេតុផលល្អគ្រប់គ្រាន់សម្រាប់គាត់ក្នុងការស្នាក់នៅទីនោះ។ គាត់បានចែករំលែកព័ត៌មានថ្មីៗថា ទីក្រុងកានតុនត្រូវរងការទម្លាក់គ្រាប់បែកអស់រយៈពេលពីរថ្ងៃ ដែលបណ្ដាលឲ្យមានប្រហោងនៅក្នុងជញ្ជាំងទីក្រុងនៅថ្ងៃទីពីរ ដែលនាំឲ្យកងទ័ពជនជាតិអង់គ្លេសចូលទៅក្នុងក្រុងវិញ បន្ទាប់ពីលោកឧបរាជចិនបានបដិសេធនៅក្នុងការធ្វើតាមការទាមទាររបស់ពួកគេ។ ពួកយើងរង់ចាំដំណឹងច្បាស់បន្ថែមយ៉ាងអន្ទះសា។ ខ្ញុំមិនប្រាកដអំពីគុណសម្បត្តិនៃ សកម្មភាពថ្មីនេះឡើយ ដូចនេះគាត់បានសម្រេចចិត្តថា នឹងមិនបញ្ចេញយោបល់អ្វីទេ។ ទោះជាយ៉ាងណា ខ្ញុំបានសម្គាល់ពីសេចក្ដីល្អរបស់ព្រះជាម្ចាស់នៅក្នុងការបញ្ជូនលោកគ្រូ បើនស៍ ចេញពីទីក្រុងសាតូវទាន់ពេលវេលា និងដោយសុវត្ថិភាព។ ដោយសារការវាយប្រហាររបស់កងទ័ពអង់គ្លេស នោះជនបរទេសនឹងត្រូវរងទុក្ខជាមិនខាន បើគេនៅក្នុងកណ្ដាប់ដៃរបស់ជនជាតិកៅតុងនៅទីក្រុងសាតូវ។

ដូច្នេះ ហេតុការណ៍ដែលហាក់បីដូចជាសោកនាដកម្មដ៏ធំ មិនយូរមិនឆាប់នឹងត្រូវបានទទួលស្គាល់ថា វាជាផ្នែកនៃ «គ្រប់ការទាំងអស់» ជាប្រយោជន៍ដល់ «អស់អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់»។ វាជាមេរៀនដ៏លំបាកមួយក្នុងចំណោមមេរៀនដ៏លំបាកៗជាច្រើនទៀត តាមរយៈអ្វីដែលលោកគ្រូ ហ័ដសិន ថេល័រ បានរៀននៅក្នុងការយល់ឃើញថា ព្រះជាម្ចាស់គ្រប់គ្រងលើគ្រប់កាលៈទេសៈនៅក្នុងជីវិត ព្រមទាំងមានកត្តាខាងក្រៅផ្សេងៗទៀតដូចជា សេចក្ដីសប្បុរសដ៏អស្ចារ្យ ប្រាជ្ញាដ៏ឈ្លាសវៃ និងអ្វីៗដែលប្រសើរបំផុតក៏នឹងកើតឡើង ដោយការរៀបចំ ឬការអនុញ្ញាតពីទ្រង់។ មិនយូរប៉ុន្មានគាត់បានដឹងថាការស្នាក់នៅទីក្រុងនីងប៉ូ ជាសញ្ញាគួរឲ្យកត់សម្គាល់ផ្សេងទៀតពីសេចក្ដីស្រឡាញ់ និងការយកព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់ ដើម្បីនាំគាត់ចូលទៅក្នុងទំនាក់ទំនងជាមួយនឹងស្ត្រីម្នាក់ ដែលជាអ្នកបំពេញជីវិតរបស់គាត់យ៉ាងល្អឥតខ្ចោះ ។

នៅភាគខាងត្បូងនៃទីក្រុង នៅក្បែរវត្តចាស់មានផ្លូវដ៏ស្ងាត់មួយនៅចន្លោះបឹងពីរដែលហៅថា ផ្លូវស្ពាន (Bridge Street)។ លោកវេជ្ជបណ្ឌិត ផាកខ័រ បានបើកឱសថស្ថានមួយនៅជិតមន្ទីរពេទ្យរបស់គាត់ ហើយនៅពេលដែលរដូវលំហើយជិតចូលមកដល់ លោកគ្រូ ហ័ដសិន ថេល័រ រីករាយដោយមានផ្ទះស្នាក់បណ្ដោះអាសន្ននៅទីនោះ។ កន្លែងតូចនេះជាកន្លែងដែលគួរឲ្យចាប់អារម្មណ៍ ព្រោះក្រោយមកវាបានក្លាយជាទីស្នាក់ការដំបូង

នៃអង្គការបេសកកម្មនៅចិនដីគោក ដែលបច្ចុប្បន្នមានដំណើរការពីរាប់រយកន្លែងនៅក្នុងខេត្តជាច្រើន។ លោកគ្រូ ហ៍ដសិន បានសរសេរការឆ្លុះបញ្ចាំងពីថ្ងៃដំបូងនោះថា៖

«ខ្ញុំចាំយ៉ាងច្បាស់អំពីការចារឈ្មោះជាអក្សរកាត់របស់ខ្ញុំនៅលើព្រិល ដែលបានប្រមូលលើកម្រាលដេករបស់ខ្ញុំពេញមួយយប់នៅក្នុងបន្ទប់ធំនៅជាន់លើ ដែលឥឡូវបានបែងចែកជាបួន ឬប្រាំបន្ទប់តូចៗជាងមុន ដែលមានភាពកក់ក្តៅ និងមានពិដាន។ គ្រឿងផ្ទះចិនប្រហែលជាអាចទប់ទឹកភ្លៀង បើសិនវាមិនធ្លុះធ្លាយ ប៉ុន្តែវាមិនអាចមានប្រសិទ្ធភាពនៅក្នុងការការពារព្រិល ដែលអាចជ្រៀតតាមប្រហោងនានា ហើយចូលមកក្នុងបានទេ។ បើទោះបីជាមិនមានគ្រឿងសង្ហារិមសព្វគ្រប់ក្តី ក៏ផ្ទះតូចនេះល្អសម្រាប់ធ្វើការងារជាមួយនឹងមនុស្សម្នាទាំងឡាយ ហើយខ្ញុំរីករាយនឹងរើចូលស្នាក់នៅ ដ្បិតមានឱកាសច្រើននៅក្នុងការបម្រើទាំងយប់ទាំងថ្ងៃ»។

ជនជាតិបរទេសដទៃទៀតនៅតំបន់នោះ លោក និងលោកស្រី ជេ. ចូនស៍ (Mr. and Mrs. J. Jones) មកពីសមាគមផ្សាយដំណឹងល្អចិន (Chinese Evangelisation Society) ជាមួយនឹងស្ត្រីម្នាក់ទៀត អមដំណើរដោយមានអ្នកបម្រើក្មេងៗពីរនាក់ ពួកគេបានបើកសាលាសម្រាប់កុមារីយ៉ាងជោគជ័យ—ជាសាលារៀនសម្រាប់កុមារីតំបូងគេនៅក្នុងប្រទេសចិន។ កញ្ញា អាល់ដឺស៊ី (Miss Aldersey) បានទទួលប្រយោជន៍ជាច្រើនពីជំនួយរបស់កញ្ញា ម៉ារា ដាយយ័រ (Maria Dyer) ដែលត្រូវកូនស្រីរបស់លោកគ្រូសាំយ៉ូអែល ដាយយ័រ (Rev. Samuel Dyer) ដែលជាបេសកជនដំបូងៗទៅកាន់ប្រទេសចិន ហើយក៏ត្រូវជាមិត្តរួមការងាររបស់លោកគ្រូ រ៉ូប៊ើត ម៉ូរីសុន (Robert Morrison)។ នៅពេលដែលលោក និងលោកស្រី ចូនស៍ ព្រមទាំងគ្រួសាររបស់ពួកគេបានរើទៅនៅក្បែរសាលានោះ ជាញឹកញាប់ប្អូនស្រីរបស់គាត់បានជួយការងារដ៏មមាញឹករបស់អ្នកម្តាយ។ ពួកគេតែងតែសួរសុខទុក្ខអ្នកជិតខាងយ៉ាងទៀងទាត់ ដោយមានជំនួយផ្នែកភាសារបស់កញ្ញា ម៉ារា បានធ្វើឲ្យការសួរសុខទុក្ខកាន់តែរីករាយឡើង។ បើទោះបីជាគាត់មានអាយុតិចជាងម្ភៃឆ្នាំ និងមមាញឹកនឹងការងារសាលាក៏ដោយ ក៏ស្ត្រីវ័យក្មេងដែលមានប្រាជ្ញា និងទេពកោសល្យរូបនេះ មានភាពស្ទាត់ជំនាញនៅក្នុងការនាំព្រលឹងដែលបាត់បង់ជាច្រើនថ្វាយព្រះ។ សម្រាប់គាត់ការងារខាងព័ន្ធកិច្ចមិនមែនត្រឹមតែជាការបង្រៀននោះទេ ប៉ុន្តែក៏ជាការនាំមនុស្សបាត់បង់យ៉ាងសកម្មទៅកាន់ព្រះគ្រីស្ទ។

ចំណាប់អារម្មណ៍របស់លោកគ្រូ ហ៉ដសិន ថេល័រ បានចម្រើនកាន់តែខ្លាំងឡើង ព្រោះជាញឹកញាប់គាត់បានជួបនឹងអ្នកគ្រូ ម៉ារា នៅផ្ទះមិត្តរួមការងាររបស់គាត់ ហើយគាត់មើលឃើញថា អ្នកគ្រូ ម៉ារា ជានារីម្នាក់ដែលគួរឲ្យចាប់អារម្មណ៍។ ការបើកចិត្ត និងភាពស្មោះត្រង់របស់នាងបានធ្វើឲ្យពួកគេបានក្លាយជាមិត្តយ៉ាងឆាប់រហ័ស ហើយការមានគុណតម្លៃដូចគ្នារបស់ពួកគេ បានធ្វើឲ្យនាងដក់នៅកន្លែងពិសេសមួយនៅក្នុងបេះដូងរបស់គាត់ ដែលមិនធ្លាប់មានសោះពីមុនមក។

មិនយូរប៉ុន្មានមិត្តភាពរបស់ពួកគេបានបញ្ចប់ ដោយសារតែហេតុការណ៍ដែលនឹកស្មានមិនដល់ ដែលត្រូវរំសាយសហគមន៍បេសកជននៅទីក្រុងនីងប៉ូ។ គេបានដឹងអំពីគម្រោងការសម្លាប់ជនបរទេសទាំងអស់ ហើយបើទោះបីជាពួកគេអាចរារាំងវាបានក៏ដោយ ក៏ការស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះជនបរទេសនៅក្នុងស្រុកធ្វើឲ្យពួកគេត្រូវបញ្ជូនក្រុមគ្រួសារព្រមទាំងក្មេងៗទៅទីក្រុងនៅឆ្នេរសមុទ្រដែរ។ ចំណេះដឹងខាងគ្រាមភាសាក្រុងសៀងហៃរបស់លោកគ្រូ ហ៉ដសិន ថេល័រ បានធ្វើឲ្យគាត់ក្លាយជាអ្នកដ៏ល្អបំផុតនៅក្នុងការដឹកនាំក្រុម ហើយបើទោះបីជា មានការលំបាកយ៉ាងណាក្នុងការចាកចេញនៅពេលនោះ ក៏គាត់មិនអាចបដិសេធកិច្ចការនេះបានដែរ។

កញ្ញា អាល់ដឺស៊ី បដិសេធមិនព្រមទៅកន្លែងសុវត្ថិភាពជាងនោះឡើយ។ ដោយសារវ័យរបស់នាងកាន់តែចាស់ទៅ នាងក៏បានផ្ទេរសាលារបស់នាងទៅបេសកកម្មព្រេសប៊ីធារានអាមេរិក (American Presbyterian Mission)។ នាងជឿថា វាមិនមែនជាពេលត្រូវផ្លាស់ប្តូរអ្វីដែលមិនចាំបាច់នោះទេ ហើយដោយបានរៀបចំការប្រុងប្រយ័ត្នដែលអាចធ្វើទៅបាន នាងបានលើកទឹកចិត្តអ្នកជំនួយវ័យក្មេងទាំងពីរនាក់ឲ្យបន្តស្នាក់នៅជាមួយនាង។ បងស្រីរបស់នាងបានភ្ជាប់ពាក្យនឹងលោក ជេ.អេស. ប៊ើឌិន (Mr. J. S. Burdon) ដែលជាមិត្តជិតស្និទ្ធរបស់លោកគ្រូ ហ៉ដសិន ថេល័រ ដោយធ្វើឲ្យប្អូនស្រីកាន់តែឯកោ និងគ្មានការការពារ។ វាពិតជាពិបាកក្នុងការចាកចេញពីនាង ជាពិសេសគឺនៅពេលនេះ ប៉ុន្តែលោកគ្រូ ហ៉ដសិន ថេល័រ គ្មានហេតុផលនឹងគិតថា វត្តមានរបស់គាត់នឹងលួងលោមនាងឲ្យបានប្រសើរឡើងទេ។ លើសពីនេះ គាត់នឹងព្យាយាមបំភ្លេចវា។

គាត់ដឹងយ៉ាងច្បាស់ថា គាត់មានអ្វីតិចតួចណាស់នៅក្នុងការផ្តល់ឲ្យមនុស្សដែលគាត់ស្រឡាញ់។ ថ្មីៗនេះ តួនាទីរបស់គាត់ជាភ្នាក់ងារនៅសមាគមផ្សាយដំណឹងល្អចិនបាន

ធ្វើឲ្យគាត់កាន់តែមានភាពអាម៉ាស់ឡើង។ គាត់បានដឹងថា មួយរយៈមកហើយសមាគមជំពាក់បំណុលគេ ហើយប្រាក់ខែរបស់គាត់បានមកពីប្រាក់មូលនិធិកម្ចី។

គាត់បានសរសេរថា គាត់តែងតែជៀសវាងនៅក្នុងការជំពាក់បំណុលគេ ពេលខ្លះត្រូវតែមានការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់លុយកាក់។ ពេលនេះដោយមានប្រាក់ចំណូលច្រើន គាត់មិនមានបញ្ហានៅក្នុងការជៀសវាងពីជំពាក់បំណុលគេទេ។ ទោះជាយ៉ាងណាសមាគមក៏នៅតែមានបំណុលគេ។ ប្រាក់ប្រចាំត្រីមាសដែលគាត់ និងអ្នកផ្សេងទៀតបើកជាញឹកញាប់បានបង់ដោយប្រាក់ដែលបានមកពីការខ្ចីគេ។ ការនេះបាននាំឲ្យមានការឆ្លើយឆ្លងរវាងគាត់ និងសមាគមដែលបានបញ្ចប់ដោយគាត់បានសុំលាឈប់ពីដំណែងនៅឆ្នាំបន្ទាប់ក្រោមហេតុផលនៃបញ្ញាចិត្ត។

ខ្ញុំជឿថា ការបង្រៀនរបស់ព្រះជាម្ចាស់គឺច្បាស់ណាស់ថា៖ «កុំឲ្យជំពាក់អ្វីដល់អ្នកណាឲ្យសោះ»។ ចំពោះខ្ញុំ ការខ្ចីប្រាក់គឺជាអ្វីដែលផ្ទុយពីព្រះគម្ពីរ ថែមទាំងធ្វើឲ្យយើងគិតថា ព្រះជាម្ចាស់បានបង្ខាំងមិនឲ្យអ្វីដែលល្អ ហើយក៏យើងព្យាយាមទទួលយកអ្វីដែលទ្រង់មិនបានប្រទានមក។ តើអ្វីដែលខុសសម្រាប់គ្រីស្ទបរិស័ទម្នាក់ អាចជាអ្វីដែលត្រូវសម្រាប់គ្រីស្ទបរិស័ទមួយក្រុមទៀតដែរឬទេ? តើអ្វីៗដែលធ្លាប់កើតឡើងបន្តគ្នាពីមុនមកអាចធ្វើឲ្យកំហុសមួយក្លាយជាត្រឹមត្រូវបានដែរឬទេ? ព្រះគម្ពីរបានបង្រៀនខ្ញុំឲ្យជៀសវាងការជំពាក់បំណុល។ ខ្ញុំមិនជឿថា ព្រះទ្រង់ខ្វះខាតធនធាន ឬក៏មិនសព្វព្រះទ័យនឹងបំពេញតម្រូវការចំពោះការងាររបស់ទ្រង់នោះឡើយ។ ប្រសិនបើ ថវិកាមិនគ្រប់គ្រាន់នៅក្នុងការធ្វើការ នោះវាប្រហែលជាមិនមែនជាកិច្ចការរបស់ព្រះជាម្ចាស់នៅពេលនោះ ឬក៏នៅក្នុងទម្រង់នោះ។ ដើម្បីជម្រះបញ្ញាចិត្តរបស់ខ្ញុំ ខ្ញុំបានលាឈប់ពីសមាគម។ វាធ្វើឲ្យខ្ញុំសប្បាយចិត្តដែលមិត្តភក្តិ សហការីរបស់ខ្ញុំ លោក ចូនស៍ ក៏បានសម្រេចចិត្តធ្វើដូចគ្នាដែរ ហើយយើងទាំងអស់គ្នាអរព្រះគុណ ដែលយើងអាចចេញមករៀងៗខ្លួនដោយគ្មានការបែកបាក់មិត្តភាព។

ការឈានជើងទៅមុខ គឺពិតជាមានការលំបាកណាស់ចំពោះសេចក្តីជំនឿរបស់ខ្ញុំ។ ខ្ញុំមិនប្រាកដថា តើព្រះអម្ចាស់សព្វព្រះទ័យឲ្យខ្ញុំធ្វើអ្វី ឬថាតើទ្រង់នឹងបំពេញសេចក្តីត្រូវការរបស់ខ្ញុំឬយ៉ាងណា ដើម្បីឲ្យខ្ញុំអាចបន្តធ្វើការដូចពីមុនបាន។ ប៉ុន្តែ ព្រះបានប្រទានពរថែមទាំងបានជួយខ្ញុំឲ្យជោគជ័យ ហើយខ្ញុំពិតជារីករាយ និងអរព្រះគុណ នៅពេលដែល

ការផ្លាស់ប្តូរពិតជាបានកើតឡើងមែន! ខ្ញុំអាចក្រឡេកមើលទៅព្រះជាម្ចាស់ដោយស្កប់ចិត្ត ហើយបានត្រៀមខ្លួនរួចរាល់ ដើម្បីធ្វើកិច្ចការបន្ទាប់ដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំ ដោយមានអារម្មណ៍ថា ខ្ញុំទទួលបានការយកព្រះទ័យទុកដាក់ដោយក្តីស្រឡាញ់ពីទ្រង់យ៉ាងពិតប្រាកដមែន។

ព្រះអង្គបានដឹកនាំខ្ញុំប្រកបដោយព្រះពរ ដែលខ្ញុំមិនអាចថ្លែងបាន។ វាមានអារម្មណ៍ថា បទពិសោធន៍ខ្លះបានបន្តកើតឡើងដូចជាបទពិសោធន៍ដំបូងៗដែលខ្ញុំជួបនៅផ្ទះដែរ។ សេចក្តីជំនឿរបស់ខ្ញុំត្រូវបានល្បងល តែវាត្រូវបានបរាជ័យជាញឹកញាប់ ហើយខ្ញុំមានអារម្មណ៍ថា សោកស្តាយ និងអាម៉ាស់ចំពោះការដែលមិនទុកចិត្តព្រះវរបិតា។ អូហ៍ ប៉ុន្តែខ្ញុំកំពុងរៀនស្គាល់ទ្រង់។ ខ្ញុំនឹងមិនចង់ខកខានចំពោះការល្បងល សូម្បីតែនៅពេលនោះក្តី។ ទ្រង់បានចូលមកជិតខ្ញុំយ៉ាងពិតប្រាកដ ហើយជិតស្និទ្ធមែន។ ការលំបាកខាងហិរញ្ញវត្ថុម្តងម្កាលមិនបានកើតចេញពីការខ្វះខាតខាងហិរញ្ញវត្ថុផ្ទាល់ខ្លួននោះទេ ប៉ុន្តែវាកើតចេញពីការជួយបំពេញសេចក្តីត្រូវការរបស់អ្នកអត់ឃ្លាន និងអ្នកជិតស្លាប់ជុំវិញយើងទៅវិញទេ។ ហើយការល្បងលដែលខ្លាំងជាងនៅផ្នែកផ្សេងទៀតត្រូវបានគ្រប់ដណ្តប់ទាំងស្រុងចំពោះបញ្ហាហិរញ្ញវត្ថុទាំងនេះ ដោយបង្កើតផលផ្លែកាន់តែច្រើនទៅតាមជម្រៅរបស់វា។

ពួកអ្នកក្រីក្រដែលពួកគេបានផ្តល់អាហារឲ្យនៅរដូវរងានោះគឺជាជនភៀសខ្លួនអត់ឃ្លាន ដែលបានសម្រុកចូលទៅក្នុងទីក្រុងសៀងហៃ ពីតំបន់ដែលខ្ទេចខ្ទាំដោយសារក្រុមបះបោរថៃភីង។ អ្នករងការឈឺចាប់ស្ថិតនៅក្នុងកម្រិតខុសៗគ្នាដូចជា ខ្លះខ្វះខាតសំលៀកបំពាក់ មានជំងឺដង្កាត់ និងអត់ឃ្លាន មនុស្សទាំងនេះបានរស់នៅផ្ទះបាក់បែកនៅតាមផ្នូរខ្មោច ឬកន្លែងគេបោះបង់ចោល និងអាគារបាក់បែក។ ទន្ទឹមនឹងមើលថែរក្សាក្រុមជំនុំមួយកន្លែងរបស់បេសកកម្មក្រុងឡុងដ៍ លោកគ្រូ ហ័ដសិន ថេល័រ បានអធិប្បាយជាប្រចាំនៅព្រះវិហារក្នុងក្រុង (City Temple) ហើយនៅតែអាចមានពេលជួបនឹងលោកចូនស៍ នៅកន្លែងដ៏កំសត់នោះ ជាកន្លែងដែលពួកគេតែងតែយកចិត្តទុកដាក់ចំពោះអ្នកជំងឺ ព្រមទាំងផ្តល់អាហារដល់មនុស្សស្រេកឃ្លានរាប់សិបនាក់ទៀត។

គាត់នៅតែបន្តគិតអំពីនាង ម៉ារា នៅទីក្រុងនីងប៉ូ នេះមិនមែនដោយសារតែគាត់គ្មានអ្វីផ្សេងទៀតធ្វើនោះទេ តែដោយសារគាត់ពិចារណាពីអាពាហ៍ពិពាហ៍។ មានដំបូន្មាន

មួយថា "កុំរៀបការ ប្រសិនបើអ្នកអាចទប់ចិត្តបាន" អាចជាការយល់ច្រលំ ប៉ុន្តែលោកគ្រូ ហ៉ដសិន ថេល័រ ចាប់ផ្តើមយល់ពីវានៅពេលដែលគាត់ប្រទះនឹងសេចក្តីស្រឡាញ់ដ៏មានឥទ្ធិពល ដែលគាត់មិនអាចព្រងើយកន្តើយនឹងវាបានទៀត។

ស្របពេលជាមួយគ្នានៅទីក្រុងនីងប៉ូ ព្រះក៏បានធ្វើការក្នុងចិត្តរបស់នាង ម៉ារា បើទោះបីនាងត្រូវប្រឈមមុខនឹងឧបសគ្គជាច្រើនទៀតក៏ដោយ។ ឧបសគ្គនេះមិនមែនមកពីអ្នកដែលនាងស្រឡាញ់ខ្លាំងនោះទេ។ កញ្ញា ម៉ារា មានចរិតចេះគិតគូរ និងទន់ភ្លន់។ នាងតែងតែមានអារម្មណ៍ថា ឯកាតាំងពីកុមារភាព នាងទន្ទឹងរង់ចាំមិត្តយល់ចិត្តពិតម្នាក់។ នាងស្ទើរតែមិនអាចចាំមុខឪពុករបស់នាងបានទេ ហើយម្តាយរបស់នាងក៏បានទទួលមរណៈភាព នៅពេលនាងមានវ័យត្រឹមតែដប់ឆ្នាំប៉ុណ្ណោះ។ ការប្រែចិត្តដ៏ស្មោះត្រង់របស់នាងនៅតាមផ្លូវទៅប្រទេសចិន ដើម្បីចូលរួមនឹងកញ្ញា អាល់ដឺសុី បានផ្លាស់ប្រែទាំងស្រុងចំពោះលក្ខណៈព័ន្ធកិច្ចរបស់នាង ប៉ុន្តែវាជាជំហរឯកោមួយសម្រាប់ក្មេងស្រីវ័យជំទង់ ជាពិសេសបន្ទាប់ពីបងស្រីរបស់នាងបានភ្ជាប់ពាក្យរួច។

បន្ទាប់មក បេសកជនវ័យក្មេងដែលធ្វើឲ្យនាងកោតសរសើរបានមកដល់ បុរសនោះមានបំណងប្រាថ្នាស្រដៀងនឹងនាងចំពោះភាពបរិសុទ្ធ ភាពមានប្រយោជន៍ និងភាពជិតស្និទ្ធជាមួយព្រះជាម្ចាស់។ គាត់មានភាពលេចធ្លោ មិនមែនដោយសារគាត់មានអំណោយទានច្រើន ឬក៏មានភាពទាក់ទាញនោះទេ—បើទោះបីជាគាត់រួសរាយរាក់ទាក់ ឆ្លាតវៃ និងពេញដោយភាពកំប្លុកកំប្លែងក៏ដោយ—ប៉ុន្តែដោយសារមានអ្វីមួយដែលធ្វើឲ្យនាងមានអារម្មណ៍ថាបានស្ងប់ចិត្ត និងមានគេយល់ចិត្ត។ គាត់ហាក់បីដូចជារស់នៅពិភពលោកដ៏ជាក់លាក់មួយ ហើយមានព្រះដ៏អស្ចារ្យពិតប្រាកដ ។ បើទោះបីនាងមិនសូវបានឃើញគាត់ក៏ដោយ ការដែលបានដឹងថា គាត់នៅជិតៗនោះធ្វើឲ្យនាងបានកម្សាន្តចិត្ត ហើយនាងមានការភ្ញាក់ផ្អើលចំពោះការដែលនាងនឹកគាត់ដល់ម្ល៉េះ នៅពេលដែលគាត់បានត្រឡប់ទៅទីក្រុងសាតូវិញ ក្រោយពេលស្នាក់នៅទីនោះបានត្រឹមតែប្រាំពីរសប្តាហ៍ប៉ុណ្ណោះ។

តាមដែលយើងដឹង ដោយសារតែមានឧបសគ្គជាច្រើនទំនាក់ទំនងរបស់ពួកគេមិនអាចបន្តទៅមុខបានទេ ដូច្នេះនាងមានការភ្ញាក់ផ្អើល និងសេចក្តីអំណរពេលនាងដឹងថា លោកគ្រូ ហ៉ដសិន ថេល័រ បានត្រឡប់មកទីក្រុងនីងប៉ូម្តងទៀត។ ប្រហែលជានោះ

ហើយជាអ្វីដែលធ្វើឲ្យនាងដឹងថា នាងកាន់តែចាប់អារម្មណ៍ចំពោះគាត់ខ្លាំងឡើង។ មិនយូរប៉ុន្មាន នាងដឹងពីអារម្មណ៍ខ្លួនឯង និងដោយចរិតស្មោះត្រង់ នាងមិនបានលាក់វាពីខ្លួននាងផ្ទាល់ ឬក៏ព្រះជាម្ចាស់នោះទេ។ នាងមិនបានខ្វល់នៅក្នុងការនិយាយអំពីគាត់ជាមួយនឹងអ្នកដទៃ ពីព្រោះពួកគេមិនឃើញអ្វីដែលនាងឃើញក្នុងគាត់នោះឡើយ។ ពួកគេមិនចូលចិត្តការដែលគាត់ស្លៀកសំលៀកបំពាក់ចិន និងផ្សារភ្ជាប់ខ្លួននៅក្នុងវប្បធម៌ចិន។ ប៉ុន្តែ នាងស្រឡាញ់សំលៀកបំពាក់ចិនរបស់គាត់ ជាពិសេសអ្វីដែលវាតំណាងនិងសតិអារម្មណ៍របស់វា។ នាងបានយល់ និងអាណិតចំពោះភាពកំសត់កម្រ និងភាពសប្បុរសរបស់គាត់ចំពោះអ្នកដែលខ្វះខាត។ ប្រសិនបើអ្នកដទៃគិតថា ទស្សនវិស័យ និងឆន្ទៈរបស់គាត់នៅក្នុងការនាំដំណឹងល្អដល់មនុស្សជាច្រើនដែលវិនាសបាត់បង់ដោយគ្មានព្រះគ្រីស្ទក្នុងស្រុក ថាជាក្តីស្រមៃដែលមិនអាចទៅរួចក្តី តែសម្រាប់នាងវិញ នាងមានការត្រាស់ហៅស្រដៀងគាត់នៅដួងចិត្តនាង ហើយក៏ប្រាថ្នាចង់រស់នៅបែបនោះ បើទោះបីជាវាហាក់បីមិនងាយស្រួលសម្រាប់មនុស្សស្រីក៏ដោយ។ ដូច្នេះ នាងបានអធិស្ឋានជាញឹកញាប់សម្រាប់មិត្តរបស់នាង ទោះបីជានាងមិនបង្ហាញច្រើនពីអារម្មណ៍របស់នាងដល់គាត់ក៏ដោយ។

ជាច្រើនខែកន្លងផុតទៅ នៅពេលដែលគាត់ត្រូវទៅរស់នៅក្រុងសៀងហៃ ហើយនាងមិនដឹងថាគាត់ត្រូវលះបង់អ្វីខ្លះនៅក្នុងការចាកចេញពីនាងឡើយ។ ចុងក្រោយ សំបុត្រក៏បានមកដល់! គាត់បានសរសេរដើម្បីប្រកាសពីសេចក្តីស្រឡាញ់របស់គាត់ចំពោះនាង ហើយសួរថាតើនាងនឹងភ្ជាប់ពាក្យជាមួយគាត់ឬទេ? ភ្លាមៗនោះនាងបានពេញដោយសេចក្តីអំណរដ៏អស្ចារ្យ វាមិនគួរឲ្យភ្ញាក់ផ្អើលនោះទេ ប៉ុន្តែផ្ទុយទៅវិញជាពន្លឺដ៏ស្រទន់នៃអ្វីដែលចាំងចែងនៅក្នុងរយៈពេលយូរមួយ ដូច្នេះនាងគិតត្រូវតាំងពីដើមមកម្ល៉េះ។ ពួកគេទាំងពីរនាក់គឺជាគូនឹងគ្នា «ព្រះជាម្ចាស់បានជ្រើសរើសអ្នកទាំងពីរ ដើម្បីដើរជាមួយគ្នានៅចំពោះទ្រង់»។

នៅពេលដែលនាងបានដើរចេញពីសេចក្តីអំណរ និងការអរព្រះគុណរបស់នាង នាងបានស្វែងរកបងស្រីរបស់នាង ជាអ្នកដែលយល់អំពីនាង។ បន្ទាប់មក នាងបានផ្តល់ដំណឹងដល់កញ្ញា អាល់ដឺស៊ី ដោយសង្ឃឹមថា នាងនឹងគាំទ្រការភ្ជាប់ពាក្យនេះ ដូចដែលនាងបានផ្តល់ការគាំទ្រដល់នាង បួរ៉េលឡា (Miss Burella) ដែរ។ ផ្ទុយទៅវិញ កញ្ញា

អាល់ដឺស៊ី បានខឹងសម្បារយ៉ាងខ្លាំងនៅពេលដែលនាងបានឮដំណឹងនេះ។

“លោកគ្រូ ហ័ដសិន នៅក្មេង ហើយក្រខ្សត់ គ្មានខ្សែស្រឡាយ មិនស្គាល់អ្នកណា តើគាត់អាចហ៊ានគិតបែបនេះបានដោយរបៀបណា?”។ ជាក់ស្តែង សំណើភ្ជាប់ពាក្យត្រូវបានបដិសេធភ្លាមៗ ហើយជាដាច់ខាត។

នាង ម៉ារា បានព្យាយាមពន្យល់ថាលោកមានន័យប៉ុណ្ណាចំពោះនាង តែគ្មានប្រយោជន៍ទេ។ ការនេះធ្វើឲ្យរឿងរ៉ាវកាន់តែអាក្រក់ទៅៗ។ នាងត្រូវការការសង្គ្រោះភ្លាមៗពីភាពល្ងង់ខ្លៅបែបនេះ។ មិត្តចិត្តល្អរបស់នាង ដែលមានចេតនាល្អបំផុតបានគ្រប់គ្រងស្ថានការណ៍ទាំងស្រុងហើយ។ ចុងក្រោយ នាងបានសរសេរសំបុត្រមួយច្បាប់ ដែលសេចក្តីសំបុត្រទាំងមូលបានបង្គាប់ឲ្យសរសេរដោយកញ្ញា អាល់ដឺស៊ី ថាមិនត្រឹមតែឲ្យបញ្ចប់អ្វីៗនោះទេ តែក៏បានស្នើសុំយ៉ាងម៉ឺងម៉ាត់ថា មិនឲ្យលើកយករឿងនោះមកនិយាយម្តងទៀតជាដាច់ខាត។

ដោយការច្របូកច្របល់ និងការខូចចិត្ត ក្នុងនាមជានារីវ័យក្មេងម្នាក់ ហើយខ្វះបទពិសោធន៍ ថែមទាំងមានការអៀនខ្មាសខ្លាំងចំពោះរឿងទាំងនេះផង។ ដូច្នេះ នាងគ្មានជម្រើសអ្វីក្រៅពីធ្វើតាមការសម្រេចចិត្តរបស់កញ្ញា អាល់ដឺស៊ី ដោយមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់មិត្តភក្តិផ្សេងទៀត។ ដោយមានអារម្មណ៍ឈឺចាប់ និងអាម៉ាស់ខ្លាំង នាងត្រូវតែទុកចិត្តលើព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ដោយដឹងថាទ្រង់ជ្រាប និងយល់អំពីស្ថានភាពរបស់នាង។ នៅក្នុងអំឡុងពេលដ៏យូរ និងឯកា សូម្បីតែពេលបងស្រីរបស់នាងក៏បានយល់ស្របជាមួយនឹងកញ្ញា អាល់ដឺស៊ី ដែរ។ នាងបានរកឃើញការកម្សាន្តចិត្តដោយជឿថា គ្មានអ្វីពិបាកខ្លាំងពេកចំពោះព្រះអម្ចាស់នោះទេ។ នាងបានរំឭកខ្លួនឯងជានិច្ចថា ប្រសិនបើព្រះជាម្ចាស់ដកយកនូវសេចក្តីសង្ឃឹមដែលនាងស្រឡាញ់បំផុតស្រដៀងនឹងលោក អ៊ីសាក នាងបានដឹងថាទ្រង់មានអំណាចនៅក្នុងការស្តារវាឲ្យបានប្រសើរឡើងវិញ។

នៅពេលរដូវផ្ការីកបានមកដល់សារជាថ្មី ហើយលោកគ្រូ ហ័ដសិន ថេល័រ អាចត្រឡប់មកពីទីក្រុងសៀងហៃវិញ ស្ថានភាពក៏កាន់តែពិបាកឡើងៗដែរ។ កញ្ញា អាល់ដឺស៊ី មិនសប្បាយចិត្តជាមួយនឹងការត្រឡប់មកវិញរបស់លោកគ្រូ ហ័ដសិន ទេ នាងមានអារម្មណ៍ថា មានតួនាទីត្រូវតែរិះគន់គាត់គ្រប់កាលៈទេសៈតែម្តង។ បន្ទាប់ពីបានទទួលសំបុត្រ

របស់នាង ម៉ារា គាត់មិនអាចណាត់ជួបគ្នាជាមួយនាងទេ ហើយមិនបានដឹងពីអារម្មណ៍ពិតរបស់នាងដែរ។ នាងមានទេពកោសល្យ និងមានភាពទាក់ទាញ ដោយទាក់ទាញមនុស្សជាច្រើនឲ្យទទួលបានការលើកទឹកចិត្ត។ ទំនៀមទំលាប់ និងរបៀបការទូតរបស់ជនជាតិចិនស្ទើរតែរារាំងពួកគេមិនឲ្យជួបគ្នា។ ប៉ុន្តែ ពួកគេទាំងពីរនាក់បានអធិស្ឋានដោយបើកដួងចិត្តចំពោះព្រះជាម្ចាស់ បើទោះបីជាពួកគេពិបាកក្តី ក៏ពួកគេនៅតែស្វែងរកបំណងព្រះហឫទ័យទ្រង់ដោយស្មោះត្រង់។ ហើយទ្រង់មានរបៀបដោះស្រាយបញ្ហាដែលមិនគួរឲ្យជឿសោះ!

ថ្ងៃរសៀលដ៏ក្តៅនៃខែកក្កដាត្រូវជាវេនរបស់លោក និងលោកស្រី ចូនស៍ ធ្វើជាអ្នកសម្របសម្រួលការប្រជុំអធិស្ឋាន។ ចំនួនស្ត្រីចូលរួមដូចធម្មតា ប៉ុន្តែការចាកចេញពិបាកជាងការមកចូលរួម ដោយសារតែមានព្យុះបានបោកបក់តាមទន្លេធ្វើឲ្យមានទឹកជំនន់លិចទីក្រុងនីងប៉ូ ហើយភ្លៀងធ្លាក់មកយ៉ាងខ្លាំងដោយមិនមានការព្រៀងទុកជាមុន។ នៅពេលនោះលោកគ្រូ ហ័ដសិន ថេល័រ រស់នៅជាមួយគ្រួសាររបស់លោក ចូនស៍ ពួកគេត្រូវពន្យារពេលនៅបន្ទប់ពិគ្រោះជំងឺដោយសារតែផ្លូវត្រូវជន់លិចអស់។ នៅពេលដែលពួកគេបានមកដល់ផ្ទះ ភ្ញៀវភាគច្រើនបានចាកចេញទៅអស់ហើយ ប៉ុន្តែអ្នកបម្រើនៅសាលាម្នាក់បានរំឭកថា កញ្ញា ម៉ារា ហើយមិត្តសម្លាញ់យើងនៅរង់ចាំកៅអីស្នែងរបស់ពួកគេនៅឡើយ។

លោក ចូនស៍ និយាយថា៖ «សូមមកចូលបន្ទប់សិក្សាខ្ញុំមក» «ហើយខ្ញុំនឹងមើលថាតើខ្ញុំអាចរៀបចំអ្វីបានខ្លះ»។ មិនយូរប៉ុន្មាន គាត់បានត្រឡប់មកវិញ ហើយនិយាយថាសុភាពនារីទាំងនោះអផ្សុកដោយនៅតែជាមួយអ្នកស្រី ចូនស៍ ហើយពួកគេមុខជារីករាយនឹងជួបលោកគ្រូ ហ័ដសិន។

បុរសនោះមិនសូវចាប់អារម្មណ៍ពីសកម្មភាពរបស់គាត់ទេ ក៏បានឡើងទៅខាងលើ ហើយបានជួបមនុស្សម្នាក់ដែលគាត់ពិតជាស្រឡាញ់ខ្លាំង។ មានអ្នកផ្សេងទៀតនៅទីនោះ ដើម្បីកំដរនារីៗតាមប្រពៃណីចិន តែគាត់មិនចាប់អារម្មណ៍អ្នកណាផ្សេងទេលើកលែងតែមុខរបស់នាង។ គាត់មានគម្រោងចង់សួរសុខទុក្ខនាង ហើយសុំការអនុញ្ញាតពីនាង ដើម្បីសរសេរសំបុត្រជូនអាណាព្យាបាលរបស់នាងនៅទីក្រុងឡុងដ៍ ប៉ុន្តែគាត់មិនអាចគ្រប់គ្រងអារម្មណ៍របស់គាត់តទៅទៀតនោះឡើយ។ នាងបានយល់ព្រមនៅចំពោះមុខមិត្តជិតស្និទ្ធជាច្រើននៅទីនោះ ទាំងមិនប្រាកដថា ពេលណាពួកគេនឹងបាន

ជួបគ្នាម្តងទៀតឡើយ។ នាងបានបង្ហាញសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់ ដោយនាងបានចាត់ទុកថា គាត់ជាទីស្រឡាញ់របស់នាងដូចគាត់ស្រឡាញ់នាងដែរ។។ ហើយនៅពេលនោះលោកគ្រូ ហ៉ដសិន ថេល័រ បានផ្តល់យោបល់ថា៖ «តោះយើង អធិស្ឋានសម្រាប់ការនេះជាមួយគ្នា»។

ការរង់ចាំរយៈពេលបួនខែពិតជាយូរណាស់ ជាពិសេសពួកគេបានដឹងថា កញ្ញា អាល់ដឺស៊ី បានសរសេរសំបុត្រទៅអ្នកផ្ទះ ដើម្បីបញ្ចុះបញ្ចូលសាច់ញាតិឲ្យយល់ស្របជាមួយនាង។ ចុះបើអាណាព្យាបាលនៅទីក្រុងឡុងដ៍លម្អៀងទៅតាមអំណះអំណាងដែលគួរឲ្យជឿរបស់នាង អាល់ដឺស៊ី? ចុះបើពួកគេបានបដិសេធសំណើរៀបការនោះ? ពួកគេទាំងពីរនាក់ទុកចិត្តយ៉ាងមុតមាំថា ការស្តាប់បង្គាប់ឪពុកម្តាយ ឬអាណាព្យាបាលនាំមកនូវព្រះពររបស់ព្រះជាម្ចាស់។

លោកគ្រូ ហ៉ដសិន បានសរសេរនៅប៉ុន្មានឆ្នាំក្រោយមកថា គាត់មិនដែលឃើញការមិនស្តាប់បង្គាប់របស់ឪពុកម្តាយនោះទេ សូម្បីតែនៅពេលដែលឪពុកម្តាយបានយល់ខុសក៏ដោយ នោះក៏នឹងមិនត្រូវទទួលការដាក់ពិន័យដែរ។ យើងអាចយកឈ្នះដោយជំនួយមកពីព្រះអម្ចាស់ ព្រោះទ្រង់អាចបើកទ្វារណាក៏បាន។ ឪពុកម្តាយមានទំនួលខុសត្រូវសំខាន់ណាស់នៅក្នុងកាលៈទេសៈនេះ។ នៅពេលដែលកូនប្រុស ឬកូនស្រី អាចនិយាយដោយស្មោះត្រង់ថា៖ «ឱព្រះអម្ចាស់អើយ ទូលបង្គំកំពុងរង់ចាំទ្រង់បង្ហាញផ្លូវដល់ទូលបង្គំ» កូនថ្វាយបញ្ហារបស់កូនស្ថិតនៅក្នុងព្រះហស្តទ្រង់ ហើយសូមទ្រង់ដោះស្រាយវាផងចុះ។

ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់ពួកគេនៅពេលដែលគាត់យកសំបុត្រដែលបានរង់ចាំដោយអន្ទះសានោះមកអាន ហើយជាការពិត ពេលនោះជិតដល់ចុងខែវិច្ឆិកា សំបុត្រដែលគាត់បានរង់ចាំដោយអន្ទះសានោះបានមកដល់ ហើយពួកគេទទួលបានអនុញ្ញាតហើយ! បន្ទាប់ពីបានធ្វើការស៊ើបអង្កេតយ៉ាងល្អិតល្អន់មក លោកពូដែលរស់នៅទីក្រុងឡុងដ៍យល់ថា លោកគ្រូ ហ៉ដសិន ថេល័រ គឺជាបេសកជនដែលមានសក្តានុពលម្នាក់។ ក្រុមលេខាធិការនៅសមាគមផ្សាយដំណឹងល្អចិនបានត្រឹមតែលើកសរសើរពីគាត់ ហើយគាត់ក៏បានទទួលការធានាពីប្រភពផ្សេងទៀតផងដែរ។ ដោយហេតុផលនេះ បានច្រានចោលនូវពាក្យចចាមអារាមដែលគួរឲ្យបារម្ភផ្សេងៗថា ជារឿងមិនសមទំនង ហើយគាត់បានយល់ស្របពេញទំហឹងចំពោះការភ្ជាប់ពាក្យរបស់ក្មួយស្រីគាត់ ដោយគ្រាន់តែ

សុំឲ្យរង់ចាំរហូតដល់នាងឈានដល់អាយុរៀបការស្របច្បាប់ ដែលមានរយៈពេលត្រឹមតែពីរខែទៀតប៉ុណ្ណោះ។

ពួកគេបានភ្ជាប់ពាក្យយ៉ាងបើកចំហតាំងពីពេលនោះមក ហើយមានពេលវេលាដ៏រីករាយនៅរដូវរងានោះ ហើយបានប៉ះប៉ូវលើសពីអ្វីដែលបានកើតឡើងកាលពីមុននោះ។ កូនក្រមុំនឹងចូលដល់អាយុម្ភៃមួយឆ្នាំនៅថ្ងៃសៅរ៍ ទី១៦ ខែមករា ជាមួយនឹងគម្រោងអាពាហ៍ពិពាហ៍នៅសប្តាហ៍បន្ទាប់។

លោកគ្រូ ហ័ដសិន បានសរសេរថា៖ «ខ្ញុំមិនដែលមានអារម្មណ៍មានក្តីសុខ ឬក៏បានពេញដោយអំណរអរសប្បាយជាងនេះទេនៅក្នុងជីវិតខ្ញុំ។ អ្នកម្តាយជាទីស្រឡាញ់អើយ កូនស្ទើរតែមិនអាចស៊ូទ្រាំបានចំពោះអ្វីដែលបានកើតឡើង ដែលបន្ទាប់ពីការស៊ូទ្រាំនឹងការទុក្ខលំបាក និងការពន្យាពេលផ្សេងៗ។ យើងមិនត្រឹមតែមានពេលចំណាយជាមួយគ្នានោះទេ ប៉ុន្តែព្រះជាម្ចាស់ក៏សព្វព្រះទ័យឲ្យយើងនឹងរៀបការនៅប៉ុន្មានថ្ងៃខាងមុខនេះដែរ! ព្រះទ្រង់ល្អណាស់ដល់ពួកយើង។ ទ្រង់ពិតជាបានឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ហើយបានត្រួសត្រាយផ្លូវសម្រាប់យើងទាស់នឹងពួកអ្នកមានអំណាច។ អូហ៍ សូមឲ្យយើងអាចរស់នៅកាន់តែស្និទ្ធជាមួយទ្រង់ និងបម្រើទ្រង់កាន់តែស្មោះត្រង់ឡើង។ ខ្ញុំចង់ឲ្យអ្នកម្តាយបានស្គាល់បណ្តូលចិត្តរបស់កូនណាស់។ នាងគឺជាស្ត្រីគ្រប់លក្ខណ៍ និងជាអ្វីគ្រប់យ៉ាងទាំងអស់ដែលកូនប្រាថ្នាចង់បាន»។

ហើយប្រាំមួយសប្តាហ៍ក្រោយមក៖

«រៀបការជាមួយមនុស្សដែលយើងស្រឡាញ់ដោយថ្នាក់ថ្នម និងភក្តីភាព គឺជាសុភមង្គលដែលគ្មានពាក្យអ្វីដែលអាចបរិយាយ ឬលើសពីការស្រមៃដល់។ គ្មានការខកចិត្តទេ។ ជារៀងរាល់ថ្ងៃ គំនិតរបស់មនុស្សដែលយើងស្រឡាញ់បានបង្ហាញ ហើយដោយមានកំណប់ទ្រព្យដូចដែលខ្ញុំមាន នោះធ្វើឲ្យខ្ញុំកាន់តែមានមោទនភាព រីករាយ ហើយកាន់តែអរព្រះគុណដោយបន្ទាបខ្លួនចំពោះព្រះជាម្ចាស់ ដែលទ្រង់ជាព្រះដែលប្រទានគ្រប់ទាំងរបស់ដ៏ល្អសម្រាប់ជាអំណោយដ៏ប្រសើរបំផុតនៅលើផែនដីនេះ»។

ជំពូកទី៨

# អំណាចនៃចម្រូត

*ចម្រូតកើតក្រោយការសាបព្រោះ ក្រោយភ្លៀងមេឃស្រឡះ*
*និមិត្តកើតក្រោយអាថ៌កំបាំង សេចក្តីសុខកើតក្រោយការឈឺចាប់។*
*— លោក អេហ្វ. អរ. ហាវើរហ្គល (F. R. Havergal)*

លោកគ្រូ ហ័ដសិន ថេល័រ នៅសល់ត្រឹមតែពីរឆ្នាំកន្លះទៀតប៉ុណ្ណោះក្នុងការបម្រើដំណាក់កាលទីមួយនៅប្រទេសចិន តែវាជាឆ្នាំដែលសំបូរសប្បាយ។ ផ្ទះតូចនៅលើផ្លូវស្ពានរបស់ពួកគាត់ ឥឡូវនេះបានក្លាយជាកន្លែងមួយដែលពោរពេញដោយភាពកក់ក្តៅ និងក្តីស្រឡាញ់។ ស្របពេលដែលកន្លែងថ្វាយបង្គំ និងបន្ទប់ទទួលភ្ញៀវនៅជាន់ផ្ទាល់ដីនៅដដែល ហើយគ្រីស្ទបរិស័ទ និងអ្នកមិនទាន់ជឿដែលមានសំណួរផ្សេងៗបន្តចេញចូលដោយសេរី ជាន់ខាងលើដែលបានផ្លាស់ប្តូរជាបន្ទប់ដ៏កក់ក្តៅ ហើយបន្ទប់ដែលមានវាំងននពិបាកសម្គាល់ណាស់ថា ពីមុនវាជាជង្រុកដាក់ឥវ៉ាន់។ ទេសភាពផ្លូវនៅខាងមុខ និងប្រឡាយទឹកនៅខាងក្រោយបន្ថែមសម្រស់ដល់វា។ វាជាការវិវឌ្ឍន៍គួរឲ្យកត់សម្គាល់ដែលបច្ចុប្បន្នស្ត្រី និងក្មេងៗអាចទទួលបានការថែទាំដូចគ្នាទៅនឹងបុរសៗ។ លោកស្រី ថេល័រ ជាម្នាក់ដែលគ្រប់គ្នាស្គាល់ច្បាស់នៅក្នុងតំបន់នោះ ហើយពួកគេស្វាគមន៍នាងយ៉ាងកក់ក្តៅនៅពេលនាងបានទៅសួរសុខទុក្ខ។ វត្តមានដ៏គួរឲ្យរីករាយរបស់គាត់បានធ្វើឲ្យមនុស្សជាច្រើនបានដក់ជាប់ក្នុងចិត្ត ដោយសារគ្រប់គ្នាស្រឡាញ់មនុស្សដែលមានពេញដោយសេចក្តីស្រឡាញ់ ហើយចំណងស្នេហ៍រវាងលោក និងលោកស្រី ថេល័រ ធ្វើឲ្យគេចាប់ចិត្តយ៉ាងខ្លាំង។

អតីតមេដឹកនាំពុទ្ធសាសនាម្នាក់ គឺជាមិត្ត និងអ្នកគាំទ្រដែលសាទរបំផុតរបស់ពួកគេ បច្ចុប្បន្នជាឈ្មួញកប្បាសម្នាក់នៅក្នុងទីក្រុង។ លោក នី (Mr. Ni) រស់នៅទីក្រុង នីងប៉ូ ជាយូរមកហើយ ប៉ុន្តែគាត់មិនដែលឮពីដំណឹងល្អឡើយ។ ទោះបីជាគាត់បានលះបង់ច្រើនយ៉ាងណាចំពោះសង្គមដែលថ្វាយបង្គំរូបព្រះទុកដូចជាប្រធាន ដោយបានចំណាយពេលវេលា និងប្រាក់កាក់ជាច្រើនដើម្បីបម្រើ «ព្រះផ្សេងៗ» ក៏ដោយ ក៏គាត់មានអារម្មណ៍ថា មិនបានស្ងប់ចិត្តទាល់តែសោះ។ សម្រាប់គាត់ ការកាន់តែចូលរួមក្នុងការប្រតិបត្តិខាងសាសនា វាហាក់បីដូចជាកាន់តែគ្មានន័យ។

ល្ងាចមួយ នៅពេលដែលគាត់បានធ្វើដំណើរឆ្លងកាត់ទ្វារកំពុងចំហមួយនៅតាមផ្លូវ គាត់បានឃើញសកម្មភាពដែលបានកើតឡើងនៅខាងក្នុង។ សម្លេងជួងបានបន្លឺឡើង ហើយមនុស្សម្នាបានជុំគ្នាដូចជាការប្រជុំមួយអញ្ជឹង។ ដោយបានដឹងថា វាជាសាលពិភាក្សាអំពីប្រធានបទ «សាសនា» គាត់ក៏បានចូលទៅក្នុងដោយចាប់អារម្មណ៍យ៉ាងខ្លាំងលើប្រធានបទ «ឈ្នួលនៃអំពើបាប» និងដំណើររបស់ព្រលឹងទៅកាន់កន្លែងដែលមិនស្គាល់។ ជនបរទេសវ័យក្មេងស្លៀកសំលៀកបំពាក់ចិនកំពុងបង្រៀនចេញពីព្រះគម្ពីរ។ គាត់និយាយសំនៀងអ្នកក្រុង នីងប៉ូ យ៉ាងស្ទាត់ជំនាញ ហើយលោក នី បានយល់ពាក្យនីមួយៗដែលគាត់បានអាន។ ប៉ុន្តែ តើវាមានអត្ថន័យយ៉ាងណាទៅ?

«ហើយដែលលោក ម៉ូសេ បានលើកសត្វពស់ឡើងនៅទីរហោស្ថានជាយ៉ាងណា នោះកូនមនុស្សក៏ត្រូវបានលើកឡើងយ៉ាងនោះដែរ…ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជម្រះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ» (យ៉ូហាន ៣:១៤, ១៦-១៧)។

បានសេចក្ដីសង្គ្រោះ មិនមែនត្រូវជំនុំជម្រះទេ មាគ៌ាចូលទៅកាន់ជីវិតអស់កល្បជានិច្ចៈ ព្រះដែលស្រឡាញ់មនុស្សលោក «កូនមនុស្ស» មិនមែនសត្វពស់ ដែលបានលើកឡើង តើទាំងអស់នេះនិយាយអំពីអ្វី?

លោក នី ស្ទើរតែមិនអាចបង្ហាញពីចំណាប់អារម្មណ៍ដ៏អស្ចារ្យរបស់គាត់។ គាត់បានសញ្ជឹងគិតអំពីរឿងរបស់សត្វពស់នៅទីរហោស្ថាន ជាសញ្ញាតំណាងឲ្យដំណោះស្រាយ

របស់ព្រះជាម្ចាស់ចំពោះអំពើបាប និងផលប៉ះពាល់ដ៏ធ្ងន់ធ្ងររបស់វា ហើយជាសញ្ញាតំណាងពីជីវិត ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ គាត់បានឃើញមានការជាប់ទាក់ទងគ្នាទៅនឹងអ្វីដែលគាត់ផ្ទាល់ត្រូវការ គ្រប់ទាំងអស់បានបើកសម្ដែងដល់គាត់ប្រកបដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ពិតណាស់ វាគឺជាការអស្ចារ្យនៃសម័យកាល ហើយអរព្រះគុណព្រះ វានៅតែបន្តកើតឡើង។ «ឯខ្ញុំ បើសិនជាខ្ញុំត្រូវលើកពីដីឡើង នោះខ្ញុំនឹងទាញមនុស្សទាំងអស់មកឯខ្ញុំ» (យ៉ូហាន ១២:៣២)។

ការប្រជុំគ្នាកំពុងជិតបញ្ចប់។ គ្រូបង្រៀនបរទេសបានឈប់និយាយ។ ដោយធ្លាប់ដឹកនាំនៅក្នុងស្ថានភាពបែបនេះ លោក នី បានក្រោកឈរនៅកន្លែងរបស់គាត់ ហើយសម្លឹងទៅអ្នកស្ដាប់ទាំងឡាយ រួចនិយាយចំៗថា៖

«ខ្ញុំបានស្វែងរកសេចក្ដីពិតអស់រយៈពេលជាយូរណាស់មកហើយ ប៉ុន្តែរកមិនឃើញសោះ។ ខ្ញុំបានធ្វើដំណើរយ៉ាងឆ្ងាយ ហើយរកមើលគ្រប់ទីកន្លែងតែមិនបានជោគជ័យទេ។ ខ្ញុំរកមិនឃើញសេចក្ដីសុខសាន្តនៅលទ្ធិខុងជឺ (Confucianism) ពុទ្ធសាសនា (Buddhism) ឬលទ្ធិតៅ (Taoism) ឡើយ ប៉ុន្តែអ្វីដែលយើងបានលឺយប់នេះបានធ្វើឲ្យខ្ញុំបានស្រាកស្បើយហើយ។ ចាប់ពីពេលនេះតទៅ ខ្ញុំជឿលើព្រះយេស៊ូវ»។

គាត់បានក្លាយជាសិស្សថ្នាក់សិក្សាព្រះគម្ពីរដ៏ឆេះឆួលម្នាក់ ហើយចំណេះដឹងរបស់គាត់ និងព្រះគុណបានរីកចម្រើនគួរឲ្យកត់សម្គាល់។ មិនយូរប៉ុន្មាន បន្ទាប់ពីការប្រែចិត្តគាត់ទទួលបានការអនុញ្ញាតឲ្យនិយាយនៅក្នុងការប្រជុំមួយនៅសមាគមដែលគាត់ធ្លាប់បានដឹកនាំ។ លោកគ្រូ ថេល័រ បានទៅជាមួយគាត់ ពិតជាមានការចាប់អារម្មណ៍ជាខ្លាំងចំពោះការធ្វើបទបង្ហាញដ៏ច្បាស់ និងលម្អិតរបស់គាត់អំពីដំណឹងល្អ។ អតីតកូនសិស្សម្នាក់របស់គាត់បានប្រែចិត្តជឿលើព្រះយេស៊ូវ តាមរយៈទីបន្ទាល់របស់គាត់ ហើយលោក នី បានចាប់ផ្ដើមស្គាល់សេចក្ដីអំណរក្នុងការដែលបាននាំអ្នកដទៃឲ្យមានសេចក្ដីជំនឿលើព្រះយេស៊ូវ។

ថ្ងៃមួយនៅពេលដែលគាត់កំពុងនិយាយជាមួយសំឡាញ់ជាបេសកជនរបស់គាត់ លោក នី បានសួរសំណួរមួយដោយស្មានមិនដល់ថា៖ «តើដំណឹងល្អបានចូលមកក្នុងប្រទេសរបស់អ្នកយូរប៉ុណ្ណាហើយ?»។ លោកគ្រូ ហ័ដសិន បានឆ្លើយទាំងស្ទាក់ស្ទើរថា៖ «រាប់រយឆ្នាំមកហើយ»។ ថាម៉េច? រាប់រយឆ្នាំមកហើយ? គាត់បានបន្តទាំងក្រៀមក្រំថា៖

“ឪពុករបស់ខ្ញុំបានស្វែងរកសេចក្តីពិត ហើយបានស្លាប់ទាំងរកវាមិនទាន់ឃើញ។ អូហ៍! ហេតុអ្វីអ្នកមិនមកឲ្យបានឆាប់ជាងនេះ?”។ វាជាពេលដ៏ឈឺចាប់ដែលលោកគ្រូ ហ័ដសិន ថេល័រ មិនអាចបំភ្លេចបាន ហើយការនោះក៏បានបង្កើនការប្តេជ្ញាចិត្តនៅក្នុងការប្រាប់អស់អ្នកដែលមិនទាន់បានស្គាល់ព្រះគ្រីស្ទដែលនៅអាចឈោងចាប់បានផងដែរ។

តម្រូវការនៃភាពអត់ធ្មត់ គឺចាំបាច់ណាស់នៅពេលនោះ ដើម្បីកុំឲ្យប្រញាប់ធ្វើអ្វីមុនព្រះវិញ្ញាណបរិសុទ្ធ ក្នុងការជួលពួកអ្នកជំនួយពេញម៉ោងដើម្បីធ្វើការ។ នៅពេលនោះបេសកជនវ័យក្មេងមិនទាន់មានសហការីជាជនជាតិចិននៅឡើយ។ លោក នី ពិតជាបានលះបង់ពេលវេលាទំនេរពីមុខជំនួញរបស់គាត់ ព្រមទាំងលោក ណេង-ខួយ (Mr. Neng-kuei) ដែលជាអ្នកធ្វើកន្ត្រក លោក វ៉ាង (Wang) ដែលជាកសិករមកពីស្រុក ហូសី (Hosi) និងលោក ស៊ុយ (Tsiu) ដែលជាគ្រូបង្រៀន ព្រមទាំងម្តាយគាត់ដែលមានចិត្តឆេះឆួលរបស់គាត់។ ប៉ុន្តែ ពួកគេមានភាពមមាញឹកនឹងការងារពេលថ្ងៃក្តី ទោះបីជាពួកគេឆ្លៀតមកផ្ទះព័ន្ធកិច្ចនៅពេលល្ងាច ហើយបានចំណាយពេលជាច្រើននៅទីនោះរាល់ថ្ងៃអាទិត្យក៏ដោយ។ វាងាយស្រួលនៅក្នុងការជួលគ្រូបង្រៀនគ្រីស្ទបរិស័ទសម្រាប់សាលារបស់លោកស្រី ថេល័រ ជាកន្លែងដែលគាត់ធ្វើការច្រើនម៉ោងជារៀងរាល់ថ្ងៃ ឬក៏ជួលអ្នកផ្សេងឲ្យធ្វើ ដោយប្រាក់បៀវត្សសមរម្យ ដើម្បីរៀបចំពួកគេសម្រាប់តួនាទីដ៏មានប្រយោជន៍។ ទោះបីជាយ៉ាងណា ពួកបេសកជនទាំងពីរនេះយល់ច្បាស់ថា វិធីនេះនឹងបណ្តាលឲ្យមានផលប៉ះពាល់មិនល្អជាជាងផលល្អ។ ការជួលពួកអ្នកជឿដែលវ័យក្មេងក្នុងជំនឿឲ្យជួយផ្សាយដំណឹងល្អមិនថាពួកគេស្មោះត្រង់ផ្សាយដំណឹងល្អប៉ុណ្ណាទេ—ជាពិសេសប្រើប្រាក់ពីប្រភពបរទេស—ទំនងនឹងបណ្តាលឲ្យឥទ្ធិពលពួកគេ ឬសូម្បីតែចរិតលក្ខណៈជាគ្រីស្ទបរិស័ទរបស់ពួកគេចុះខ្សោយ។ ពេលនោះនឹងត្រូវមកដល់ នៅពេលនោះគ្រប់គ្នានឹងដឹងច្បាស់លាស់ថា ព្រះជាម្ចាស់បានត្រាស់ហៅពួកគេ ហើយនៅពេលនោះនឹងមានគ្រីស្ទបរិស័ទស្ម័គ្រចិត្តគាំទ្រពួកគេ។ តើប្រទេសចិននឹងទទួលដំណឹងល្អតាមណា បើមិនមែនតាមរយៈក្រុមជំនុំជនជាតិចិននោះ? ហើយតើអ្នកប្រែចិត្តជឿមានបទពិសោធន៍ក្នុងសេចក្តីអំណរនៃការបម្រើដោយស្ម័គ្រចិត្ត និងមិនទទួលប្រាក់កម្រៃដែលចេញពីសេចក្តីស្រឡាញ់សម្រាប់ព្រះគ្រីស្ទបានដោយរបៀបណា លុះត្រាតែពួកបេសកជនចេះអត់ធ្មត់ និងរង់ចាំសម្រាប់ការរីកចម្រើនខាងព្រលឹងវិញ្ញាណសិន?

លោកគ្រូ ហ៉ាដសិន ថេល័រ និងសហការីបានពេញដោយអំណរនៅក្នុងការបម្រើរបស់ពួកគាត់ ទន្ទឹមនឹងមើលឃើញអ្នកប្រែចិត្តជឿថ្មីៗបានចម្រើនធំធាត់នៅជុំវិញពួកគាត់។ គាត់បានធ្វើការវេជ្ជសាស្ត្របន្តិចបន្តួចស្រប ពេលជាមួយនឹងការបង្រៀននៅតាមដងផ្លូវនានា និងនៅកន្លែងថ្វាយបង្គំ ស្វាគមន៍ភ្ញៀវ ទទួលខុសត្រូវផ្នែកទំនាក់ទំនង ហិរញ្ញវត្ថុ និងរៀបចំការធ្វើដំណើរផ្សាយដំណឹងល្អ។ យ៉ាងណាមិញ គាត់មិនបណ្ដោយឲ្យមានអ្វីមករំខានកិច្ចការសំខាន់ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងប្រចាំថ្ងៃជាមួយគ្រីស្ទបរិស័ទ និងអស់អ្នកដែលចង់រៀនបន្ថែមទៀតនោះទេ។

វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ដែលអ្នកប្រែចិត្តជឿបានរីកចម្រើននៅក្នុងព្រះគុណ និងចំណេះដឹងនៅក្នុងព្រះជាម្ចាស់ដោយសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់ចំពោះពួកគេដោយពួកបេសកជន។ រាល់ល្ងាច ហើយបន្ទាប់ពីការជួបជុំជាលក្ខណៈសាធារណៈ ពួកបេសកជននិងពួកគេបានចំណាយពេលជួបគ្នាបីដងដើម្បីសិក្សាមេរៀនដែលត្រូវបានរៀបចំយ៉ាងយកចិត្តទុកដាក់។ ដំបូង ពួកគេបានបង្រៀនមេរៀនមួយចេញពីព្រះគម្ពីរសញ្ញាចាស់ ដែលជាមេរៀនដែលលោកគ្រូ ហ៉ាដសិន ថេល័រ រីករាយក្នុងការពន្យល់មេរៀនខាងព្រះវិញ្ញាណនេះ។ បន្ទាប់មក សម្រាកបន្តិច រួចពួកគេអានអត្ថបទមួយជំពូកដែលដកស្រង់ចេញពីសៀវភៅ “ផ្លូវស្ថានសួគ៌” (Pilgrim's Progress ) ឬក៏សៀវភៅដែលមានប្រយោជន៍ផ្សេងទៀត។ ចុងក្រោយ ពួកគេបានពិភាក្សាលើអត្ថបទនៃព្រះគម្ពីរសញ្ញាថ្មី ដើម្បីយកទៅអនុវត្តក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ទម្លាប់នេះបានកើតជារៀងរាល់យប់ រហូតទៅដល់ការថ្វាយបង្គំថ្ងៃអាទិត្យ និងការឈោងចាប់អ្នកមិនទាន់ជឿផងដែរ។

ថ្ងៃអាទិត្យក៏មានពេលបង្រៀនផងដែរ។ ពួកគ្រីស្ទបរិស័ទបានធ្វើការលះបង់គួរឲ្យកត់សម្គាល់ ពួកគេបិទតូប និងហាងនានា ដោយបានលះបង់មួយភាគប្រាំពីរនៃការបើកមុខជំនួញរបស់ពួកគេ។ យ៉ាងណាមិញ លោកគ្រូ ហ៉ាដសិន ថេល័រ និងសហការីជឿជាក់ថា ក្រុមជំនុំដែលរឹងមាំ និងអាចផ្គត់ផ្គង់ខ្លួនឯងបានមិនអាចបង្កើតឡើងដោយពឹងផ្អែកលើមូលដ្ឋានណាផ្សេងទៀតឡើយ។ ពួកគេបានប្ដេជ្ញាចិត្តនឹងធ្វើឲ្យការលះបង់ទាំងពេលវេលាចំពោះព្រះជាម្ចាស់នេះពេញដោយសកម្មភាពដែលមានភាពរីកចម្រើន និងអំណរ។ ពួកគេបានរៀបចំការថ្វាយបង្គំ ហើយបានបែងចែកពួកគ្រីស្ទបរិស័ទជាក្រុមអ្នកស្វែងយល់ អ្នកជំងឺ ក្មេងៗសិស្សសាលា និងអ្នកបម្រើជាថ្នាក់ៗ សម្រាប់ការចូលរួម និងការណែនាំ

ផ្ទាល់ខ្លួនជាទៀងទាត់។ ការនេះបានធ្វើឲ្យថ្ងៃអាទិត្យជាថ្ងៃមួយដែលបេសកជនបួននាក់នោះត្រូវចំណាយកម្លាំងកាយច្រើនក្នុងការបម្រើ។ ទោះបីជាពួកគេត្រូវធ្វើការនឿយហត់ និងអស់កម្លាំងក៏ដោយ ក៏ពួកគេអាចយល់កាន់តែច្បាស់អំពីការលះបង់របស់អ្នកជឿ។ អ្នកជឿថ្មីខ្លះបានដើរចម្ងាយដ៏ឆ្ងាយ ហើយគ្មានអាហារអស់មួយថ្ងៃ ទន្ទឹមនឹងនោះ អ្នកផ្សេងទៀតបានប្រឈមនឹងការបៀតបៀន និងការបាត់បង់ផ្ទាល់ខ្លួនផងដែរ។ បើទោះបីជាមានការលះបង់ច្រើនក៏ដោយ ក៏ពួកគេភាគច្រើនបានស្ម័គ្រចិត្តទ្រាំទ្រនឹងវា ដើម្បីបានឱកាសថ្វាយបង្គំនៅថ្ងៃនៃព្រះអម្ចាស់ ដោយការទទួលស្គាល់ពីផលវិជ្ជមានដែលកើតមានពេញមួយសប្តាហ៍។

ក្រុមជំនុំក៏ចម្រើនឡើង ពួកបេសកជនកាន់តែមានភាពពេញវ័យ ហើយឱកាសនៃការចាប់ផ្តើមព័ន្ធកិច្ចថ្មីក៏បានបើកចំហឲ្យពួកគេ។ សន្ធិសញ្ញារបស់ទីក្រុងទៀនស៊ីន (The Treaty of Tientsin) បានចុះហត្ថលេខានៅរដូវក្តៅក្រោយការរៀបអាពាហ៍ពិពាហ៍របស់លោកគ្រូ ហ៍ដសិន ថេល័រ ទីបំផុតបានបើកទឹកដីខេត្តដីគោកទាំងអស់។ ឥឡូវនេះ ពួកជនបរទេសមានសិទ្ធិធ្វើដំណើរដោយមានការការពារ ដោយគ្រាន់ប្រើលិខិតឆ្លងដែន។ ដូច្នេះ ឥឡូវនេះពួកគេអាចទៅ និងប្រើប្រាស់ទីកន្លែង ដែលពួកគេបានអធិស្ឋាន ហើយរង់ចាំអស់ពេលជាយូរមកហើយ។

លោកគ្រូ ហ៍ដសិន ថេល័រ បានសរសេរនៅខែវិច្ឆិកាថា៖ “អ្នកម្តាយប្រហែលជាបានឮអំពីសន្ធិសញ្ញាថ្មីហើយ។ យើងអាចនឹងខ្វះបេសកជននៅទីក្រុងនីងប៉ូ ដោយខ្លះនឹងត្រូវឡើងទៅដីគោក។ អូហ៍ ហើយតើក្រុមជំនុំនៅស្រុកយើងមិនបានភ្ញាក់ឡើង ហើយបញ្ជូនគ្នាយើងមកច្រើនទៀត ដើម្បីផ្សាយដំណឹងល្អទេឬ?

មានមនុស្សច្រើននាក់ក្នុងចំណោមយើងពិតជាចង់ទៅណាស់ ប៉ុន្តែកាតព្វកិច្ច និងចំណងបានរារាំង មានតែព្រះអម្ចាស់ប៉ុណ្ណោះអាចស្រាយឲ្យយើងបាន។ សូមឲ្យព្រះជាម្ចាស់ប្រទានសមត្ថភាពដល់អ្នកជឿជាជនជាតិដើម រៀបចំពួកគេសម្រាប់ការគ្រប់គ្រងក្រុមជំនុំដែលមានរួចហើយ ប្រយោជន៍ឲ្យយើងអាចចាប់ផ្តើមក្រុមជំនុំថ្មីៗទៀតបាន។

ពួកគេមានអារម្មណ៍ថា មានបន្ទុកនៅក្នុងដួងចិត្តនៅក្នុងការបង្កើតក្រុមជំនុំមួយដែលអាចរីកចម្រើន និងផ្គត់ផ្គង់ខ្លួនឯងបានដោយព្រះពររបស់ព្រះជាម្ចាស់។ ពួកគេមិនអាចព្រងើយកន្តើយចំពោះក្រុមអ្នកជឿតូចៗ ដែលនៅតែត្រូវការពួកគេដូចជាឪពុកម្តាយខាង

ព្រលឹងវិញ្ញាណឡើយ។ ព្រះបានប្រគល់អ្នកជឿថ្មីទាំងនេះឲ្យពួកគាត់ថែរក្សា និងអធិស្ឋានឲ្យ បើលាចាកពួកគេសម្រាប់ផលប្រយោជន៍របស់អ្នកផ្សេងទៀត ដែលនេះមានន័យថាជាការធ្វេសប្រហែសនូវទំនួលខុសត្រូវធំបំផុតនៃការថែទាំរបស់ឪពុកម្តាយ។ ភាពជឿជាក់របស់ពួកគាត់គឺពិតជាត្រឹមត្រូវ ដូចដែលអនាគតបានបង្ហាញយ៉ាងច្បាស់មែន។

គ្រីស្ទបរិស័ទទាំងនេះ មានលោក នី លោក ណោង ខួយ លោក វ៉ាង និងអ្នកដទៃទៀតជាមនុស្សដែលព្រះអាចប្រើប្រាស់បាន។ បើទោះបីជាពួកគេក្រីក្រ និងខ្វះការអប់រំ ក៏ពួកគេបានក្លាយជា "អ្នកនេសាទមនុស្ស" ដែរ។ យ៉ាងហោចណាស់មនុស្សប្រាំមួយ ឬប្រាំពីរនាក់ក្នុងចំណោមអ្នកប្រែចិត្តជឿដំបូងៗទាំងនេះបានជួយអ្នកដឹកនាំជាទីស្រឡាញ់របស់ពួកគេនៅក្នុងពេលឆ្នាំដំបូងៗនៃអង្គការបេសកកម្មនៅចិនដីគោក។ បើគ្មានជំនួយពីពួកគេទេ គម្រោងថ្មីនឹងមិនអាចជោគជ័យបានឡើយ។ វាពិបាកនៅក្នុងការបញ្ជាក់ពីផលប៉ះពាល់នៃការខិតខំធ្វើការខ្លាំងនៅផ្លូវស្ពាននាពេលនោះ។ ពួកបេសកជនបានពង្រឹងកូនៗនៃសេចក្តីជំនឿរបស់ពួកគេ ហើយក៏គ្មានវិធីណាប្រសើរជាងនេះនៅក្នុងការបន្តព្រះពរខាងព្រលឹងវិញ្ញាណនោះឡើយ»។

នៅកំឡុងពេលនៃការអបអរចម្រូតទាំងឡាយ លោកគ្រូ ហ័ដសិន ថេល័រ បានជួបនឹងសេចក្តីទុក្ខសោកថ្មី ហើយស្មានមិនដល់ ដែលបានតម្រូវឲ្យគាត់ត្រូវទទួលយកកាតព្វកិច្ចថ្មី។ នៅទល់មុខទីលំនៅ លោកវេជ្ជបណ្ឌិត ផាកខ័រ ទើបតែបានបញ្ចប់ការសាងសង់មន្ទីរពេទ្យថ្មី។ ទីតាំងដ៏ល្អប្រសើរនៅទ្វារក្រុង ហើយមានទេសភាពមាត់ទន្លេ អគារធំទូលាយបានធ្វើឲ្យមនុស្សរាប់ពាន់នាក់មានការចាប់អារម្មណ៍ជារៀងរាល់ថ្ងៃ។ មន្ទីរពេទ្យត្រូវបានរចនាយ៉ាងល្អឥតខ្ចោះ ដើម្បីបំពេញតម្រូវការសហគមន៍ ដែលលោកវេជ្ជបណ្ឌិត ផាកខ័រ បានខិតខំអភិវឌ្ឍន៍អស់ជាច្រើនឆ្នាំ។ យ៉ាងណាមិញ ផ្ទះរបស់លោកវេជ្ជបណ្ឌិតមានសេចក្តីទុក្ខសោកជាទម្ងន់ ដោយព្រោះគាត់កំពុងតែទួញសោកក្នុងការបាត់បង់ប្រពន្ធជាទីស្រឡាញ់របស់គាត់ភ្លាមៗ ដែលបានទទួលមរណភាពក្រោយពីបានឈឺក្នុងរយៈពេលខ្លីដោយបន្សល់ទុកនូវកូនតូចៗបួននាក់ ហើយម្នាក់កំពុងឈឺធ្ងន់ថែមទៀត។ លោកវេជ្ជបណ្ឌិត ផាកខ័រ បានដឹងថា គាត់ត្រូវតែយកកូនៗត្រឡប់ទៅប្រទេសស្កុតឡែនវិញ។ ប្រសិនបើគាត់គួរតែត្រឡប់ទៅស្កុតឡែនវិញ តើនឹងមានអ្វីកើតឡើងចំពោះមន្ទីរពេទ្យព្រោះបន្ទប់អ្នកជំងឺនានាពេញដោយអ្នកជំងឺ ហើយបន្ទប់ពេទ្យមមាញឹក មនុស្សជាច្រើន

ត្រូវការថែទាំខាងវេជ្ជសាស្ត្រជារៀងរាល់ថ្ងៃ។ ដោយសារគ្មានវេជ្ជបណ្ឌិតណាផ្សេងទៀតទំនេរ អាចចូលមកបំពេញកន្លែងគាត់បាន ហើយរដូវរងាក៏កាន់តែខិតចូលមកដល់ ការបិទមន្ទីរពេទ្យវាហាក់បីដូចជាមិនអាចស្រមៃបានឡើយ។ បើទោះបីជាគ្មានប្រាក់មូលនិធិនៅសល់សម្រាប់មន្ទីរពេទ្យក៏ដោយ ដោយសារប្រាក់កម្រៃបានមកពីការព្យាបាលអ្នកជំងឺនៅគ្លីនិកឯកជនរបស់គាត់ក៏គាត់សង្ឃឹមថា យ៉ាងហោចណាស់សហការីចាស់របស់គាត់៖ លោកគ្រូ ហ័ដសិន ថេល័រ អាចនឹងបន្តបើកដំណើរការបន្ទប់ព្យាបាលបានដែរ។ ដូច្នេះគាត់បានស្នើការដែលឥតបានព្រៀងទុកនេះទៅលោកគ្រូ ថេល័រ។

បន្ទាប់ពីបានរង់ចាំការដឹកនាំពីព្រះអម្ចាស់ លោកគ្រូ ហ័ដសិន បានចងចាំពីការជំរុញពីព្រះជាម្ចាស់ក្នុងការទទួលមើលខុសត្រូវមិនត្រឹមតែបន្ទប់ព្យាបាលប៉ុណ្ណោះទេ តែក៏ត្រូវទទួលយកមន្ទីរពេទ្យទាំងមូលផងដែរ ដោយទុកចិត្តទាំងស្រុងលើព្រះដែលឆ្លើយតបចំពោះការអធិស្ឋានក្នុងការប្រទានជំនួយដែលចំបាច់។

ជួនកាលមានអ្នកជំងឺក្នុងមន្ទីរពេទ្យច្រើនរហូតដល់ហាសិបនាក់ រួមជាមួយអ្នកជំងឺដទៃទៀតនៅបន្ទប់ព្យាបាល។ តាមធម្មតា គ្រែសាមសិបត្រូវបានបម្រុងទុកសម្រាប់ពួកអ្នកជំងឺឥតបង់ប្រាក់ និងអ្នកមកជាមួយពួកគេ ហើយប្រហែលមានអ្នកជក់អាភៀនចំនួនដូចគ្នាដែលបង់ប្រាក់សម្រាប់ថ្លៃស្នាក់នៅរបស់ពួកគេ នៅខណៈពេលដែលកំពុងព្យាយាមផ្តាច់ការញៀន។ មន្ទីរពេទ្យផ្គត់ផ្គង់គ្រប់តម្រូវការទាំងអស់ដល់អ្នកជំងឺដោយឥតបង់ប្រាក់ រួមទាំងការផ្គត់ផ្គង់បរិក្ខារពេទ្យសម្រាប់អ្នកមកព្យាបាលនៅផ្នែកអ្នកជំងឺមិនសម្រាកយប់ក្នុងមន្ទីរពេទ្យ ដែលនេះធ្វើឲ្យថ្លៃចំណាយប្រចាំថ្ងៃយ៉ាងច្រើន។ មន្ទីរពេទ្យក៏ត្រូវការចូលរួមចំណែកជួយបង់ប្រាក់ឈ្នួលអ្នកឆ្នាំ ដើម្បីអាចដំណើរការទៅមុខ។ រហូតមកដល់ពេលនេះ ការព្យាបាលរបស់អ្នកជំងឺជនបរទេសបានផ្តល់មូលនិធិដែលចាំបាច់ ប៉ុន្តែដោយសារតែការចាកចេញរបស់លោកវេជ្ជបណ្ឌិត ផាកឌ័រ ប្រភពនៃប្រាក់ចំណូលនេះក៏ត្រូវបានបញ្ចប់ដែរ។ បើទោះជាយ៉ាងណាក្តី តើព្រះមិនបានសន្យាទេឬថា អ្វីដែលយើងទូលសូមនៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវនឹងបានសម្រេច (យ៉ូហាន ១៤:១៣)? ហើយតើយើងមិនបានលើកទឹកចិត្តឲ្យផ្តល់អាទិភាពលើការស្វែងរកនគរព្រះជាម្ចាស់ជាមុនសិន គឺមិនមែនជាស្វែងរកមធ្យោបាយ ដើម្បីពង្រីកនគរព្រះទេ ដោយដឹងប្រាកដថា «គ្រប់ទាំងអស់» នឹងត្រូវប្រទានមកទេឬអី (ម៉ាថាយ ៦:៣៣)? ព្រះបន្ទូលសន្យាទាំងនេះល្មមសម្រាប់

យើងជឿទុកចិត្តបាន។

បេសកជនក្មេងៗនោះមិនបានព្រួយបារម្ភចំពោះស្ថានភាពដែលស្មានមិនដល់ ដែលមិត្តរបស់គេនៅឯស្រុកកំណើតមិនបានគិតថា រឿងនេះនឹងកើតឡើងនោះឡើយ ហើយត្រូវចំណាយពេលរាប់ខែ ដើម្បីទទួលការឆ្លើយតបសំបុត្ររបស់ពួកគេ។ ពួកគេពឹងលើព្រះជាម្ចាស់តែម្យ៉ាងគត់ចំពោះការផ្គត់ផ្គង់ ហើយទ្រង់ក៏មិនឲ្យពួកគេខកចិត្តដែរ។ គន្លឹះនៃសេចក្ដីជំនឿដែលត្រៀមរួចជាស្រេចសម្រាប់គ្រាអាសន្នគឺជាការមានចិត្តស្ងប់ ទុកចិត្តលើព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ដែលនាំទ្រង់ចូលមកជិតដួងចិត្តអ្នកជឿ។

លោកគ្រូ ថេល័រ បានសរសេរថា ប្រាំបីថ្ងៃមុនពេលគាត់បានចាប់ផ្ដើមគ្រប់គ្រងមន្ទីរពេទ្យនៅទីក្រុងនីងប៉ូ ប្រាកដណាស់គាត់មិនបានដឹងទេថា គាត់នឹងត្រូវធ្វើដូច្នេះ ហើយមិត្តភក្តិនៅស្រុកកំណើតរបស់គាត់ក៏នឹកស្មានមិនដល់ដែរ។

ប៉ុន្តែព្រះអម្ចាស់បានជ្រាបជាមុនអំពីការនោះ ហើយហេតុការណ៍នឹងបង្ហាញយ៉ាងជាក់ច្បាស់។

នៅពេលក្រុមជំនួយការរបស់លោកវេជ្ជបណ្ឌិត ផាកខ័រ បានដឹងថា មូលនិធិនៅមានសម្រាប់តែការចំណាយនៅខែនោះ និងខែក្រោយ ហើយថាការអធិស្ឋាននឹងជាជម្រើសតែមួយគត់ ពួកគេបានសម្រេចចិត្តចាកចេញ ហើយទុកកន្លែងសម្រាប់អ្នកធ្វើការដទៃទៀត។ នេះគឺជាការផ្លាស់ប្ដូរ ដែលលោកវេជ្ជបណ្ឌិត ផាកខ័រ ចង់បានក្នុងពេលដ៏យូរ ប៉ុន្តែមិនបានដឹងថា ត្រូវទទួលបានអ្នកជួយផ្សេងទៀតមកជួយដោយរបៀបណាទេ។ លោកគ្រូ ហ៊ដសិន ថេល័រ បានដឹងអំពីរបៀបទាក់ទាញអ្នកជួយផ្សេងទៀត ហើយបានចូលទៅជិតពួកគ្រីស្ទបរិស័ទដែលគាំទ្រគាត់នៅផ្លូវស្ពាន។ ពួកគេបានទុកចិត្តព្រះជាម្ចាស់សម្រាប់ទាំងតម្រូវការខាងរូបកាយ និងព្រលឹងវិញ្ញាណរបស់ពួកគេដូចធម្មតា ដូចដែលគ្រូរបស់ពួកគេបានរំឭកជារឿយៗថា ព្រះវរបិតាដ៏ស្រឡាញ់ និងល្អ មិនអាចបំភ្លេចតម្រូវការរបស់កូនៗទ្រង់បានឡើយ។ ពួកគេបានទៅមន្ទីរពេទ្យដោយស្ម័គ្រចិត្ត ដើម្បីគាំទ្រពួកបេសកជន ហើយបានបង្ហាញពីភាពស្មោះត្រង់របស់ព្រះជាម្ចាស់។ ពួកគេក៏បានចូលរួមដោយមធ្យោបាយផ្សេងៗ អ្នកខ្លះធ្វើការតាមពេលណាដែលគេអាចជួយបាន អ្នកខ្លះទៀតធ្វើការពេញម៉ោងដោយមិនមានការសន្យាថា នឹងទទួលប្រាក់ឈ្នួលឲ្យ ប៉ុន្តែក៏នៅតែទទួលបានការផ្គត់ផ្គង់ដែរ។ ពួកគេក៏បានប្ដេជ្ញា ដើម្បីអធិស្ឋាន អំពីសេចក្ដីតម្រូវការ

ផ្សេងៗរបស់មន្ទីរពេទ្យ។

ដំបូងៗ អ្នកជំងឺមិនអាចពន្យល់បានទេថា ហេតុអ្វីបរិយាកាសថ្មីបានចាប់ផ្តើមនៅបន្ទប់ពិគ្រោះជំងឺ និងសាលជំងឺឡើយ ប៉ុន្តែពួកគេមិនដែលស្រាកស្រាន្តពីសេចក្តីអំណររីករាយទេ ដោយមានអារម្មណ៍ថារាក់ទាក់ដូចជាផ្ទះ និងមានសេចក្តីសាទរចំពោះអ្វីដែលបានធ្វើ។ ពីមួយថ្ងៃទៅមួយថ្ងៃពេញដោយការចាប់អារម្មណ៍។ ក្រុមការងារដូចជាលោក វ៉ាង ជាអ្នកកាត់ស្មៅ លោក វ៉ាង ជាអ្នកគូរគំនូរ លោក នី លោក ណេង ខួយ ព្រមទាំងអ្នកផ្សេងទៀតវាហាក់បីដូចជាមានអាថ៌កំបាំងចំពោះភាពរីករាយគ្មានទីបញ្ចប់ ព្រមទាំងមានរឿងជាច្រើនទៀតដែលអាចចែករំលែកបាន។ ពួកមានចិត្តសប្បុរស និងចេះគិតគូរចំពោះកិច្ចការនៅសាលព្យាបាល ហើយបានចំណាយពេលទំនេររបស់ខ្លួននិយាយអំពីព្រះមួយអង្គដែលបានផ្លាស់ប្រែនៅក្នុងជីវិត និងត្រៀមខ្លួនរួចជាស្រេចនៅក្នុងការស្វាគមន៍ដល់អស់អ្នកណាដែលបានស្វែងរកទ្រង់ពីការសម្រាក។ មានសៀវភៅ រូបភាព  និងការច្រៀងដែលបានបង្កើតគ្រប់យ៉ាងលាន់រំពងដូចជាចម្រៀងមួយបទ។ ការប្រជុំប្រចាំថ្ងៃនៅក្នុងបន្ទប់ថ្វាយបង្គំធ្វើឲ្យអ្នកដែលចូលរួមប្រាថ្នាចង់បានបន្ថែមទៀត។

មានតែរឿងអាថ៌កំបាំងតិចតួចដែលកើតឡើងនៅប្រទេសចិន ហើយដំណើរការហិរញ្ញវត្ថុមន្ទីរពេទ្យត្រូវបានគេទាំងអស់ដឹង។ អ្នកជំងឺបានដឹងយ៉ាងឆាប់រហ័សអំពីស្ថានភាព និងមានចិត្តអន្ទះសាចង់ដឹងថា តើនឹងមានអ្វីកើតឡើងចំពោះមន្ទីរពេទ្យនេះ។ ពួកគេមានរឿងរ៉ាវជាច្រើន ដើម្បីគិត និងនិយាយអំពីការនោះ នៅពេលដែលមូលនិធិរបស់លោកវេជ្ជបណ្ឌិត ផាកខ័រ បានអស់ ហើយប្រាក់បម្រុងរបស់លោកគ្រូ ហ័ដសិន ថេល័រ ក៏បានថយចុះ ដោយធ្វើឲ្យមនុស្សជាច្រើនបានធ្វើការសន្និដ្ឋានផ្សេងៗថា នឹងមានអ្វីកើតឡើងបន្ទាប់ទៀត។ ពិតមែនហើយ ក្នុងកំឡុងពេលនេះលោកគ្រូ ហ័ដសិន ថេល័រ និងក្រុមដ៏តូចរបស់គាត់បានឆ្លើយតបដោយការអធិស្ឋានឥតឈប់ឈរ។ ការប្រឈមនេះប្រហែលជាកាន់តែជាក់ស្តែង និងសំខាន់បំផុតជាងអ្វីដែលគាត់បានជួបពីមុនមក ដោយមិនគ្រាន់តែជារឿងអនាគតមន្ទីរពេទ្យប៉ុណ្ណោះទេ ប៉ុន្តែជារឿងទាក់ទងនឹងសេចក្តីជំនឿរបស់មនុស្សជាច្រើននាក់ទៀតផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពីមួយថ្ងៃទៅមួយថ្ងៃបានកន្លងផុតទៅដោយមិនមានការឆ្លើយតបការអធិស្ឋាននោះទេ។ ក្រោយមកនៅព្រឹកមួយ លោក ខួយ ហ័រ ដែលជាចុងភៅ បាននាំដំណឹងដ៏ធ្ងន់ធ្ងរទៅប្រាប់ចៅហ្វាយរបស់គាត់ថា៖ ពួក

គេបានហែកបាវអង្ករចុងក្រោយហើយ ហើយវានឹងអស់យ៉ាងឆាប់រហ័ស។

លោកគ្រូ ហ៊ុដសិន ថេល័រ បានឆ្លើយថា៖ «អញ្ចឹង វាត្រូវតែជិតដល់ពេលដែលព្រះជាម្ចាស់ជួយយើងហើយ»។ ហើយវាបានក្លាយមកជាការពិត។ មុនពេលដែលពួកគេបានប្រើអង្ករអស់ពីបាវ សំបុត្រមួយក៏បានមកដល់បេសកជនវ័យក្មេង ដែលជារឿងមួយគួរឲ្យអស្ចារ្យបំផុតដែលគាត់ធ្លាប់ជួប។

លោក ប៊ឺកហ្គ័រ (Berger) បានផ្ញើសែកហាសិបផោនមក (ស្មើនឹង $៨.៩៨០,០០ ដុល្លារ បច្ចុប្បន្ននេះ) ដូចជាសែកមុនៗដែរ។ យ៉ាងណា សំបុត្ររបស់គាត់បានពន្យល់ថា គាត់កំពុងមមាញឹកជាមួយនឹងការទំនួលខុសត្រូវចំពោះការទទួលមរតកច្រើនគួរសមដែរ ដោយសារតែការទទួលមរណៈភាពថ្មីៗរបស់ឪពុកគាត់។ ដោយមិនចង់បង្កើនការចំណាយផ្ទាល់ខ្លួន គាត់ក៏បានស្វែងរកការដឹកនាំពីព្រះអំពីរបៀបចាត់ចែងទ្រព្យសម្បត្តិនេះសម្រាប់កិច្ចការព្រះ។ លោក ប៊ឺកហ្គ័រ បានសួរមិត្តសម្លាញ់នៅប្រទេសចិនរបស់គាត់ថា តើពួកគេអាចជួយគាត់កំណត់ពីរបៀបចាត់ចែងមូលនិធិឲ្យមានប្រសិទ្ធភាពបានដោយរបៀបណា។ គាត់បានបញ្ចូលគ្រោងសម្រាប់តម្រូវការភ្លាមៗរបស់ពួកគេ ហើយបានស្នើសុំការឆ្លើយតបលម្អិតមួយ បន្ទាប់ពីការពិចារណា ដោយការអធិស្ឋានលើការដែលអាចប្រើប្រាស់ប្រាក់កាក់កាន់តែមានគុណប្រយោជន៍។

ប្រាក់ហាសិបផោន (ស្មើនឹង $៨.៩៨០,០០ ដុល្លារ បច្ចុប្បន្ន) បានដាក់នៅលើតុ ហើយមិត្តសម្លាញ់ដែលនៅឆ្ងាយរបស់គាត់ ក៏មិនបានដឹងទេអំពីរឿងបាវអង្ករចុងក្រោយ ឬក៏តម្រូវការជាច្រើនទៀតរបស់មន្ទីរពេទ្យឡើយ ហើយក៏ថែមទាំងបានស្នើសុំផ្តល់មូលនិធិបន្ថែមទៀត។ ដោយគ្មានការសង្ស័យលោកគ្រូ ហ៊ុដសិន ថេល័រ មានអារម្មណ៍រំជួលចិត្តក្រៃលែងដោយការដឹងគុណ និងស្ងប់ស្ងែងក្នុងចិត្ត។ សូមស្រមៃថា ប្រសិនបើគាត់មានការស្ទាក់ស្ទើរនៅក្នុងការទទួលយកការគ្រប់គ្រងមន្ទីរពេទ្យ ព្រោះតែមូលនិធិមិនគ្រប់គ្រាន់ ឬខ្វះសេចក្តីជំនឿនោះ។ គាត់អាចនឹងខកខានមិនបានក្លាយជាសក្ខីភាពពីការផ្គត់ផ្គង់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដោយមានព្រះជាម្ចាស់ដ៏មានព្រះចេស្តា និងស្មោះត្រង់ចំពោះសេចក្តីសន្យា យើងមិនគួរខ្វះសេចក្តីជំនឿទេ!

អង្គការកងទ័ពសង្គ្រោះ (Salvation Army) មិនទាន់បានកើតមានឡើងនៅឡើយទេពេលនោះ ប៉ុន្តែការជួបជុំសរសើរតម្កើងនៅក្នុងបន្ទប់ថ្វាយបង្គំគឺដូចគ្នានឹងការចម្រៀង

សរសើរតម្កើង និងការស្រែកឡើងដោយសេចក្តីអំណរដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វាមិនដូចជាការជួបជុំកងទ័ពផ្សេងទេ វាជាការជួបជុំដ៏ខ្លី ដោយសារតែមានអ្នកជំងឺនៅក្នុងសាលព្យាបាល។ ហើយបុរសៗ និងស្ត្រីៗដែលមិនទាន់ជឿដែលស្គាល់តែជីវិតគ្មានន័យ និងអស់សង្ឃឹមបានស្តាប់ដោយយកចិត្តទុកដាក់។

មានមនុស្សជាច្រើនបានសួរ និងមានអារម្មណ៍ថា «តើរូបព្រះដែលអាចធ្វើអ្វីគ្រប់បែបនេះបាននៅឯណា? តើពួកគេធ្លាប់ជួយសង្គ្រោះយើងចេញពីបញ្ហាឬទេ ឬក៏ធ្លាប់ឆ្លើយតបចំពោះការអធិស្ឋានបែបនេះទេ?»។

ជំពូកទី៩

# ឆ្នាំអាថ៌កំបាំង

*អូហ៍ ដើម្បីសង្គ្រោះពួកគេ! ខ្ញុំសុខចិត្តលះបង់ និងបូជាជីវិត ព្រមទាំងស្លាប់សម្រាប់ពួកគេ។*

កិច្ចការដ៏មមាញឹក និងរីករាយនេះ បានជះឥទ្ធិពលយ៉ាងគួរឲ្យកត់សម្គាល់ដល់អស់អ្នកដែលបានចូលរួម។ ក្នុងរយៈពេលប្រាំបួនខែ អ្នកជំងឺដប់ប្រាំមួយនាក់ដែលបានព្យាបាលនៅមន្ទីរពេទ្យ បានទទួលបុណ្យជ្រមុជទឹក ហើយមនុស្សជាងសាមសិបនាក់ផ្សេងទៀតកំពុងត្រៀមខ្លួនចូលរួមថ្វាយបង្គំនៅព្រះវិហារមួយក្នុងចំណោមព្រះវិហារជាច្រើននៅទីក្រុងនីងប៉ូ។ ទោះបីជាយ៉ាងណា បន្ទាប់ពីប្រាំមួយឆ្នាំដ៏មមាញឹកនៅក្នុងប្រទេសចិន បញ្ហាចុះថយខាងសុខភាពរបស់លោកគ្រូ ហ៉ដសិន ថេល័រ ក៏បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ ហើយកម្លាំងរបស់គាត់ក៏កំពុងធ្លាក់ចុះយ៉ាងឆាប់រហ័សដែរ។

លោកគ្រូ ហ៉ដសិន បានសរសេរសំបុត្រទៅលោកឪពុករបស់គាត់ថាៈ «មនុស្សជាច្រើនកំពុងតែជិតស្លាប់ ហើយព្រះជាម្ចាស់កំពុងប្រទានពរដល់កិច្ចការទាំងនេះ តែយើងក៏កាន់តែហត់នឿយ ហើយត្រូវការជំនួយផងដែរ»។

«តើលោកពុកមានស្គាល់បុរសៗវ័យក្មេងដែលមានប្តេជ្ញាចិត្តលះបង់ ព្រមទាំងមានចិត្តឆេះឆួលក្នុងការបម្រើព្រះនៅប្រទេសចិន ជាអ្នកស្វែងរកត្រឹមតែតម្រូវការចំបាច់មួយចំនួនប៉ុណ្ណោះ ហើយស្ម័គ្រចិត្តមកបម្រើនៅទីនេះដែរឬទេ? ខ្ញុំប្រាថ្នាចង់បានអ្នកជួយបែបនេះបួន ឬប្រាំនាក់! ពួកគេអាចចាប់ផ្តើមដូចជាអធិប្បាយជាភាសាចិនក្នុងរយៈពេលប្រាំមួយខែ ហើយមូលនិធិសម្រាប់ការឧបត្ថម្ភរបស់ពួកគេនឹងបានផ្តល់ជូនជាការឆ្លើយតប

នឹងការអធិស្ឋាន»។

មនុស្សកំពុងតែស្លាប់ ប៉ុន្តែព្រះជាម្ចាស់កំពុងប្រទានពរដល់កិច្ចការដែលយើងកំពុងធ្វើ។ រឿងបន្ទាន់ទាំងនេះបានជំរុញឲ្យលោកគ្រូ ហ័ដសិន ថេល័រ ទ្រាំទ្រទាំងនឹងជម្ងឺធ្ងន់ធ្ងរ និងការលោគ្នាដ៏ឈឺចាប់ នៅពេលដែលគាត់ត្រូវត្រឡប់មកផ្ទះនៅទីក្រុងឡុងដ៍វិញដោយសារបញ្ហាសុខភាពនៅក្នុងឆ្នាំ១៨៦០។ រឿងបន្ទាន់ទាំងនេះដែលបានជំរុញឲ្យគាត់បន្តទៅនៅឆ្នាំក្រោយៗមកទៀត នៅពេលដែលវាហាក់បីដូចជាវេជ្ជបណ្ឌិតនិយាយត្រូវអំពីការដែលគាត់មិនអាចមានសុខភាពល្អគ្រប់គ្រាន់ក្នុងការត្រឡប់ទៅប្រទេសចិនវិញទេ។ តម្រូវការដ៏សម្បើមដែលគាត់បានឃើញ ព្រមទាំងស្មារតីទំនួលខុសត្រូវដ៏ធំធេងចំពោះកាតព្វកិច្ចបានបញ្ឆេះភ្លើងដ៏សន្ធោសន្ធៅមួយនៅក្នុងវិញ្ញាណរបស់គាត់ ហើយគ្មានអ្វីអាចបញ្ឈប់គាត់បានឡើយ មិនមែនសុខភាពទ្រុឌទ្រោម មិនមែនខ្វះការលើកទឹកចិត្ត ក៏មិនមែនឧបសគ្គណាផ្សេង អាចបន្ថយការត្រាស់ហៅរបស់គាត់នៅក្នុងការនាំព្រះគ្រីស្ទទៅដល់មនុស្សរាប់លាននាក់ដែលកំពុងត្រូវការទ្រង់នោះទេ។

លោកគ្រូ ហ័ដសិន បានតាំងលំនៅនៅចុងខាងកើតទីក្រុងឡុងដ៍នៅជិតមន្ទីរពេទ្យចាស់របស់គាត់ ហើយក៏អាចបន្តការសិក្សាផ្នែកវេជ្ជសាស្ត្ររបស់គាត់បាន នៅពេលដែលសុខភាពគាត់បានប្រសើរឡើង។ គាត់បានពិនិត្យឡើងវិញនូវកណ្ឌគម្ពីរជាភាសានីងប៉ូជាអក្សររ៉ូម៉ាំង (Romanized Ningpo Testament) សម្រាប់ការបោះពុម្ពថ្មី ដែលសមាគមព្រះគម្ពីរបានយល់ព្រមឲ្យបោះពុម្ពផ្សាយ។ គាត់បានសរសេរសំបុត្រឆ្លើយឆ្លងនឹងបុរសណាដែលគិតគូរអំពីការចូលរួមបម្រើការងារព័ន្ធកិច្ចនៅប្រទេសចិន ហើយជាលទ្ធផលមានបុរសម្នាក់បានទៅចូលរួមជាមួយលោក និងលោកស្រី ចូនស៍ នៅទីក្រុងនីងប៉ូ។ ការចាប់អារម្មណ៍ពីសំណាក់អ្នកដទៃបានថយចុះបន្តិចម្តងៗ ដែលបណ្តាលឲ្យលោក និងលោកស្រី ថេល័រ ព្រមទាំងមិត្តមួយចំនួនរបស់គាត់ឲ្យត្រូវពឹងផ្អែកលើការអធិស្ឋាន និងការអត់ធ្មត់។ នៅអាយុម្ភៃប្រាំបួនឆ្នាំ និងម្ភៃបួនឆ្នាំ វាមិនងាយស្រួលទេក្នុងការចូលមករស់នៅតំបន់ក្រីក្រមួយនៅទីក្រុងឡុងដ៍ ដោយឃ្លាតឆ្ងាយពីការងារដែលពួកគេស្រឡាញ់នៅប្រទេសចិន។ ប៉ុន្តែ ឆ្នាំដ៏លំបាកទាំងនេះ គឺសំខាន់នៅក្នុងការពង្រឹងនិមិត្ត ហើយនឹងកាផេះឆ្អួលដែលជាការចាំបាច់សម្រាប់ការដឹកនាំពេលអនាគតរបស់ពួកគេ។

យើងនឹងបានដឹងតិចតួចណាស់អំពីបទពិសោធន៍របស់ពួកគេអំឡុងឆ្នាំអាថ៌កំបាំង

ទាំងប្រាំឆ្នាំនោះទេ ប្រសិនបើយើងមិនបានរកឃើញសៀវភៅកំណត់ត្រាស្តើងៗដែលពេញដោយអក្សររបស់លោកគ្រូ ហ័ដសិន ថេល័រ នៅក្នុងប្រអប់ឈើចាស់ និងប្រឡាក់ពេញដោយធូលីនោះទេ។ ពួកយើងបានរកឃើញវាម្តងមួយៗនៅក្នុងចំណោមប្រដាប់ប្រដាឈប់ប្រើប្រាស់ចាស់ៗជាច្រើន រហូតដល់យើងអាចរកគ្រប់សៀវភៅកំណត់ត្រាទាំងដប់ពីរភាគ ដោយមិនបាត់មួយភាគសោះឡើយ។ កំណត់ត្រាដ៏ចាស់ទាំងនេះបានបើកបង្ហាញរឿងដែលមិនគួរឲ្យជឿ ដែលជារឿយៗធ្វើឲ្យយើងស្រក់ទឹកភ្នែក។

អត្ថបទដែលមិនបានព្រៀងទុកនេះបង្ហាញអំពីទំនាក់ទំនងដ៏ស៊ីជម្រៅជាមួយព្រះជាម្ចាស់ ហើយនិងការពឹងផ្អែកលើទ្រង់ទាំងស្រុង។ លោកអ្នកអាចរកឃើញពីសេចក្តីជំនឿនៅក្នុងនោះ ដែលបានអនុវត្តសព្វគ្រប់សូម្បីតែតាមព័ត៌មានលម្អិតតូចៗ។ ភាពស្មោះស្ម័គ្រ និងការលះបង់ខ្លួនឯង បាននាំពួកគាត់ឲ្យមកបម្រើកិច្ចការដោយឥតឈប់ឈរ។ ការអធិស្ឋានដោយអត់ធ្មត់ និងការតស៊ូរបស់ពួកគាត់ជាញឹកញាប់ក៏បានជួបនឹងការឆ្លើយតបដ៏អស្ចារ្យផងដែរ។ ប៉ុន្តែ ក៏មានអ្វីលើសនេះទៀតផងដែរដូចជា៖ ការលះបង់ដ៏ធំធេងរបស់ព្រលឹងមួយដែលឆេះឆួលនៅក្នុងតាមព្រះជាម្ចាស់ប្រកិត (ទំនុកតម្កើង ៦៣:៨)។ លោកអ្នកអាចមើលឃើញពីកម្លាំងរបស់មនុស្សម្នាក់ដែលបន្តសាងឡើង នៅពេលដែលគាត់បានជ្រើសរើសរស់នៅដោយសេចក្តីជំនឿ មិនមែនដោយសារអ្វីដែលគាត់មើលឃើញទេ គឺជាការទុកចិត្តដែលមិនអាចថ្លែងបានរបស់មនុស្សណាម្នាក់ដែលបានប្រកាន់ភ្ជាប់នឹងព្រះជាម្ចាស់ ហើយមានតែព្រះអង្គប៉ុណ្ណោះទើបអាចធ្វើឲ្យគាត់បានស្កប់ចិត្តបាន៖ គ្មានអ្វីផ្សេងទៀតឡើយ។

“តែបើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថាមានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់” (ហេព្រើរ ១១:៦)។

ពេលវេលាពេញដោយភាពស្ងៀមស្ងាត់ កិច្ចការធម្មតាលាយនឹងការលំបាក និងសេចក្តីអំណរជាច្រើនខុសៗគ្នា។ កូនស្រីតូចដែលបាននាំសេចក្តីអំណរដ៏ច្រើននៅទីក្រុងនីងប៉ូពេលនេះមានប្អូនប្រុសបីនាក់ទៀតហើយ។ ពួកគេត្រូវមើលថែផ្ទះ និងកូនៗរបស់ពួកគេទាំងធនធានមានកម្រិត ជាញឹកញាប់សាកល្បងសេចក្តីជំនឿរបស់ពួកគេ នៅពេលដែលលោក និងលោកស្រី ថេល័រ បានពឹងផ្អែកលើព្រះជាម្ចាស់។ ពួកគេក៏ត្រូវផ្តល់មូលនិធិ និង

គ្រប់គ្រងការងារនៅទីក្រុងនីងប៉ូផងដែរ មានន័យថា ត្រូវធ្វើការផ្ទៀងផ្ទាត់ច្រើនលើកច្រើនសារ។ ការកែសម្រួលព្រះគម្ពីរសញ្ញាថ្មីកាន់តែមមាញឹក នៅពេលដែលគាត់បានរួមបញ្ចូលឯកសារយោងនៅចុងសន្លឹក។ ឯកសារយោងទាំងនោះពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់គ្រីស្ទបរិស័ទនៅទីក្រុងនីងប៉ូ ហើយបើទោះបីការរៀបចំនេះត្រូវការពេលវេលាច្រើនក៏ដោយ ក៏វាបាននាំព្រះពរដ៏ធំធេងដល់បេសកជនវ័យក្មេងម្នាក់នេះ ដែលបានចំណាយពេលរាប់ម៉ោងជារៀងរាល់ថ្ងៃ ដើម្បីសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ។

វាពិតជាអស្ចារ្យណាស់ចំពោះកិច្ចការដ៏ច្រើនដែលគាត់បានធ្វើ ហើយវានឹងពិបាកជឿណាស់បើគ្មានកំណត់ត្រានេះ។ ជារៀងរាល់ថ្ងៃ លោកគ្រូ ថេល័រ បានកត់ត្រាពេលវេលាដែលគាត់បានចំណាយលើការងារចម្បងរបស់គាត់ ហើយបានសរសេរដូចខាងក្រោមនេះថា៖

ថ្ងៃទី២៧ ខែមេសា៖ បានកែសម្រួលអស់រយៈពេលប្រាំពីរម៉ោងនៅពេលល្ងាចនៅសាលអិចហ្សិតធ័រ (Exeter Hall)។

ថ្ងៃទី២៨ ខែមេសា៖ បានកែសម្រួលអស់រយៈពេលប្រាំបួនម៉ោងកន្លះ។

ថ្ងៃទី៣០ ខែមេសា៖ បានកែសម្រួលអស់រយៈពេលប្រាំម៉ោងកន្លះ អំឡុងពេលប្រជុំនានានៅសមាគមបេសកជនបាទីស្ទ (Baptist Missionary Society)។

ថ្ងៃទី១ ខែឧសភា៖ បានកែសម្រួលអស់រយៈពេលប្រាំបីម៉ោងកន្លះ ហើយមានភ្ញៀវរហូតដល់ម៉ោង១០យប់។

ថ្ងៃទី២ ខែឧសភា៖ បានកែសម្រួលអស់រយៈពេលដប់បីម៉ោង។

ថ្ងៃទី៣ ខែឧសភា៖ នៅថ្ងៃអាទិត្យនៅ បេយស៍វ៉តធ័រ (Bayswater)។ នៅពេលព្រឹក ខ្ញុំបានឮលោកគ្រូ លេវីស (Mr. Lewis) អធិប្បាយអំពីកណ្ឌគម្ពីរ យ៉ូហាន ៣:៣៣ ហើយទទួលពិធីលាងព្រះអម្ចាស់នៅរសៀលនោះ។ នៅពេលល្ងាច ខ្ញុំបាននៅផ្ទះ ហើយបានអធិស្ឋានអំពីកិច្ចការនៅប្រទេសចិនរបស់ពួកយើង។

ថ្ងៃទី៤ ខែឧសភា៖ បានចំណាយពេលបួនម៉ោងលើការកែសម្រួល (ការផ្ទៀងផ្ទាត់តាមសំបុត្រ និងមានភ្ញៀវ)។

ថ្ងៃទី៥ ខែឧសភា៖ បានកែសម្រួលអស់រយៈពេលដប់មួយម៉ោងកន្លះ។

ថ្ងៃទី៧ ខែឧសភា៖ បានកែសម្រួលអស់រយៈពេលប្រាំបួនម៉ោងកន្លះ។

ថ្ងៃទី៨ ខែឧសភា៖ បានកែសម្រួលអស់រយៈពេលដប់ម៉ោងកន្លះ។

ថ្ងៃទី៩ ខែឧសភា៖ បានចំណាយពេលដប់បីម៉ោងលើការកែសម្រួល។

ថ្ងៃទី១០ ខែឧសភា៖ នៅពេលព្រឹក ខ្ញុំមានពេលវេលាដ៏មានអំណរជាមួយលោក ឡែ-ជុន (Lae-djun) ដើម្បីពិភាក្សាអំពីផ្នែកទីមួយនៃកណ្ឌគម្ពីរ ហេព្រើរ ជំពូកទី១១។ ខ្ញុំក៏បានសរសេរទៅលោក ជេមស៍ មីដូស៍ (James Meadows)។ នៅពេលរសៀល ម៉ារា និងខ្ញុំបានអធិស្ឋានអំពីការរើចេញពីផ្ទះ ការព្រួយបារម្ភរបស់លោក មីដូស៍ សេចក្ដីស្រឡាញ់ដ៏ពិត ការកែសម្រួល និងបញ្ហាផ្សេងៗទៀត។ ខ្ញុំក៏បានសរសេរទៅលោក ឡត (Mr. Lord) ផងដែរ។ នៅពេលល្ងាច ខ្ញុំបានស្ដាប់លោក ខែនណិឌី (Mr. Kennedy) អធិប្បាយអំពីកណ្ឌគម្ពីរ ម៉ាថាយ ២៧:៤២៖ «[បណ្ដាជននិយាយទៅកាន់ព្រះយេស៊ូវ] [វា] ជួយសង្គ្រោះមនុស្សឯទៀតបាន តែមិនអាចនឹងជួយសង្គ្រោះដល់ខ្លួនវាបានទេ»។ ឱ!សូមឲ្យទូលបង្គំបានចិត្តសុភាព អត់ធ្មត់ និងចេះស្រឡាញ់ដូចព្រះយេស៊ូវ! ឱព្រះអម្ចាស់អើយ! សូមជួយឲ្យទូលបង្គំបានដូចជាទ្រង់ផង។

លោកគ្រូ ថេល័រ កំពុងប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីបញ្ចុះបញ្ចូលក្រុមប្រធាននិកាយផ្សេងៗឲ្យទៅផ្សាយដំណឹងល្អនៅប្រទេសចិន ដែលបានបង្កើតផ្នែកដ៏ធំនៃកិច្ចការរបស់គាត់នៅពេលនោះ។ គាត់បានទៅសួរសុខទុក្ខលេខាធិការនៅសមាគមជាច្រើនតែម្នាក់ឯង ឬក៏ទៅជាមួយអ្នកដែលធ្វើការកែសម្រួលជាមួយគាត់ លោកគ្រូគង្វាល អេហ្វ.អេហ្វ ហ្គឺស (Rev. F. F. Gough) មកពី ស៊ីអិម.អេស. (C.M.S.) ដោយពន្យល់អំពីតម្រូវការទៅលើតំបន់ឆ្ងាយៗដែលខ្វះការយកចិត្តទុកដាក់ ដែលឥឡូវនេះអាចចូលទៅបានហើយដោយសារតែលិខិតឆ្លងដែនអាចអនុញ្ញាតសម្រាប់ការធ្វើដំណើរ និងការតាំងលំនៅនៅក្នុងកន្លែងឆ្ងាយដាច់ស្រយាលបានហើយ។ ទោះបីជាបានទទួលការឆ្លើយតបដោយក្ដីអាណិតអាសូរក៏ដោយ ក៏វាច្បាស់ណាស់ថា គ្មានប្រធានណាម្នាក់បានត្រៀមខ្លួនក្នុងការទទួលយកទំនួលខុសត្រូវចំពោះគម្រោងដ៏សំខាន់នេះឡើយ។

រឿងទាំងនេះបានជះឥទ្ធិពលលើលោកគ្រូ ហ័ដសិន ថេល័រ ហើយនៅពេលដែលបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ទៅលើតំបន់ខ្លះនៅប្រទេសចិនបានរួមផ្សំទៅនឹងការសិក្សាយ៉ាងហ្មត់ចត់ទៅលើព័ន្ធកិច្ចទាំងមូល ផលប៉ះពាល់ គឺធំមហិមាណាស់។ មិត្តភក្តិ និងគ្រូគង្វាលរបស់គាត់ លោក ឡេវីស ក៏ជាអ្នកកែសម្រួលនៅ «ទស្សនាវដ្ដីបាទីស្ទ» (Baptist

Magazine) បានសុំគាត់ឲ្យសរសេរអត្ថបទជាភាគ ដើម្បីបង្កើនចំណាប់អារម្មណ៍ទៅលើបេសកកម្មទៅកាន់ទីក្រុងនីងប៉ូ (Ningpo Mission)។ លោកគ្រូ ហ័ដសិន បានចាប់ផ្តើមសរសេរវា ហើយអត្ថបទមួយច្បាប់បានចេញផ្សាយរួចរាល់ហើយ នៅពេលលោក ឡេវីស បានផ្ញើអត្ថបទទីពីរទៅ។ លោក ឡេវីស បានជឿជាក់ថា អត្ថបទទាំងនេះពិតជាចាំបាច់ និងមានសារៈសំខាន់ពន់ពេកណាស់គឺ មិនគួរបោះពុម្ពផ្សាយតែនៅទស្សនាវដ្តីនិកាយបាទីស្ទមួយគត់ប៉ុណ្ណោះ។

គាត់ទទូចថាៈ «បន្ថែមវាទៅ ហើយទុកវាក្តោបលើគ្រប់ផ្នែកនៃប្រទេសទាំងមូល ដើម្បីបោះពុម្ពផ្សាយទុកជាការអំពាវនាវសម្រាប់ទឹកដីនៃប្រទេសចិន»។

ការនេះបាននាំឲ្យមានការសិក្សាលម្អិតនៃតម្រូវការខាងព្រលឹងវិញ្ញាណគ្រប់ផ្នែកទាំងអស់នៃប្រទេសចិន រួមបញ្ចូលទាំងតំបន់ដាច់ស្រយាលនានាផង។ ខណៈពេលដែលនៅក្នុងទីក្រុងនីងប៉ូ តម្រូវការភ្លាមៗនៅជុំវិញគាត់មានធំសម្បើម។ ដូច្នេះ លោកគ្រូ ហ័ដសិន មិនអាចផ្តោតអារម្មណ៍ទៅលើតម្រូវការដែលធំជាងនេះបានឡើយ។ ប៉ុន្តែពេលនេះ ដោយមានផែនទីប្រទេសចិននៅលើជញ្ជាំងបន្ទប់សិក្សារបស់គាត់ និងការសន្យាជាច្រើនរបស់ព្រះជាម្ចាស់ពីព្រះគម្ពីរដែលគាត់សិក្សាបានស្រើបព្រលឹងរបស់គាត់ គាត់មានអារម្មណ៍ថា បាននៅជិតខេត្តនៃទឹកដីដ៏ធំ ក៏ដូចជាតំបន់ឆ្នេរដែលគាត់ធ្លាប់ធ្វើការពីមុន។ វាមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេដែលថា ការអធិស្ឋានបានក្លាយជារបៀបតែមួយនៅក្នុងការសម្រាលបន្ទុកដ៏ធ្ងន់នៅក្នុងចិត្តគាត់។

មានវិបត្តិធំបានកើតឡើង នៅពេលការអធិស្ឋានមិនបានផ្តល់ការកម្សាន្តចិត្ត ហើយផ្ទុយមកវិញគាត់កាន់តែមានអារម្មណ៍ថា ជាប់ជំពាក់កាន់តែខ្លាំងឡើងនៅក្នុងកិច្ចការដែលគាត់មានអារម្មណ៍ភ័យខ្លាចនឹងបំពេញ។ គាត់បានដឹងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរថា ព្រះជាម្ចាស់អាចប្រើប្រាស់ សូម្បីតែមនុស្សដូចគាត់ ដើម្បីឆ្លើយតបការអធិស្ឋានទាំងឡាយរបស់គាត់។

ខ្ញុំកាន់តែជឿជាក់ថា ព្រះជាម្ចាស់សព្វព្រះទ័យឲ្យខ្ញុំស្វែងរកអ្នកចម្រូតស្មោះត្រង់ពីទ្រង់ ហើយដើម្បីធ្វើការជាមួយពួកគេ។ ប៉ុន្តែអស់រយៈពេលដ៏យូរ ការខ្វះសេចក្តីជំនឿរបស់ខ្ញុំបានរារាំងខ្ញុំពីការឈានជំហានដំបូង។

ខ្ញុំបានរៀនពីការសិក្សាព្រះគម្ពីរថា ដើម្បីរកបានអ្នកចម្រូតដ៏ស្មោះត្រង់ យើងមិនត្រឹម

តែត្រូវការការអំពាវនាវយ៉ាងលម្អិតសម្រាប់ការជួយឡើយ ប៉ុន្តែដំបូងត្រូវអធិស្ឋានដោយស្មោះអស់ពីចិត្តទៅកាន់ព្រះជាម្ចាស់ ដើម្បីបញ្ជូនពួកអ្នកចម្រូតមក ហើយទីពីរជួយឲ្យជីវិតខាងឯព្រលឹងវិញ្ញាណរបស់ក្រុមជំនុំកាន់តែចាក់ឫសជ្រៅដល់ចំណុចមួយដែលមនុស្សម្នាមានអារម្មណ៍ថា ត្រូវជំរុញឲ្យចាកចេញពីផ្ទះរបស់ពួកគេ ដើម្បីបម្រើ។ វិធីសាស្រ្តនៃពួកសាវ័កនេះ គឺមិនធ្វើឲ្យមានការព្រួយបារម្ភអំពីការរកវិធី និងមធ្យោបាយនោះទេ ប៉ុន្តែជាការចេញទៅ ហើយធ្វើកិច្ចការទាំងនោះ ដោយទុកចិត្តលើសេចក្តីសន្យារបស់ទ្រង់ថា៖ «ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង» (ម៉ាថាយ ៦:៣៣)។

ការមិនជឿធ្វើឲ្យយើងម្តងទុកចិត្តដូច្នេះ ម្តងដូច្នោះ?! ខ្ញុំមិនមានការសង្ស័យទេថា ប្រសិនបើខ្ញុំបានអធិស្ឋានសូមឲ្យមានអ្នកច្រូតមកធ្វើការជាមួយខ្ញុំដោយនៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះទ្រង់នឹងប្រទានឲ្យពួកគេមកជាមិនខាន។ ខ្ញុំមិនមានការសង្ស័យចំពោះការឆ្លើយតបទៅនឹងការអធិស្ឋានបែបនេះទេ យើងនឹងទទួលបានមធ្យោបាយឆ្ពោះទៅមុខ ហើយទ្វារនឹងបើកចំហឲ្យយើងទៅដល់តំបន់នានានៅក្នុងប្រទេសចិនដែលដំណឹងល្អមិនទាន់ទៅដល់។ ប៉ុន្តែ ខ្ញុំមិនទាន់បានរៀនទុកចិត្តលើអំណាច និងព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងការថែរក្សាខ្ញុំនៅឡើយ ដូច្នេះវាមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលខ្ញុំមិនអាចទុកចិត្តទ្រង់ថា ព្រះអង្គអាចនឹងថែរក្សាអ្នកផ្សេងទៀតដែលនឹងចូលរួមជាមួយខ្ញុំ។ ខ្ញុំខ្លាចថា នៅពេលប្រឈមមុខចំពោះគ្រោះថ្នាក់ ការលំបាក និងសេចក្តីល្បួងលទាំងឡាយដែលភ្ជាប់ទាក់ទងនឹងការងារបែបនេះ គ្រីស្ទបរិស័ទដែលមានបទពិសោធន៍តិចតួចខ្លះនឹងបរាជ័យ ហើយបន្ទោសខ្ញុំចំពោះការលើកទឹកចិត្តពួកគេឲ្យចាប់ផ្តើមខិតខំប្រឹងប្រែងធ្វើការ ទាំងដែលពួកគេមិនទាន់ត្រៀមខ្លួនរួចរាល់។

តើខ្ញុំអាចធ្វើអ្វីបាន? ការមានអារម្មណ៍ថា ខ្លួនមានកំហុសចំពោះការបង្ហូរឈាមកាន់តែកើនខ្លាំងឡើងៗ ពីព្រោះខ្ញុំមិនបានសុំ ឲ្យមានអ្នកចម្រូតស្ម័គ្រចិត្តចូលមក ឬទៅប្រទេសចិននោះទេ ហើយជារៀងរាល់ថ្ងៃ មនុស្សរាប់ម៉ឺនៗរាប់ពាន់នាក់បានស្លាប់ដោយមិនបានស្គាល់ព្រះគ្រីស្ទ។ ការគិតអំពីប្រទេសចិនដែលកំពុងតែស្លាប់បានដុតកម្លោចដួងចិត្ត និងគំនិតរបស់ខ្ញុំ ដោយធ្វើឲ្យខ្ញុំគ្មានសន្តិភាពនៅពេលថ្ងៃ ហើយសម្រាកបានតិចតួចនៅពេលយប់ រហូតដល់សុខភាពរបស់ខ្ញុំបានធ្លាក់ទ្រុឌទ្រោម។

ឆ្នាំដ៏អាថ៌កំបាំងនោះបានបំពេញកិច្ចការរបស់វា។ ឧបករណ៍ដែលព្រះជាម្ចាស់អាចប្រើប្រាស់បានរៀបចំរួចជាស្រេច ហើយការអធិស្ឋានឥតឈប់ឈរពីផ្ទះតូចមួយនៅទីក្រុងឡុងដ៍ភាគខាងកើតនោះនឹងទទួលបានការឆ្លើយតបយ៉ាងឆាប់រហ័ស ប៉ុន្តែនឹកស្មានមិនដល់ឡើយ។

ជំពូកទី១០

# មនុស្សដែលប្ដេជ្ញាចុះចូលចំពោះព្រះជាម្ចាស់

*ជំហាននៃក្ដីជំនឿនាំយើងធ្លាក់ទៅលើអ្វីដែលហាក់ដូចជាទីចំហ តែជាន់លើថ្មដ៏រឹងមាំនៅខាងក្រោម។*

— *លោក ជេ. ជី. វាយធ័រ (J. G. Whittier)*

រដូវក្ដៅក៏បានចូលមកដល់ម្ដងទៀតព្រមជាមួយអាកាសធាតុដ៏ក្ដៅ និងផ្លូវហុយនៅទីក្រុងឡុងដ៍នៅភាគខាងកើត។ ដោយមើលឃើញថា លោកគ្រូ ហ័ដសិន មានសុខភាពមិនសូវស្រួល មិត្តចាស់របស់គាត់បានអញ្ជើញគាត់ឲ្យស្នាក់នៅបីថ្ងៃនៅឆ្នេរនៃទីក្រុងប្រាយតុន (Brighton)។ លោកស្រី ថេល័រ ព្រួយបារម្ភអំពីសុខភាពរបស់ប្ដីនាងជាខ្លាំង តែនាងនៅតែសប្បាយចិត្ត ដែលបានទៅជួបមិត្តសម្លាញ់របស់គាត់។ បើទោះបីជាលោកស្រី ថេល័រ មិនយល់អំពីបទពិសោធន៍ដែលនាងកំពុងតែជួបប្រទះនេះទាំងស្រុងក៏ដោយក៏លោកគ្រូ ហ័ដសិន មិនអាចបង្ហាញឲ្យប្រពន្ធរបស់គាត់ឃើញទាំងស្រុងនូវការជ្រួលច្របល់ចិត្ត ដែលកំពុងស្ទើរតែមិនអាចទ្រាំទ្របាននោះទេ។

គាត់បានប្រឈមមុខនឹងវិបត្តិតែម្នាក់ឯងនៅលើឆ្នេរខ្សាច់ប្រាយតុននៅព្រឹកថ្ងៃអាទិត្យនោះ។ គាត់បានចូលរួមថ្វាយបង្គំនៅព្រះវិហារជាមួយអ្នកផ្សេងៗទៀត ប៉ុន្តែពេលឃើញ

មនុស្សជាច្រើនកំពុងអបអរដោយសេចក្ដីអំណរចំពោះការសង្គ្រោះធ្វើឲ្យគាត់ព្រួយចុកចាប់យ៉ាងក្រៃលែង។ គាត់បានគិតដល់ព្រលឹងអស់អ្នកដែលបាត់បង់ និងមិនមានអ្នកយកចិត្តទុកដាក់ជាច្រើននៅប្រទេសចិន ដោយនឹកគិតអំពីព្រះបន្ទូលរបស់ព្រះគ្រីស្ទថា៖ «ខ្ញុំនៅមានចៀមផ្សេងទៀត ខ្ញុំត្រូវតែនាំពួកគេមកដែរ»។ ព្រះសូរសៀងរបស់ព្រះអម្ចាស់ និងសេចក្ដីស្រឡាញ់នៃព្រះភក្ត្ររបស់ព្រះអម្ចាស់បានទូលអង្វរដោយភាពស្ងៀមស្ងាត់។

គាត់ដឹងថា ព្រះជាម្ចាស់កំពុងតែមានបន្ទូលមកកាន់គាត់។ គាត់យល់ថា ប្រសិនបើគាត់ចុះចូលចំពោះបំណងព្រះហឫទ័យរបស់ទ្រង់ ហើយអធិស្ឋានដោយមានការដឹកនាំពីទ្រង់ នោះព្រះជាម្ចាស់នឹងប្រទានអ្នកផ្សាយដំណឹងល្អសម្រាប់ទឹកដីប្រទេសចិនជាមិនខាន។ គាត់មិនមានការព្រួយបារម្ភអំពីការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុរបស់ពួកគេទេ ពីព្រោះព្រះអង្គដែលបានត្រាស់ហៅ និងបញ្ជូនពួកគេមកនឹងធានាថា ពួកគេនឹងមានអាហារបរិភោគប្រចាំថ្ងៃ។ ប៉ុន្តែ គាត់ក៏បានសញ្ជឹងគិតអំពីការបរាជ័យដែលអាចកើតឡើងចំពោះពួកគេដែរ។ លោកគ្រូ ហ៍ដសិន ថេល័រ បានដឹងយ៉ាងច្បាស់អំពីស្ថានភាពនៅប្រទេសចិន សេចក្ដីល្បួងដែលពួកគេនឹងត្រូវប្រឈម ហើយនិងសត្រូវពិតដែលមិនងាយនឹងកម្ចាត់ចោលបាន។ គាត់មានការភ័យខ្លាច ហើយចង់ដឹងថា តើនឹងមានអ្វីកើតឡើង ប្រសិនបើមិត្តរួមការងាររបស់គាត់ត្រូវប្រឈមមុខនឹងសម្ពាធយ៉ាងខ្លាំង និងរងទុក្ខ ហើយបានបន្ទោសដល់គាត់នោះ។

ចិត្តសង្ស័យបានលួចចូលមកតាមរយៈការមិនជឿ អារក្សបានល្បួងឲ្យគាត់មានអារម្មណ៍ថា បើទោះបីជាការអធិស្ឋាន ទាំងមានសេចក្ដីជំនឿក្ដី បាននាំគាត់ធ្លាក់ចូលទៅក្នុងបញ្ហា ដូច្នេះគាត់ត្រូវតែស្វែងរកដំណោះស្រាយដោយដកខ្លួនចេញទៅ។ ខ្ញុំបានបរាជ័យដោយមិនបានយល់ឃើញថា ព្រះជាម្ចាស់ដែលប្រកបដោយអំណាចដែលផ្គត់ផ្គង់ដល់មនុស្ស ហើយធនធានទាំងឡាយក៏អាចនឹងទ្រទ្រង់ដល់ពួកគេផងដែរ ទោះបីជានៅតំបន់ដាច់ស្រយាលនៅប្រទេសចិនក្ដី។

ខណៈពេលដែលមានមនុស្សមួយលាននាក់បានស្លាប់ជារៀងរាល់ខែនៅលើទឹកដីដ៏ធំធេងនោះ ដោយមិនបានស្គាល់ព្រះជាម្ចាស់។ ការនេះពិតជាបានប៉ះពាល់ចិត្តគាត់យ៉ាងខ្លាំង។ គាត់ដឹងថា គាត់ត្រូវតែធ្វើការសម្រេចចិត្ត ដោយសារគាត់មិនអាចនឹងទ្រាំទ្រចំពោះអារម្មណ៍បែបនេះបានទៀតទេ។ វាពិតជាងាយស្រួលណាស់នៅក្នុងការអធិស្ឋានសុំឲ្យ

មានពួកអ្នកចម្រូតបន្ថែមទៀត ប៉ុន្តែគាត់ចង់ដឹងថា គាត់អាចស្ម័គ្រចិត្ត ឬក៏អាចទទួលបន្ទុកនៃការដឹកនាំនេះបានដែរឬទេ។

ដោយមានអារម្មណ៍ថា មានទុក្ខព្រួយនឹងកើតទុក្ខខាងក្នុងវិញ្ញាណជាខ្លាំង ខ្ញុំក៏បានដើរចេញទៅឆ្នេរខ្សាច់តែម្នាក់ឯង។ នៅទីនោះ ព្រះជាម្ចាស់បានយកឈ្នះលើភាពមិនជឿរបស់ខ្ញុំ ហើយខ្ញុំបានថ្វាយខ្លួនទៅព្រះជាម្ចាស់សម្រាប់ការបម្រើមួយនេះ។ ក្នុងនាមជាអ្នកបម្រើព្រះអង្គ ខ្ញុំបានទូលប្រាប់ទ្រង់ថា សូមទ្រង់ទទួលរាល់ទំនួលខុសត្រូវទាំងអស់សម្រាប់លទ្ធផល និងផលវិបាក ហើយតួនាទីរបស់ខ្ញុំគឺស្ដាប់បង្គាប់ និងដើរតាមទ្រង់ ចំណែកឯផ្នែករបស់ទ្រង់គឺដឹកនាំ មើលថែរក្សា និងបង្ហាញផ្លូវខ្ញុំ ព្រមទាំងអស់អ្នកដែលនឹងត្រូវធ្វើការជាមួយខ្ញុំដែរ។ តើខ្ញុំអាចបញ្ជាក់ពីសេចក្ដីសុខសាន្តដែលបានចាក់បំពេញក្នុងចិត្តដែលមានបន្ទុកយ៉ាងធ្ងន់របស់ខ្ញុំបានដោយរបៀបណា?

ហើយបន្ទាប់មក នៅទីនោះ ខ្ញុំបានទូលសូមព្រះជាម្ចាស់ប្រទានឲ្យមានអ្នកចម្រូតមកធ្វើការចំនួនម្ភៃបួននាក់ មួយខេត្តពីរនាក់សម្រាប់១១ខេត្ត ដែលគ្មានបេសកជនម្នាក់សោះ ហើយពីរនាក់សម្រាប់ប្រទេសម៉ុងហ្គោលី (Mongolia)។ ខ្ញុំបានសរសេរសំណើនៅលើគែមព្រះគម្ពីរដែលខ្ញុំបានកាន់ ព្រមទាំងបានត្រឡប់ទៅផ្ទះវិញ។ នៅទីបំផុតចិត្តរបស់ខ្ញុំបានស្ងប់ក្រោយពីប៉ុន្មានខែដែលមិនបានស្ងប់ ហើយខ្ញុំមានទំនុកចិត្តថា ព្រះអម្ចាស់នឹងប្រទានពរដល់កិច្ចការរបស់ទ្រង់ ហើយខ្ញុំក៏នឹងមានចំណែកក្នុងព្រះពរនោះផងដែរ។

សង្គ្រាមនៅក្នុងចិត្តខ្ញុំក៏បានបញ្ចប់សព្វគ្រប់ ហើយគ្រប់យ៉ាងបានត្រឡប់មកមានសេចក្ដីសុខសាន្ត និងសេចក្ដីអំណរ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំអាចហើរឡើងទៅលើកូនភ្នំ ហើយទៅផ្ទះរបស់លោក ភៀស (Mr. Pearce)។ ខ្ញុំក៏បានសម្រាន្តលក់យ៉ាងស្កប់ស្កល់នៅយប់នោះដែរ! ប្រពន្ធសម្លាញ់ចិត្តរបស់ខ្ញុំបានជឿថា លើទឹកដីប្រាយតុនបានធ្វើការអស្ចារ្យសម្រាប់ខ្ញុំ ហើយវាពិតជាបានធ្វើការអស្ចារ្យមែន។

ជំពូកទី១១

# មនុស្សដែលព្រះជាម្ចាស់បានបញ្ជូនទៅ

*ចូរទុកចិត្តលើព្រះយេហូវ៉ាចុះ*
*នោះលោកអ្នកនឹងមានសុវត្ថិភាពនៅពេលលោកអ្នកធ្វើដំណើរទៅមុខ*
*ចូរយកចិត្តទុកដាក់លើកិច្ចការរបស់ទ្រង់ដោយសម្លឹងមើលជាប់ជានិច្ច*
*នោះកិច្ចការរបស់លោកអ្នកនឹងបានសម្រេចជាមិនខានឡើយ។*
*— លោក ប៉ូល ហ្គើរហាដ (Paul Gerhardt)*

មានសុភមង្គលហើយដល់អ្នកណាដែលព្រះយេហូវ៉ាបានត្រាស់ហៅឲ្យដើរឈានទៅមុខតាមគ្រប់ទាំងផ្លូវនៃសេចក្តីជំនឿ ដែលមិនបានទទួលអ្វីពីខាងក្រៅតែបានទទួលសេចក្តីអាណិតអាសូរ និងជំនួយពីដៃគូជីវិតឡើយ។ លោកគ្រូ ហ៉ាដសិន ថេល័រ មានបទពិសោធន៍ប្រាំពីរឆ្នាំកន្លះក្នុងជីវិតអាពាហ៍ពិពាហ៍ដោយមិនមានការខកចិត្តចំពោះមនុស្សដែលគាត់ស្រឡាញ់ ហើយនាងក៏មិនបានធ្វើឲ្យគាត់ខកចិត្តដែរសូម្បីតែពេលនេះ។ បើទោះបីលោកគ្រូ ហ៉ាដសិន មានការចុះខ្សោយខាងសុខភាពក្នុងវ័យត្រឹមតែម្ភៃប្រាំបីឆ្នាំព្រមទាំងមានកូនៗបួននាក់ត្រូវថែរក្សាក៏ដោយ ក៏លោកស្រី ថេល័រ ទទួលយកបេសកកម្មប្តីរបស់គាត់ក្នុងការផ្សាយដំណឹងល្អទៅកាន់ទឹកដីប្រទេសចិនភ្លាមៗ ក្រោយពីនាងបាន

ដឹងអំពីរឿងនេះ។ នាងបានក្លាយជាអ្នកកម្សាន្តចិត្ត និងបំផុសគំនិតនៅក្នុងរបៀបថ្មីមួយ។ នាងបានសរសេរសំបុត្រឲ្យគាត់ សេចក្តីជំនឿរបស់នាងបានពង្រឹងសេចក្តីជំនឿរបស់គាត់ ការអធិស្ឋានរបស់នាងបានគាំទ្រដល់ព័ន្ធកិច្ចទាំងឡាយ ហើយបទពិសោធន៍ជាក់ស្តែង និងចិត្តដែលពេញដោយក្តីស្រឡាញ់របស់នាងបានធ្វើឲ្យនាងទទួលបានងារថាជា មាតានៃអង្គការបេសកកម្មនៅចិនដីគោក (Mother of the Mission)។

មិនយូរប៉ុន្មាន ផ្ទះធំជាងមុននៅផ្លូវខូប៊ើន (Coborn Street) ដែលពួកគេបានរើទៅ ចាប់ផ្តើមមានមនុស្សចង់ទៅបម្រើនៅប្រទេសចិនជាច្រើននាក់។ បន្ទប់ទទួលភ្ញៀវដែលហាក់បីដូចជាទូលាយ ស្ទើរតែមិនអាចទទួលការជួបជុំមិត្តភក្តិសម្រាប់ការជួបជុំអធិស្ឋានរាល់ថ្ងៃសៅរ៍បាន។ ប្រាក់ហាសិបដុល្លារ (ប្រហែលស្មើនឹងប្រាក់ $១.៩៩០,00 ដុល្លារបច្ចុប្បន្ន)  ជាប្រាក់ទាំងអស់ដែលលោកគ្រូ ហ័ដសិន មាន ហើយបានប្រើដើម្បីបើកគណនីធនាគារសម្រាប់ "អង្គការបេសកកម្មនៅចិនដីគោក) វាបានត្រឡប់ទៅជាប្រាក់រាប់រយដុល្លារ ដោយសារតែអំណោយស្ម័គ្រចិត្តនានាពីអស់អ្នកដែលចង់ចូលរួមនៅក្នុងបេសកកម្មទៅកាន់ទឹកដីប្រទេសចិន ហើយពួកគេបានចាប់ផ្តើមបង្កើតគម្រោងសម្រាប់ការចេញដំណើររបស់ក្រុមដំបូង។

ជារៀងរាល់ថ្ងៃអាទិត្យ លោកគ្រូ ហ័ដសិន បានឆ្លៀតពេលស្ងៀមស្ងាត់សរសេរនៅក្នុងបន្ទប់អង្គុយលេងនៅផ្លូវលេខ៣០ ខូប៊ើន។ លោកស្រី ថេល័រ អង្គុយនៅនឹងតុដោយកាន់ប៊ិចមួយនៅក្នុងដៃ ស្របពេលដែលលោក ថេល័រ ដើរទៅវិញទៅមក ដោយគិតគូរយ៉ាងសកម្មអំពីប្រធានបទដែលពួកគេយកចិត្តទុកដាក់លើ។ អត្ថបទដែលលោក ឡេវីស បានណែនាំឲ្យសរសេរមានសារៈសំខាន់កាន់តែខ្លាំងឡើងៗ។ ពួកគេប្រឈមមុខទៅនឹងសេចក្តីត្រូវការបន្ទាន់មួយក្នុងការផ្សាយអំពីតម្រូវការដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេសចិន ហើយពួកគេកំពុងធ្វើកិច្ចការខិតខំប្រឹងប្រែងថ្មី គេផ្តោតទៅលើការលើកឡើងនូវសេចក្តីត្រូវការនោះដោយពឹងផ្អែកលើព្រះជាម្ចាស់។ នៅពេលដែលពួកគាត់បានអធិស្ឋាន និងបានសរសេរកូនសៀវភៅ "សេចក្តីត្រូវការខាងព្រលឹងវិញ្ញាណនៅប្រទេសចិន និងកាតព្វកិច្ចរបស់យើង" ("China's Spiritual Need and Claims") ឡើង វាបានប្រែក្លាយជាកូនសៀវភៅមួយដែលទំនើប មានប្រសិទ្ធភាពខ្លាំងក្នុងការជំរុញដល់ដួងចិត្តរបស់គ្រីស្ទបរិស័ទឲ្យឆេះឆួលឡើង (រ៉ូម ១:១៤-១៥)។ ឥទ្ធិពលរបស់វា គឺមិនអាចកាត់ថ្លៃបាន៖

ដោយបញ្ជូនមនុស្សជាច្រើនទៅប្រទេសចិនបន្ទាប់ពីការបោះពុម្ពវគ្គថ្មីនីមួយៗ បានទាញយកចិត្តអាណិតអាសូរដ៏ទូលំទូលាយសម្រាប់ការខិតខំប្រឹងប្រែងទាំងឡាយរបស់បេសកជន ហើយបានពង្រឹងសេចក្តីជំនឿ និងដាស់តឿនឲ្យមានការអធិស្ឋាន និងការជាប់ចិត្តនឹងព្រះជាម្ចាស់ច្រើនឡើង។ គ្រប់ឃ្លា គ្រប់ប្រយោគ បានបញ្ចូលដោយសេចក្តីអធិស្ឋាន ដែលហាក់បីដូចជាមានអំណាចព្រះនៅក្នុងនោះ។

កូនសៀវភៅនោះ បានធ្វើឲ្យគាត់មានមិត្តភក្តិ និងឱកាសជាច្រើន។ ពួកគាត់បានបោះពុម្ពសារឡើងវិញនៅក្នុងអំឡុងពេលបីសប្តាហ៍នៃការបោះពុម្ព ហើយទទួលបានលិខិតសរសើរដូចជានៅសំបុត្រមុនរបស់លោកឯកឧត្តម ឡូត រ៉េតស្តុកឃ៍ (Lord Radstock) ដែលទើបតែស្លាប់ថ្មីៗនេះ។

“ខ្ញុំបានអានកូនសៀវភៅរបស់ប្អូនប្រុស ហើយវាបានប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំង។ ខ្ញុំសង្ឃឹមថា ព្រះវិញ្ញាណបរិសុទ្ធប្រទានអំណាចដល់ប្អូនក្នុងការនិយាយអំពីព្រះបន្ទូលដែលនឹងបញ្ជូនមនុស្សជាច្រើនទៅកាន់ចំការទំពាំងបាយជូរ។ ប្អូនប្រុសសម្លាញ់អើយ! ចូរពង្រីកបំណងប្រាថ្នារបស់ប្អូនប្រុសចុះ! ចូរអធិស្ឋានសូមអ្នកច្រូតរាប់រយនាក់ទៀតចុះ ហើយព្រះអម្ចាស់នឹងប្រទានពួកគេមកដល់ប្អូនប្រុស”។

ទោះជាយ៉ាងណា គោលដៅដំបូងមិនមែនមនុស្សរាប់រយនាក់នោះទេ គឺត្រឹមតែម្ភៃប្អូននាក់ប៉ុណ្ណោះ ហើយលោកគ្រូ ហ័ដសិន បានកត់ត្រាការអធិស្ឋានរបស់គាត់ដោយការសរសេរដៃយ៉ាងច្បាស់ៗ នៅក្នុងព្រះគម្ពីរដែលគាត់ប្រើប្រាស់អស់ជាយូរឆ្នាំ។ ភាពជោគជ័យមិនបានធ្វើឲ្យគាត់មានអំណរខ្លាំងពេកនោះទេ ផ្ទុយទៅវិញ វាបានបង្កើនភាពមានទំនួលខុសត្រូវចំពោះកាតព្វកិច្ចរបស់គាត់ទៅវិញ។ នៅរដូវរងាដែលគួរឲ្យចងចាំនោះ គាត់បាននាំយកសារមួយ ដែលគាត់បានជឿថា បានមកពីព្រះជាម្ចាស់ នៅពេលគាត់បានទៅពីកន្លែងមួយទៅកន្លែងមួយទៀត ដោយបានបញ្ឆេះដួងចិត្តក្នុងការយល់ដឹងអំពីព្រះហឫទ័យ និងវត្តមានរបស់ព្រះជាម្ចាស់ស្រដៀងគ្នានឹងគាត់ដែរ។

នៅសម័យនោះ មនុស្សម្នាគិតថា វាជារឿងថ្មី ហើយប្លែកក្នុងការគិតថា សេចក្តីជំនឿល្មមគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋានគ្រឹះខាងហិរញ្ញវត្ថុក្នុងកិច្ចការនាំដំណឹងល្អទៅដល់កន្លែងដ៏ឆ្ងាយៗនៅពិភពលោកនេះ។ គ្មាននរណាម្នាក់ធ្លាប់ឮអំពី “បេសកកម្មនៃសេចក្តីជំនឿ” (“faith missions”) ទេ គេធ្លាប់ឮតែការបង្កើតក្រុមប្រឹក្សាគណៈនិកាយ

ប៉ុណ្ណោះ។ ប៉ុន្តែ បើទោះបីជាលោកគ្រូ ហ័ដសិន ថេល័រ នៅក្មេងក៏ដោយ ក៏គាត់បានស្គាល់ព្រះជាម្ចាស់យ៉ាងជាក់ច្បាស់ដែរ។ គាត់បានសរសេរអំពីការឃើញព្រះជាម្ចាស់ធ្វើឲ្យព្យុះស្ងប់នៅសមុទ្រ ផ្លាស់ប្តូរទិសដៅខ្យល់ ព្រមទាំងនាំទឹកភ្លៀងមកនៅពេលមានគ្រោះរាំងស្ងួត គ្រប់ការទាំងអស់ឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់គាត់។ គាត់បានសរសេរអំពីការឃើញព្រះជាម្ចាស់បានការពារគាត់កុំឲ្យគេសម្លាប់ ហើយទ្រង់ក៏បានធ្វើឲ្យអ្នកដែលពេញដោយកំហឹងបានស្ងប់តាមរយៈការអធិស្ឋានដែរ។ គាត់បានឃើញព្រះជាម្ចាស់ប្រោសអ្នកជំងឺ ហើយបានធ្វើឲ្យអ្នកដែលមើលទៅហាក់បីដូចជាអស់សង្ឃឹមបានរស់ឡើងវិញដោយសារការអធិស្ឋាន។ អស់រយៈពេលជាងប្រាំបីឆ្នាំ គាត់មានបទពិសោធន៍សេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់នៅក្នុងការបំពេញសេចក្តីត្រូវការរបស់គ្រួសារ និងការងាររបស់គាត់តាមរយៈការអធិស្ឋាន រួមទាំងការគិតស្មានមិនដល់ដូចជាសេចក្តីត្រូវការដ៏ច្រើនទាំងនោះផង។ តើគាត់មិនអាចលើកទឹកចិត្តអ្នកដទៃឲ្យពឹងផ្អែកលើសេចក្តីស្រឡាញ់ដែលមិនអាចបំភ្លេចបាន ព្រមទាំងភាពស្មោះត្រង់របស់ព្រះជាម្ចាស់ដែលមិនអាចបាត់នោះបានដោយរបៀបណាទៅ?

យើងត្រូវចាំថា យើងកំពុងតែទាក់ទងជាមួយព្រះមួយអង្គ ដែលជាព្រះអម្ចាស់ដ៏ពេញដោយអំណាច និងព្រះចេស្តា ព្រះហស្តនៃព្រះយេហូវ៉ាមិនមែនរួញខ្លីដែលនឹងជួយសង្គ្រោះមិនបាននោះទេ ព្រះកាណ៌ទ្រង់ក៏មិនបានទៅជាធ្ងន់ ដែលនឹងស្តាប់មិនឮនោះដែរ (អេសាយ ៥៩:១)។ ព្រះជាម្ចាស់ដដែលនេះ បង្គាប់ឲ្យយើងទូលសូម និងទទួលដើម្បីឲ្យសេចក្តីអំណររបស់យើងបានពេញលេញ ព្រមទាំងបើកមាត់របស់យើងឲ្យបានធំ ដើម្បីឲ្យទ្រង់បាននឹងបំពេញវា។ យើងត្រូវចាំក្នុងចិត្តថា ព្រះដ៏មានសេចក្តីមេត្តាករុណាបានអនុញ្ញាតឲ្យអំណាចព្រះចេស្តាទ្រង់ប្រើប្រាស់តាមការអធិស្ឋានដ៏ស្មោះត្រង់នោះ តែទ្រង់ក៏មិនមើលស្រាលចំពោះអស់អ្នកដែលធ្វេសប្រហែសក្នុងការអធិស្ឋាន ដើម្បីជាប្រយោជន៍ដល់អស់អ្នកដែលកំពុងវិនាសដែរ។

អស់អ្នកដែលមិនធ្លាប់មានពិសោធន៍នឹងភាពស្មោះត្រង់នៃព្រះដែលកាន់តាមសេចក្តីសន្យានឹងគិតថា វាជារឿងប្រថុយប្រថានក្នុងការបញ្ជូនអ្នកផ្សាយដំណឹងល្អជនជាតិអឺរ៉ុបម្ភៃបួននាក់ទៅកាន់ទឹកដីដ៏សែនឆ្ងាយដែលគ្មានអ្នកជឿព្រះដោយពឹងផ្អែកលើព្រះជាម្ចាស់ទាំងស្រុងប៉ុណ្ណោះ (ចោទិយកថា ៧:៩)។ ប៉ុន្តែ សម្រាប់អស់អ្នកដែលមានបទពិសោធន៍

ជាច្រើនឆ្នាំក្នុងការជឿជាក់លើព្រះអម្ចាស់ទាំងនៅស្រុកកំណើត និងនៅបរទេស ទាំងនៅលើគោក និងលើទឹក ទាំងឈឺ និងជា នៅក្នុងគ្រោះថ្នាក់ តម្រូវការ ព្រមទាំងការជិតស្លាប់ ការភ័យខ្លាចបែបនេះនឹងមិនសមហេតុផលទាល់តែសោះ។

ពួកគេកំពុងធ្វើកិច្ចការសំខាន់ខ្លាំង ដែលមិនអាចដាក់ដែនកំណត់ដោយត្រឹមតែនិកាយមួយឡើយ។ ដោយដឹងថា អង្គការបេសកកម្មចិនដីគោកមិនផ្តល់ប្រាក់ខែ គឺល្មមនឹងរុញរាគ្រប់គ្នា លើកលែងតែអស់អ្នកដែលមានបទពិសោធន៍គ្រប់គ្រាន់នៅក្នុងការទុកចិត្តលើព្រះជាម្ចាស់ ហើយម្នាក់ៗចែករំលែកបទពិសោធន៍រួមគ្នា មិនមែនមានតែឈ្មោះ។

លោកគ្រូ ថេល័រ បានបន្តដោយនិយាយថា យើងត្រូវតែពិចារណា តើសមាជិកមកពីនិកាយផ្សេងអាចធ្វើការជាមួយគ្នាឆ្ពោះតម្រង់ទៅរកគម្រោងផ្សាយដំណឹងល្អដោយគ្មានជម្លោះនៃសេចក្តីជំនឿផ្ទាល់ខ្លួនបានដែរឬយ៉ាងណា។ បន្ទាប់ពីអធិស្ឋានយ៉ាងពេញទំហឹងរួច ហើយយល់ថាវាអាចទៅរួច យើងក៏បានសម្រេចចិត្តថា អញ្ជើញបងប្អូនរួមជំនឿផ្សេងៗទៀត ដែលបានទទួលយកព្រះបន្ទូលរបស់ព្រះយ៉ាងអស់ពីចិត្ត ហើយបានត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ហាញសេចក្តីជំនឿរបស់ពួកគេដោយការធ្វើដំណើរទៅកាន់ទឹកដីប្រទេសចិន ដោយពឹងផ្អែកទាំងស្រុងទៅលើព្រះបន្ទូលសន្យាទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរ។

ព្រះបន្ទូលបានចែងថា៖ «ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងអស់ រួមទាំងអាហារ និងសំលៀកបំពាក់នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង» (ម៉ាថាយ ៦:៣៣) ។ បើសិនមានអ្នកណាម្នាក់សង្ស័យថា ព្រះជាម្ចាស់មានព្រះបន្ទូលជាការពិតឬយ៉ាងណា នោះពួកគេមិនគួរទៅប្រទេសចិន ដើម្បីផ្សាយអំពីសេចក្តីជំនឿនោះឡើយ ប៉ុន្តែបើពួកគេជឿមែន នោះប្រាកដណាស់ថា ព្រះបន្ទូលសន្យាគ្រប់គ្រាន់ហើយសម្រាប់ពួកគេ។ យើងក៏មានការធានាពីទ្រង់ផងដែរថា៖ «…ទ្រង់នឹងមិនសំចៃទុករបស់ល្អអ្វី ដល់ពួកអ្នកដែលដើរដោយទៀងត្រង់ឡើយ» (ទំនុកតម្កើង ៨៤:១១)។ បើគេមិនបានតាំងចិត្តក្នុងការរស់នៅដោយសេចក្តីទៀងត្រង់ទេ នោះពួកគេគួរតែនៅផ្ទះ។ បើសិនពួកគេរស់នៅដោយសេចក្តីទៀងត្រង់វិញ នោះពួកគេមានអ្វីគ្រប់យ៉ាងដែលពួកគេត្រូវការដែលស្របតាមនៃការធានាហើយ។ ព្រះជាម្ចាស់ ទ្រង់គឺជាម្ចាស់លើគ្រប់ទាំងមាស និងប្រាក់នៅលើផែនដី ព្រមទាំងហ្វូងសត្វទាំងប៉ុន្មាននៅលើភ្នំទាំងពាន់ផង (ហាកាយ

២:៨; ទំនុកដំកើង ៥០:១០)។ យើងមិនចាំបាច់ត្រូវធ្វើជាអ្នកញុំាតែបន្លែទេ។

យើងអាចមានមូលនិធិគាំទ្រ បើសិនជាយើងចង់បានវា ប៉ុន្តែយើងគិតថា វាមិនចាំបាច់ និងអាចបង្កឲ្យមានគ្រោះថ្នាក់ផងដែរ។ យើងគួរតែមានការភ័យខ្លាច ចំពោះទាំងការប្រើថវិកាខុសគោលដៅ និងប្រាក់បរិច្ចាគមកដោយចេតនាខុសឆ្គង។ យើងអាចគ្រប់គ្រងថវិកាដែលព្រះអម្ចាស់បានសម្រេចព្រះទ័យប្រទានមកយើង ទោះបីតិចតួចយ៉ាងណាក្តី ប៉ុន្តែយើងមិនត្រូវទទួលយកប្រាក់ដែលមិនស្អាត ឬប្រាក់ដែលបានផ្តល់មកខុសកន្លែងនោះទេ។ វាជារឿងប្រសើរជាងក្នុងការដែលគ្មានប្រាក់ សូម្បីតែសម្រាប់ទិញនំប៉័ងបរិភោគ។ ប្រទេសចិនសំបូរសត្វក្អែកណាស់ ហើយព្រះអម្ចាស់ក៏អាចបញ្ជូនពួកវាឲ្យពាំអាហារមកឲ្យយើង។ ព្រះជាម្ចាស់បានប្រទានអាហារដល់ជនជាតិអ៊ីស្រាអែលបីលាននាក់នៅទីរហោស្ថានអស់រយៈពេលសែសិបឆ្នាំ។ ខណៈពេលដែលយើងមិនរំពឹងថា ទ្រង់នឹងបញ្ជូនបេសកជនបីលាននាក់ទៅកាន់ប្រទេសចិនទេ ប៉ុន្តែបើសិនជាទ្រង់បញ្ជូនមែន នោះទ្រង់ប្រាកដជានឹងមានធនធានគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ពួកគេទាំងអស់គ្នាដែរ។

ចូរឲ្យយើងប្រាកដថា យើងបន្តសម្លឹងមើលទៅកាន់ព្រះជាម្ចាស់ ដើរតាមផ្លូវរបស់ទ្រង់ ព្រមទាំងព្យាយាមឲ្យបានគាប់ព្រះទ័យ និងថ្វាយសិរីល្អដល់ទ្រង់ក្នុងគ្រប់ការទាំងអស់ មិនថារឿងតូច ឬធំប៉ុណ្ណាក្តី។ ចូរទុកចិត្តថា កិច្ចការដែលបានធ្វើតាមរបៀបរបស់ព្រះជាម្ចាស់ នឹងមិនចេះខ្វះជំនួយពីព្រះអង្គឡើយ។

កង្វល់សំខាន់មួយរបស់លោកគ្រូ ហ័ដសិន ថេល័រ គឺគាត់មិនចង់ឲ្យអង្គការបេសកកម្មថ្មីរបស់គាត់បង្អាក់មនុស្ស ឬធនធានពីអង្គការទាំងឡាយដែលមានស្រាប់នោះឡើយ។ វានឹងមិនចំណេញសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់នោះទេ ក្នុងការយកការងារពីម្នាក់ទៅប្រគល់ឲ្យម្នាក់ទៀតតាមរបៀបនេះ។ គម្រោងបានរាប់បញ្ចូលការធ្វើបន្ទប់ស្នាក់នៅសម្រាប់អ្នកបេសកជនដែលអង្គការបេសកកម្មដទៃមិនទទួល ជាពិសេសពួកអ្នកដែលមិនបានទទួលការអប់រំនៅសាកលវិទ្យាល័យ ហើយគ្មាននរណាម្នាក់ជួលពួកគេ ដើម្បីឲ្យចូលរួមក្នុងអង្គការបេសកកម្មនៅចិនដីគោកទេ។ ពួកគេជឿថា ប្រសិនបើព្រះជាម្ចាស់សព្វព្រះទ័យឲ្យពួកគេចូលរួមក្នុងកិច្ចការដ៏ជាក់លាក់មួយនេះ នោះទ្រង់នឹងជំរុញចិត្តពួកគេឲ្យស្ម័គ្រចិត្តចូលរួមផងដែរ។ ទន្ទឹមនឹងនោះដែរក៏នឹងគ្មានការអំពាវនាវសុំខាងផ្នែកហិរញ្ញវត្ថុនោះឡើយ។ ប្រសិនបើអង្គការបេសកកម្មចិនដីគោកនេះអាចដំណើរការទៅបានដោយ

ផ្អែកទៅលើការអធិស្ឋានតែម្យ៉ាង ដោយមិនចាំបាច់សុំគេឲ្យប្រាក់កាក់ ឬបង្កើតបញ្ជីអ្នកបរិច្ចាគ វាអាចចម្រើនឡើងជាមួយនឹងក្រុមអង្គការបេសកកម្មចាស់ដោយគ្មានការប្រថុយប្រថាននៃការប្តូរទិសដៅនៃការបរិច្ចាគផងដែរ។ ការធ្វើបែបនេះអាចមានប្រយោជន៍ ដោយបង្វែរការយកចិត្តទុកដាក់ចំពោះការយកចិត្តទុកដាក់លើព្រះអម្ចាស់នៃចម្រូតវិញ ហើយដោយផ្តល់ការអនុវត្តជាក់ស្តែងនៃជំនឿស្នូលដែលថា មានតែព្រះជាម្ចាស់តែមួយគត់ប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់កិច្ចការរបស់ទ្រង់។

ចំពោះអ្វីដែលនៅសល់ដែលត្រូវការរៀបចំ ពួកគេពេញចិត្តនឹងការចាត់ចែងដ៏សាមញ្ញរបស់អង្គការដែលទើបតែបានបង្កើតឡើងនេះ។ វាពិតជាអស្ចារ្យណាស់នៅក្នុងរបៀបដែលព្រះជាម្ចាស់បានប្រទានមនុស្សម្នាក់ ដើម្បីជួយគ្រប់គ្រងការងារអង្គការនៅក្នុងស្រុក។ លោក និងលោកស្រី បឺកហ្គ័រ នៅភ្នំសេនធ៍ (Mr. and Mrs. Berger of Saint Hill) បានក្លាយជាមិត្តសម្លាញ់ ដែលមានការប្តេជ្ញាចិត្តដូចលោក និងលោកស្រី ថេល័រ ដែរ។ ពួកគេបានអធិស្ឋាន ហើយបានលះបង់ជីវិតរបស់ពួកគេសម្រាប់ការនេះ ដោយផ្លាស់ប្តូរផ្ទះដ៏ស្រស់ស្អាតរបស់ពួកគេទៅជាមជ្ឈមណ្ឌល ដើម្បីជាប្រយោជន៍ដល់ព័ន្ធកិច្ចអង្គការបេសកកម្មនៅចិនដីគោក។

លោកគ្រូ ហ៉ដសិន បាននិយាយថា នៅពេលដែលគាត់បានសម្រេចចិត្តឈានទៅមុខជាមួយនឹងទំនាក់ទំនង នោះលោកគ្រូ បឹកហ្គ័រ បានយល់ព្រមធ្វើជាអ្នកតំណាងពួកគេក្នុងស្រុក។ ភាពជាដៃគូបានអភិវឌ្ឍដោយរលូន។ ពួកគាត់កាន់តែមានភាពជិតស្និទ្ធ។ ពួកគាត់បានដាក់ឈ្មោះអង្គការបេសកកម្មចិនដីគោកនេះនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់គាត់។ ពួកគាត់ទាំងពីរនាក់មិនបានសុំ ឬតែងតាំងអ្នកណា ដើម្បីជួយការងារនេះទេ វាបានកើតឡើងដោយឯកឯង។

ពួកបេក្ខជនបានពិភាក្សាគ្នា ហើយបានយល់ច្បាស់អំពីភាពសំខាន់នៃគោលការណ៍ខាងព្រលឹងវិញ្ញាណថា ជាមូលដ្ឋាននៃអង្គការបេសកកម្មចិនដីគោក។ ពួកគេបានឯកភាពគ្នាអំពីការរៀបចំយ៉ាងសាមញ្ញជាលាយលក្ខណ៍អក្សរនៅចំពោះវត្តមានរបស់លោកបឹកហ្គ័រ ហើយនោះគឺជាអ្វីដែលពួកគេបានធ្វើ។

លោកគ្រូ ថេល័រ បានលើកឡើងយ៉ាងសាមញ្ញថា យើងបានចែកទៅក្នុងនាមជាកូនព្រះ ដើម្បីធ្វើតាមសេចក្តីបង្គាប់របស់ទ្រង់ក្នុងការធ្វើការងាររបស់ព្រះអង្គ ដោយពឹងផ្អែក

លើទ្រង់ខាងផ្នែកធនធាន ដោយស្លៀកសំលៀកបំពាក់ដូចជាអ្នកក្នុងស្រុក ហើយដើម្បីទៅកន្លែងដាច់ស្រយាលក្នុងស្រុក។ ខ្ញុំជាអ្នកដឹកនាំនៃអង្គការបេសកកម្មប្រទេសចិន... នោះគ្មានការសង្ស័យទេថា អ្នកណានឹងដោះស្រាយបញ្ហាគ្រប់យ៉ាង។

ដូចគ្នានេះដែរ លោក បឹកហ្គ័រ ជាអ្នកគ្រប់គ្រងអង្គការនៅក្នុងស្រុក។ គាត់នឹងសរសេរឆ្លើយឆ្លងជាមួយពួកបេក្ខជន គ្រប់គ្រងមូលនិធិបោះពុម្ព និងផ្សាយទស្សនាវដ្ដីរបស់អង្គការម្តងម្កាលដែលមានការបញ្ជូនបេសកជនថ្មីនៅពេលមានប្រាក់មូលនិធិគ្រប់គ្រាន់ ហើយតែងតែជៀសវាងពីការជំពាក់បំណុលជានិច្ច។ ការជៀសវាងការជំពាក់បំណុល គឺជាគោលការណ៍គ្រឹះមួយសម្រាប់អ្នកគ្រប់គ្នាពាក់ព័ន្ធ។

វាងាយស្រួលដូចដែលព្រះជាម្ចាស់ប្រទានមកជាមុន ដូចដែលលោកគ្រូ ហ័ដសិន បានបង្ហាញ ហើយទ្រង់ក៏សព្វព្រះទ័យនៅក្នុងការធ្វើបែបនេះដែរ។ ព្រះប្រាជ្ញាញាណទ្រង់ពិបាកនឹងធ្វើឲ្យគោលបំណងរបស់ព្រះអង្គបរាជ័យ ដោយសារគ្រាន់តែខ្វះខាតប្រាក់កាក់ណាស់។ ទោះបីជាយ៉ាងណា ប្រាក់ដែលបានទទួលមកដោយមិនសមស្រប គឺប្រាកដជាបង្អាក់ដល់ព្រះពរជាមិនខាន។

បញ្ហាជាច្រើនអាចដោះស្រាយបានតែតាមរយៈបទពិសោធន៍ប៉ុណ្ណោះ ដូចយើងអាចមើលឃើញនៅឧទាហរណ៍ជាក់ស្តែងរបស់លោក បឹកហ្គ័រ។ គាត់ធ្លាប់ជាអ្នកដឹកនាំជំនួញដ៏ជោគជ័យម្នាក់ និងជាអ្នកផលិតម្សៅជំឡូង។ គាត់បានយល់ថា វាដូចជាដើមឈើនៅលើដីផ្ទះគាត់អញ្ចឹង អ្វីដែលមានជីវិតវានឹងលូតលាស់។

លោកអ្នកត្រូវតែរង់ចាំដើមឈើឲ្យលូតលាស់សិន មុនពេលវាអាចបែកមែកសាខាបានច្រើន។ ជាដំបូង លោកអ្នកមានត្រឹមតែគល់ដ៏តូចមួយព្រមទាំងស្លឹកពីរបីសន្លឹក ឬក៏មានតែពន្លកតិចៗប៉ុណ្ណោះ។ បន្ទាប់មក មែកតូចៗក៏ចាប់ផ្តើមលេចឡើងមក។ ចុងក្រោយមែកតូចៗទាំងនេះនឹងត្រឡប់ទៅជាមែកធំៗ ស្ទើរតែដូចជាដើមឈើផ្សេងទៀតអញ្ចឹង។ ប៉ុន្តែ រឿងទាំងអស់នេះត្រូវការពេលវេលា និងការអត់ធ្មត់។ ប្រសិនបើដើមឈើនៅមានជីវិត វានឹងលូតលាស់តាមរបៀបរបស់វាជាមិនខាន។

នៅពេលដែលក្រុមដំបូងរបស់អង្គការបេសកកម្មចិនដីគោកបានរៀបចំធ្វើដំណើរតាមកប៉ាល់ទៅ ពួកគេបានទទួលការឆ្លើយតបពីការអធិស្ឋានរបស់ពួកគេជាច្រើន។ ការឆ្លើយតបពីការអធិស្ឋានរបស់ពួកគេពិតជាការអស្ចារ្យយ៉ាងខ្លាំង ដូច្នេះពួកគេបានសៀតបញ្ចូល

ព័ត៌មានថ្មីនេះនៅក្នុងទស្សនាវដ្ដីដំបូងនោះ (First Occasional Paper) ដោយការលើកឡើងថា ចំនួនសរុបទាំងអស់ដែលបានត្រូវការសម្រាប់ការធ្វើដំណើរ និងគ្រឿងស្លៀកពាក់បានទទួលរួចរាល់ហើយ។ បទពិសោធន៍ទាំងនេះបានកើតចេញពីការអធិស្ឋានរាល់ពេលថ្ងៃត្រង់នៅផ្ទះរបស់លោកគ្រូ ហ៊ុដសិន ថេល័រ ពីការប្រជុំនៅទីនោះរាល់សប្ដាហ៍ និងនៅ សេនធ៍ ហៀល ព្រមទាំងថ្ងៃសម្រាប់ការអធិស្ឋានពិសេសៗ និងការតមអាហារផងដែរ។ គ្រប់រឿងរ៉ាវទាំងអស់នោះជំរុញឲ្យមានទំនាក់ទំនងដ៏ជិតស្និទ្ធ និងពេញដោយអំណរជាមួយព្រះជាម្ចាស់។

ភាពមិនសំខាន់របស់មនុស្ស និងភាពគ្រប់គ្រាន់របស់ព្រះជាម្ចាស់ក៏បានស្ដែងយ៉ាងច្បាស់នៅថ្ងៃចុងក្រោយទាំងនោះនៅផ្លូវ ខូប៊ើន (Coborn)។ មិត្តសម្លាញ់របស់គាត់ដែលបានមកសួរសុខទុក្ខគាត់ និងត្រឡប់មកដោយមានអារម្មណ៍ដូចនោះដែរ។ ក្នុងចំណោមប្រអប់និងកញ្ចប់ជាច្រើន យើងបានចូលរួមប្រជុំអធិស្ឋានចុងក្រោយជាមួយនឹងមនុស្សកកកុញដែលពេញបន្ទប់ និងជណ្ដើរដោយពួកគេនៅកន្លែងណាដែលអង្គុយបាន។ ផែនទីនៅព្យួរនៅលើជញ្ជាំងនៅឡើយ ហើយមានព្រះគម្ពីរមួយដែលត្រូវបើក រួចបានដាក់នៅលើតុ។

លោកគ្រូ ថេល័រ បានសរសេរថា បំណងប្រាថ្នា និងគោលបំណងដ៏ធំនៃបេសកកម្មថ្មីរបស់ពួកយើង គឺដើម្បីបង្កើតឲ្យមានវត្តមានគ្រីស្ទបរិស័ទនៅខេត្តដែលមិនទាន់មានបេសកជនទៅដល់ទាំងដប់មួយរបស់ប្រទេសចិន និងនៅក្នុងទឹកដីធ្លាក់ក្រោមការគ្រប់គ្រងរបស់ប្រទេសចិននៅរាជ្យវង្សឈីង (ជាទឹកដីតំបន់ ម៉ាន់ជូរី ម៉ុងហ្គោលី ស៊ីនជាំង និងទីបេ Chinese Tartary) ។

“អស់អ្នកដែលបានឃើញត្រឹមតែការលំបាកបាននិយាយថា វាជារឿងដ៏ល្ងីល្ងើ។ អ្នកផ្សេងដែលមានបំណងល្អចំពោះពួកយើងនឹងឃើញថា វាជាកិច្ចការរបស់មនុស្សអស្ចារ្យ។ មិត្តសម្លាញ់ជាច្រើនរបស់ពួកគេមិនអាចធ្វើអ្វីបានក្រៅពីបារម្ភឡើយ”។

អ្នកខ្លះបារម្ភថា គេអាចនឹងបំភ្លេចលោកអ្នកចោល។ គ្មានគណកម្មការ ឬក៏អង្គការមកតំណាងឲ្យលោកអ្នកដល់សាធារណៈជន លោកអ្នកអាចនឹងមិនមានការយកចិត្តទុកដាក់នៅទឹកដីដ៏សែនឆ្ងាយនោះ។ មានការអះអាងជាច្រើននៅសព្វថ្ងៃនេះ។ ហើយមិនយូរប៉ុន្មាន លោកអ្នកអាចនឹងមានអារម្មណ៍ថា ខ្វះសូម្បីតែភាពសំខាន់នៃជីវិត។

គាត់ឆ្លើយដោយស្រទន់ថាៈ «ខ្ញុំនឹងយកកូនៗខ្ញុំទៅជាមួយខ្ញុំ វាមិនពិបាកក្នុងការចងចាំថា ពួកគេត្រូវការអាហារពេលព្រឹក នៅពេលព្រឹក អាហារពេលថ្ងៃត្រង់ នៅកណ្ដាលថ្ងៃត្រង់ ហើយអាហារពេលល្ងាចនៅពេលយប់ទេ។ តាមពិតទៅ ខ្ញុំមិនអាចបំភ្លេចពួកគេបានឡើយ បើទោះបីជាខ្ញុំបានព្យាយាមបំភ្លេចពួកគេក៏ដោយ។ ហើយខ្ញុំក៏មិនជឿថាព្រះវរបិតាដែលគង់នៅស្ថានសួគ៌យកព្រះទ័យទុកដាក់ និងថែរក្សាបីបាច់កូនៗរបស់ខ្ញុំដែលជាកូនៗរបស់ទ្រង់ តិចជាងខ្ញុំដែលគ្រាន់តែជាឪពុកនៅលើផែនដីនោះទេ ។ ទេ! ទ្រង់នឹងមិនបំភ្លេចយើងទេ!»។

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ទំនុកចិត្តរបស់ពួកគេកើនច្រើនឡើងៗ ហើយត្រូវបានបង្ហាញថាជាត្រឹមត្រូវ ដោយសារអស់អ្នកដែលពួកគេបាននាំមក។

ជំពូកទី១២

# ភាពបន្ទាន់ខាងឯព្រលឹងវិញ្ញាណ

*មនុស្សស្លាប់ក្នុងភាពងងឹតនៅក្បែរអ្នក ដោយគ្មានក្ដីសង្ឃឹមណាមួយជួយបំភ្លឺផ្លូវរបស់ពួកគេឡើយ។ ចូរចាប់ចន្លុះ ហើយគ្រវីវាឲ្យធំ ចន្លុះនោះនឹងបំភ្លឺគ្រាដែលងងឹតបំផុត។*

*— លោក អេច. បូណា៎រ (H. Bonar)*

កំណត់ត្រានៅពីរបីឆ្នាំបន្ទាប់ បង្ហាញយ៉ាងច្បាស់អំពីការគាំទ្រដ៏ខ្លាំងក្លានៅពីក្រោយអ្នកដឹកនាំ និងអ្នកចម្រូតដំបូងជាច្រើនរបស់បេសកកម្មថ្មីនេះ។ ជាក់ស្ដែងណាស់ថាព្រលឹងវិញ្ញាណដែលពេញដោយការឆេះឆួលបានជំរុញពួកគេ—ឲ្យមានភាពឆេះឆួលខ្លាំងដែលបានជួយពួកគេឲ្យយកឈ្នះលើឧបសគ្គ និងការសាកល្បងគ្រប់បែបយ៉ាង។ សេចក្ដីស្រឡាញ់ឥតស្រាកស្រាន្ដរបស់ពួកគេចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទ បានចាក់បំពេញពួកគេដោយសេចក្ដីអំណរ ដោយទ្រង់បានផ្ដល់ឯកសិទ្ធិឲ្យពួកគេស្គាល់ទ្រង់នឹងចូលរួមក្នុងការរងទុក្ខរបស់ទ្រង់ក្នុងរបៀបថ្មី និងស៊ីជម្រៅជាងមុន (ភីលីព ៣:១០)។ ពួកគេក៏មានអារម្មណ៍ថា សេចក្ដីស្រឡាញ់ដ៏ខ្លាំងរបស់ទ្រង់បានជំរុញពួកគេចំពោះព្រលឹងដែលកំពុងតែស្លាប់នៅជុំវិញខ្លួនដែរ (១កូរិនថូស ៥:១៤)។ សព្វថ្ងៃនេះ វាហាក់បីដូចជាហួសសម័យបន្តិចនៅក្នុងការនិយាយអំពីព្រលឹងដែលត្រូវការសេចក្ដីសង្គ្រោះ។ ទោះបីជាយ៉ាង

ណាក្តី កណ្ឌគម្ពីរយ៉ូហាន ៣:១៦ រម្លឹកយើងថា សេចក្តីស្រឡាញ់នៃព្រះជាម្ចាស់ និងព្រះយេស៊ូវគឺជាកម្លាំងជំរុញចិត្ត ដែលបង្កើតផលផ្លែតាមរយៈអ្នកជឿទាំងឡាយ ដោយលើសអស់ទាំងប្រាជ្ញា និងធនធានទាំងអស់នៅលើលោកីយ៍នេះ។

«ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។

នៅសម័យទំនើបនេះ យើងប្រហែលជាមានទ្រព្យសម្បត្តិកាន់តែច្រើន រីករាយនឹងការអប់រំកាន់តែប្រសើរ ព្រមទាំងទទួលបានបទពិសោធន៍កាន់តែងាយស្រួលក្នុងការធ្វើដំណើរ និងអ្វីៗដែលនៅជុំវិញខ្លួនយើង សូម្បីតែការធ្វើជាបេសកជនក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ តើយើងមានអារម្មណ៍ដូចគ្នានៃភាពបន្ទាន់ និងការជឿជាក់យ៉ាងជ្រាលជ្រៅដែលជំរុញអ្នកកាន់តំណែងមុនរបស់យើងដែរឬទេ? តើយើងចែករំលែកក្តីស្រឡាញ់ផ្ទាល់ខ្លួនដ៏ឆេះឆួលដូចគ្នាចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទដែរឬទេ? បើយើងខ្វះចំណុចទាំងនេះ វាជាការខាតបង់ដែលគ្មានអ្វីអាចមកជំនួសបានទេ។

មានក្រុមតូចមួយ បានធ្វើដំណើរឆ្លងកាត់សមុទ្រពណ៌ខៀវស្រងាត់ និងដែនទឹកដែលគ្មានព្រំដែន ដើម្បីបម្រើព្រះជាម្ចាស់របស់ពួកគេ។ ពួកគេឆ្លងកាត់មហាសមុទ្រដ៏ធំសម្បើម ដើម្បីនាំសាររបស់ព្រះសង្គ្រោះអេម៉ាញូអែលទៅដែនដីដ៏សែនឆ្ងាយហៅថា ស៊ីននីម (Sinim អេសាយ ៤៩:១២)។ ពួកគេបានឮសម្រែកពីទិសបូព៌ាដ៏ឆ្ងាយ ជាសម្លេងស្រែកហៅនៃឈាមបងប្អូនរបស់ពួកគេ៖ ជារៀងរាល់ខែ មនុស្សចំនួនមួយលាននាក់បានស្លាប់នៅប្រទេសចិន ដោយមិនបានស្គាល់ព្រះជាម្ចាស់សោះ។ ពួកគេគ្មានជំនួយឯណាក្រៅពីព្រះជាម្ចាស់តែមួយអង្គគត់ ហើយពួកគេពឹងផ្អែកលើព្រះវរបិតារបស់ខ្លួនសម្រាប់ការផ្គត់ផ្គង់សេចក្តីត្រូវការនៅប្រទេសក្រៅរបស់ពួកគេដែរ។ ព្រះជាម្ចាស់គឺជាម្ចាស់លើភាពពេញលេញរបស់ពិភពលោក ហើយគ្រប់ទាំងអំណាចនៅលើលោកីយ៍ និងនៅស្ថានសួគ៌ក៏ជារបស់ផងទ្រង់ដែរ។ បើទោះបីជាមានភាពទន់ខ្សោយក៏ដោយ ក៏ពួកគេឈរមាំ ទោះបីជាក្រក្តី ក៏ពួកគេជាអ្នកមានតាមរយៈសេចក្តីសន្យារបស់ផងទ្រង់ដែរ។ វាល្មមគ្រប់គ្រាន់សម្រាប់ពួកគេហើយ—ពួកគេឆ្លើយតបចំពោះសម្រែកទួញសោក ដែលជាសម្រែកឈាមរបស់បងប្អូនខ្លួន៖ ជារៀងរាល់ខែ មនុស្សចំនួនមួយលាននាក់វិនាសនៅប្រទេស

ចិន ដោយមិនស្គាល់ព្រះជាម្ចាស់ឡើយ។

ការធ្វើដំណើរតាមសំពៅក្តោង ដែលតូចជាងប្រាំបីរយតោនអស់រយៈពេលបួនខែ គឺជាឧបសគ្គមួយដ៏ធំសម្រាប់ក្រុមបេសកជនដប់ប្រាំមួយនាក់ ព្រមទាំងកូនៗបួននាក់ទៀត។ ពួកគេបានអធិស្ឋានជាច្រើនមុនពេលធ្វើដំណើរ ដោយអធិស្ឋានសូមមិនត្រឹមតែសុវត្ថិភាពនោះទេ ប៉ុន្តែក៏អធិស្ឋានសូមឲ្យនាយសំពៅអាចទទួលដំណឹងល្អរបស់ព្រះជាម្ចាស់ផងដែរ។ ពួកគេបានចំណាយពេលមួយថ្ងៃរៀបចំបន្ទប់តូចលើកប៉ាល់ មុនពេលចាប់ផ្តើមរៀនភាសាចិន ដោយមានលោក ថេល័រ ជាអ្នកបង្រៀននៅពេលព្រឹក ហើយលោកស្រី ថេល័រ ជាអ្នកបង្រៀននៅពេលរសៀល។ ពេលខ្លះ ពួកសិស្សពុលទូកទាំងអស់គ្នា ដោយទុកឲ្យគ្រូបង្រៀនធ្វើកាតព្វកិច្ចបម្រើច្រើនឡើង ហើយថែមទាំងធ្វើជាអ្នកបម្រើពួកគេទៀតផង។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេសម្របខ្លួននឹងការជិះសំពៅក្តោងបាន ហើយពួកបេសកជនក្មេងៗទម្លាប់ទៅនឹងជីវិតនៅលើសមុទ្របានយ៉ាងឆាប់រហ័ស។ ពួកគេទាំងអស់គ្នានៅក្មេងណាស់ៗ ដោយមានអ្នកដឹកនាំមានវ័យសាមសិបបួនឆ្នាំ គឺជាអ្នកមានអាយុច្រើនជាងគេក្នុងក្រុមនោះ។

នៅលើសំពៅក្តោងតូចនោះ និងការរស់នៅជិតៗគ្នាបានសាកល្បងលក្ខណសម្បត្តិរបស់ពួកគេ ដោយអនុញ្ញាតឲ្យពួកនាយសំពៅឃើញថាតើ ពួកអ្នកដំណើរពិតជាបានអនុវត្តនូវអ្វី ដែលពួកគេបានបង្រៀនដែរឬយ៉ាងណា។ ច្បាស់ណាស់ ពួកនាយសំពៅបានសង្កេតមើលពួកគេយ៉ាងដិតដល់ ទាំងអំឡុងពេលពួកគេធ្វើការ និងអំឡុងពេលពួកគេទំនេរ។ ពួកបេសកជនបានធ្វើយ៉ាងល្អបំផុត ដើម្បីធ្វើឲ្យការធ្វើដំណើរមានភាពរីករាយដល់អ្នកគ្រប់គ្នាដែលនៅលើទូក តាមរយៈការអធិស្ឋាន និងការរង់ចាំដោយអត់ធ្មត់។ ក្រោយមក ពួកនាវិកបានស្នើសុំចូលរួមជួបប្រជុំដោយខ្លួនគេផ្ទាល់ ហើយការនេះបានដឹកនាំទៅរកចលនាផ្លាស់ប្តូរខាងព្រលឹងវិញ្ញាណ ដែលជាលទ្ធផលពួកនាវិកភាគច្រើនប្រែចិត្តទទួលជឿព្រះ។ ដោយអានសំបុត្រចាប់ត្រង់នោះមក បង្ហាញពីការទទួលខុសត្រូវគួរឲ្យចាប់អារម្មណ៍មួយរបស់ពួកអ្នកត្រួសត្រាយផ្លូវអង្គការបេសកកម្មចិនដីគោកដែលបានលះបង់គ្រប់ទាំងអស់ក្នុងការដឹកនាំព្រលឹងដែលបាត់បង់ទៅកាន់ព្រះគ្រីស្ទ។ ពួកគាត់មិនល្អគ្រប់លក្ខណ៍នោះទេ ហើយជួនកាលកំហុសរបស់ពួកគាត់បានរារាំងផ្លូវព័ន្ធកិច្ចរបស់ខ្លួន។ ប៉ុន្តែ ពួកគាត់មិនគ្រាន់តែទទួលកំហុសទាំងនេះនោះទេ។ ពួកគាត់

ក៏បានសោកស្ដាយដោយស្មោះអស់ពីចិត្ត និងបានទទួលស្គាល់ភាពបរាជ័យទាំងឡាយរបស់ខ្លួនផងដែរ ដែលសេចក្ដីនោះបានផ្សះផ្សាទំនាក់ទំនងខាងព្រលឹងវិញ្ញាណរបស់ពួកគាត់ និងជាមួយអ្នកដទៃទៀតផង។

បន្ទាប់មក វាហាក់បីដូចជាខ្មាំងសត្រូវដ៏ធំមិនអាចបំផ្លាញប្រយោជន៍របស់ក្រុមបេសកជនទៀតបាន «មេគ្រប់គ្រងរាជ្យលើអាកាស» បានសម្រេចចិត្តចង់ពន្លិចសំពៅ និងអ្វីគ្រប់យ៉ាងទាំងអស់ជំនួសវិញ (អេភេសូរ ២:២)។ ប៉ុន្តែណាពិតជាការអស្ចារ្យមែន ដែលពួកគេបានទៅដល់ទិសដៅរបស់ខ្លួនដោយសុវត្ថិភាព បើទោះបីពួកគាត់បានប្រឈមមុខនឹងព្យុះសង្ឃរា និងខ្យល់គំហុកនៅតាមផ្លូវទៅសមុទ្រចិនក៏ដោយ។ ក្នុងរយៈពេលដប់ប្រាំថ្ងៃ ព្យុះសង្ឃរាបានបោកបក់មកមួយហើយមួយទៀតមកលើពួកគេ ដោយបានបណ្ដាលឲ្យទូករបស់ពួកគាត់ស្ទើរតែបាក់បែកអស់។

លោកគ្រូ ហ័ដសិន បានសរសេរនៅដប់ពីរថ្ងៃក្រោយជួបប្រទះនឹងបទពិសោធន៍នេះដែលទស្សនីភាពពិតជាគួរឲ្យខ្លាចណាស់។ សំពៅបានរំកិលយ៉ាងខ្លាំងដែលគួរឲ្យភ័យខ្លាច ដងក្ដោងរបស់សំពៅ និងធ្នឹមផ្ដេកបានបាក់ចុះ ដោយធ្វើឲ្យរហែកក្ដោងសំពៅ ហើយបានបោក និងបុកយ៉ាងខ្លាំងនឹងបរិវេណសំខាន់នៃទូក។ ផ្នែកខាងក្រៅនៃទូកមានរលកមិនដាច់សោះពីត្រង់ក្បាលសំពៅកន្លែងពួកកម្មករបន្ទោរបង់ទៅដល់កន្សៃសំពៅ។ សម្លេងគ្រហឹមរបស់ទឹករលក សម្លេងទង្គិចគ្នារបស់ច្រវាក់ ដងក្ដោង និងធ្នឹមផ្ដេកបានបាក់បែក និងក្ដោងស្រួចបានរហែកដែលធ្វើឲ្យមិនអាចឮអ្វីផ្សេងក្រៅពីសម្លេងទាំងនេះ។

អស់រយៈពេលបីថ្ងៃ គ្រោះថ្នាក់កាន់តែកើនឡើង ពីព្រោះទឹកបានចូលសំពៅបាននាំទៅតាមខ្សែទឹកយ៉ាងលឿន។ ភ្លើងទាំងអស់បានរលត់ រកធ្វើម្ហូបអ្វីមិនបានសោះ។ អស់មួយរយៈ ក៏គ្មានទឹកស្អាតសម្រាប់បរិភោគ ហើយទាំងបុរស និងស្ត្រីបានបូមទឹកចេញពីសំពៅ។ ទោះជាយ៉ាងណាក្ដី ការអធិស្ឋាននៅតែជាចម្លើយដ៏អស្ចារ្យ ដែលគ្មាននរណាម្នាក់បានបាត់បង់ជីវិត ឬក៏រងរបួសធ្ងន់ធ្ងរនោះឡើយ។ ការអធិស្ឋានបានរក្សាសេចក្ដីសុខសាន្តលើសពីការយល់បាន សូម្បីតែម្ដាយដែលបារម្ភអំពីកូនៗរបស់គាត់ ក៏អាចទទួលបានបទពិសោធន៍ ដូចអ្វីដែលកណ្ឌគម្ពីរហាបាគុក ៣:១៨ បានពណ៌នាថា៖ «គង់តែខ្ញុំនឹងរីករាយ ដោយសារព្រះយេហូវ៉ា ខ្ញុំនឹងអរសប្បាយក្នុងព្រះដ៏ជួយសង្គ្រោះខ្ញុំដែរ»។

ការឆ្លើយតបចំពោះការអធិស្ឋាន គឺអស្ចារ្យដូចនៅពេលក្រោយៗមកទៀតអញ្ចឹង នៅ

ពេលដែលក្រុមបានចេញដំណើរពីទីក្រុងសៀងហៃ គ្រប់គ្នាបានស្លៀកសំលៀកបំពាក់ចិន ដើម្បីស្វែងរកផ្ទះនៅលើទឹកដីនាពេលអនាគតដ៏គោកដ៏ឆ្ងាយ។ ការធ្វើដំណើរតាមផ្ទះលើទូកបានជួយឲ្យស្ត្រី និងក្មេងអាចលាក់ខ្លួនពីពួកអ្នកដែលចង់ដឹងចង់ឮដ៏សម្បើម នៅពេលពួកគេបានធ្វើដំណើរឆ្លងកាត់ពីក្រុងមួយទៅទីក្រុងមួយទៀត ស្របពេលកំពុងព្យាយាមរកកន្លែងមួយសម្រាប់ពួកកម្លោះៗតាំងលំនៅ។ ទោះជាយ៉ាងណា ពួកគេបានប្រឈមនឹងភាពបរាជ័យមួយហើយមួយទៀត។ គ្រប់ពេលពួកគេបានគិតថា ពួកគេបានទទួលបានជោគជ័យ ការចចារបែរជាត្រូវបរាជ័យ ដែលពួកគេត្រូវបន្តដំណើររបស់ពួកគេទៅស្រុកហានចូវ (Hangzhou) ជាក្រុមតែមួយដដែល។ គ្រួសារបេសកជនពីរបីគ្រួសារបានតាំងលំនៅនៅទីក្រុងនោះ ហើយការមកដល់របស់ក្រុមដ៏ធំបែបនេះអាចបង្កឲ្យមានការគម្រាមកំហែងយ៉ាងខ្លាំងដល់ពួកគេ ព្រមទាំងបណ្ដាលឲ្យមានការប្រឆាំងយ៉ាងខ្លាំង។ ដោយសារត្រូវបានប្រឈមមុខជាមួយភាពចុះត្រជាក់ខ្លាំងនៅពេលយប់នៅលើផ្ទៃទឹក និងសមាជិកក្រុមពីរបីនាក់បានធ្លាក់ខ្លួនឈឺ ហើយពួកនាវិកចង់ត្រឡប់ទៅផ្ទះសម្រាប់រដូវរងា ដូច្នេះពួកគេគ្មានជម្រើសឯទៀត។ លោកគ្រូ ហ៉ាដសិន បានទទួលបន្ទុកទំនួលខុសត្រូវធ្ងន់ជាងពេលណាៗទាំងអស់ នៅពេលដែលគាត់ចាកចេញពីទូកនៅតំបន់ដាច់ស្រយាលខាងក្រៅទីក្រុង ដើម្បីស្វែងរកកន្លែងស្នាក់នៅចាំបាច់ជាបន្ទាន់។

លោកស្រី ថេល័រ បានគិតអំពីស្ថានភាពយ៉ាងស៊ីជម្រៅ ដោយមានសេចក្ដីជំនឿយ៉ាងទំនុកចិត្ត និងស្ងប់ស្ងៀម គាត់ក៏បាននាំបេសកជនវ័យក្មេងទាំងនេះមក ដើម្បីអធិស្ឋានជាមួយគ្នា។  គាត់បានលើកឡើងពីការកម្សាន្តចិត្តដែលគាត់បានទទួលពីកណ្ឌគម្ពីរទំនុកតម្កើង ដែលគាត់អាននៅព្រឹកនោះថា៖ «តើអ្នកណានឹងនាំទូលបង្គំចូលក្នុងទីក្រុងមាំមួនបាន តើអ្នកណានឹងនាំទូលបង្គំទៅឯស្រុកអេដំម ឱព្រះអង្គអើយ…សូមទ្រង់ប្រោសមេត្តាជួយយើងខ្ញុំទាស់នឹងពួកសត្រូវ ដ្បិតសេចក្ដីជំនួយរបស់មនុស្ស នោះឥតប្រយោជន៍ទេ»។ ពួកគេអានព្រះគម្ពីរជាមួយគ្នា ហើយបន្ទាប់មកការអធិស្ឋានរយៈពេលមួយម៉ោងនោះ ការថប់បារម្ភដ៏ឈឺចាប់បានក្លាយទៅជាពេលវេលាគួរឲ្យចងចាំមួយនៃការប្រកបគ្នា។

តើសំឡេងរបស់លោកគ្រូ ហ៉ាដសិន នៅខាងក្រៅធ្វើឲ្យមនុស្សនៅក្នុងទូករំជួលចិត្តមែនទេ? តើគាត់អាចត្រឡប់មកបានយ៉ាងឆាប់បែបនេះមែនទេ? ហើយតើគាត់បាននាំដំណឹងអ្វីមកដែរ? «មុនដែលគេអំពាវនាវ នោះអញនឹងតបឆ្លើយ ហើយកាលគេកំពុងតែ

ចេញសម្ដីនៅឡើយ នោះអញនឹងស្ដាប់ដែរ» (អេសាយ ៦៥:២៤)។ បាទ! គ្រប់យ៉ាងមិនអីទេ ផ្ទះមួយខ្នងបានរៀបចំរួចរាល់ ហើយកំពុងតែរង់ចាំពួកគេ។ បេសកជនម្នាក់នៅទីក្រុងហានចូវ ត្រូវទៅឆ្ងាយរយៈពេលមួយសប្ដាហ៍ ហើយបានទុកសំបុត្រមួយច្បាប់ថា៖ ផ្ទះរបស់គាត់ មានគ្រឿងសង្ហារិមយ៉ាងស្រួលនៅទំនេរសម្រាប់ក្រុមរបស់លោកគ្រូ ហ៉ដសិន។ ដោយមានទីតាំងនៅផ្លូវស្ងាត់មួយ ពួកគេអាចទៅដល់ទីនោះដោយទូកបាន ដោយគ្មានអ្នកណាចាប់អារម្មណ៍នោះទេ ហើយនៅយប់នោះ ពួកអ្នកធ្វើដំណើរដែលនឿយហត់ និងរីករាយបានសម្រាកនៅទីក្រុងដ៏ធំនោះ។

ក្នុងអំឡុងពេលពីរបីថ្ងៃ ទោះបីជាធម្មតាលំបាកក្ដី ក៏លោកគ្រូ ហ៉ដសិន បានរកបានផ្ទះមួយសម្រាប់ពួកគាត់នៅដែរ—លំនៅឋានដ៏ធំទូលាយ ដែលពីមុនធ្លាប់ជាលំនៅឋានរបស់មន្ត្រីរាជការម្នាក់ ពេលនេះបានប្រែក្លាយទៅជាកន្លែងរស់នៅដ៏តូចចង្អៀតសម្រាប់មនុស្សជាច្រើនគ្រួសារ។ ផ្ទះនោះ គឺសមស្របសម្រាប់ការសម្រេបខ្លួន ហើយបើទោះបីជាម្ចាស់ថ្មីបានកាន់កាប់ផ្ទះនោះមួយផ្នែកក៏ដោយ ក៏ពួកគេបានផ្ដើមការងារព័ន្ធកិច្ចរបស់ពួកគេជាមួយអ្នកជិតខាងនៅក្នុងលំនៅដ្ឋានរបស់ពួកគេដែរ។ ចិត្តដែលពេញដោយសេចក្ដីស្រឡាញ់មិនត្រូវការពាក្យសម្ដីច្រើន ដើម្បីមកបញ្ជាក់នោះទេ ហើយកញ្ញា ហ្វូលឌីង (Miss Faulding) ដែលជាសមាជិកក្មេងជាងគេនៅក្នុងក្រុមអាចមានទំនាក់ទំនងជាមួយស្ត្រីដទៃទៀតបានហើយ។

នាងបានសរសេរនៅពាក់កណ្ដាលខែធ្នូថា យើងបានធ្វើឲ្យផ្ទះកាន់តែកក់ក្ដៅបន្តិចឡើងហើយ ប៉ុន្តែក៏នៅមានអ្វីជាច្រើនដែលត្រូវធ្វើផងដែរ។ លោកគ្រូ ហ៉ដសិន និងបុរសក្មេងៗទាំងនោះបានធ្វើពិដានក្រដាសនៅលើស៊ុមឈើ ដើម្បីរាំងខ្យល់ត្រជាក់ ដោយសារតែបន្ទប់នៅជាន់លើមានដំបូលដូចជាបន្ទប់ថ្វាយបង្គំ។ ពួកគេបានបិទក្រដាសលើរនាំងខណ្ឌចែកបន្ទប់ផ្សេងៗ។ យើងក៏នៅតែមានភាពរញ៉េរញ៉ៃបន្តិចដែរ ប៉ុន្តែយើងក៏កំពុងតែដំណើរការទៅមុខដែរ ហើយខ្ញុំសង្ឃឹមថា យើងនឹងដោះស្រាយវារួចរាល់នៅថ្ងៃណាមួយ។

អ្នកស្នាក់នៅនឹងចាកចេញនៅសប្ដាហ៍ក្រោយ។ ពួកគេភាគច្រើនរស់នៅបន្ទប់ជាន់ផ្ទាល់ដី។ ខ្ញុំសប្បាយចិត្តណាស់ដែលពួកគេនៅទីនេះ ពីព្រោះមនុស្សជាច្រើនបានចូលរួមការអធិស្ឋានជាភាសាចិន ហើយបានស្ដាប់យ៉ាងយកចិត្តទុកដាក់។ យើងមិនទាន់អាចទៅសួរសុខទុក្ខបាននៅខាងក្រៅឡើយទេ ប៉ុន្តែខ្ញុំក៏បានអាន និងបាននិយាយជាមួយនឹង

ពួកស្ត្រីទាំងនោះជារៀងរាល់ថ្ងៃដែរ ហើយពួកគាត់ហាក់បីដូចជាចូលចិត្តចំពោះការចូលរួមនោះណាស់ដែរ។ ខ្ញុំមានសេចក្តីសង្ឃឹមខ្លាំងចំពោះស្ត្រីម្នាក់។

មុនថ្ងៃបុណ្យណូអែលចូលមកដល់ មនុស្សហាសិបទៅហុកសិបនាក់បានចូលរួមយ៉ាងជាប់លាប់ក្នុងការថ្វាយបង្គំរាល់ថ្ងៃអាទិត្យ ហើយលោកគ្រូ ថេល័រ បានបញ្ចប់សព្វគ្រប់ហើយនូវដំណើរការផ្សាយដំណឹងល្អយ៉ាងហោចណាស់ក៏មួយជើងដែរ។ នៅជិតទីក្រុងសាវហ្សាន (Siaoshan) លោកគ្រូ ហ័ដសិន និងលោក មីដដូវស៍ (Mr. Meadows) ចាប់បានឱកាសដ៏ល្អក្នុងការប្រកាសដំណឹងល្អ ហើយបានរៀបចំជួលផ្ទះតូចមួយ ដោយមានគម្រោងរៀបចំឲ្យអ្នកមកថ្មីខ្លះបានស្នាក់នៅទីនោះយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ សំបុត្រគាត់ផ្ញើទៅលោក ប៊ើកហ្គើ ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្ត និងចិត្តឆេះឆួលក្នុងការធ្វើបេសកកម្មដ៏សំខាន់របស់ពួកគេ។

“លោកគ្រូនឹងសប្បាយចិត្តដោយដឹងថា វិធីផ្ញើសំបុត្រនានាដោយអ្នកនាំសំបុត្រក្នុងស្រុក និងការផ្ទេរប្រាក់ទៅក្នុងប្រទេស គឺពិតជាមានប្រសិទ្ធិភាពណាស់។ ខ្ញុំមិនរំពឹងថាលោកគ្រូនឹងមានបញ្ហានៅក្នុងការផ្ញើប្រាក់ទៅបណ្តាខេត្តណាមួយនៅក្នុងចក្រភព ដែលមិនអាចដោះស្រាយបានយ៉ាងឆាប់រហ័សនោះទេ។ ស្រដៀងគ្នានេះដែរ លោកគ្រូក៏អាចផ្ញើសំបុត្រនានាពីតំបន់ដាច់ស្រយាលបំផុតទៅកាន់កំពង់ផែបានដែរ។ ការទំនាក់ទំនងនេះ មានការយឺតយ៉ាវ ហើយប្រហែលជានឹងមានតម្លៃថ្លៃ ប៉ុន្តែវាក៏អាចគួរឲ្យទុកចិត្តបានសមរម្យដែរ។ ការនេះបានបើកឱកាសសម្រាប់យើងនៅក្នុងការធ្វើការនៅក្នុងប្រទេស”។

អាកាសធាតុនៅថ្ងៃទី៤ ខែធ្នូ ត្រជាក់បន្តិចសម្រាប់ការរស់នៅក្នុងផ្ទះមួយ ដែលខ្វះពិដាន ហើយមានជញ្ជាំង និងបង្អួចបន្តិចបន្តួច។ នៅក្នុងបន្ទប់គេងរបស់ខ្ញុំ មានប្រហោងនៅជញ្ជាំងទំហំប្រហែល២ម៉ែត្រគុណនឹង៣ម៉ែត្រ ដែលបានក្រាលដោយកម្រាលមួយដូច្នេះមានខ្យល់ចេញចូលស្រួលណាស់។ យ៉ាងណាក៏ដោយ ក៏យើងមិនបានយកចិត្តទុកដាក់ច្រើនទៅលើរឿងទាំងនេះដែរ។ នៅជុំវិញខ្លួនយើង គឺជាមនុស្សក្រីក្រដែលកំពុងស្ថិតនៅក្នុងភាពងងឹត—ទីក្រុងធំៗដែលគ្មានក្រុមបេសកជន ទីក្រុងមានប្រជាជនកុះករតែគ្មានបេសកជន ហើយភូមិជាច្រើនរាប់មិនអស់ ដែលមិនដែលឮអំពីដំណឹងល្អ។ ខ្ញុំមិនអាចស្រមៃបានទេថា មានអារម្មណ៍មិនយកចិត្តចំពោះបញ្ហាទាំងនេះ ឬក៏ការព្រងើយកន្តើយចំពោះពួកគេ ព្រោះតែការភ័យខ្លាចចំពោះភាពមិនស្រួលនោះឡើយ។ សូមព្រះជាម្ចាស់

ជួយយើងឲ្យនៅតែមានការប្តេជ្ញាចិត្ត និងសេចក្តីស្មោះត្រង់ចំពោះទ្រង់ និងបេសកកម្ម ដែលពួកយើងធ្វើ។

ស្របពេលជាមួយគ្នានេះដែរ គាត់ពិតជាមមាញឹកយ៉ាងខ្លាំងនៅស្រុកហានចូវ។ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីចិន ពួកអ្នកជំងឺបានសម្រុកទៅមន្ទីរពេទ្យ ថ្ងៃខ្លះឃើញច្រើនរហូតដល់ទៅពីររយនាក់ ហើយចំនួនដូចគ្នានេះក៏បានចូលរួមថ្វាយបង្គំរាល់ថ្ងៃអាទិត្យដែរ។ នៅពេលដែលក្រុមកម្លាំងបន្ថែមដំបូងបានមកដល់ពីប្រទេសអង់គ្លេសនៅដើមឆ្នាំ ១៨៦៧ លោកគ្រូ ថេល័រ មានការមមាញឹកយ៉ាងខ្លាំង ដូច្នេះលោកមិនអាចចំណាយពេលជាមួយពួកគេរហូតដល់ជាច្រើនម៉ោងក្រោយមក។ នៅខណៈនោះ គាត់បានឈរនៅតុដោយប្រកាសដំណឹងល្អដល់ពួកអ្នកជំងឺនៅទីធ្លានោះ ហើយអាចបានត្រឹមតែស្រែកដោយការស្វាគមន៍យ៉ាងកក់ក្តៅ នៅពេលដែលក្រុមថ្មីនោះបានចូលមកក្នុងដោយអមដំណើរជាមួយលោកគ្រូ មីដដូវស៍។ ពួកអ្នកមកថ្មីមានភាពលើសពីរីករាយចំពោះស្ថានភាពនេះ ហើយមិនយូរប៉ុន្មានលោកគ្រូ ចន ម៉ាកខាតធី (John McCarthy) បានធ្វើការជាមួយលោកគ្រូ ហ័ដសិន  ព្រមទាំងក្នុងពេលឆាប់ៗបានក្លាយជាជំនួយការដ៏សំខាន់នៅក្នុងការងារវេជ្ជសាស្រ្ត។ ស្របពេលមានបញ្ហាខាងក្រៅ មិត្តរួមការងាររបស់គាត់មានឱកាសធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកដឹកនាំដែលពួកគេស្ងើចសរសើរ ដែលជាមនុស្សម្នាក់បានបង្ហាញឧត្តមគិតដ៏ខ្ពង់ខ្ពស់របស់ពួកគេ។

នៅ៣៨ឆ្នាំក្រោយមក លោកគ្រូ ម៉ាកខាតធី បានសរសេរពីប្រទេសចិនភាគខាងលិចដោយបានរៀបរាប់ថាលោកគ្រូ ថេល័រ មានចិត្តសប្បុរស ពេញដោយក្តីស្រឡាញ់ ព្រមទាំងបានគិតគូរដល់អ្នកគ្រប់គ្នារហូតដល់ភ្លេចគិតដល់ខ្លួនឯង។ លោកបាននាំព្រះពរដល់គ្រប់ទីកន្លែងដែលគាត់ទៅ ថែមទាំងបានប្រទានកម្លាំង និងការកម្សាន្តចិត្តដល់អស់អ្នកដែលគាត់បានជួប។ គាត់តែងតែធ្វើជាគំរូជានិច្ចនូវអ្វីដែលបេសកជនម្នាក់គួរតែធ្វើ។

សូម្បីតែនៅពេលដំបូងៗ អ្នកខ្លះបានរិះគន់មនុស្សគ្រប់គ្នាដែលនៅជុំវិញខ្លួនពួកគេដោយសារតែភាពបរាជ័យខាងព្រលឹងវិញ្ញាណរបស់ពួកគេ។ ការអាក់អន់ស្រពន់ចិត្តដែលមានកាលពីពេលធ្វើដំណើរនៅតែបន្តមាន ហើយលោកស្រី ហ័ដសិន ក៏ត្រូវបានប៉ះពាល់ដោយសារការរិះគន់ដូចគ្នានឹងស្វាមីរបស់គាត់ដែរ។ គាត់មិនបានពិភាក្សាអំពីបញ្ហានេះរហូតដល់ជាច្រើនខែក្រោយមក សូម្បីតែនៅពេលដែលគាត់សរសេរទៅលោក

ស្រី បើកហ្គើ ដោយសារតែពួកគេចង់យកឈ្នះលើបញ្ហានេះដោយសេចក្តីស្រឡាញ់ និងការអត់ធ្មត់។ គាត់បាននិយាយរឿងតែនៅពេលដែលអ្នកនៅ សេនធ៍ ហៀល បានសុំឲ្យគាត់បានពន្យល់អំពីស្ថានភាពដោយលម្អិតតែប៉ុណ្ណោះ។

“សូមអធិស្ឋានសម្រាប់យើងឲ្យបានច្រើន ព្រោះយើងពិតជាត្រូវការព្រះគុណនៃការការពារពីព្រះណាស់នៅពេលនេះ។ នៅទីនេះ យើងច្បាំងនឹងអារក្សសាតាំងនៅក្នុងកន្លែងដ៏ខ្លាំងបំផុតរបស់វា ហើយវាក៏មិនទៅណាដោយមិនបានរំខានយើងឡើយ។ វានឹងជារឿងដ៏ល្ងង់ខ្លៅណាស់នៅក្នុងការធ្វើដំណើរមកកាន់ទីនេះដោយពឹងផ្អែកលើកម្លាំងរបស់យើងផ្ទាល់! ប៉ុន្តែ ព្រះជាម្ចាស់ដែលគង់នៅខាងយើង ទ្រង់ខ្លាំងជាងអ្នកណាទាំងអស់ ដែលទាស់ប្រឆាំងនឹងយើង។ ខ្ញុំពិតជាព្រួយចិត្តជាខ្លាំងក្នុងការឃើញទំនាស់បានកើតឡើងក្នុងចំណោមក្រុមបងប្អូនស្រីៗរបស់យើង ជាអ្វីដែលខ្ញុំកំពុងព្រួយបារម្ភនាពេលថ្មីៗនេះ។ ខ្ញុំមិនប្រាកដថាតើបញ្ហាអវិជ្ជមានរបស់លោក នីកូល (Nicol) នឹងត្រូវលាតត្រដាងដោយរបៀបណា។ រឿងមួយដែលខ្ញុំប្រាកដគឺថា “សេចក្តីសង្ឃឹមរបស់អ៊ីស្រាអែល” នឹងមិនបោះបង់យើងចោលឡើយ។ មនុស្សម្នាក់ប្រហែលស្ទើរតែចង់សួរថា៖ “ហេតុអ្វីបានជាគេអនុញ្ញាតឲ្យលោក នីកូល មកប្រទេសចិន?”។ ប្រហែលជាដូច្នេះ នោះអង្គការបេសកកម្មរបស់យើងអាចនឹងបង្កើតឡើងដោយត្រឹមត្រូវតាំងពីដំបូង។

នៅពេលដែលរដូវក្តៅចេះតែបន្តទៅមុខ មានការឈឺចាប់បានសាកល្បងសេចក្តីជំនឿ និងការទ្រាំទ្រផ្សេងៗ ប៉ុន្តែព្រលឹងវិញ្ញាណជាច្រើនបានបន្តទទួលបានសេចក្តីសង្គ្រោះ ហើយក្រុមជំនុំក៏បានរីកចម្រើនឡើងដែរ ដែលពេលនេះមានសមាជិកជាងមួយពាន់ប្រាំរយនាក់។ នៅពេលដែលការជ្រមុជទឹកលើកដំបូងបានធ្វើឡើងនៅខែឧសភា លោកស្រី ថេល័រ បានសរសេរទៅលោកស្រី បើកហ្គើ ម្តងទៀត។

“ប្រហែលជាព្រះអម្ចាស់ជាទីស្រឡាញ់ ទ្រង់ព្រះចិន្តាថា យើងត្រូវរងការឈឺចាប់ ដើម្បីឲ្យយើងបានបន្ទាបខ្លួននៅកណ្តាលព្រះពរដ៏សម្បូរបែបដែលទ្រង់បានប្រទានមកក្នុងកិច្ចការរបស់យើង”។

ប៉ុន្តែ គាត់ស្ទើរតែមិនរំពឹងថា នឹងមានសេចក្តីទុក្ខព្រួយផ្ទាល់ខ្លួនដ៏ខ្លាំងក្លានៅរដូវក្តៅនេះទេ។

កូនស្រីរបស់ពួកគាត់ដែលមានអាយុជិតប្រាំបីឆ្នាំ គឺជាកូនស្រីម្នាក់ដែលគួរឲ្យស្រឡាញ់

និងឆ្លាតជាងគេក្នុងចំណោមរបស់កូនទាំងអស់របស់ពួកគាត់។ ពួកគេបានស្វាគមន៍កំណើតរបស់កូននេះនៅទីក្រុងនីងប៉ូ។ នាងបានស្រឡាញ់ព្រះអម្ចាស់យេស៊ូវ ព្រមទាំងអ្នកគ្រប់គ្នានៅជុំវិញពួកគាត់យ៉ាងអស់ពីចិត្ត ថែមទាំងបានជួយការងារយ៉ាងច្រើន និងមើលថែរក្សាប្អូនតូចៗរបស់នាង ដោយធ្វើជាបងស្រីដែលប្រសើរបំផុតតាមដែលនាងអាចធ្វើបាន។ ទោះជាយ៉ាងណា កុមារី ហ្គ្រេសស៊ី (Gracie) បានចាប់ផ្តើមចុះខ្សោយផ្នែកសុខភាពនៅពេលខែក្តៅ និងមានពេលយូរ ហើយសូម្បីតែការធ្វើដំណើរទៅទីទួលនោះក៏មិនអាចជួយសង្គ្រោះជីវិតដ៏ក្មេងរបស់នាងបានដែរ។

លោកគ្រូ ថេល័រ បានជួបប្រឈមមុខនឹងស្ថានភាពនេះដោយខ្លួនឯងផ្ទាល់ និងអ្នកដែលគាត់ស្រឡាញ់បំផុត នៅខណៈពេលដែលគាត់នៅក្បែរកូនដែលកំពុងតែជិតស្លាប់របស់គាត់នៅវិហារបាក់បែកមួយ។

គាត់បានសរសេរសំបុត្រទៅលោកគ្រូ ប៊ើកហ្គ៍ ថា៖ «ការលះបង់ជីវិតរបស់យើងដោយការបម្រើដល់ទឹកដីនេះ ប្រជាជននេះ និងអាកាសធាតុនេះ មិនមែនគ្មានន័យ ឬក៏មិនមែនគ្មានការពិចារណានោះទេ។ យើងកំពុងព្យាយាមបម្រើដោយស្មោះត្រង់ ហើយបើទោះបីមិនសក្តិសមក៏ដោយ ក៏យើងមានការជោគជ័យខ្លះដែរ។ ឥឡូវនេះ ទ្រង់មិនបានបោះបង់យើងចោលឡើយ»។

លោកគ្រូ ថេល័រ បានសរសេរសំបុត្រទៅម្តាយរបស់គាត់កាន់តែសេរីឡើងថា៖

«កូនស្រីតូច ហ្គ្រេស៊ី ជាទីស្រឡាញ់របស់យើង! យើងនឹកដល់សំឡេងដ៏ផ្អែមល្ហែមរបស់នាងនៅពេលព្រឹក ដែលជាសំឡេងស្វាគមន៍ដល់ពួកយើងទាំងពេលយើងភ្ញាក់ឡើង ទាំងពេលថ្ងៃ និងពេលល្ងាច។ នៅពេលកូនចេញដើរ កូនបានទម្លាប់នឹងដើរជាមួយនាងដែលដើរលោតអញ្ជើលៗនៅក្បែរកូន គំនិតដ៏សែនឈឺចាប់បានវាយប្រហារកូន «តើវាអាចកើតឡើងដោយរបៀបណាទៅដែលថា កូននឹងមិនអាចប៉ះដៃដ៏តូចនោះម្តងទៀតទេ… នឹងលែងបានឃើញពន្លឺភ្លឺផ្លេករបស់ភ្នែកដ៏ភ្លឺថ្លាទាំងគូនោះទៀត? »។ ប៉ុន្តែនាងមិនបាត់បង់ទេ។ កូនក៏នឹងមិនចង់បាននាងត្រឡប់មកវិញដែរ។ កូនអរព្រះគុណព្រះដែលនាងជាម្នាក់ដែលព្រះជាម្ចាស់សព្វព្រះទ័យដកយកទៅនៅជាមួយទ្រង់ ជាជាងកូនៗផ្សេង បើទោះបីនាងជាពន្លឺព្រះអាទិត្យនៅក្នុងជីវិតពួកយើងក៏ដោយ។

កូនមិនគិតថា កូនធ្លាប់ឃើញអ្វីដែលល្អឥតខ្ចោះ និងស្រស់ស្អាត ដូចជាសាកសព

កូនជាទីស្រឡាញ់របស់កូនទេ។ រោមភ្នែកក្រាស់ដូចសូត្រនៅខាងក្រោមចិញ្ចើមតូចទាំងគូដូចធ្នូ ច្រមុះស្រួចដូចចម្លាក់ដ៏ប្រណិត មាត់តូចញញឹមតិចៗ ស្បែកសដ៏បរិសុទ្ធ—រូបភាពទាំងនោះបានដក់ជាប់យ៉ាងជ្រៅនៅក្នុងដួងចិត្ត និងការចងចាំរបស់កូន។ នាងតូចពាក់អាវក្រៅចិនតូចដ៏ស្អាតរបស់នាង ព្រមទាំងយកដៃទាំងគូដាក់នៅលើទ្រូងដោយមានកាន់ផ្កាមួយទងជាប់ក្នុងដៃ—វាពិតជាគួរឲ្យស្រឡាញ់យ៉ាងខ្លាំងណាស់ ហើយពិបាកក្នុងការដែលមិនបានមើលម្តងទៀត!

សូមជួយអធិស្ឋានសម្រាប់ពួកយើងផង។ ជួនកាល កូនស្ទើរតែមានអារម្មណ៍ថា វាច្រើនលើសលប់ណាស់ដោយការលំបាក ដែលបានជាប់ទាក់ទងនឹងការងាររបស់យើងទាំងខាងក្នុងចិត្ត និងខាងក្រៅ។ ប៉ុន្តែ ទ្រង់បានសន្យាថា៖ «អញនឹងមិនចាកចេញពីឯងក៏មិនបោះបង់ឯងចោលឡើយ» ហើយ «ដ្បិតកម្លាំងអញបានពេញខ្នាតដោយសេចក្តីកម្សោយ»។ ដូច្នេះ សូមឲ្យសេចក្តីនោះបានក្លាយជារឿងពិតចុះ»។

លោក និងលោកស្រី ថេល័រ បានថ្វាយជីវិតពួកគាត់ជាថ្មីម្តងទៀតក្នុងការផ្សាយដំណឹងល្អពាសពេញប្រទេសចិននៅអំឡុងពេលកាន់ទុក្ខរបស់ពួកគាត់។ នៅចុងឆ្នាំ ពួកគេបានធ្វើដំណើរទៅគ្រប់ទីក្រុងសំខាន់ៗនៅក្នុងចិកគាំង (Chekiang បច្ចុប្បន្នឈ្មោះ ស៊ីជាំង)។ ពួកគាត់ក៏ចាប់តាំងមានវត្តមាននៅទីក្រុងណាន់យីង នៅខេត្តជិតៗនោះ ហើយសមាជិកបេសកជនអង្គការបេសកកម្មចិនដីគោកនៅទីតាំងនោះ ហើយរហូតដល់ត្រូវធ្វើដំណើរម្តែបួនថ្ងៃទៅវិញទៅមក។ ក្រុមជំនុំនៅទីក្រុងហាងចូវ (Hangchow) បានសាងមូលដ្ឋានគ្រឹះយ៉ាងរឹងមាំជាមួយលោក វ៉ាង ឡេ-ជុន (Wang Lae-djun) ដែលបម្រើការជាគ្រូគង្វាលដោយអនុញ្ញាតឲ្យអ្នកដឹកនាំអង្គការបេសកកម្មចិនដីគោកចេញពីមណ្ឌលនោះនៅពេលនិទាឃៈរដូវឈានមកដល់។

នៅសម័យនោះ ការបើកកន្លែងអ្វីមួយនៅប្រទេសចិនស្ទើរតែធ្វើឲ្យមានគ្រោះថ្នាក់ដល់ជីវិតជានិច្ច។ កុប្បកម្មបានកើតឡើងជាញឹកញាប់ណាស់ ពួកគេបានធ្វើវាហាក់បីដូចជាទម្លាប់ទៅហើយ ហើយវាជារឿងធម្មតាសម្រាប់លោកគ្រូ ហ៉ដសិន ក្នុងការនិយាយជាមួយអ្នកដែលបានបាត់បង់ជើងម្ខាង ហើយអាចដើរបានដោយប្រើឈើច្រត់តែប៉ុណ្ណោះ។

«ប៉ុន្តែ តើលោកអ្នកនឹងធ្វើអ្វី ប្រសិនបើក្រុមកុប្បកម្មមួយបានផ្ទុះឡើងនៅប្រទេសចិន ហើយអ្នកត្រូវតែរត់គេចពីទីនោះ?»។

ចម្លើយយ៉ាងខ្លីគឺ៖ «ខ្ញុំមិនបានគិតអំពីការរត់នោះឡើយ ខ្ញុំបានជឿថា "អ្នកពិការ" នឹង "រកចំណីបាន"»។

តាមពិតទៅ គាត់បានធ្វើបែបនេះ នៅពេលវេលាបានមកដល់ ហើយគាត់មានឱកាសដើម្បីយកឈ្នះបញ្ហាទាំងឡាយ ដែលអមមកជាមួយនៃការមកដល់របស់ដំណឹងល្អនៅក្នុងស្រុកវិនចូវ (Wenchow)។

ពួកក្រុមកុប្បកម្មបានស្រែក ស្របពេលដែលពួកគេបានប្លន់យករបស់គ្រប់យ៉ាងពីគាត់ ដោយយកសូម្បីតែឈើច្រត់របស់គាត់ថា៖ «ហេតុអ្វីអ្នកមិនរត់ទៅ?»។

«គាត់បានឆ្លើយដោយញញឹមថា៖ "រត់គេច!" តើមនុស្សអាចរត់ដោយប្រើតែជើងម្ខាងបានដោយរបៀបណា? ខ្ញុំចង់ដឹងណាស់!»។

ភាពក្លាហាន និងភាពរាក់ទាក់របស់គាត់បានធ្វើឲ្យពួកគេបានទម្លាក់អាវុធចុះ ហើយអំណាចនៃការអធិស្ឋានដែលមើលមិនឃើញមានជ័យជម្នះដោយឯកឯងហើយ។

លោកគ្រូ ចច ដាំងឃិន (George Duncan) ជាម្នាក់ដែលមានរូបរាងខ្ពស់ដូចជាអ្នករស់នៅតាមតំបន់ភ្នំ បានក្លាយបេសកជនដំបូងគេនៅស្រុកណានគីង។ គាត់រីករាយនឹងរស់នៅក្នុងដំណាក់ប៉មស្គរ (Drum Tower) នៅពេលដែលគ្មានផ្ទះណាទៀតនៅទំនេរ ដោយរស់នៅបន្ទប់ក្រោមដីជាមួយកណ្ដុរ និងជួងដ៏ធំមួយ ហើយបានចំណាយពេលរបស់គាត់ច្រើនថ្ងៃក្នុងចំណោមបណ្ដាជននៅតាមផ្លូវ និងហាងតែនានា។ នៅពេលដែលប្រាក់របស់គាត់ចាប់ផ្ដើមអស់ ចុងភៅជនជាតិចិន និងមិត្តភក្តិរបស់គាត់បានសួរថា តើអ្វីជាជំហានបន្ទាប់របស់ពួកគេ ពីព្រោះការចាកចេញពីទីក្រុង និងកន្លែងជួលរបស់ពួកគាត់អាចនឹងមានន័យថា ពួកគាត់មិនអាចត្រឡប់មកវិញទៀតទេ។

ពួកគេបានសួរបេសកជនថា៖ «តើគួរធ្វើអ្វី?» «អញ្ចឹង ចូរយើងទុកចិត្តលើព្រះអម្ចាស់ ហើយធ្វើការល្អចុះ។ ធ្វើដូច្នេះ យើងនឹងរស់នៅលើទឹកដីនេះ ហើយប្រាកដណាស់ថាទ្រង់នឹងផ្គត់ផ្គង់ដល់យើងរាល់គ្នា»។

ច្រើនថ្ងៃបានកន្លងផុតទៅ លោកគ្រូ ហ័ដសិន បានដឹងថា គាត់មិនអាចផ្ញើប្រាក់ទៅទីក្រុងណាគីង (បច្ចុប្បន្នណានជីង) តាមរយៈធនាគារក្នុងស្រុកបានទេ។ ដោយមានក្ដីបារម្ភអំពីលោក ដាំងឃិន គាត់បានទាក់ទងទៅបេសកជនផ្សេងទៀត ដើម្បីឲ្យជួយ។ មកដល់ពេលនេះ ចុងភៅបានបរិច្ចាគប្រាក់សន្សំទាំងអស់របស់គាត់ជួយក្នុងស្ថានភាពនេះ

ដោយធ្វើឲ្យពួកគេគ្មានសល់ប្រាក់មួយកាក់មួយសេនសោះក្នុងខ្លួន។ ផ្ទុយទៅវិញ លោក ដាំងយិន បានបន្តការបង្រៀនដូចធម្មតា ដោយប្រាប់មិត្តសម្លាញ់ដែលកំពុងបារម្ភថា៖

“ចូរគ្រាន់តែ “ទុកចិត្តព្រះអម្ចាស់ ហើយធ្វើការល្អចុះ”។ សេចក្ដីសន្យារបស់ទ្រង់នៅតែដដែល នោះយើងនឹងរស់នៅលើទឹកដីនេះ ហើយប្រាកដណាស់ថា ទ្រង់នឹងផ្គត់ផ្គង់ដល់យើងរាល់គ្នា”។

នៅល្ងាចនោះ លោក រ៉ូដឡែនដ៍ (Rudland) បានដឹងថា កម្រិតទឹកនៅតំបន់ ហ្គ្រែនខាណល (Grand Canal) បានចុះទាប ដោយត្រូវបង្ខំឲ្យគាត់ត្រូវធ្វើដំណើរតាមផ្លូវគោក ដែលធ្វើឲ្យគាត់ត្រូវទៅដល់ ណានយីង ពីរបីថ្ងៃលឿនជាងការធ្វើដំណើរតាមទូក។ នៅពេលគាត់បានមកដល់ផ្ទះ គាត់បានដឹងថា ទាំងទូរខោអាវ និងកាបូបបាននៅទទេស្អាត។ លោក ដាំងយិន បានចំណាយពេលពេញមួយថ្ងៃដើរ និងបង្រៀននៅលើផ្លូវដែលគ្មានទីបញ្ចប់ ហើយនៅតាមផ្លូវត្រឡប់មកវិញ គាត់មានការហត់នឿយ និងឃ្លានជាខ្លាំង នៅពេលដែលគាត់បានជួបជំនួយការជនជាតិចិនរបស់គាត់រត់មកជួបគាត់ដោយពុំបានព្រៀងទុក។

គាត់បានហៅដោយដកដង្ហើមមិនដល់គ្នាថា៖ «អូហ៍ លោក គ្រប់យ៉ាងមិនអីទេ! លោក រ៉ូដឡែនដ៍—លុយ—អាហារពេលល្ងាចដ៏ឆ្ងាញ់!»។

“លោក ដាំងយិន បានឆ្លើយដោយដាក់ដៃថ្នមៗលើស្មាគាត់ថា៖ «តើខ្ញុំមិនបានប្រាប់អ្នកព្រឹកនេះទេឬអីថា ការទុកចិត្តលើព្រះដ៏មានព្រះជន្មរស់តែងតែមិនអីនោះទេ?»។

លោកគ្រូ ហ៉ាដសិន មិនទាន់ស្កប់ចិត្តដោយគ្រាន់តែបានលើកទឹកចិត្តបុរសៗវ័យក្មេងឲ្យមកធ្វើការត្រួសត្រាយនោះទេ។ គាត់ និងលោកស្រី ថេល័រ បានត្រៀមខ្លួនប្រឈមមុខនឹងគ្រោះថ្នាក់ ឬការលំបាកទាំងឡាយជាស្រេច ដោយបានដឹងអំពីការត្រាស់ហៅខាងឯព្រលឹងវិញ្ញាណសម្រាប់ពួកគាត់ថា ខ្លាំងដូចការត្រាស់ហៅរបស់អ្នកផ្សេងទៀតនៅក្នុងអង្គការបេសកកម្មចិនដីគោករបស់ពួកគាត់ដែរ។ បន្ទាប់ពីដប់ប្រាំមួយខែនៃការរស់នៅក្នុងជីវិត និងការងារដែលមានស្ថេរភាពនៅស្រុក ហាងចូវ ការចាកចេញពីកន្លែងនោះពិតជាពិបាកណាស់។ ក្រុមជំនុំបានរីកចម្រើនឡើងរហូតដល់មានសមាជិកហាសិបនាក់បានទទួលពិធីបុណ្យជ្រមុជទឹក ហើយមានមនុស្សជាច្រើនបានបង្ហាញចំណាប់អារម្មណ៍ក្នុងការចូលរួម។ ដោយមានលោក វ៉ាង ឡៃ-ជុន ជាគ្រូគង្វាល ជំនួយការលោក ម៉ាកខា

ធី និងកញ្ញា ហ្វូលឌីង ជាអ្នកមើលថែរក្សាពួកស្ត្រីៗ ពួកគាត់បានដឹងថា ការខិតខំប្រឹងប្រែងរបស់ព័ន្ធកិច្ចនឹងបន្តទៅមុខទៀត។ ពួកគាត់ត្រូវតែជួយគាំទ្រពួកអ្នកត្រួសត្រាយផ្លូវដែលនៅឆ្ងាយ ហើយនាំដំណឹងល្អទៅកាន់ទីក្រុងដ៏អ៊ូអរ ស្រុក និងភូមិ ហើយមិនធ្លាប់ឮដំណឹងល្អពីមុនមកសោះ។ ដូច្នេះ បើទោះបីជាមានការលំបាកក្នុងការរើផ្ទះសម្បែងរបស់ពួកគេ ហើយត្រូវរស់នៅបណ្តោះអាសន្ននៅលើទូកជាមួយកូនៗខ្លួនក៏ដោយ ក៏ពួកគាត់បានចាកចេញនៅរដូវផ្ការីក ហើយត្រៀមខ្លួនជួបនឹងលោក ដាំងឃិន នៅទីក្រុងណានឃីង (បច្ចុប្បន្នណានជីង) ឬក៏ស្នាក់នៅកន្លែងណាដែលអាចស្នាក់នៅបាន នៅពេលដែលឱកាសហុចឲ្យមកនៅតាមផ្លូវទៅទីនោះ។

បន្ទាប់ពី ការស្នាក់នៅពីរខែនៅលើទូក ពួកអ្នកដំណើរអាចតាំងលំនៅនៅទីក្រុងដ៏ធំមួយនៅក្នុងស្រុកយ៉ាងចូវ។ ពួកគាត់បានចំណាយពេលបីសប្តាហ៍ជាមួយលោក ហែនរី គ័រដុន (Henry Cordon) ជាបេសកជនម្នាក់ពីអង្គការបេសកកម្មចិនដីគោក ដែលបានចាប់ផ្តើមធ្វើការនៅក្នុងក្រុងដ៏ល្បីឈ្មោះនៅស្រុកស៊ូចូវ ហើយបានប្តូរទៅស្រុកជីនគាំង (ឬសិនជាំង) នៅក្នុងការប្រជុំនៅ ហ្គ្រែន ខាណល រួចទៅទន្លេយ៉ាងជី (Yangtze River) ដ៏ធំនោះ។ លោកគ្រូ ហ័ដសិន បានកត់សម្គាល់យ៉ាងឆាប់រហ័សពីភាពសំខាន់នៃតំបន់នេះ ហើយបានចាប់ផ្តើមធ្វើការចរចាសម្រាប់ទីកន្លែង ដែលពួកគេទទួលបាននៅពេលក្រោយ។ ខណៈដែលការចរចាបានរំពឹងទុកថា នឹងចំណាយពេលខ្លះនឹងធ្វើ ពួកគាត់បានបន្តដំណើររបស់ខ្លួនឆ្លងកាត់ទន្លេយ៉ាងជី និងបានធ្វើដំណើរប៉ុន្មានគីឡូម៉ែត្រទៅភាគខាងជើងនៃ ហ្គ្រែន ខាណល។ ចុងក្រោយ ពួកគាត់បានទៅទីក្រុងដ៏គួរឱ្យកត់សម្គាល់ ដែលលោក ម៉ាកូ ប៉ូឡូ (Marco Polo) ធ្លាប់បានគ្រប់គ្រង ព័ទ្ធជុំវិញដោយជញ្ជាំងកំផែង និងផ្ទះរបស់មនុស្សសាមសិបប្រាំមួយម៉ឺននាក់ ដែលមិនទាន់បានឮពីព្រះរាជសាររបស់ព្រះគ្រីស្ទនៅឡើយ។

លោកស្រី ហ័ដសិន បានសរសេរសំបុត្រទៅកាន់លោកស្រី ប៊ើកហ្គើ ថា ប្រសិនបើបងស្រីមិនមែនជាអ្នកធ្វើដំណើរដែលមានបទពិសោធន៍នោះទេ ខ្ញុំគិតថា វាពិបាកនឹងជឿណាស់ថា បងស្រីអាចនឹងយល់ពីអារម្មណ៍ ដែលយើងមាននៅថ្ងៃច័ន្ទអាទិត្យមុននេះ។ នៅថ្ងៃនោះ យើងបានរើចេញពីទូកធ្លាយមកបន្ទប់ស្នាក់នៅសណ្ឋាគារលំដាប់កំពូលរបស់ចិនជាប្រភេទផ្ទះស្នាក់នៅ ប្តីខ្ញុំជាអ្នកដែលដឹងច្រើនអំពីការស្នាក់នៅរបស់អ្នកធ្វើ

ដំណើរជនជាតិចិនមិនធ្លាប់ឃើញសណ្ឋាគារបែបនេះពីមុនមក ហើយសណ្ឋាគារនោះក៏ស្ថិតនៅក្នុងទីក្រុងយ៉ាងចូវដែរ។

ម្ចាស់សណ្ឋាគារដ៏រួសរាយរាក់ទាក់ម្នាក់ និងភ្ញៀវដែលចង់ដឹងបាននាំឲ្យការចាប់ផ្តើមអ្វីៗដោយរលូន។ នៅពេលដែលរាជការបានចេញសេចក្តីប្រកាសគាំទ្រ ក្រុមគ្រួសារបានរើចូលទៅក្នុងផ្ទះមួយនៅពាក់កណ្តាលខែកក្កដា។ កម្តៅក្តៅខ្លាំងពិបាកនឹងទ្រាំទ្រ ហើយពួកគាត់បានសង្ឃឹមថា នឹងមានអាកាសធាតុត្រជាក់ជាងនេះនៅខែសីហា។ ទោះជាយ៉ាងណាក៏លំហូរនៃអ្នកជំងឺ និងភ្ញៀវមិនបានថមថយចុះដែរ។ វត្តមានរបស់គ្រួសារជនជាតិបរទេសនៅក្នុងទីក្រុងបានទាញយកចំណាប់អារម្មណ៍យ៉ាងពិសេស ជាពិសេសដោយសារតែលោកគ្រូ ហ័ដសិន ជាវេជ្ជបណ្ឌិតម្នាក់ដែលមានសមត្ថភាព។ របៀបនិយាយភាសាចិន និងអាកប្បកិរិយាដ៏គួរស្រឡាញ់របស់លោកស្រី ថេល័រ បានធ្វើឲ្យពួកស្ត្រីៗមានការចាប់អារម្មណ៍ជាខ្លាំង ហើយរឿងនេះបានកើតឡើងនៅទីក្រុងហាងចូវ បណ្តាជនក៏បានទទួលយកដំណឹងល្អផងដែរ។

សត្រូវបានចូលរួមយ៉ាងសកម្ម ដើម្បីប្រឆាំងនឹងពួកគាត់។ វាហាក់បីដូចជាមិនអាចទៅរួចទេថា ដែលពួកសាតាំងអនុញ្ញាតឲ្យមានការលុកលុយចូលទៅក្នុងទឹកដីរបស់វាដោយមិនមានការរំខាននោះឡើយ។ ពួកបញ្ញវ័ន្តនៅក្នុងក្រុងប្រមូលផ្តុំគ្នា ហើយបានបង្កជាជម្លោះឡើង។ ខិតប័ណ្ណអនាមិកបានចាប់ផ្តើមផ្ទុះឡើងពាសពេញទីក្រុង ដោយចោទប្រកាន់ជនបរទេសពីបទឧក្រិដ្ឋដ៏សាហាវៗ ដែលភាគច្រើនជាអ្នកផ្សាយ «ដំណឹងល្អនៃព្រះយេស៊ូវ»។ ភ្លាមៗនោះ ពួកបេសកជនបានសង្កេតឃើញថា សាធារណៈជនកើតមានការស្អប់យ៉ាងឆាប់រហ័ស។ ភ្ញៀវដែលប្រកបដោយភាពរួសរាយរាក់ទាក់បានជំនួសមកវិញដោយហ្វូងមនុស្សអនាធិបតេយ្យ ដែលគ្មានច្បាប់ទម្លាប់នៅមាត់ទ្វារ ស្របពេលដែលផ្ទាំងបដាថ្មីបានបង្កើនភាពចលាចល។ តាមរយៈការអត់ធ្មត់ និងសេចក្តីសប្បុរស ពួកបេសកជនបានរារាំងការធ្វើកុប្បកម្មម្តងហើយម្តងទៀត។ លោកគ្រូ ហ័ដសិន ស្ទើរតែមិនហានចាកចេញពីផ្ទះអស់រយៈពេលប៉ុន្មានថ្ងៃ ជាកន្លែងដែលគាត់បានឆ្លើយតបទៅនឹងសំណួរ និងបានគ្រប់គ្រងហ្វូងមនុស្សឲ្យមានសណ្តាប់ធ្នាប់វិញ។

អ្នកនៅផ្ទះមានការអរព្រះគុណព្រះយ៉ាងខ្លាំង ជាពិសេសចំពោះការមកដល់របស់គ្រួសាររបស់លោក និងលោកស្រី រ៉ដឡែនដ៍ និងលោក ដាំងឃិន នៅពេលដែលព្យុះ

ហាក់បីដូចជាបានស្ងប់ចុះហើយនោះ។ ភ្លៀងបានធ្លាក់យ៉ាងខ្លាំងនៅខែសីហា បានជួយបំបែកហ្វូងមនុស្ស និងកម្ដៅដ៏ក្ដៅខ្លាំងបាន។ ទោះជាយ៉ាងណាក្ដី ក៏ភាពធូរស្រាលនេះនៅមិនយូរទេឡើយ។ ជនជាតិបរទេសពីរនាក់មកទីក្រុង ជីនគាំង (បច្ចុប្បន្នសិនជាំង) ដែលមិនបានស្លៀកសំលៀកបំពាក់បែបចិនដូចពួកបេសកជន តែបែរជាបានស្លៀកសំលៀកបំពាក់បែបបរទេសយ៉ាងបើកចំហ មកទស្សនាទីក្រុងយ៉ាងចូវ បានបង្កឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ពួកអ្នកជំនាញខាងអក្សរសាស្ត្របានឃើញឱកាសដ៏ល្អឥតខ្ចោះនេះ ហើយបានធ្វើសកម្មភាពម្ដងទៀត។ ភ្លាមៗនោះ ក្រោយពេលដែលពួកភ្ញៀវបានចាកចេញ ពួកគេគិតថា គ្រប់យ៉ាងបានស្ងប់ហើយ ស្រាប់តែមានពាក្យចចាមអារ៉ាមបានចាប់ផ្ដើមរីករាលដាលថា ក្មេងៗបានបាត់ខ្លួននៅគ្រប់កន្លែង។ មហាជនបានជឿថា ពួកក្មេងៗយ៉ាងហោចម្ភៃប្អូននាក់បានក្លាយជាជនរងគ្រោះរបស់ពួកជនបរទេសដ៏ព្រៃផ្សៃនោះ។

«ចូរក្លាហានឡើង—តោះយើងនាំគ្នាសងសឹកចំពោះកំហុសរបស់ពួកយើង! វាយប្រហារ! បំផ្លាញ! យើងនឹងទទួលទ្រព្យដ៏ច្រើនពីពួកវា!»។

សែសិបប្រាំបីម៉ោងក្រោយមក នៅពេលដែលទូករបស់ពួកគេបានចូលមកជិតទីក្រុងជីនកាំង (បច្ចុប្បន្នបេកាំង) ពួកគាត់បានរងរបួស និងរងទុក្ខជាខ្លាំង ប៉ុន្តែក្រុមបេសកជនដែលមិនបានស្រងាកចិត្តឡើយ តែបានអរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់ការការពាររបស់ទ្រង់ នៅអំឡុងពេលផ្ទុះអំពើហិង្សាដ៏ខ្លាំងក្លា ដែលស្ទើរតែបានយកឈ្នះលើពួកគេ។

លោកស្រី ថេល័រ បានសរសេរសំបុត្រនៅពេលពួកគេបានធ្វើដំណើរថា៖ «ព្រះជាម្ចាស់របស់ពួកយើងបាននាំយើងឆ្លងកាត់ការទាំងនេះ ហើយសូមឲ្យការនេះ នាំយើងឲ្យរស់នៅកាន់តែពេញលេញ ដើម្បីជាការសរសើរតម្កើង និងថ្វាយសិរីល្អដល់ទ្រង់។ យើងបានជួបនឹងព្យុះទីហ្វុងមួយផ្សេងទៀត មិនយូរដូចព្យុះទីហ្វុងដែលបានកើតឡើងជិតពីរឆ្នាំមុននោះទេ ប៉ុន្តែមានគ្រោះថ្នាក់ដូចគ្នាចំពោះអាយុជីវិតរបស់ពួកយើង ហើយកាន់តែគួរឲ្យខ្លាចនៅពេលវាបានកើតឡើង។ ខ្ញុំជឿថា ព្រះជាម្ចាស់នឹងប្រើប្រាស់បទពិសោធន៍នេះ ដើម្បីជាសិរីល្អរបស់ទ្រង់ ហើយខ្ញុំក៏សង្ឃឹមថា ការនោះនឹងនាំមកនូវការរីកចម្រើននៃការផ្សាយដំណឹងល្អដែរ»។

— សូមលោកស្រីទទួលនូវការរាប់អានដ៏កក់ក្ដៅអំពីខ្ញុំនៅក្នុងព្រះសង្គ្រោះដ៏មានព្រះជន្មរស់...

ហ្វុងកុប្បុករមិនយល់សោះអំពីភាពត្រជាក់ចិត្ត និងកម្លាំង ដែលបានមកពីការមានវត្តមានរបស់ព្រះសង្គ្រោះ។ ពួកគេបានមានការអស្ចារ្យចំពោះអ្វីមួយ ដែលពួកគេមិនអាចនឹងស្គាល់បានថាជាអ្វីឡើយ ដែលបានរារាំងពួកគេពីការធ្វើអំពើហិង្សាធ្ងន់ធ្ងរនានា។ បើទោះបីការស្លាប់ខិតជិតមកដល់ក្តី ក៏ព្រះអង្គបានរារាំងវាម្តងហើយម្តងទៀតដែរ។ ទាំងលោកគ្រូ ថេល័រ និងអស់អ្នកដែលនៅសល់កំពុងប្រឈមមុខនឹងគ្រោះថ្នាក់នៃការបំពាន ដែលប្រថុយនឹងសេចក្តីកំហឹងរបស់បណ្តាជន និងភ្លើងនៅព័ទ្ធជុំវិញផ្ទះរបស់ពួកគាត់ នៅពេលដែលគាត់បានស្វែងរកជំនួយពីអាជ្ញាធរក្នុងស្រុក គឺបានការពារដោយព្រះហស្តដ៏មើលមិនឃើញ។

អ្នកម្តាយបានទ្រាំទ្រអស់ជាច្រើនម៉ោងដោយការថប់បារម្ភ នៅពេលគាត់បានការពារកូនៗ ព្រមទាំងពួកស្ត្រីនៅបន្ទប់ខាងលើរហូតដល់ពួកគេត្រូវបានបង្ខំឲ្យចេញមកក្រៅដោយសារភ្លើង។ ឪពុកដែលនៅឆ្ងាយពីពួកគេ បានឮសម្រែកហ្វុងកុប្បុករយ៉ាងខ្លាំងឲ្យបំផ្លាញពីការិយាល័យមន្ត្រីរាជការចិន។ បើទោះបីជាមានចលាចលក៏ដោយ ក៏អ្នកស្រីហ៊ែដសិន នៅតែបន្តត្រជាក់ចិត្តនៅខាងក្រៅ ដោយប្រឈមនឹងព្រឹត្តិការណ៍ដ៏អាក្រក់នានា ថែមទាំងបានជួយសង្គ្រោះអាយុជីវិតមនុស្សម្តងហើយម្តងទៀត ដោយសារការគិតយ៉ាងឆាប់រហ័ស និងការស្ទាត់ជំនាញខាងភាសារបស់គាត់ គាត់បានធ្វើគ្រប់យ៉ាងស្របពេលដែលចិត្តរបស់គាត់សែនឈឺ និងពេញដោយក្តីបារម្ភចំពោះមនុស្សដែលពួកគាត់ស្រឡាញ់ ដោយខ្លាចថា ពួកគេនឹងមិនអាចបានជួបគ្នាម្តងទៀតទេ។

ការចរចាមានរយៈពេលវែង និងមានឧបសគ្គ មុនពេលដែលផ្ទះនៅស្រុកយ៉ាងចូវបានជួសជុលរួច ហើយក្រុមរបស់ពួកគាត់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅវិញបាន។ ពួកគេបានរៀបចំព្រឹត្តិការណ៍ដ៏សំខាន់មួយ ដើម្បីស្វាគមន៍ពួកគាត់ ហើយអ្នកដឹកនាំអង្គការបេសកកម្មចិនដីគោកមានភាពរីករាយនឹងសរសេរប្រាប់ពួកគាត់ថា លទ្ធផលរឿងក្តីរបស់ពួកគាត់នឹងអាចជួយសម្រួលដល់ដំណើរការនៅក្នុងប្រទេសកាន់តែងាយស្រួលខ្លាំងឡើងៗ។ ទោះបីជាយ៉ាងណាក្តី តាមរយៈជីវិតរបស់គ្រួសារបេសកជន ហើយអាកប្បកិរិយារាក់ទាក់របស់ពួកគាត់បានជួយកាត់បន្ថយការសង្ស័យបន្តិចម្តងៗ។ ទង្វើបានស្តែងឲ្យឃើញច្បាស់ជាងពាក្យសម្តី ហើយអ្នកជិតខាងមានរឿងមួយចំនួនក្នុងការជញ្ជឹងគិត នៅពេលដែលគេឃើញពួកក្មេងៗបានត្រឡប់មកវិញ ទោះបីជាមានរឿងគ្រប់យ៉ាង

បានកើតឡើងក៏ដោយ ហើយនៅពេលវាបានស្តែងឲ្យឃើញថា លោកស្រី ថេល័រ បានត្រឡប់មកវិញដោយស្ម័គ្រចិត្ត សូម្បីតែនៅពេលគាត់ចង់បានភាពសុខសាន្ត និងភាពស្ងប់ស្ងាត់ក៏ដោយ។

លោកស្រីបានសរសេរសំបុត្រទៅមិត្តជិតស្និទ្ធគាត់នៅសៃនធ៍ ហៀល ថា៖ «ព្រះជាម្ចាស់បានសម្រេចបំណងប្រាថ្នាក្នុងចិត្តរបស់គាត់។ គាត់មានអារម្មណ៍ថា ប្រសិនបើកូនរបស់គាត់មានសុវត្ថិភាព គាត់នឹងសុខចិត្តឲ្យកូនគាត់កើតនៅក្នុងទីក្រុងនេះ នៅក្នុងផ្ទះនេះ ហើយនៅក្នុងបន្ទប់មួយនេះជាជាងកើតនៅកន្លែងផ្សេងៗទៀត។ កន្លែងផ្សេងនោះ រួមមានទាំងផ្ទះដ៏ស្រស់ស្អាតរបស់មិត្តឯងដែរ ដែលជាកន្លែងដែលខ្ញុំធ្លាប់បានទទួលការថែរក្សាយ៉ាងថ្នាក់ថ្នមពីអ្នកផ្ទាល់ ព្រមទាំងដឹងថា តើគួរឲ្យត្រេកអរដ៏អស្ចារ្យយ៉ាងណាចំពោះភាពសុខស្រួល និងភាពប្រណិត»។

ដោយគ្មានការសង្ស័យ ការមកដល់របស់កូនប្រុសទីបួនបានបង្កើតចំណាប់អារម្មណ៍វិជ្ជមាន ដូចគ្នាទៅនឹងការជាសះស្បើយយ៉ាងឆាប់រហ័សរបស់អ្នករបួសគ្រប់គ្នានៅក្នុងកុប្បកម្ម។ ផ្ទុយទៅវិញ រង្វាន់ដ៏ធំបំផុត គឺការដែលបានដឹងថា ម្ចាស់សណ្ឋាគារដែលបានស្វាគមន៍ពួកគាត់មុននៅក្នុងទីក្រុង និងមនុស្សពីរនាក់ផ្សេងទៀត ដែលបានប្រថុយប្រថានយ៉ាងខ្លាំងនៅក្នុងការជួយពួកគាត់នៅអំឡុងកុប្បកម្ម ឥឡូវនេះបានក្លាយជាអ្នកជឿម្នាក់ដែរ ដោយបានសារភាពអំពើបាបរបស់គាត់ចំពោះព្រះគ្រីស្ទហើយ ថែមទាំងកំពុងរៀបចំធ្វើពិធីជ្រមុជទឹកទៀតផង។

«ឯអ្នកដែលកណ្ដៀតពូជ សម្រាប់សាបព្រោះ ចេញទៅទាំងយំ នោះប្រាកដជានឹងចូលមកវិញដោយអំណរ ព្រមទាំងយកកណ្ដាប់មកផង» (ទំនុកតម្កើង ១២៦:៦)។

ជំពូកទី១៣

# ពេលវេលាដ៏ខ្មៅងងឹត

*ផែនដី និងនរករួមគ្នាទាស់ប្រឆាំងនឹងខ្ញុំហើយ ប៉ុន្តែខ្ញុំមានអំណាចរបស់ព្រះនៅជាមួយខ្ញុំ គឺព្រះយេស៊ូវទ្រង់ជាអ្វីៗទាំងអស់ ហើយទ្រង់ក៏ជាម្ចាស់របស់ខ្ញុំដែរ។*

*— ដឹបបលយូ. ធី. ម៉ាតសុន (W. T. Matson)*

លោកគ្រូ ប៊ើកហ្គ័រ កំពុងប្រឈមមុខនឹងព្យុះដ៏អាក្រក់មួយនៅប្រទេសអង់គ្លេសនៅរដូវរងាខ្លាំងជាងព្យុះមួយដែលវាយប្រហារបេសកកម្មតូចនៅប្រទេសចិនទៅទៀត។ កុប្បកម្មនៅក្រុងយ៉ាងចូវ បានបណ្តាលឲ្យមានការរិះគន់នៅក្នុងសភា (Parliament) និងនៅទូទាំងប្រទេសអង់គ្លេស ដែលជារឿងពិបាកនឹងជឿ។ ការយល់ច្រលំ បានបណ្តាលឲ្យសារព័ត៌មានសាធារណៈវាយប្រហារយ៉ាងខ្លាំងទៅលើក្រុមបេសកជន ដោយចោទប្រកាន់ពួកគាត់ថា បង្កហានិភ័យសង្គ្រាមជាមួយប្រទេសចិន ហើយទាមទារឲ្យទូកកាំភ្លើងធំរបស់ចក្រភពអង់គ្លេសគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងបំផ្លាស់បំប្រែជនជាតិចិនរបស់ពួកគេ “ដោយប្រើមាត់កាំភ្លើងធំ និងកាំភ្លើងមានចុងកាំបិត”។ ប្រាកដណាស់! លោកគ្រូហ៉ដសុន និងមិត្តរួមការងាររបស់គាត់ ស្ទើរតែមិនមែនជាអ្នកដែលបង្កហេតុផលណាមួយចំពោះការរិះគន់ទាំងនេះ។ ពួកអាជ្ញាធរកុងសុល (consular authorities) បានឆ្លើយតបចំពោះករណីរបស់ពួកគាត់ក្នុងរបៀបមួយ ដែលពួកបេសកជននឹកស្មានមិនដល់ ឬក៏មិនចង់បាន។ ដោយធ្វើតាមសេចក្តីបង្គាប់របស់ការិយាល័យការបរទេស (Foreign Office) និងមន្ត្រីរបស់ការិយាល័យនេះ បានឆ្លៀតឱកាសជំរុញឲ្យមានសិទ្ធិសន្ធិសញ្ញា។ ទោះជាយ៉ាងណា មុនការទាមទារដែលមិនសមហេតុផលរបស់ឯកអគ្គរាជទូតអង់គ្លេស

(British Ambassador) បានអនុវត្តតាម ការផ្លាស់ប្តូររដ្ឋាភិបាលអង់គ្លេស បានធ្វើឲ្យស្ថានការណ៍កាន់តែស្មុគស្មាញឡើង។ លោកស្រី ថេល័រ បានសរសេរ ដើម្បីបន្ថយការខ្វល់ខ្វាយរបស់ប្តីរបស់គាត់ ដោយបានចែកចាយរាល់ព័ត៌មានលម្អិតទាំងអស់ជាមួយលោក និងលោកស្រី ប៊ើកហ្គ័រ។

គាត់បានសរសេរបញ្ជូលថា “នៅពេលប្រឈមមុខនឹងការកាត់សេចក្តីដ៏អាក្រក់ពីសំណាក់លោកីយ៍ ឬក៏រឿងយល់ច្រលំដ៏គួរឲ្យកាន់តែឈឺចាប់ពីសំណាក់បងប្អូនគ្រីស្ទបរិស័ទដូចគ្នា ហើយជាញឹកញាប់ វិធីសាស្រ្តដែលល្អបំផុត គឺត្រូវបន្តធ្វើការអ្វីដែលយើងត្រូវធ្វើ ហើយទុកចិត្តថា ព្រះជាម្ចាស់ការពារកិច្ចការរបស់យើង។  បើទោះបី វាជារឿងសំខាន់ដែលលោកអ្នកយល់ទាំងស្រុងអំពីកិច្ចការ និងហេតុផលទាំងឡាយរបស់យើងក្នុងការទាំងអស់នោះ។ ខ្ញុំសូមផ្តល់ដំបូន្មានជំទាស់នឹងការប្រាប់ការពិតដែលថា លោកមិដហើសធ៍ (Mr. Medhurst) ដែលជាមេកុងស៊ុល (Consul General) និងតាមរយៈគាត់ នោះលោក រ៉ូដឌឺហ្វ័ត អាល់ខកឃ៍ (Sir Rutherford Alcock) បានលូកលាន់ចូលទៅក្នុងរឿងនោះ ដោយគ្មានការស្នើសុំពីពួកយើងទេ។ រដ្ឋាភិបាលបច្ចុប្បន្ននៅអង់គ្លេស បានរិះគន់ដល់ពួកអ្នកនៅទីនេះ ដែលបានធ្វើតាមគោលនយោបាយ ដែលរដ្ឋាភិបាលមុនតម្រូវឲ្យពួកគេអនុម័តតាម។ វានឹងជារឿងអយុត្តិធម៌ និងមិនដឹងគុណសោះចំពោះយើង ក្នុងការធ្វើឲ្យស្ថានភាពរបស់ពួកគេកាន់តែលំបាកឡើងៗ ដោយទម្លាក់កំហុសទាំងអស់ទៅលើពួកគេផងដែរ”។

គ្មានជម្រើសអ្វី ក្រៅពីទ្រាំទ្រនឹងកាលៈទេសៈដ៏លំបាកនេះដោយអធិស្ឋាន និងអត់ធ្មត់ឡើយ ដែលកាលៈទេសៈដ៏លំបាកនេះបានអូសបន្លាយរហូតដល់គាត់រស់នៅបានស្កប់សុខម្តងទៀតនៅក្រុងយ៉ាងចូវ។ ជាការពិត នៅបួនខែក្រោយមកលោកគ្រូ ប៊ើកហ្គ័រ បានសរសេរមកពីសេនធ៍ហៀល។

“បញ្ហានៅស្រុកយ៉ាងចូវ ពេលនេះបានក្លាយជាបញ្ហាត្រូវពិភាក្សានៅដំណាក់របស់អ្នកដឹកនាំ (the House of Lords)។ វាស្ទើរតែមិនគួរឲ្យជឿថា ផលប៉ះពាល់កំពុងរាលដាលនៅពាសពេញផ្ទៃប្រទេសទេ។ អរព្រះគុណដល់ព្រះជាម្ចាស់ ខ្ញុំអាចនិយាយបានថា “គ្មានផលប៉ះពាល់ណា ប៉ះពាល់ដល់ខ្ញុំ” ទេ។ ខ្ញុំជឿថា ទ្រង់បានត្រាស់ហៅយើងឲ្យធ្វើកិច្ចការនេះ ហើយយើងមិនគួររត់គេចពីវា ឬបណ្តោយឲ្យឧបសគ្គនោះយកឈ្នះលើយើង

ឡើយ។ ចូរមានកម្លាំងឡើង ព្រះយេហូវ៉ាជាម្ចាស់នៃចម្បាំង»។

វិបត្តិកាន់តែអាក្រក់ឡើងៗ នៅពេលដែលការអាក់អន់ស្រពន់ចិត្តកើនឡើងខ្លាំងដល់កំពូលនៅក្នុងចំណោមសមាជិកអង្គការបេសកកម្មចិនដីគោក ហើយយើងត្រូវតែស្នើសុំឲ្យអ្នកដែលបង្កបញ្ហាតាំងពីដំបូងលាឈប់ពីការងារ។ ការពណ៌នាអំពីបញ្ហារបស់ពួកដែលបង្កបញ្ហាបានបង្កើនការយល់ច្រឡំជាច្រើននៅស្រុកកំណើតរបស់ពួកគាត់នៅអង់គ្លេស ហើយបើទោះបីមានការដឹកនាំដ៏ក្លៀវក្លា និងឆ្លាតវៃរបស់លោក បើកហ្គ័រ ក៏ដោយ ក៏ការនោះបានធ្វើឲ្យអ្នកគាំទ្រមួយចំនួនបានរវាតចិត្តចេញពីការងារនេះដែរ។ បញ្ហានេះ ព្រមទាំងការរិះគន់របស់សារព័ត៌មានសាធារណៈ បានធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណូលគួរឲ្យកត់សម្គាល់ ជាលទ្ធផលបណ្ដាលឲ្យថ្នាក់ដឹកនាំអង្គការបេសកកម្មចិនដីគោកប្រឈមមុខនឹងឧបសគ្គសំខាន់ធំៗជាច្រើនរាប់មិនអស់។

“សូមអធិស្ឋានសម្រាប់យើង” លោកគ្រូ ថេល័រ បានសរសេរបន្ថែមទៀតបន្ទាប់ពីកុប្បកម្មថា «យើងត្រូវការព្រះគុណខ្លាំងណាស់។ វាពិបាកនៅក្នុងការរក្សាភាពអត់ធ្មត់ ការអត់ទ្រាំ និងភាពប៉ិនប្រសព្វជានិច្ច នៅពេលប្រឈមមុខនឹងការលំបាក និងការយល់ច្រឡំនៅចំណោមមនុស្សជាច្រើន ដែលមានសញ្ជាតិ ភាសា និងនិស្ស័យខុសៗគ្នា។ សូមអធិស្ឋានឲ្យព្រះអម្ចាស់ប្រទានឲ្យខ្ញុំមាននូវចក្ខុវិស័យមួយច្បាស់លាស់ ការវិនិច្ឆ័យច្បាស់លាស់ ប្រាជ្ញា ចិត្តសុភាព អាកប្បកិរិយាអត់ធ្មត់ គោលបំណងជាក់លាក់ សេចក្ដីជំនឿដែលឥតរង្គោះរង្គើ ព្រមទាំងសេចក្ដីស្រឡាញ់ ដែលប្រហាក់ប្រហែលទៅនឹងសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ ដើម្បីបំពេញកិច្ចការងាររបស់ខ្ញុំឲ្យមានប្រសិទ្ធិភាព។ សូមទូលទ្រង់ឲ្យប្រទានដល់យើងរាល់គ្នានូវធនធានគ្រប់គ្រាន់ ព្រមទាំងអ្នកជំនួយដែលសមស្របសម្រាប់កិច្ចការដ៏មហិមា ដែលយើងទើបតែបានចាប់ផ្ដើមនេះ»។

បើទោះបីជាមានអ្វីៗបានកើតឡើងក៏ដោយ ក៏ការផ្សាយដំណឹងល្អនៃការត្រួសត្រាយរបស់អង្គការបេសកកម្មិនដីគោកមិនបានបញ្ឈប់ឡើយ សូម្បីតែមុនពេលដែលបញ្ហានៅស្រុកយ៉ាងចូវត្រូវបានដោះស្រាយ។ លោកគ្រូ ថេល័រ បានចេញដំណើរដ៏សំខាន់មួយតាមបណ្ដោយព្រំដែនខែនណលទៅកាន់ទីក្រុងមួយ ដោយមានគោលបំណងទៅកាន់ខេត្តភាគខាងជើង។ ស្របពេលជាមួយគ្នានេះដែរ លោក មីដដូស៍ បានប្រគល់កិច្ចការនៅទីក្រុងនីងប៉ូ ដើម្បីចាប់ផ្ដើមការងារថ្មីទៅស្រុកអាញវ៉ៃ (Anhwei បច្ចុប្បន្នអានវ៉េ) ទឹក

ដីដំបូងខាងលិចខេត្តជីនគាំង (បច្ចុប្បន្នសិនជាំង) ជាកន្លែងដែលមានមនុស្សចំនួនម្ភៃលាននាក់បានរស់នៅ តែមិនទាន់មានបេសកជនប្រូតេស្តង់ សូម្បីតែម្នាក់នៅឡើយ។

ប៉ុន្តែ ជំនួសដោយការទទួលបានមនុស្ស និងធនធានកាន់តែច្រើន ដូចដែលពួកគាត់បានអធិស្ឋានទូលសូម ពួកគាត់បានឃើញការថយចុះគួរឲ្យកត់សម្គាល់របស់ប្រាក់មូលនិធិពីស្រុកកំណើតរបស់ខ្លួន។ បើទោះបីជា ពួកគេមិនបានរំពឹងទុកក៏ដោយ ក៏ពួកគាត់បានត្រៀមខ្លួនជាស្រេចសម្រាប់ស្ថានភាពនេះ ដែលនោះជាការលើកទឹកចិត្តមែនទែន។ ដោយសារព្រះអម្ចាស់មួយអង្គ ដែលបានអនុញ្ញាតឲ្យមានការលំបាកនេះកើតឡើង ក៏បានប្រទានការផ្គត់ផ្គង់នៅក្នុងរបៀបដ៏អស្ចារ្យរបស់ទ្រង់ផងដែរ។

លោក ចច មូល័រ (George Müller) ជាបុរសម្នាក់រស់នៅប្រទេសអង់គ្លេស ដែលគ្មានប្រាក់មួយកាក់មួយសេនសោះ ដូចជាសត្វស្លាបនៅលើអាកាស ឬក៏ផ្កានៅក្នុងទីវាល ប៉ុន្តែលោកបានទ្រទ្រង់គ្រួសារមួយ ដែលមានកុមារកំព្រាប្រហែលពីរពាន់នាក់ តាមរយៈការអធិស្ឋាន និងសេចក្តីជំនឿ ដែលក្រោយមក ចំនួននោះបានកើនឡើងទ្វេដង។ លោកគ្រូ មូល័រ កំពុងបង្ហាញសេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់ ទាំងដែលគ្មានប្រាក់ឧបត្ថម្ភ ទាំងដែលមិនស្នើសុំជំនួយ ហើយក៏មិនបានប្រាប់ពីសេចក្តីត្រូវការរបស់គាត់ដល់អ្នកណាផ្សេងទៀតក្រៅពីព្រះជាម្ចាស់ ដែលគាត់បានពឹងផ្អែកទៅលើទាំងស្រុងលើសេចក្តីសន្យារបស់ទ្រង់ដែរ។ ការនេះបានបំផុសសេចក្តីជំនឿរបស់លោកគ្រូ ហ៍ដសុន ថេល័រ ព្រមទាំងអ្នកដទៃទៀតដែរ។ ប៉ុន្តែ ចិត្តដែលពេញដោយក្តីមេត្តារបស់លោកគ្រូ មូល័រ មិនបានស្កប់ស្កល់នៅឡើយទេ លុះត្រាតែគាត់បានចូលរួមចំណែកដោយផ្ទាល់ចំពោះការងាររបស់បេសកជននៅកន្លែងដ៏ខ្មៅងងឹតបំផុតនៃលោកីយ៍នេះសិន។ គាត់បានអធិស្ឋានសម្រាប់ប្រាក់រៃអង្គាស ដើម្បីគាំទ្រការបង្រៀនដំណឹងល្អនៅបណ្តាប្រទេសផ្សេងៗ រួមទាំងប្រទេសចិនផងដែរ ព្រមទាំងបានរកឃើញសេចក្តីអំណរក្នុងការក្លាយជាផ្លូវមួយ ដើម្បីជាជំនួយរបស់ព្រះជាម្ចាស់នៅកាលៈទេសៈដ៏លំបាកៗជាច្រើន។ វាហាក់បីដូចជាព្រះអម្ចាស់សណ្តាប់គាត់យ៉ាងពិសេស ហើយអាចប្រើប្រាស់គាត់សម្រាប់ព័ន្ធកិច្ចសំខាន់ៗជាច្រើនទៀត ដែលអ្នកផ្សេងទៀតខកខាន ឬមិនបានត្រៀមខ្លួនជាស្រេចសម្រាប់ការនោះ។

ឧទាហរណ៍៖ បន្ទាប់ពីមានកុប្បកម្មនៅស្រុកយ៉ាងចូវបានកើតឡើង ហើយមុនពេល

ដែលព័ត៌មានអាចឮទៅដល់ប្រទេសអង់គ្លេស លោក មូល័រ មានអារម្មណ៍បណ្ដាលចិត្ត ឲ្យផ្ញើជំនួយខាងហិរញ្ញវត្ថុទៅបេសកកម្មទៅកាន់ទឹកដីប្រទេសចិន។ គាត់បានបរិច្ចាគរួច រាល់ ត្រឹមតែនៅមួយ ឬពីរថ្ងៃ ក្រោយពីការធ្វើកុប្បកម្មប៉ុណ្ណោះ គាត់បានសរសេរទៅកាន់ លោកគ្រូ បើកហ្គ័រ ដើម្បីសុំឈ្មោះសមាជិកផ្សេងរបស់អង្គការបេសកកម្មកចិនដីគោក ដែលគាត់អាចឧបត្ថម្ភ និងអធិស្ឋានឲ្យ។ លោកគ្រូ បើកហ្គ័រ បានផ្ដល់ឈ្មោះចំនួនប្រាំ មួយនាក់ដល់គាត់ ដើម្បីពិចារណាក្នុងការជួយ ហើយគាត់ក៏បានសម្រេចចិត្តថា ឧបត្ថម្ភ ដល់ពួកគាត់ទាំងអស់គ្នា។

មួយឆ្នាំក្រោយមក នៅពេលដែលមានការខ្វះខាតសាច់ប្រាក់សម្រាប់ព័ន្ធកិច្ចនៅ ប្រទេសចិន លោកគ្រូ មូល័រ បានសរសេរម្ដងទៀត ដើម្បីផ្ដល់ជំនួយបន្ថែម។ នៅពេល ដែលសំបុត្រកំពុងតែនៅតាមផ្លូវលោកគ្រូ ថេល័រ បានផ្ញើប្រាក់ខែសម្រាប់ខែធ្នូ ថែមទាំង បានសរសេរទៅកាន់អ្នកចម្រូតម្នាក់ថា៖

«នៅអំឡុងឆមាសទីមួយខាងហិរញ្ញវត្ថុនៃឆ្នាំនេះ គ្រប់គ្នាបានចូលរួមជាងមួយពាន់ ផោន (ស្មើនឹង $22.120,00 ដុល្លារ បច្ចុប្បន្ន) តិចជាងឆ្នាំមុន។ ខ្ញុំមិនបានជួលចុងភៅ ទៀតឡើយ ពីព្រោះវាចំណាយតិចជាងនៅក្នុងការយកអាហារឆ្អិនស្រាប់ដែលដឹកជញ្ជូន ពីភោជនីយដ្ឋានក្នុងតម្លៃមួយដុល្លារ (ស្មើនឹង $២២ ដុល្លារ បច្ចុប្បន្ន) ម្នាក់ជារៀងរាល់ ខែ។ សូមអធិស្ឋានដោយជំនឿចំពោះប្រាក់មូលនិធិ ដើម្បីជៀសវាងការកាត់បន្ថយការងារ របស់យើង»។

គាត់បានចាត់ទុកការកាត់បន្ថយភាពសុខស្រួលរបស់គាត់នោះ គឺជារឿងតូចតាច ប៉ុន្តែ អរព្រះគុណព្រះ «ការកាត់បន្ថយការងាររបស់យើង» នោះមិនមែនជាអ្វីដែលគាត់ត្រូវតែធ្វើ ទេ! មុនពេលដាច់ឆ្នាំ នៅក្នុងឱកាសនោះ គាត់បានទទួលសំបុត្ររបស់លោក មូល័រ។

«ជូនចំពោះប្អូនប្រុសជាទីស្រឡាញ់! ខ្ញុំទទួលអារម្មណ៍នៃការត្រាស់ហៅយ៉ាងខ្លាំង ដើម្បីឲ្យមកជួយកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងប្រទេសចិនទាំងផ្នែកធនធាន និងការ អធិស្ឋាន។ ថ្មីៗនេះ ខ្ញុំប្រាថ្នាចង់ជួយផ្នែកហិរញ្ញវត្ថុដល់បងប្អូនប្រុសស្រីជាទីស្រឡាញ់ ទាំងអស់ដែលនៅជាមួយប្អូន ដើម្បីបង្ហាញពួកគេអំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ ខ្ញុំ។ ព្រះអម្ចាស់សម្រេចបំណងប្រាថ្នារបស់ខ្ញុំហើយ»។

មានមូលប្បទានប័ត្រចំនួនដប់មួយសន្លឹកសម្រាប់សមាជិករបស់អង្គការបេសកកម្ម

ចិនដីគោកដែលលោកគ្រូ មូល័រ មិនបានជួយឧបត្ថម្ភពីមុនមក។ លោកគ្រូ ប៊ើកហ្គ័រ បានសរសេរបន្តនៅក្នុងសំបុត្រដដែលនោះទៀតថា៖

"លោក មូល័រ បានគិតអំពីរឿងនេះម្តងទៀត ហើយបានសុំឈ្មោះមនុស្សគ្រប់គ្នាដែលបានចូលរួមជាមួយ  ស៊ី.អាយ.អិម (C.I.M. ដែលមានន័យថា អង្គការបេសកកម្មនៅចិនដីគោក) ព្រោះគាត់ចង់ផ្ញើជំនួយដល់អ្នកគ្រប់គ្នា តាមលទ្ធភាពដែលគាត់អាចធ្វើបាន លុះត្រាតែយើងដឹងហេតុផលដែលមិនគួរផ្ញើមក។ ប្រាកដណាស់ ព្រះអម្ចាស់ជ្រាបថា ប្រាក់រ៉ៃអង្គាសរបស់យើងកំពុងតែអស់ទៅៗហើយ ហើយបានបំផុសគំនិតអ្នកបម្រើដ៏ស្មោះត្រង់របស់ទ្រង់ឲ្យផ្តល់ជំនួយមកទៀត"។

វាមិនមែនគ្រាន់តែជារឿងប្រាក់កាក់នោះទេ ការអាណិតអាសូរពេញដោយការអធិស្ឋានពីមនុស្សបែបនេះ ក៏បានធ្វើឲ្យដង្វាយរបស់គាត់ក្លាយជាការលើកទឹកចិត្តដ៏អស្ចារ្យ នៅពេលនេះផងដែរ។

នៅក្នុងសំបុត្រដែលគាត់ផ្ញើទៅបេសកជននានា លោក មូល័រ បានសរសេរថា គោលដៅចម្បងរបស់គាត់គឺ ប្រាប់ឲ្យពួកគេដឹងថា គាត់ស្រឡាញ់ពួកគេនៅក្នុងព្រះអម្ចាស់ គាត់ក៏មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការងារបម្រើព្រះអម្ចាស់នៅប្រទេសចិនផងដែរ ទាំងអធិស្ឋានសម្រាប់ពួកគេជារៀងរាល់ថ្ងៃផង។

ខ្ញុំគិតថា "ការដឹងថាមាននរណាម្នាក់ដែលអាណិតដល់លោកអ្នក ហើយអធិស្ឋានសម្រាប់លោកអ្នកទំនងជាលើកទឹកចិត្តលោកអ្នក នៅពេលដែលខ្លួនប្រឈមនឹងឧបសគ្គ ការល្បួងល ការលំបាក និងការខកចិត្តនានាផងដែរ។ ប៉ុន្តែ សូម្បីតែវាហាក់បីដូចជាគ្មាននរណាម្នាក់ខ្វល់ខ្វាយដល់លោកអ្នក ក៏ព្រះអម្ចាស់នឹងនៅតែគង់នៅជាមួយលោកអ្នកដែរ។ សូមគិតអំពីបទពិសោធន៍ដែលសាវ័ក ប៉ុល មាននៅទីក្រុងរ៉ូម (២ធីម៉ូថេ ៤:១៦-១៨)។

សូមពឹងផ្អែកលើទ្រង់ សម្លឹងមើលទ្រង់ ហើយពឹងអាងលើទ្រង់ចុះ។ សូមប្រាកដថា បើលោកអ្នកដើរជាមួយទ្រង់ ហើយសម្លឹងមើលទ្រង់ជាជំនួយ នោះព្រះអង្គនឹងមិនធ្វើឲ្យលោកអ្នកខកចិត្តឡើយ។ បងប្រុសម្នាក់ដែលបានដើរតាមព្រះអម្ចាស់អស់រយៈពេលសែសិបបួនឆ្នាំកំពុងសរសេរសំបុត្រនេះ ដើម្បីលើកទឹកចិត្តប្អូនដោយចែកចាយជាមួយប្អូនថា ព្រះអម្ចាស់មិនដែលធ្វើឲ្យយើងខកចិត្តឡើយ។ សូម្បីតែក្នុងការលំបាកខ្លាំងបំផុត

ក្នុងការសាកល្បងដ៏លំបាកបំផុត ក្នុងភាពក្រីក្រ និងភាពចាំបាច់បំផុត ទ្រង់មិនដែលខាននឹងប្រោសខ្ញុំឡើយ។ ព្រះគុណរបស់ទ្រង់បានអនុញ្ញាតឲ្យបងទុកចិត្តលើទ្រង់ ហើយទ្រង់តែងតែជាជំនួយរបស់បង។ បងមានសេចក្តីអំណរយ៉ាងខ្លាំងនៅក្នុងការសរសើរព្រះនាមទ្រង់»។

លោកគ្រូ ថេល័រ ផ្ទាល់កម្រត្រូវការការលើកទឹកចិត្តបែបនេះណាស់ ពីព្រោះវាហាក់បីដូចជាចម្លែកណាស់ចំពោះបញ្ហាកុប្បកម្មនៅស្រុកយ៉ាងចូវស្រាលជាង បើប្រៀបធៀបទៅនឹងការល្បងលផ្នែកខាងក្នុងដែលគាត់បានប្រឈម។ ប្រហែលភាពតានតឹងមកពីស្ថានភាពខាងក្រៅបានរារាំងខ្លះៗដល់សេចក្តីអំណរ និងការសម្រាកខាងព្រលឹងវិញ្ញាណរបស់គាត់។ ហើយបន្ទាប់ពីបានទទួលបទពិសោធន៍កាន់តែខ្លាំងឡើង ដែលកំពុងតែចូលមកជិតគាត់ ក៏គ្មានការលំបាកណាធ្លាប់ធ្វើឲ្យគាត់រសាយពីសេចក្តីអំណរក្នុងព្រះអម្ចាស់នោះឡើយ។

គាត់ធ្លាប់ពោលថា «វាពិតជាមិនសំខាន់ទេថា វាមានសម្ពាធខ្លាំងប៉ុណ្ណានោះ តែអ្វីដែលសំខាន់គឺថា តើសម្ពាធនោះនៅត្រង់ណា។ សូមឲ្យប្រាកដថា វាមិនមែនមករវាងលោកអ្នក និងព្រះអម្ចាស់នោះទេ—នោះនៅពេលសម្ពាធកាន់តែធ្ងន់ វានឹងកាន់តែសង្កត់អ្នកទៅចំពោះទ្រូងទ្រង់»។

នៅពេលនោះ គាត់មិនបានរៀនអំពីអាថ៌កំបាំង ដែលក្រោយមកបានចាក់បំពេញជីវិតរបស់គាត់ដោយសេចក្តីអំណរយ៉ាងខ្លាំង ហើយជាញឹកញាប់គាត់ប្រទះនឹងពេលវេលាដ៏ខ្មៅងងឹត និងភាពជិតអស់សង្ឃឹមផ្នែកខាងក្នុង។

«ជាញឹកញាប់ ខ្ញុំបានសុំឲ្យអ្នកម្តាយខ្ញុំ នឹកចាំពីខ្ញុំនៅក្នុងសេចក្តីអធិស្ឋានរបស់គាត់ ហើយខ្ញុំពិតជាត្រូវការសេចក្តីអធិស្ឋានទាំងនេះគ្រប់ពេលវេលា។ នៅពេលនេះ ខ្ញុំត្រូវការសេចក្តីអធិស្ឋានទាំងនេះជាជាងពេលណាៗទាំងអស់។ មានមនុស្សខ្លះច្រណែនខ្ញុំ មនុស្សជាច្រើនផ្សេងទៀតមើលងាយខ្ញុំ ហើយក៏មានមនុស្សជាច្រើនទៀតស្អប់ខ្ញុំដែរ។ ជាញឹកញាប់ ខ្ញុំត្រូវគេស្តីបន្ទោសចំពោះរឿងរ៉ាវផ្សេងៗ ទាំងដែលខ្ញុំមិនដឹងអ្វីទាំងអស់ចំពោះការនោះ ឬក៏មិនមែនជាកំហុសរបស់ខ្ញុំសោះ។ ខ្ញុំកំពុងផ្លាស់ប្តូរច្បាប់ដែលបានបង្កើតឡើងនៃការអនុវត្តបេសកកម្ម ដោយប្រយុទ្ធប្រឆាំងនឹងប្រព័ន្ធដ៏ធំនៃគោលជំនឿខុសឆ្គង រួមទាំងអបិយជំនឿផ្សេងៗដោយធ្វើការនៅក្នុងរបៀបថ្មីមួយ ដែលមានពួកអ្នក

ជំនួយមានបទពិសោធន៍ប៉ុន្មាននាក់។ ជារឿយៗ ខ្ញុំខស្សាហ៍ឈឺ ហើយប្រឈមទាំងវិបត្តិផ្លូវចិត្ត និងវិបត្តិជាក់ស្តែង។ ប្រសិនបើព្រះអម្ចាស់មិនមានសេចក្តីមេត្តាករុណាយ៉ាងអស្ចារ្យនោះទេ ហើយប្រសិនបើខ្ញុំមិនជឿយ៉ាងមុតមាំថា កិច្ចការទាំងអស់ជារបស់ទ្រង់ ហើយថា ទ្រង់ជួយខ្ញុំនៅក្នុងការប្រយុទ្ធដ៏ស្វិតស្វាញនោះទេ នោះខ្ញុំប្រាកដជាបោះបង់ចោលបាត់ហើយ ដ្បិតចម្បាំងនេះស្រេចនៅព្រះយេហូវ៉ាវិញ ហើយទ្រង់នឹងទទួលជ័យជម្នះ។ យើងប្រហែលបរាជ័យម្តងហើយម្តងទៀត ប៉ុន្តែទ្រង់មិនដែលនឹងបរាជ័យសោះឡើយ។ ហើយសេចក្តីអធិស្ឋានរបស់អ្នកម្តាយកាន់តែសំខាន់ឡើងសម្រាប់ខ្ញុំពេលនេះ ជាងពេលពីមុនទៅទៀត។

ទំនួលខុសត្រូវរបស់ខ្ញុំកាន់តែកើនឡើង ហើយខ្ញុំកាន់តែត្រូវការព្រះគុណដ៏ពិសេសជាច្រើនទៀត ដើម្បីបំពេញតម្រូវការទាំងនោះ។ ទោះជាយ៉ាងណា ក៏ខ្ញុំមានការសោកស្តាយឥតឈប់ឈរ ដែលខ្ញុំដើរតាមទ្រង់ពីចម្ងាយ ហើយរៀនយ៉ាងយឺតៗអំពីរបៀបធ្វើត្រាប់តាមចៅហ្វាយដ៏ប្រសើរថ្លៃថ្លារបស់ខ្ញុំ។

ខ្ញុំមិនអាចប្រាប់អ្នកម្តាយបានទេថា ជាញឹកញាប់ការល្បួងលកើតមានច្រើនប៉ុណ្ណានៅចំពោះមុខខ្ញុំ។ ខ្ញុំមិនដែលដឹងថា ចិត្តរបស់ខ្ញុំអាក្រក់ប៉ុណ្ណាទេ។ ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ស្រឡាញ់ការបម្រើទ្រង់ ហើយចង់បម្រើទ្រង់ក្នុងគ្រប់ការទាំងអស់។ ហើយគ្មានអ្វីសំខាន់សម្រាប់ខ្ញុំជាងព្រះសង្គ្រោះដ៏ថ្លៃថ្លា ហើយតាមរយៈទ្រង់ព្រះអង្គបានទទួលយកខ្ញុំនោះឡើយ។ ជាញឹកញាប់ ខ្ញុំបានល្បួងឲ្យគិតថា មនុស្សមានបាបដូចខ្ញុំមិនអាចជាកូនព្រះបានឡើយ។ ប៉ុន្តែ ខ្ញុំព្យាយាមបដិសេធគំនិតទាំងនេះ ហើយជំនួសមកវិញដោយការកាន់តែមានសេចក្តីអំណរច្រើនឡើងនៅក្នុងភាពវិសេសរបស់ព្រះយេស៊ូវ ហើយនៅក្នុងព្រះគុណដ៏បរិបូរណ៍ ដែលធ្វើឲ្យយើងត្រូវបានទទួលយកនៅក្នុងព្រះអម្ចាស់ដ៏ជាទីស្រឡាញ់។ ព្រះវរបិតាសព្វព្រះហឫទ័យចំពោះទ្រង់ ហើយយើងគួរតែធ្វើបែបនោះដែរ។ អូហ៍! ប៉ុន្តែ ខ្ញុំខ្វះមិនដល់សិរីល្អទៀតយ៉ាងណាទៅ! សូមព្រះជាម្ចាស់ជួយខ្ញុំឲ្យស្រឡាញ់ទ្រង់កាន់តែច្រើន ហើយបម្រើទ្រង់កាន់តែប្រសើរជាងនេះ។ សូមជួយអធិស្ឋានសម្រាប់កូន។ សូមឲ្យព្រះអម្ចាស់រក្សាខ្ញុំពីអំពើបាប ញែកខ្ញុំជាបរិសុទ្ធពេញលេញ ហើយប្រើប្រាស់ខ្ញុំបន្ថែមទៀតក្នុងការបម្រើទ្រង់។

ព្រះវិញ្ញាណបរិសុទ្ធតែងតែបង្កើតឲ្យយើងឃ្លាន និងស្រេកនូវសេចក្តីសុចរិត ដើម្បីព្រះ

គ្រីស្ទអាចចម្អែតព្រលឹងដែលកំពុងស្រេកឃ្លានទាំងនោះ។

ការជឿលើព្រះយេស៊ូវដែលត្រូវគេឆ្កាងនាំសេចក្ដីសុខសាន្ដដល់មនុស្សមានបាប ដូចគ្នានេះដែរ ការជឿលើការរស់ឡើងវិញរបស់ព្រះយេស៊ូវបានផ្ដល់នូវសេចក្ដីសង្គ្រោះរាល់ថ្ងៃដល់ពួកបរិសុទ្ធ។

អ្នកម្ដាយមិនអាចជួយសង្គ្រោះខ្លួនឯងទាំងស្រុង ឬក៏ដោយផ្នែកណាមួយបានឡើយ»។

ជំពូកទី១៤

# ជីវិតដែលបានផ្លាស់ប្រែ

*ទ្រង់គង់នៅក្នុងខ្ញុំ ហើយខ្ញុំនៅជាប់នឹងទ្រង់។ ទ្រង់បំពេញព្រលឹងដែលទទេស្អាតរបស់ខ្ញុំពេលនេះ និងរហូតតទៅ។*

— *អេច. បូណា (H. Bonar)*

ប្រាំមួយខែបន្ទាប់ពីការសរសេរសំបុត្រមុន សំពៅមួយដែលធ្វើដំណើរទៅខាងជើងតាមប្រឡាយទឹកធំប្រែក្តនខែនណាលបាននាំអ្នកដំណើរម្នាក់ពេញដោយសេចក្តីអំណរយ៉ាងខ្លាំងដែលគាត់បានរកឃើញថ្មីៗនេះ។ នៅស្រុកយ៉ាងចូវ លោកគ្រូ ជូដ៍ (Mr. Judd) បានរង់ចាំការត្រឡប់មកវិញពីមិត្តសម្លាញ់ និងអ្នកដឹកនាំរបស់គាត់ ប៉ុន្តែគាត់ត្រៀមខ្លួនស្ទើរតែមិនទាន់សម្រាប់ការផ្លាស់ប្តូរនៅក្នុងមិត្តសម្លាញ់ដែលគាត់ស្គាល់យ៉ាងច្បាស់នោះ។ លោកគ្រូ ហ័ដសិន ថេល័រ បាននិយាយចូលក្នុងសាច់រឿងរបស់គាត់យ៉ាងលឿន។ គាត់បានដើរទៅវិញទៅមកនៅក្នុងបន្ទប់ ព័ទ្ធដៃនៅខាងក្រោយខ្នង រួចនិយាយដោយយ៉ាងលាន់ថា៖ «អូហ៍ លោក ជូដ៍! ព្រះជាម្ចាស់បានបំផ្លាស់ខ្ញុំឲ្យក្លាយជាមនុស្សម្នាក់ថ្មីហើយ! ព្រះជាម្ចាស់បានបំផ្លាស់ខ្ញុំឲ្យក្លាយជាមនុស្សម្នាក់ថ្មីហើយ!»។

បទពិសោធន៍ដែលបានកើតឡើងក្រោយពីការអធិស្ឋាន គឺពិតជាអស្ចារ្យណាស់ ប៉ុន្តែវាសាមញ្ញ ស្ទើរតែមិនអាចពិពណ៌នាបាន។ វាដូចជាកាលពីមុន៖ «ខ្ញុំខ្វាក់ តែឥឡូវខ្ញុំមើលឃើញ!»។

លោកគ្រូ ថេល័រ បានទទួលសំបុត្រមួយចំនួនមកពីជីងគាំង (បច្ចុប្បន្ន ស៊ិនជាំង) ដែលមានមួយច្បាប់មកពីលោកគ្រូ ចន ម៉ាកខាធី សរសេរមកពីស្រុកហាំងចូវ។ ពន្លឺនៃ

ព្រះដ៏ត្រចះត្រចង់បានផ្តល់ពន្លឺខាងក្នុងគំនិតគាត់ ធ្វើឲ្យគ្រប់យ៉ាងហាក់ស្រស់ស្រាយឡើង។ គាត់អន្ទះសាចង់ចែករំលែកបទពិសោធន៍គាត់ជាមួយលោកគ្រូ ថេល័រ ពីព្រោះគាត់បានយល់ច្បាស់ពីការលំបាកខាងអារម្មណ៍ ដែលមិត្តសម្លាញ់របស់គាត់កំពុងតែជួបប្រទះ។ ទោះជាយ៉ាងណា គាត់មិនប្រាកដថាត្រូវចាប់ផ្តើម ឬក៏រៀបរាប់អំពីបទពិសោធន៍របស់គាត់ទាំងនោះតាមរយៈពាក្យសម្តីដោយរបៀបណាឡើយ។

គាត់បានសរសេរថា៖ «ខ្ញុំសង្ឃឹមថា យើងអាចនិយាយគ្នាអំពីរបៀបរស់នៅក្នុងភាពបរិសុទ្ធជាមួយគ្នា។ នៅពេលប្អូនប្រុសបាននិយាយមកបងអំពីការនោះ វាបានបំពេញចិត្តរបស់បងជាងអ្វីៗទាំងអស់ ដែលបងបានអាន។ នេះក៏ព្រោះតែការមានអារម្មណ៍ថា ដូចជាការបរាជ័យមួយដែលខ្វះមិនដល់អ្វីដែលខ្ញុំគួរតែប្រាថ្នាចង់បានម្តងហើយម្តងទៀត។ បងបានបន្តស្វែងរកផ្លូវមួយដោយឥតស្រាកស្រាន្ត ដើម្បីទទួលបានការរួបរួមជាមួយនឹងព្រះជានិច្ច ជាការប្រកបគ្នាដែលពេលខ្លះមានអារម្មណ៍ថាពិតនៅចំពោះមុខ ប៉ុន្តែជាញឹកញយវាហាក់នៅសែនឆ្ងាយ»។

“តើប្អូនដឹងទេ ពេលនេះបងជឿហើយថា ការខ្នះខ្នែង ការប្រាថ្នាចង់បាន ហើយការសង្ឃឹមចង់បាន ពេលវេលាល្អៗ មិនមែនជាផ្លូវទៅកាន់សេចក្តីបរិសុទ្ធ សេចក្តីសុខសាន្ត ឬក៏សេចក្តីមានប្រយោជន៍នោះឡើយ។ ដោយឥតសង្ស័យ ធ្វើបែបនេះពិតជាល្អ ប្រសើរជាងការដែលបានស្កប់ចិត្តដោយសមិទ្ធផលអន់ៗ ក៏ប៉ុន្តែចុងក្រោយនោះក៏មិនមែនជាផ្លូវល្អផងដែរ។ ខ្លឹមសារមួយឃ្លា ដែលដកស្រង់ចេញពីសៀវភៅមួយក្បាល មានចំណងជើងថា៖ “ព្រះគ្រីស្ទជាគ្រប់ទាំងអស់ ក្នុងទាំងអស់ (Christ is All)”។ ពិតជាបានរំលឹកដល់ខ្ញុំ ដោយនិយាយថា៖

“ពេលលោកអ្នកទទួលជឿព្រះយេស៊ូវគ្រីស្ទ នោះជាទីចាប់ផ្តើមនៃដំណើរការឆ្ពោះទៅកាន់ភាពបរិសុទ្ធ កាលណាលោកអ្នកស្រឡាញ់ទ្រង់អស់ពីចិត្ត នោះសេចក្តីបរិសុទ្ធក៏ចម្រើនឡើង។ នៅពេលលោកអ្នកតែងអាងលើទ្រង់ជានិច្ច នោះសេចក្តីបរិសុទ្ធរបស់អ្នកនឹងពេញលេញ”។

“មនុស្សបរិសុទ្ធជាងគេ មានព្រះគ្រីស្ទច្រើនជាងគេនៅក្នុងខ្លួន ហើយទទួលយកសេចក្តីអំណរដ៏លើសលប់នៅកិច្ចការដែលព្រះយេស៊ូវបានសម្រេចនៅលើឈើឆ្កាង។ សេចក្តីជំនឿទន់ខ្សោយធ្វើឲ្យលោកអ្នកយឺតយ៉ាវ ហើយការបរាជ័យជាច្រើនផង”។

"ពេលនេះ ខ្ញុំគាំទ្រពេញទំហឹងចំពោះល្បះចុងក្រោយ។ ខ្ញុំចង់រស់នៅប្រកបដោយព្រះគុណទ្រង់ ដោយអនុញ្ញាតឲ្យព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់ខ្ញុំធ្វើការតាមព្រះហឫទ័យផងទ្រង់ក្នុងខ្ញុំសម្រាប់ដំណើរនៃការញែកចេញជាបរិសុទ្ធរបស់ខ្ញុំ។ ខ្ញុំតាំងចិត្តឲ្យស្ថិតនៅជាប់នឹងព្រះ មិនមែនដោយខំប្រឹងប្រែង ឬប្រឆាំងដោយកម្លាំងខ្លួនឯង ប៉ុន្តែដោយសម្លឹងមើលទៅព្រះជាម្ចាស់ ទុកចិត្តទ្រង់សម្រាប់កម្លាំង និងអំណាចដែលយើងត្រូវការ ហើយសម្រាកនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះសង្គ្រោះដ៏មានរិទ្ធិចេស្តា ដោយមានសេចក្តីអំណរក្នុងភាពពេញលេញនៃសេចក្តីសង្គ្រោះពីគ្រប់ទាំងអំពើបាប។ នេះមិនមែនជារឿងថ្មីនោះទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ថ្មីសម្រាប់ខ្ញុំ។ វាដូចជាថ្ងៃដ៏អស្ចារ្យបានរះមកលើខ្ញុំ។ ខ្ញុំស្វាគមន៍ការនោះដោយសេចក្តីភ័យខ្លាច និងសេចក្តីជំនឿ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានមកដល់គែមមាត់សមុទ្រដែលគ្មានព្រំដែន ហើយគ្រាន់តែបានភ្លក់នូវអ្វីដែលពិតជាធ្វើឲ្យបានស្កប់ចិត្ត។ ឥឡូវនេះ មានតែព្រះគ្រីស្ទមួយអង្គគត់សម្រាប់ខ្ញុំជាប្រភពនៃអំណាចសម្រាប់ការបម្រើ ព្រមទាំងជាមូលដ្ឋានសម្រាប់សេចក្តីសុខសាន្តដែលមិនប្រែប្រួល"។

"ដូច្នេះ តើយើងអាចធ្វើយ៉ាងណា ដើម្បីបង្កើនសេចក្តីជំនឿ? គឺដោយគ្រាន់តែគិតជានិច្ចពីព្រះគ្រីស្ទជានរណា ហើយនិងគ្រប់ទាំងអស់នៃទ្រង់គឺសម្រាប់យើង៖ ព្រះជន្មទ្រង់ ការសុគតរបស់ទ្រង់ ព្រះរាជកិច្ចរបស់ទ្រង់ ព្រមទាំងព្រះអង្គទ្រង់តែមួយ ដែលបានបើកសម្តែងនៅក្នុងព្រះគម្ពីរ។ មិនមែនដោយសារការខំប្រឹងប្រែង ដើម្បីបានសេចក្តីជំនឿនោះទេ ប៉ុន្តែដោយផ្តោតអារម្មណ៍ទៅព្រះមួយអង្គដែលស្មោះត្រង់ទៅវិញទេតើ—ដែលនោះហាក់ជាអ្វីដែលយើងត្រូវការ។ គ្រាន់តែទុកចិត្តទាំងស្រុងទៅលើព្រះអម្ចាស់ដ៏ជាទីស្រឡាញ់របស់យើង ទាំងនៅគ្រប់ពេលនេះ និងនៅក្នុងភាពអស់កល្បជានិច្ច"។

យើងមិនបានដឹងទេ ថាតើការអស្ចារ្យនឹងកើតឡើងដោយរបៀបណាខ្លះ ប៉ុន្តែលោកគ្រូហ៉ដសិន ថេល័រ បានសរសេរថា៖ "នៅពេលដែលខ្ញុំអាន ខ្ញុំអាចមើល ហើយយល់ឃើញវាទាំងអស់។ ខ្ញុំបានបែរទៅរកព្រះយេស៊ូវ ហើយនៅពេលដែលសម្លឹងមើលទៅទ្រង់ អូហ៍ សេចក្តីអំណរបានចាក់បំពេញលើខ្ញុំហើយ!"។

លោកគ្រូ ជូដង់ បានកត់ត្រាទៀតថា "ពេលនោះគាត់ជាមនុស្សម្នាក់ដែលពេញដោយសេចក្តីអំណរ ជាគ្រីស្ទបរិស័ទម្នាក់ដែលមានភាពរីករាយ។ ពីមុន គាត់ជាបុគ្គលម្នាក់ដែលរុំព័ទ្ធដោយបន្ទុក ហើយមានការសម្រាកខាងឯព្រលឹងវិញ្ញាណតិចតួចណាស់។ តែពេល

នេះ គាត់បានរកឃើញសេចក្ដីសម្រាកនៅក្នុងព្រះយេស៊ូវ ហើយអនុញ្ញាតឲ្យទ្រង់ធ្វើកិច្ចការទាំងឡាយនៅក្នុងគាត់ និងតាមរយៈគាត់ដែលធ្វើឲ្យរឿងទាំងអស់ខុសគ្នាស្រលះពីមុន។ បន្ទាប់ពីការផ្លាស់ប្ដូរនេះ នៅពេលដែលគាត់បង្រៀននៅក្នុងការប្រជុំនានា ហាក់មានអំណាចអ្វីមួយបានហូរចេញពីគាត់ ហើយសេចក្ដីសុខសាន្តថ្មីបានចាក់បំពេញគាត់នៅក្នុងជីវិតប្រចាំថ្ងៃរបស់គាត់។ គាត់មិនបារម្ភខ្លាំងដោយសេចក្ដីទុក្ខព្រួយទៀតឡើយ នៅពេលគាត់មានបញ្ហា។ គាត់បានផ្ទេរបន្ទុកគ្រប់យ៉ាងទៅព្រះជាម្ចាស់នៅក្នុងរបៀបថ្មីមួយ ថែមទាំងបានចំណាយពេលកាន់តែច្រើននៅក្នុងការអធិស្ឋាន។ ជំនួសដោយការធ្វើការដល់យប់ជ្រៅ គាត់បានចាប់ផ្ដើមចូលសម្រាន្តពីព្រលប់ ហើយបានក្រោកឡើងនៅម៉ោង៥ព្រឹក ដើម្បីចំណាយពេលសិក្សាព្រះគម្ពីរ និងអធិស្ឋានរហូតដល់ពីរម៉ោង មុនពេលចាប់ថ្ងៃថ្មី»។

គាត់ទទួលបានជីវិតផ្លាស់ប្រែថ្មីមួយ—ដល់ចំណុចមួយដែលគាត់អាចនិយាយថាៈ «ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ»។ កាលពីប្រាំមួយខែមុន គាត់ទើបតែបាននិយាយដោយសោកស្ដាយថាៈ «ខ្ញុំសោកស្ដាយដែលខ្ញុំដើរតាមចៅហ្វាយដ៏ថ្លៃថ្លារបស់ខ្ញុំពីចម្ងាយបែបនេះ ហើយរៀនយ៉ាងយឺតពីរបៀបយកតម្រាប់តាមទ្រង់»។ ពេលនេះ គំនិតនៃការធ្វើតាមទ្រង់បានវិនាសហើយ! គាត់កំពុងទទួលបទពិសោធន៍ជាក់ស្ដែងដ៏អស្ចារ្យ ដែលព្រះគ្រីស្ទបានរស់នៅក្នុងគាត់។ ភាពខុសប្លែកគ្នានេះពិតជាអស្ចារ្យខ្លាំងណាស់—សេរីភាពចូលមកជំនួសចំណង ជ័យជម្នះចូលមកដោយស្ងាត់ៗជំនួសភាពបរាជ័យ ហើយការស្ងប់ចិត្តដោយពឹងលើភាពគ្រប់គ្រាន់នៃព្រះមួយអង្គបានចូលមកជំនួសអារម្មណ៍ភ័យខ្លាច និងទន់ខ្សោយ។ ការផ្លាស់ប្រែនេះពិតជាជ្រាលជ្រៅណាស់ ដែលបណ្ដាលចិត្តលោកគ្រូ ហ័ដសិន ឲ្យចែករំលែកបទពិសោធន៍អាថ៌កំបាំងដ៏មានតម្លៃនេះដល់អស់អ្នកដែលមានចំណាប់អារម្មណ៍ ដែលគាត់បានជួបប្រទះ។ សព្វថ្ងៃ មានមនុស្សជាច្រើននៅតែត្រូវការសេចក្ដីជំនួយនេះ ដែលនេះជាមូលហេតុដែលយើងចែករំលែកសម្រង់សេចក្ដីមួយពីសំបុត្រមួយក្នុងចំណោមសំបុត្រពីមុនៗរបស់គាត់លើប្រធានបទនោះ។ គាត់បានសរសេរទៅប្អូនស្រីក្នុងព្រះម្ចាស់របស់គាត់ លោកស្រី ប្រ៊ូមហាល (Mrs. Broomhall) ដែលកំពុងដោះស្រាយជាមួយឧបសគ្គធំៗនៅក្នុងការបីបាច់ថែរក្សាគ្រួសារមួយដែលមានកូនដប់នាក់។

«អរគុណប្អូនស្រីខ្លាំងណាស់ចំពោះសំបុត្រដ៏វែង និងជាទីស្រឡាញ់នេះ។ បងមិនគិតថា ប្អូនស្រីសរសេរសំបុត្របែបនេះមកបងទេ តាំងពីយើងបានត្រឡប់មកប្រទេសចិនវិញ។ បងយល់អំពីការនោះ ដូចបងអញ្ចឹង ប្អូនស្រីគ្មានពេលទំនេរអាចសរសេរបានទេ—វាមិនមែនជារឿងថា ចង់សរសេរ ឬមិនចង់នោះទេ។ ទាំងផ្លូវកាយ និងផ្លូវចិត្តត្រឹមតែអាចទ្រាំទ្រភាពតានតឹងមួយចំនួន ហើយអាចត្រឹមតែធ្វើការងារមួយចំនួនប៉ុណ្ណោះ»។

«ថ្មីៗនេះ ការងាររបស់បងពិតជាច្រើន លំបាក ឬមានតម្រូវការច្រើនណាស់ណា ប៉ុន្តែឥឡូវនេះភាពតានតឹង និងបន្ទុកបានធូរស្បើយអស់ហើយ។ កាលពីប៉ុន្មានអាទិត្យមុន ប្រហែលជាពេលវេលាដ៏រីករាយបំផុតសម្រាប់ជីវិតរបស់បង ហើយបងក៏អន្ទះសានៅក្នុងការចែកចាយបន្តិចបន្តួចអំពីអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់ព្រលឹងរបស់បង។ បងមិនប្រាកដថា បងអាចពន្យល់វាបានល្អប៉ុណ្ណានោះទេ នៅពេលដែលគ្មានអ្វីជាពិសេសថ្មី ចម្លែក ឬក៏អស្ចារ្យ—ប៉ុន្តែពេលដូចគ្នានេះដែរ គ្រប់យ៉ាងគឺជារឿងថ្មី»។

«ប្រសិនបើបងអាចពន្យល់ពីអ្វីដែលបានលើកមកពីខាងដើម វានឹងកាន់តែច្បាស់ជាង។ មែនហើយប្អូនស្រីសម្លាញ់អើយ រយៈពេលប្រាំមួយ ឬប្រាំបីខែ បងមានក្តីបារម្ភពន់ពេកណាស់អំពីតម្រូវការនៃភាពបរិសុទ្ធ ភាពក្លៀវក្លា និងអំណាចខាងព្រលឹងវិញ្ញាណកាន់តែសម្បើម ទាំងសម្រាប់ខ្លួនបងផ្ទាល់ និងសម្រាប់បេសកកម្មរបស់ពួកយើង។ ប៉ុន្តែតម្រូវការផ្ទាល់ខ្លួនរបស់បងបានមកដល់មុន ហើយកំពុងតែបន្ទាន់ខ្លាំងបំផុត។ បងបានដឹងថា វាជារឿងដែលមិនកតញ្ញូ និងគ្រោះថ្នាក់បែបណា ដែលមិនបានចូលទៅកាន់តែជិតព្រះជាម្ចាស់។ បងបានអធិស្ឋានយ៉ាងខ្លាំង ទាំងឈឺចាប់ ទាំងបានតមអាហារ ទាំងបានព្យាយាមយ៉ាងខ្លាំង ទាំងបានខិតខំរកដំណោះស្រាយ ទាំងបានសិក្សាព្រះគម្ពីរដោយយកចិត្តទុកដាក់ ហើយថែមទាំងបានរកពេលសញ្ជឹងគិត—ប៉ុន្តែគ្មានអ្វីបានផលសោះ។ បងមានអារម្មណ៍ថា ត្រូវរងទម្ងន់នៃអំពើបាបជាប់ជានិច្ច ស្ទើរតែគ្រប់ជារៀងរាល់ម៉ោងពេញមួយថ្ងៃ»។

«បងបានដឹងថា ប្រសិនបើបងគ្រាន់តែអាចនៅជាប់ជាមួយព្រះគ្រីស្ទ នោះគ្រប់យ៉ាងនឹងមិនអីទេ ប៉ុន្តែបងមិនអាចធ្វើបានឡើយ។ បងចាប់ផ្តើមរាល់ថ្ងៃដោយការអធិស្ឋានតាំងចិត្តនៅក្នុងការរក្សាការផ្តោតអារម្មណ៍ទៅលើទ្រង់ ប៉ុន្តែការទាមទារពីការងាររបស់បង ជាញឹកញយពិតជាលំបាកណាស់ ហើយការរំខានឥតឈប់ឈរដែលនាំឲ្យនឿយ

ណាយអស់កម្លាំងទាំងនោះ បានធ្វើឲ្យបងភ្លេចទ្រង់។ នៅក្នុងបរិយាកាសបែបនេះ នោះអារម្មណ៍មួម៉ៅអាចនឹងកើតឡើងយ៉ាងងាយស្រួល ដែលនឹងល្បួងយើងមានភាពឆាប់ខឹង គំនិតដែលកាចសាហាវ ហើយម្តងម្កាលក៏ធ្វើឲ្យកាន់តែពិបាកគ្រប់គ្រងពាក្យសម្ដីមិនល្អទាំងឡាយ។ រាល់ថ្ងៃ បានបញ្ចប់ដោយកំណត់ត្រានៃអំពើបាប និងភាពបរាជ័យនៃការខ្វះភាពរឹងមាំ។ បើទោះបីជា បងមានចិត្តចង់ធ្វើឲ្យបានល្អក៏ដោយ ក៏បងមិនបានដឹងថា បងត្រូវធ្វើការទាំងនោះដោយរបៀបណាដែរ»។

មានសំណួរមួយចំនួនបានលើកឡើងថា៖ តើគ្មានការជួយសង្គ្រោះទេឬ? តើត្រូវតែមានទំនាស់ជាប់ជានិច្ច និងបរាជ័យជាញយដងបែបនេះមែនទេ? តើខ្ញុំអាចអធិប្បាយដោយស្មោះត្រង់ថា អស់អ្នកណាដែលទទួលជឿព្រះយេស៊ូវគ្រីស្ទ «នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ» ដោយរបៀបណា ទាំងដែលនោះមិនមែនបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំនោះផង? ជំនួសដោយការកាន់តែរឹងមាំ បងហាក់បីដូចជាកំពុងតែចុះខ្សោយ ហើយមិនសូវមានអំណាចទាស់ប្រឆាំងនឹងអំពើបាបនោះឡើយ។ ទាំងសេចក្តីជំនឿ ហើយសូម្បីតែសេចក្តីសង្ឃឹមក៏កំពុងរសាត់បាត់ដែរ។ បងស្អប់ខ្លួនឯង និងអំពើបាបរបស់បង ប៉ុន្តែនៅតែមិនបានចម្រើនកម្លាំងទាស់ប្រឆាំងនឹងវាសោះ។ យ៉ាងណាមិញ បងក៏មានអារម្មណ៍ថា ជាកូនព្រះម្នាក់ដែរ មិនថាមានអ្វីកើតឡើងក៏ដោយ ព្រះវិញ្ញាណរបស់ទ្រង់គង់នៅក្នុងចិត្តរបស់បងនឹងស្រែកឡើងថា «ឱអ័ប្បា ព្រះវរបិតាអើយ!»។ ប៉ុន្តែ បងពិតជាគ្មានអំណាចក្រោកឡើង ដើម្បីបានឯកសិទ្ធក្នុងនាមជាកូនព្រះបានឡើយ។

បងជឿថា សេចក្តីបរិសុទ្ធអាចនឹងកើតមានឡើងដោយសន្សឹមៗ ដោយតែងតែពឹងអាងលើការឧស្សាហ៍ប្រើមធ្យោបាយនៃព្រះគុណ។ បងមានបំណងចិត្ត និងត្រូវការសេចក្តីបរិសុទ្ធលើសអ្វីៗទាំងអស់ ប៉ុន្តែបើទោះបីជាបងខិតខំប្រឹងខ្លាំងប៉ុណ្ណាក្តី ក៏សេចក្តីបរិសុទ្ធតែងតែរត់គេចពីបងជានិច្ច ធ្វើឲ្យសេចក្តីសង្ឃឹមស្ទើរតែវិនាសបាត់អស់។ បងបានចាប់ផ្តើមគិតថា ប្រហែលជាព្រះជាម្ចាស់មិនព្រមឲ្យសេចក្តីបរិសុទ្ធមិនឲ្យចូលក្នុងជីវិតនេះ ដើម្បីធ្វើឲ្យស្ថានសួគ៌កាន់តែទាក់ទាញ។ បងបានដឹងថា បងមិនអាចទទួលសេចក្តីបរិសុទ្ធដោយខ្លួនឯងផ្ទាល់នោះឡើយ។ បងបានទទួលស្គាល់ចំពោះសេចក្តីកម្សោយរបស់បងចំពោះព្រះអម្ចាស់ ហើយបានសុំជំនួយ និងកម្លាំងពីទ្រង់។ ជួនកាល បងបានជឿថា ព្រះអង្គនឹងទ្រទ្រង់បង តែពេលយប់មកដល់ បងអាចត្រឹមតែសារភាពទៅព្រះជាម្ចាស់នូវអំពើ

បាប និងការបរាជ័យ ដែលបងបានធ្វើតែប៉ុណ្ណោះ។

បងមិនចង់ឲ្យប្អូនគិតថា នេះគ្រាន់តែជាបទពិសោធន៍ដ៏យូរនៅអំឡុងពេលជាច្រើនខែ និងគួរឲ្យនឿយណាយនោះឡើយ។ បងស្ទើរតែទៅរកភាពអស់សង្ឃឹម ដោយការបែបនេះកើតមានញឹកញាប់ខ្លាំងពេកនៅក្នុងចិត្តគំនិតរបស់បង។ ប៉ុន្តែ ព្រះគ្រីស្ទហាក់មានតម្លៃជាងពេលណាៗទាំងអស់ ទ្រង់ជាព្រះសង្គ្រោះមួយអង្គអាចសង្គ្រោះមនុស្សមានបាបដូចបងនេះ! ជួនកាល ក៏មានពេលវេលានៃសេចក្តីសុខសាន្ត ហើយនិងសេចក្តីអំណរនៅក្នុងព្រះអម្ចាស់ ប៉ុន្តែសេចក្តីទាំងនេះកំពុងរត់គេច ថែមទាំងមានការខ្វះខាតអំណាចយ៉ាងគួរឲ្យកត់សម្គាល់។ អូហ៍ តើព្រះអម្ចាស់មានសេចក្តីសប្បុរសយ៉ាងណាហ្ន៎ ដើម្បីបញ្ចប់ការលំបាកនេះ។

បងមានទំនុកចិត្តថា ព្រះគ្រីស្ទមានគ្រប់ទាំងអស់ដែលបងត្រូវការ ប៉ុន្តែបញ្ហាពិតនោះគឺនៅត្រង់ថា អាចចូលទៅកាន់ការទាំងអស់នោះដោយរបៀបណា។ ទ្រង់ពិតជាស្តុកស្តម្ភណាស់ ហើយបងវិញក្រខ្សត់ ទ្រង់ខ្លាំង ហើយបងខ្សោយ។ បងបានយល់ច្បាស់ថា ឫស និងគល់សម្បូរទៅដោយជីវជាតិ ប៉ុន្តែបងមិនបានដឹងអំពីរបៀបដឹកជញ្ជូនជីវជាតិនេះទៅកាន់មែកតូចៗរបស់បងទេ។ បន្តិចម្តងៗបងបានដឹងថា សេចក្តីជំនឿគឺជាការទាមទារតែមួយមុខគត់—គឺសេចក្តីជំនឿ ជាដៃដែលអាចចាប់យកភាពបរិបូរណ៍របស់ទ្រង់ ហើយយកមកធ្វើជារបស់បង។ យ៉ាងណាមិញ បងខ្វះសេចក្តីជំនឿ។

បងព្យាយាម ដើម្បីឲ្យមានជំនឿ ប៉ុន្តែសេចក្តីជំនឿនោះមិនបានមកទេ។ បងបានព្យាយាមអនុវត្តការទាំងនោះ ប៉ុន្តែគ្មានប្រយោជន៍ទេ។ កាលដែលបងកាន់តែបានឃើញព្រះគុណដ៏បរិបូរណ៍នៅក្នុងព្រះយេស៊ូវ និងសេចក្តីពោរពេញរបស់ព្រះសង្គ្រោះដ៏ថ្លៃថ្លារបស់យើង នោះកាន់តែធ្វើឲ្យកំហុសរបស់បង និងភាពគ្មានជំនួយរបស់បងកាន់តែបានកើនឡើង (កូឡុស ១:១៩; ២:៩)។ អំពើបាបពីមុនរបស់បងហាក់បីដូចជាតូចតាចទេ បើប្រៀបធៀបទៅនឹងអំពើបាបនៃការមិនជឿ ដែលបានបណ្តាលឲ្យគេបដិសេធនៅក្នុងការជឿព្រះបន្ទូលព្រះជាម្ចាស់ និងជាពិសេសដោយធ្វើបែបនោះ ហាក់ដូចជាហៅទ្រង់ថា ជាអ្នកកុហក។ បងមានអារម្មណ៍ថា ការមិនជឿ គឺជាអំពើបាបដែលគួរតែដាក់ទោសរបស់លោកីយ៍ ប៉ុន្តែបងបានបន្តធ្វើវាតាមទំនើងចិត្ត។ បងបានអធិស្ឋានសូមសេចក្តីជំនឿ ប៉ុន្តែសេចក្តីជំនឿនោះមិនបានមកសោះ។ តើបងត្រូវធ្វើបែបណា?

នៅពេលដែលបងកំពុងស្ថិតនៅក្នុងសេចក្តីទុក្ខដ៏សម្បើម សំណេរមួយជួរមកពីសំបុត្ររបស់សម្លាញ់ ម៉ាកខេតធី បានបើកភ្នែក និងព្រះវិញ្ញាណនៃព្រះបានបង្ហាញបងនូវសេចក្តីពិតរបស់ភាពរួមគ្នានៅក្នុងព្រះយេស៊ូវ ក្នុងរបៀបមួយបងមិនដែលយល់ពីមុនមក។ លោកគ្រូ ម៉ាកខាតធី ក៏បានប្រឈមនឹងអារម្មណ៍បរាជ័យដែរ ប៉ុន្តែបានរកឃើញសេចក្តីពិតមុនពេលដែលបងបានរកឃើញវា។ គាត់បានសរសេរថា៖ (ហើយខ្ញុំកំពុងរម្លឹកពីការចងចាំ) ថា៖

“តើយើងអាចធ្វើឲ្យសេចក្តីជំនឿរឹងមាំបានដោយរបៀបណា? មិនមែនព្យាយាមឲ្យមានសេចក្តីជំនឿនោះទេ ប៉ុន្តែដោយការពឹងអាងទៅលើព្រះមួយអង្គដ៏ស្មោះត្រង់។ នៅពេលដែលខ្ញុំអាន ខ្ញុំបានយល់ឃើញអ្វីគ្រប់យ៉ាង! “ទោះបើយើងមិនជឿក្តី ក៏ទ្រង់នៅតែស្មោះត្រង់ដដែល”។ ខ្ញុំបានសម្លឹងទៅព្រះយេស៊ូវ ហើយបានឃើញថា (អូហ៍ សេចក្តីអំណរបានហូរចុះមក នៅពេលខ្ញុំបានយល់ច្បាស់ពីសេចក្តីពិតនេះ!) នោះគឺជាអ្វីដែលទ្រង់បានសន្យា “យើងនឹងមិនចាកចេញពីឯង”»។

“មានសេចក្តីសម្រាកក្នុងទ្រង់» បងគិតថា “បងបានប្រឹងដោយឥតប្រយោជន៍ ដើម្បីស្វែងរកសេចក្តីសម្រាកក្នុងទ្រង់។ បងនឹងមិនព្យាយាមទៀតទេ។ តើទ្រង់មិនបានសន្យាថា ទ្រង់គង់នៅជាមួយយើង—ក៏មិនបោះបង់យើងចោលទេឬអី?» ហើយប្អូនសម្លាញ់ខ្ញុំអើយ! ទ្រង់នឹងមិនដែលចាកចេញពីប្អូន ក៏មិនបោះបង់ចោលប្អូនឡើយ។

នេះមិនមែនជាអ្វីគ្រប់យ៉ាង ដែលទ្រង់បានបង្ហាញបងទេ មិនបានសូម្បីពាក់កណ្តាលអ្វីដែលទ្រង់បានបង្ហាញផង។ នៅពេលដែលបងបានធ្វើការឆ្លុះបញ្ចាំងទៅលើឃ្លា ទំពាំងបាយជូរ និងខ្នែងរបស់វា ពន្លឺនៃព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បង្ហូរដោយផ្ទាល់ទៅក្នុងព្រលឹងរបស់បងដល់ម្ល៉េះហ្ន៎! តើកំហុសរបស់បងធំខ្លាំងណាស់មែនទេ នៅក្នុងការចង់ស្រូបយកជីវជាតិ និងសេចក្តីបរិបូរណ៍ពីព្រះអង្គ! បងដឹងថា ព្រះយេស៊ូវនឹងមិនដែលបោះបង់ចោលបងឡើយ ហើយបងក៏ជាផ្នែកមួយនៃព្រះកាយទ្រង់ រូបសាច់ និងឆ្អឹងទ្រង់។ ដើមទំពាំងបាយជូរ មិនគ្រាន់តែជាឫសនោះឡើយ ប៉ុន្តែវាជាអ្វីៗទាំងអស់—ជាឫស ដើម មែក មែកតូចៗ ស្លឹក ផ្កា និងផ្លែ។ ហើយព្រះយេស៊ូវមិនគ្រាន់តែជាដើមទំពាំងបាយជូរនោះទេ ទ្រង់ក៏ជាដី និងជាពន្លឺថ្ងៃ ជាខ្យល់ ជាទឹក ហើយជាអ្វីៗលើសជាងអ្វីដែលយើងធ្លាប់សុបិន ប្រាថ្នាចង់បាន ឬក៏ត្រូវការទៅទៀត។ អូហ៍ បងមានភាពអំណរក្នុងការរក

ឃើញសេចក្ដីពិតនេះ! បងពិតជាអធិស្ឋានថា សូមឲ្យការយល់ដឹងរបស់ប្អូនផងដែរនឹងបានបំភ្លឺឡើង ដែលប្អូននឹងស្គាល់ ហើយរីករាយនឹងភាពបរិបូរណ៍ដែលបានប្រទានមកដល់យើងរាល់គ្នាក្នុងអង្គព្រះគ្រីស្ទដោយឥតគិតថ្លៃ។

ប្អូនសម្លាញ់ចិត្តអើយ! វាជារឿងអស្ចារ្យណាស់ ដែលបានរួបរួមជាមួយព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញ និងបានតាំងឡើង ហើយដើម្បីក្លាយជាកម្មសិទ្ធព្រះយេស៊ូវយ៉ាងពិតប្រាកដ។ សូមពិចារណាមើលថា ឃ្លានេះមានន័យយ៉ាងដូចម្ដេច? ប្រសិនបើព្រះគ្រីស្ទជាសេដ្ឋី តើខ្ញុំអាចក្រទេ (២កូរិនថូស ៨:៩)? តើដៃស្ដាំរបស់ប្អូនអាចមានបានទេ ស្របពេលដែលដៃឆ្វេងរបស់ប្អូនក្រនោះ? ឬក៏ក្បាលរបស់ប្អូនបំពេញបានជីវជាតិគ្រប់គ្រាន់ទេ ស្របពេលដែលរាងកាយប្អូនស្រេកឃ្លាន? ជាមួយគ្នានេះដែរ សូមគិតអំពីអត្ថន័យនេះចំពោះការអធិស្ឋាន។ បេឡាករធនាគារនឹងមិនប្រាប់អតិថិជនទេថា “ដៃរបស់ប្អូនប៉ុណ្ណោះ ដែលជាអ្នកសរសេរមូលប្បទានប័ត្រ មិនមែនប្អូនទេ” ឬ “ខ្ញុំមិនអាចបង់លុយទៅដៃរបស់អ្នកបានទេ តែអាចបង់ឲ្យតែអ្នកម្នាក់ប៉ុណ្ណោះ”។ ស្រដៀងគ្នានេះដែរ សេចក្ដីអធិស្ឋានរបស់យើងមិនអាចទទួលការបដិសេធបានទេ បើសិនយើងទូលសូមនៅព្រះនាមព្រះយេស៊ូវ ដោយមិនអត្ថន័យគ្រាន់សម្រាប់ជាប្រយោជន៍របស់ព្រះយេស៊ូវនោះទេ ប៉ុន្តែពីព្រោះយើងជាកម្មសិទ្ធរបស់ទ្រង់ ក្នុងនាមជាផ្នែកមួយរបស់ទ្រង់។ ដរាបណា យើងបាននៅក្នុងរង្វង់នៃគុណសម្បត្តិរបស់ព្រះយេស៊ូវ ដែលធំទូលាយនោះ យើងនឹងមិនអីទេ។ ប្រសិនបើយើងទូលសូមអ្វីមួយ ដែលមិនស្របតាមព្រះគម្ពីរ និងបំណងព្រះហឫទ័យទ្រង់ នោះសូម្បីតែព្រះគ្រីស្ទ ក៏មិនធ្វើឲ្យវាសម្រេចឡើយ។ ប៉ុន្តែ ប្រសិនបើយើងទូលសូមអ្វីស្របតាមបំណងព្រះហឫទ័យទ្រង់ នោះយើងនឹងដឹងថា យើងបានអ្វីដែលយើងបានសូមពីទ្រង់ហើយដែរ (១យ៉ូហាន ៥:១៤, ១៥)។

ទិដ្ឋភាពដ៏ស្រទន់បំផុត គឺសេចក្ដីសម្រាក ដែលបានមកជាមួយនឹងការកំណត់អត្តសញ្ញាណជាមួយនឹងព្រះគ្រីស្ទ។ បងមិនបារម្ភចំពោះអ្វីគ្រប់យ៉ាងទៀតទេ ព្រោះបងដឹងថា ព្រះអង្គអាចសម្រេចបំណងព្រះហឫទ័យផងទ្រង់ ដែលនោះក៏ជាបំណងប្រាថ្នារបស់បងដែរ។ កន្លែងណាដែលទ្រង់ដាក់បង ឬដាក់បងដោយរបៀបណាមិនសំខាន់នោះទេ ព្រោះទ្រង់នឹងពិចារណាទៅលើរឿងនោះ មិនមែនជាបងឡើយ។ ព្រះអង្គនឹងប្រទានព្រះគុណសម្រាប់ស្ថានភាពងាយស្រួល និងល្អមសម្រាប់ស្ថានភាពលំបាកៗបំផុត។ ដូច

អ្នកបម្រើដែលពឹងផ្អែកលើបងចំពោះរឿងប្រាក់កាក់ មិនថាទិញរបស់របរថោក ឬថ្លៃនោះទេឡើយ បងក៏ពឹងផ្អែកលើព្រះជាម្ចាស់សម្រាប់ការដឹកនាំ ព្រះគុណ និងកម្លាំង ដោយមិនគិតពីស្ថានភាពអ្វីទាំងអស់។ គ្មានអ្វីត្រូវសង្ស័យពី សមត្ថភាពរបស់ទ្រង់នឹងយកជ័យជម្នះលើគ្រប់ឧបសគ្គ ហើយធនធានរបស់ទ្រង់ជារបស់បង ព្រោះទ្រង់ជារបស់បង ទ្រង់គង់នៅជាមួយបង ហើយទ្រង់មានព្រះជន្មនៅក្នុងបង។

ដោយសារព្រះគ្រីស្ទមានព្រះជន្មគង់នៅក្នុងចិត្តបងតាមរយៈសេចក្ដីជំនឿ នោះបងពិតជារីករាយណាស់! បងប្រាថ្នាថា បងអាចប្រាប់ប្អូនអំពីការនោះផ្ទាល់មាត់ ជាជាងការសរសេរចុះបែបនេះ។ បងមិនបានប្រសើរជាងបងពីមុនទេ។ នៅក្នុងន័យមួយដែលបងមិនចង់ក្លាយជា ហើយបងក៏មិនកំពុងព្យាយាមធ្វើដែរ។ ប៉ុន្តែ បងបានស្លាប់ និងបានកប់ជាមួយផងព្រះគ្រីស្ទ—មែនហើយ ហើយក៏បានរស់ឡើងវិញជាមួយទ្រង់ដែរ! ឥឡូវនេះ ព្រះគ្រីស្ទទ្រទ្រង់ការរស់នៅក្នុងបងវិញ ហើយដែលបងរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ ដែលទ្រង់ស្រឡាញ់បង ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសបងដែរ (កាឡាទី ២:២០)។

បងត្រូវតែបញ្ចប់វាត្រឹមហ្នឹងសិនហើយពេលនេះ។ បងមិនបាននិយាយអស់អ្វីគ្រប់យ៉ាង ដែលបងចង់និយាយឡើយ ឬក៏មិនបាននិយាយអ្វីនៅក្នុងរបៀបដែលបងចង់និយាយដែរ ប៉ុន្តែបងមិនមានពេលច្រើនទៀត។ សូមព្រះជាម្ចាស់ជួយឲ្យប្អូនយល់នូវសេចក្ដីពិតដ៏អស្ចារ្យទាំងនេះ។ សូមកុំនៅបន្តនិយាយថាៈ “តើអ្នកណានឹងឡើងទៅឯស្ថានសួគ៌” គឺដើម្បីនឹងនាំព្រះគ្រីស្ទចុះមក (រ៉ូម ១០:៦)។ សូមកុំគិតថា ទ្រង់គង់នៅឆ្ងាយ ព្រោះព្រះជាម្ចាស់បានភ្ជាប់យើងជាមួយទ្រង់ ជាអវយវៈនៃព្រះកាយរបស់ផងទ្រង់ (១កូរិនថូស ៦:១៧)។ ទន្ទឹមគ្នានេះដែរ យើងមិនគួរគិតថា សេចក្ដីពិតទាំងនេះ សម្រាប់តែអ្នកដែលបានជ្រើសតាំងមួយចំនួននោះឡើយ។ សេចក្ដីពិតទាំងនេះ គឺសម្រាប់អ្នកជឿគ្រប់គ្នា ហើយអ្នកណាដែលមើលរំលងសេចក្ដីពិតនេះគឺគេមិនគោរពចំពោះព្រះអម្ចាស់របស់យើង។ ព្រះគ្រីស្ទគឺជាអំណាចតែមួយគត់សម្រាប់ការរំដោះយើងចេញពីអំពើបាប ឬសម្រាប់ការបម្រើរបស់យើង។

ហើយគ្រប់អ្វីៗទាំងអស់គឺសាមញ្ញ ហើយជាក់ស្ដែងណាស់ ដូចជាអ្នកម្ដាយដែលរវល់ម្នាក់ដែលបានរកឃើញ នៅពេលដែលគាត់បានរកឃើញសេចក្ដីសុខសាន្តនេះ តាមរយៈ

សេចក្ដីជំនឿ។

មានគេបានសួរគាត់ជាច្រើនឆ្នាំក្រោយមកថា៖ «លោកគ្រូ ថេល័រ តើលោកគ្រូដឹងទេថា លោកគ្រូតែងតែនៅជាប់នឹងព្រះគ្រីស្ទឬទេ?»។

គាត់បានឆ្លើយថា៖ «ពេលខ្ញុំកំពុងដេកពីកាលយប់មិញ» «តើខ្ញុំបានចាកចេញពីផ្ទះរបស់ខ្ញុំ ដោយព្រោះតែខ្ញុំមិនដឹងអំពីការនោះមែនទេ? យើងមិនគួរមានអារម្មណ៍ថា យើងមិននៅជាប់ជាមួយនឹងព្រះគ្រីស្ទរៀងជាទេ»។

ខ្ញុំប្រែប្រួល តែទ្រង់មិនដែលប្រែប្រួលសោះ ព្រះគ្រីស្ទមិនបានសុគតរហូតទេ។ សេចក្ដីពិតជារបស់ផងទ្រង់ មិនមែនសេចក្ដីពិតរបស់ផងខ្ញុំ ដែលជាកន្លែងខ្ញុំរកឃើញសេចក្ដីសម្រាក សេចក្ដីស្រឡាញ់ជារបស់ផងទ្រង់ មិនមែនសេចក្ដីស្រឡាញ់របស់ផងខ្ញុំ បានចងភ្ជាប់យើងជាមួយគ្នា។

ជំពូកទី១៥

# មិនស្រេកទៀតទេ

*ខ្ញុំមិនអំពល់នឹងសួរថា៖ បើដូច្នេះ តើខ្ញុំត្រូវគិតដូចម្ដេចវិញ?*
*ខ្ញុំដឹងថានឹងមានទឹកភ្នែក ការភ័យខ្លាច និងទុក្ខសោក*
*បន្ទាប់មក ព្រះសង្គ្រោះដែលពេញដោយសេចក្ដីស្រឡាញ់នឹងយាងមកកាន់តែជិត*
*យើងខ្ញុំ រួចមានព្រះបន្ទូលថា៖ «យើងនឹងចាត់ចែងសម្រាប់ថ្ងៃស្អែក»។*

លោកគ្រូ ថេល័រ បន្តការមានបទពិសោធន៍ជាប់នឹងព្រះគ្រីស្ទរាប់ខែ និងរាប់ឆ្នាំនោះតទៅ។ សម័យកាលដែលចិត្តមិនស្កប់មែនបានត្រឡប់មកវិញឡើយ ហើយព្រលឹងដែលស្រេកឃ្លាននឹងមិនដែលកាត់ចេញពីភាពពេញលេញរបស់ព្រះគ្រីស្ទទៀតឡើយ។ បើទោះបីជា ការល្បងលកាន់តែជ្រាលជ្រៅ ហើយខ្លាំងជាងពីមុនក្ដី ក៏សេចក្ដីអំណរបានហូរមកយ៉ាងពេញបរិបូរណ៍មកពីព្រះវត្តមានព្រះជាម្ចាស់។ លោកគ្រូ ហ័ដសិន ថេល័រ បានរកឃើញអាថ៌កំបាំងទៅកាន់សេចក្ដីសុខសាន្តផ្នែកខាងក្នុងចិត្តរបស់គាត់។ តាមរយៈបទពិសោធន៍នេះ គាត់មានការយល់ដឹងកាន់តែជ្រាលជ្រៅឡើងចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ហើយអ្វីៗគ្រប់យ៉ាងដែលទ្រង់បានប្រទានមកដល់ពួកយើង មកអមជាមួយនឹងការចុះចូល—ជាការថ្វាយខ្លួនគាត់ទាំងស្រុងចំពោះព្រះជាម្ចាស់។

ខ្ញុំលែងមានការព្រួយបារម្ភអំពីអ្វីទាំងអស់ ពីព្រោះខ្ញុំដឹងថា ព្រះអង្គអាចបំពេញបំណងព្រះហឫទ័យទ្រង់បាន ហើយបំណងព្រះហឫទ័យទ្រង់ ក៏ជាបំណងចិត្តរបស់ខ្ញុំដែរ។ វាមិនសំខាន់ទេថា ព្រះអង្គដាក់ខ្ញុំនៅកន្លែងណា ឬដោយរបៀបណានោះឡើយ។ ព្រះអង្គជាអង្គដែលគិតគូរការនេះជាជាងខ្ញុំ មិនថាជាស្ថានភាពនោះស្រួល ឬលំបាកក្ដី ព្រះអង្គ

មុខជាប្រទានព្រះគុណទ្រង់មកជាមិនខាន។ ដូចជាអ្នកបម្រើម្នាក់មិនខ្វល់ថា ខ្ញុំប្រើគាត់ឲ្យទៅទិញរបស់របរថោក ឬទំនិញថ្លៃៗនោះឡើយ។ នៅក្នុងករណីទាំងពីរនេះអ្នកបម្រើរំពឹងថា ទទួលប្រាក់ពីចៅហ្វាយនាយ ហើយយកទំនិញដែលគាត់បានទិញមកវិញ។ ស្រដៀងគ្នានេះដែរ ប្រសិនបើព្រះជាម្ចាស់ដាក់ខ្ញុំនៅក្នុងការទ័លប្រាជ្ញាយ៉ាងសម្បើមណាមួយ នោះព្រះអង្គប្រាកដជាប្រទានការណែនាំដ៏ច្រើននៅក្នុងស្ថានភាពលំបាកៗ ព្រមទាំងប្រទានព្រះគុណដ៏ច្រើន ហើយនៅក្នុងកាលដែលមានពេញដោយភាពតានតឹង និងសេចក្តីល្បួងល នោះព្រះអង្គនឹងប្រទានកម្លាំងគ្រប់ល្មមសម្រាប់យើងជាមិនខាន។ ខ្ញុំគ្មានការព្រួយបារម្ភថា ធនធានរបស់ព្រះអង្គនឹងខ្វះខាតឡើយ! ហើយខ្ញុំអាចពឹងផ្អែកទៅលើធនធានរបស់ទ្រង់បាន ដោយសារតែព្រះអម្ចាស់នៃខ្ញុំ គង់នៅជាមួយខ្ញុំហើយមានព្រះជន្មរស់នៅក្នុងខ្ញុំ។

គាត់បានស្គាល់ថា តើវាមានន័យយ៉ាងណាក្នុងការចុះចូលនឹងព្រះគ្រីស្ទជាយូរមកហើយ ប៉ុន្តែវាជាកម្រិតថ្មីមួយទៀតនៃការថ្វាយខ្លួនគាត់ផ្ទាល់ទាំងស្រុងដោយអំណរ និងដោយគ្មានដែនកំណត់ ហើយថ្វាយអ្វីៗគ្រប់យ៉ាងចំពោះព្រះជាម្ចាស់ ប៉ុន្តែសេចក្តីទាំងនេះមានលើសពីនោះទៅទៀត។ កិច្ចការនេះមិនមែនជាការដែលមនុស្សសុខចិត្តលះបង់របស់ជាក់លាក់ណាមួយ នៅពេលព្រះជាម្ចាស់តម្រូវឲ្យគេធ្វើដូច្នោះ ប៉ុន្តែវាជាការទទួលនិងបំពេញបំណងព្រះហឫទ័យព្រះជាម្ចាស់ដោយស្មោះត្រង់ សេចក្តីស្រឡាញ់ និងអំណរទាំងនៅក្នុងរឿងសំខាន់ និងរឿងតូចតាច ដោយជឿថា មាគ៌ារបស់ព្រះជាម្ចាស់តែងតែល្អបំផុតសម្រាប់រាស្ត្រទ្រង់។ ការនេះបានផ្លាស់ប្តូរឧបសគ្គឲ្យទៅជាឱកាសមួយសម្រាប់ព្រះគុណព្រះ ដើម្បីយកឈ្នះលើការលំបាកដោយប្រែក្លាយ "ជ្រលងនៃសេចក្តីទុក្ខសោក" ឲ្យទៅជា "ប្រភពទឹក" ដែលជាខ្សែទឹកនៃព្រះពរបន្តហូរ។

សូម្បីតែមុនពេលការសម្លាប់រង្គាលនៅទៀនស៊ីន (Tientsin) លោក និងលោកស្រីថេល័រ បានប្រឈមមុខនឹងការកើតទុក្ខយ៉ាងខ្លាំង។ ពួកគាត់ត្រូវបែកផ្លូវគ្នាជាមួយកូនៗពួកគាត់ ពីព្រោះគ្មានសាលារៀន ឬមជ្ឈមណ្ឌលសុខភាពសមរម្យសម្រាប់រដូវក្តៅនៅប្រទេសចិនទេពេលនោះ។ អាកាសធាតុ ហើយនិងរបៀបរស់នៅរបស់ពួកគាត់កំពុងតែប៉ះពាល់ដល់សុខភាពកូនៗពួកគាត់យ៉ាងខ្លាំង។ ពួកគាត់មានកូនម្នាក់បានស្លាប់នៅប្រទេសចិនរួចហើយ ដែលធ្វើឲ្យពួកគាត់មិនអាចបំភ្លេចទឹកដីនេះបានឡើយ។ ពួកគាត់បានទទួល

ការស្នើដោយដឹងគុណយ៉ាងខ្លាំងពីកញ្ញា អ៊ីមមីលី ប្លេតឆ្លីយ៍ (Emily Blatchley) ជាលេខា និងជាមិត្តសម្លាញ់ដ៏ស្មោះត្រង់របស់ពួកគាត់ចំពោះការយកកូនប្រុសពីរនាក់ និងកូនស្រីម្នាក់របស់ពួកគាត់ទៅប្រទេសអង់គ្លេសវិញ ហើយមើលថែទាំពួកគេ។

នេះមានន័យថា ពួកគាត់ត្រូវបែកផ្លូវគ្នាត្រូវទៅឆ្ងាយហើយ ហើយភាគខាងកើត និងភាគខាងលិចពិតជានៅឆ្ងាយពីគ្នាខ្លាំងណាស់នៅពេលនោះ។ យ៉ាងណាមិញ សូម្បីតែមុនពេលក្រុមអ្នកធ្វើដំណើរវ័យក្មេងអាចទៅដល់ឆ្នេរសមុទ្របាន ក៏ពួកគាត់មានការលាគ្នាកាន់តែយូរមួយដែរ។ ក្មេងប្រុសដែលមានអាយុក្មេងជាងគេ មានអាយុត្រឹមតែប្រាំឆ្នាំប៉ុណ្ណោះ គាត់មានសុខភាពទន់ខ្សោយជាងគេ។ ឪពុកម្តាយរបស់គាត់ មានការព្រួយបារម្ភដែលបានសង្កេតឃើញថា ភាពតានតឹងនៃការបែកគ្នាមួយនេះកំពុងតែធ្វើឲ្យបញ្ហាសុខភាពដែលមានស្រាប់របស់កូននេះកាន់តែធ្ងន់ធ្ងរឡើងៗ។ ពួកគាត់បាននៅមើលគាត់ពេញមួយយប់នៅលើទូក ដែលកំពុងតែធ្វើដំណើរចុះទៅព្រែកស្រុកយ៉ាងចូវ ប៉ុន្តែលុះដល់ជិតភ្លឺឡើង ក្មេងប្រុសនោះក៏បានគេងលង់លក់រហូតទៅ។ នៅលើទឹកទន្លេក្រាស់នៃទន្លេយ៉ាងជី ក្មេងប្រុសតូចបានលាចាកលោកដោយសុខសាន្ត និងដោយគ្មានការភ័យខ្លាចទៅកាន់កន្លែងដ៏ប្រសើរមួយទៀតហើយ។

នៅចំពោះមុខព្យុះដ៏កំណាចនេះ ឪពុកម្តាយរបស់ក្មេងប្រុសបានធ្វើដំណើរឆ្លងផុតទន្លេដែលមានទទឹងប្រហែលជាងបីគីឡូម៉ែត្រ ដើម្បីទៅបញ្ចុះសពកូនប្រុសតូចសំណព្វចិត្តរបស់ពួកគាត់នៅស្រុកជីនគាំង (បច្ចុប្បន្ន សិនជាំង) មុនពេលបន្តដំណើរជាមួយអ្នកផ្សេងទៀតទៅកាន់ក្រុងសៀងហៃ។ បន្ទាប់ពី បញ្ជូនអ្នកគ្រប់គ្នាទៅឡើងលើកប៉ាល់បារាំងដែលគ្រោងចេញដំណើរនៅពេលថ្ងៃរះរួចហើយ លោកគ្រូ ហ៊ុដសិន បានសរសេរសំបុត្រទៅលោក ប៊ើកហ្គ័រ ថា៖

“ខ្ញុំបានជួបកូនខ្ញុំដែលភ្ញាក់ពីគេងជាលើកចុងក្រោយនៅប្រទេសចិន នៅពេលដែលខ្ញុំកំពុងត្រឡប់ទៅរកប្រពន្ធរបស់ខ្ញុំនៅលើកប៉ាល់នៅឡើយ។ យើងគ្មានការបារម្ភអំពីកូនតូចៗទាំងពីរនាក់របស់យើងឡើយ ពួកគេបានសម្រាកនៅក្នុងព្រះហស្តព្រះយេស៊ូវហើយ។ ហើយពេលនេះ បងប្រុសអើយ! បើទោះបីជាខ្ញុំយំមិនឈប់ក៏ដោយ ក៏ខ្ញុំអរព្រះគុណព្រះជាម្ចាស់ដែលអនុញ្ញាតឲ្យមនុស្សដែលមិនស័ក្តិសមដូចជារូបខ្ញុំបានចូលរួមចំណែកនៅក្នុងកិច្ចការដ៏អស្ចារ្យនេះ។ ខ្ញុំគ្មានការស្តាយក្រោយទេ ចំពោះការចូលរួមក្នុង

កិច្ចការនេះ។ កិច្ចការនេះ ជាកម្មសិទ្ធិរបស់ផងទ្រង់ មិនមែនជារបស់ផងយើងឡើយ ប៉ុន្តែវានៅតែជារបស់ផងយើង មិនមែនដោយសារតែយើងបានចូលរួមនោះឡើយ ប៉ុន្តែពីព្រោះយើងជាកម្មសិទ្ធិរបស់ផងទ្រង់ ហើយក៏បានរួមជាមួយព្រះមួយអង្គដែលជាម្ចាស់នៃកិច្ចការនេះ»។

ពួកគេអាចទ្រាំទ្របានដោយសេចក្តីពិតនេះឯង។ ប្រទេសចិនមិនដែលធ្លាប់ជួបប្រទះនឹងរដូវក្តៅដែលពេញដោយរឿងក្តៅក្រហាយច្រើនជាងរដូវក្តៅនេះឡើយ៖ បញ្ហាទាំងនេះបានចាប់ផ្តើមនៅឆ្នាំ១៨៧០។ ប៉ុន្តែ បើទោះបីជាត្រូវជួបនឹងរឿងគ្រប់យ៉ាងក្តី ហើយចិត្តរបស់ពួកគាត់ចង់ជួបកូនរបស់ពួកគាត់រកអ្វីថ្លែងមិនបានក៏ដោយ ក៏ពួកគាត់មានអារម្មណ៍ថា បានសម្រាក និងអរសប្បាយក្នុងព្រះជាម្ចាស់ជាងពេលណាៗទាំងអស់ទៅទៀត។

ខ្ញុំមិនអាចក្រៅពីជាកោតសរសើរ និងស្ញប់ស្ញែងយ៉ាងខ្លាំងចំពោះព្រះគុណដែលបានទ្រទ្រង់ និងបានកម្សាន្តចិត្តដល់អ្នកម្តាយៗដ៏ជាទីស្រឡាញ់បំផុតនោះឡើយ។ ក្រោយមក លោកគ្រូ ហ៍ដសិន បានរម្លឹកថា អាថ៌កំបាំងនោះគឺព្រះយេស៊ូវបានចម្អែតដួងចិត្ត និងព្រលឹងដ៏ស្រេកឃ្លានរបស់គាត់យ៉ាងជ្រាលជ្រៅ។

លោកស្រី ថេល័រ ក៏បានរីកចម្រើនក្នុងសេចក្តីជំនឿនារដូវក្តៅនោះដែរ។ បញ្ហាទាំងនោះហាក់បីដូចជាបានបង្កើនជំនឿដល់គាត់ ដោយសារតែព្យុះនៃបញ្ហាដែលនៅជុំវិញពួកគាត់បានកើតឡើង។ បន្ទាប់ពីបែកគ្នាពីកូនៗ នោះជំងឺបានរីករាលដាលក្នុងក្រុមបេសកជននៃអង្គការបេសកកម្មចិនដីគោក ហើយមុនពេលដែលពួកគាត់បានមកដល់ស្រុកជីនគាំង (បច្ចុប្បន្ន សិនជាំង) ពួកគាត់បានដឹងថា លោកស្រី ជូដដ៍ នៅទីនោះ ហើយឈឺជិតស្លាប់។ លោកគ្រូ ហ៍ដសិន មិនអាចចាកចេញពីទូកទេ ដោយសារតែគាត់មានអ្នកជំងឺផ្សេងទៀតដែលគាត់មើលថែ ប៉ុន្តែគាត់បានយល់ព្រមឲ្យលោកស្រី ថេល័រ ទៅតែម្នាក់ឯង ដើម្បីផ្តល់ជាជំនួយអ្វីក៏ដោយដែលគាត់អាចជួយបាន។

បន្ទាប់ពីមើលថែអ្នកដទៃអស់ជាច្រើនថ្ងៃច្រើនយប់មក នោះលោកគ្រូ ជូដដ៍ ស្ទើរតែអស់កម្លាំងរលីង។ នៅពេលដែលគាត់បានឮសម្លេងចេញពីទីផ្លា ជាសញ្ញានៃការមកដល់ដោយនឹកស្មានមិនដល់មួយ។ គាត់ឆ្ងល់ថា អ្នកណានឹងមកដល់យប់ថ្មើរនេះ ហើយពួកគេបានធ្វើដំណើរទៅណាមកណា។ គ្មានកប៉ាល់ណាឡើងមកទន្លេខាងលើទេ ហើយទូកប្រជាជនក្នុងស្រុកក៏មិនបានធ្វើដំណើរនៅពេលយប់ដែរ។ ក្រៅពីនេះ មានម្នាក់បានរុញ

រទេះរុញមួយចូលទីធ្លា។ មានស្ត្រីម្នាក់បានធ្វើដំណើរពេញមួយថ្ងៃនៅលើរទេះដែលគ្មានរ៉ឺស័រទៅដល់ទីនោះដោយម្នាក់ឯង ហើយរំពេចនោះលោក ជូដដ៍ ក៏បានឃើញមុខមនុស្សដែលគាត់សង្ឃឹមចង់ឃើញខ្លាំងបំផុត។

បើទោះបីលោកស្រី ថេល័រ កំពុងតែឈឺ និងអស់កម្លាំងពីការធ្វើដំណើរដ៏វែងឆ្ងាយក៏ដោយ ក៏គាត់បានទទូចឲ្យខ្ញុំទៅសម្រាន្ត ហើយគាត់នឹងមើលថែរក្សាប្រពន្ធខ្ញុំដោយខ្លួនឯង។ គាត់បានបដិសេធមិនព្រមចូលសម្រាកឡើយ។

គាត់បានពោលថាៈ «អត់ទេ! បងប្រុសបានធ្វើការច្រើនល្មមហើយ ដូច្នេះកុំនៅដល់យប់ជ្រៅទៀត។ សូមបងប្រុសទៅសម្រាកចុះ ពីព្រោះខ្ញុំនឹងនៅជាមួយប្រពន្ធបង មិនថាបងប្រុសទៅសម្រាកឬមួយក៏អត់ទេ»។

«ខ្ញុំមិនអាចបំភ្លេចបាននោះទេពីភាពម៉ឺងម៉ាត់ និងភាពគួរឲ្យស្រឡាញ់ កាលគាត់បាននិយាយនោះឡើយ។ ទឹកមុខរបស់គាត់ពេញដោយភាពស្រស់បស់ពីព្រះមួយអង្គដែលគាត់បានរកឃើញសេចក្តីអំណរ និងកម្លាំង»។

មានតែការអធិស្ឋានទេ ដែលបានជួយអ្នកជម្ងឺឱ្យជាសះស្បើយ ដូចដែលការអធិស្ឋាននោះបានជួយស្តារស្ថានភាពនៅអំឡុងពេលដ៏លំបាកៗនារដូវក្តៅនោះ។

លោកគ្រូ ថេល័រ បានសរសេរសំបុត្រទៅកាន់មិត្តស្និទ្ធស្នាលរួមអង្គការបេសកកម្មចិនដីគោករបស់គាត់ ដែលពួកគេបានប្រឈមមុខនឹងការល្បងលពីមុន តែពេលនេះការរំជើបរំជួលដ៏ធំធេងកំពុងតែបានអង្រួនគ្រឹះមូលដ្ឋាននៃសមាគមក្នុងស្រុកស្ទើរតែគ្រប់ទីកន្លែងនៅពេលតែមួយ។ ខ្ញុំពិតជាពិបាកក្នុងការពណ៌នាថា តើជនជាតិចិនមានការតក់ស្លុត និងរន្ធត់ចិត្តប៉ុណ្ណា នៅពេលដែលពួកគេគិតដំបូងថា អ្នកចេះមន្តអាគមក្នុងស្រុកបានធ្វើមន្តអាគមដាក់លើពួកគេ ឬក៏ពណ៌នាថាពួកគេមានកំហឹង និងការខឹងសម្បារនៅពេលពួកគេបានឮថា សត្រូវដ៏សម្ងាត់ទាំងនេះកំពុងធ្វើការឲ្យជនជាតិបរទេស។ នៅស្រុកធានស៊ិន មនុស្សគ្រប់គ្នាបានដឹងថា ប្រជាជនបានបះបោរ ហើយបានសម្លាប់ទៅលើបងប្អូនស្រីដែលធ្វើការសប្បុរសធម៌ (Sisters of Charity) សម្តេចសង្ឃ និងសូម្បីតែអ្នកធ្វើការនៅកុងសូលបារាំងយ៉ាងព្រៃផ្សៃ។ ដូច្នេះ តើមានអ្វីទៅដែលបានរារាំងពួកគេនៅក្នុងទីកន្លែងដែលដាច់ស្រយាលនេះ ជាកន្លែងដែលបងប្អូនយើងនៅដាច់ឆ្ងាយពីការការពារ? ចម្លើយគឺៈ មានតែព្រះហស្តដ៏មានព្រះចេស្តារបស់ផងព្រះជាម្ចាស់ទេ ដែល

បានឆ្លើយតបទៅនឹងការអធិស្ឋានដែលប្រួបប្រួមគ្នា និងឥតឈប់ឈរនៅក្នុងព្រះនាមដ៏មានអំណាចរបស់ផងព្រះយេស៊ូវ។ ហើយអំណាចដូចគ្នានេះ បានអនុញ្ញាតឲ្យយើងបានស្ងប់ចិត្តនៅក្នុងព្រះយេស៊ូវ ដោយព្រះវត្តមានទ្រង់ សេចក្តីស្រឡាញ់ទ្រង់ និងការយកព្រះទ័យទុកដាក់របស់ផងទ្រង់។

ការអានអំពីបទពិសោធន៍នេះងាយស្រួលទេ ប៉ុន្តែមានតែអស់អ្នកដែលធ្លាប់ជួបពេលវេលាដ៏គ្រោះថ្នាក់បែបនោះទេទើបពិតជាអាចយល់ច្បាស់ថាមានភាពតានតឹងប៉ុណ្ណា។ កម្តៅនៅរដូវក្តៅនោះក្តៅខ្លាំង ហើយមានរយៈពេលយូរផង ដែលបានធ្វើឲ្យប្រជាជនក្នុងស្រុកកាន់តែមានភាពចលាចល។ យើងត្រូវជម្លៀសស្ត្រីៗ និងក្មេងៗទៅកាន់ឆ្នេរ ហើយនៅពេលមួយដែលវាហាក់ដូចជាអាជ្ញាធរចិននឹងត្រូវបង្ខំឲ្យពួកគេចាកចេញពីតំបន់នោះ។ កិច្ចការនេះទាមទារឲ្យមានការទំនាក់ទំនងច្រើនជាមួយនឹងមន្ត្រីចិន និងមន្ត្រីបរទេស ព្រមទាំងតាមសំបុត្រចំពោះអ្នកធ្វើការកំពុងមានគ្រោះថ្នាក់បំផុត។ ស្ថានភាពនៅផ្ទះអង្គការបេសកកម្មចិនដីគោកនៅជីនគាំង (បច្ចុប្បន្នសិនជាំង) បានជំរុញទៅដល់ដែនកំណត់ ហើយភាពតានតឹងពិតជាខ្លាំងដែលគ្មានសល់កន្លែងទំនេរឡើយ។

សំណេររបស់លោកគ្រូ ហ័ដសិន នៅខែមិថុនាសំដៅទៅលើកុប្បកម្មនៅយ៉ាងចូវថាពេលវេលាចាស់ៗហាក់បីដូចជាត្រឡប់មកវិញហើយ ប៉ុន្តែពេលនេះក្តីបារម្ភរបស់យើងមិនបានកំណត់ត្រឹមតែមួយកន្លែងនោះទេ។

នៅចំណុចនេះ វាហាក់បីដូចជាពួកគេនឹងត្រូវបោះបង់ចោលស្ថានីយទាំងអស់នៅតាមទន្លេ។ លោក និងលោកស្រី ថេល័រ បានកំពុងរស់នៅជីនគាំង (បច្ចុប្បន្នសិនជាំង) ដែលស្ថិតនៅកណ្តាលប្រទេសជាងស្រុកយ៉ាងចូវ ដោយលោកសម្រាន្តនៅលើឥដ្ឋក្នុងបន្ទប់ទទួលភ្ញៀវ ឬផ្លូវដើរក្នុងផ្ទះ ដើម្បីលោកស្រី ថេល័រ អាចប្រើបន្ទប់គេងរួមជាមួយស្ត្រីៗផ្សេងទៀត។

បន្ទាប់ពីការសម្លាប់រង្គាលនៅធានសិន គាត់បានបន្តដោយកត់ត្រាថា មានការលំបាកមួយហើយមួយទៀតតាមមកយ៉ាងឆាប់រហ័ស ប៉ុន្តែនោះគឺជាព្រះជាម្ចាស់ជាអ្នកគ្រប់គ្រង វាមិនមែនកើតឡើងដោយចៃដន្យនោះទេ។ នៅណាយីង ភាពរឹកររពិតជាអាក្រក់ខ្លាំងណាស់។ នៅទីនេះខ្ញុំសង្ឃឹមថា ពាក្យចចាមអារ៉ាមហាក់កំពុងតែស្ងាត់ទៅវិញហើយចុះ ប៉ុន្តែនៅស្រុកយ៉ាងចូវ ពាក្យចចាមអារ៉ាមនៅតែអាក្រក់ខ្លាំងនៅឡើយ។ សូមជួយ

អធិស្ឋានសម្រាប់យើងផង។ ខ្ញុំមានអារម្មណ៍ថាបានស្ងប់នៅក្នុងចិត្ត ប៉ុន្តែគំនិតរបស់ខ្ញុំតានតឹងជាពេកពន់ណាស់ ដោយការលំបាកដែលមិនចេះចប់មិនចេះហើយនេះ។

ទោះជាយ៉ាងណាក៏ដោយ ក៏គ្រាលំបាកទាំងនេះមិនបានរារាំងទិដ្ឋភាពខាងព្រលឹងវិញ្ញាណសម្រាប់លោក និងលោកស្រីថេល័រ ហើយនិងកិច្ចការដែលពួកគាត់បានមានចំណែកនោះដែរ។ នៅខែមិថុនា ជាអំឡុងពេលដ៏ក្ដៅបំផុតលោកស្រី ថេល័រ បានសរសេរទៅកញ្ញា ប្លេតឆ្លេយ៍ ថា៖

«យើងបើកថ្នាក់រៀនរាល់ថ្ងៃអាទិត្យ និងថ្នាក់រៀនពេលល្ងាចមួយអាទិត្យពីរបីថ្ងៃ ដើម្បីចូលរួមជាមួយនឹងគ្រីស្ទបរិស័ទជនជាតិចិនដែលចេះអានដើម្បីសិក្សាព្រះគម្ពីរបន្ថែម ហើយដើម្បីនឹងបង្រៀនអស់អ្នកដែលមិនចេះអានអក្សរ។ការសិក្សានេះក៏បានធ្វើជាគំរូមួយដល់សមាជិកក្មេងៗរបស់អង្គការបេសកកម្មចិនដីគោក ដោយបង្ហាញពួកគេថា បើទោះបីជាយើងមានកាលវិភាគមមាញឹកក៏ដោយ ក៏យើងផ្ដល់អាទិភាពទៅលើការជួយបងប្អូនគ្រីស្ទបរិស័ទ ហើយនិងអ្នកដែលនៅជុំវិញខ្លួនយើងឲ្យរៀនអាន និងយល់អំពីព្រះគម្ពីរដោយខ្លួនពួកគេផ្ទាល់»។

បើទោះបីជាវាទាមទារឲ្យចំណាយពេលច្រើនក្ដី លោកគ្រូ ហ័ដសិន បានរកឃើញថាបទពិសោធន៍ខាងវិញ្ញាណរបស់គាត់កាន់តែចម្រើនឡើងច្រើនជាងការបង្អាក់វិញ។ សៀវភៅកម្រងរបស់គាត់បានបង្ហាញអំពីព្រះពរផ្សេងៗ ដែលបានជួយឲ្យគាត់ឆ្លងកាត់ឧបសគ្គដោយជោគជ័យ ជាជាងផ្ដោតតែទៅលើឧបសគ្គទាំងនោះផ្ទាល់។ ឧទាហរណ៍៖ នៅពាក់កណ្ដាលខែមិថុនា គាត់បានសរសេរសំបុត្រទៅកញ្ញា ឌីសហ្គ្រេស (Desgraz) ដោយលើកឡើងយ៉ាងលម្អិតអំពីក្ដីបារម្ភរបស់នាងអំពីកុប្បកម្មនៅស្រុកយ៉ាងចូវ។

«ហើយពេលនេះ ខ្ញុំបានរកឃើញខគម្ពីរដែលត្រូវនឹងប្អូនស្រីយ៉ាងល្អឥតខ្ចោះ ហើយវាពិតជាព្រះពរដល់ព្រលឹងរបស់បងណាស់!  កណ្ឌគម្ពីរ យ៉ូហាន ៧:៣៧-៣៩ "បើអ្នកណាស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ" តើអ្នកណាមិនចេះស្រេក? តើអ្នកណាមិនធ្លាប់ស្រេកក្នុងគំនិត ចិត្ត ឬក៏រូបកាយរបស់ពួកគេ? វាមិនសំខាន់ទេថា ធ្លាប់ស្រេកបែបណា ឬសូម្បីតែធ្លាប់មានសេចក្ដីស្រេកទាំងអស់ក្ដី។ នៅពេលអ្នក "ចូរមកឯព្រះយេស៊ូវ" តើអ្នកនៅតែស្រេកទៀតឬ? ប្រាកដជាមិនស្រេកទៀតទេ! ដូច្នេះ "ចូរឲ្យអ្នកនោះមកឯព្រះអង្គ ហើយផឹកចុះ"» (យ៉ូហាន ៧:៣៧)។

“តើព្រះយេស៊ូវអាចបំពេញតម្រូវការខ្ញុំបានទេ? ប្រាកដណាស់ ទ្រង់អាចបំពេញតម្រូវការ ហើយលើសពីនេះទៅទៀត។ មិនថាផ្លូវ ឬការបម្រើខ្ញុំលំបាកប៉ុណ្ណាទេ មិនថាការបាត់បង់របស់ខ្ញុំសោកសៅយ៉ាងណាទេ ឬក៏មនុស្សដែលខ្ញុំស្រឡាញ់នៅឆ្ងាយប៉ុណ្ណាទេ មិនថាខ្ញុំមានអារម្មណ៍ថាគ្មានជំនួយ ឬក៏ព្រលឹងខ្ញុំប្រាថ្នាជ្រាលជ្រៅប៉ុណ្ណា-ក៏ព្រះយេស៊ូវអាចបំពេញគ្រប់ទាំងតម្រូវការទាំងនេះបាន និងលើសពីនេះទៀតផង។ ព្រះអង្គមិនគ្រាន់តែប្រទានការសម្រាកតែមួយមុខ ដែលនឹងក្លាយជាការធូរស្បើយដ៏ធំធេងនោះឡើយ ប៉ុន្តែទ្រង់ក៏បានសន្យានឹងប្រទានអ្វីមួយដែលចម្អែតខ្ញុំផងដែរ។ ទោះជាយ៉ាងណា មានអ្វីមួយដែលប្រសើរជាងការនេះទៅទៀត។ ព្រះយេស៊ូវមានព្រះបន្ទូលថា៖ “អ្នកណាដែលជឿដល់ខ្ញុំ (ជឿខ្ញុំ ហើយទុកចិត្តទាំងស្រុងពាក្យខ្ញុំ) នោះនឹងមានទន្លេទឹករស់ហូរចេញ…មក…”»។

“តើវាអាចទៅរួចទេ ដែលដីរីងស្ងួត ហើយហួតហែង មិនត្រឹមតែបានស្រោចស្រប់ឡើងប៉ុណ្ណោះទេ—តែបានធ្វើឲ្យដីរីងស្ងួតប្រែទៅជាមានសំណើម ហើយកន្លែងដែលក្តៅត្រូវប្រែទៅជាត្រជាក់—ហើយដើម្បីធ្វើឲ្យដីប្រែទៅជាជោកជាំ ដោយមានប្រភពទឹកផុសចេញមក ហើយខ្សែទឹកក៏ហូរចេញពីទីនោះ?»

“ពិតណាស់! ទឹកនេះមិនគ្រាន់តែជាទឹកហូរនៅតាមជម្រាលភ្នំបណ្តោះអាសន្ន ដែលរីងទឹកអស់បន្ទាប់ពីភ្លៀងរាំងនោះឡើយ ប៉ុន្តែជាទន្លេ “ហូរចេញពីទ្រង់” ដូចជាទន្លេយ៉ាងជីដ៏ធំ ដែលតែងតែមានទឹកជ្រៅ និងពេញជានិច្ច។ ក្នុងគ្រារាំងស្ងួត ខ្សែទឹកនឹងរីងស្ងួត ហើយទឹកក្នុងប្រឡាយនឹងត្រូវហូរចេញអស់ ប៉ុន្តែទន្លេយ៉ាងជីមិនដែលនឹងរីងស្ងួតឡើយ។ វាជាទន្លេមួយដែលមានអំណាចមួយ តែងតែមានទឹកហូរខ្លាំង ហើយមិនអាចបញ្ឈប់បានដែរ»។

“ចូរមកឯខ្ញុំ ហើយផឹកចុះ» គាត់បានសរសេរសំបុត្រមួយទៀតនៅខែមិថុនា។ កុំគ្រាន់តែមកឯខ្ញុំ ហើយផឹកត្រឹមតែបន្តិចដោយប្រញាប់ កុំមកឯខ្ញុំគ្រាន់រម្ងាប់ការស្រេកតែមួយភ្លែត ឬក៏បំបាត់ការស្រេកឃ្លានរបស់អ្នកជាបណ្តោះអាសន្ននោះឡើយ។ ទេ! “ចូរផឹក” ឬ “បន្តផឹក” ឲ្យទៅជាទម្លាប់ជាប់ជានិច្ចចុះ។ យើងប្រហែលមិនអាចព្យាបាលដើមចមនៃសេចក្តីស្រេកទឹកបានទេ។ តែអ្នកណាដែលមក អ្នកណាដែលផឹកអាចនឹងស្រស់ស្រាយ ហើយបានប្រសើរឡើង។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរតែបន្តមក បន្តផឹកជាប់ជានិច្ច។ គ្មានបញ្ហាអ្វីនៅក្នុងការបង្ហូរទឹកចេញពីប្រភពទឹក ឬក៏បង្ហូសទឹកចេញពីទន្លេទេ!»

គាត់មិនបានដឹងថាគាត់ត្រូវការការកម្សាន្តចិត្តរបស់ព្រះគ្រីស្ទខ្លាំងប៉ុណ្ណាទេ នៅពេលគាត់កំពុងសរសេរសំបុត្រនារដូវក្តៅនោះ។ ប៉ុន្តែ ព្រះមួយអង្គដែលគាត់កំពុងរៀនទុកចិត្តនៅក្នុងរបៀបមួយថ្មី ហើយកាន់តែជ្រាលជ្រៅនោះមិនធ្វើឲ្យគាត់ខកចិត្តឡើយ។

ប្រាំមួយអាទិត្យក្រោយមក សេចក្តីអំណរ និងសេចក្តីទុក្ខសោកបានលាយឡំគ្នាយ៉ាងចម្លែកនៅក្នុងផ្ទះបេសកជននៅជីងគាំង។ លោក និងលោកស្រី ថេល័រ បានទទួលបានកូនប្រុសម្នាក់ ដែលបាននាំមកនូវសេចក្តីអំណរដល់ពួកគាត់។ យ៉ាងណាមិញ ជំងឺអាសន្នរោគ (cholera) បានរីករាលដាលយ៉ាងធ្ងន់ធ្ងរដល់អ្នកម្តាយដែលបណ្តាលឲ្យគាត់ទន់ខ្សោយ ដោយបានប៉ះពាល់ដល់ការបំបៅកូន។ ទម្រាំពួកគេបានរកបានម៉ែដោះជនជាតិចិនបាន វាយឺតពេលទៅហើយសម្រាប់ទារកតូច។ ទារកតូចនេះបានស្លាប់ បន្ទាប់ពីកើតមកបានត្រឹមតែមួយសប្តាហ៍។ មិនយូរប៉ុន្មាន ម្តាយរបស់គេក៏បានលាចាកលោកទៅតាមគេផងដែរ។

លោកគ្រូ ហ័ដសិន បានសរសេរថា «បើទោះបីជាប្រពន្ធគាត់មានរាងកាយចុះខ្សោយក្តី ក៏សេចក្តីសុខសាន្តនៃព្រលឹងរបស់គាត់ដឹងថា ព្រះវត្តមានព្រះគង់នៅជិតគាត់ ហើយសេចក្តីអំណររបស់គាត់គឺជាបំណងព្រះហឫទ័យព្រះ ដែលទ្រង់បានគ្រោងឲ្យគាត់បានជួបនឹងបទពិសោធន៍ទាំងនេះលើសពីការពិពណ៌នាទៅទៀត»។

គាត់បានជ្រើសរើសបទចម្រៀងសរសេរតម្កើងមួយបទដោយផ្ទាល់ ដែលសក្តិសមនឹងគាត់ជាពិសេសសម្រាប់បុណ្យសព «ឱព្រះសង្គ្រោះដ៏បរិសុទ្ធ មិត្តសម្លាញ់ដែលមើលមិនឃើញអើយ!»។

*ថ្វីបើជំនឿ និងក្តីសង្ឃឹមត្រូវសាកល្បងជារឿយៗ*
*គេមិនទូលសូម ឬក៏ត្រូវការអ្វីផ្សេងទៀតឡើយ*
*សុខជាពន់ពេក ស្ងប់ជាពន់ពេក ពេញចិត្តជាពន់ពេក*
*ជាព្រលឹងដែលនៅជាប់នឹងទ្រង់*
*ពួកគេមិនខ្លាចសាតាំង ឬផ្នូរឡើយ*
*ពួកគេដឹងថាទ្រង់គង់នៅជិត ហើយមានអំណាចសង្គ្រោះគេ*
*ពួកគេមិនខ្លាចនឹងឆ្លងរលកទន្លេយ័រដាន់ឡើយ*
*ឲ្យតែពួកគេនៅជាប់នឹងទ្រង់*

ពួកគាត់មិនបានដឹងថា ជីវិតរបស់លោកស្រី ថេល័រ កំពុងតែខិតចូលទៅដល់ទីបញ្ចប់ឡើយ ដោយព្រោះតែសេចក្ដីស្រឡាញ់យ៉ាងខ្លាំងរបស់ពួកគេដែលមានចំពោះគាត់។ ថ្វីបើលោកស្រី ថេល័រ មានសភាពចុះខ្សោយទៅៗក៏ដោយ ក៏ពួកគេមិនគិតថានឹងអាចត្រូវបែកគ្នានោះឡើយ។ លោកស្រី ថេល័រ មានអាយុត្រឹមតែសាមសិបបីឆ្នាំ ហើយគាត់មិនមានអារម្មណ៍ឈឺចាប់អ្វីទេ គ្រាន់តែមានការនឿយហត់ទៅៗប៉ុណ្ណោះ។ ពីរថ្ងៃមុន មរណភាពរបស់លោកស្រី លោកស្រីបានទទួលសំបុត្រមួយច្បាប់ពីលោកស្រី ប៊ើកហ្គ័រ ព្រមជាមួយដំណឹងនៃការទៅដល់ទីក្រុងសេនធ៍ហៀល ដោយមានសុវត្ថិភាពរបស់កញ្ញា ប្លេតឆ្លេយ៍ និងកូនៗរបស់គាត់។ សេចក្ដីលម្អិតរបស់សំបុត្រស្ដីពីការទទួលរាក់ទាក់ ដោយកក់ក្ដៅរបស់ពួកគេ ហើយការថែរក្សាយកចិត្តទុកដាក់សម្រាប់ភាពសុខសាន្តរបស់ពួកគេ បាននាំមកនូវសេចក្ដីអំណរយ៉ាងពេកពន់ដល់គាត់។ លោកស្រីពិតជាអរគុណយ៉ាងអនេក និងមិនចង់បានអ្វីក្រៅពីសរសើរតម្កើងព្រះជាម្ចាស់ចំពោះសេចក្ដីសប្បុរសទ្រង់ឡើយ។ ជារឿយៗ សំបុត្រលោកស្រី ប៊ើកហ្គ័រ បានមកដល់ចំពេលដែលកំពុងតែត្រូវការ ហើយភាពចេះគិតគូររបស់គាត់បានធ្វើឲ្យលោកស្រីប្រមើលឃើញស្ថានភាពដែលពួកគេកំពុងប្រឈមមុខនៅពេលពួកគេទទួលសំបុត្ររបស់លោកស្រី ហើយសំបុត្រនេះក៏មិនខុសពីសំបុត្រមុនៗដែរ។

លោកស្រីបានសរសេរថា៖ «ពេលនេះ ជាពេលខ្ញុំត្រូវលាសម្លាញ់ហើយ។ សូមព្រះអម្ចាស់ហ៊ុមព័ទ្ធបងប្អូនដោយព្រះហស្តដែលគង់នៅអស់កល្បជានិច្ចនៃទ្រង់»។

លោកស្រី ថេល័រ បាននឹងកំពុងតែសម្រាកក្នុងព្រះហស្តទ្រង់ហើយ។

មនុស្សម្នាក់ដែលនៅក្នុងហេតុការណ៍នោះបានសរសេរថា៖ «ខ្ញុំមិនធ្លាប់បានឃើញទិដ្ឋភាពបែបនេះសោះពីមុនមក។ កាលលោកស្រី ថេល័រ បានដកដង្ហើមចុងក្រោយរបស់គាត់ហើយ លោកគ្រូ ហ័ដសិន ក៏បានលុតជង្គង់ចុះ ហើយបានប្រគល់គាត់ទៅកាន់ព្រះអម្ចាស់។ លោកបានអរព្រះគុណព្រះជាម្ចាស់សម្រាប់ពេលវេលាដ៏មានក្ដីសុខ ដែលពួកគាត់បានចំណាយជាមួយគ្នាអស់រយៈពេលដប់ពីរឆ្នាំកន្លះកន្លងមក គាត់ក៏ព្រមទាំងបានអរព្រះគុណទ្រង់សម្រាប់ការស្វាគមន៍លោកស្រីថេល័រទៅក្នុងព្រះវត្តមានរបស់ផងទ្រង់ ហើយបានថ្វាយខ្លួនគាត់យ៉ាងឱឡារិកម្ដងទៀត ចំពោះការបម្រើទ្រង់»។

ពន្លឺព្រះអាទិត្យបានរះឡើងខ្ពស់ផុតទីក្រុង ភ្នំតូចៗ និងទន្លេ។ សូរសៀងជីវិតបានបន្លឺ

ឡើងពីទីធ្លា និងផ្លូវជាច្រើនរាប់មិនអស់។ ប៉ុន្តែ នៅបន្ទប់ខាងលើនៃផ្ទះមួយខ្នងរបស់ជនជាតិចិន ដែលគេឃើញផ្ទៃមេឃពណ៌ខៀវ សេចក្តីសុខសាន្តដ៏អស្ចារ្យបានលេចឡើង។

«នឹងមិនដែលស្រេកទៀតទេ» ឥឡូវនេះ តើវាអាចជាការពិតទេ? «ដើម្បីយល់ពីសេចក្តីនោះ 'នឹង' មានន័យថា «នឹង» ដែល «មិនដែល» មានន័យថា «មិនដែល» ហើយដែល «ស្រេក» សំដៅទៅលើ «បំណងចិត្តទាំងឡាយណាដែលមិនទាន់បានសម្រេចនៅឡើយ»។ ជារឿយៗ លោកគ្រូ ហ៉ដសិន បាននិយាយជាច្រើនឆ្នាំក្រោយមកថា «វាប្រហែលជាការយល់ដឹងយ៉ាងជ្រាលជ្រៅបំផុតមួយ ដែលព្រះជាម្ចាស់បានបើកសម្តែងដល់យើងហើយ»។ នៅអំឡុងពេលនៃភាពអស់សង្ឃឹមទាំងស្រុងនោះ សេចក្តីសន្យានេះបានបង្ហាញយ៉ាងជាក់ច្បាស់នៅក្នុងដួងចិត្តដែលឈឺផ្សារបស់គាត់។

លោកគ្រូ ហ៉ដសិន ថេល័រ បានផ្ញើសំបុត្រទៅអ្នកម្តាយលោកនៅខែសីហាថា៖

«ខ្ញុំពិតជាមានអំណរដែលដឹងថា ព្រះជាម្ចាស់បានធ្វើ ឬបានអនុញ្ញាតឲ្យគ្រប់អ្វីៗទាំងអស់កើតឡើង ហើយធ្វើអ្វីៗគ្រប់យ៉ាង សម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ទ្រង់»។

«មានតែព្រះជាម្ចាស់មួយអង្គប៉ុណ្ណោះទើបជ្រាបថា ប្រពន្ធសំណព្វចិត្តរបស់ខ្ញុំសំខាន់យ៉ាងណាសម្រាប់ខ្ញុំ ហើយថាគាត់ជាពន្លឺនៃកែវភ្នែករបស់ខ្ញុំ ហើយជាអំណរនៃដួងចិត្តខ្ញុំខ្លាំងយ៉ាងណាខ្លះ។ នៅថ្ងៃចុងក្រោយរបស់គាត់ យើងមិនបានដឹងថា វាជាថ្ងៃចុងក្រោយរបស់គាត់ទេ យើងនៅតែបង្ហាញសេចក្តីស្រឡាញ់ដ៏មានសុភមង្គលដែលយើងមានរួមគ្នានោះឡើយ។ កាយវិការចុងក្រោយរបស់នាង គឺជាការយកដៃមកឱបជុំវិញករបស់ខ្ញុំ ដាក់ដៃរបស់គាត់លើក្បាលខ្ញុំ ហើយខ្ញុំជឿថា បើទោះបីជា មាត់គាត់ហើបនិយាយមិនបានក៏ដោយ ក៏គាត់បានសូមព្រះឲ្យប្រទានពរដល់ខ្ញុំដែរ។ ព្រះជាម្ចាស់បានជ្រាបថា វាជាការល្អនៅក្នុងការដកយកគាត់ទៅ នោះក៏ល្អសម្រាប់គាត់ហើយ ក្នុងកាលដែលទ្រង់បានដកយកគាត់ទៅដោយគ្មានការឈឺចាប់ ហើយវាក៏ជាការល្អសម្រាប់ខ្ញុំដែរ។ ពេលនេះ ខ្ញុំត្រូវតែប្រឈមមុខនឹងការងារ និងការឈឺចាប់តែម្នាក់ឯង ប៉ុន្តែខ្ញុំមិនមែននៅតែម្នាក់ឯងឡើយ ព្រោះតែព្រះជាម្ចាស់កាន់តែខិតចូលមកជិតខ្ញុំជាងពេលណាៗទាំងអស់»។

ជូនចំពោះលោក បើកហ្គ័រ៖

«នៅពេលដែលខ្ញុំគិតអំពីការបាត់បង់របស់ខ្ញុំ ដួងចិត្តខ្ញុំស្ទើរប្រេះបែកទៅហើយ ប៉ុន្តែខ្ញុំ

ក៏អរព្រះគុណចំពោះព្រះអម្ចាស់ដែលបានសង្គ្រោះគាត់ចេញពីសេចក្ដីវេទនា និងឲ្យគាត់មានសេចក្ដីសុខសាន្តយ៉ាងក្រៃលែងដែរ។ យ៉ាងណាមិញ ទឹកភ្នែកខ្ញុំក៏ស្រក់ចុះ ដោយសេចក្ដីអំណរជាជាងសេចក្ដីទុក្ខសោកវិញ។ ជាពិសេសលើសជាងអ្វីៗទាំងអស់ ខ្ញុំអរសប្បាយនៅក្នុងព្រះជាម្ចាស់តាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ—ចំពោះកិច្ចការ មាគ៌ាការថែរក្សា និងផ្គត់ផ្គង់របស់ទ្រង់ និងចំពោះអង្គទ្រង់ផ្ទាល់។ ព្រះអង្គកំពុងតែអនុញ្ញាតឲ្យខ្ញុំភ្លក់ (តាមរយៈការល្បងល) និងយល់អំពីសេចក្ដីសប្បុរស ការទទួលយក និងបំណងព្រះហឫទ័យដ៏គ្រប់លក្ខណ៍របស់ផងទ្រង់។ ខ្ញុំពិតជារីករាយនឹងបំណងព្រះហឫទ័យទ្រង់ណាស់ វាជាអ្វីដែលខ្ញុំពេញចិត្ត ជាការដែលគ្រប់លក្ខណ៍ ហើយជាសេចក្ដីស្រឡាញ់ដែលមានសកម្មភាព។ ហើយមិនយូរប៉ុន្មាននោះ យើងនឹងជួបជុំគ្នាម្ដងទៀតនៅក្នុងបំណងព្រះហឫទ័យដ៏អស្ចារ្យរបស់ទ្រង់ ហើយនឹងមិនដែលឃ្លាតពីគ្នាទៀតទេ។ “ឱព្រះវរបិតាអើយ! ទូលបង្គំចង់ឲ្យអស់អ្នកដែលព្រះអង្គបានប្រទានឲ្យមករស់នៅមួយទូលបង្គំ បានមករស់នៅកន្លែងដែលទូលបង្គំនៅដែរ” (យ៉ូហាន ១៧:២៤)។

យ៉ាងណាមិញ ខ្ញុំជួបប្រទះការទុក្ខព្រួយ ជាពិសេសនៅអំឡុងពេលគាត់មានជំងឺ ហើយមិនបានសម្រាន្តអស់ជាច្រើនយប់។

លោកគ្រូ ហ័ដសិន បាននឹកចាំពីអារម្មណ៍ឯកាយ៉ាងពន់ពេក នៅអំឡុងពេលដែលគាត់ជាប់នៅក្នុងបន្ទប់របស់គាត់ ដោយនឹករលឹកដល់ប្រពន្ធសម្លាញ់របស់គាត់ និងសម្លេងកូនៗរបស់គាត់នៅប្រទេសអង់គ្លេស។ ពេលនោះហើយ ដែលគាត់បានយល់អំពីសារៈសំខាន់នៃព្រះបន្ទូលរបស់ផងព្រះអម្ចាស់នេះ៖ “តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ”។ គាត់ដឹងថា គាត់ស្រែកអំពាវនាវដល់ព្រះអម្ចាស់ប្រហែលម្ភៃដងក្នុងមួយថ្ងៃ នៅពេលដែលគាត់មានអារម្មណ៍ថា ការស្រេកនៅក្នុងចិត្តរបស់គាត់បានត្រឡប់មកវិញហើយ។

“ឱព្រះអម្ចាស់អើយ! ព្រះអង្គបានសន្យានឹងទូលបង្គំថា ទូលបង្គំនឹងមិនស្រេកទៀតឡើយ”។

“មិនថា ទូលបង្គំស្រែកអំពាវនាវរកព្រះអង្គនៅពេលថ្ងៃ ឬយប់ឡើយ ព្រះអង្គនឹងយាងមក ហើយចម្អែតដួងចិត្តដ៏ខ្វះខាតរបស់ទូលបង្គំយ៉ាងរហ័ស។ ជាញឹកញាប់ ទូលបង្គំចង់ដឹងណាស់ថា មនុស្សដែលទូលបង្គំស្រឡាញ់ ដែលទ្រង់ជាអ្នកបានដកចេញទៅ អាចនឹង

កំពុងតែមានអំណរក្នុងព្រះវត្តមានទ្រង់លើសជាងទូលបង្គំ ដែលកំពុងតែនៅក្នុងបន្ទប់ដ៏សែនឯកានេះឬយ៉ាងណា។ ព្រះអង្គពិតជាឆ្លើយតបចំពោះសេចក្តីអធិស្ឋាន៖

ឱ! ព្រះអម្ចាស់យេស៊ូវអើយ! សូមព្រះអង្គក្លាយជាសេចក្តីពិតដ៏រស់រវើកដល់ទូលបង្គំ។ ដើម្បីទូលបង្គំអាចមើលឃើញទ្រង់ច្បាស់ជាងអ្វីៗទាំងអស់ កាន់តែគួរឲ្យស្រឡាញ់ និងកាន់តែស្និទ្ធស្នាលជាងសូម្បីតែទំនាក់ទំនងដ៏ផ្អែមល្ហែមបំផុតនៅលើផែនដីនេះ»។

នៅអំឡុងពេលនេះ សំបុត្រដែលគាត់បានរៀបចំសរសេរទៅកាន់កូនៗរបស់គាត់ គឺជាសំបុត្រដែលមានតម្លៃបំផុត និងកំពុងតែបើកបង្ហាញឲ្យឃើញថា ដួងចិត្តរបស់ផងគាត់ប្រាថ្នាចង់បានពួកគេដោយសេចក្តីស្រឡាញ់ដ៏អស្ចារ្យ។

ជារឿយៗ ឪពុកគិតអំពីកូនៗជាទីស្រឡាញ់របស់ពុកជានិច្ច ហើយមើលរូបថតកូនៗរហូតទឹកភ្នែកហូរជោគថ្ពាល់គាត់។ ពេលខ្លះ គាត់ស្ទើរតែខ្លាចថា គាត់នឹងមានអារម្មណ៍មិនសប្បាយចិត្ត ដោយគិតថាអ្នកនៅឆ្ងាយប៉ុណ្ណា។ ប៉ុន្តែ ព្រះអម្ចាស់យេស៊ូវ ដែលមិនបោះបង់ចោលគាត់នោះ ព្រះអង្គមានព្រះបន្ទូលថា «កុំខ្លាចអី យើងនឹងបន្តចម្អែតដល់ដួងចិត្តរបស់ឯង»។ នោះខ្ញុំអរព្រះគុណទ្រង់ ទាំងត្រេកអរដែលព្រះអង្គនឹងគង់នៅក្នុងចិត្ត ទ្រង់នឹងបំពេញសេចក្តីសន្យារបស់ទ្រង់សម្រាប់ខ្ញុំ។

«ពុកសូមជូនពរកូនៗជាទីស្រឡាញ់អើយ សូមឲ្យកូនស្គាល់អំពីតម្លៃនៃការថ្វាយដួងចិត្តកូនទៅកាន់ព្រះយេស៊ូវជារៀងរាល់ថ្ងៃ។ ពុកបានព្យាយាមរក្សាដួងចិត្តឲ្យស្ថិតនៅកន្លែងមួយដែលត្រឹមត្រូវ ប៉ុន្តែវាចេះតែវង្វេងចេញពីទីនោះ។ នៅទីបំផុត ពុកបានឈប់ព្យាយាមដោយកម្លាំងខ្លួនឯង ហើយទទួលយកការរក្សារបស់ព្រះអម្ចាស់វិញ។ តើកូនមិនយល់ថានេះជាវិធីល្អប្រសើរទេមែនទេ? ពេលខ្លះ កូនប្រហែលគិតថា៖ “កូននឹងព្យាយាមជៀសវៀងពីការមានចិត្តគំនិតអាត្មានិយម មិនសុភាព ឬមិនស្តាប់បង្គាប់នោះទេ”។ ប៉ុន្តែ សូម្បីតែនៅពេលកូនព្យាយាមធ្វើបែបនេះក្តី ក៏អ្នកកូនប្រហែលជាមិនជោគជ័យដែរ។ យ៉ាងណាមិញ ព្រះយេស៊ូវបានមានព្រះបន្ទូលថា៖ “ចូរទុកចិត្តដល់យើងចុះ។ ចូរប្រគល់ដួងចិត្តដ៏តូចរបស់ឯងមកឯយើងរក្សា បើសិនជាឯងពិតជាទុកចិត្តយើងលើការនោះមែន”។ ហើយព្រះអង្គនឹងរក្សាដួងចិត្តកូន»។

«ពុកធ្លាប់ព្យាយាមគិតអំពីព្រះយេស៊ូវច្រើន ប៉ុន្តែពុកបែរជាឧស្សាហ៍ភ្លេចទ្រង់ទៅវិញ។ ពេលនេះ ពុកទុកចិត្តលើព្រះយេស៊ូវក្នុងការជួយពុកឲ្យនឹកចាំអំពីទ្រង់ ហើយព្រះអង្គក៏បាន

ធ្វើដូច្នេះមែន។ នេះគឺជាវិធីសាស្រ្តមួយដ៏ប្រសើរ។ ចូរកូនសុំឲ្យកញ្ញា ប្លេតឆ្លេយ៍ ពន្យល់បន្ថែមអំពីវិធីសាស្រ្តនេះ ហើយអធិស្ឋានសូមឲ្យព្រះជាម្ចាស់ពន្យល់យ៉ាងច្បាស់ដល់កូន ហើយជួយដល់កូនឲ្យទុកចិត្តព្រះយេស៊ូវបែបយ៉ាងដូច្នេះដែរចុះ»។

លោកគ្រូ ហ៍ដសិន បានសរសេរទៅកញ្ញា ប្លេតឆ្លេយ៍ អំពីប្រធានបទដូចគ្នាពីបន្ទប់គេងដែលមិនសូវស្រួលរបស់គាត់នៅលើកប៉ាល់ដែលធ្វើដំណើរតាមឆ្នេរសមុទ្រមួយ។

«ខ្ញុំបានសរសេរទៅកាន់កូនៗជាទីស្រឡាញ់របស់ខ្ញុំម្តងទៀត។ ខ្ញុំពិតជាចង់ឲ្យពួកគេរៀនតាំងពីតូចអំពីសេចក្តីពិតដ៏មានតម្លៃ ដែលបានចូលមកក្នុងជីវិតខ្ញុំក្នុងកាលដែលខ្ញុំមានអាយុច្រើនហើយ អំពីការរួមមកតែមួយជាមួយនឹងព្រះគ្រីស្ទ និងការមានព្រះជន្មគង់នៅរបស់ទ្រង់។ សេចក្តីពិតទាំងនេះ ហាក់មិនពិបាកយល់ជាងការប្រោសលោះនោះទេ។ ប៉ុន្តែ សេចក្តីទាំងពីរនេះត្រូវការការបង្រៀនពីព្រះ ហើយមិនត្រូវការអ្វីផ្សេងទៀតនោះឡើយ។ សូមព្រះជាម្ចាស់ជួយអ្នកបង្ហាញពីព្រះជន្មព្រះគ្រីស្ទដល់កូនៗខ្ញុំ ហើយអាចប្រាប់ពួកគេអំពីទ្រង់។ ព្រះអង្គបានដឹកនាំ និងបានបង្រៀនដល់ពួកយើងអស្ចារ្យយ៉ាងណាទៅ! ខ្ញុំពិបាកនឹងជឿថាមានដួងចិត្តដែលសម្រាក និងសុខសាន្ត ដែលខ្ញុំអាចនឹងរីករាយបានក្នុងជីវិតនេះណាស់! វាដូចជាស្ថានសួគ៌បានចាប់ផ្តើមនៅទីនេះ មិនអញ្ចឹងឬអី? ការរួបរួមជាមួយព្រះគ្រីស្ទធ្វើឲ្យស្ថានសួគ៌ ឬក៏ផែនដីហាក់មិនសូវសំខាន់»។

«វាគឺជាក្តីអំណរដែលដឹងថា ព្រះយេស៊ូវមានព្រះជន្មគង់នៅជាមួយប្អូនស្រី» លោកគ្រូ ហ៍ដសិន សរសេរទៅប្អូនស្រីរបស់គាត់ឈ្មោះ លោកស្រី វ៉កគ័រ (Mrs. Walker) នៅក្នុងការធ្វើដំណើរខាងវិញ្ញាណតែមួយ «ចិត្តរបស់ប្អូនស្រីពេញដោយព្រះអង្គទាំងស្រុង ហើយសេចក្តីស្រឡាញ់របស់ទ្រង់បានរម្លឹកប្អូនថា ព្រះអង្គសព្វព្រះហឫទ័យនឹងប្រកបជាមួយនឹងប្អូនគ្រប់ពេលវេលាទាំងអស់ មិនមែនតែតាមរយៈការខំប្រឹងប្រែងរបស់ប្អូនដើម្បីឲ្យបាននៅជាប់ក្នុងទ្រង់នោះទេ។ ប៉ុន្តែ ដោយសារព្រះអង្គគឺជាជីវិត កម្លាំង និងសេចក្តីសង្គ្រោះរបស់ផងយើងវិញ។ ព្រះអង្គគឺជាប្រាជ្ញាញាណ សេចក្តីសុចរិត ការញែកជាបរិសុទ្ធ និងការប្រោសលោះរបស់ផងយើង។ ព្រះអង្គចម្រើនកម្លាំងដល់យើងនៅក្នុងការបម្រើ ហើយបង្កើតផលផ្លែ។ ព្រះហស្តរបស់ព្រះអង្គគឺជាកន្លែងដែលយើងសម្រាកនៅបច្ចុប្បន្ននេះ ហើយនិងរហូតតទៅ»។

ទន្ទឹមគ្នានេះដែរ ភាពលំបាកមកពីខាងក្រៅមិនបានថមថយឡើយ។ ដោយស្ថានភាព

នយោបាយ កិច្ចការនានាមើលទៅហាក់បីដូចជាកាន់តែគម្រាមកំហែងជាងពេលណាៗទាំងអស់ដែលលោកគ្រូ ហ៉ដសិន ធ្លាប់ជួបនៅប្រទេសចិន។ ការសម្លាប់រង្គាលនៅធានស៊ិន ដែលបានឆក់យកជីវិតជនជាតិបរទេសម្ភៃមួយនាក់រួមទាំងកុងស៊ុលជនជាតិបារាំងម្នាក់នៅមិនទាន់បានដោះស្រាយនៅឡើយ ដោយសារអាជ្ញាធរចិនបានដឹងថា ពួកអឺរ៉ុបបានជាប់រវល់នឹងសង្គ្រាម ដូច្នេះពួកគេមិនបានធ្វើអ្វី ដើម្បីកាត់បន្ថយការប្រឆាំងនឹងជនជាតិបរទេសទេ។ លោកគ្រូ ហ៉ដសិន បានចែករំលែកអំពីស្ថានភាពដ៏ធ្ងន់ធ្ងរដែលបានកើតឡើងនៅក្នុងសំបុត្រមួយដែលគាត់បានផ្ញើការអំពាវនាវដល់អ្នកគាំទ្រទាំងអស់នៃអង្គការបេសកកម្មចិនដីគោករបស់គាត់ឲ្យញែកថ្ងៃ៣១ ខែធ្នូ ដើម្បីតមអាហារ និងការអធិស្ឋានសម្រាប់ស្ថានភាពនោះ។

គាត់បានសរសេរថា៖ «យើងអាចមើលឃើញថា ឆ្នាំនេះជាឆ្នាំមួយដែលគួរឲ្យកត់សម្គាល់តាមរបៀបជាច្រើន។ ប្រហែលពួកយើងគ្រប់គ្នាបានជួបនឹងគ្រោះថ្នាក់ ការយល់ច្រឡំ និងបញ្ហាផ្សេងៗ។ ទោះជាយ៉ាងណា ក៏ព្រះអម្ចាស់បានសង្គ្រោះយើងរាល់គ្នាចេញពីការទាំងអស់នោះហើយដែរ។ ហើយអ្នកខ្លះដែលធ្លាប់ជួបនឹងសេចក្ដីទុក្ខសោកយ៉ាងពេកពន់ អាចពោលបានថា វាពិតជាឆ្នាំនៃព្រះពរសម្រាប់ព្រលឹងរបស់ពួកយើងមែន ហើយពួកគេបានអរព្រះគុណសម្រាប់ព្រះពរទាំងនោះ។ សម្រាប់ខ្ញុំ វាជាឆ្នាំទុក្ខសោក និងក៏ជាឆ្នាំនៃព្រះពរសម្រាប់ជីវិតខ្ញុំ ហើយខ្ញុំជឿថា អ្នកផ្សេងទៀតក៏មានបទពិសោធន៍ស្រដៀងគ្នានេះដែរ។ យើងបានភ្លក់រសជាតិនៃភាពស្មោះត្រង់របស់ព្រះជាម្ចាស់—សមត្ថភាពព្រះអង្គក្នុងការទ្រទ្រង់យើងនៅក្នុងគ្រាមានទុក្ខលំបាក ហើយព្រះអង្គបានប្រទានការអត់ធ្មត់នៅអំឡុងពេលនៃការរងទុក្ខ និងសង្គ្រោះយើងពីគ្រោះថ្នាក់ដែរ។ ហើយប្រសិនបើគ្រោះថ្នាក់កាន់តែខ្លាំង ឬក៏សេចក្ដីទុក្ខកាន់តែធំបានកើតមាននៅចំពោះមុខ យើងសង្ឃឹមថានឹងប្រឈមនឹងការទាំងនោះដោយកាន់តែទុកចិត្តព្រះជាម្ចាស់របស់យើងខ្លាំងជាងមុនថែមទៀត។

យើងមានរឿងជាច្រើនដែលយើងត្រូវអរព្រះគុណព្រះជាម្ចាស់ ពីព្រោះយើងបានបង្ហាញគ្រីស្ទបរិស័ទចិនថា ទាំងយើង និងពួកគេអាចប្រឈមនឹងគ្រោះថ្នាក់បាន។ ពួកគេប្រហែលជាបានរៀននៅក្នុងការពឹងអាងលើព្រះជាម្ចាស់ ជាជាងអំណាចបរទេសសម្រាប់ការការពារ ដោយសារតែការការពារនោះមិនអាចធានាបាននោះទេ ព្រមទាំងមិនគួរឲ្យទុក

ចិត្តផង។ ហើយពីព្រោះយើងនៅតែស្ងប់ចិត្ត និងមានអំណរក្នុងកាលដែលយើងបំពេញភារកិច្ចរបស់យើងនៅឡើយ។ ប្រសិនបើយើងមិនបានប្រើឱកាសនេះជាប្រយោជន៍ដល់ពួកគេ ឬមិនបានពឹងផ្អែកលើព្រះជាម្ចាស់ ដើម្បីថែរក្សាយើងឲ្យមានសុវត្ថិភាព ឬជួយយើងឲ្យឆ្លងផុតពីគ្រោះថ្នាក់ដូចដែលព្រះអង្គសព្វព្រះហឫទ័យថាជាអ្វីដែលប្រសើរបំផុតនោះទេ នោះចូរទទួលស្គាល់កំហុសរបស់យើងចំពោះព្រះដ៏ស្មោះត្រង់របស់យើង ដែលរក្សាសេចក្តីសន្យារបស់ទ្រង់ចុះ។

ខ្ញុំជឿថា យើងទាំងអស់គ្នាដឹងថា យើងជាបាវបម្រើរបស់ព្រះ ដែលព្រះអង្គបានបញ្ជូនមកឲ្យកាន់ភារកិច្ច ដើម្បីឲ្យយើងបម្រើកិច្ចការរបស់ទ្រង់។ ព្រះអង្គបានបង្ហាញឱកាសដែលយើងបានចាប់យក ហើយក្នុងអំឡុងពេលវេលាដ៏រំភើបនាពេលអតីតកាល ទ្រង់ក៏បានរក្សាយើងឲ្យមានសុវត្ថិភាពដែរ។ យើងបានមកប្រទេសចិនមិនមែនដោយសារការងារព័ន្ធកិច្ចនៅទីនេះងាយស្រួល ឬមានសុវត្ថិភាពឡើយ ប៉ុន្តែដោយសារព្រះអង្គបានត្រាស់ហៅយើងវិញទេតើ។ យើងបានចាប់ផ្តើមមុខងារបម្រើបច្ចុប្បន្នរបស់យើង មិនមែនដោយសារការសន្យានៃការការពាររបស់មនុស្សនោះទេ។ ប៉ុន្តែ ជាការទុកចិត្តលើសេចក្តីសន្យាថា ព្រះអង្គនឹងគង់នៅជាមួយយើង។ មិនថារឿងរ៉ាវហាក់បីដូចជាងាយស្រួល ឬលំបាក មានសុវត្ថិភាព មានគ្រោះថ្នាក់ ឬមិនថាមនុស្សគេអនុញ្ញាត ឬមិនអនុញ្ញាតនោះឡើយ ក៏មិនបានផ្លាស់ប្តូរទំនួលខុសត្រូវរបស់យើងនោះដែរ។ បើយើងប្រឈមមុខនឹងគ្រោះថ្នាក់ពិសេស ខ្ញុំទុកចិត្តថា យើងនឹងមានព្រះគុណនៅក្នុងការបង្ហាញថា យើងទុកចិត្តព្រះអង្គខ្លាំងប៉ុណ្ណា ហើយដោយរក្សាភាពស្មោះត្រង់នៅក្នុងការបំពេញភារកិច្ចរបស់យើង នោះយើងនឹងបង្ហាញថា យើងដើរតាមអ្នកគង្វាលល្អដែលមិនរត់ ទោះបីប្រឈមមុខនឹងសេចក្តីស្លាប់ក្តី។ ទោះជាយ៉ាងណាក្តី ដើម្បីបង្ហាញពីសេចក្តីជំនឿនៅក្នុងពេលដ៏មានគ្រោះថ្នាក់បែបនេះ យើងត្រូវតែចម្រើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ជាចាំបាច់នៅពេលនេះ (២ពេត្រុស ៣:១៧)។ វាយឺតពេលពេកហើយនៅក្នុងការត្រៀមខ្លួន ដើម្បីហ្វឹកហាត់ក្នុងកាលដែលប្រឈមមុខនឹងខ្មាំងសត្រូវរួចហើយ។

លោកគ្រូ ហ័ដសិន បានលើកឡើងចំពោះការផ្គត់ផ្គង់ផ្នែកសម្ភារៈថាៈ

“អ្នកមិនត្រូវការការរម្លឹកអំពីការផ្គត់ផ្គង់ដ៏សប្បុរស ដែលព្រះអម្ចាស់បានប្រទានមកយើងចំពេលដែលយើងត្រូវការពីអ្នកបរិច្ចាគទាំងឡាយ ឬសេចក្តីពិតដ៏អស្ចារ្យដែលព្រះ

អង្គនៅតែស្មោះត្រង់ ហើយព្រះអង្គមិនអាចធ្វើផ្ទុយពីលក្ខណៈរបស់ផងទ្រង់បានឡើយ។ ប្រសិនបើយើងពិតជាទុកចិត្ត និងស្វែងរកទ្រង់ នោះយើងនឹងមិនត្រូវអាម៉ាស់នោះទេ។ ផ្ទុយទៅវិញ ការរកឃើញកាន់តែឆាប់ប្រសើរ ជាជាងការរកឃើញនៅពេលក្រោយថា មូលដ្ឋានគ្រឹះផ្សេងទៀតមិនគួរឲ្យទុកចិត្តនោះឡើយ។ ការពឹងផ្អែកលើប្រាក់បរិច្ចាគសម្រាប់អង្គការបេសកកម្មចិនដីគោក ឬក៏ម្ចាស់ជំនួយ ជំនួសឲ្យព្រះដ៏មានព្រះជន្មរស់គឺជាការជំនួសដ៏អន់មួយហើយ»។

នៅដើមឆ្នាំ១៨៧១ ការរងទុក្ខទាំងថ្ងៃ និងសេចក្តីងងឹតនៃបន្ទុកធ្ងន់បានចូលមកតាមរយៈការឈឺចាប់ខាងរូបកាយ។ លោកគ្រូ ហ៉ាដសិន បានរកឃើញថា បញ្ហាថ្លើមធ្ងន់ធ្ងរបានបណ្តាលឲ្យគាត់សម្រាន្តមិនលក់ ហើយធ្វើឲ្យមានការបាក់ទឹកចិត្តដ៏សែនឈឺចាប់ក្នុងព្រលឹងវិញ្ញាណគាត់។ ស្ថានភាពជំងឺរបស់គាត់កាន់តែធ្ងន់ធ្ងរឡើងៗ ដោយសារតែបញ្ហានៅលើដើមទ្រូង ដែលមិនត្រឹមតែបណ្តាលឲ្យមានការឈឺតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានធ្វើឲ្យគាត់ពិបាកដកដង្ហើមផងដែរ។ ខណៈពេលដែលវេលាចេះតែកន្លងផុតទៅ អារម្មណ៍នៃការបាត់បង់របស់គាត់មិនបានថមថយនោះឡើយ។ វាគឺជាអំឡុងពេលដ៏លំបាកនេះ ដែលគាត់បានទទួលកម្លាំង និងការយល់ថ្មីពីសេចក្តីសន្យា ដែលមានសារៈសំខាន់រួចទៅហើយសម្រាប់គាត់ «អ្នកណាដែលផឹកទឹកខ្ញុំឲ្យ»។ គំនិតនៃទម្លាប់បន្តបន្ទាប់ នៅក្នុងអត្ថបទក្រិកដើមបានបង្ហាញពីកិរិយាសព្ទបច្ចុប្បន្នកាលបានផ្តល់នូវអត្ថន័យថ្មីមួយចំពោះអត្ថបទគម្ពីរ ហើយបានបំពេញតម្រូវការអចិន្ត្រៃយ៍របស់គាត់។

លោកគ្រូ ហ៉ាដសិន បានលើកឡើងជាញឹកញាប់នៅជាច្រើនឆ្នាំក្រោយមកទៀតថា ចូរកុំផ្លាស់ប្តូរព្រះបន្ទូលព្រះអង្គសង្គ្រោះឡើយ។ វាមិនមែន «អស់អ្នកណាដែលធ្លាប់បានផឹក» ប៉ុន្តែ «អស់អ្នកណាដែលផឹក»។ ព្រះអង្គមិនបានមានបន្ទូលអំពីការផឹកតែម្តង ឬក៏ច្រើនដងនោះឡើយ ប៉ុន្តែជាទម្លាប់បន្តដែលៗខាងឯវិញ្ញាណ។ នៅក្នុងកណ្ឌគម្ពីរយ៉ូហាន ៦:៣៥ បានចែងថា៖ «ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំជាទម្លាប់ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ»។ ទម្លាប់នៃការចូលកាន់ព្រះជាម្ចាស់ដោយសេចក្តីជំនឿមិនកើតមានឡើងរួមជាមួយនឹង ការឃ្លាន និងស្រេកនោះឡើយ។

ជាញឹយៗ ខ្ញុំគិតថាយើងគិតខុសដោយឈប់ផឹក នៅពេលដែលយើងកំពុងតែស្រេក

នៅឡើយ។ ជំនួសវិញ យើងគួរតែបន្តផឹក ដោយដឹងគុណចំពោះគ្រប់ទាំងឱកាសនៅក្នុងការផឹកទឹករស់ឲ្យបានកាន់តែច្រើន។

ជំពូកទី១៦

# ភាពបរិបូរណ៍ហូរហៀរ

*ទូលបង្គំប្រគល់ជីវិតរបស់ទូលបង្គំទៅក្នុងព្រះហស្តដ៏ខ្លាំងពូកែរបស់ទ្រង់*
*ដើម្បីឲ្យកិច្ចការនឹងបានសម្រេច*
*ដ្បិត តើអ្នកណាអាចធ្វើការដ៏អស្ចារ្យទាំងនេះ*
*ដូចព្រះមួយអង្គដែលមានអំណាចព្រះចេស្ដាបាន?*

លោកគ្រូ ហ៍ដសិន នៅសល់សាមសិបឆ្នាំដ៏មមាញឹកក្នុងនាមជានាយកប្រតិបត្តិរបស់អង្គការបេសកកម្មនៅចិនដីគោក មុនពេលដែលគាត់បានលាឈប់ ហើយឥឡូវនេះជាងសាមសិបឆ្នាំបានកន្លងផុតទៅហើយ។ រយៈកាលហុកសិបឆ្នាំនេះ ស្មើនឹងអាយុមនុស្សពីរជំនាន់ បានផ្ដល់ពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការវាយតម្លៃលទ្ធផលសេចក្ដីជំនឿ និងសេចក្ដីអំណរក្នុងព្រះជាម្ចាស់ ដែលបានសង់គ្រឹះនៃជីវិតគាត់។ ប្រសិនបើបទពិសោធន៍ដែលយើងបានតាមដានគ្រាន់តែជាអារម្មណ៍បណ្ដោះអាសន្ន និងមិនបានផ្អែកទៅលើការពិត ប្រសិនបើវាគ្រាន់តែជាខាងឯវិញ្ញាណតែមិនបានប្រែក្លាយទៅជាការអនុវត្ត ហើយប្រសិនបើព្រះជាម្ចាស់មិនគ្រប់គ្រាន់សម្រាប់ការបំពេញតម្រូវការនៃព្រះរាជកិច្ចទ្រង់ដោយគ្មានជំនួយខាងហិរញ្ញវត្ថុ និងជំនួយរបស់មនុស្សទេ នោះការសាកល្បងនៃពេលវេលានឹងបានបង្ហាញថា ការទាំងនេះគ្រាន់តែជាដំណើរនៃការភ័ន្តច្រឡំខាងឯវិញ្ញាណប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ប្រសិនបើលោកគ្រូ ហ៍ដសិន ថេល័រ ពិតជាបានរកឃើញនូវអាថ៌កំបាំងនៃអំណាច និងព្រះពរតាមរយៈការរស់នៅ គឺរស់រួបរួមនឹងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ទោះជាគាត់មានចំណុចខ្វះខាតក្ដីក៏នោះលទ្ធផលនៃការទ្រាំទ្រ

គឺជាទីបន្ទាល់ចំពោះសេចក្តីពិតនេះគ្រប់ពេលវេលា។

ព្រះទ្រង់អាចធ្វើបានគ្រប់ការទាំងអស់ ដ្បិតព្រះគ្រីស្ទដែលជាអ្នកតំណាងអំណាចនៃព្រះនៅក្នុងភាពជាមនុស្ស ហើយសម្រាប់ខ្ញុំនៅពេលដែលខ្ញុំកែប្រែថ្មីឡើងវិញទាំងស្រុងក្នុងព្រះគ្រីស្ទ និងបានរំដោះពីការគ្រប់គ្រងពីអំពើបាប នោះខ្ញុំអាចនឹងធ្វើបានគ្រប់ការទាំងអស់ដែរ។

នៅឆ្នាំ១៨៧០ គឺជាអំឡុងពេលដ៏លំបាកៈ លោកគ្រូ ហ័ដសិន ថេល័រ គឺជាបុរសក្មេងម្នាក់ក្នុងវ័យជាងសាមសិបឆ្នាំដោយអង្គការបេសកកម្មចិនដីគោកមានសមាជិកត្រឹមតែសាមសិបបីនាក់ប៉ុណ្ណោះ។ ពួកគាត់តាំងស្ថានីយនៅក្នុងខេត្តចំនួនបី ហើយបានបង្កើតក្រុមជំនុំតូចៗពី១០ទៅ១២ក្រុមជំនុំជាមួយនឹងអ្នកប្រែចិត្តជឿមួយចំនួន។ ទោះបីជាដំណើរការនោះនៅតូចនៅឡើយក្តី ក៏ទំនួលខុសត្រូវធំដែរ ជាពិសេសសម្រាប់មនុស្សម្នាក់ដែលបាននឿយហត់ពីការធ្វើព័ន្ធកិច្ចប្រាំឆ្នាំនៅប្រទេសចិន។

ច្បាស់ណាស់ថា នៅចុងឆ្នាំ១៨៧១ លោក និងលោកស្រី ប៊ើកហ្គ័រ មិនអាចបន្តកិច្ចប្រឹងប្រែងរបស់ពួកគាត់ក្នុងការមើលខុសត្រូវលើការងារក្នុងស្រុករបស់អង្គការបេសកកម្មចិនដីគោកបានទៀតទេ ដោយសារតែបញ្ហាសុខភាពចុះខ្សោយ ដែលបានតម្រូវឲ្យពួកគាត់ត្រូវទៅរស់នៅបរទេសនៅរដូវរងា។ ពួកគាត់ត្រូវតែលក់មជ្ឈមណ្ឌលដែលមានទីតាំងនៅសេនធ៍ហៀល ហើយមានម្នាក់ទៀតត្រូវចូលមកកាន់កាប់រាល់ការគ្រប់គ្រងទំនួលខុសត្រូវដែលមានទាំង ការឆ្លើយឆ្លង គណនេយ្យ កិច្ចការវិចារណកថា ការធ្វើតេស្តបេក្ខជនថ្មី និងការគ្រប់គ្រងកិច្ចការជាក់ស្តែង។ ចំណងសេចក្តីស្រឡាញ់ដោយសេចក្តីអាណិតអាសូរនៅតែរឹងមាំដដែល ប៉ុន្តែលោកគ្រូ ហ័ដសិន ស្ទើរតែទទួលអារម្មណ៍កណ្តោចកណ្តែងនៅពេលដែលគាត់បានទទួលយកនូវទំនួលខុសត្រូវ ដែលបានតម្រូវឲ្យគាត់ត្រូវស្នាក់នៅប្រទេសអង់គ្លេសមួយរយៈនោះមក។

សេនធ៍ ហៀល ពិតជាខុសគ្នាច្រើនពីមជ្ឈមណ្ឌលថ្មីនៅផ្លូវផាយឡែនដ៍ (Pyrland Road) ជាផ្លូវតូចជាយក្រុងនៅក្នុងឡុនដុនខាងជើង ហើយការរើពីបណ្ណាល័យលោកគ្រូ ប៊ើកហ្គ័រ ទៅបន្ទប់តូចខាងក្រោយ ដោយប្រើទាំងជាបន្ទប់សិក្សា និងការិយាល័យក៏ស្មើនឹងការផ្លាស់ប្តូរដ៏ធំផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ មនុស្សជាច្រើនរីករាយនឹងការចងចាំផ្ទះ «លេខប្រាំមួយ ហើយផ្ទះនៅជាប់វា ដែលត្រូវបានទិញតាមតម្រូវការដែល

កើតឡើង។ អស់រយៈពេលជាងម្ភៃឆ្នាំ ផ្ទះបេសកកម្មរបស់អង្គការបេសកកម្មចិនដីគោក បានដំណើរការពីមជ្ឈមណ្ឌលនេះ វានៅតែប៉ុន្មានជំហានពីការិយាល័យកណ្តាលបច្ចុប្បន្នប៉ុណ្ណោះ។ ការប្រជុំអធិស្ឋានប្រចាំសប្តាហ៍ បានប្រព្រឹត្តទៅនៅបន្ទប់ជាន់ផ្ទាល់ដី ដោយបន្ទប់ពីរបានបើកទ្វារ ហើយមានក្រុមប្តេជ្ញាចិត្តជាច្រើនដូចជា "ក្រុមចិតសិប" និង "ក្រុមមួយរយ" បានចាប់ផ្តើមពីទីនោះទៅ។ ប៉ុន្តែ នេះគឺជាការចាប់ផ្តើមទៅមុខដោយបន្ទាបខ្លួននៅដើមឆ្នាំ១៨៧២ ក្នុងកាលដែលលោកគ្រូ ហ៉ាដសិន តែម្នាក់ឯងបានមើលខុសត្រូវ និងបានតម្រង់ការងារនៅក្នុងអង្គការបេសកកម្មចិនដីគោក។

នៅដើមឆ្នាំនោះលោកគ្រូ ហ៉ាដសិន បានសរសេរថា "ផ្លូវរបស់ខ្ញុំមិនងាយស្រួលនោះទ្បើយ។ ខ្ញុំមានអារម្មណ៍កាន់តែមានអំណរនៅក្នុងព្រះយេស៊ូវជាងពេលណាៗទាំងអស់ ហើយខ្ញុំជឿជាក់ថា ទ្រង់នឹងមិនធ្វើឲ្យយើងខកចិត្តនោះទ្បើយ។ យើងបានផ្អែកលើទ្រង់កាន់តែខ្លាំងជាជាង តាំងពីព័ន្ធកិច្ចនៃអង្គការបេសសកកម្មចិនដីគោកបានចាប់ផ្តើម។ ការពឹងផ្អែកនេះ ប្រហែលសម្រាប់ជាការល្អបំផុត។ ឧបសគ្គទាំងឡាយបានផ្តល់ឱកាសមួយដល់ទ្រង់ ដើម្បីបង្ហាញអំពីអំណាចព្រះចេស្តារបស់ព្រះអង្គ។ បើគ្មានឧបសគ្គនោះទេ យើងពិតជាមិនអាចយល់បានទេថា ព្រះជាម្ចាស់ដ៏ជាព្រះរបស់យើងទ្រង់ទន់ភ្លន់ ស្មោះត្រង់ និងមានអំណាចព្រះចេស្តាប៉ុណ្ណាទ្បើយ។ ការផ្លាស់ប្តូរទាក់ទងនឹងលោក និងលោកស្រី បើកហ្គ័រ គឺជាការលំបាកណាស់សម្រាប់ខ្ញុំ។ ប៉ុន្តែ ខ្ញុំចូលចិត្តការលំបាកទាំងនោះ! វាមានអារម្មណ៍ថា ដូចជាការភ្ជាប់ទៅនឹងអតីតកាលរបស់ខ្ញុំត្រូវបានកាត់ផ្តាច់អញ្ចឹង ដែលបានរួមបញ្ចូលទាំងការស្លាប់របស់មនុស្សជាទីស្រឡាញ់របស់ខ្ញុំ ដែលខ្ញុំតែងតែនឹករលឹកដល់ជាញឹកញាប់។ យ៉ាងណាមិញ ព្រះអង្គមានព្រះបន្ទូលថា៖ "មើល អញធ្វើទាំងអស់ទ្បើងជាថ្មី" ដែរ"។

លោកគ្រូ ហ៉ាដសិន ច្បាស់ជាបានដឹងហើយថា វាពិបាកណាស់នៅក្នុងការបង្ខាំងខ្លួនឯងឲ្យធ្វើការក្នុងការិយាល័យ នៅពេលដែលគាត់ប្រាថ្នាចង់ឲ្យការងារព័ន្ធកិច្ចដ៏សម្បើមនៃអង្គការបេសកកម្មចិនដីគោកឲ្យកាន់តែរីកចម្រើនទៅមុខ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយអាទិត្យទៅមួយអាទិត្យ ហើយគាត់មិនប្រញាប់ប្រញាល់នៅក្នុងការចាប់ផ្តើមការរៀបចំគម្រោងថ្មី ដោយមិនមានការបញ្ជាក់គ្រប់គ្រាន់ចំពោះអ្វីដែលព្រះអម្ចាស់បានសព្វព្រះហឫទ័យឲ្យគាត់ធ្វើនោះទ្បើយ។ គាត់បានអធិស្ឋានសម្រាប់ពួកអ្នកជំនួយដ៏ស័ក្តិសម

ប៉ុន្តែវាហាក់បីដូចជាគ្មានការឆ្លើយតបសោះ ហើយកិច្ចការរបស់គាត់បានរារាំងគាត់ពីការចូលរួមនឹងអ្វីដែលគាត់បានគិតថា កាន់តែសំខាន់។ គាត់ប្រហែលជាមានអារម្មណ៍ថាគ្មានការអត់ធ្មត់ ឬបាក់ទឹកចិត្ត។ ប៉ុន្តែ គាត់នៅតែព្យាយាមបន្តប្រាប់នូវមេរៀនខ្លះៗ ដែលគាត់កំពុងតែរៀនទៅដល់នរណាម្នាក់ប្រឈមមុខនឹងឧបសគ្គស្រដៀងគ្នានឹងគាត់ដែរ។

មេរៀននោះកម្សាន្តចិត្តខ្ញុំជាពន់ពេកដោយដឹងថា ព្រះជាម្ចាស់បានជ្រើសរើសកិច្ចការដែលខ្ញុំត្រូវធ្វើសម្រាប់ខ្ញុំ ដោយដាក់ខ្ញុំនៅកន្លែងដែលខ្ញុំកំពុងតែឈរនៅពេលនេះ។ ខ្ញុំមិនបានស្វែងរកមុខតំណែងនេះទេ ហើយខ្ញុំក៏មិនហ៊ានបោះបង់វាចោលដែរ។ ទ្រង់ជ្រាបអំពីមូលហេតុដែលដាក់ខ្ញុំនៅទីនេះ—ដើម្បីឲ្យធ្វើអ្វីមួយ រៀនពីអ្វីមួយ ឬក៏ទ្រាំទ្រនឹងការលំបាកទាំងឡាយដែរ។ «ឯអ្នកណាដែលជឿ នោះមិនត្រូវរួសរាន់ឡើយ»។ ការរៀនអំពីការនេះ វាក៏មិនងាយស្រួលសម្រាប់អ្នកណាម្នាក់ក្នុងចំណោមយើងដែរ ប៉ុន្តែខ្ញុំពិតជាជឿថា ការចំណាយពេលដប់ឆ្នាំនៅក្នុងការចាប់យកមេរៀននេះនឹងស័ក្តិសមនឹងតម្លៃរបស់វា...លោក ម៉ូសេ ហាក់បីដូចជាបានចំណាយពេលសែសិបឆ្នាំ ដើម្បីរៀនមេរៀនដូចគ្នានេះដែរ...ស្របពេលជាមួយគ្នាដែរ យើងគួរតែជៀសវាងពីភាពប្រញាប់ប្រញាល់នៃអាកប្បកិរិយាដែលគ្មានការអត់ធ្មត់ និងតក់ក្រហល់ ក៏ដូចជាលទ្ធផលនៃការខកចិត្ត និងការអស់កម្លាំងផងដែរ។

ជីវិតដែលដាក់កំហិតនេះ បានបង្កើតផលផ្លែ ដោយសារតែការភ្ជាប់ទំនាក់ទំនងដោយស្មោះត្រង់ចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយវាគួរឲ្យចាប់អារម្មណ៍ក្នុងការឃើញមនុស្សក្មេងៗ ជាពិសេសបានឆ្លើយតបចំពោះឥទ្ធិពលរបស់វា។ បុរសវ័យក្មេងមានប្រាជ្ញាឈ្លាសវៃម្នាក់នៅទីក្រុងឡុងដ៍  បានប្ដេជ្ញាចិត្តចំពោះព្រះអម្ចាស់ ហើយចង់ចាប់យកឱកាសសម្រាប់កិច្ចការនានានៃជីវិតរបស់គាត់នៅឯប្រទេសចិន។ គាត់បានធ្វើដំណើរទៅផាយទ្បែនដ៍ រ៉ូដ ហើយបានចូលទៅក្នុងបន្ទប់ដែលបានតុបតែងយ៉ាងសាមញ្ញមួយ ជាកន្លែងដែលមនុស្សកំពុងជួបប្រជុំគ្នា ដើម្បីជំនុំអធិស្ឋាន។

គាត់បាននឹកចាំអំពីអក្សរធំៗនៅទល់មុខមាត់ទ្វារ ដែលយើងបានចូលថា៖ «ព្រះនៃខ្ញុំទ្រង់នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការ» (ភីលីព ៤:១៩)។ ដោយសារតែខ្ញុំមិនទម្លាប់នឹងការឃើញអក្សរតាំងនៅជញ្ជាំងបែបនោះ វាបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង។ មានមនុស្សចន្លោះពី១២ទៅ២០នាក់បានចូលរួម។

លោកគ្រូ ហ័ដសិន បានចាប់ផ្តើមការប្រជុំដោយជ្រើសរើសបទចម្រៀងសរសើរតម្កើងមួយបទ ដោយអង្គុយនៅមុខអាម៉ូនីញ៉ូម (“harmonium” ឧបករណ៍ភ្លេងម្យ៉ាងស្រដៀងនឹងព្យាណូ) ហើយបានដឹកនាំការច្រៀងសរសើរតម្កើង។ រូបរាងគាត់មិនបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះឡើយ។ គាត់មានរាងស្តើង ហើយមានសម្លេងស្រទន់។ ដូចយុវជនវ័យក្មេងជាច្រើន ខ្ញុំប្រហែលគិតថា អំណាចស្មើនឹងសម្លេងខ្លាំង ហើយបានរំពឹងថាអ្នកដឹកនាំម្នាក់ត្រូវតែបង្ហាញពីការបង្គាប់បញ្ជា។ ទោះជាយ៉ាងណាក៏ដោយ នៅពេលគាត់បាននិយាយថា៖ «សូមអធិស្ឋាន» ហើយបានចាប់ផ្តើមដឹកនាំអធិស្ឋាន គំនិតខ្ញុំបានចាប់ផ្តើមផ្លាស់ប្តូរ។ ខ្ញុំមិនធ្លាប់ឮនរណាម្នាក់អធិស្ឋានរបៀបនេះសោះ។ ការអធិស្ឋានមានភាពសាមញ្ញ ទន់ភ្លន់ ក្លាហាន ព្រមទាំងមានអំណាច ការអធិស្ឋាននោះបានធ្វើឲ្យខ្ញុំស្ងាត់ និងបានបន្ទាបខ្ញុំចុះ ដោយបានបង្ហាញយ៉ាងច្បាស់ថា ព្រះជាម្ចាស់រាប់គាត់ទុកជាមិត្តសម្លាញ់របស់ផងទ្រង់។ ការអធិស្ឋានបែបនេះ ច្បាស់ណាស់កើតចេញពីការចំណាយពេលស្ងៀមស្ងាត់ច្រើនតែម្នាក់ឯងជាមួយនឹងព្រះជាម្ចាស់ ហើយទទួលអារម្មណ៍ថាដូចជាទឹកសន្សើមថ្មីៗដែលមកពីព្រះយេហូវ៉ាអញ្ចឹង។

តាំងពីពេលនោះមក ខ្ញុំបានឮមនុស្សជាច្រើនអធិស្ឋាននៅទីសាធារណៈ ប៉ុន្តែការអធិស្ឋានរបស់លោកគ្រូ ហ័ដសិន និងការអធិស្ឋានរបស់លោកគ្រូ ស្ពើចិន (Mr. Spurgeon) គឺមានចំណុចពិសេសណាស់។ អ្នកដែលបានឮការអធិស្ឋានរបស់ពួកគាត់នឹងមិនអាចភ្លេចបានទេ។ ការស្តាប់លោកគ្រូ ស្ពើចិន អធិស្ឋានគឺជាបទពិសោធន៍មួយក្នុងជីវិត នៅពេលគាត់ហាក់បីដូចជាក្តោបក្តាប់ពួកជំនុំចំនួនប្រាំមួយពាន់នាក់ដោយដៃ ហើយដឹកនាំពួកគេចូលទៅកាន់ទីបរិសុទ្ធ។ ការស្តាប់លោកគ្រូ ហ័ដសិន ទូលអង្វរសម្រាប់ប្រទេសចិនធ្វើឲ្យលោកអ្នកយល់ពីអត្ថន័យដ៏ពិតនៃខគម្ពីរ «ដ្បិតសេចក្តីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់» (យ៉ាកុប ៥:១៦)។ ការប្រជុំមានរយៈពេលពីម៉ោង៤ដល់ម៉ោង៦ ប៉ុន្តែវាមានអារម្មណ៍ថា ដូចជាការប្រជុំអធិស្ឋានដ៏ខ្លីបំផុតតាមដែលខ្ញុំធ្លាប់ចូលរួម។

មាននារីដែលមានការអប់រំល្អ និងប្រណិតពីភាគខាងលិចនៃប្រទេសអង់គ្លេសបានមកដល់ទីក្រុងឡុងដ៍ ដើម្បីចូលរួមសន្និបាតម៉ាលដ៍មេយ៍ (Mildmay Conference) ហើយបានស្នាក់នៅក្នុងនាមជាភ្ញៀវម្នាក់នៅផ្លូវផាយឡែនដ៍។ នាងបានស្តាប់ការថ្លែង

សុន្ទរកថាបើករបស់លោកគ្រូ ហ័ដសិន ទៅកាន់បណ្តាជនចំនួនពីរទៅបីពាន់នាក់នៅក្នុងសាលដ៏ធំ ហើយបានសង្កេតពីឥទ្ធិពលរបស់គាត់លើគោលគំនិតអ្នកដឹកនាំគ្រីស្ទបរិស័ទ។ ទោះជាយ៉ាងណាក្តី ក៏ជីវិតប្រចាំថ្ងៃនៅក្បែរផ្ទះព័ន្ធកិច្ចរបស់អង្គការបេសកកម្មចិនដីគោក ដែលជាកន្លែងដែលគាត់ប្រឈមនឹងឧបសគ្គដោយអំណរ ហើយលីបន្ទុកនោះដោយសេចក្តីជំនឿ បានធ្វើឲ្យនាងចាប់អារម្មណ៍យ៉ាងខ្លាំងបំផុត។

កញ្ញា សូលតូ (Miss Soltau) បានសរសេរថា នាងបានចាំថា “លោកគ្រូ ហ័ដសិន កំពុងទទូចពួកគេឲ្យនៅស្ងាត់នៅក្នុងចំណោមអ្នកដទៃទៀត ដើម្បីតែទំនាក់ទំនងតម្រូវការរបស់ពួកគាត់ជាមួយព្រះជាម្ចាស់”។ ថ្ងៃមួយ បន្ទាប់ពីពិសារអាហារពេលព្រឹកបន្តិចបន្តួចរួចមក ដោយស្ទើរតែមិនសល់អ្វីសោះសម្រាប់អាហារពេលល្ងាច នាងរំភើបយ៉ាងខ្លាំងដែលបានឮលោកគ្រូ ហ័ដសិន ច្រៀងបទសរសើរតម្កើងសម្រាប់កុមារ។

“ព្រះយេស៊ូវស្រឡាញ់ខ្ញុំណាស់ គម្ពីរប្រាប់ឲ្យដឹងជាក់ច្បាស់”។

បន្ទាប់មក គាត់បាននាំយើងឲ្យសរសើរតម្កើងព្រះអម្ចាស់ចំពោះសេចក្តីស្រឡាញ់មិនប្រែប្រួលរបស់ទ្រង់ ដើម្បីចែកចាយតម្រូវការរបស់យើង ហើយសំអាងលើសេចក្តីសន្យារបស់ទ្រង់។ មុនពេលថ្ងៃលិច យើងកំពុងតែមានអំណរចំពោះការឆ្លើយតបដ៏សប្បុរសនានារបស់ទ្រង់។

បន្ទាប់ពីលោកគ្រូ បើកហ្គ័រ បានចូលនិវត្តន៍ នោះប្រាក់រ៉ៃអង្គាសកាន់តែខើចទៅៗ ហើយលោកគ្រូ ហ័ដសិន ក៏កាន់តែតាំងចិត្តមោះមុតជាងពេលណាៗទាំងអស់ ដើម្បីឲ្យកិច្ចការអាចដំណើរការទៅបាន។ ថ្ងៃមួយ នៅផ្លូវដាយឡែនដ៍ ខណៈពេលដែលគាត់កំពុងឈរនៅខាងមុខផែនទីនៃប្រទេសចិន គាត់បានបែរទៅសម្លាញ់ពីរបីនាក់ ហើយនិយាយថា៖

“តើបងប្អូនមានសេចក្តីជំនឿក្នុងការចូលរួមជាមួយខ្ញុំ ហើយអធិស្ឋានទៅកាន់ព្រះជាម្ចាស់សម្រាប់ឲ្យមានមនុស្សប្រុសដប់ប្រាំបីនាក់ទៀត ដើម្បីចាប់ដៃគ្នាជាគូៗចេញទៅកាន់ខេត្តទាំងប្រាំបួនដែលដំណឹងល្អមិនទាន់ទៅដល់ដែរឬទេ?”

កញ្ញា សូលតូ ជាសមាជិកម្នាក់ក្នុងក្រុម ហើយនៅតែនឹកចាំពីការដែលពួកគាត់បានកាន់ដៃគ្នាព័ទ្ធជុំវិញផែនទី ដោយប្តេជ្ញាចិត្តអធិស្ឋានរៀងរាល់ថ្ងៃសម្រាប់អ្នកផ្សាយដំណឹងល្អដែលពួកគាត់ត្រូវការទាំងដប់ប្រាំបីនាក់ រហូតដល់ព្រះជាម្ចាស់ផ្តត់ផ្គង់អ្នកទាំងនោះមក។ គ្មានការសង្ស័យអំពីសេចក្តីជំនឿរបស់ពួកគេទេ។ ប៉ុន្តែ ពួកគាត់មិនដឹង

អំពីការពង្រីកកាន់តែធំ ដែលបម្រុងនឹងកើតមាននោះឡើយ។ តួនាទីសំខាន់របស់កញ្ញា សូលតូ នឹងដើរនៅក្នុងការអភិវឌ្ឍន៍អង្គការបេសកកម្មចិនដីគោក ឬក៏ការចូលរួមដែលមានលក្ខណៈពិសេសរបស់លោក អេហ្វ. ដឹបបលយូ. បលល័រ (F. W. Baller) ជាបុរសវ័យក្មេងដែលមានប្រាជ្ញាឈ្លាសវៃម្នាក់បានលើកឡើងពីខាងដើមនោះ នឹងចូលរួមជាមួយគាត់។ នៅពេលនេះ ពួកគាត់ទាំងពីរនាក់បានចូលមកក្នុងព័ន្ធកិច្ច ដោយសារឥទ្ធិពលដោយប្រយោលនៃជីវិតរបស់លោកគ្រូ ហ័ដសិន។

ពេលវេលានៃការរង់ចាំបានបង្កើតផលផ្លែ ហើយនៅពេលលោកគ្រូ ហ័ដសិន អាចត្រឡប់ទៅប្រទេសចិនវិញ គាត់បានបង្កើតក្រុមប្រឹក្សានៃមិត្តដែលទុកចិត្តបាននៅក្នុងទីក្រុងឡុងដ៍ ហើយបានទុកឲ្យកញ្ញា ប្លេតឆ្លេយ៍ នៅមើលថែរក្សាផ្ទះសំបែង និងកូនៗនៅផ្លូវផាយទ្បែនដ៍។ គាត់បានប្រគល់ប្រាក់បន្តិចបន្តួចទៅលេខាធិការដ៏មានកិត្តិយស—ត្រឹមតែម្ភៃមួយផោន (ស្មើនឹង $៣.៩៧០,០០ ដុល្លារ បច្ចុប្បន្ន)។ ទោះជាយ៉ាងនេះក្តី ក៏ពួកគាត់មិនមានជំពាក់អ្នកណាដែរ ហើយលោកគ្រូ ហ័ដសិន បានសរសេរសំបុត្រដោយមានទំនុកចិត្តទៅកាន់អ្នកឧបត្ថម្ភអង្គការបេសកកម្មចិនដីគោកផ្សេងៗទៀត។

នៅពេលដែលកិច្ចការយើងកាន់តែរីកចម្រើនឡើង យើងត្រូវការអ្នកជួយបន្ថែមទៀតទាំងនៅស្រុកកំណើត និងនៅបរទេស ប៉ុន្តែវិធីសាស្ត្រយើងក៏នៅតែមិនផ្លាស់ប្តូរដែរ។ យើងនឹងបន្តទូលសូមព្រះជាម្ចាស់សម្រាប់ជំនួយខាងផ្នែកហិរញ្ញវត្ថុបន្ថែមទៀតតាមរយៈការអធិស្ឋាន។ ទ្រង់នឹងជំរុញចិត្តដល់អ្នកដែលទ្រង់បានរើសឲ្យបម្រើធ្វើជាអ្នកផ្តល់ជំនួយខាងហិរញ្ញវត្ថុរបស់ផងទ្រង់។ កាលណាយើងមានប្រាក់រែអង្គាស យើងនឹងផ្ញើវាទៅកាន់ប្រទេសចិន ហើយកាលណាយើងគ្មានប្រាក់រែអង្គាស យើងនឹងមិនផ្ញើអ្វីទៅទេ ហើយយើងក៏មិនខ្ចីប្រាក់អ្នកណាដែរ ដោយជៀសវាងមានការជំពាក់បំណុលគេ។ ប្រសិនបើព្រះសាកល្បងសេចក្តីជំនឿរបស់យើងដូចពីមុន នោះព្រះអម្ចាស់នឹងសម្តែងសេចក្តីស្មោះត្រង់របស់ទ្រង់ជានិច្ច។ បើទោះបីជា សេចក្តីជំនឿរបស់យើងអន់ថយចុះក៏ដោយ ក៏សេចក្តីស្មោះត្រង់របស់ទ្រង់មិនថយចុះដែរ ដូចមានសេចក្តីចែងទុកមកថា៖ “បើទុកជាយើងមិនស្មោះត្រង់ក៏ដោយ គង់តែទ្រង់នៅស្មោះត្រង់ដដែល” (២ធីម៉ូថេ ២:១៣)។

អ្នកដឹកនាំនៃអង្គការបេសកកម្មចិនដីគោកត្រូវការទំនុកចិត្តរបស់គាត់ច្រើនជាងពេលណាៗទាំងអស់ នៅពេលដែលគាត់បានត្រឡប់ទៅប្រទេសចិនវិញ បន្ទាប់ពីមិនបានទៅ

អស់រយៈពេល១៥ខែ។ ជំងឺ និងឧបសគ្គផ្សេងៗទៀតបានធ្វើឲ្យមនុស្សមួយចំនួននៅមជ្ឈមណ្ឌលចាស់នៅក្នុងខេត្តនៃប្រទេសចិនមានការបាក់ទឹកចិត្តចំពោះកិច្ចការបម្រើព្រះជាម្ចាស់។ ក្រុមជំនុំតូចៗកំពុងតែជួបការលំបាក ទីតាំងបេសកកម្មមួយចំនួនខ្វះខាតបុគ្គលិកធ្វើការ ខ្លះបានបិទទ្វារ ដោយបន្សល់ឲ្យលោកគ្រូ ហ័ដសិន មិនប្រាកដថា គួរតែចាប់ផ្តើមផ្តល់ជំនួយចាំបាច់ និងការលើកទឹកចិត្តពីកន្លែងណាទៅមុនឡើយ។ ជាជាងការរៀបគម្រោងពង្រីកព័ន្ធកិច្ចទៅកាន់ខេត្តដែលដំណឹងល្អមិនទាន់ទៅដល់ គាត់គ្រាន់តែផ្តោតទៅលើការពង្រឹងការងារដែលមានស្រាប់។ ជាប្រយោជន៍ដល់ការកម្សាន្តចិត្តគាត់ គាត់មានដៃគូដែលភក្តី ដែលព្រះជាម្ចាស់បានប្រទានមកក្នុងជីវិតរបស់គាត់។ កញ្ញា ហ្វូលឌីង (Faulding) គឺជាអ្នកដឹកនាំគួរឲ្យស្រឡាញ់នៃព័ន្ធកិច្ចស្ត្រីនៅក្នុងស្រុកហាងចូវ បានក្លាយជាប្រពន្ធទីពីររបស់គាត់ ហើយបានចាប់ផ្តើមព័ន្ធកិច្ចដែលនៅក្បែរគាត់ដោយមិនបានគិតពីខ្លួនឯង ហើយអស់រយៈពេលសាមសិបបីឆ្នាំបានធ្វើឲ្យសមាជិកទាំងមូលនៃអង្គការបេសកកម្មចិនដីគោកស្រឡាញ់គាត់។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគាត់ពីរនាក់ត្រូវនៅឆ្ងាយពីគ្នាញឹកញាប់ដែរ។ នៅអំឡុងរដូវរងាពេញដោយព្រិលយ៉ាងក្រាស់ក្រាលនៅលើដី លោកគ្រូ ហ័ដសិន បានធូរចិត្តដោយប្រពន្ធរបស់គាត់មិនបានធ្វើដំណើរដ៏លំបាកនានាដែលគាត់ត្រូវធ្វើ ដែលជាញឹកញាប់ ការធ្វើដំណើរនោះជួបការលំបាកយ៉ាងខ្លាំង។

ខ្ញុំបានអញ្ជើញសមាជិកក្រុមជំនុំ និងអ្នកដែលចង់ដឹងអំពីព្រះជាម្ចាស់ឲ្យប្រកបអាហារពេលល្ងាចជាមួយខ្ញុំនៅថ្ងៃស្អែក។ ខ្ញុំចង់ឲ្យពួកគេទាំងអស់គ្នាបានជួបគ្នា។ សូមឲ្យព្រះអម្ចាស់ប្រទានពរដល់យើងគ្រប់គ្នា។ បើទោះបីជាអ្វីៗហាក់បីដូចជាកំពុងបាក់ទឹកចិត្តក៏ដោយ ក៏យើងនៅមានសង្ឃឹមដែរ ដោយព្រះពររបស់ព្រះជាម្ចាស់ ព្រមទាំងការយកចិត្តទុកដាក់មួយចំនួន នោះកិច្ចការទាំងឡាយនឹងបានរីកចម្រើននៅពេលឆាប់ៗនេះ។

សេចក្តីជំនឿរបស់លោក ហ័ដសិន បានបង្ហាញជាក់ច្បាស់ដោយគោលជំនឿរបស់គាត់ដែលថា «ដោយព្រះពររបស់ព្រះជាម្ចាស់ នោះអ្វីៗនឹងបានរីកចម្រើនឡើងពេលឆាប់ៗនេះប្រសិនបើយើងថែរក្សាវា»។ គាត់បានទទួលយកកិច្ចការដ៏លំបាកបំផុតសម្រាប់ខ្លួនគាត់ដោយពឹងផ្អែកលើអំណាចដ៏មានកម្លាំងរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយដោះស្រាយនឹងបញ្ហាដោយការអធិស្ឋាន និងការអត់ធ្មត់ ដែលបានជំរុញអ្នកប្រែចិត្តជឿ និងបេសកជន

មានចិត្តខ្នះខ្នែងគ្រប់ជំពូក។ ដោយមានលោកស្រី ថេល័រ ចូលរួមជាមួយគាត់នៅជ្រលងយ៉ាងជឺ គាត់បានចំណាយពេលបីខែនៅទីក្រុងណាងឃីង (បច្ចុប្បន្នណានជីង) ដោយបានលះបង់ពេលវេលាជាច្រើនចំពោះការផ្សាយដំណឹងល្អផ្ទាល់។

គាត់បានសរសេរមកពីទីក្រុងណាងឃីងថា៖ រាល់យប់ យើងបានទាក់ទាញហ្វូងមនុស្សយ៉ាងច្រើនជាមួយនឹងរូបភាព ព្រមទាំងផ្ទាំងរូបភាពគោម ហើយប្រាប់ពួកគេអំពីព្រះយេស៊ូវ។ យប់មិញ យើងមានមនុស្សប្រាំរយនាក់មកចូលរួមនៅកន្លែងថ្វាយបង្គំ។ អ្នកខ្លះនៅរយៈពេលខ្លី ស្របពេលដែលអ្នកខ្លះទៀតនៅទីនោះជិតបីម៉ោង។ សូមឲ្យព្រះអម្ចាស់ប្រទានពរដល់ពេលវេលានៅទីនេះ ដើម្បីជាប្រយោជន៍ដល់មនុស្សជាច្រើន។ រាល់រសៀល ពួកស្ត្រីៗមកសួរសុខទុក្ខ ហើយស្ដាប់ព្រះបន្ទូល។

លោកអ្នកនឹងយល់បានអំពីគំនិតមួយនៃកម្លាំងខាងក្នុងរបស់នាងតាមរយៈសំណួរមួយ ដែលនាងបានសួរទៅកញ្ញា ប្លេតឆ្លេយ៍ នៅក្នុងសំបុត្រមួយច្បាប់៖

“ប្រសិនបើលោកអ្នកធ្លាប់ផឹកពីប្រភពទឹកដ៏រស់ តើអ្វីដែលអាចនឹងធ្វើឲ្យជីវិតរបស់លោកអ្នកពេញបរិបូរណ៍ហូរហៀរបាន? ចម្លើយគឺ៖ ព្រះយេស៊ូវ ព្រះយេស៊ូវ ព្រះយេស៊ូវ!”

នៅក្នុងន័យនេះ គាត់បានកាន់ពែងមួយយ៉ាងពេញ ហើយសេចក្ដីពេញបរិបូរណ៍ជាអ្វីដែលយើងពិតជាត្រូវការ។ ការសួរសុខទុក្ខសមាជិកនៃអង្គការបេសកកម្មចិនដីគោកបានធ្វើឲ្យសម្រេចគោលបំណងពួកគេ ហើយបានបន្តរហូតដល់លោកគ្រូ ហ៍ដសិន បានទៅគ្រប់ស្ថានីយទាំងអស់ ព្រមទាំងកន្លែងនៅក្រៅពីស្ថានីយនៅក្នុងអង្គការបេសកកម្មយ៉ាងហោចណាស់មួយដង។ ដោយមិនទាន់ស្កប់ចិត្ត គាត់បានជួបជាមួយនឹងអ្នកដឹកនាំជនជាតិចិននៅកន្លែងនីមួយៗ ដូចជាពួកអ្នកផ្សាយដំណឹងល្អ អ្នកចែកចាយព្រះគម្ពីរ គ្រូបង្រៀន ព្រមទាំងពួកស្ត្រីដែលបានបង្រៀនព្រះគម្ពីរ ពួកគាត់បានទទួលជំនួយផ្ទាល់ខ្លួនពីគាត់ស្ទើរតែគ្មានការរើសមុខ។ នៅពេលដែលពួកគេនៅជាមួយគ្នា ទាំងជំនួយលោកស្រី ថេល័រ ធំធេងមិនអាចកាត់ថ្លៃបានទេ ហើយជាញឹកញាប់ពួកគាត់ក៏បានធ្វើការឆ្លើយតបសំបុត្ររហូតដល់យប់ជ្រៅ។ នៅក្នុងដំណើរចុះព្យាបាលជំងឺ លោកស្រីបានចូលរួមជាមួយគាត់ជាញឹកញាប់ ឬក៏លោកស្រីនឹងស្នាក់នៅស្ថានីយមួយជាមួយអ្នកជំងឺ ស្របពេលដែលគាត់បានរើទៅស្ថានីយផ្សេងទៀត។ ពួកបេសកជនមានអំណរគុណចំពោះជំនាញខាងវេជ្ជសាស្ត្ររបស់គាត់ ក្នុងកាលដែលមិនទាន់មានវេជ្ជបណ្ឌិតណាផ្សេងនៅ

ក្នុងអង្គការបេសកកម្មចិនដីគោក ឬគ្មានវេជ្ជបណ្ឌិតណានៅកន្លែងដែលនៅឆ្ងាយពីកំពង់ផែសន្ធិសញ្ញា។ ប្រាកដណាស់ ការនេះបានបង្កើតទំហំការងាររបស់លោកគ្រូ ហ័ដសិន ដូចកាលគាត់បានមកដល់ស្ថានីយមួយនៅដាច់ឆ្ងាយ ហើយបានរកឃើញមានសំបុត្រចំនួនកៅសិបប្រាំបីកំពុងរង់ចាំគាត់ ឬនៅពេលគាត់បានចំណាយពេលនៅថ្ងៃបន្ទាប់សរសេរអំពីការណែនាំមួយទំព័រអំពី “កូនរបស់លោក អាលាំង” ("Aliang's baby") ដោយមានលោក អាលាំង ជាអ្នកជំនួយដ៏ប្រសើរនៅជីនគាំង (បច្ចុប្បន្នស៊ិនជាំង)។ ប៉ុន្តែ មិនសំខាន់ថា វាជាសំបុត្រវែង ឬក៏ការធ្វើដំណើរកាន់តែច្រើននោះទេ គឺគាត់ពិតជារីករាយចំពោះគ្រប់វិធីដែលគាត់អាចជួយពួកគេបាន។ ការបម្រើមនុស្សគ្រប់គ្នាគឺជាឯកសិទ្ធិ ដែលគាត់ប្រាថ្នាចង់ធ្វើបំផុត។

ព្រះអម្ចាស់កំពុងជួយយើងធ្វើការបានចម្រើនឡើង (គាត់អាចសរសេរនៅប្រាំបួនខែក្រោយមក) ហើយកិច្ចការបម្រើព្រះចេះតែរីកចម្រើនទៅមុខជានិច្ច ជាពិសេសនៅតំបន់សំខាន់ៗរបស់ជំនួយការជនជាតិចិន។ ជំនួយការត្រូវការឧបត្ថម្ភ ការយកចិត្តទុកដាក់ ហើយនឹងការណែនាំជាច្រើន ប៉ុន្តែពួកគេកំពុងរីកចម្រើននូវមុខជំនាញ និងភាពសម្បូរបែប ហើយដោយឥតសង្ស័យអនាគតប្រទេសចិនពឹងទៅលើពួកគេហើយ។ ខ្ញុំឃើញបេសកជនបរទេសថា ជាគ្រោងទ្រទ្រង់បណ្ដោះអាសន្ននៅជុំវិញអាគារដែលកំពុងតែសាងសង់ ឆាប់ៗនេះយើងអាចធ្វើបានកាន់តែប្រសើរដោយគ្មានពួកគេ—ឬផ្ទុយទៅវិញឆាប់ៗនេះ យើងអាចរើពួកគាត់នោះចេញ ដើម្បីផ្ដល់ការទ្រទ្រង់បណ្ដោះអាសន្នដូចគ្នានៅកន្លែងមួយផ្សេងទៀត។

ការអធិស្ឋាន និងនិមិត្តរបស់គាត់បានដើរទន្ទឹមគ្នាជាមួយនឹងការខិតខំប្រឹងប្រែងឥតឈប់ឈរទាំងនេះ! វាអាចនឹងងាយស្រួលក្នុងការមើលរំលងតម្រូវការដ៏ធំផ្សេងទៀត ដោយសារតែតម្រូវការភ្លាមៗ ជាពិសេសនៅក្នុងកាលដែលប្រាក់កាក់សម្រាប់កិច្ចការបម្រើព្រះមានការខ្វះខាត។ ប៉ុន្តែ សម្រាប់លោកគ្រូ ហ័ដសិន វាជារឿងផ្ទុយពីនេះ។ នៅពេលគាត់បានធ្វើដំណើរចេញពីទីតាំងមួយទៅទីតាំងមួយទៀត ដោយធ្វើដំណើរឆ្ងាយៗនៅចន្លោះស្ថានីយបេសកកម្មទាំងនោះពាសពេញតំបន់ដែលពេញទៅដោយមនុស្សរួសរាយរាក់ទាក់ ហើយអាចឈោងចាប់បាន នោះដួងចិត្តរបស់គាត់មានអារម្មណ៍សោកសៅ និងអាណិតអាសូរចំពោះអស់អ្នកដែលមិនទាន់បានឈោងចាប់បាន ទាំងជិត និងឆ្ងាយ។

«កាលពីអាទិត្យមុន ខ្ញុំនៅទីក្រុងថៃភីង ខណៈពេលដែលខ្ញុំបានសរសេរសំបុត្រទៅកាន់ក្រុមប្រឹក្សានៅទីក្រុងឡុងដ៍។ ដួងចិត្តខ្ញុំមានអារម្មណ៍ក្រៀមក្រំណាស់ចំពោះហ្វូងមនុស្សដែលមានពេញនៅលើផ្លូវបី ឬបួនគីឡូម៉ែត្រ ដោយធ្វើឲ្យមានការពិបាកដើរ ដោយសារតែវាជាថ្ងៃមនុស្សដើរផ្សារច្រើន។ យើងបានធ្វើការប្រកាស ដំណឹងល្អបន្តិចបន្តួចតែប៉ុណ្ណោះ ពីព្រោះយើងកំពុងស្វែងរកទីតាំងមួយ ដើម្បីបង្កើតកិច្ចការអចិន្ត្រៃយ៍នៅទីនោះ ប៉ុន្តែខ្ញុំទទួលអារម្មណ៍ថា ព្រះបានបណ្តាលចិត្តខ្ញុំឲ្យទៅជញ្ជាំងកំផែងក្រុង ហើយអំពាវនាវដល់ព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់បង្ហាញសេចក្តីមេត្តាករុណាចំពោះប្រជាជនទាំងឡាយ ហើយបើកចិត្តពួកគេ ក៏ដូចជាអនុញ្ញាតឲ្យយើងចូលទៅដល់ពួកគេ»។

យើងបានជួបនឹងមនុស្សដែលមានទុក្ខកង្វល់បួននាក់ដោយមិនបានដឹងខ្លួន។ បុរសចំណាស់ម្នាក់បានមករកយើងឃើញ បើទោះបីជាខ្ញុំមិនប្រាកដថា គាត់បានរកយើងឃើញដោយរបៀបណាក៏ដោយ ហើយគាត់ក៏បានតាមខ្ញុំទៅដល់ទូកយើងដែរ។ ខ្ញុំក៏បានអញ្ជើញគាត់ចូល ហើយបានសួរឈ្មោះគាត់។

គាត់បានឆ្លើយថា៖ «ខ្ញុំឈ្មោះ ទីង (Dzing)។ ប៉ុន្តែ សំណួរដែលធ្វើឲ្យខ្ញុំមានបញ្ហា ហើយជាសំណួរមួយដែលខ្ញុំមិនអាចរកចម្លើយបាននោះគឺ៖ តើខ្ញុំគួរតែធ្វើដូចម្តេចចំពោះអំពើបាបរបស់ខ្ញុំ? អ្នកវិទូរបស់យើងបានពោលថា គ្មានជាតិក្រោយទេ ប៉ុន្តែខ្ញុំគិតថា វាពិបាកជឿពួកគេណាស់...។ អូហ៍ លោក! ខ្ញុំបានដេកគិតនៅលើគ្រែ។ ខ្ញុំអង្គុយតែម្នាក់ឯងនៅពេលថ្ងៃគិតអំពីការនោះ។ ខ្ញុំគិតម្តងហើយម្តងទៀត ប៉ុន្តែខ្ញុំគិតមិនឃើញទេថា ត្រូវធ្វើអ្វីចំពោះអំពើបាបរបស់ខ្ញុំនោះឡើយ។ ខ្ញុំអាយុ៧២ឆ្នាំហើយ។ ខ្ញុំក៏មិនរំពឹងថា អាចរស់នៅបានដប់ឆ្នាំទៀតទេ។ មានពាក្យមួយឃ្លាបានពោលថា៖ “យើងមិនដឹងថា នឹងមានអ្វីកើតឡើងនៅថ្ងៃស្អែកទេ»។ តើលោកគ្រូអាចប្រាប់ខ្ញុំបានទេថា ខ្ញុំត្រូវធ្វើយ៉ាងដូចម្តេចចំពោះអំពើបាបរបស់ខ្ញុំ?”»។

ខ្ញុំបានឆ្លើយថា៖ «ខ្ញុំប្រាកដជាអាច។ យើងបានធ្វើដំណើររាប់ពាន់គីឡូម៉ែត្រ ដើម្បីឆ្លើយសំណួរនេះ។ សូមស្តាប់ ហើយខ្ញុំនឹងពន្យល់អំពីអ្វីដែលលោកចង់ដឹង និងត្រូវដឹង»។

នៅពេលដែលដៃគូខ្ញុំបានត្រឡប់មកវិញ គាត់បានស្តាប់រឿងដ៏អស្ចារ្យអំពីឈើឆ្កាងម្តងទៀត ហើយវាធ្វើឲ្យគាត់បានស្ងប់ចិត្ត ទាំងបានកម្សាន្តចិត្តគាត់ផងដែរ។ គាត់រីករាយដែលបានដឹងថា យើងបានជួលផ្ទះមួយខ្នង ហើយបានសង្ឃឹមថា ឆាប់ៗនេះ យើងនឹង

មានអ្នកចែកចាយសៀវភៅគ្រីស្ទបរិស័ទមករស់នៅក្នុងទីក្រុងដែរ។

នៅក្រុងជាងហាសិបនៅក្នុងខេត្តជិកគាំង (បច្ចុប្បន្នស៊ិនជាំង) ត្រូវការអ្នកធ្វើការបម្រើព្រះ ពីព្រោះមិនមាននរណាម្នាក់ធ្វើជាទីបន្ទាល់អំពីព្រះគ្រីស្ទនៅទីនោះទេ។ មានមនុស្សរាប់លាននាក់កំពុងរង់ចាំហើយ ហើយយើងមិនអាចព្រងើយកន្តើយបានទេ។ លោកគ្រូ ហ៍ដសិន ដោយនៅក្នុងទូកគាត់តែម្នាក់ឯង ត្រូវតែទុកចិត្តព្រះអម្ចាស់ចំពោះបន្ទុកនេះ។ សេចក្ដីជំនឿរបស់គាត់កាន់តែរឹងមាំឡើង ហើយនៅថ្ងៃបន្ទាប់ ថ្ងៃទី២៧ ខែមករា ឆ្នាំ១៨៧៤ គាត់បានកត់ត្រាបទពិសោធន៍នេះនៅក្នុងព្រះគម្ពីររបស់គាត់។

«ខ្ញុំបានទូលសូមព្រះជាម្ចាស់ឲ្យប្រទានអ្នកផ្សាយដំណឹងល្អជនជាតិចិន៥០ ឬ១០០ នាក់ ហើយឲ្យមានបេសកជនជាច្រើនតាមភាពចាំបាច់ ដើម្បីបង្កើតវត្តមានអ្នកផ្សាយដំណឹងល្អនៅក្រុងហ្វូ (Fu) ទាំងបួន និងក្រុងសិន (Hsien) ទាំង៤៨ នៅក្នុងខេត្តជិកគាំង (បច្ចុប្បន្នស៊ិនជាំង) ដែលនៅតែមិនទាន់មានអ្នកជឿនៅឡើយ។ ដូច្នេះ ដើម្បីឲ្យអ្នកបម្រើរបស់ព្រះចាប់ផ្ដើមធ្វើការនៅក្នុងខេត្តទាំងប្រាំបួន ដែលមិនទាន់មានអ្នកផ្សាយដំណឹងល្អនៅឡើយ។ សំណើនេះ បានធ្វើឡើងក្នុងព្រះនាមព្រះយេស៊ូវ»។

«ទូលបង្គំសូមអរព្រះគុណដល់ព្រះអម្ចាស់យេស៊ូវ ចំពោះសេចក្ដីសន្យាដែលព្រះអង្គបានប្រទានមកទូលបង្គំ ដើម្បីជាទីពឹងអាង។ សូមប្រទានដល់ទូលបង្គំអស់ទាំងកម្លាំងនៃរូបកាយ ប្រាជ្ញានៃគំនិត ហើយនិងព្រះគុណនៃព្រលឹងដែលទូលបង្គំត្រូវការសម្រាប់ធ្វើកិច្ចការដ៏ប្រសើររបស់ព្រះអង្គ»។

គួរឲ្យភ្ញាក់ផ្អើល ជំនួសឲ្យការចម្រើនកម្លាំង គាត់បានធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់។ គាត់បានចំណាយពេលរាប់អាទិត្យនៅលើគ្រែ ដោយទ្រាំទ្រនឹងការឈឺចាប់ ហើយប្រកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿរបស់គាត់នៅក្នុងនិមិត្តរបស់ព្រះជាម្ចាស់។ អស់រយៈពេលជាច្រើនខែ ប្រាក់រៀអង្គាសក៏ខ្វះខាត ហើយធ្វើឲ្យពិបាកក្នុងការបែងចែកធនធានតិចតួចដោយមិនមានអ្វីបានសន្សំទុកសម្រាប់ការពង្រីកកិច្ចការបម្រើព្រះឡើយ។ ប៉ុន្តែ គាត់បានសរសេរទៅកាន់លេខាធិការនៅទីក្រុងឡុងដ៍ ដោយតាំងចិត្តថា នឹងរើទៅដីគោក។ គាត់បានបង្ហាញពីបំណងចិត្តយ៉ាងជ្រាលជ្រៅរបស់គាត់ក្នុងការផ្សាយដំណឹងល្អនៅក្នុងខេត្តដែលពិតជាត្រូវការមួយចំនួនឆាប់ៗនេះ ដោយរង់ចាំយ៉ាងខ្ជាប់ខ្ជួនសម្រាប់ការនេះ ហើយដោយអធិស្ឋាននៅពេលយប់ ដោយចង់ដឹងថា តើគាត់ខ្វល់ខ្វាយអំពីការនេះលើសពីព្រះ

ជាម្ចាស់ឬយ៉ាងណា។

ការរីកចម្រើនទៅមុខដែលហាក់បីដូចជាកាន់តែមិនអាចទៅរួចទៀតទេ។ ទោះបីជាយ៉ាងណា គាត់បានឃើញកំណត់ត្រានៃប្រតិបត្តិការជាមួយព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរនៅចំពោះមុខគាត់ ហើយគាត់មានអារម្មណ៍ជឿជាក់ក្នុងចិត្តថា ពេលវេលាព្រះជាម្ចាស់សម្រាប់ចិនដីគោកនៅជិតនេះ។ ក្នុងកាលដែលគាត់បានសម្រាកនោះទីនោះដោយបានធូរស្បើយយ៉ាងយឺតៗ គាត់បានទទួលសំបុត្រមួយច្បាប់ពីមនុស្សម្នាក់ដែលគាត់មិនបានស្គាល់សោះ ដែលបានផ្ញើរមកអស់រយៈពេលពីរខែទៅហើយពីប្រទេសអង់គ្លេស។

“ជូនចំពោះលោកគ្រូជាទីគោរព!

ខ្ញុំពិតជាដឹងគុណចំពោះព្រះជាម្ចាស់ណាស់។ ខ្ញុំសង្ឃឹមថា អាចផ្តល់ប្រាក់៨០០ផោន (ស្មើនឹងប្រហែល $១៤៥,៨៨៥.០០ ដុល្លារ បច្ចុប្បន្ន) នៅរយៈពេលពីរខែ ដើម្បីពង្រីកការងារបម្រើព្រះនៅអង្គការបេសកកម្មនៅចិនដីគោកឲ្យកាន់តែធំឡើង។ សូមនឹកចាំក្នុងចិត្តថា សម្រាប់ខេត្តថ្មីៗ...

ខ្ញុំជឿថា  ក្រដាសសំណុំបែបបទសម្រាប់ទទួលប្រាក់បរិច្ចាគលោកគ្រូស្រស់ស្អាតណាស់៖ “ព្រះយេហូវ៉ាជាទង់ជ័យរបស់ខ្ញុំ” ហើយ “ព្រះយេហូវ៉ានឹងផ្គត់ផ្គង់” (និក្ខមនំ ១៧:១៦)។ ប្រាកដណាស់ ប្រសិនបើយើងបង្ហាញសេចក្តីជំនឿ ហើយផ្តល់ការសរសើរតម្កើង នោះព្រះយេហូវ៉ានៃពួកពលបរិវារនឹងសព្វព្រះហឫទ័យចំពោះការនោះ»។

មនុស្សដែលទើបនឹងងើបពីឈឺម្នាក់នេះស្ទើរតែមិនជឿថា អ្វីដែលគាត់កំពុងអានគឺត្រឹមត្រូវដែលថា គាត់បានទទួលប្រាក់៨០០ផោន (ស្មើនឹងប្រហែល $១៤៥,៨៨៥.០០ ដុល្លារបច្ចុប្បន្ន) សម្រាប់ «ខេត្តថ្មីៗ»។ វាហាក់បីដូចជា អារម្មណ៍ថា អាថ៌កំបាំងដ៏ជ្រាលជ្រៅនៅក្នុងដួងចិត្តគាត់បានឆ្លុះបញ្ចាំងនៅក្នុងទំព័រក្រដាសដែលមកពីបរទេសនេះ។ សំបុត្រនោះបានផ្ញើមក មុនពេលគាត់បានកត់ត្រានៅក្នុងសេចក្តីអធិស្ឋានគាត់នៅក្នុងព្រះគម្ពីរគាត់ទៅទៀត ហើយពេលនេះវាបានមកដល់ព្រមជាមួយការបញ្ជាក់យ៉ាងច្បាស់អស្ចារ្យចំពេលដែលគាត់ត្រូវការវាបំផុត។ ប្រាកដណាស់ ពេលនេះជាពេលដែលព្រះបានតាំងឡើង!

គាត់បានរើពីបន្ទប់អ្នកជម្ងឺទៅកាន់ជ្រលងយ៉ាងជី ហើយនៅក្នុងអំឡុងរដូវផ្ការីកនេះការប្រមូលផ្តុំដ៏សំខាន់មួយបានកើតឡើងនៅជិនគាំង (បច្ចុប្បន្នជីងគាំង)។ គ្រីស្ទបរិស័ទចិននៅជិតស្ថានីយបេសកកម្មទាំងអស់ជួបប្រទះនឹងភាពភ្ញៀវក្លាឡើងវិញ។ ក្រុមជំនុំទាំង

ឡាយកំពុងស្វាគមន៍អ្នកប្រែចិត្តជឿថ្មីៗ ហើយអ្នកដឹកនាំជនជាតិដើមកាន់តែមានសេចក្ដីសោមនស្សរីករាយ និងសមត្ថភាពឡើងថែមទៀត។ បេសកជនចាស់ៗមានអារម្មណ៍ថាទទួលបានការគាំទ្រ បើទោះបីជាមានតម្រូវការជាច្រើនពីតំបន់ពួកគាត់ក៏ដោយ ហើយបុរសៗវ័យក្មេងដែលស្ទាត់ជំនាញខាងភាសាមានបំណងធ្វើការខាងត្រួសត្រាយផ្លូវ។ មានមនុស្សជាច្រើនបានឆ្លៀតពេលពីការងារពួកគេ ដើម្បីអធិស្ឋាន និងរៀបគម្រោងមួយសប្ដាហ៍ជាមួយលោកគ្រូ ហ័ដសិន មុនពេលគាត់ និងលោកគ្រូ ជូដដ៍ ចាប់ផ្ដើមធ្វើដំណើរឡើងទៅតាមដងទន្លេ ដើម្បីបង្កើតមូលដ្ឋានមួយសម្រាប់អ្នកដែលឆេះឆួលចូលរួមតំបន់ភាគខាងលិចនៃអង្គការបេសកកម្មចិនដីគោក។

តើព្រះអម្ចាស់មិនបានលើកទឹកចិត្តយើងទេឬអី នៅពេលដែលទ្រង់បានល្បងលយើងយ៉ាងជ្រាលជ្រៅដោយការខ្វះប្រាក់ជំនួយ ស្របពេលដែលលោកគ្រូ ហ័ដសិន បានសរសេរពីស្រុកជិនគាំង (បច្ចុប្បន្នជឹងគាំង)?

ការយល់ដឹងថ្មីនៃសេចក្ដីអំណរ និងសេចក្ដីសង្ឃឹមមិនមែនដោយសារតែមានការផ្គត់ផ្គង់យ៉ាងច្រើននោះទេ ដូចដែលពួកអ្នករាល់គ្នានឹងអាននៅក្នុងសំបុត្រខាងក្រោមដែលលោកគ្រូ ហ័ដសិន បានសរសេរទៅកាន់មិត្តម្នាក់ ដែលមានបទពិសោធន៍យ៉ាងជ្រាលជ្រៅនឹងជីវិតនៃសេចក្ដីជំនឿ។

“កិច្ចការរបស់យើងមិនដែលជាប់ទាក់ទងនឹងបញ្ហាប្រឈមពិតប្រាកដ ឬបានតម្រូវឲ្យមានសេចក្ដីជំនឿច្រើនបែបនេះទេ។ កញ្ញា ប្លេតឆ្លេយ៍ ជាមិត្តសម្លាញ់យើងឈឺ ហើយចង់ជួបខ្ញុំ កូនៗយើងត្រូវការយើង ប្រាក់ជំនួយក៏កាន់តែអស់ ការងារចាំបាច់ត្រូវតែផ្លាស់គ្នាធ្វើ ដើម្បីឲ្យមានអ្នកខ្លះបានទៅផ្ទះ អ្នកផ្សេងទៀតចេញមកធ្វើការ ហើយដើម្បីឲ្យកាន់តែលូតលាស់ឡើង។ បញ្ហាជាច្រើនទៀតពិបាកពន្យល់នៅក្នុងសំណេរណាស់។ រឿងទាំងអស់នេះ នឹងជាបន្ទុកដ៏ច្រើនលើសលុប ប្រសិនបើយើងត្រូវផ្ទុកវាតែម្នាក់ឯង។ ប៉ុន្តែ ព្រះអម្ចាស់ទ្រយើង និងបន្ទុករបស់យើង ដោយចាក់បំពេញដួងចិត្តយើងដោយសេចក្ដីអំណរក្នុងទ្រង់មួយអង្គគត់—មិនមែននៅក្នុងទ្រង់ បូកនឹងសមតុល្យធនាគារទេ—ដែលខ្ញុំមិនដែលមានអារម្មណ៍កាន់តែមានសេរីភាពពីទុក្ខកង្វល់ និងការថប់បារម្ភឡើយ។

កាលពីអាទិត្យមុន នៅពេលដែលខ្ញុំបានមកដល់ទីក្រុងសៀងហៃ យើងពិតជាត្រូវការជំនួយខ្លាំងណាស់។ សំបុត្រទាំងពីរបានមកដល់ ប៉ុន្តែគ្មានការផ្ញើរប្រាក់ទេ ហើយ

សៀវភៅគណនីបានបង្ហាញថា គ្មានទឹកប្រាក់នៅស្រុកកំណើតសោះ។ ខ្ញុំបានថ្វាយបញ្ហាទាំងអស់ទៅកាន់ព្រះជាម្ចាស់។ ពេលភ្ញាក់ពីដំណេកនៅព្រឹកបន្ទាប់ ខ្ញុំមានអារម្មណ៍ព្រួយណាស់ ប៉ុន្តែព្រះយេហូវ៉ាបានធានាអះអាងនឹងខ្ញុំដោយព្រះបន្ទូលទ្រង់ថា៖ “យើងដឹងពីសេចក្តីទុក្ខលំបាកពួកគេ ហើយក៏បានយាងចុះមក ដើម្បីជួយសង្គ្រោះដែរ” ហើយ “ប្រាកដណាស់! យើងនឹងនៅជាមួយឯង”។ នៅម៉ោង៦ព្រឹក ខ្ញុំមានទំនុកចិត្តថា ជំនួយកំពុងតែមកតាមផ្លូវដូចពីពេលមុនដែរ ហើយជិតដល់ពេលថ្ងៃត្រង់ ខ្ញុំទទួលសំបុត្រមួយច្បាប់ពីលោក ម៉ូល័រ។ សំបុត្ររបស់គាត់បានទទួលការពន្យារពេលមកដល់ទីក្រុងនីងប៉ូ ហើយនៅពេលដែលសំបុត្រនោះបានមកដល់ខ្ញុំ វាមានលុយជាងបីរយផោន (ប្រហែលស្មើនឹង $៥៤,៧១១.០០ ដុល្លារ បច្ចុប្បន្ន)។

ពេលនេះ តម្រូវការរបស់ខ្ញុំគឺធំដុំ និងបន្ទាន់ ប៉ុន្តែព្រះជាម្ចាស់កាន់តែអស្ចារ្យ និងកាន់តែចូលមកជិតខ្ញុំ។ ដោយសារតែ ទ្រង់មានព្រះជន្មគង់នៅ ហើយគឺជាទ្រង់ហើយ គ្រប់យ៉ាងត្រូវតែមិនអីទេ ហើយគ្រប់យ៉ាងនឹងបានជាល្អ។ អូហ៍ ប្អូនប្រុសជាទីស្រឡាញ់អើយ សេចក្តីអំណរនៃការដឹង ការមើលឃើញ ព្រមទាំងការទុកចិត្តលើព្រះដ៏រស់នៅក្នុងស្ថានភាពដ៏លំបាក ហើយចម្លែករបស់យើង គឺជារឿងដ៏ប្រសើរខ្លាំងណាស់! ខ្ញុំគ្រាន់តែជាអ្នកធ្វើការថ្វាយទ្រង់ទេ។ ទ្រង់នឹងថែរក្សាព្រះកិត្តិយសទ្រង់ ផ្គត់ផ្គង់ដល់អ្នកបម្រើទ្រង់ ទាំងបំពេញអស់ទាំងសេចក្តីត្រូវការយើងតាមរយៈទ្រព្យសម្បត្តិទ្រង់ ក៏ដូចជាការដែលប្អូនប្រុសបានគាំទ្រយើងតាមរយៈការអធិស្ឋាន ការធ្វើការដោយស្មោះត្រង់ ព្រមទាំងធ្វើការដោយសេចក្តីស្រឡាញ់របស់ប្អូនផងដែរ»។

នៅអំឡុងខែមេសា ឆ្នាំ១៨៧៤ លោកស្រី ថេល័រ ទទួលបានក្រដាសមួយសន្លឹកពីប្តីគាត់ ដែលបានបញ្ជាក់ពីទំនុកចិត្តស្រដៀងគ្នានេះដែរ៖ «កាលពីម្សិលមិញ យើងមានសមតុល្យភាពទឹកប្រាក់ចំនួន ០.៨៧ សេន។ សូមរាជ្យរបស់ព្រះអម្ចាស់បានតម្កើងឡើង នេះគឺជាសេចក្តីអំណរ និងសេចក្តីសុខសាន្តរបស់យើង!»។ នៅពេលសមតុល្យភាពទឹកប្រាក់កាន់តែធ្លាក់ចុះទៅៗ គាត់បានធានានឹងលោក ថេល័រ ថា៖ “យើងមានទឹកប្រាក់នេះ និងសេចក្តីសន្យាទាំងអស់របស់ព្រះជាម្ចាស់”»។

គាត់បានចាំថា៖ «ប្រាក់ ០.២៥ សេន បូកនឹងសេចក្តីសន្យាទាំងអស់របស់ព្រះជាម្ចាស់! វាធ្វើឲ្យមានអារម្មណ៍ថា មានស្តុកស្តម្ភដូចជា ស្តេចគ្រីសឹស (Croesus) អញ្ចឹង ហើយ

ការនេះបានជំរុញចិត្តគាត់ឲ្យច្រៀងសរសើរព្រះអង្គ»។

«ខ្ញុំនឹងមិនដូរការដ៏មានព្រះពររបស់ខ្ញុំនឹងអ្វីដែលល្អ ឬអស្ចារ្យនៅលើផែនដីនេះទេ ហើយដរាបណាសេចក្ដីជំនឿខ្ញុំនៅតែរឹងមាំ នោះខ្ញុំនឹងមិនច្រណែននឹងទ្រព្យសម្បត្តិមនុស្សមានបាបឡើយ»។

បទចម្រៀងសរសើរតម្កើងនៅសន្និបាតនារដូវផ្ការីកនៅជីនគាំង (បច្ចុប្បន្នសិនជាំង) គឺ «ព្រះយេហូវ៉ានឹងប្រទានមកឲ្យក្នុងរបៀបមួយ ឬក៏ផ្លូវមួយផ្សេងទៀត» ហើយដោយនឹកចាំឃ្លានេះក្នុងចិត្តលោកគ្រូ ហ័ដសិន បានសរសេរទៅកញ្ញា ប្លេតឆ្លេយ៍ថាៈ

«ខ្ញុំប្រាកដក្នុងចិត្តថា ប្រសិនបើយើងរង់ចាំ នោះព្រះយេហូវ៉ានឹងប្រទានមក។ លោកគ្រូ ជូដជ៍ ហើយនឹងខ្ញុំនឹងទៅវ៉ូឆាង (Wuchang) ឆាប់ៗនេះ ដើម្បីមើលថា តើយើងអាចទិញទីស្នាក់ការកណ្ដាលនៅទីកន្លែងនោះ ឬក៏អត់។ ចាប់ពីពេលនោះមក យើងមានបំណងចាប់ផ្ដើមការងារព័ន្ធកិច្ចនៅភាគខាងលិចនៃប្រទេសចិនក្នុងកាលដែលព្រះជាម្ចាស់អនុញ្ញាតឲ្យយើងធ្វើ។ តម្រូវការបន្ទាន់នៅបណ្ដាខេត្តដែលដំណឹងមិនទាន់ទៅដល់ និងប្រាក់ជំនួយ ដែលយើងមានសម្រាប់ការងារព័ន្ធកិច្ច ជាពិសេសនៅតំបន់ទាំងនោះ ជំរុញចិត្តឲ្យយើងចាត់វិធានការឥឡូវនេះ ខណៈពេលដែលយើងមិនមានមូលនិធិសម្រាប់ការចំណាយជាទូទៅ។ ខ្ញុំស្រមៃមិនចេញទេថា តើយើងអាចឆ្លងផុតខែក្រោយបានដោយរបៀបណា ប៉ុន្តែខ្ញុំក៏រំពឹងទាំងស្រុងថា យើងនឹងឆ្លងផុត។ ព្រះអម្ចាស់នឹងមិនធ្វើឲ្យយើងខកចិត្តឡើយ។

នៅពេលនោះ ឧបសគ្គ និងការរាំងស្ទះថ្មីៗបានកើតឡើង។ ទោះបីជា គាត់មានភាពក្លាហាន និងភក្ដីភាព ក៏ដោយ ក៏សុខភាពកញ្ញា ប្លេតឆ្លេយ៍ បានធ្លាក់ចុះខ្សោយ ដោយសារតែទំនួលខុសត្រូវរាប់មិនអស់របស់គាត់។ កុមារកុមារីនៅផ្លូវផាយឡែនជ៍ ត្រូវការការមើលថែ ហើយការងារនៃអង្គការបេសកកម្មចិនដីគោកនៅក្នុងស្រុកស្ទើរតែផ្អាកមួយរយៈ បើទោះជា គាត់មានទេពកោសល្យ និងការតាំងចិត្តក៏ដោយ ក៏ព្រោះតែគាត់ក្លាយជាចំណុចកណ្ដាលនៃដំណើរការទាំងអស់។ នៅពេលពួកគាត់បានរកផ្ទះឲ្យលោក ជូដជ៍ អាចស្នាក់នៅបាននៅវ៉ូឆាងរួចហើយ លោក និងលោកស្រី ថេល័រ ក៏បានប្រញាប់ត្រឡប់ទៅផ្ទះនៅអង់គ្លេសវិញ។ ទោះបីជាយ៉ាងណាក៏ដោយ មុនពេលដែលពួកគាត់អាចចាកចេញពីប្រទេសចិន មិត្តសម្លាញ់គាត់ ដែលពួកគាត់បានតាំងចិត្តថានឹងជួយបានទទួល

មរណភាព។

ពីរបីសប្តាហ៍ក្រោយមក ការត្រឡប់មកផ្ទះ ប្រែក្លាយជារឿងចម្លែក និងពេញដោយការឈឺចាប់ ដោយកន្លែងរបស់កញ្ញាប្លេតឆ្លេយ៍នៅទទេស្អាត កូនៗខ្ចាត់ខ្ចាយមិននៅជាមួយគ្នា ហើយការប្រជុំអធិស្ឋានប្រចាំសប្តាហ៍ក៏បានផ្អាកផងដែរ។ ប៉ុន្តែ ស្ថានភាពក៏មិនទាន់ធ្លាក់ដល់ចំណុចអាក្រក់បំផុតដែរ។ អំឡុងពេលធ្វើដំណើរឡើងទៅទន្លេយ៉ាងជី ជាមួយលោកគ្រូ ជូដដ៏ លោកគ្រូ ហ៉ដសិន ក៏បានរងរបួសយ៉ាងធ្ងន់ធ្ងរពីការដួលផងដែរ។ ការប៉ះទង្គិចឆ្អឹងខ្នងបានវិវឌ្ឍន៍យ៉ាងយឺតៗ ហើយវាមិនធ្វើទុក្ខរហូតទាល់តែជាច្រើនសប្តាហ៍ក្រោយមកនៃការត្រឡប់មកវិញ ដែលការងារដ៏មមាញឹកនៃជីវិតនៅទីក្រុងឡុងដ៍បានចាប់ផ្តើមប៉ះពាល់ដល់គាត់។ ក្រោយមក ជើងផ្នែកខាងក្រោយគាត់បានចាប់ផ្តើមពិការបន្តិចម្តងៗ ដោយតម្រូវឲ្យគាត់ត្រូវសម្រាកលើសាឡុងទាំងស្រុងតែម្តង។ នៅក្នុងដំណាក់កាលដ៏សកម្មបំផុតរបស់គាត់ គាត់អាចត្រឹមតែសម្រាន្តនៅបន្ទប់ជាន់ខាងលើ ដឹងរឿងគ្រប់យ៉ាងដែលបានត្រូវធ្វើ ហើយអ្វីទាំងអស់ត្រូវទុកចោល—ដោយគាត់គ្រាន់តែសម្រាន្តនៅទីនោះ ដោយមានអំណរក្នុងព្រះជាម្ចាស់តែប៉ុណ្ណោះ។

ចូរអរសប្បាយឡើងក្នុងព្រះជាម្ចាស់! បើទោះបីគាត់មានសង្ឃឹមតិចតួចថា នឹងអាចឈរឬក៏ដើរបានម្តងទៀតក៏ដោយ ក៏សេចក្តីបរិបូរណ៍ពោរពេញជាមួយនឹងភាពឆេះឆួល និងសេចក្តីសង្ឃឹមគ្មានទីបញ្ចប់គឺជាតម្រូវការជាបន្ទាន់របស់គាត់ តាមរយៈសេចក្តីអធិស្ឋាន និងការឆ្លើយតបរបស់ព្រះជាម្ចាស់ រួមទាំងឱកាសដែលកើតមានឡើងនៅប្រទេសចិន ព្រមទាំងការរស់នៅខាងព្រះវិញ្ញាណដែលបានផ្តល់កម្លាំងដល់ក្រុមជំនុំនៅប្រទេសអង់គ្លេស ដែលគាត់បានប្រាថ្នាចង់ផ្លាស់ប្តូរទៅជាកិច្ចខិតខំប្រឹងប្រែងខាងបេសកកម្ម ហើយគាត់មានសេចក្តីអំណរនៅក្នុងបំណងព្រះហឫទ័យព្រះជាម្ចាស់ថា "ល្អ! អាចទទួលយកបាន ហើយគ្រប់លក្ខណ៍"។ ប្រាកដណាស់ថា ការពង្រីកយ៉ាងសំខាន់របស់អង្គការបេសកកម្មនៅចិនដីគោកមានប្រភពដើមចេញពីអំឡុងពេលនៃការរងទុក្ខនោះ។

ពេលនេះ លោកគ្រូ ហ៉ដសិន ត្រូវសម្រាកនៅលើគ្រែប្រអប់ដ៏ចង្អៀត ប៉ុន្តែផែនទីនៃប្រទេសចិនទាំងមូលនៅតែព្យួរនៅចុងជើងគាត់។ គាត់ទទួលអារម្មណ៍ថា ព្រះវត្តមានព្រះវិញ្ញាណបរិសុទ្ធនៅហ៊ុមព័ទ្ធគាត់ជានិច្ច ហើយគាត់អាចចូលទៅព្រះតាមរយៈព្រះយេស៊ូវ។ មួយរយៈក្រោយមក បន្ទាប់ពីសេចក្តីអធិស្ឋានពួកគាត់បានឆ្លើយតប ហើយ

អ្នកត្រួសត្រាយផ្លូវនៃអង្គការបេសកកម្មចិនដីគោករបស់គាត់បាននាំការបង្រៀនអំពីព្រះគ្រីស្ទពាសពេញបណ្ដាខេត្តនៃចិនដីគោក នោះអ្នកដឹកនាំម្នាក់មកពីក្រុមជំនុំប្រទេសស្កុតឡែនដ៍បាននិយាយទៅកាន់លោកគ្រូ ហ៍ដសិន ថា៖

“ជួនកាល លោកគ្រូប្រហែលជាមានអារម្មណ៍ថា មានការល្បួងឲ្យមានសេចក្ដីអំនួតដោយសារតែរបៀបដ៏អស្ចារ្យដែលព្រះជាម្ចាស់បានប្រើប្រាស់លោកគ្រូ។ ខ្ញុំសង្ស័យថាមានមនុស្សរស់ណាបានទទួលកិត្តិយសអស្ចារ្យជាងនេះទៀត”។

គាត់បានឆ្លើយតបដោយស្មោះចេញពីចិត្តថា៖ “ផ្ទុយពីនេះទៅវិញទេ ខ្ញុំតែងតែគិតថាព្រះជាម្ចាស់ប្រហែលជាស្វែងរកនរណាម្នាក់ដែលតូចតាច ហើយខ្សោយល្មមនឹងប្រើបាន ហើយទ្រង់បានរកឃើញខ្ញុំ”។

ឆ្នាំនោះ បានបញ្ចប់ដោយទស្សនវិស័យដ៏ខ្មៅងងឹត។ ការធ្វើចលនាទៅមករបស់លោកគ្រូ ហ៍ដសិន បានធ្លាក់ចុះ ហើយគាត់អាចត្រឹមតែរើខ្លួនទៅមកនៅលើគ្រែដោយប្រើខ្សែតោងពីខាងលើតែប៉ុណ្ណោះ។ ដំបូង គាត់អាចសរសេរសំបុត្របានបន្តិចបន្តួចដែរ តែក្រោយមកគាត់មិនអាចសូម្បីតែកាន់ប៊ិកសរសេរ ហើយពេលខ្លះ លោកស្រី ហ៍ដសិន មិនអាចជួយគាត់សរសេរសំបុត្របានផង។ នៅដើមឆ្នាំ១៨៧៥ អត្ថបទខ្លីមួយបានលេចឡើងនៅក្នុងកាសែតគ្រីស្ទបរិស័ទ ដែលមានចំណងជើងថា “សេចក្ដីអំពាវនាវសូមការអធិស្ឋានតាំងនាមជំនួសជនជាតិចិនចំនួនមួយរយហាសិបលាននាក់”។ វាបានបង្ហាញយ៉ាងច្បាស់នូវការពិតអំពីខេត្តទាំងប្រាំបួនដែលមិនទាន់បានផ្សាយដំណឹងល្អ និងគោលដៅនៃអង្គការបេសកកម្មចិនដីគោក។ អត្ថបទបានលើកឡើងអំពីការបរិច្ចាគទឹកប្រាក់ចំនួនបួនពាន់ផោន (ស្មើនឹង $៧៧៤,១៤៤ ដុល្លារ បច្ចុប្បន្ន) នាពេលថ្មីៗនេះ ដើម្បីផ្សាយដំណឹងល្អទៅកាន់តំបន់ដាច់ស្រយាលទាំងនេះ។ គ្រីស្ទបរិស័ទជនជាតិចិន បានរៀបចំចូលរួម។ តម្រូវការចម្បង គឺដើម្បីមានបេសកជនបុរសៗវ័យក្មេងកាន់តែច្រើនឡើងដែលបានត្រៀមខ្លួនរួចរាល់ ដើម្បីទ្រាំទ្រនឹងការលំបាកទាំងឡាយ ដើម្បីដឹកនាំផ្លូវ។

ឱបងប្អូនអ្នកអានជាគ្រីស្ទបរិស័ទទាំងឡាយអើយ! សូមថ្វាយដួងចិត្តបងប្អូនទៅព្រះជាម្ចាស់ ហើយចំណាយពេលមួយនាទីក្នុងការអធិស្ឋានដ៏ស្មោះត្រង់ ដោយទូលសូមឲ្យព្រះជាម្ចាស់នឹងជំរុញចិត្តមនុស្សដែលស័ក្តិសមនឹងការងារចំនួនដប់ប្រាំបីនាក់ ដើម្បីឲ្យពួកគេប្ដេជ្ញាចិត្តនៅក្នុងការធ្វើកិច្ចការនេះ។

ការអំពាវនាវ មិនបានលើកឡើងថា អ្នកដឹកនាំនៃអង្គការបេសកកម្មចិនដីគោក ប្រៀបបីដូចជាមនុស្សពិការដ៏អស់សង្ឃឹមម្នាក់នោះទេ។ វាក៏មិនបានរម្លឹកថា គាត់ និងប្រពន្ធគាត់បានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួនបួនពាន់ផោន (បច្ចុប្បន្នប្រហែលស្មើនឹង $៧៧៤.១៤៤,០០ ដុល្លារ បច្ចុប្បន្ន) ដែលពួកគេបានលះបង់ទៅលើកិច្ចការបម្រើព្រះជាម្ចាស់ឡើយ។ ការអំពាវនាវមិនបាននិយាយអំពីសេចក្តីសន្យាដែលបានធ្វើឡើងនៅពីរឆ្នាំ ឬបីឆ្នាំមុន ដើម្បីអធិស្ឋានដោយស្មោះត្រង់សម្រាប់អ្នកផ្សាយដំណឹងល្អទាំងដប់ប្រាំបីនាក់ រហូតដល់ព្រះអម្ចាស់បានប្រទានពួកគេមកនោះទេ។ ទោះបីជាយ៉ាងណាក្តី អស់អ្នកដែលអានសេចក្តីអំពាវនាវបានដឹងកាន់តែច្រើនចំពោះការនេះ ហើយទទួលសេចក្តីរំជើបរំជួលពីឥទ្ធិពល ដែលមានតែអ្នកចាក់ឫសជ្រៅក្នុងព្រះជាម្ចាស់ ទើបអាចធ្វើការទាំងនេះបាន។

មិនយូរប៉ុន្មាន ការឆ្លើយតបសំបុត្ររបស់លោកគ្រូ ហ័ដសិន បានកើនឡើងយ៉ាងគួរឲ្យកត់សម្គាល់ ក្នុងកាលដែលគាត់មានសេចក្តីអំណរនៅក្នុងការឆ្លើយឆ្លងវា—ឬជាជាងនេះនៅក្នុងការឃើញព្រះជាម្ចាស់បានរៀបចំ និងជួយការនេះ។

នៅពេលនោះ អង្គការបេសកកម្មចិនដីគោកមិនមានអ្នកជំនួយដែលមានប្រាក់ខែទេ ប៉ុន្តែព្រះជាម្ចាស់បានដឹកនាំអ្នកស្ម័គ្រចិត្តឲ្យមករាល់ថ្ងៃដោយគ្មានការរៀបចំទុកជាមុន ដើម្បីមកជួយក្នុងការសរសេរតាមអាន។ ប្រសិនបើមាននរណាម្នាក់ ដែលបានដល់នៅពេលព្រឹកដោយគ្មានពេលវេលាគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងសំបុត្រទាំងអស់ នោះអ្នកស្ម័គ្រចិត្តផ្សេងទៀតប្រាកដជាមកជួយ ហើយជួនកាលអ្នកស្ម័គ្រចិត្តម្នាក់ ឬពីរនាក់នឹងចូលមកនៅពេលរសៀល។ យូរៗម្តង មានមិត្តភក្តិវ័យក្មេងធ្វើការនៅទីក្រុងនឹងមកសួរសុខទុក្ខគាត់ នៅក្រោយម៉ោងធ្វើការដើម្បីគ្រប់គ្រងកំណត់ត្រាផ្សេងៗ ឬដើម្បីបញ្ចប់សំបុត្រណាដែលមិនទាន់បានឆ្លើយតប។ នេះគឺជាទម្លាប់ប្រចាំថ្ងៃ។ ពេលវេលាមួយដែលរីករាយបំផុតក្នុងជីវិតខ្ញុំ គឺជាអំឡុងពេលនៃការបង្ហំឲ្យអសកម្មនេះ ក្នុងកាលដែលខ្ញុំរកធ្វើអ្វីមិនបានសោះ ក្រៅពីអរសប្បាយឡើងក្នុងព្រះអម្ចាស់ គឺរង់ចាំទ្រង់យ៉ាងអត់ធ្មត់ ហើយរង់ចាំមើលទ្រង់បំពេញរាល់ទាំងតម្រូវការរបស់ខ្ញុំ។ សំបុត្រខ្ញុំមិនដែលឆ្លើយតបទៀងទាត់ និងឆ្លើយតបបានលឿនជាជាងពេលនេះទេ មិនថាមុន ឬក៏ក្រោយពេលនោះឡើយ។

មនុស្សដប់ប្រាំបីនាក់ ដែលយើងបានអធិស្ឋានទូលសូមពីព្រះជាម្ចាស់ក៏បានចាប់ផ្តើម

មកដល់។ ពីដំបូង យើងបានឆ្លើយឆ្លងសំបុត្រគ្នាទៅវិញទៅមក ក្រោយមកពួកគាត់បានមកសួរសុខទុក្ខខ្ញុំដល់បន្ទប់។ មិនយូរប៉ុន្មាន ខ្ញុំបានបើកថ្នាក់រៀនភាសាចិននៅក្បែរគ្រែខ្ញុំ។ នៅពេលវេលាមកដល់ហើយ នោះព្រះអម្ចាស់បានចាត់ពួកគេឲ្យចេញទៅ។ មិត្តសម្លាញ់នៅម៉ាយដ៍មេយ៍ បានអធិស្ឋានសម្រាប់ខ្ញុំឲ្យបានជាសះស្បើយ។ ព្រះបានប្រទានពរដល់ការព្យាបាលនានា ហើយខ្ញុំក៏បានជាសះស្បើយមែន។ មូលហេតុនៃការឈឺរបស់ខ្ញុំលែងជាប់ទាក់ទងទៀតហើយ។ ប្រសិនបើខ្ញុំមានសុខភាពល្អ ហើយសកម្ម នោះប្រហែលជាអ្នកខ្លះបានគិតថា អ្វីដែលបណ្តាលឲ្យអ្នកទាំងដប់ប្រាំបីនាក់ចេញទៅប្រទេសចិន គឺជាការទទូចសុំបន្ទាន់របស់ខ្ញុំ ជាជាងគិតថា វាគឺជាការអន្តរាគមន៍របស់ព្រះជាម្ចាស់។ ប៉ុន្តែ ការគ្មានភាពសកម្មទាំងស្រុង គ្រាន់តែអាចកំណត់សំណូមពរអធិស្ឋានតែប៉ុណ្ណោះ ចំណែកឯការឆ្លើយតបចំពោះការអធិស្ឋាននោះ ច្បាស់ណាស់គឺបានមកពីព្រះជាម្ចាស់ផ្ទាល់។

នៅពេលនោះ ការឆ្លើយតបចំពោះការអធិស្ឋានសម្រាប់ប្រាក់ជំនួយក៏អស្ចារ្យផងដែរ។ នៅពេលយើងចាំបាច់ត្រូវផ្ញើប្រាក់ប្រចាំខែទៅកាន់ប្រទេសចិន គឺមានទឹកប្រាក់ទាបណាស់មានចំនួន២៣៥ផោន (ប្រហែលស្មើនឹង $៤៥,៣២៩.00 ដុល្លារ បច្ចុប្បន្ន) តិចជាងការចំណាយធម្មតា។ យើងបានអធិស្ឋានអំពីតម្រូវការនេះ ហើយអរព្រះគុណព្រះ យើងមិនចាំបាច់ត្រូវរង់ចាំការឆ្លើយតបយូរឡើយ។ នៅល្ងាចនោះ អ្នករត់សំបុត្របាននាំសំបុត្រមួយច្បាប់ព្រមជាមួយនឹងមូលប្បទានប័ត្រមួយសន្លឹក ដែលមានទឹកប្រាក់ចំនួន ២៣៥.៧.៩ ផោន (ប្រហែលស្មើនឹង $៤៥,៤៧៥.00 ដុល្លារ បច្ចុប្បន្ន) បានមកពីការលក់ចាន។ ក្រោយមក នៅពេលលោកគ្រូ ហ៎ដសិន មានសុខភាពល្អល្មមនឹងចូលរួមការប្រជុំម្តងទៀតបាន នោះអភិជនជនជាតិរុស្ស៊ីម្នាក់ឈ្មោះលោក ខោនធ៍ បូប្រ៊ីនស្គី (Count Bobrinsky) ដែលជាម្នាក់បានស្តាប់សុន្ទរកថារបស់គាត់បានចូលមកជិតគាត់។ នៅពេលពួកគាត់កំពុងធ្វើដំណើរទៅទីក្រុងឡុងដ៍ជាមួយគ្នា លោក ខោនធ៍ បូប្រ៊ីនស្គី បានលូកយកកូនសៀវភៅរបស់គាត់។

គាត់បាននិយាយថា៖ «សូមឲ្យខ្ញុំបានចូលរួមចំណែកដ៏តិចតួចនេះ ចំពោះកិច្ចការបម្រើព្រះរបស់លោកគ្រូនៅប្រទេសចិនផង»។

លោកគ្រូ ហ៎ដសិន បានដឹងថា ប្រហែលជាមានការយល់ច្រឡំអ្វីមួយហើយ នៅពេលដែលគាត់បានទទួលទឹកប្រាក់ដ៏សម្បើមបែបនេះ។

គាត់បានសួរថា៖ «ក្រែងប្អូនប្រុសបានតាំងចិត្តប្រគល់ប្រាក់ប្រាំផោនឲ្យខ្ញុំមែនទេ? សូមឲ្យខ្ញុំបានប្រគល់ប្រាក់នេះត្រឡប់ទៅវិញ។ ប្រាក់នេះ៥០ផោន (ប្រហែល $៩,៦៤២.០០ ដុល្លារ បច្ចុប្បន្ន) មិនមែនប្រាំផោនទេ!»។

លោក ខោនធ៍ បានតបទាំងភ្ញាក់ផ្អើលថា៖ «ខ្ញុំមិនអាចទទួលយកវាត្រឡប់មកវិញបានទេ។ ខ្ញុំបានតាំងចិត្តប្រគល់ប្រាំផោនមែន ប៉ុន្តែព្រះជាម្ចាស់ប្រហែលជាសព្វព្រះទ័យឲ្យខ្ញុំប្រគល់៥០ផោនដល់លោកគ្រូហើយ។ ដូច្នេះ ខ្ញុំមិនអាចទទួលយកប្រាក់នោះត្រឡប់មកវិញបានទេ»។

លោកគ្រូ ហ័ដសិន បានភ្ញាក់ផ្អើលចំពោះហេតុការណ៍នេះយ៉ាងខ្លាំង ហើយក៏បានមកដល់ផ្លូវផាយទ្បែនដ៍ ទាំងឃើញគ្រួសារគាត់ជួបជុំគ្នា ដើម្បីធ្វើការប្រជុំអធិស្ឋានពិសេសមួយ។ ពួកគាត់ចាំបាច់ត្រូវផ្ញើប្រាក់ទៅប្រទេសចិន ប៉ុន្តែពួកគាត់នៅខ្វះប្រាក់៤៩.១១ផោនទៀត។ ក្រោយមក លោកគ្រូ ហ័ដសិន បានដាក់ក្រដាសប្រាក់៥០ផោននៅលើតុ។ ប្រាក់ទាំងនេះហាក់បីដូចជាបានប្រទានមកផ្ទាល់ពីព្រះហស្តរបស់ព្រះជាម្ចាស់។

សូម្បីតែជាច្រើនឆ្នាំក្រោយមកនៃការឆ្លើយតបការអធិស្ឋាន ក៏ផ្លូវចូលទៅកាន់ចិនដីគោកនៅតែបិទដដែល។ តាមពិតទៅ ក្រោយពីការបញ្ជូនអ្នកត្រួសត្រាយផ្លូវទាំងដប់ប្រាំបីនាក់ចេញហើយ វាហាក់បីដូចជាជៀសមិនរួច ដែលសង្គ្រាមមួយនឹងត្រូវផ្ទុះឡើងដោយសារតែការធ្វើឃាតមន្ត្រីជនជាតិអង់គ្លេសម្នាក់។ ការចរចាបានជាប់គាំងអស់ជាច្រើនខែ ដោយសាររដ្ឋាភិបាលចិនបដិសេធមិនផ្តល់ដំណោះស្រាយស្កប់ចិត្តណាទាំងអស់ដល់ឯកអគ្គរាជទូតអង់គ្លេស ហើយឯកអគ្គរាជទូតអង់គ្លេសស្ទើរតែចាកចេញពីទីក្រុងបេកាំងទៅ។ វាមើលទៅហាក់បីដូចជាមិនអាចជៀសសង្គ្រាមបាននោះទេ ហើយមិត្តភក្តិមួយចំនួននៅក្នុងអង្គការបេសកកម្មចិនដីគោកបានព្យាយាមបញ្ចុះបញ្ចូលលោកគ្រូ ហ័ដសិន មិនឲ្យចេញទូកទៅជាមួយអ្នកធ្វើការថ្មីទាំងប្រាំបីនាក់នោះទេ។

ពួកគាត់បានលើកឡើងថា៖ «អ្នកទាំងអស់គ្នានឹងត្រូវត្រឡប់មកវិញទៅ ហើយការដែលបញ្ជូនអ្នកត្រួសត្រាយទៅកាន់ខេត្តឆ្ងាយៗ គឺមិនអាចទៅរួចឡើយ»។

តើមានកំហុសទេ? តើពួកគាត់បានប្រគល់មនុស្ស និងប្រាក់ទៅដោយឥតប្រយោជន៍មែនទេ? តើទឹកដីចិនដីគោកនៅតែបន្តបិទដោយគ្មានដំណឹងល្អចូលមែនទេ?

នៅក្នុងកាប៊ីនជាន់ទីបីនៃកប៉ាល់របស់ប្រទេសបារាំងមួយ មានបុរសម្នាក់កំពុងលុត

ជង្គង់អធិស្ឋានទៅកាន់ព្រះជាម្ចាស់។ ពីរឆ្នាំមុននោះ គាត់បានសរសេរថា៖ «ព្រលឹងខ្ញុំទន្ទឹងរង់ចាំយ៉ាងខ្លាំង ដើម្បីផ្សាយដំណឹងល្អដល់មនុស្សចំនួន១៨០លាននាក់នៅក្នុងបណ្ដាខេត្តដែលដំណឹងល្អទៅមិនទាន់ដល់ទាំងនេះ។ អូហ៍ ប្រសិនបើខ្ញុំមានជីវិតមួយរយដើម្បីឲ្យ ឬក៏ប្រើដើម្បីសុខុមាលភាពរបស់ពួកគេ មិនដឹងជាល្អយ៉ាងណាទេ!»។ គាត់បានធ្វើគ្រប់យ៉ាងតាមដែលគាត់អាចធ្វើបាន ដោយរក្សានិមិត្តគាត់ បើទោះបីជាជួបការបាក់ទឹកចិត្តគ្រប់បែបយ៉ាងក៏ដោយ។ ហើយពេលនេះ នឹងមានអ្វីកើតឡើងបន្ទាប់ទៀត?

ពេលវេលាព្រះជាម្ចាស់ពិតជាបានមកដល់ហើយ។ សម្រាប់ទ្រង់ វាមិនដែល «យឺតពេលពេក» នោះឡើយ។ នៅពេលចុងក្រោយ ការិយាល័យការបរទេសចិនមានការផ្លាស់ប្ដូរមួយ។ លោក លី ហាំងចាង (Li Hung-chang) ដែលជារដ្ឋបុរស និងទូតបានប្រញាប់ទៅកាន់ឆ្នេរសមុទ្រ ដោយបានជួបជាមួយរដ្ឋមន្ត្រីអង់គ្លេសនៅក្រុងឆិហ្វូ (Chefoo បច្ចុប្បន្នយ៉ាងតាយ) ដែលជាកន្លែងដែលពួកគេបានចុះហត្ថលេខាលើអនុសញ្ញាដែលគួរឲ្យចងចាំ ដែលទីបំផុតបានផ្ដល់សេរីភាព និងសិទ្ធិចូលទៅគ្រប់តំបន់ទាំងអស់នៃប្រទេសចិន។ លោកគ្រូ ហ័ដសិន មានសេចក្ដីសោមនស្សជាខ្លាំងនៅក្នុងការចងចាំថា៖ «ដូចដែលបងប្អូនយើងបានត្រៀមខ្លួនជាស្រេច។ មិនឆាប់ពេក ហើយក៏មិនយឺតពេលពេកដែរ ទ្វារដែលបានរង់ចាំអស់ពេលដ៏យូរ ពេលនេះបានបើកទ្វារដោយខ្លួនឯងហើយ»។

ជំពូកទី១៧

# ព្រះពរកាន់តែបរិបូរណ៍ ហូរហៀរ

*ព្រះគ្រីស្ទ គឺជាប្រភពទឹករស់*
*ជាអណ្តូងដ៏ជ្រៅនៃសេចក្តីស្រឡាញ់ដ៏ផ្អែម*
*ខ្ញុំបានភ្លក់ទឹកប្រភពទឹកទាំងឡាយនៅលើផែនដីហើយ*
*ហើយខ្ញុំនឹងផឹកទឹកពីនគរស្ថានសួគ៌ឲ្យច្រើនថែមទៀត។*
*— អេ.អរ. ខាសសិន (A. R. Cousin)*

នៅរយៈពេលជាងពីរឆ្នាំក្រោយមក អ្នកត្រួសត្រាយផ្លូវរបស់អង្គការបេសកកម្មចិនដីគោក បានធ្វើដំណើរជិតប្រាំម៉ឺនគីឡូម៉ែត្រទៅកាន់ខេត្តនានាក្នុងទឹកដីចិនដីគោក ដោយបានចែកចាយអំពីដំណឹងល្អនៃសេចក្តីស្រឡាញ់នៃការប្រោសលោះដោយឥតឈប់ឈរ។ ការនេះ ជាការសាកល្បងសេចក្តីជំនឿដ៏ធំបំផុតមួយ ដែលលោកគ្រូ ហ័ដសិនធ្លាប់បានជួប។ ប្រទេសមួយនេះ បានទទួលយកដំណឹងល្អគួរឲ្យកត់សម្គាល់ ហើយវាគួរឲ្យអាចយល់បាន បន្ទាប់ពីការទ្រាំទ្រនឹងការលំបាកអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីត្រួសត្រាយផ្លូវ ក្រុមបេសកជនវ័យក្មេងទាំងនោះចង់ប្រើឱកាសដែលកំពុងមាន ដើម្បីសង់ផ្ទះពួកគាត់ជាមូលដ្ឋានអចិន្ត្រៃយ៍សម្រាប់កិច្ចការរបស់ខ្លួន។ ជាធម្មតា ការងារនេះ

តម្រូវឲ្យមានមេផ្ទះ។ អ្នកត្រួសត្រាយផ្លូវ៣ទៅ៤នាក់ដែលបានភ្ជាប់ពាក្យជាស្រេចដើម្បីរៀបការ និងបានកំពុងតែរង់ចាំការអនុញ្ញាតពីលោកគ្រូ ហ៉ាដសិន ដើម្បីនាំក្រុមស្ត្រីជនជាតិស្បែកសចូលមកកាន់ទឹកដីខាងក្នុងក្នុងនាមជាសហការីរបស់ពួកគាត់។ ពួកគាត់ប្រហែលជាមិនបានស្មានទុកជាមុន ដូចជាអ្នកដឹកនាំពួកគេបានធ្វើឡើយ នៅក្នុងផលប៉ះពាល់ទាំងអស់ រួមទាំងរឿងដែលថា មិនយូរប៉ុន្មានស្ត្រីដទៃៗទៀតនឹងត្រូវចាប់ផ្តើមធ្វើដំណើរដ៏លំបាក ដើម្បីទ្រទ្រង់កិច្ចការដែលបានចាប់ផ្តើមដោយពួកម្តាយនានាក្នុងការតាំងទីលំនៅនៅកន្លែងដាច់ស្រយាលទាំងនោះ។

ជាច្រើនឆ្នាំមុន លោកគ្រូ ហ៉ាដសិន បានប្រឈមមុខរួចរាល់ហើយជាមួយរឿងនេះ ហើយក៏បានចាប់ផ្តើមគាំទ្រព័ន្ធកិច្ចស្ត្រីផងដែរ។ ដូចការរំពឹងទុកមែន មានការប្រឆាំងយ៉ាងខ្លាំងបានកើតឡើង នៅពេលគាត់បានអនុញ្ញាតឲ្យគូស្វាមីភរិយារៀបការរួចហើយចេញដំណើរលើកដំបូងទៅកាន់ទឹកដីដាច់ស្រយាលខាងក្នុង។ ការងារព័ន្ធកិច្ចក្នុងប្រទេសចិន បានកំពុងតែឈានចូលទៅកាន់ដំណាក់កាលថ្មីមួយទៀត ដោយតម្រូវឲ្យមានការលះបង់យ៉ាងថ្មី និងការទាមទារកាន់តែច្រើនខាងសេចក្តីជំនឿ និងការតស៊ូ។

ស្ថានភាពបានវិវត្តទៅតាមពេលវេលា។ រយៈពេលជាងមួយឆ្នាំ លោកគ្រូ ហ៉ាដសិន បានប្រឈមមុខនឹងការរិះគន់ដែលសំដៅទៅលើការធ្វើដំណើរដ៏វែងឆ្ងាយរបស់ពួកអ្នកត្រួសត្រាយផ្លូវ។ ការធ្វើដំណើរទាំងនេះ មិនបានទៅដោយរលូនជានិច្ចឡើយ។ ពួកគាត់ត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ផ្សេងៗ និងការបរាជ័យទន្ទឹមនឹងការលើកទឹកចិត្តដ៏សំខាន់ដូចគ្នា។ ដូចពីមុនដែរ ពួកគាត់បានជួបប្រទះទាំងទំនាស់ខាងក្រៅ និងក្តីព្រួយបារម្ភខាងក្នុង ហើយលោកគ្រូ ហ៉ាដសិន កំពុងជាប់ដៃដោះស្រាយកិច្ចការរដ្ឋបាលរបស់ព័ន្ធកិច្ចនៅទីក្រុងជីនគាំង (បច្ចុប្បន្នស៊ិនជាំង) បានធូរចិត្តដែលបាននៅជិតក្នុងការដឹកនាំ និងជួយគាំទ្រពួកគេដែរ។

អាថ៌កំបាំង ដើម្បីឲ្យខ្លួនគាត់មានកម្លាំងគឺងាយនឹងរកឃើញណាស់។ នៅវេលាណាដែលគាត់មានពេល លោកគ្រូ ហ៉ាដសិន ចូលទៅមើលទំនុកសរសើរតម្កើង ដើម្បីលំហែអារម្មណ៍ ដោយលេងភ្លេង ហើយច្រៀងបទចម្រៀងសរសើរតម្កើងដែលគាត់ចូលចិត្ត ប៉ុន្តែតែងតែចូលទៅឯឃ្លាមួយដែលថា៖

“ព្រះយេស៊ូវអើយ ទូលបង្គំកំពុងតែសម្រាកក្នុងក្តីអំណរដោយសារទ្រង់ជាព្រះ ទូល

បង្គំកំពុងតែរកឃើញភាពអស្ចារ្យនៃព្រះហឫទ័យដែលពេញដោយក្តីស្រឡាញ់របស់ទ្រង់ហើយ»។

មានម្តងនោះ នៅពេលលោក ចច នីកូល (George Nichol) ជាម្នាក់ក្នុងចំណោមអ្នកផ្សាយដំណឹងល្អទាំង១៨នាក់ បាននៅធ្វើការជាមួយគាត់ ស្របពេលការិយាល័យគាត់ក៏បានទទួលសំបុត្រមួយច្បាប់អមជាមួយដំណឹងអំពីកុប្បកម្មដ៏ធ្ងន់ធ្ងរនៅស្ថានីយបេសកកម្មចាស់ពីរកន្លែងដែរ។ នោះបុរសវ័យក្មេងបានគិតថា លោកគ្រូ ហ័ដសិន ប្រហែលជាចង់នៅតែម្នាក់ឯងហើយ ពេលគាត់បម្រុងនឹងដើរចេញទៅ គាត់មានការភ្ញាក់ផ្អើល ដោយគាត់បានឮសម្លេងនរណាម្នាក់បានចាប់ផ្តើមហួចយ៉ាងគ្រលួចនូវបទចម្រៀងដ៏ស្រទន់ពីបទទំនុកសរសើរតម្កើងដ៏ល្បីមួយបទ។

«ព្រះយេស៊ូវអើយ ទូលបង្គំកំពុងតែសម្រាកក្នុងក្តីអំណរនៃទ្រង់ដោយសារទ្រង់ជាព្រះ»។

លោក នីកូល មិនអាចជួយអ្វីបានទេ ក្រៅពីបានងាកក្រោយ ដោយលើកឡើងថា៖ «ហេតុអ្វីក៏គាត់ចេះហួចសប្បាយទៅកើត ទាំងដែលពួកសម្លាញ់យើងកំពុងស្ថិតក្នុងគ្រោះថ្នាក់ដ៏ខ្លាំងដូច្នេះ!»។

លោកគ្រូ ហ័ដសិន បានតបដោយត្រជាក់ចិត្តថា៖ «តើប្អូនប្រុសចង់ឲ្យខ្ញុំថប់បារម្ភហើយកើតទុក្ខឬអី? ការនោះនឹងមិនបានជួយអ្វីដល់ពួកគេទេ ហើយច្បាស់ជារាំងខ្ញុំពីការធ្វើកិច្ចការរបស់ខ្ញុំជាមិនខាន។ ខ្ញុំទើបតែផ្ទេរបន្ទុកនេះទៅកាន់ព្រះយេហូវ៉ាតែប៉ុណ្ណោះ!»។

នេះគឺជាអាថ៌កំបាំងរបស់គាត់ទាំងយប់ទាំងថ្ងៃ គាត់ «គ្រាន់តែថ្វាយបន្ទុករបស់គាត់ទៅកាន់ព្រះជាម្ចាស់ប៉ុណ្ណឹងបានហើយ»។ ជាញឹកញាប់ អស់អ្នកដែលមិនទាន់សម្រាន្តនៅក្នុងផ្ទះតូចនៅជីនគាំង (បច្ចុប្បន្នស៊ិនជាំង) នឹងឮលោកគ្រូ ហ័ដសិន ច្រៀងចម្រៀងសរសើរតម្កើងដែលគាត់ចូលចិត្តយ៉ាងស្រទន់នៅម៉ោងពីរ ឬម៉ោងបីទៀបភ្លឺ។ គាត់បានដឹងថា គាត់អាចគ្រាន់តែរស់នៅក្នុងជីវិតមួយបែប—ជាជីវិតដែលមានព្រះពរនៃការសម្រាកនិងការរីករាយក្នុងព្រះអម្ចាស់នៅគ្រប់ស្ថានភាពទាំងអស់ ដោយទុកចិត្តថា ទ្រង់នឹងដោះស្រាយគ្រប់ឧបសគ្គទាំងអស់ មិនថាខាងក្នុង ខាងក្រៅ មិនថាធំ ឬតូចក្តី។

លោកគ្រូ ហ័ដសិន បានត្រឡប់មកទីក្រុងឡុងដ៏វិញ ស្របពេលដែលមនុស្សប្រាំមួយ

លានាក់នៅប្រទេសចិនភាគខាងជើងបានប្រឈមមុខការអត់ឃ្លាននៅក្នុងខេត្តមួយ ដោយមានតែអ្នកត្រួសត្រាយផ្លូវនៃអង្គការបេសកកម្មចិនដីគោកប៉ុន្មាននាក់ប៉ុណ្ណោះជាបេសកជននៅទីនោះ។ ក្មេងៗរាប់ពាន់នាក់កំពុងតែជិតស្លាប់ ហើយក្មេងស្រីជំទង់ៗកំពុងត្រូវតែបានលក់ឲ្យធ្វើជាទាសកររគេ ហើយបាននាំទៅបណ្ដាទីក្រុងនានានៅភាគខាងត្បូងដែរ។ លោកគ្រូ ហ័ដសិន បានត្រឡប់មកផ្ទះវិញពេញទៅដោយបន្ទុកពីស្ថានភាពអាក្រក់លើសលប់នេះ និងបានកំពុងតែធ្វើអ្វីគ្រប់យ៉ាងដែលគាត់អាចធ្វើបាន ដើម្បីជួយគាំទ្រទៅដល់កិច្ចខិតខំប្រឹងប្រែងសង្គ្រោះនេះ។ បើទោះបីជា ប្រាក់ជំនួយបានត្រៀមរួចរាល់សម្រាប់សង្គ្រោះក្មេងៗក៏ដោយ ក៏មិនមានស្ត្រីណាទំនេរអាចធ្វើដំណើរទៅកាន់ខេត្តដែលគ្រោះមហន្តរាយនោះបានវាយប្រហារ ដើម្បីកាន់កាប់ការងារនោះដែរ។ គ្មានស្ត្រីស្បែកសណា បានឆ្លងភ្នំដែលខណ្ឌចែកសានស៊ី (Shansi) ពីឆ្នេរសមុទ្រឡើយ ហើយដើម្បីទៅដល់តំបន់នោះតម្រូវឲ្យធ្វើដំណើរពីរសប្ដាហ៍ដោយជិះរទេះលាឆ្លងកាត់ផ្លូវដ៏មានគ្រោះថ្នាក់ ហើយពេលយប់ត្រូវសម្រាកនៅក្នុងផ្ទះសំណាក់មិនស្អាតទៀតផង។

លោក និងលោកស្រី ហ័ដសិន បានបែកគ្នាក្នុងកាលដែលគាត់បាននៅផ្ទះត្រឹមតែ២ទៅ៣ខែតែប៉ុណ្ណោះ ខណៈដែលលោក ហ័ដសិន ត្រូវចេញទៅដើម្បីបំពេញបេសកកម្មគាត់។ កូនសៀវភៅកំណត់ត្រាចាស់តូចមួយបានប្រាប់លម្អិតអំពីបទពិសោធន៍ដែលបានពង្រឹងសេចក្ដីជំនឿរបស់លោកស្រី ហ័ដសិន ខណៈពេលគាត់បានអធិស្ឋានសម្រាប់ការបញ្ជាក់ឲ្យច្បាស់ថា តើការត្រាស់ហៅនេះពិតជាមកពីព្រះឬយ៉ាងណា។ នៅពេលគាត់បានដឹងជាក់ហើយ គាត់មិនបានស្ទាក់ស្ទើរទេ បើទោះបីជាត្រូវលះបង់ដើម្បីលោកគ្រូ ហ័ដសិន ដែលជាអ្នកស្នើគំនិតនេះក៏ដោយ។ គាត់បានប្រឈមមុខនឹងការចាកចេញពីកូនៗទាំងប្រាំពីរនាក់ រួមទាំងកូនបង្កើតពីរនាក់ កូនធំៗបួននាក់ ព្រមទាំងកូនស្រីចិញ្ចឹមម្នាក់។ គាត់បានទូលថ្វាយការបារម្ភយ៉ាងខ្លាំងនោះទៅកាន់ព្រះជាម្ចាស់ដែលទ្រង់ជាអង្គដែលប្រទានដំណោះស្រាយចំពោះគ្រប់ឧបសគ្គទាំងអស់ ហើយបានប្រទានកម្លាំងដើម្បីតស៊ូនៅពេលបែកគ្នា និងការងារពិបាកដែលមានគ្រោះថ្នាក់នៅខាងមុខនាប្រទេសចិនដែរ។

“យើងត្រូវការមនុស្សដែលសុខចិត្តលះបង់ខ្លួនឯងចោល ហើយផ្ទុកឈើឆ្កាង។ ខ្ញុំអធិស្ឋានទូលសូមឲ្យព្រះជាម្ចាស់បណ្ដុះព្រលឹងវិញ្ញាណនេះទាំងក្នុងខ្ញុំ និងបង។ ខ្ញុំមាន

សេចក្តីអាម៉ាស់ដែលខ្ញុំបានរងការប៉ះពាល់ពីការគិតដល់បង និងកូនៗសម្លាញ់របស់យើង ច្រើនជាងមនុស្សចំនួនរាប់លាននាក់ ដែលកំពុងស្លាប់នៅទីនេះ បើទោះជាយើងប្រាកដថា នឹងបាននៅជាមួយគ្នាអស់កល្បជានិច្ចក៏ដោយ»។

នៅពេលភរិយាលោកគ្រូ ហ័ដសិន បានត្រួសត្រាយផ្លូវរួចមក វាកាន់តែងាយស្រួលទៀតសម្រាប់គាត់នៅក្នុងការស្វាគមន៍ស្ត្រីដទៃទៀតឲ្យចូលរួមបម្រើជាមួយគាត់នៅក្នុងប្រទេសចិននៅជួរមុខ។ នៅពេលពួកគាត់បានជួបគ្នាមួយឆ្នាំក្រោយមកនៅឆ្នាំ១៨៧៩ រង្វាន់របស់គាត់គឺជាការបានភរិយាមកចូលរួមជាមួយនៅប្រទេសចិន នៅក្នុងកាលដែលកិច្ចការស្ត្រីបានចាប់ផ្តើមទៅមុខយ៉ាងសន្សឹមៗនៅខេត្តនីមួយៗនៅទឹកដីចិនដីគោក។ រឿងរ៉ាវប៉ុន្មានឆ្នាំនេះ  គឺគួរឲ្យចាប់អារម្មណ៍ដូចជាដំណើររឿងនៅក្នុងប្រលោមលោកអញ្ចឹង។ ពួកស្ត្រីៗដំបូងធ្វើដំណើរទៅភាគខាងលិចដ៏ឆ្ងាយបានជួបនឹងគ្រោះមហន្តរាយដោយត្រូវសំពៅលិចនៅជ្រលងទន្លេយ៉ាងជឺ ដោយប្រើពេលវេលាសម្រាប់បុណ្យណូអែលមិនធម្មតា គឺដោយយករបស់របរសម្រាប់ការរៀបអាពាហ៍ពិពាហ៍ពួកគេចេញដាក់ហាលឲ្យស្ងួតនៅលើថ្ម។ នៅពេលទៅដល់គោលដៅរបស់ខ្លួន មានហ្វូងមនុស្សដ៏សម្បើមបានមកចោមរោមពួកគាត់!

លោកស្រី និច (Nich) បានសរសេរមកពីក្រុងជុនឃីង (បច្ចុប្បន្នចុងឈីង) ថា៖ «អស់ជិតរយៈពេលពីរខែហើយ ខ្ញុំបានជួបស្ត្រីរាប់រយនាក់រៀងរាល់ថ្ងៃ។ ផ្ទះរបស់យើងដូចជាកន្លែងតាំងពិព័រណ៍អញ្ចឹង»។

ដោយសារតែគាត់ជាស្ត្រីស្បែកសតែម្នាក់ឯងនៅក្នុងខេត្តមួយដែលមានមនុស្សចំនួនប្រហែលហុកសិបលាននាក់ ជាញឹកញាប់ គាត់បានដួលសន្លប់ដោយសារភាពនឿយហត់ និងអស់កម្លាំងនៅកណ្តាលចំណោមភ្ញៀវរបស់គាត់។ គាត់ភ្ញាក់ដឹងខ្លួនវិញដោយគាត់ឃើញថា មានពួកស្ត្រីៗបង្ហាញក្តីស្រឡាញ់ និងការព្រួយបារម្ភចំពោះគាត់ ខណៈពេលដែលគាត់សន្លប់។ មានស្ត្រីម្នាក់ តែងតែប្រព្រឹត្តនឹងគាត់ដូចជាកូនស្រីរបស់គាត់ជារឿយៗបានឲ្យគ្រែស្នែងជូនគាត់មកលេងផ្ទះគាត់ ដោយទទូចឲ្យលោកស្រី និចឆ្លូតត្រឡប់មកវិញដោយជិះគ្រែស្នែងភ្លាមៗ។ គ្រែដ៏មានផាសុកភាពបំផុត បានត្រៀមរួចជាស្រេចសម្រាប់គាត់ ហើយបន្ទាប់ពីឲ្យស្ត្រីក្មេងៗទាំងអស់ទៅអស់ហើយ ស្ត្រីម្នាក់នោះក៏ជួយបក់ផ្លិតឲ្យគាត់ដោយផ្ទាល់រហូតគាត់បានសម្រាន្តលក់ទៅ។ ពួកគេបានរៀបចំ

អាហារពេលល្ងាចដែលគួរឲ្យចង់បរិភោគសម្រាប់គាត់ ហើយពួកគេនឹងឃាត់មិនឲ្យលោកស្រី និចឆូល លាទៅវិញទេ លុះត្រាតែគាត់បានបរិភោគឆ្អែតចប់សព្វគ្រប់ជាមុនសិន។

គ្រប់កន្លែងដែលពួកស្ត្រីដំបូងបានទៅ ពួកគាត់ក៏បានជួបនឹងការភ្ញាក់ផ្អើល—មនុស្សម្នារីករាយនឹងជួបពួកគេ ជាញឹកញាប់ពួកគេចង់ឮអំពីសាររបស់ស្ត្រីទាំងនោះ ដោយមិនបង្ហាញគ្រាន់តែការចង់ដឹងចង់ឮ ប៉ុន្តែក៏បង្ហាញអំពីក្តីអាណិតអាសូរពិតប្រាកដផងដែរ។ ហើយវាបានធ្វើឲ្យមានឥទ្ធិពលយ៉ាងឆាប់រហ័សលើ—ការរស់នៅ និងការបង្រៀនអំពីព្រះយេស៊ូវដោយបើកចំហ។ នៅចុងឆ្នាំទីពីររបស់ពួកគេ ពួកស្ត្រីបេសកជនអបអរ នៅពេលពួកគេបាននាំឲ្យមានអ្នកប្រែចិត្តជឿព្រះយេស៊ូវហុកសិប ឬចិតសិបនាក់ប្រែចិត្តជឿ ហើយថ្វាយបង្គំនៅក្រុមជំនុំតូចៗនៅក្នុងខេត្តនានានៅចិនដីគោកដ៏សែនឆ្ងាយ។

លោកស្រី អ៊ីមមីលី ឃីង (Emily King) គឺជាស្ត្រីដំបូងដែលបានមកសួរសុខទុក្ខស្ត្រីៗនៅភាគខាងជើងឆៀងខាងត្បូង ក្រោយពីការធ្វើដំណើរបីខែឡើងទៅទន្លេហាន (Han) ប៉ុន្តែគាត់ក៏ជាមនុស្សដំបូងផងដែរ ដែលបានទទួលមរណៈភាពនៅក្នុងខែឧសភា ឆ្នាំ១៨៨១។ មុនពេលដែលគាត់ស្លាប់ទៅ គាត់មានអំណរក្នុងការឃើញស្ត្រី១៨នាក់បានទទួលពិធីជ្រមុជទឹក នៅពេលពួកគេប្រកាសសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ។ ទោះបីជាគាត់បានទទួលមរណៈភាពដោយសារជំងឺគ្រុនពោះវៀននៅក្នុងទីក្រុងហានជុង (Hanchung) ក៏ដោយក៏គាត់បានស្កប់ចិត្តដោយសារឥទ្ធិពលដែលគាត់មានទៅលើពួកស្ត្រីៗដែរ ហើយគាត់បានយកចិត្តទុកដាក់លើរឿងនោះ ជាជាងមានអារម្មណ៍ក្រៀមក្រំដែលត្រូវចាកចេញពីស្វាមីគាត់ និងកូនៗគាត់។ គាត់បានរកឃើញការស្កប់ចិត្តនៅក្នុងការរួមចំណែកក្នុងនិមិត្តរបស់ព្រះគ្រីស្ទ (មនុស្សទូទុក្ខ) ដែលទ្រង់បានឃើញ “ផលនៃការដែលព្រលឹងទ្រង់រងវេទនា” ក្នុងចំណោមពួកគាត់ដែលទ្រង់បានរង់ចាំជាយូរមកហើយ (អេសាយ ៥៣:១១)។

លោកគ្រូ ហ័ដសិន បានយល់អំពីតម្លៃដែលបានលះបង់សម្រាប់កិច្ចការនេះខ្លាំងជាងអ្នកណាទាំងអស់ ហើយបានអធិស្ឋានជានិច្ចមិនដែលខកខានចំពោះរឿងនេះឡើយ។

គាត់បានសរសេរទៅម្តាយរបស់គាត់ក្នុងពេលមានការសាកល្បងជាច្រើនថា៖ “ខ្ញុំមិនអាចបង្ហាញថា ខ្ញុំសប្បាយចិត្តយ៉ាងណាទេដែលបានឃើញការងារីកចម្រើន និងខ្លាំងក្លាឡើងនៅតំបន់ដាច់ស្រយាលនៃប្រទេសចិន ទោះបីជាមានបញ្ហាប្រឈមជាច្រើនបានកើត

ឡើងក៏ដោយ ក៏វាជាអ្វីដែលមានតម្លៃសម្រាប់ឲ្យយើងរស់នៅ ហើយក៏មានតម្លៃ ដើម្បីឲ្យយើងស្លាប់សម្រាប់វាផងដែរ»។

មានការរីកចម្រើនយ៉ាងឆាប់រហ័ស និងអស្ចារ្យបន្ទាប់ពីពេលនោះមក។ ទោះជាយ៉ាងណាក៏ដោយ ស្របគ្នានឹងការរីកចម្រើនថ្មីនីមួយៗ ហើយការទទួលអំណាចនៃព្រះ និងព្រះពរហើយលោកគ្រូ ហ៉ាដសិន ក៏បានឆ្លងកាត់បទពិសោធន៍ផ្ទាល់ខ្លួននៃការរងទុក្ខ និងការសាកល្បងដែរ។ ជីវិតរបស់គាត់ត្រូវតែចូលទៅឲ្យកាន់តែជ្រៅទៅៗ ក្នុងព្រះជាម្ចាស់។ ជួនកាល វាប្រហែលជាហាក់បីដូចជាថា ការងារដែលពួកគេធ្វើកំពុងដើរលើទំនោរនៃភាពជោគជ័យ។ ពួកគេបានបោះជំហាននៃសេចក្តីជំនឿដ៏រុងរឿង ហើយបានទទួលចម្លើយដ៏រុងរឿងចំពោះការអធិស្ឋាននោះដែរ។ ប៉ុន្តែ មានតែអ្នកដែលធ្វើការនៅពីក្រោយរឿងនេះប៉ុណ្ណោះទេ ដែលបានដឹងពីការត្រៀមចិត្តទុកជាមុន និងការទទួលបន្ទុកជាប់ជានិច្ច។ ពួកគេមានការគោរពចំពោះពួកគាត់ដែលបានពិនិត្យដោយប្រុងប្រយ័ត្ន និងជ្រាលជ្រៅចំពោះគំនិត និងអារម្មណ៍ដ៏ជ្រាលជ្រៅរបស់គេ ការសាកល្បងជំនឿបែបនេះ និងការអនុវត្តខាងឯព្រលឹងដ៏ជ្រាលជ្រៅបែបនេះ។ មនុស្សម្នាក់ត្រូវតែត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការគ្រប់យ៉ាងជាមួយព្រះជាម្ចាស់ ស្លាប់ជារៀងរាល់ថ្ងៃក្នុងភាពស្ងប់ស្ងាត់ ការពិតជាក់ស្តែង ដើម្បីបម្រើមិត្តសម្លាញ់របស់គាត់ ហើយជាអ្នកតូចជាងគេ និងជាអ្នកបម្រើគេទាំងអស់ ហើយបន្តអង្វរសម្រាប់ពួកគេ។ គាត់មិនត្រឹមតែត្រូវទ្រាំទ្រចំពោះភាពបរាជ័យ និងភាពទន់ខ្សោយរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវលើកពួកគេឡើងដោយជំនឿដែលជួយពួកគេ និងដោយសេចក្តីស្រឡាញ់ដល់កម្រិតខ្ពស់ជាងមុនផងដែរ—នេះគឺជាវិធីតែមួយគត់ដែលភាពជោគជ័យខាងវិញ្ញាណអាចសម្រេចបាន។

មុនការរីកចម្រើនដែលធ្វើឲ្យការងារមានភាពស្រស់ស្អាត—ពេលបេសកជនជាស្ត្រីបានធ្វើដំណើរទៅក្នុងទឹកដីចិនដីគោកដំបូង—មានគ្រាមួយនៃការរងទុក្ខដ៏ខ្លាំងក្លា និងយូរអង្វែងបានកើតឡើង។ នៅឆ្នាំ១៨៧៩ ជីវិតរបស់លោកគ្រូ ហ៉ាដសិន ប្រឈមនឹងហានិភ័យបីដងដោយសារជំងឺធ្ងន់ធ្ងរ។ នៅឆ្នាំបន្ទាប់ ដោយសារវិធីសាស្ត្រថ្មីកំពុងត្រូវបានសាកល្បង និងបញ្ជាក់ដោយការសព្វព្រះហឫទ័យពីព្រះ អង្គការបេសកកម្មចិនដីគោក បានប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរផ្សេងៗ និងរាប់មិនអស់ជាច្រើន។ លោកស្រី ថេល័របានគូសបញ្ជាក់ពីគោលការណ៍សំខាន់មួយ នៅពេលគាត់សរសេរនៅពេលនោះ៖

«តើលោកអ្នកគិតថា ប្រសិនបើយើងបន្តប្តេជ្ញាថា មិនព្រមឲ្យសម្ពាធណាមួយធ្វើឲ្យប៉ះពាល់ចំពោះទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអម្ចាស់ នោះយើងអាចទទួលបានជោគជ័យដែលនឹងបន្លឺឡើងពីគ្រប់ផ្នែកនៃបេសកកម្មរបស់យើងជានិច្ចដែរឬទេ? ថ្មីៗនេះខ្ញុំបានចាប់អារម្មណ៍ថា ការងារសំខាន់បំផុតរបស់យើង គឺជាការងារដែលមើលមិនឃើញ គឺជាការអធិស្ឋាន និងទូលអង្វរនៅកន្លែងស្ងាត់។ សេចក្តីជំនឿរបស់យើងត្រូវតែទទួលបានជ័យជម្នះសម្រាប់ដៃគូធ្វើការជាមួយយើងដែលព្រះបានប្រទានមកដល់យើង។ ពួកគាត់ដោះស្រាយនឹងការតយុទ្ធដែលអាចមើលឃើញ ខណៈពេលដែលយើងត្រូវប្រឈមមុខដោះស្រាយនឹងអ្វីដែលមើលមិនឃើញ។ នៅពេលដែលកិច្ចការនោះជារបស់ផងទ្រង់ ហើយយើងបានមកក្នុងព្រះនាមទ្រង់ តើយើងរំពឹងនឹងអ្វីដែលតូចជាងការទទួលជ័យជម្នះជាបន្តបន្ទាប់បានដែរឬទេ?»

ប្រៀបដូចជាច្បាប់ខាងឯវិញ្ញាណៈ គ្រានៃការសាកល្បង គឺតែងតែនាំទៅរកការរីកចម្រើន និងព្រះពរ។ ឧទាហរណ៍ៈ  រឿងនេះបានកើតឡើង នៅពេលដែលអ្នកដឹកនាំបេសកកម្មចិនដីគោកបានធ្វើដំណើរទៅភាគខាងលិច ក្រោយពីនិយាយលាលោកស្រីថេល័រ ដែលចាកចេញឆ្ងាយពីផ្ទះ ដើម្បីជួបជាមួយអ្នកធ្វើការថ្វាយព្រះដ៏វ័យក្មេងមួយចំនួន។

លោកគ្រូ ហ័ដសិន  បានសរសេរថាៈ «ប្អូនជាទីស្រឡាញ់នឹងជិះទូកឆ្លងកាត់សមុទ្រមេឌីទែរ៉ាណេ ហើយនឹងទៅដល់ទីក្រុងណាបែលនៅប្រទេសអ៊ីតាលីឆាប់ៗនេះ។ អូនកំពុងរង់ចាំទូកជិះទៅ វ៉ូចាង។ អូនមិនចាំបាច់ប្រាប់ប្អូនថា បងនឹកប្អូនប៉ុណ្ណាទេ ពីព្រោះប្អូនដឹងហើយ។ ទោះយ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់កំពុងបង្ហាញបងថា នៅក្នុងព្រះវត្តមាន និងសេចក្តីស្រឡាញ់របស់ទ្រង់ យើងមានភាពបរិបូរណ៍ក្នុងព្រះអង្គហើយ។ ព្រះអង្គកំពុងជួយបងឲ្យមានអំណរក្នុងស្ថានភាពលំបាករបស់យើង ភាពក្រីក្ររបស់យើង និងក្នុងការចូលនិវត្តន៍ពីអង្គការបេសកកម្មចិនដីគោករបស់យើង។ ការលំបាកទាំងអស់នេះ គ្រាន់តែជាដំណាក់កាលក្នុងការបង្ហាញអំពីព្រះគុណ អំណាចព្រះចេស្តា និងសេចក្តីស្រឡាញ់របស់ទ្រង់ប៉ុណ្ណោះឯង»។

គាត់បានសរសេរបន្តពីវ៉ូចាង នៅពេលដែលការប្រជុំបានចាប់ផ្តើម ដោយនិយាយថាៈ «បងរវល់ណាស់។ ព្រះជាម្ចាស់កំពុងប្រទានពរដល់យើងដោយប្រទានពេលវេលាដ៏មាន

អំណរនៃការប្រកបគ្នា និងការបញ្ជាក់ឡើងវិញនូវគោលការណ៍ដែលដឹកនាំសកម្មភាពរបស់យើង»។

នៅក្នុងប្រយោគខ្លីនោះ ក្នុងកាលដែលបានមើលវិបត្តិដែលពួកគេបានជួបប្រទះមកជាមួយ បានបំភ្លឺយ៉ាងភ្លឺដល់ព្រឹត្តិការណ៍សំខាន់ៗដែលកើតឡើង បន្ទាប់ពីការប្រកបគ្នារបស់ពួកគេនៅវ៉ូចាង ។ ក្រុមបេសកជនវ័យក្មេងមិនបានដឹងពីការនោះទេ ប៉ុន្តែពួកគាត់ឈានដល់ចំណុចរបត់មួយ ហើយសូម្បីតែលោកគ្រូ ហ៉ដសិន ក៏មិនច្បាស់លាស់អំពីស្ថានភាពដែលនឹងកើតឡើងដែរ។ បន្ទាប់ពីការអធិស្ឋានអស់ជាច្រើនឆ្នាំៈ ការអត់ធន់ និងការខិតខំយ៉ាងខ្ជាប់ខ្ជួន នោះពួកគាត់បានទទួលឱកាសមិនធ្លាប់មានពីមុនមក។ ទឹកដីចិនដីគោកបានបើកចំហសម្រាប់ពួកគាត់។ ការពង្រឹងព័ន្ធកិច្ចត្រូវការនៅគ្រប់ទីតាំងដែលបានបង្កើតឡើងនៅទូទាំងភាគខាងជើងឆ្ងាយ ខាងត្បូង និងខាងលិច។ ការស្ទាក់ស្ទើរនៅក្នុងការឈានទៅមុខមានន័យថា ការដកខ្លួនចេញពីជំហរផ្អែកលើជំនឿដែលពួកគេបានជឿពីដំបូង។ ការនោះមានន័យថា ពួកគេផ្តោតទៅលើឧបសគ្គជាជាងព្រះជាម្ចាស់។ ជាការពិតមានការខ្វះខាតអស់ជាច្រើនឆ្នាំមកហើយទាក់ទងនឹងប្រាក់មូលនិធិ ហើយក៏មានអ្នកធ្វើការបម្រើព្រះថ្មីតែប៉ុន្មាននាក់ប៉ុណ្ណោះបានមក។ វាជារឿងសាមញ្ញក្នុងការប្រកាសថា មិនមានការពង្រីកបន្ថែមទៀតទេនាពេលនោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការបដិសេធមិនដំណើរការនឹងធ្វើឲ្យខូច និងបង្អាក់ការងារ ដោយខ្ជះខ្ជាយឱកាសដែលព្រះបានផ្តល់ឲ្យ ហើយមិនយូរប៉ុន្មានឈានទៅដល់ការបិទស្ថានីយបេសកកម្មដែលបានបើកដោយចំណាយប្រាក់អស់ជាច្រើន។ នេះទំនងជាប្រាកដថា វាមិនអាចជាផ្លូវរបស់ទ្រង់ក្នុងការផ្សព្វផ្សាយដំណឹងល្អទូទាំងប្រទេសចិនដីគោកនោះទេ។

តើអ្វីទៅជាលទ្ធផលនៃរយៈពេលរង់ចាំព្រះជាម្ចាស់យ៉ាងស្ងៀមស្ងាត់? វាគឺជាជំហាននៃសេចក្តីជំនឿដ៏គួរឲ្យភ្ញាក់ផ្អើល ដែលដំបូងហាក់ដូចជាបាត់បង់ការគាំទ្រពីមិត្តសម្លាញ់របស់យើង។ ពួកគាត់បានធ្វើការស្នើសុំយ៉ាងក្លាហានទៅកាន់ក្រុមជំនុំនៅប្រទេសរៀងៗខ្លួនសុំឲ្យមានអ្នកធ្វើការបម្រើព្រះថ្មីចំនួនចិតសិបនាក់ទៀត ដើម្បីនឹងចេញមកធ្វើការបម្រើព្រះក្នុងរយៈពេលបីឆ្នាំខាងមុខ ដែលក្រោយមកសមាជិកនៃអង្គការបេសកកម្មចិនដីគោកស្ទើរតែទាំងអស់បានចុះហត្ថលេខា។ អង្គការបេសកកម្មមានសមាជិកប្រហែលមួយរយនាក់ប៉ុណ្ណោះ ហើយពួកគាត់មានការខ្វះខាតថវិកាអស់ពេលជាយូរណាស់មកហើយ។

យ៉ាងណាក៏ដោយក៏ក្រុមនៅវ៉ូចាងមានទំនុកចិត្តយ៉ាងខ្លាំងថា ព្រះជាម្ចាស់កំពុងដឹកនាំពួកគេក្នុងការអធិស្ឋានជាក់លាក់មួយ ដោយសេចក្ដីសង្ឃឹម។ មានសមាជិកម្នាក់បានបន្លឺវាចាឡើងថា៖

«វាពិតជាការល្អ ប្រសិនបើយើងអាចជួបគ្នាម្ដងទៀត ហើយរៀបចំការប្រជុំសរសើរតម្កើងរួមគ្នាម្ដង នៅពេលចុងក្រោយនៃពួកចិតសិបនាក់បានទៅដល់ប្រទេសចិន»!

ពួកគេបានយល់ព្រមលើរយៈពេលបីឆ្នាំ (១៨៨២-១៨៨៤) ដើម្បីរង់ចាំចម្លើយ ដោយទទួលយក និងរៀបចំទទួលអ្នកចម្រូតថ្មីនៅក្នុងពេលខ្លីនឹងពិបាក។

មនុស្សម្នាក់ទៀតដែលអនុវត្តជាក់ស្ដែងបាននិយាយថា៖ «បន្ទាប់មកយើងនឹងត្រូវខ្ចាត់ខ្ចាយទៅគ្រប់ទីកន្លែង។ ប៉ុន្តែហេតុអ្វីបានជាយើងមិនរៀបចំការប្រជុំសរសើរតម្កើងឥឡូវនេះទៅ? ហេតុអ្វីបានជាមិនអរព្រះគុណចំពោះពួក៧០នាក់ឲ្យហើយ មុនពេលយើងចេញទៅតាមផ្លូវរៀងៗខ្លួនរបស់យើង?»។

ការនេះត្រូវបានអនុញ្ញាត ហើយការប្រជុំបានធ្វើឡើងដោយអនុញ្ញាតឲ្យគ្រប់គ្នា ដែលបានចូលរួមនៅក្នុងការអធិស្ឋានក៏បានរួបរួមនៅក្នុងការអរព្រះគុណដែរ។

អ្នកទាំង៧០នាក់ ត្រូវបានប្រទានមកយ៉ាងអស្ចារ្យនៅបីឆ្នាំបន្ទាប់។ ប៉ុន្តែ ទ្រង់បានល្បងលសេចក្ដីជំនឿបានក្នុងរបៀបជាច្រើន។ បញ្ហាប្រាក់ជំនួយនៅតែជាបញ្ហាយ៉ាងធំ ប៉ុន្តែត្រូវបានគ្របសង្កត់ដោយបញ្ហាប្រឈមដែលទាក់ទងនឹងការងារនោះផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ក៏លោកគ្រូ ហ័ដសិន អាចសរសេរយ៉ាងដូច្នេះថា៖

«ខ្ញុំកាន់តែមានអារម្មណ៍ថា កំពុងទទួលព្រះពរនៃការទុកចិត្តពិតប្រាកដលើព្រះជាម្ចាស់។ ទ្រង់បានល្បងលសេចក្ដីជំនឿរបស់យើង ប៉ុន្តែក៏ជួយជ្រោមជ្រែងដល់ពួកយើងដែរ។ ហើយក្នុងកាលដែលសេចក្ដីស្មោះត្រង់របស់យើងចេះតែរសាយទៅ ក៏ទ្រង់មិនរវាតព្រះទ័យដែរ។ “ទ្រង់មិនអាចបដិសេធអង្គទ្រង់ផ្ទាល់បានទេ”» (២ធីម៉ូថេ ២:១៣)។

«រឿងរ៉ាវកើតឡើងនៅឆ្នាំនេះ ព្រមទាំងការល្បងលដ៏ពិសេសទាំងឡាយរបស់រឿងរ៉ាវនោះផ្ទាល់ស្ទើរតែគ្រប់ទិសទី ធ្វើឲ្យដួងចិត្តរបស់ខ្ញុំពុះកញ្ជ្រោលឡើង ហើយបរិបូរណ៍ហូរហៀរទៅដោយសេចក្ដីស្រឡាញ់ចំពោះព្រះអម្ចាស់យេស៊ូវ។ ទ្រង់ជ្រាបពីការបែកគ្នា និងរឿងរ៉ាវដែលជាប់ពាក់ព័ន្ធនឹងការបែកគ្នារបស់យើង ហើយទ្រង់បានត្រឡប់ការខាតបង់ទាំងអស់ទៅជាផលចំណេញយ៉ាងគួរឲ្យកត់សម្គាល់…ខ្ញុំសូមអភ័យទោសដែលខ្ញុំ

បានបន្តរៀបរាប់រឿងរ៉ាវបន្តយ៉ាងយូរ។ ដួងចិត្តដែលរីករាយរបស់ខ្ញុំទទួលអារម្មណ៍ថា វាត្រូវតែបង្ហាញដោយខ្លួនវា សូម្បីតែនៅចំកណ្តាលរឿងតួលេខ និងប្រតិបត្តិការប្រាក់កាក់នេះក៏ដោយ»។

នៅពេលដែលបីឆ្នាំដំបូងបានកន្លងផុតទៅ វាច្បាស់ណាស់ថា មានការសង្ស័យយ៉ាងខ្លាំងនៅស្រុកកំណើតពួកគាត់ទាក់ទងនឹងការទទូចសុំ ក្នុងអំឡុងពេលដែលគេរង់ចាំពួកអ្នកទាំងចិតសិបនាក់នោះ។ លោកគ្រូ ហ័ដសិន ស្ថិតនៅក្នុងស្រុកឆ្វែហ្វូ (បច្ចុប្បន្នយ៉ានតាយ) នៅពេលនោះ ហើយមានអារម្មណ៍ថា ព្រះបណ្តាលចិត្តឲ្យទូលសុំព្រះអម្ចាស់ចំពោះការយល់ស្របទៅលើបញ្ហានេះដោយច្បាស់ៗ។ ការនេះបានកើតឡើងនៅក្នុងការប្រជុំអធិស្ឋានប្រចាំថ្ងៃមួយនៅអំឡុងថ្ងៃទី២ ខែកុម្ភៈ ហើយមនុស្សពីរបីនាក់ដែលនៅទីនោះមានអារម្មណ៍ថា មានសេរីភាពក្នុងការថ្វាយសំណើនេះទៅកាន់ព្រះជាម្ចាស់។

យើងបានដឹងថា សេចក្តីស្រឡាញ់របស់ព្រះវរបិតាគឺធ្វើឲ្យកូនៗរបស់ទ្រង់រីករាយឡើង ដូច្នេះយើងបានទូលសុំទ្រង់ដោយសេចក្តីស្រឡាញ់ គឺសូមឲ្យទ្រង់ប្រទាននូវសេចក្តីអំណរដល់យើង ហើយកំឡាចិត្តអ្នកដែលអៀនខ្មាសនៅក្រុមជំនុំនៅស្រុកកំណើត ដោយដឹកនាំអ្នកបម្រើដ៏បរិបូរណ៍របស់ទ្រង់ឲ្យបង្កើតព្រះពរដ៏ធំសម្រាប់ពួកគាត់ផង និងគ្រួសាររបស់ពួកគាត់ផង ដោយបរិច្ចាគប្រាក់ដោយក្តីសប្បុរសចំពោះបុព្វហេតុដ៏ពិសេសនេះ។

ពីរបីថ្ងៃក្រោយមក លោកគ្រូ ហ័ដសិន បានឡើងទូកទៅកាន់ប្រទេសអង់គ្លេស ហើយបានដឹងពីលទ្ធផលនៃការប្រជុំអធិស្ឋាន នៅពេលដែលគាត់បានឈប់នៅទីក្រុងអេដិន (Aden)។ ពួកគាត់មិនបានផ្ញើព័ត៌មាននៃការប្រជុំពិសេសទៅស្រុកកំណើតទេ ប៉ុន្តែនៅផ្លូវផាយឡែនដ៍ ពួកគាត់រីករាយនឹងការបានទទួលប្រាក់បរិច្ចាគចំនួនបីពាន់ផោន (ប្រហែលស្មើនឹង $៦១១.៣០០,០០ ដុល្លារ បច្ចុប្បន្ន) នៅថ្ងៃទី២ ខែកុម្ភៈ បានមកព្រមជាមួយសារមួយច្បាប់ថា៖ «ចូរសូមពីអញនោះអញនឹងឲ្យសាសន៍ទាំងឡាយដល់ឯង ទុកជាមរដក ហើយអស់ទាំងចុងផែនដីទុកជាកេរ្តិ៍អាកររបស់ឯង» (ទំនុកតម្កើង ២:៨)។ ហើយការនោះមិនទាន់អស់នៅឡើយទេ។ អំណោយនោះបានមកដោយមិនធម្មតាដោយមានឈ្មោះក្មេងៗប្រាំនាក់ ព្រមទាំងឪពុកម្តាយពួកគេផងដែរ។ តើមានអ្វីអាចនឹងលើកទឹកចិត្តជាងការឃើញព្រះជាម្ចាស់ឆ្លើយតបការអធិស្ឋានដោយច្បាស់ៗបែបនេះបានទៅ?

ជាច្រើនឆ្នាំក្រោយមក រឿងដូចគ្នាបានកើតឡើង នៅពេលដែលជំហានសំខាន់ៗផ្សេង

ទៀតបានឆ្ពោះទៅកាន់សេចក្ដីជំនឿបានកើតឡើង។

ព្រះជាម្ចាស់បានប្រទានពរដល់ការធ្វើដំណើររបស់អ្នកទាំង៧០នាក់ជាខ្លាំង ដែលអង្គការបេសកកម្មចិនដីគោកបានទទួលកម្រិតថ្មីនៃការជះឥទ្ធិពលនៅឯស្រុកកំណើតពួកគាត់។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះ អង្គការនេះបានបង្ហាញពីលក្ខណៈនៃការងារត្រួសត្រាយផ្លូវ។ លោក អាឡិចសែនឌ័រ វ៉ាយលី មកពីសមាគមបេសកកម្មទីក្រុងឡុងដ៍ (Alexander Wylie of the London Missionary Society) បានសរសេរមកថា៖ «ពួកគេកំពុងបើកប្រទេស ហើយនេះជាអ្វីដែលយើងចង់បាន។ បេសកកម្មផ្សេងទៀតកំពុងដំណើរការបានល្អ ប៉ុន្តែពួកគេមិនមែនកំពុងតែធ្វើកិច្ចការនេះទេ»។ ដូច្នេះ នៅពេលលោក ចន ម៉ាកខែតធី បានមកដល់ប្រទេសអង់គ្លេស បន្ទាប់ពីបានដើរឆ្លងកាត់ប្រទេសចិនពីខាងកើតទៅខាងលិច ស្របពេលដែលបានផ្សាយដំណឹងល្អដល់មនុស្សអំពីព្រះគ្រីស្ទ ហើយនៅពេលលោក ជេ. ដឹបបលយូ. ស្ទីវិនសុន (J.W. Stevenson) និងលោកបណ្ឌិត ហែនឌ្រី សុលតូ ដែលជាអ្នកដំបូងបានចូលទៅកាន់ភាគខាងកើតប្រទេសចិនពីភូមា ពួកគាត់បានធ្វើដំណើរតាមទន្លេយ៉ាងជីទៅកាន់ទីក្រុងសៀងហៃ ពេលពួកគាត់បានត្រឡប់មកវិញ  ពួកគាត់បានជួបលោកគ្រូ ហ័ដសិន នៅប្រទេសអង់គ្លេសព្រមជាមួយការត្រាស់ហៅអ្នកចម្រូតថ្មីចិតសិបនាក់ ដើម្បីចូលរួមអង្គការបេសកកម្មចិនដីគោក។ ការនេះបានប៉ះពាល់ចិត្តគ្រីស្ទបរិស័ទយ៉ាងខ្លាំង។ បងថ្លៃលោកគ្រូ ហ័ដសិន គឺលោកបេនចាមីន ប្រូមហាល (Benjamin Broomhall) បានចំណាយពេលប្រាំពីរឆ្នាំក្នុងការរៀបចំផ្លូវសម្រាប់អង្គការបេសកកម្មចិនដីគោកនៅទីក្រុងឡុងដ៍។ គាត់ និងលោកស្រី ប្រូមហាល បានកែប្រែទីស្នាក់ការកណ្ដាលនៅផ្លូវផាយឡែនដ៍របស់ពួកគេទៅជាមជ្ឈមណ្ឌលនៃសេចក្ដីស្រឡាញ់ និងសេចក្ដីអធិស្ឋាន។ ដោយសារការមានអំណោយទានក្នុងការចងមិត្តភាព និងការមានដួងចិត្តសម្រាប់ក្រុមជំនុំនៃព្រះទាំងអស់របស់គាត់ នោះលោកគ្រូ បេនចាមីន បានរកឃើញឱកាសជាច្រើន ដើម្បីចែកចាយអំពីទីបន្ទាល់នៃអង្គការបេសកកម្មចិនដីគោកនោះ។ មានមនុស្សជាច្រើនចង់រៀនអំពីរបៀបដែលការងារដែលមើលទៅហាក់ដូចជាថា មិនអាចទៅរួចនោះបានទទួលជោគជ័យ និងរបៀបដែលកិច្ចការពង្រីកត្រូវបានគាំទ្រដោយគ្មានការអំពាវនាវ ឬការប្រមូលប្រាក់។

កុមារនៅទីក្រុងខេមប្រ៊ីជបានសរសេរថា៖ «ដរាបណាលោកគ្រូនៅរស់—ខ្ញុំនឹងឮឈ្មោះ

លោកគ្រូ ហ័ដសិន ថេល័រ គ្រប់ពេលវេលាទាំងអស់នៅស្រុកកំណើត—ខ្ញុំចង់ប្រគល់ថវិកាដែលខ្ញុំបានសន្សំដល់លោកគ្រូ ដើម្បីជួយក្មេងៗជនជាតិចិនឲ្យស្រឡាញ់ព្រះយេស៊ូវដែរ»។

លោក ខេនុន វីលប័រហ្វ័ស (Canon Wilberforce) មកពីទីក្រុងថាមតុនខាងត្បូង (Southampton) កំពុងសួរថា «តើលោកគ្រូមានចិត្តទូលាយល្មមក្នុងការចែកចាយព្រះបន្ទូលពីព្រះគម្ពីរនៅផ្ទះរបស់ខ្ញុំសម្រាប់មនុស្សប្រហែល៦០នាក់ ហើយស្នាក់នៅពេញមួយយប់ដែរឬទេ។ សូមជួយយើងធ្វើការនេះក្នុងនាមព្រះអម្ចាស់ដែលជាចៅហ្វាយរបស់យើងផងចុះ»។

លោកឯកឧត្តម ឡត រ៉េតស្តកឃ៍ បានសរសេរសំបុត្រពីទ្វីបអឺរ៉ុប ដោយផ្ញើសេចក្តីស្រឡាញ់ដ៏ធំធេងទៅកាន់លោកគ្រូនៅក្នុងព្រះអម្ចាស់ «លោកគ្រូជួយយើងច្រើនណាស់នៅប្រទេសអង់គ្លេស ដោយពង្រឹងជំនឿរបស់យើង»។

លោកបណ្ឌិត អែនឌ្រូ បូណា (Andrew Bonar) បានទទួលប្រាក់មួយរយផោន (ប្រហែលស្មើនឹង $២០.៣៧០,០០ ដុល្លារ បច្ចុប្បន្ន) ពីមិត្តគ្រីស្ទបរិស័ទព្រីសប៊ីធារានដែលគាត់មិនស្គាល់ម្នាក់ដែលយកចិត្តទុកដាក់លើទឹកដីស៊ីនីម (ប្រទេសចិន)។ លោក ស្ព័រជិន បានផ្ញើការអញ្ជើញទៅលោកគ្រូ ហ័ដសិន ដើម្បីមកអធិប្បាយនៅក្រុមជំនុំថាប៉រណាក់ខល (Tabernacle) ហើយកញ្ញា ម៉ាកហ្វឺសុន (Macpherson) ក៏បានអញ្ជើញគាត់ទៅបេតណាល់ហ្គ្រីន (Bethnal Green)។

លោក ប៊ើកហ្គ័រ បានសរសេរមកជាមួយនឹងមូលប្បទានប័ត្រចំនួន៥០០ផោន (ប្រហែលស្មើនឹង $១០១.៨៨០,០០ ដុល្លារ បច្ចុប្បន្ន) ថា៖ «ដួងចិត្តខ្ញុំនៅតែក្នុងការងារដ៏ពេញដោយសិរីល្អរបស់ព្រះអង្គ។ ខ្ញុំចូលរួមដោយស្មោះអស់ពីចិត្តក្នុងការអធិស្ឋានសម្រាប់អ្នកចម្រូត៧០នាក់ទៀត—ប៉ុន្តែកុំឈប់ត្រឹម៧០នាក់អី! យើងប្រាកដជានឹងឃើញការអស្ចារ្យជាងនេះទៅទៀត ប្រសិនបើយើងលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់យើង ដោយស្វែងរកតែសិរីល្អរបស់ព្រះ និងមានបំណងសម្រាប់សេចក្តីសង្គ្រោះនៃព្រលឹងដែលបាត់បង់»។

សេចក្តីជំនឿរបស់លោក ប៊ើកហ្គ័រ បានជាសក្ខីភាពដែលថា៖ «យើងមុខជានឹងឃើញការធំជាងនេះទៅទៀត»។ ពួកអ្នកទាំង៧០នាក់ដែលព្រះបានប្រទានមក បានបញ្ជាក់ថា

ជាការឆ្លើយតបយ៉ាងបរិបូរណ៍ចំពោះការអធិស្ឋាន។ មុនពេលក្រុមចុងក្រោយទាំង៧០ នាក់បានចេញដំណើរ ក្រុមខេមប្រ៊ីជ ប៊ែន (Cambridge Band) ដ៏ល្បីល្បាញបានមកបន្តបន្ទាប់ពីពួកគាត់។ ទីបន្ទាល់ដែលចង្អុលបង្ហាញពួកគេបានរាលដាលពេញសាកលវិទ្យាល័យអង់គ្លេសព្រមនឹងចលនាខាងវិញ្ញាណដ៏ជ្រាលជ្រៅដែលបានពង្រីកទៅជ្រុងឆ្ងាយនៃពិភពលោក មុនពេលពួកគេចាកចេញពីប្រទេសអង់គ្លេស។ ប្រាកដណាស់ វាជាជំនោរនៃព្រះពរខាងវិញ្ញាណដែលកំពុងកើនឡើង។ លោកគ្រូ ហ័ដសិន ក៏បានចំណាយពេលវេលា ដើម្បីសរសេរ និងបោះពុម្ពថ្មីនៃសៀវភៅ "សេចក្តីត្រូវការខាងព្រលឹងវិញ្ញាណនៅប្រទេសចិន និងកាតព្វកិច្ចរបស់យើង" ("China's Spiritual Need and Claims") ដែលកាន់តែធ្វើឲ្យការងារបម្រើព្រះកាន់តែស៊ីជម្រៅ និងអាចទ្រទ្រង់បាន។

លោកគ្រូ ហ័ដសិន បានខកខានចូលរួមកិច្ចប្រជុំលាគ្នាចុងក្រោយរបស់ក្រុមខេមប្រ៊ីជនៅឯសាលប្រជុំ អ៊ិចហ្សិតធ័រ ហ័ល (Exeter Hall) ហើយបានបន្តទៅប្រទេសចិនដោយគ្មានពួកគេ ដោយសារតែពួកគេត្រូវធ្វើឲ្យពន្យារពេលដោយការស្តារជំនឿ និងការប្តេជ្ញាចិត្តឡើងវិញខាងឯវិញ្ញាណកំពុងកើតឡើងនៅក្នុងចំណោមពួកនិស្សិតនៅក្នុងមជ្ឈមណ្ឌលសាកលវិទ្យាល័យ។ មានរឿងពីរខុសគ្នាដែលគួរឲ្យចាប់អារម្មណ៍បានកើតឡើង មួយគឺភាពរំភើបនៃការជួបជុំដ៏ធំនោះ ដែលមានការគាំទ្រដល់អ្វីៗគ្រប់យ៉ាងដែលអង្គការបេសកកម្មចិនដីគោកបានធ្វើបទបង្ហាញ និងមួយទៀតគឺការអធិស្ឋានតែម្នាក់ឯងជារៀងរាល់ថ្ងៃនៅក្នុងកាប៊ីនកប៉ាល់របស់លោកគ្រូ ហ័ដសិន ដែលនាំគាត់ត្រឡប់ទៅការពិតនៃចម្បាំងតយុទ្ធដ៏ខ្លាំងក្លា។ លេខាធិការសមាគមបេសកកម្មក្រុមជំនុំ (Church Missionary Society) បានពណ៌នាការងារនេះថាជាការត្រួវឈានដល់កម្រិតថ្មីមួយនៃការអាណិតអាសូរ និងការជឿជាក់នៃវាស្រ្តរបស់ព្រះអម្ចាស់ ដែលគាំទ្រដោយរលកដ៏ធំនៃភាពរីករាយដ៏ក្លៀវក្លា។ លោកគ្រូ ប្រ៊ូមហល បានសរសេរថា៖ អង្គការបេសកកម្មចិនដីគោកបានត្រឡប់ទៅជាទីពេញនិយមវិញ ប៉ុន្តែមិនមែនគ្មានការព្រួយបារម្ភនោះទេ។ ទោះជាយ៉ាងណាក៏ដោយក៏នៅក្នុងប្រទេសចិនលោកគ្រូ ហ័ដសិន ថេល័រ ត្រូវប្រឈមមុខនឹងទិដ្ឋភាពដ៏លំបាកៗនៃបទពិសោធន៍នេះ។

គាត់បានសរសេរពីសមុទ្រចិនថា៖ "ឆាប់ៗនេះ យើងនឹងត្រូវនៅកណ្តាលចម្បាំង ប៉ុន្តែព្រះអម្ចាស់ដ៏ជាព្រះនៃយើងទ្រង់គង់នៅក្នុងចំណោមយើង គឺមានអំណាចព្រះ

ចេស្តា—ដូច្នេះ យើងនឹងទុកចិត្ត ហើយមិនភ័យខ្លាចឡើយ។ “ទ្រង់នឹងសង្គ្រោះយើង”» (សេផានា ៣:១៧)។ ទ្រង់នឹងជួយសង្គ្រោះយើងនៅគ្រប់ស្ថានភាពទាំងអស់។

ហើយបន្ទាប់មក បានពីរបីខែក្រោយមក គាត់បានសរសេរទៅប្រពន្ធរបស់គាត់ថា៖

«រាងកាយ និងអារម្មណ៍របស់អូនជាទីស្រឡាញ់ជាញឹកញាប់ចុះទន់ខ្សោយ វាមិនអីទេ។ ចូរចាំថា ព្រះមិនដែលធ្វើឲ្យយើងខកចិត្តឡើយ។ ចូរអធិស្ឋានឲ្យបានច្រើន អធិស្ឋានគ្រប់ពេលវេលា ពីព្រោះសាតាំងប្រឆាំងយើងយ៉ាងសាហាវ។

មានរឿងជាច្រើនដែលគួរឲ្យព្រួយបារម្ភ។ អវត្តមានរបស់អូនជាទីស្រឡាញ់ គឺជាការសាកល្បងដ៏ខ្លាំងដែលបងប្រឈមជានិច្ច ហើយមានទាំងទំនាស់ធម្មតាផង និងទំនាស់ដែលនឹកស្មានមិនដល់ផង។ ទោះជាយ៉ាងណាក៏ដោយ ក៏ការលើកទឹកចិត្តតែងតែអស្ចារ្យដែរ—គ្មានពាក្យណាផ្សេងអាចរៀបរាប់បានជិតការពិតបានទេ ហើយបងក៏មិនអាចបង្ហាញការពិតពាក់កណ្តាលទៀតជាលាយលក្ខណ៍អក្សរបានដែរ។ គ្មាននរណាម្នាក់អាចស្រមៃឃើញដល់ការងារក៏អស្ចារ្យមិនគួរឲ្យជឿ ដែលកើតឡើងតាមរយៈអង្គការបេសកកម្មចិនដីគោករបស់យើងបានទេ។ អង្គការបេសកកម្មផ្សេងៗទៀតប្រហែលជាក៏កំពុងធ្វើឲ្យមានឥទ្ធិពលយ៉ាងខ្លាំងផងដែរ។ បងរំពឹងថា ឆ្នាំនេះជាឆ្នាំដ៏អស្ចារ្យ»។

ឆ្នាំ១៨៨៦ គឺជាឆ្នាំដ៏អស្ចារ្យ ដែលបានដឹកនាំទៅកាន់ភាពកាន់តែរីកចម្រើនឡើង ដែលព្រះបានប្រទានចម្លើយដ៏លេចធ្លោចំពោះការអធិស្ឋានដែលបានលើកឡើងមកពីខាងដើម។

លោកគ្រូ ហ័ដសិន បានចំណាយពេលជាច្រើនខែក្នុងការទៅមើលស្រុកនានា ដែលជាកន្លែងមានអ្នកចម្រូតថ្មីៗជាច្រើនរស់នៅ។ គាត់បានធ្វើដំណើរកាត់ស្រុកសានស៊ី ដោយធ្វើសន្និសីទ ហើយសរសេររបាយការណ៍នៅក្នុងកូនសៀវភៅដ៏មានតម្លៃមួយដែលមានចំណងជើងថា៖ «សម័យនៃព្រះពរ» (“Days of Blessings”)។ ឥទ្ធិពល និងទីបន្ទាល់ដ៏ស្ងប់ស្ងាត់របស់គាត់ បានបង្ហាញពីអាថ៌កំបាំងដ៏ជ្រាលជ្រៅរបស់ព្រះដល់ពួកអ្នកចម្រូតវ័យក្មេងទាំងនោះ។ ពេលវេលាទាំងនោះពិតជា៖ «សម័យនៃព្រះពរ» ពិតមែន ជាពិសេសនៅក្នុងស្រុករបស់លោកគ្រូគង្វាល ស៊ី (Pastor Hsi) នៅពេលដែលលោកគ្រូ ហ័ដសិន បានជួបអ្នកប្រាជ្ញកាន់លទ្ធិខុងជឺដែលបានប្រែចិត្តជឿព្រះយេស៊ូវជាលើកដំបូង។ ភាពស្រស់ស្អាតនៃសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក និងការដឹងគុណបានភ្លឺឡើងមក

នៅពេលដែលពួកគេពិភាក្សាអំពីការងារនាពេលអនាគត។

លោក ស្ទីវិនសុន (Mr. Stevenson) បានចងចាំអស់អ្នកដែលបាននៅជាមួយពួកគាត់ថា “យើងទាំងអស់គ្នាបានឃើញនិមិត្តនាពេលនោះ ដែលនោះ គឺជាសម័យស្ថានសួគ៌នៅលើផែនដី។ គ្មានអ្វីមើលទៅហាក់បីដូចជាពិបាកនោះទេ”។

នៅពេលលោកគ្រូ ហ៍ដសិន បានធ្វើដំណើរចុះតាមទន្លេហាននៅផ្នែកចុងក្រោយនៃការធ្វើដំណើររបស់គាត់ វាសមហេតុផលសម្រាប់គាត់ក្នុងការមើលថែក្មេងស្រីអាយុប្រាំឆ្នាំម្នាក់។ ឪពុកម្ដាយដែលជាបេសកជនរបស់នាងបានយល់ថា ការប្ដូរនាងឲ្យទៅរស់នៅតំបន់ឆ្នេរ គឺជាមធ្យោបាយតែមួយក្នុងការសង្គ្រោះជីវិតនាង។ ដោយសារតែគ្មានស្ត្រីនៅក្នុងក្រុម ពួកគាត់បានដឹងថា រយៈពេលមួយខែ ឬប្រាំមួយសប្ដាហ៍ លោកគ្រូ ហ៍ដសិន ដែលជាអ្នកដឹកនាំអង្គការបេសកកម្មចិនដីគោក នឹងធ្វើជាអ្នកថែទាំតែម្នាក់គត់របស់នាងតូច អ៊ែននី (Mss Annie) ទាំងយប់ទាំងថ្ងៃ។ ប៉ុន្តែ ពួកគេពេញចិត្តទាំងស្រុងចំពោះការរៀបចំបែបនេះ។

នាងតូចដែលខ្ញុំជួយមើលថែ គឺកំពុងតែរីកចម្រើនយ៉ាងអស្ចារ្យ នៅពេលលោកគ្រូអាចសរសេរពីលើទូក។ នាងតាមខ្ញុំស្អិតគួរឲ្យស្រឡាញ់ណាស់ ហើយវាមានអារម្មណ៍ល្អមែនទែន ដែលមានដៃតូចៗឱបកខ្ញុំម្ដងទៀត។

បន្ទាប់ពីការធ្វើដំណើររបស់គាត់ លោកគ្រូ ហ៍ដសិន បានចូលរួមកិច្ចប្រជុំលើកដំបូងនៃក្រុមប្រឹក្សាបេសកកម្មរបស់ប្រទេសចិន (China Council of the Mission) នៅចុងឆ្នាំ។ ស្នងការខេត្តដែលត្រូវបានតែងតាំងថ្មីបានជួបនៅអានឃីង (Anking) រួមទាំងលោក ស្ទីវិនសុន និងលោក មែកខែតធី។ ពួកគាត់បានប្ដេជ្ញាចិត្តពេញមួយសប្ដាហ៍ក្នុងការអធិស្ឋាន និងតមអាហារ ដើម្បីរៀបចំចិត្តរបស់ខ្លួនសម្រាប់បញ្ហាដ៏សំខាន់ដែលនឹងមាននៅខាងមុខ។ ជាមួយនឹងបទពិសោធន៍ម្ភៃឆ្នាំក្នុងតួនាទីជានាយកប្រតិបត្តិ លោក ហ៍ដសិន មានគោលបំណងដឹកនាំពួកគេឆ្ពោះទៅរកអង្គការដ៏ឆ្លាតវៃ និងមានប្រយោជន៍សម្រាប់ការរីកចម្រើនបន្ថែមទៀត។ ប៉ុន្តែ សូម្បីតែគាត់ក៏មានការភ្ញាក់ផ្អើលចំពោះការផ្ដល់យោបល់របស់សន្និសីទដែរ—ពួកគេត្រូវការអ្នកចម្រូតថ្មីចំនួនមួយរយនាក់ជាបន្ទាន់សម្រាប់ដំណើរការសំខាន់ៗណាមួយដែលនឹងកើតឡើង។

លោកគ្រូ ហ៍ដសិន បានពិនិត្យស្ថានភាពឡើងវិញដោយប្រុងប្រយ័ត្ន ហើយទីបំផុត

បានយល់ស្របថា ដោយមានស្ថានីយកណ្តាលចំនួនហាសិប និងបើកចំហនៅប្រទេសចិន អ្នកចម្រូតថ្មីចំនួនមួយរយនាក់នៅឆ្នាំក្រោយនឹងមិនគ្រប់គ្រាន់សម្រាប់ការវិវត្តដែលរំពឹងទុកនោះទេ។ លោក ស្មីនសុន ដែលឥឡូវជានាយករងនៃអង្គការបេសកកម្មចិនដីគោក មានពោរពេញដោយសេចក្តីជំនឿ និងសេចក្តីក្លាហាន។ គាត់បានចែកចាយកំណត់ត្រាពន្យល់ពីស្ថានភាពដល់សមាជិកអង្គការបេសកកម្មចិនដីគោកទាំងអស់គ្នា ហើយដោយមានការយល់ព្រមពីលោកគ្រូ ហ៉ដសិន គាត់បានបញ្ជូនបណ្តាញ (a cable) ម្នាក់ទៅកាន់ទីក្រុងឡុងដ៍ដោយពោលថា៖ «សូមជួយអធិស្ឋានសម្រាប់អ្នកចម្រូតថ្មីចំនួនមួយរយនាក់ក្នុងឆ្នាំ១៨៨៧ផង» ។

តើអ្នកនៅស្រុកកំណើតពួកគាត់រំភើបចិត្តយ៉ាងណាហ្ន៎ ក្នុងកាលដែលពួកគាត់បានដឹងអំពីការជ្រើសរើសអ្នកចម្រូតថ្មីមួយរយនាក់សម្រាប់ប្រទេសចិនក្នុងរយៈពេលតែមួយឆ្នាំ! គ្មានអង្គការបេសកកម្មណាដែលគិតថា នឹងបញ្ជូនអ្នកជំនួយកម្លាំងជាច្រើននាក់បែបនេះទេ។ នៅពេលនោះ អង្គការបេសកកម្មទៅកាន់ចិនដីគោកមានសមាជិកត្រឹមតែចំនួន១៩០នាក់ប៉ុណ្ណោះ ដូច្នេះហើយ ពួកគាត់បានកំណត់គោលដៅយ៉ាងម៉ឺងម៉ាត់ក្នុងការបង្កើនចំនួនមនុស្សឲ្យលើសពី៥០ភាគរយក្នុងឆ្នាំបន្ទាប់។ គ្រប់គ្នាស្ទើរតែផុតដង្ហើម ប៉ុន្តែក្រោយមកលោកគ្រូ ហ៉ដសិន បានត្រឡប់មកវិញ។ ដោយមានសេចក្តីជំនឿយ៉ាងរឹងមាំ និងការលើកតម្កើងសិរីល្អដល់ព្រះជាម្ចាស់ គាត់បានបង្កើតឲ្យមានការស្អាងឡើងខាងឯព្រលឹងវិញ្ញាណឡើងវិញ ដែលបានសាយភាយយ៉ាងឆាប់រហ័សក្នុងចំណោមអ្នកបម្រើក្នុងបេសកកម្ម។ មានមនុស្សជាច្រើនបានរួមគ្នាអធិស្ឋានចំណុចការអធិស្ឋានបី ដែលពួកគាត់បានអធិស្ឋាននៅក្នុងប្រទេសចិន គឺដោយទូលសូមឲ្យព្រះជាម្ចាស់ចាត់បញ្ជូនអ្នកចម្រូតដែលទ្រង់បានជ្រើសរើសចំនួន១០០នាក់ និងផ្គត់ផ្គង់ប្រាក់បន្ថែមចំនួន៥ម៉ឺនដុល្លារ (ប្រហែលស្មើនឹង $១.៦៧៧.១៣៣,០០ ដុល្លារ បច្ចុប្បន្ន) ដែលត្រូវការដោយមិនចាំបាច់ធ្វើការអំពាវនាវ ឬការប្រមូលប្រាក់ណាមួយឡើយ និងដើម្បីទទួលបានប្រាក់យ៉ាងច្រើននៅក្នុងកាត់បន្ថយការទាក់ទងគ្នាទៅវិញទៅមកមួយចំនួន ដែលនោះជារឿងមានប្រយោជន៍ដល់ពួកគេ ដោយសារតែបុគ្គលិកការិយាល័យតូច។

នៅឆ្នាំ១៨៨៧ មានបុរស និងស្ត្រីចំនួន៦០០នាក់បានស្ម័គ្រចិត្តបម្រើជាមួយអង្គការបេសកកម្មចិនដីគោក ហើយមានមនុស្សចំនួន១០២នាក់ត្រូវបានជ្រើសរើស ប្រដាប់

ខ្លួន និងចាត់ឲ្យចេញទៅប្រទេសចិន។ មិនមែនត្រឹមតែ៥ម៉ឺនដុល្លារទេ តែប្រាក់ប្រាំម៉ឺនប្រាំពាន់ដុល្លារ (ប្រហែលស្មើនឹង $១.៨២៥.៤២៧,00 ដុល្លារ បច្ចុប្បន្ន) បន្ថែមទៀតត្រូវបានទទួលដោយមិនបាច់ស្នើសុំ ដែលការនោះបានបំពេញគ្រប់តម្រូវការទាំងអស់។ មានអំណោយត្រឹមតែចំនួន១១ប៉ុណ្ណោះ បានធ្វើឲ្យមានចំនួនទឹកប្រាក់សរុបច្រើនបែបនេះ ដែលស្ទើរតែមិនបង្កើនបន្ទុកការងាររបស់បុគ្គលិក ដែលធ្វើការដល់កំណត់ស្រាប់ទៅហើយ។ សំខាន់បំផុតនោះ ពួកគាត់មានជំនឿកាន់តែរឹងមាំ ហើយដួងចិត្តបានបំពេញដោយសេចក្តីប្រាថ្នាថ្មី និងកាន់តែស៊ីជម្រៅ គ្រប់ពេលដែលដំណើររឿង៖ «អ្នកចម្រូតទាំងមួយរយនាក់» “The Hundred” បានចែករំលែកដល់អ្នកស្តាប់។

អ្នកជំនួញ និងជាអ្នកផ្សាយដំណឹងល្អជនជាតិអាមេរិកវ័យក្មេងម្នាក់បានទៅលេងទីក្រុងឡុងដ៍ដោយឥតបានព្រាងទុកជាមុន ហើយមានអារម្មណ៍ថា ព្រះបានបណ្តាលចិត្តឲ្យអញ្ជើញលោកគ្រូ ហ័ដសិន ឲ្យទៅលេងសហរដ្ឋអាមេរិក។ លោក ហែនរី ដឹបបលយូ. ហ្វ្រូសធ៍ (Henry W. Frost) មានការខកចិត្តយ៉ាងខ្លាំងលើសលប់ នៅពេលដែលលោកគ្រូ ហ័ដសិន មិនបានឆ្លើយតបនឹងគាត់ ព្រោះគាត់បានជឿជាក់ថា ព្រះជាម្ចាស់បានដឹកនាំការធ្វើដំណើររបស់គាត់ទៅកាន់ប្រទេសអង់គ្លេសនៅក្រោមហេតុផលនេះ។ ទោះបីជាមានការចាប់អារម្មណ៍ដល់បេសកកម្មទៅកាន់ចិនដីគោក និងជាមួយលោក ហ័ដសិន ដោយផ្អែកលើអ្វីដែលគាត់បានឃើញ និងបានឮក៏ដោយ ក៏គាត់បានត្រឡប់ទៅទីក្រុងញូវយ៉ក (New York) ដោយភាពច្របូកច្របល់យ៉ាងខ្លាំងដែរ ដោយគិតថា បេសកកម្មរបស់គាត់បានបរាជ័យហើយ។ តែទោះជាយ៉ាងណាក្តី ក៏កិច្ចការព្រះជាម្ចាស់ចំពោះរឿងនេះទើបតែចាប់ផ្តើមតែប៉ុណ្ណោះ។

លោកគ្រូ ហ័ដសិន បានមកដល់សហរដ្ឋអាមេរិកនៅរដូវក្តៅមួយឆ្នាំក្រោយមកក្នុងឆ្នាំ១៨៨៨ ហើយលោក ឌី.អែល ម៉ូដឌី (D. L. Moody) រួមជាមួយមេដឹកនាំនៃសន្និសីទព្រះគម្ពីរនាហ្គារា (Niagara Bible Conference) បានស្វាគមន៍គាត់យ៉ាងកក់ក្តៅ។ ព្រឹត្តិការណ៍ដ៏គួរឲ្យភ្ញាក់ផ្អើលបានកើតឡើងក្នុងការឆ្លើយតបទៅនឹងការអធិស្ឋាន ទាំងនៅនាហ្គារា និងនៅណតស៍ហ្វៀលដ៍ (Northfield) ជាពិសេសការអធិស្ឋានចេញពីដួងចិត្តដែលបានជួបការខកចិត្តម្តងរួចមកហើយនោះ តែឥឡូវនេះបានរីករាយឡើងវិញដែលឃើញព្រះជាម្ចាស់ធ្វើការលើសពីអ្វីដែលគាត់បានស្រមៃទៅទៀត។

នៅពេលដែលលោក ហ័ដសិន បានទៅប្រទេសចិន បីខែក្រោយមក គាត់មិនទៅតែម្នាក់ឯងទេ។ មានយុវជន និងយុវនារីចំនួន១៨នាក់ទៀតបានចូលរួមជាមួយគាត់ដែរ ដែលជាការរួមចំណែកដ៏អស្ចារ្យពីទ្វីបដ៏ធំនេះ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ព្រះទៅកាន់អង្គការបេសកកម្មចិនដីគោក។ ពួកគេតំណាងឲ្យនិកាយផ្សេងៗពីសហរដ្ឋអាមេរិក និងកាណាដា។ ការគាំទ្រ និងការអធិស្ឋានដែលមិននឹកស្មានដល់ គឺគ្រាន់តែជាការចាប់ផ្តើមនៃលំហូរនៃការគាំទ្រជាបន្តសម្រាប់ប្រទេសចិនដែលចាប់មានតាំងពីពេលនោះមក។ ចំណាប់អារម្មណ៍ គឺខ្ពស់ខ្លាំងណាស់នៅពេលនោះ ដែលក្រុមប្រឹក្សាអាមេរិកខាងជើង (North American Council) ត្រូវតែបង្កើតឡើង។ លោក ហែនរី ដាប់បលយូ. ហ្វ្រូសធ៍ ដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងព្រឹត្តិការណ៍ទាំងនេះ បានទទួលខុសត្រូវក្នុងការធ្វើជាអ្នកតំណាង និងដឹកនាំការងារនេះផ្ទាល់ ទោះបីជាត្រូវការការមានការលះបង់ផ្ទាល់ខ្លួន និងក្រុមគ្រួសារផងយ៉ាងសន្ធឹកសន្ធាប់ក៏ដោយ។ នេះគឺជាគំនិតផ្តួចផ្តើមដ៏ជោគជ័យបំផុតមួយ ដែលព្រះអម្ចាស់បានដឹកនាំលោកគ្រូ ហ័ដសិន ឆ្លងកាត់ក្នុងការបម្រើព័ន្ធកិច្ចរបស់ទ្រង់ ហើយការនោះក៏បានចាក់បំពេញគាត់នូវសេចក្តីជំនឿជាថ្មី និងភាពក្លាហាន ដើម្បីប្រឈមមុខនឹងអ្វីៗទាំងអស់ដែលនឹងមកអំពីការនោះ ផងដែរ។

ជំហានឆ្ពោះទៅមុខដ៏អស្ចារ្យមួយបានឈានមកហើយ ហើយចាប់ពីពេលនោះមក អង្គការបេសកកម្មចិនដីគោក ដែលជាការបម្រើព្រះបែបអន្តរនិកាយ និងបានក្លាយជាអន្តរជាតិ។ លោកគ្រូ ហ័ដសិន នៅសល់រយៈពេលដប់ពីរឆ្នាំទៀតក្នុងការបម្រើយ៉ាងសកម្ម ដែលជាឆ្នាំនៃការបម្រើទូទាំងពិភពលោក។ ដំណើរទស្សនកិច្ចរបស់គាត់ទៅប្រទេសស្កេនឌីណាវី (Scandinavia) បានយកឈ្នះលើចិត្តដ៏កក់ក្តៅរបស់គ្រីស្ទបរិស័ទនៅប្រទេសស៊ុយអែត (Swedish) និងប្រទេសន័រវេស (Norwegian)។ ក្រុមដែលបានប្តេជ្ញាចិត្តពីប្រទេសអាល្លឺម៉ង់បានចាប់ផ្តើមធ្វើការជាមួយអង្គការបេសកកម្មចិនដីគោក។ ប្រទេសអូស្ត្រាលី (Australia) និងនូវែលហ្សេឡង់ (New Zealand) បានស្វាគមន៍លោកគ្រូ ហ័ដសិន ថាជាឥស្សរជនដែលធ្លាប់ស្គាល់ និងជាបុគ្គលជាទីស្រឡាញ់រាប់អាន។ ក្រុមប្រឹក្សាចិននៅទីក្រុងសៀងហៃបានប្រែក្លាយទៅជាមជ្ឈមណ្ឌលនៃអង្គការធំជាងស្ថាបនិករបស់ខ្លួនដែលមិនធ្លាប់ស្រមៃឃើញពីមុនមក។

ក្នុងអំឡុងឆ្នាំចុងក្រោយនោះ ភាពបរិបូរណ៍ខាងវិញ្ញាណគឺអស្ចារ្យបំផុត ជាមួយនឹង

លំហូរនៃព្រះពរដូចគ្នាដែលលាតសន្ធឹងដល់ផ្នែកដាច់ស្រយាលបំផុតនៃពិភពលោក។ ទស្សនៈរបស់គ្រូគង្វាលម្នាក់នៃព្រះវិហារដែលបានធ្វើជាម្ចាស់ផ្ទះទទួលលោកគ្រូ ហ័ដសិន ក្នុងទីក្រុងម៉ែលប៊ើន (Melbourne) ផ្ដល់នូវការយល់ដឹងដ៏គួរឲ្យចាប់អារម្មណ៍នៅក្នុងបរិបទនេះ។

គាត់ជាគំរូជាក់ស្ដែងមួយក្នុងការរក្សាចិត្តស្ងប់។ គាត់បានយកសេចក្ដីសុខសាន្តប្រចាំថ្ងៃរបស់គាត់ពីនគរស្ថានសួគ៌—"ខ្ញុំទុកសេចក្ដីសុខសាន្តនៅនឹងអ្នករាល់គ្នា" (យ៉ូហាន ១៤:២៧)។ ប្រសិនបើអ្វីមួយមិនរំខានព្រះអង្គសង្គ្រោះ ឬមិនរកាំព្រះទ័យទ្រង់ទេ នោះការនោះក៏មិនរកាំចិត្តគាត់ដែរ។ គាត់មានគោលបំណងរក្សាចិត្តឲ្យស្ងប់ដូចព្រះអម្ចាស់យេស៊ូវនៅក្នុងស្ថានភាពណាមួយដែរ សូម្បីតែនៅគ្រាដ៏លំបាកបំផុតក៏ដោយ។ គាត់មិនសូវស្គាល់ការប្រញាប់ប្រញាល់ ការញាប់ញ័រ ឬចិត្តក្ដៅក្រហាយទេ។ គាត់បានស្គាល់សេចក្ដីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត ហើយថា គាត់មិនអាចរស់នៅដោយគ្មានសេចក្ដីសុខសាន្តនោះបានទេ។

ខ្ញុំបានប្រាប់លោកគ្រូ ហ័ដសិន ថា "ខ្ញុំហាក់ដូចជានៅក្នុងបន្ទប់សិក្សា ហើយគាត់នៅក្នុងបន្ទប់ទំនេរធំមួយ។ គាត់រវល់ជាមួយមនុស្សរាប់លាននាក់ ហើយខ្ញុំនៅជាមួយតែមនុស្សដប់នាក់ប៉ុណ្ណោះ។ សំបុត្ររបស់គាត់មានសារៈសំខាន់ខ្លាំងណាស់ ខណៈពេលដែលសំបុត្រខ្ញុំមិនសូវសំខាន់ទេ។ ខ្ញុំមានការព្រួយបារម្ភ និងសេចក្ដីទុក្ខព្រួយ ប៉ុន្តែគាត់តែងតែមានចិត្តស្ងប់។ ខ្ញុំបានសុំឲ្យគាត់ប្រាប់ខ្ញុំពីអ្វីដែលធ្វើឲ្យយើងមានភាពខុសគ្នា"។

គាត់បានឆ្លើយថា៖ "លោក ម៉ាកាតនី (Macartney) ជាទីស្រឡាញ់ខ្ញុំអើយ! សេចក្ដីសុខសាន្តដែលអ្នកបានលើកឡើង គឺលើសពីឯកសិទ្ធិដ៏រីករាយសម្រាប់ខ្ញុំទៅទៀត គឺវាជាការចាំបាច់ណាស់។ ខ្ញុំមិនអាចដោះស្រាយជាមួយកិច្ចការទាំងអស់ ដែលខ្ញុំត្រូវធ្វើដោយគ្មានសេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ "ដែលជាសេចក្ដីសុខសាន្តលើសអស់ពីការយល់ដឹងទាំងអស់បានទេ" ដោយជួយឃុំគ្រងលើបេះដូង និងដួងចិត្តរបស់ខ្ញុំបានទេ"។

បទពិសោធន៍សំខាន់របស់ខ្ញុំជាមួយលោកគ្រូ ហ័ដសិន មានសេចក្ដីបែបដូច្នេះថា៖ "តើប្អូនមានការប្រញាប់ប្រញាល់ ឆេវឆាវ ឬអាក់អន់ចិត្តមែនទេ? ចូរងើយមុខឡើង ហើយសម្លឹងទៅកាន់ព្រះមួយអង្គដែលពេញដោយសិរីល្អ! សូមឲ្យព្រះភក្ត្ររបស់ព្រះយេស៊ូវភ្លឺមកដល់ប្អូនចុះ—ជាព្រះភក្ត្រដ៏អស្ចារ្យរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ តើទ្រង់មានការ

ព្រួយបារម្ភ ឬតូចព្រះទ័យមែនឬ? ទ្រង់មិនបានបិទការខ្វល់ខ្វាយនៅលើព្រះនលាត (មានន័យថា «ថ្ងាស») របស់ផងទ្រង់ទេ មិនមានសូម្បីតែការបារម្ភដ៏តិចតួចបំផុត។ ទោះជាយ៉ាងណាក្តី ទ្រង់ក៏ចូលរួមក្នុងរាជកិច្ចទាំងឡាយដូចប្អូនដែរ»។

ខ្ញុំបានដឹងរួចមកហើយអំពី «ការបង្រៀននៅឯ ឃេសស៊ីកឃ៍ (Keswick)» មុននោះ វាមិនមែនជារឿងថ្មីសម្រាប់ខ្ញុំទេ។ ខ្ញុំបានទទួលយកការពិតដ៏អស្ចារ្យទាំងនោះ ហើយកំពុងចែករំលែកវាជាមួយនឹងអ្នកដទៃទៀត។ ប៉ុន្តែ នេះគឺជាសេចក្តីពិត ដែលជាតំណាងនៃ "ការបង្រៀននៅឯ ឃេសស៊ីកឃ៍"» ដែលខ្ញុំមិនដែលរំពឹងថា នឹងបានយល់ឃើញការនោះទេ។ វាបានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅដល់ខ្ញុំ។ នៅទីនេះមានបុរសម្នាក់អាយុជិត៦០ឆ្នាំហើយ លីបន្ទុកដ៏សម្បើម ប៉ុន្តែនៅស្ងប់ស្ងាត់ក្នុងចិត្ត និងគ្មានការរំខាន។ អូហ៍ គំនរសំបុត្រ! សំបុត្រមួយក្នុងចំណោមសំបុត្រទាំងនោះអាចនាំមកនូវដំណឹងនៃការស្លាប់ កង្វះហិរញ្ញវត្ថុ កុបកម្ម ឬបញ្ហាធ្ងន់ធ្ងរផ្សេងទៀតក៏ថាបាន។ តែយ៉ាងណាក៏ដោយ ក៏គាត់បានបើក អាន និងឆ្លើយតបទៅសំបុត្រនីមួយៗដោយភាពស្ងប់ស្ងាត់មិនផ្លាស់ប្តូរ—ព្រះគ្រីស្ទជាហេតុផលនៃសេចក្តីសុខសាន្ត និងជាប្រភពនៃភាពស្ងប់ស្ងាត់របស់គាត់។ ដោយការរស់នៅក្នុងព្រះគ្រីស្ទ គាត់បានទាញយកជំនួយពីព្រះអង្គ និងធនធានរបស់ទ្រង់រាល់ពេលដែលដោះស្រាយបញ្ហាទាំងនេះ។ គាត់បានសម្រេចកិច្ចការនេះតាមរយៈជំនឿដ៏សាមញ្ញ ហើយឥតឈប់ឈរ។

គាត់មានសេរីភាព និងលក្ខណៈយ៉ាងអស្ចារ្យ។ គ្មានពាក្យណាមួយអាចពណ៌នាអំពីវាបានឡើយ លើកលែងតែឃ្លាព្រះគម្ពីរថា៖ «នៅក្នុងព្រះ»។ គាត់បានរស់នៅជាប់លាប់ជានិច្ចនៅក្នុងវត្តមានរបស់ព្រះ ហើយព្រះគង់នៅក្នុងគាត់ ដោយនូវការរស់នៅក្នុង «ការប្រកាន់ភ្ជាប់» ពិតប្រាកដដូចដែលបានរៀបរាប់នៅក្នុងកណ្ឌគម្ពីរយ៉ូហានជំពូក១៥។ ប៉ុន្តែឥរិយាបថដូចគូស្នេហ៍របស់គាត់នឹងព្រះគ្រីស្ទ គឺជារឿងគួរឲ្យកត់សម្គាល់! ទំនាក់ទំនងរបស់គាត់ជាមួយព្រះគ្រីស្ទបានឆ្លុះបញ្ចាំងអំពីបទពិសោធន៍ដ៏សម្បូរបែបនៃបទចម្រៀងសាឡូម៉ូន។ គាត់មានការលាយបញ្ចូលគ្នាដ៏អស្ចារ្យ—រវាងភាពរឹងមាំ និងភាពទន់ភ្លន់របស់មនុស្សម្នាក់ដែល បើទោះបីជាមានទំនួលខុសត្រូវធ្ងន់ធ្ងរដូចជាចៅក្រមនៅកន្លែងធ្វើការក៏ដោយ ក៏នៅតែរក្សាភាពកក់ក្តៅ និងសេចក្តីស្រឡាញ់ដូចជាអ្នកផ្ទះនៅក្នុងដួងចិត្តគាត់ដែរ។

តាមរយៈការទាំងអស់៖ និមិត្ត និងភាពបន្ទាន់ខាងវិញ្ញាណពីឆ្នាំមុនៗនៅតែដដែល។ តាមពិតទៅ អារម្មណ៍នៃទំនួលខុសត្រូវក្នុងការធ្វើតាមបញ្ជាចុងក្រោយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានរីកចម្រើន នៅពេលដែលគាត់បានយល់អត្ថន័យនៃមហាបេសកកម្មកាន់តែច្បាស់ជាងមុន។

គាត់បានសារភាពដោយអាម៉ាស់នៅឆ្នាំ១៨៨៩ ថាគាត់មិនបានយល់ច្បាស់ពីអត្ថន័យអំពីអ្វីដែលព្រះយេស៊ូវមានបំណងព្រះហឫទ័យពិតប្រាកដនៅពេលទ្រង់បានបង្គាប់យើងឲ្យ “ផ្សាយដំណឹងល្អដល់គ្រប់មនុស្សជាតិ” នោះទេ។ គាត់បានធ្វើការអស់ជាច្រើនឆ្នាំដើម្បីផ្សព្វផ្សាយដំណឹងល្អឲ្យកាន់តែទូលំទូលាយ ដូចជាអ្នកផ្សេងទៀតជាច្រើនដែរ ហើយបានបង្កើតយុទ្ធសាស្ត្រ ដើម្បីចូលទៅដល់គ្រប់ខេត្តដែលដំណឹងល្អមិនទាន់ទៅដល់ និងតំបន់តូចៗជាច្រើនរាប់មិនអស់នៅក្នុងប្រទេសចិន ដោយមិនបានយល់ច្បាស់លាស់អំពីព្រះរាជសារនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូវទេ។

គ្រប់មនុស្សជាតិទាំងអស់? ចំនួនអ្នកទៅថ្វាយបង្គំនៅព្រះវិហារប្រូតេស្តង់សរុបនៅក្នុងប្រទេសចិនមានត្រឹមតែ៤ម៉ឺននាក់ប៉ុណ្ណោះ។ ទោះបីជាលោកអ្នកបង្កើនចំនួនពីរដងឬបីដងទាំងរាប់បញ្ចូលអ្នកដើរតាម ហើយសន្មតថា ម្នាក់ៗផ្សព្វផ្សាយរាជសាររបស់ព្រះទៅកាន់មនុស្សប្រាំបីនាក់ដែលជាជនជាតិពួកគេក៏ដោយ ក៏មានតែ១លាននាក់ប៉ុណ្ណោះដែលនឹងឮអំពីដំណឹងល្អ។ ពាក្យ “ទៅគ្រប់មនុស្សជាតិទាំងអស់” បានធ្វើឲ្យគាត់រំជួលចិត្តយ៉ាងខ្លាំង។ ប៉ុន្តែ តើក្រុមជំនុំនៅឆ្ងាយប៉ុណ្ណា ហើយតើគាត់នៅឆ្ងាយប៉ុណ្ណាពីការពិតក្នុងការទទួលយកពាក្យបង្គាប់របស់ទ្រង់ដោយត្រង់ៗ ហើយធ្វើតាមដូចអ្វីដែលទ្រង់បានបង្គាប់នោះ!

គាត់បានសរសេរដោយសេចក្តីជំនឿយ៉ាងមុតមាំថា៖ “តើយើងនឹងប្រព្រឹត្តចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅក្នុងទំនាក់ទំនងទៅនឹងសេចក្តីបង្គាប់ចុងក្រោយរបស់ទ្រង់យ៉ាងដូចម្តេច? តើយើងនឹងពិតជាឈប់ហៅទ្រង់ថាជា “ព្រះអម្ចាស់”? តើយើងបានត្រៀមខ្លួនរួចរាល់នៅក្នុងការទទួលស្គាល់ទ្រង់ថា ព្រះអង្គសង្គ្រោះយើងចេញពីទណ្ឌកម្មអំពើបាប ប៉ុន្តែមិនសុខចិត្តទទួលស្គាល់ថា ទ្រង់ “បានទិញយើងដោយតម្លៃ” ឬថា ព្រះគ្រីស្ទមានសិទ្ធិទាមទារការស្តាប់បង្គាប់យ៉ាងដាច់ខាតពីយើងបានមែនឬ?”។

មានអ្នកដើរតាមព្រះអម្ចាស់តិចតួចណាស់ដែលទទួលស្គាល់ថា ព្រះគ្រីស្ទជាព្រះ

អម្ចាស់របស់ពួកគាត់ទាំងស្រុង ឬទ្រង់មិនមែនជាព្រះអម្ចាស់ទាល់តែសោះ។ ដរាបណាយើងគិតថា យើងអាចវាយតម្លៃលើព្រះបន្ទូលរបស់ព្រះជាជាងអនុញ្ញាតឲ្យព្រះបន្ទូលព្រះវាយតម្លៃលើយើង ហើយដរាបណាយើងមានអារម្មណ៍ថា យើងអាចថ្វាយដល់ព្រះនូវចំណែកអ្វីក៏បានដែលយើងជ្រើសរើស នោះយើងកំពុងដើរតួជាអ្នកដែលគ្រប់គ្រង ហើយទ្រង់ក្លាយជាកូនបំណុលរបស់យើង ហើយទ្រង់ត្រូវអរគុណដល់យើងចំពោះអ្វីដែលយើងបានផ្ដល់ឲ្យទ្រង់ ហើយទ្រង់ជំពាក់យើង ដោយសារយើងបានធ្វើតាមបំណងព្រះហឫទ័យទ្រង់។ ទោះជាយ៉ាងណាក្ដី ប្រសិនបើទ្រង់ពិតជាព្រះអម្ចាស់មែន នោះយើងគួរតែប្រព្រឹត្តចំពោះទ្រង់ទៅតាមឋានៈនោះ។ «ហេតុអ្វីបានជាអ្នករាល់គ្នាហៅខ្ញុំថា «ឱព្រះអម្ចាស់ៗអើយ» តែមិនធ្វើតាមពាក្យខ្ញុំវិញដូច្នេះ?» (លូកា ៦:៤៦)។

ដោយមិននឹកស្មានដល់ លោកគ្រូ ហ័ដសិន ថេល័រ បានឈានទៅដល់និមិត្តដ៏ធំបំផុតនៃជីវិតរបស់គាត់ ដែលជាគោលដៅមួយនឹងដឹកនាំការដឹកនាំដ៏មមាញឹកនាឆ្នាំចុងៗក្រោយរបស់គាត់គឺ៖ ការមានបំណងដ៏ច្បាស់លាស់ និងខិតខំប្រឹងប្រែងជាយថាក្រមប្រព័ន្ធ ដើម្បីធ្វើតាមសេចក្ដីបង្គាប់របស់ចៅហ្វាយគាត់ ហើយការនាំដំណឹងល្អនៃសេចក្ដីស្រឡាញ់ដ៏ប្រោសលោះរបស់ទ្រង់ទៅកាន់មនុស្សគ្រប់ៗរូបនៅក្នុងប្រទេសចិន។ គាត់ជឿថា អង្គការបេសកកម្មចិនដីគោកមិនអាចសម្រេចកិច្ចការនេះតែម្នាក់ឯងបាននោះឡើយ ប៉ុន្តែគាត់មានទំនុកចិត្តថា ប្រសិនបើការងារព័ន្ធកិច្ចបានបែងចែកយ៉ាងត្រឹមត្រូវនោះធនធានក្រុមជំនុំនឹងមានលើសពីអាចធ្វើកិច្ចការនេះបានទៅទៀត។

គាត់មិនបានឃើញការនោះបានសម្រេចនៅសម័យគាត់ទេ។ ដោយមានឆន្ទៈនៅក្នុងកិច្ចសហប្រតិបត្តិការរបស់អង្គការបេសកកម្មចិនដីគោក ពួកគាត់បានចាប់ផ្ដើមការងារនៅខេត្តគាំងស៊ី (Kiangsi បច្ចុប្បន្នជាំងស៊ី) ហើយគម្រោងនានាកំពុងតែអភិវឌ្ឍន៍ ដើម្បីឲ្យមានដំណើរការទូទាំងប្រទេសចិនតាមរយៈបេសកកម្មទាំងអស់។ ទោះជាយ៉ាងណាក៏ដោយក៏ការគ្រប់គ្រង និងការត្រួតត្រារបស់ព្រះជាម្ចាស់បាននាំឲ្យមាននូវការជ្រមុជដ៏ជ្រៅនៃការរងទុក្ខជាមុនផងដែរ។ ភាពច្របូកច្របល់នៃការបះបោរ (Boxer rebellion) នៅឆ្នាំ១៩០០ បានលេបត្របាក់ប្រទេស ហើយសមាជិកអង្គការបេសកកម្មចិនដីគោកបានប្រឈមមុខនឹងកំហឹងពីរឿងនេះច្រើនជាងអង្គការបេសកកម្មផ្សេងៗទៀត។ លោកគ្រូហ័ដសិន ទើបតែបានត្រឡប់ទៅប្រទេសអង់គ្លេសវិញ បន្ទាប់ពីគាត់មានបញ្ហាសុខភាព

យ៉ាងធ្ងន់ធ្ងរ ហើយបើទោះបី លោកស្រី ថេល័រ មិនយល់ទាំងស្រុងពីការបារម្ភរបស់គាត់ក្ដី ក៏គាត់បានលើកទឹកចិត្តលោកគ្រូ ហ៍ដសិន ឲ្យបន្តទៅរកកន្លែងស្ងប់ស្ងាត់ក្នុងប្រទេសស្វីស ដែលជាកន្លែងដែលជួយឲ្យសុខភាពរបស់គាត់បានធូរស្បើយកាលពីប៉ុន្មានឆ្នាំមុន។

វិបត្តិបានវាយប្រហារយ៉ាងខ្លាំងនៅពេលនោះ តេឡេក្រាមនីមួយៗ (telegrams) បានពេញទៅដោយរបាយការណ៍អំពីកុបកម្ម ការសម្លាប់រង្គាលសមាជិកនៃអង្គការបេសកកម្មចិនដីគោក និងក្រុមគ្រួសាររបស់ពួកគាត់ និងជនភៀសខ្លួនដែលត្រូវបានគេតាមប្រមាញ់ពីស្ថានីយបេសកកម្មមួយទៅស្ថានីយបេសកកម្មមួយទៀតទូទាំងអង្គការបេសកកម្មចិនដីគោក។ ដួងចិត្តដែលបានគាំទ្រតាំងពីយូរណាស់មកហើយចំពោះក្រុមសហការីទាំងនេះ នៅចំពោះព្រះអម្ចាស់មិនអាចទ្រាំទ្របានទៀតទេ ហើយបេះដូងស្ទើរតែឈប់លោត។ បើមិនមែនរស់នៅតែឯងនៅក្រុងដេវ៉ូស (Davos) ដែលជាកន្លែងដែលព័ត៌មានខ្លះទៅមិនដល់គាត់ ម្ល៉េះលោកគ្រូ ហ៍ដសិន ថេល័រ ប្រហែលជាបានស្លាប់ព្រមជាមួយនឹងអ្នកដែលលះបង់ជីវិតរបស់ពួកគេ ដើម្បីព្រះគ្រីស្ទ និងប្រទេសចិនទៅហើយ នៅក្នុងព្រឹត្តិការណ៍ដ៏គួរឲ្យភ័យរន្ធត់នៅរដូវក្ដៅនោះ។ បើទោះបីជារឿងគ្រប់យ៉ាងបានកើតឡើងក៏ដោយ ក៏គាត់បានរួចជីវិតដែរ ដោយនៅជាប់នឹងព្រះជាម្ចាស់។

នៅក្នុងកាលដែលអ្វីៗធ្លាក់ដល់ចំណុចអាក្រក់បំផុត គាត់បានពោលថា៖ «ខ្ញុំអានមិនចេញទេ។ ខ្ញុំមិនអាចអធិស្ឋានបានឡើយ។ ខ្ញុំគិតស្ទើរតែមិនចេញ—ប៉ុន្តែ ខ្ញុំអាចទុកចិត្តលើព្រះជាម្ចាស់បាន»។

វិបត្តិនៃការបះបោរបានបញ្ចប់ហើយ ពាក្យដ៏ស្ងប់ស្ងាត់របស់គ្រូគង្វាលសក់សនៅស្រុកសានស៊ី (Shanxi) ក៏បានក្លាយជាការពិតដែរ។ វិបត្តិនោះបាននាំឲ្យមនុស្សរាប់ពាន់នាក់បានស្លាប់ រួមទាំង ៥៨ នាក់សមាជិកនៃអង្គការបេសកកម្មចិនដីគោក និងកូនរបស់ពួកគេចំនួន ២១ នាក់ ទាំងគ្រីស្ទបរិស័ទច្រើននាក់ទៀត ដែលបានជឿតាមរយៈកិច្ចការរបស់បេសកជន។

«គាត់បាននិយាយស្ទើរតែផុតដង្ហើមចុងក្រោយថា៖ "អាណាចក្រនានាអាចនឹងត្រូវវិនាសទៅ ប៉ុន្តែក្រុមជំនុំនៃព្រះគ្រីស្ទមិនដែលនឹងបំផ្លាញបានឡើយ"»។

គាត់ និងគ្រីស្ទបរិស័ទចិនរាប់រយនាក់ផ្សេងទៀតបានបង្ហើយទីបន្ទាល់របស់ខ្លួនយ៉ាងជឿជាក់ដោយឈាមរបស់ពួកគាត់ផ្ទាល់។ ហើយតាមរយៈភាពជឿជាក់ដូចគ្នានេះ អស់

អ្នកដែលបានរួចជីវិតបានចាប់ផ្ដើមធ្វើជាទីបន្ទាល់តាមរយៈជីវិតដ៏ស្មោះត្រង់របស់ពួកគាត់ម្ដងទៀត។

លោក ឌី.អ៊ី. ហូសធ៍ (D. E. Hoste) ដែលត្រូវបានតែងតាំងដោយលោកគ្រូ ហ៉ាដសិន ជាអ្នកស្នងតំណែងបន្តពីគាត់ បានគ្រប់គ្រងស្ថានការណ៍ដោយភាពឆ្លាតវៃ ហើយគាត់បានផ្លាស់ប្តូរខ្មាំងសត្រូវឲ្យត្រឡប់មកជាមិត្តវិញ។ ហើយអាជ្ញាធរចិនបានទទួលស្គាល់យ៉ាងឆាប់រហ័សនូវការដឹងគុណរបស់ពួកគេចំពោះការប្រកាន់ខ្ជាប់យ៉ាងពិតប្រាកដចំពោះការបង្រៀនរបស់ព្រះគ្រីស្ទ ដែលធ្វើឲ្យពួកគេចាប់អារម្មណ៍ខ្លាំងលើសពីការអធិប្បាយមុនៗទៅទៀត។

លោកគ្រូ ហ៉ាដសិន បានរស់នៅឃើញថ្ងៃថ្មីនៃឱកាសកើតឡើងនៅក្នុងប្រទេសចិន ហើយបានធ្វើដំណើរត្រឡប់ទៅទឹកដីដែលគាត់ស្រឡាញ់ និងបានអធិស្ឋានសម្រាប់ទីនោះជារឿយៗវិញ។ ទោះជាយ៉ាងណាក្តីក៏គាត់បានត្រឡប់មកវិញតែម្នាក់ឯងទេ។ ដៃគូជាទីស្រឡាញ់របស់គាត់ ដែលជាអ្នកលើកទឹកចិត្តយ៉ាងខ្លាំង បានរីករាយថ្ងៃចុងក្រោយនៃការធ្វើដំណើរជាមួយគ្នារបស់ពួកគាត់ ហើយបានសម្រាន្តទៅនៅលើទឹកដីវីវ៉េយ (Vevey) ក្បែរបឹង ជឺនីវ៉ា (Lake Geneva) ជាកន្លែងដែលពួកគាត់បានសង់ផ្ទះចុងក្រោយរបស់ខ្លួន។ នៅក្នុងវ័យចិតសិបបីឆ្នាំ គាត់បានធ្វើដំណើរឆ្ពោះទៅកាន់ប្រទេសចិនម្តងទៀត បានអមដំណើរដោយកូនប្រុស និងកូនប្រសាស្រីគាត់ ដែលបានចាប់ផ្តើមដំណើរដ៏អស្ចារ្យបំផុតមួយនៃជីវិតរបស់គាត់។

មានគ្រីស្ទបរិស័ទច្រើនស្រឡាញ់ និងគោរពគាត់ នៅពេលដែលគាត់បានធ្វើដំណើរឆ្លងកាត់ពីកន្លែងមួយទៅកន្លែងមួយទៀត គ្រប់ទីកន្លែងបានស្វាគមន៍គាត់ថាជា “អ្នកផ្តល់គុណប្រយោជន៍របស់ប្រទេសចិន” ដែលតាមរយៈគាត់ ដំណឹងល្អបានទៅដល់ខេត្តនៅដីគោកទាំងនោះ។ បន្ទាប់ពីធ្វើដំណើរឡើងទៅទន្លេយ៉ាងជី ទៅកាន់ក្រុងហានគូ (Hankow) និងដោយចំណាយពេលប៉ុន្មានសប្តាហ៍នៅភាគខាងជើងខេត្តហ៊ូណាន (Hunan) លោកគ្រូ ហ៉ាដសិន មានអារម្មណ៍រឹងមាំគ្រប់គ្រាន់ក្នុងការធ្វើដំណើរម្តងទៀតទៅកន្លែងមួយផ្សេងទៀត។ គាត់មិនដែលរំពឹងថា ខ្លួនគាត់នឹងបានមកដល់ខេត្តហ៊ូណានដែលជាខេត្តដំបូងក្នុងចំណោមខេត្តទាំងប្រាំបួនដែលក្រុមអ្នកត្រួសត្រាយផ្លូវនៃអង្គការ ស៊ី.អាយ.អិម. បានចូលមកផ្សាយដំណឹងល្អនោះទេ ហើយវាក៏បានក្លាយទៅជាខេត្តមួយដែល

ពិបាកបំផុតដែរ។ លោកគ្រូ អ័ដាម ឌ័រវ៉ឺដ (Adam Dorward) បានធ្វើការ ហើយបានរងទុក្ខអស់រយៈពេលជាងប្រាំបីឆ្នាំនៅទីនេះ—គ្មានផ្ទះសម្បែង រងការបៀតបៀន ចុងក្រោយភៀសខ្លួនចេញពីកុបកម្មមកស្លាប់តែម្នាក់ឯង—តែគាត់បានស្លាប់ដោយរីករាយនៅក្នុងការថ្វាយជីវិតរបស់គាត់ដោយសង្ឃឹមហើយជាលទ្ធផលបាននាំឲ្យយើងឃើញដល់សព្វថ្ងៃនេះ។ លោកគ្រូ ហ័ដសិន បានដាក់ខេត្តនោះនៅក្នុងការអធិស្ឋានរបស់គាត់អស់រយៈពេលជាង៣០ឆ្នាំមកហើយ ដូច្នេះ វាជាការសមរម្យដែលថា សេចក្ដីអំណរដ៏អស្ចារ្យចុងក្រោយសម្រាប់គាត់ គឺការស្វាគមន៍ដោយក្តីស្រឡាញ់ពីសំណាក់ពួកអ្នកប្រែចិត្តជឿលើព្រះយេស៊ូវនៅខេត្តហ៊ូណាន។ គ្រីស្ទបរិស័ទបានប្រមូលផ្តុំគ្នាយ៉ាងអន្ទះសានៅរដ្ឋធានីនៅក្នុងផ្ទះរបស់លោកវេជ្ជបណ្ឌិត ហ្វ្រេងឃ៍ ឃែលល័រ (Frank Keller) ដែលជាមនុស្សដំបូងគេដែលទទួលបានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ក្នុងខេត្តនេះ ដោយទន្ទឹងរង់ចាំការថ្វាយបង្គំនៅថ្ងៃអាទិត្យជាមួយអ្នកដឹកនាំជាទីស្រឡាញ់ដែលពួកគាត់ធ្លាប់បានឮគេតំណាលយ៉ាងច្រើនអំពីគាត់។ ពួកអ្នកដែលមកដល់មុនបានជួបគាត់នៅថ្ងៃសៅរ៍ ហើយពួកបេសកជននៅក្នុងទីក្រុងបានមកចូលរួមក្នុងការទទួលស្វាគមន៍ ដែលលោកវេជ្ជបណ្ឌិត និងលោកស្រី ឃែលល័រ បានគ្រោងទុកដោយចិត្តសប្បុរស។

នៅល្ងាចនោះ ពេលវេលាកំណត់របស់គាត់បានឈានចូលមកដល់។ វាមិនមែនជាសេចក្ដីស្លាប់រហូតឡើយ ប៉ុន្តែជាការចាប់ផ្តើមដ៏មានអំណរ និងឆាប់រហ័សនៃជីវិតដ៏នៅអស់កល្បជានិច្ច។

«ឱលោកឪពុក លោកឪពុកខ្ញុំអើយ ជាព្រះរាជរថ និងទ័ពសេះ របស់ពួកអ៊ីស្រាអែលអើយ!» (២ពង្សាវតារក្សត្រ ១៣:១៤)។ បរិយាកាសបន្ទប់ហាក់ដូចជាពោរពេញទៅដោយសេចក្ដីសុខសាន្ត ដែលមិនអាចពណ៌នាបាន។

ជំពូកទី១៨

# ប្រភពទឹកនៅតែបន្តបង្ហូរមក

*ទ្រង់មានបន្ទូលប្រាប់ខ្ញុំអំពីទន្លេដ៏ភ្លឺដែលហូរចេញពីទ្រង់មកកាន់ខ្ញុំ ដូច្នេះខ្ញុំអាចនឹងធ្វើជាដើមឈើមួយដើមដែលល្អនិងបង្កើតផលផ្លែ ដើម្បីបំពេញព្រះហឫទ័យទ្រង់។*
— *លោក ធ័រស្ទីហ្គិន (Tersteegen)*

នៅពេលដែលព្រះជាម្ចាស់ដកលោកគ្រូ ហ័ដសិន ភ្លាមៗពីចំណុចកណ្តាលនៃប្រទេសចិន ដើម្បីទៅនៅជាមួយព្រះអម្ចាស់ដែលគាត់ស្រឡាញ់ នោះមានមនុស្សជាច្រើនមានអារម្មណ៍ថា ការរំពឹងទុកស្ទើរតែត្រូវបានផ្អាកផងដែរ។ ពួកគេងឿងឆ្ងល់អំពីអនាគតនៃអង្គការបេសកកម្មចិនដីគោកថា នឹងអាចបន្តទៀតបានដែរឬទេ។ លោកគ្រូ ហ័ដសិន គឺជាមនុស្សម្នាក់ដែលមានជំនឿយ៉ាងប្រសើរក្រៃលែង! នៅពេលដែលគាត់នៅរស់ ហើយអធិស្ឋាន នោះអ្វីៗគ្រប់យ៉ាងហាក់ដូចជាល្អ។ ប៉ុន្តែឥឡូវនេះ តើនឹងមានរឿងអ្វីកើតឡើងចំពោះអង្គការបេសកកម្មចិនដីគោក? វាគឺជារឿងធម្មតាក្នុងការព្រួយបារម្ភ ប៉ុន្តែប៉ុន្មានឆ្នាំកន្លងមកនេះ វាច្បាស់ណាស់ថា ទោះបីជាលោកឪពុក និងជាអ្នកដឹកនាំជាទីស្រឡាញ់នៃបេសកកម្មបានលាស្លាប់ទៅហើយក្តី ក៏ព្រះអម្ចាស់ដែលគាត់បានផ្ញើអស់ទាំងសេចក្តីទុកចិត្ត ទ្រង់គង់នៅជាមួយយើងរាល់គ្នាផងដែរ។

លោកគ្រូ ហ៉ដសិន បានផ្ដល់គុណតម្លៃយ៉ាងពិសេសចំពោះពាក្យពេចន៍នៅលើបន្ទាត់នៃដើមជំពូកនេះ ដោយសារតែបន្ទាត់ទាំងនេះបានបញ្ជាក់អត្ថន័យដ៏សំខាន់អំពីអាថ៌កំបាំងខាងឯព្រលឹងវិញ្ញាណរបស់គាត់។

គាត់បានសរសេរថា «វាយ៉ាងសាមញ្ញណាស់ ប៉ុន្តែតើទ្រង់មិនបានដាំយើងរាល់គ្នានៅក្បែរទន្លេនៃទឹករស់ទេឬអី ដើម្បីឲ្យយើងអាចលូតលាស់បានល្អ ហើយបង្កើតផលផ្លែសម្រាប់ជាសេចក្ដីអំណរដល់រាស្ត្រទ្រង់?»។

លោកគ្រូ ហ៉ដសិន បានផ្ដល់អាទិភាពលើព្រះជាម្ចាស់លើសអ្វីៗផ្សេងទៀតរួមមាន៖ ការងារគាត់ តម្រូវការរបស់ប្រទេសចិន បេសកកម្មគាត់ និងបទពិសោធន៍ខ្លួនគាត់ផ្ទាល់ផងដែរ។ គាត់បានជឿទៅលើសេចក្ដីពិតដែលព្រះបានសន្យាថា «ចូរយកព្រះយេហូវ៉ាជាសេចក្ដីអំណររបស់អ្នករាល់គ្នាចុះ នោះទ្រង់នឹងប្រទានឲ្យអ្នកបានដូចបំណងប្រាថ្នា» (ទំនុកតម្កើង ៣៧:៤)។ តើសេចក្ដីសន្យានេះ មិននៅតែជាការពិតសម្រាប់យើងសព្វថ្ងៃនេះទេឬអី? សូមឲ្យបទពិសោធន៍របស់អ្នកដឹកនាំពីអង្គការបេសកកម្មម្នាក់នេះ បានតំណាងឲ្យបទពិសោធន៍របស់មនុស្សជាច្រើនទៀតផងចុះ។

កញ្ញា សូលតូ បានសរសេរថា កិច្ចការបម្រើព្រះចេះតែចម្រើនឡើងៗជាលំដាប់ ហើយប្រសិនបើគាត់មិនបានស្គាល់ព្រះគ្រីស្ទឲ្យបានខ្ជាប់ខ្ជួនដូចជាជីវិតរបស់គាត់ទេ នោះគាត់មិនអាចបន្តធ្វើកិច្ចទាំងនេះបានឡើយ។ ប៉ុន្តែ ព្រះអង្គកំពុងតែបង្រៀនខ្ញុំនូវមេរៀនដ៏អស្ចារ្យពីភាពគ្រប់គ្រាន់របស់ទ្រង់ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ទ្រង់បានបីខ្ញុំឆ្ពោះទៅមុខដោយគ្មានអារម្មណ៍តានតឹង ឬភ័យខ្លាចចំពោះការបាក់បែកនោះទេ។

ប្រភពទឹកនៅតែបន្តហូរមក ដូចអ្វីៗដែលអង្គការបេសកកម្មចិនដីគោកកំពុងពង្រីក និងបន្តរីកចម្រើនឡើងតែងតែបានក្លាយជាការពិត។ ឧបសម្ព័ន្ធនៅខាងក្រោមនឹងបង្ហាញការពិតដ៏សំខាន់អំពីការអភិវឌ្ឍ៣០ឆ្នាំចុងក្រោយនេះ ហើយការទាំងនោះពិតជាអស្ចារ្យណាស់។ ប៉ុន្តែសម្រាប់ពេលនេះ យើងនឹងផ្ដោតទៅលើទិដ្ឋភាពជាក់ស្ដែងរបស់ជីវិតខាងឯព្រលឹងវិញ្ញាណរបស់លោកគ្រូ ហ៉ដសិន នៅពេលយើងប្ដូរពីអតីតកាលមកកាន់បច្ចុប្បន្នកាលវិញ។ គាត់បានយល់សេចក្ដីពិតដ៏ជ្រាលជ្រៅ ដែលបានស្គាល់តែអ្នកណាដែលស្គាល់ព្រះច្បាស់ប៉ុណ្ណោះ៖ «ព្រះជាម្ចាស់មិនបានប្រទានឲ្យយើងនូវជីវិតដែលតែងតែឈ្នះនោះទេ តែទ្រង់ប្រទានឲ្យយើងនូវជីវិតដែលចេះប្រឈមមុខ និងយកជ័យជម្នះលើឧបសគ្គទៅវិញទេ»។ លោកគ្រូ ហ៉ដសិន

បានជឿថា ការយកឈ្នះលើឧបសគ្គអាស្រ័យលើការពឹងផ្អែកលើទំនាក់ទំនងជាមួយព្រះជាម្ចាស់ប្រចាំថ្ងៃ ហើយសូម្បីតែរៀងរាល់ម៉ោងផង។ ទំនាក់ទំនងនេះអាចរក្សាបានតែតាមរយៈការអធិស្ឋានផ្ទាល់ខ្លួន និងការសិក្សាព្រះបន្ទូលប៉ុណ្ណោះ ដែលនេះជារបៀបដែលព្រះជាម្ចាស់បើកសម្ដែងអង្គទ្រង់ដល់អស់អ្នកណាដែលរង់ចាំព្រះអង្គ។

លោកគ្រូ ហ៉ដសិន មិនងាយនឹងរកពេលអធិស្ឋាន និងសិក្សាព្រះគម្ពីរនៅក្នុងជីវិតដែលមិនទៀងទាត់របស់គាត់បានទេ ប៉ុន្តែគាត់បានដឹងថា ការទាំងនេះចាំបាច់ណាស់។ អ្នកនិពន្ធបានសរសេរថា យើងនឹកចាំពីការធ្វើដំណើរជាមួយគាត់ពីមួយខែទៅមួយខែនៅភាគខាងជើងនៃប្រទេសចិនដោយប្រើរទេះ និងរទេះរុញ ហើយដោយស្នាក់នៅផ្ទះសំណាក់ដ៏សាមញ្ញៗបំផុត។ ជាញឹកញាប់ គាត់ស្នាក់នៅបន្ទប់តែមួយជាមួយអ្នកធ្វើការ និងអ្នកដំណើរផ្សេងៗទៀត ពួកគាត់នឹងទុកកន្លែងផ្ទាល់ខ្លួនសម្រាប់ឪពុករបស់ពួកគាត់ និងខ្លួនពួកគាត់ផ្ទាល់ដោយបាំងវាំងននបណ្ដោះអាសន្នមួយ។ ហើយបន្ទាប់ពីនោះ ក្រោយពេលមនុស្សចូលសម្រាកស្ងាត់អស់ហើយ មិនថាលោកគ្រូ ថេល័រ អស់កម្លាំងយ៉ាងណាឡើយ ក៏ពួកគាត់សម្គាល់ឃើញថា មានពន្លឺឈើគូស និងពន្លឺភ្លើងទៀនឆេះឡើង ជាសញ្ញាថា គាត់កំពុងសិក្សាព្រះគម្ពីរតូចរបស់គាត់។ ជាធម្មតា គាត់បានចំណាយពេលពីម៉ោង២ភ្លឺដល់ម៉ោង៤ភ្លឺ ដើម្បីអធិស្ឋាន ក្នុងកាលដែលគាត់ប្រើភាពស្ងប់ស្ងាត់នៅក្នុងការទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ទៀនដែលភ្លឺនោះបានបង្រៀនយើងអំពីអំណាចនៃការអធិស្ឋានផ្ទាល់ខ្លួនជាជាងការអធិប្បាយណាមួយ ហើយវាគឺជាសញ្ញាមួយអំពីការរស់ដោយសេចក្ដីជំនឿ មិនមែនគ្រាន់តែនិយាយថា ជឿនោះឡើយ។

លោកគ្រូ ហ៉ដសិន រកឃើញថា ផ្នែកដ៏ពិបាកបំផុតក្នុងការងារជាបេសកជនគឺ ការបន្តសិក្សាព្រះគម្ពីរ និងការអធិស្ឋានឲ្យបានទៀងទាត់។ គាត់លើកឡើងថា៖ «សាតាំងតែងតែដាក់ការងារអ្វីមួយឲ្យលោកអ្នកធ្វើ នៅពេលដែលលោកអ្នកគួរតែរវល់នឹងការអធិស្ឋាន និងសិក្សាព្រះគម្ពីរ ហើយការនេះមានដូចជា សូម្បីតែរៀបចំវាំងននបង្អួចឡើងទៅ»។ គាត់យល់ស្របទាំងស្រុងជាមួយការលើកឡើងសំខាន់ៗទាំងនេះ៖

«ចូរចំណាយពេលរបស់លោកអ្នក។ ចូរអនុញ្ញាតឲ្យព្រះជាម្ចាស់បើកសម្ដែងអង្គទ្រង់ដល់លោកអ្នកចុះ។ ចូរទុកពេលឲ្យខ្លួនអ្នកនៅស្ងៀម ហើយស្ងាត់នៅចំពោះទ្រង់ ដោយរង់ចាំទទួលការបញ្ជាក់ពីព្រះវត្តមានទ្រង់ចំពោះលោកអ្នក ហើយទុកឲ្យអំណាចទ្រង់ធ្វើការក្នុង

អ្នកតាមរយៈព្រះវិញ្ញាណបរិសុទ្ធចុះ។ ចូរចំណាយពេលអានព្រះបន្ទូលទ្រង់ដូចជាកំពុងនៅក្នុងព្រះវត្តមានទ្រង់ ដើម្បីឲ្យលោកអ្នកអាចយល់អំពីអ្វីដែលទ្រង់រំពឹងពីលោកអ្នកនឹងធ្វើ និងអំពីអ្វីដែលទ្រង់សន្យាដល់លោកអ្នកផងដែរ។ ចូរឲ្យព្រះបន្ទូលបង្កើតបរិយាកាសបរិសុទ្ធនៅជុំវិញ និងនៅក្នុងលោកអ្នកចុះ គឺជាពន្លឺដ៏វិសុទ្ធនៃស្ថានសួគ៌ ដែលជាកន្លែងដែលព្រលឹងលោកអ្នកអាចស្ញើយល្ហែជាថ្មី និងចម្រើនឡើងសម្រាប់កិច្ចការក្នុងជីវិតប្រចាំថ្ងៃរបស់លោកអ្នក»។

ជីវិតរបស់លោកគ្រូ ហ័ដសិន ថេល័រ បានចាក់បំពេញយ៉ាងបរិបូរណ៍ហូរហៀរជាមួយសេចក្ដីអំណរ និងអំណាច ដោយសារតែព្រះគុណរបស់ព្រះជាម្ចាស់។ សូម្បីតែពេលគាត់មានវ័យលើសពី៧០ឆ្នាំ គាត់បានផ្អាកបន្តិចស្របពេលដែលដៃកាន់ព្រះគម្ពីរអង្គុយក្នុងបន្ទប់របស់គាត់នៅក្រុងឡូសាន (Lausanne) ហើយប្រាប់កូនរបស់គាត់ម្នាក់ក្នុងចំណោមកូនផ្សេងទៀតថា៖ «ថ្ងៃនេះ ប៉ាបានអានព្រះគម្ពីរចប់គម្រប់លើកទី៤០ នៅក្នុងរយៈពេល៤០ឆ្នាំនេះ»។ គាត់មិនគ្រាន់តែបានអានព្រះគម្ពីរទេ គាត់បានរស់នៅដោយកាន់តាមព្រះបន្ទូលផងដែរ។

លោកគ្រូ ហ័ដសិន ថេល័រ បានលះបង់អ្វីគ្រប់បែបយ៉ាង ដើម្បីដើរតាមព្រះគ្រីស្ទ។ គាត់បានសរសេរនៅពេលដែលគាត់ធ្វើការនៅប្រទេសចិនថា៖ «យើងត្រូវការមនុស្សដែលស្រឡាញ់ឈើឆ្កាង» ស្របពេលដែលគាត់បំពេញកិច្ចការនៅប្រទេសចិន។ ប្រសិនបើគាត់អាចនៅនិយាយជាមួយយើងបច្ចុប្បន្ននេះ តើគាត់នឹងមិនជំរុញយើងដោយមហិច្ឆតាធំបំផុតទេឬអី៖ «ដើម្បីឲ្យយើងស្គាល់ទ្រង់ ដែលជាព្រះមួយអង្គដែលយើងស្រឡាញ់ខ្លាំងបំផុត ហើយដើម្បីបានភ្លក់បទពិសោធន៍អំណាចនៃការរស់ឡើងវិញរបស់ទ្រង់ និងការរងទុក្ខជាមួយទ្រង់ទេឬអី?»។ តើយើងមិនឮសំនៀងដ៏ស្វាត់របស់លោកម្ដងទៀតទេឬអី នៅពេលដែលគាត់និយាយថា៖

យើងត្រូវប្ដេជ្ញាចិត្តខ្លួនយើងទៅនឹងជីវិតនៃលោកីយ៍។ ជីវិតសុខស្រួល និងធ្វើទៅតាមសេចក្ដីប៉ងប្រាថ្នារបស់ខ្លួននឹងមិនមានអំណាចនោះទេ។ ដើម្បីបង្កើតផលផ្លែ យើងត្រូវតែផ្ទុកឈើឆ្កាងតាមព្រះយេស៊ូវ។ មិនមានព្រះគ្រីស្ទពីរផ្សេងគ្នានោះទេ—មួយអង្គសម្រាប់គ្រីស្ទបរិស័ទធម្មតាត្រជាក់ល្ហឹម ហើយមួយអង្គទៀតសម្រាប់អ្នកដែលរងទុក្ខ និងប្ដេជ្ញាចិត្តបម្រើដ៏អស្ចារ្យក្នុងការបម្រើព្រះ។ មានព្រះគ្រីស្ទតែមួយអង្គប៉ុណ្ណោះ។ តើលោកអ្នកសុខចិត្តនៅជាប់នឹងទ្រង់ ហើយបង្កើតផលផ្លែដ៏ច្រើនដែរឬទេ?

# សេចក្ដីបន្ថែម

នៅពេលលោកគ្រូ ហ៉ាដសិន ថេល័រ បានលាចេញពីតំណែងដឹកនាំអង្គការបេសកកម្មចិនដីគោកនៅឆ្នាំ១៩០០ ដែលនោះគឺ៥ឆ្នាំមុនពេលគាត់ទទួលមរណភាព នៅពេលនោះអង្គការបេសកកម្មចិនដីគោកមានបេសកជនចំនួន៧៥០នាក់។ នៅឆ្នាំ១៩៣២ សមាជិកបានកើនឡើងដល់ចំនួន១២៨៥នាក់។ នៅអំឡុងពេលក្រោមការដឹកនាំរបស់លោក ហ៉ាដសិន អង្គការបេសកកម្មចិនដីគោកទទួលបានប្រាក់ចំណូលរាប់លានដុល្លារ ដោយគ្រាន់តែសូមជំនួយពីព្រះជាម្ចាស់ យ៉ាងហោចណាស់៤លានដុល្លារ (ប្រហែលជាង $៩២ លានដុល្លារ បច្ចុប្បន្ន)។ នៅចន្លោះឆ្នាំ១៩០០ ដល់ ១៩៣២ ប្រាក់ចំណូលសរុបបានកើនឡើងជិតដល់២០លានដុល្លារ (ប្រហែលជាង$៤៦០លានដុល្លារ បច្ចុប្បន្ន) ដោយគ្រាន់តែទូលសូមពីព្រះជាម្ចាស់ប៉ុណ្ណោះ។ ហើយអង្គការបេសកកម្មនេះមិនមានជំពាក់បំណុលនរណាទេ។ អ្នកចម្រូតជនជាតិចិនចំនួនប្រាំពីររយនាក់បានចូលរួមជាមួយបេសកកម្មនេះ ដែលនោះជាការឆ្លើយតបយ៉ាងធំធេងចំពោះការអធិស្ឋានរបស់លោក ថេល័រ ហើយអង្គការបេសកកម្មចិនដីគោកបានជ្រមុជទឹកដល់អ្នកប្រែចិត្តទទួលជឿលើព្រះយេស៊ូវចំនួនមួយម៉ឺនបីពាន់នាក់ចាប់តាំងពីអង្គការបានចាប់ផ្ដើមបង្កើតមក។ ឥឡូវនេះ មានអ្នកចម្រូតជនជាតិចិនពី៣ទៅ៤ពាន់នាក់ ដែលបានធ្វើការជាមួយអង្គការ ស៊ី.អាយ.អិម. ហើយចំនួនអ្នកដែលធ្វើពិធីបុណ្យជ្រមុជទឹកតាំងពីឆ្នាំ១៩០០ ដល់ ១៩៣២ គឺមួយសែននាក់។ “មិនមែនយើងខ្ញុំ ឱព្រះយេហូវ៉ាអើយ មិនមែនយើងខ្ញុំដែលគួរលើកតម្កើងទេ សូមទ្រង់លើកតម្កើងព្រះនាមនៃទ្រង់វិញ” (ទំនុកដំកើង ១១៥:១)។

លោក ហ៉ាដសិន គឺជាស្ថាបនិក និងជានាយកប្រតិបត្តិនៃការងារមួយដែលមិនអាច

ជំនួសបាននៅក្នុងតួនាទីនេះ។ ទោះជាយ៉ាងណាក៏ដោយក៏អ្នកដឹកនាំដែលព្រះបានលើកឡើងឲ្យស្នងតំណែងពីគាត់ គឺលោកគ្រូ ឌី. អ៊ី. ហូសថ៍ បាននាំមកនូវទេពកោសល្យពិសេសផ្ទាល់ខ្លួនរបស់គាត់។ ចាប់តាំងពីឆ្នាំ១៩០០មក ទោះបីជាមានទំនួលខុសត្រូវកើនឡើងក៏ដោយក៏ជីវិតនៃការអធិស្ឋានរបស់លោកគ្រូ ហូសថ៍ បានទ្រទ្រង់គាត់ និងនាំព្រះពរដល់ចិនដីគោក ហើយគាត់បានដឹកនាំការងារឲ្យរីកចម្រើនតាមរយៈពេលវេលាដ៏លំបាកផងដែរ។

ពេលវេលានៃការសាកល្បងដ៏ច្រើនលើសលប់ និងការបរាជ័យជាក់ស្ដែងបានកើតឡើង។ នៅពេលដែលបដិវត្តន៍បានផ្ទុះឡើង ហើយប្រទេសចិនបានផ្លាស់ប្ដូរយ៉ាងឆាប់រហ័សទៅជាប្រទេសសាធារណរដ្ឋ រដ្ឋកាលនៃភេរវកម្មបានកាន់កាប់នៅក្នុងតំបន់មួយចំនួន ហើយអង្គការបេសកកម្មចិនដីគោកបានប្រឈមនឹងតម្រូវការបន្ថែមទៅក្នុងបញ្ជីទុក្ករបុគ្គល (សមាជិកនៃអង្គការបេសកកម្មចិនដីគោកត្រូវរងទុក្ខ ឬស្លាប់ដោយសារជំនឿ និងកិច្ចបម្រើ) របស់ខ្លួន។ នៅក្នុងទីក្រុងសៀន (Sian) ដែលជារាជធានីនៃចក្រភពហ្វូងមនុស្សដែលគ្មានច្បាប់បានសម្លាប់លោកស្រីប៉ែកម៉ែន (Mrs. Beckman) និងកូន៦នាក់មកពីគ្រួសារបេសកជនរួមជាមួយលោក វ៉ាតនេ (Mr. Vatne) ដែលបានព្យាយាមការពារពួកគាត់ផងដែរ។ មានបេសកជនជាច្រើននាក់ត្រូវបោះបង់ចោលមុខតំណែងរបស់ខ្លួន ដើម្បីរកទីតាំងដែលមានសុវត្ថិភាព ខណៈពេលដែលអ្នកនៅសល់អាចផ្ដល់ជម្រកដល់ប្រជាជនដែលមានការភ័យខ្លាច ជាពិសេសស្ដ្រីដែលស្វែងរកការជ្រកកោននៅក្នុងផ្ទះរបស់បេសកជន។ ពេលវេលាទាំងនោះបានផ្ដល់ឱកាសដ៏មានតម្លៃក្នុងការបង្ហាញដំណឹងល្អតាមរយៈទាំងសកម្មភាព និងពាក្យសម្ដី ដែលនាំឲ្យមានការកើនឡើងយ៉ាងខ្លាំងនូវសុច្ឆន្ទៈចំពោះបេសកជនទាំងឡាយនៅក្នុងតំបន់ខាងក្នុង។

ការគ្មានច្បាប់ និងអំពើចោរកម្មដ៏ឃោរឃៅបានរីករាលដាលឡើង ក៏ដូចជាការតវ៉ារបស់សិស្សនិស្សិតផងដែរ។ ក្រុមបេសកជន និងគ្រីស្ទបរិស័ទនៅប្រទេសចិនប្រឈមមុខនឹងគ្រោះថ្នាក់កាន់តែខ្លាំងឡើងៗ។ ទោះជាយ៉ាងណាក៏ដោយ ក៏វាជារឿងគួរឲ្យភ្ញាក់ផ្អើលដែរ ដែលការផ្លាស់ប្ដូរដ៏ធំបែបនេះបានកើតឡើងជាមួយនឹងការបង្ហូរឈាម និងចលាចលតិចតួចប៉ុណ្ណោះ។ ប្រទេសចិនដែលបានបាត់បង់សន្តិសុខ និងស្ថិរភាព ហើយខំស្វែងរកអ្វីដែលប្រសើរជាង បានក្លាយជាជនរងគ្រោះរបស់ពួកចោរ។ ការធ្វើមនោគមវិជ្ជា

កុម្មុយនិស្ត និងមនោគមវិជ្ជាបូលសេវិគ (Bolshevik) ដ៏ងប់ងល់បានធ្វើឲ្យស្ថានការណ៍កាន់តែអាក្រក់ទៅៗក្នុងវិស័យជាច្រើន ហើយការឈ្លានពានឥតឈប់ឈរពីមហាអំណាចជិតខាងនាពេលថ្មីៗនេះបានកាន់តែបង្កើនទុក្ខព្រួយបន្ថែមទៀត។

សុភាសិតចិនបុរាណមួយបានពោលថា៖ «នៅពេលបងប្អូនឈ្លោះគ្នា នោះអ្នកដទៃជាអ្នកទទួលផលចំណេញ»។ ហើយសុភាសិតផ្សេងទៀតក៏បានពោលផងដែរថា៖ «សាងអ្វីមួយអាចប្រើពេលរាប់រយឆ្នាំ តែបំផ្លាញវិញប្រើពេលតែមួយថ្ងៃប៉ុណ្ណោះ»។

ទោះបីជាមានអ្វីៗកើតឡើងក៏ដោយ ក៏ព្រះជាម្ចាស់បានការពារកិច្ចការរបស់យើងផងដែរ ដោយអនុញ្ញាតឲ្យមានការរីកចម្រើនជាលំដាប់នៅក្នុងការខិតខំផ្សាយដំណឹងល្អរបស់អង្គការបេសកកម្មចិនដីគោក។ ដោយព័ន្ធកិច្ចរបស់ពួកគាត់បានផ្ដោតទៅលើកិច្ចការផ្សាយដំណឹងល្អ ជាជាងការជួយកសាងស្ថាប័ន ដូច្នេះហើយបានជានាំមកនូវភាពរួសរាយរាក់ទាក់របស់មនុស្សជាច្រើន និងឆន្ទៈរបស់ពួកគេក្នុងការស្ដាប់ការកម្សាន្តចិត្តនៅក្នុងដំណឹងល្អ។ ឱកាសនេះ គឺជាឱកាសល្អជាងពេលណាទាំងអស់ ដើម្បីលក់សៀវភៅគ្រីស្ទបរិស័ទ និងសម្រាប់គ្រីស្ទបរិស័ទធ្វើជាទីបន្ទាល់តាមរយៈជីវិតរបស់ពួកគេ ដោយសារអំណាចនៃសេចក្ដីសង្គ្រោះរបស់ព្រះគ្រីស្ទ។ «ការប្រោសឲ្យជាពីអាវវែងគ្មានថ្នេររបស់ទ្រង់» គឺជាអ្វីដែលប្រទេសចិនត្រូវការ ហើយដួងចិត្តដែលរងភាពខ្វះខាតជាច្រើនកំពុងងាកទៅរកទ្រង់ ដើម្បីមានជីវិត និងក្ដីសង្ឃឹមចំពេលមានស្ថានភាពអស់សង្ឃឹមដូចនេះ។

វាច្បាស់ណាស់ចំពោះអស់អ្នកណាដែលសម្លឹងទៅរកព្រះជាម្ចាស់សម្រាប់ការដឹកនាំថា ឥឡូវនេះ មិនមែនជាពេលដែលត្រូវកាត់បន្ថយការងារព័ន្ធកិច្ចនោះទេ។ គោលជំនឿនេះបាននាំឲ្យអង្គការបេសកកម្មចិនដីគោក ផ្លាស់ប្ដូរពីគោលការណ៍នៃការរង់ចាំទៅជាការឆ្ពោះទៅរកការជំរុញដ៏សំខាន់មួយ ដោយធ្វើតាមទស្សនៈវិស័យថ្មីៗ និងមហិច្ឆតាដ៏ធំរបស់លោកគ្រូ ហ៉ដសិន។ លោកគ្រូ ហ៉ដសិន បានបង្ហាញពីការយល់ដឹងថ្មីមួយអំពីបទបញ្ញត្តិដ៏ច្បាស់របស់ព្រះអម្ចាស់ «ការផ្សាយដំណឹងល្អដល់មនុស្សគ្រប់ជាតិទាំងអស់»។

បើគ្មានការលះបង់ និងការប្ដេជ្ញាចិត្តទេ នោះកិច្ចការនេះក៏មិនអាចសម្រេចទៅបានដែរ មិនថាយើងត្រូវលះបង់ប៉ុណ្ណា ដើម្បីធ្វើតាមបង្គាប់ចៅហ្វាយរបស់យើងក៏ដោយ។ បើទោះបីជាយ៉ាងក្ដីក៏ខ្ញុំពិតជាជឿនៅក្នុងជម្រៅនៃព្រលឹងរបស់ខ្ញុំថា វាច្បាស់ជាបានសម្រេចជា

មិនខាន។

ខ្ញុំដឹងប្រាកដថា ព្រះជាម្ចាស់បានដឹកនាំខ្ញុំ នៅពេលខ្ញុំបានសរសេរ ហើយបោះពុម្ពកូនសៀវភៅទាំងនេះ «ការផ្សាយដំណឹងល្អដល់មនុស្សគ្រប់ជាតិទាំងអស់»។

គ្រាប់ពូជរស់នឹងនៅតែបង្កើតផលផ្លែ សូម្បីតែនៅពេលវាធ្លាក់ទៅលើដី ហើយងាប់។ លោកគ្រូ ហ័ដសិន បានទទួលមរណភាពមុនពេលរលកទីពីរនៃការរងទុក្ខបានចូលមកដល់ គឺវិបត្តិធ្ងន់ធ្ងរបានចូលមកដល់នាឆ្នាំ១៩២៧។ នៅឆ្នាំដែលមានសោកនាដកម្មនោះ សមាជិកជាងប្រាំមួយរយនាក់នៃអង្គការបេសកកម្មចិនដីគោកត្រូវចាកចេញពីទីតាំងរបស់ខ្លួន នៅពេលរដ្ឋាភិបាលភាគខាងលិចបារម្ភអំពីការកើនឡើងថ្មី និងខ្លាំងនៃមនោសញ្ចេតនា ហើយបានផ្តល់ការណែនាំប្រជាជនរបស់ពួកគេឲ្យចាកចេញពីស្រុកខាងក្នុង។

លោកបណ្ឌិត រ៉ូប៊ើត អេច. ហ្គ្លូវើរ (Dr. Robert H. Glover) នាយកអង្គការបេសកកម្មចិនដីគោកនៅអាមេរិកខាងជើង (North American Director of the Mission) បានសរសេរថា «អ្នកឃោសនានៅទីក្រុងមូស្គូ (Moscow) បានជំរុញឲ្យទាហាន និងនិស្សិតនៅប្រទេសចិនប្រព្រឹត្តអំពើហិង្សា ដោយផ្តោតសំខាន់ទៅលើក្រុមបេសកជន និងជនបរទេសផ្សេងទៀត។ ជាលទ្ធផល បេសកជនភាគច្រើននៅទូទាំងប្រទេសចិនត្រូវបានបង្ខំឲ្យបោះបង់ចោលមុខតួនាទីរបស់ខ្លួន ចាកចេញពីអ្នកប្រែចិត្តជឿ និងចោលការងារដែលបានធ្វើជាច្រើនឆ្នាំ ហើយធ្វើដំណើរទៅកាន់ឈូងសមុទ្រ។ ជាលទ្ធផល រាប់រយនាក់បេសកជនរបស់អង្គការ ស៊ី. អាយ. អិម. និងអ្នកផ្សេងទៀត ត្រូវចាកចេញពីតំបន់ដីគោកនៃប្រទេសចិន ដោយមានការបិទមិនឲ្យពួកគាត់ត្រឡប់មកវិញទេ»។

ការផ្គត់ផ្គង់សម្រាប់ជនភៀសខ្លួនទាំងនេះក្នុងការតាំងទីលំនៅដ៏ចង្អៀតលើសលប់បានដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរលើប្រាក់មូលនិធិរបស់អង្គការបេសកកម្មចិនដីគោក។ ត្រឹមតែទីក្រុងសៀងហៃមួយតម្រូវឲ្យយើងជួល និងផ្តល់គ្រឿងសង្ហារិមដល់ផ្ទះចំនួន១៤ខ្នង ហើយយើងត្រូវចំណាយលើការធ្វើដំណើរទាំងអស់ដោយធនធានមានចំនួនកំណត់។ អ្នកគាំទ្រអង្គការ ស៊ី. អាយ. អិម. ជាច្រើននៅស្រុកកំណើតបានកត់សម្គាល់ថា ការងារនោះត្រូវបានផ្អាកជាបណ្តោះអាសន្ន ហើយបានបង្វែរការបរិច្ចាគសម្រាប់បេសកជនទៅកន្លែងផ្សេងទៀត។ ប្រសិនបើអង្គការបេសកកម្មចិនដីគោកបានពឹងផ្អែកលើម្ចាស់ជំនួយ

របស់ខ្លួនជំនួសឲ្យព្រះដ៏មានព្រះជន្មរស់ នោះលទ្ធផលអាចនឹងខុសគ្នាខ្លាំង។ ប៉ុន្តែ ជាញឹកញាប់លោកគ្រូ ហ័ដសិន បានរម្លឹកខ្លួនគាត់ និងអ្នកដទៃទៀតថា "ព្រះជាម្ចាស់ស្មើនឹងភាពបន្ទាន់ទាំងអស់" ហើយការផ្គត់ផ្គង់របស់ព្រះអង្គសម្រាប់អង្គការ ស៊ី. អាយ. អិម. ក្នុងអំឡុងវិបត្តិឆ្នាំ១៩២៧ គឺជាចម្លើយដ៏គួរឲ្យកត់សម្គាល់បំផុតមួយចំពោះការអធិស្ឋានដែលអង្គការបេសកកម្មនេះធ្លាប់មាន។

ប្រាក់ចំណូលរបស់អង្គការ ស៊ី. អាយ. អិម. បានធ្លាក់ចុះយ៉ាងគំហុក មិនមែនរាប់ពាន់ដុល្លារនោះទេ ប៉ុន្តែរាប់ម៉ឺនដុល្លារក្នុងមួយឆ្នាំ។ ដោយប្រឈមមុខនឹងតម្រូវការកើនឡើងយ៉ាងខ្លាំងលើធនធានរបស់ខ្លួន ហើយការប្ដេជ្ញាចិត្តថា នឹងមិនស្នើសុំជំនួយផ្នែកហិរញ្ញវត្ថុ ឬជាជំពាក់បំណុលគេនោះ តើពួកគាត់នឹងដោះស្រាយស្ថានភាពដោយរបៀបណាជាមួយនឹងប្រាក់ចំណូលដែលកាត់បន្ថយចំនួន $១១៤.000,00 ដុល្លារ (ប្រហែលស្មើនឹង $២.០៦៥.៧៦៥,00 ដុល្លារ បច្ចុប្បន្ន)?

"ព្រះជាម្ចាស់ស្មើនឹងភាពបន្ទាន់ទាំងអស់" ៖ នៅឆ្នាំនោះព្រះអង្គរីករាយក្នុងការធ្វើការតាមរបៀបដែលមិននឹកស្មានដល់។ លុយដែលផ្ញើទៅប្រទេសចិនពីប្រទេសកំណើតត្រូវតែប្ដូរទៅជាប្រាក់ក្នុងអត្រាផ្លាស់ប្ដូរជានិច្ច។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅឆ្នាំនោះអត្រានេះបានបន្តគាំទ្រដល់មូលនិធិបេសកកម្មផងដែរ។ លុយពីស្រុកកំណើតដែលបានទិញបានប្រាក់កាន់តែច្រើន ហើយនៅចុងឆ្នាំវាបានសម្រេចថា ទោះបីជាប្រាក់តិចជាង $១១៤.000,00 ដុល្លារ ត្រូវបានបញ្ជូនទៅប្រទេសចិន បើប្រៀបធៀបទៅនឹងឆ្នាំមុនក៏ដោយក៏អង្គការបេសកកម្មចិនដីគោកពិតជាបានប្រាក់ចំណេញចំនួន $១១៥.000,00 ដុល្លារ ពីអត្រាប្ដូរប្រាក់។ ជាលទ្ធផល តម្រូវការទាំងអស់ត្រូវបានបំពេញ ហើយឆ្នាំដ៏លំបាកនោះបានប្រែក្លាយទៅជាឆ្នាំនៃការដឹងគុណដ៏បរិបូរណ៍មួយ។

លោកបណ្ឌិត ហ្គ្លើវ បានបន្តការពិភាក្សាអំពីការដែលបានបិទទ្វារថា៖

ជាការពិតណាស់ វាជាពេលវេលាដ៏ក្រៀមក្រំ ហើយតាមទស្សនៈរបស់មនុស្ស ស្ថានភាពហាក់បីដូចជាក្រៀមក្រំណាស់។ តើមានឱកាសសម្រាប់ការងារព័ន្ធកិច្ចនឹងបើកឡើងវិញដែរឬទេ? អ្នកដែលមានមន្ទិលសង្ស័យ មនុស្សទុទិដ្ឋិនិយម និងមនុស្សកំសាកម្នាក់ៗមានចម្លើយរៀងៗខ្លួន។ ទោះជាយ៉ាងណាក៏ដោយក៏បេសកជនមួយចំនួនរួមទាំងអ្នកមកពីអង្គការ ស៊ី. អាយ. អិម. បានមើលស្ថានភាពកាន់តែមានភាពសុទិដ្ឋិនិយម ហាក់ដូច

ជាពួកគេមានការយល់ដឹងដ៏ពិសេសមួយ។

ពួកគេគ្មានការសង្ស័យទេថា សាតាំងបានវាយប្រហារ ដើម្បីបំផ្លាញការងារព័ន្ធកិច្ច។ ប៉ុន្តែ ព្រះបន្ទូលមិនបានបង្រៀនឲ្យអ្នកបម្រើព្រះគួរទទួលយកភាពបរាជ័យក្រោមស្នាដៃរបស់សាតាំងឡើយ។ ប្រាកដណាស់ មិនមែនទេ។ សាតាំងមិនដែលបំផ្លាញបំណងព្រះទ័យរបស់ព្រះគ្រីស្ទតាមរយៈការបៀតបៀនឡើយ។ សាវ័ក ប៉ុល ដែលជាបេសកជនដ៏អស្ចារ្យម្នាក់បានលើកឡើងថា តាមរយៈការបៀតបៀនរបស់គាត់គឺវាបានជួយផ្សព្វផ្សាយដំណឹងល្អ ហើយគាត់បានលើកទឹកចិត្តមិត្តរួមការងាររបស់គាត់កុំភ័យខ្លាចចំពោះសត្រូវរបស់ខ្លួនឡើយ។ ព្រះគម្ពីរសញ្ញាថ្មីបានកត់ត្រាអំពីរបៀបដែលព្រះបានប្រែក្លាយការប្រឆាំង និងការបៀតបៀនទៅជាឧបករណ៍សម្រាប់ជំរុញបេសកកម្ម។ រាល់ការវាយប្រហារដោយសត្រូវនៅសព្វថ្ងៃនេះគួរតែនាំទៅរកការរីកចម្រើនថ្មី និងសមិទ្ធផលកាន់តែច្រើន។

អង្គការបេសកកម្មចិនដីគោកបានមើលឃើញស្ថានការណ៍ដ៏លំបាកដែលខ្លួនជួបប្រទះទុកថាជា «ឱកាស»...តើការងារព័ន្ធកិច្ចពួកគាត់នៅក្នុងប្រទេសចិនពិតជាត្រូវបញ្ចប់មែនទេ? វាមិនអាចទេ ដរាបណាមហាបេសកកម្មរបស់ព្រះគ្រីស្ទនៅតែមាន នោះគោលដៅនៃការចែកចាយដំណឹងល្អជាមួយមនុស្សរាប់លាននាក់របស់ប្រទេសចិននៅតែមិនទាន់អាចសម្រេចបាននៅឡើយ។ ពួកគាត់ត្រូវតែបន្តការងារ មិនថាត្រូវចំណាយអ្វីឡើយ។ ដូច្នេះ អង្គការ ស៊ី. អាយ. អិម. បានអធិស្ឋានយ៉ាងអស់ពីចិត្តទៅកាន់ព្រះសម្រាប់ឱកាស ដើម្បីបន្តការងាររបស់ខ្លួន និងសម្រាប់ទិសដៅច្បាស់លាស់សម្រាប់ផែនការអនាគតរបស់ពួកគេ។

លោកបណ្ឌិត ហ្វ្លស៊ើរ បន្តធ្វើទីបន្ទាល់ថា «ទាំងនោះគឺជាថ្ងៃនៃការត្រួតពិនិត្យយ៉ាងស៊ីជម្រៅ និងការអធិស្ឋានដោយសង្វាត។ វាគឺជាអំឡុងពេលនៃការសាកល្បងដែលព្រះបានផ្តល់នូវការនិមិត្តមួយ និងការជឿជាក់សម្រាប់ការរីកចម្រើនដ៏សំខាន់មួយ។ ពេលនោះហើយ បន្ទាប់ពីធ្វើការស្ទង់មតិយ៉ាងម៉ត់ចត់លើកិច្ចការ ស៊ី. អាយ. អិម. ទាំងមូល អ្នកដឹកនាំអង្គការ ស៊ី. អាយ. អិម. មានអារម្មណ៍ថា បណ្តាលឲ្យទូលសុំទៅកាន់ព្រះជាម្ចាស់ និងរាស្ត្ររបស់ទ្រង់ មិនមែនត្រឹមតែមួយរយនាក់ប៉ុណ្ណោះទេ ប៉ុន្តែសុំឲ្យមានអ្នកធ្វើការបម្រើព្រះចំនួនពីររយនាក់បន្ថែមទៀតសម្រាប់ការជំរុញការផ្សាយដំណឹងល្អដ៏សំខាន់មួយនេះ។

អ្នកគាំទ្រអង្គការបេសកកម្មចិនដីគោកមានការសប្បាយចិត្តយ៉ាងខ្លាំង និងមានការប៉ះពាល់យ៉ាងខ្លាំងនៅពេលពួកគាត់បានទទួលការអំពាវនាវនេះ។ ពួកគាត់ជឿថា វាជា

បំណងព្រះហឫទ័យរបស់ព្រះ ដែលជាលទ្ធផលនៃការអធិស្ឋានជាច្រើន ហើយភ្លាមៗនោះការងារក៏ចាប់ផ្តើមមានអារម្មណ៍ថា រស់ឡើងវិញ។ រយៈពេលពីរឆ្នាំ (១៩២៩-៣១) បានកន្លងផុតទៅ ស្របពេលដែលពួកគេរង់ចាំបេសកជនថ្មីដោយអន្ទះសា។ ទោះបីជាមានបញ្ហាប្រឈមជាច្រើន រួមទាំងការប្រឆាំងខ្លាំងនៅក្នុងប្រទេសចិនក៏ដោយ ក៏បទពិសោធន៍ទាំងនោះបានក្លាយទៅជាការលើកទឹកចិត្ត និងភាពរីជួមានយ៉ាងជ្រាលជ្រៅដែរ។

នៅឆ្នាំ១៩៣១ មិនត្រឹមតែក្រុមចុងក្រោយនៃក្រុមពីរយ—៩១នាក់មកពីអាមេរិកខាងជើង—បានចេញទៅប៉ុណ្ណោះទេ ប៉ុន្តែការរៀបចំសម្រាប់ការស្វាគមន៍ពួកគាត់នៅក្នុងប្រទេសចិន គឺគួរឲ្យចាប់អារម្មណ៍ដូចគ្នា។ ទីស្នាក់ការកណ្តាលនៅសៀងហៃដែលហួសសម័យរបស់អង្គការ ស៊ុ. អាយ. អិម. ត្រូវបានជំនួសនៅឆ្នាំនោះនៅកន្លែងដែលសមស្រប និងធំជាងនេះដែលព្រះបានប្រទានមក ដោយមិនគិតថ្លៃសម្រាប់អង្គការ ស៊ុ. អាយ. អិម.។ បន្ទាប់ពីអធិស្ឋានជាច្រើនដង ឱកាសមួយបានកើតឡើងក្នុងការលក់កន្លែងចាស់ក្នុងតម្លៃ៦៥ដងនៃតម្លៃដើម។ សមាជិកនៃអង្គការ ស៊ុ. អាយ. អិម. ម្នាក់ដែលបានទទួលមរណភាពតាំងពីពេលនោះបានប្រគល់ទ្រព្យសម្បត្តិនេះមក។ បន្ទាប់ពីជាងសែសិបឆ្នាំ នេះអនុញ្ញាតឲ្យបង្កើតទីស្នាក់ការកណ្តាលថ្មីនៅពេលដែលពួកគេត្រូវការជាបន្ទាន់សម្រាប់ការងារពង្រីកព័ន្ធកិច្ច។ អគារថ្មីក៏បានត្រៀមរួចរាល់ទាន់ពេល ដើម្បីទទួលក្រុមដ៏គួរឲ្យចាប់អារម្មណ៍នៅរដូវស្លឹកឈើជ្រុះមុន នៅពេលដែលអ្នកបម្រើព្រះថ្មីជាងមួយរយនាក់ទាំងអស់បានមកដល់ប្រទេសចិនក្នុងរយៈពេលតែមួយខែ ដើម្បីធ្វើការឲ្យអង្គការបេសកកម្មចិនដីគោក។

ការផ្គត់ផ្គង់ដ៏អស្ចារ្យជួយផ្គត់ផ្គង់ច្រើនជាងអ្វីដែលអ្នកដឹកនាំដ៏ឆ្លាតវៃបំផុតរបស់អង្គការបេសកកម្មចិនដីគោកអាចរំពឹងទុកបានទៅទៀត។ នៅពេលដែលកងកម្លាំងជប៉ុនបានបើកការវាយប្រហារដែលមិននឹកស្មានដល់ទាំងស្រុងលើទីក្រុងសៀងហៃកាលពីដើមឆ្នាំ១៩៣២ ហើយការប្រយុទ្ធគ្នាភាគច្រើនផ្តោតលើទីក្រុង ហុងគីវ ដែលជាស្រុកដែលអតីតទីស្នាក់ការរបស់អង្គការបេសកកម្មចិនដីគោក។ ទាន់ពេលវេលានោះ ព្រះហស្តដឹកនាំរបស់ព្រះបាននាំទៅដល់ការផ្លាស់ទីតាំងអង្គការ ស៊ី. អាយ. អិម. ដែលមានចម្ងាយប្រហែលជិត៥គីឡូម៉ែត្រត្រឡប់ទៅកន្លែងតាំងទីលំនៅអន្តរជាតិទៅកាន់ទីតាំងដែលមានសុវត្ថិភាពជាង។ តើមានអ្នកណាទៀតក្រៅពីព្រះអាចទស្សន៍ទាយ និងរៀបចំសម្រាប់ស្ថានការណ៍ដែលនឹកស្មានមិនដល់ និងទុក្ខព្រួយតាមរបៀបដ៏អស្ចារ្យបែបនេះ?

ត្រូវហើយ! ព្រះអង្គនៅតែយកព្រះទ័យទុកដាក់ចំពោះសេចក្តីត្រូវការនៃការងាររបស់ទ្រង់ផ្ទាល់។ វាមិនមែនជារឿងគួរភ្ញាក់ផ្អើលទេ ដែលអង្គការបេសកកម្មចិនដីគោកបានអះអាងយ៉ាងមុឹងម៉ាត់លើសេចក្តីពិតចាស់ ដែលបេសកកម្មនោះត្រូវបានបង្កើតឡើង។ វាមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលនៅឆ្នាំ១៩៣២ យើងប្រារព្ធដោយការដឹងគុណដល់ខួបមួយរយឆ្នាំនៃកំណើតរបស់ឪពុកខាងឯវិញ្ញាណ ដែលគាត់ជាអ្នកដឹកនាំ ដោយប្រើសេចក្តីជំនឿ និងការគោរពប្រតិបត្តិដល់ព្រះរបស់គាត់បានបង្កើតអង្គការបេសកកម្មនេះឡើង។ អរគុណព្រះជាម្ចាស់ បេសកជនទាំង១២៨៥នាក់អាចធ្វើការបញ្ជាក់ឡើងវិញដោយរីករាយនូវការជឿជាក់របស់ស្ថាបនិករបស់ខ្លួននៅថ្ងៃនេះ។

ព្រះដ៏មានព្រះជន្មគង់នៅមានព្រះជន្មរស់នៅឡើយ ហើយព្រះបន្ទូលដ៏មានព្រះជន្មរស់របស់ទ្រង់គឺជាព្រះបន្ទូលដ៏រស់ដែល។ យើងអាចពឹងផ្អែកលើព្រះបន្ទូលនេះទាំងស្រុងបាន។ យើងអាចជឿទុកចិត្តនូវពាក្យពេចន៍ណាដែលព្រះទ្រង់ធ្លាប់មានបន្ទូល ឬបានសរសេរដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ដែរ។

គ្រាន់តែសាកល្បងសេចក្តីស្រឡាញ់របស់ទ្រង់ចុះ នោះបទពិសោធន៍របស់លោកអ្នកនឹងបង្ហាញថា តើវាអស្ចារ្យប៉ុណ្ណា? អស់អ្នកដែលទុកចិត្តលើសេចក្តីពិតរបស់ទ្រង់នឹងទទួលព្រះពរពីទ្រង់ជាមិនខាន។ ឱពួកអ្នកបរិសុទ្ធអើយ! ចូរគោរពដល់ទ្រង់ចុះ នោះលោកអ្នកនឹងគ្មានអ្វីត្រូវខ្លាចទៀតឡើយ។ ចូររីករាយក្នុងការបម្រើទ្រង់ចុះ នោះព្រះអង្គនឹងបំពេញតម្រូវការរបស់អ្នកជាមិនខាន។

អតីតកាលមិនបានប្រើឲ្យអស់លទ្ធភាព ឬតម្រូវការឲ្យធ្វើការអស្ចារ្យសម្រាប់ព្រះជាម្ចាស់នោះទេ។ ក្រុមជំនុំដែលពឹងផ្អែកលើប្រវត្តិសាស្ត្រអតីតកាលរបស់ខ្លួនសម្រាប់ការអស្ចារ្យនៃអំណាច ហើយព្រះគុណរបស់ខ្លួន គឺជាក្រុមជំនុំដែលបានធ្លាក់ចុះហើយ។

“អ្នកមានគុណដ៏ធំបំផុតនៅសម័យនេះ គឺជាមនុស្សម្នាក់ដែលនាំគ្រូៗ និងក្រុមជំនុំបែរទៅរកការអធិស្ឋានវិញ”

— លោក អ៊ី. អិម បោនស៍ នៅក្នុងអំណាចតាមរយៈការអធិស្ឋាន” E. M. Bounds, *(Power through Prayer)*។

# គម្រោងកាលប្បវត្តិ

**នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៨៣២៖** លោកគ្រូ ជេមស៍ ហ័ដសិន ថេល័រ បានកើតនៅ
បើនស្លីយ៍ ទីក្រុងយកសៀរ ប្រទេសអង់គ្លេស (Barnsley, Yorkshire, England )។

**នៅខែមិថុនា ឆ្នាំ១៨៤៩៖** ទទួលជឿលើព្រះគ្រីស្ទ។ បន្ទាប់មក គាត់ក៏បានទទួលការត្រាស់ហៅនៅក្នុងការបម្រើព្រះមួយជីវិត។

**នៅខែឧសភា ឆ្នាំ១៨៥០៖** ចាប់ផ្តើមការសិក្សាខាងវេជ្ជសាស្ត្រនៅទីក្រុងហល និងធ្វើជាជំនួយការវេជ្ជបណ្ឌិត រ៉ូប៊ើត ហាតឌីយ៍។

**នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៨៥៣៖** បានឡើងកប៉ាល់ចេញទៅប្រទេសចិន ក្នុងនាមជាបេសកជនរបស់សមាគមផ្សាយដំណឹងល្អចិន។

**ឆ្នាំ១៨៥០-១៨៦៤៖** ការបះបោររបស់ពួកថៃភីង។

**ថ្ងៃទី០១ ខែមីនា ឆ្នាំ១៨៥៤៖** លោកគ្រូ ហ័ដសិន ថេល័រ បានធ្វើដំណើរទៅដល់ទីក្រុងសៀងហៃដោយកប៉ាល់។

**ឆ្នាំ១៨៥៤-១៨៥៥៖** បានធ្វើដំណើរផ្សាយដំណឹងល្អចំនួន១០ដង។

**ពីខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ១៨៥៥៖** ស្នាក់នៅផ្ទះជាលើកដំបូងនៅក្នុងទឹកដី “ចិនដីគោក”៖ ប្រាំមួយសប្តាហ៍នៅកោះនៃស្រុកសុងមីង។

**ឆ្នាំ១៨៥៥-១៨៥៦ ៖** ចំណាយពេលប្រាំពីរខែជាមួយលោកគ្រូ វីលលៀម ស៊ី. ប៊ើនស៍។

**ខែតុលា ឆ្នាំ១៨៥៦៖** តាំងលំនៅនៅក្រុងនីងប៉ូ។

**នៅខែមិថុនា ឆ្នាំ១៨៥៧៖** លាឈប់ពីការងារនៅសមាគមផ្សាយដំណឹងល្អចិន។

**នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៨៥៨៖** បានរៀបការជាមួយនឹងកញ្ញា ម៉ារា ជេ. ដាយយ័រ។

**នៅខែកញ្ញា ឆ្នាំ១៨៥៩៖** បានចូលមកគ្រប់គ្រងមន្ទីរពេទ្យរបស់វេជ្ជបណ្ឌិត ផាកខ័រ នៅទីក្រុងនីងប៉ូ។

**នៅរដូវក្តៅ ឆ្នាំ១៨៦០៖** ត្រឡប់ទៅប្រទេសអង់គ្លេស សម្រាប់វិស្សមកាលជាលើកដំបូង។

**ពីឆ្នាំ១៨៦០-១៨៦៥៖** ឆ្នាំអាថ៌កំបាំង។

**នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៨៦៥៖** បានចុះចូលនឹងព្រះនៅក្រុងប្រាយតុន ហើយអធិស្ឋានសូមអ្នកធ្វើការបម្រើព្រះជាមួយគាត់ចំនួនម្ភៃនាក់នៅទឹកដីចិនដីគោក។

**នៅខែធ្នូ ឆ្នាំ១៨៦៦៖** ការតាំងទីលំនៅជាមួយក្រុមឡាមើម័រ នៅក្រុងហានចូវ។

**នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៨៦៧៖** មរណភាពរបស់កុមារីគ្រេស៊ី។

**នៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៨៦៨៖** កុបកម្មនៅក្រុងយ៉ាងចូវ។

**នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៨៦៩៖** បានចូលរួមនៅក្នុងការផ្លាស់ប្រែជីវិត៖ «ព្រះជាម្ចាស់បានបង្កើតខ្ញុំក្លាយជាមនុស្សថ្មីម្នាក់ហើយ!»។

**នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៨៧០៖** មរណភាពរបស់លោកស្រី ហ័ដសិន ថេល័រ (លោកស្រី ម៉ារា ដាយយ័រ)។

**នៅខែមីនា ឆ្នាំ១៨៧២៖** ការចូលនិវត្តន៍របស់លោកគ្រូ ដាប់បិលយូ. ប៊ើកហ្គើរ។

**នៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៨៧២៖** ការបង្កើតក្រុមប្រឹក្សាក្រុងឡុងដ៍នៃអង្គការបេសកកម្មចិនដីគោក។

**នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៨៧២៖** ការវិលត្រឡប់មកប្រទេសចិនវិញជាមួយលោកស្រីថេល័រ (លោកស្រី ហ្វូលឌីង)

**នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៨៧៤៖** កំណត់ត្រាអធិស្ឋានសម្រាប់អ្នកត្រួសត្រាយជាបេសកជនសម្រាប់ខេត្តទាំងប្រាំបួនដែលដំណឹងល្អទៅមិនដល់។

**នៅខែមិថុនា ឆ្នាំ១៨៧៤៖** បើកសាខាបេសកកម្មប៉ែកខាងលិចនៅវូឆាងជាមួយលោកគ្រូ ជូដ៍។

**នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៨៧៤៖** មរណភាពរបស់កញ្ញា អិមមីលី ប្លេតឆ្លេយ។

**នៅរដូវរងាឆ្នាំ១៨៧៤-១៨៧៥៖** ការធ្លាក់ខ្លួនដល់ចំណុចទាបបំផុត—លោកគ្រូ ហ័ដសិន បានសម្រាកនៅប្រទេសអង់គ្លេសដោយសារតែពិការនៅអវយវៈខាងក្រោម

(paralyzed)។

**នៅខែមករា ឆ្នាំ១៨៧៥៖** អំពាវនាវឲ្យអធិស្ឋានសុំអ្នកត្រួសត្រាយផ្លូវចំនួន១៨នាក់សម្រាប់ខេត្តដែលដំណឹងល្អទៅមិនដល់ទាំងប្រាំបួន។

**នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៨៧៦៖** ចុះហត្ថលេខាលើអនុសញ្ញាឆិហ្វូ។

**ពីឆ្នាំ១៨៧៦-១៨៧៨៖** ពង្រីកដំណើរផ្សាយដំណឹងល្អនានាពាសពេញទឹកដីចិនដីគោក។

**នៅរដូវរំហើយ ឆ្នាំ១៨៧៨៖** លោកស្រី ថេល័រ ដឹកនាំក្រុមបេសកជនស្ត្រីៗឈានមុខទៅកាន់ទឹកដីដ៏សែនឆ្ងាយ។

**នៅរដូវរំហើយ ឆ្នាំ១៨៧៩៖** លោកស្រី ចច នីខូល និងលោកស្រី ជី. ដឹបបលយូ ក្លាក (Mrs G. W. Clarke ) បានត្រួសត្រាយផ្លូវសម្រាប់ការងាររបស់ស្ត្រីនៅភាគខាងលិចនៃប្រទេសចិន។

**នៅខែឧសភា ឆ្នាំ១៨៨១៖** មរណភាពរបស់លោកស្រី ចច ឃីង នៅហានឆុង។

**នៅខែវិច្ឆិកា ឆ្នាំ១៨៨១៖** ការអំពាវនាវសុំអ្នកចម្រូតទាំងចិតសិបនាក់ (វ៉ូឆាង)។

**នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៨៨៥៖** ការចាកចេញទៅប្រទេសចិនរបស់ក្រុមខេមប្រ៊ីជ។

**នៅថ្ងៃទី១៣ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៨៨៦៖** ការប្រជុំលើកដំបូងនៃក្រុមប្រឹក្សាចិន និងអំពាវនាវរកអ្នកចម្រូតទាំងមួយរយនាក់ (នៅអានឃីង)។

**នៅខែធ្នូ ឆ្នាំ១៨៨៧៖** ដំណើរទស្សនកិច្ចទៅកាន់ប្រទេសអង់គ្លេសរបស់លោកគ្រូ ហ៊ែនរី ដាប់បិលយូ. ហ្វ្រូសធ៍ ដោយអញ្ជើញលោក ហ៉ដសិន ទៅសហរដ្ឋអាមេរិក។

**នៅរដូវក្តៅ ឆ្នាំ១៨៨៨៖** ដំណើរទស្សនកិច្ចទីមួយរបស់លោកគ្រូ ហ៉ដសិន ទៅកាន់អាមេរិកខាងជើង។

**នៅខែតុលា ឆ្នាំ១៨៨៩៖** ទស្សនវិស័យធំបំផុតនៃជីវិតរបស់គាត់ (ការផ្សាយដំណឹងល្អដល់គ្រប់មនុស្សជាតិ)។

**នៅខែវិច្ឆិកា ឆ្នាំ១៨៨៩៖** ដំណើរទស្សនកិច្ចជាលើកទីមួយទៅកាន់ប្រទេសស៊ុយអែត ណ័រវេ និងដាណឺម៉ាក។

**នៅខែសីហា ឆ្នាំ១៨៩០៖** ដំណើរទស្សនកិច្ចជាលើកដំបូងនៅប្រទេសអូស្ត្រាលី។

**នៅខែឧសភា ឆ្នាំ១៩០០៖** ការចាប់ផ្តើមផ្ទុះឡើងនៃ «ការបះបោរអ្នកប្រដាល់»។

**នៅខែសីហា ឆ្នាំ១៩០០៖** លោកគ្រូ ឌី. អ៊ី. ហូសធ៍ បានតែងតាំងជាអគ្គនាយកស្ដីទី។

**នៅខែវិច្ឆិកា ឆ្នាំ១៩០២៖** លោកគ្រូ ហ៉ដសិន លាលែងពីតំណែងនាយកប្រតិបត្តិ ហើយលោកគ្រូ ឌី. អ៊ី. ហូសធ៍ ឡើងមកកាន់តំណែងជំនួស។

**នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩០៤៖** មរណភាពរបស់លោកស្រី ហ៉ដសិន នៅក្នុងប្រទេសស្វីស។

**នៅខែកុម្ភៈ ឆ្នាំ១៩០៥៖** ដំណើរត្រឡប់ទៅកាន់ប្រទេសចិនជាលើកចុងក្រោយរបស់លោកគ្រូ ហ៉ដសិន។

**នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩០៥៖** មរណភាពរបស់លោកគ្រូ ហ៉ដសិន នៅស្រុកហ៊ូណាន។

**នៅឆ្នាំ១៩២៧៖** ការត្រាស់ហៅឲ្យមានអ្នកចម្រូតបន្ថែម ២០០ នាក់ទៀត។

**នៅឆ្នាំ១៩៣០៖** គោលការណ៍នៃការគ្រប់គ្រងដោយខ្លួនឯងនៅក្នុងក្រុមជំនុំ។

**នៅឆ្នាំ១៩៣៤៖** លោក ចន និងលោកស្រី ប៉ែតធី ស្ដែម ត្រូវគេសម្លាប់នៅខេត្តអែនញយ។

**នៅឆ្នាំ១៩៤៩៖** ពួកកុម្មុយនិស្តកាន់កាប់ប្រទេសចិន។

**នៅឆ្នាំ១៩៤៩៖** បានចាត់បញ្ជូនអ្នកចម្រូតថ្មី ៤៩ នាក់ទៀត ទោះបីជាមានសម្ពាធកើតឡើងក៏ដោយ។

**នៅឆ្នាំ១៩៥០-១៩៥២៖** អង្គការ ស៊ី. អាយ. អិម ត្រូវបានដកចេញពីប្រទេសចិន ហើយចាប់ផ្ដើមធ្វើនៅប្រទេសផ្សេងវិញ។

**នៅឆ្នាំ១៩៦៤៖** អង្គការ ស៊ី. អាយ. អិម បានប្ដូរឈ្មោះទៅជាអង្គការ អូ. អិម. អេហ្វ. (O.M.F អក្សរពេញ “Overseas Missionary Fellowship”)។

**នៅអំឡុងឆ្នាំ១៩៧០-១៩៨០៖** ក្រុមជំនុំនៅក្នុងប្រទេសចិនមានសមាជិកកើនឡើងរហូតដល់ ២១.៥ លាននាក់ដែលបានទទួលពិធីបុណ្យជ្រមុជទឹក។

**នៅឆ្នាំ១៩៨៨៖** គេបានចាត់គ្រីស្ទបរិស័ទដែលមានជំនាញដំបូងទៅបម្រើជាបេសកជននៅប្រទេសចិន។

**នៅឆ្នាំ១៩៨៩៖** ចាប់ផ្ដើមការឈោងចាប់ប្រជាជនអាស៊ីនៅប្រទេសភាគខាងលិច។

**នៅឆ្នាំ១៩៩០៖** ឈោងចាប់ប្រទេសដែលបិតមិនឲ្យដំណឹងល្អចូលចំនួន៦បន្ថែមទៀត។

**នៅឆ្នាំ១៩៩៣៖** អង្គការត្រូវបានប្តូរឈ្មោះទៅជាអង្គការ អូ. អិម. អេហ្វ. អន្តរជាតិ (OMF International)។

**នៅឆ្នាំ១៩៩៨៖** បានផ្តោតទៅលើកន្លែងដែលមានអ្នកជឿលើពុទ្ធសាសនា។

**នៅឆ្នាំ២០០៦៖** លោកបណ្ឌិត ផាទ្រីក ហ្វុង (Dr. Patrick Fung) ត្រូវបានតែងតាំងជានាយកប្រតិបត្តិជនជាតិអាស៊ីដំបូង។ គាត់បានផ្តល់ជា «ការត្រាស់ហៅអ្នកចម្រូត ៩០០ នាក់» ពេលមកដល់៥ឆ្នាំ។

**នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០៖** មានសមាជិកថ្មីចំនួន ៥៩៩ នាក់បន្ថែមទៀតដែលបានចូលរួម ធ្វើការជាមួយអង្គការ អូ. អិម. អេហ្វ. អន្តរជាតិចាប់តាំងពីឆ្នាំ២០០៦។ អង្គការ អូ. អិម. អេហ្វ. អន្តរជាតិ មានសមាជិកជិតដល់ ៣ ពាន់នាក់ ដែលក្នុងនោះមាន ៣៦ ប្រទេសបានចូលរួម ហើយបានធ្វើការតាំងពីនៅការិយាល័យក្នុងប្រទេសកំណើតរហូតដល់តំបន់អាស៊ីខាងកើត។



កាលលោក ហ៉ដសិន ថេល័រ នៅអាយុ ២១ឆ្នាំ (គំនូរប្រេង)



លោក ហ័ដសិន ថេល័រ និងលោកស្រី ម៉ារា ថេល័រ នៅឆ្នាំ១៨៦០



ក្រុមឡាមើម័រ (Lammermuir group ឆ្នាំ១៨៦៦) លោក ហ៉ាដសិន ថេល័រ និងលោកស្រី ម៉ារា ថេល័រ ជាមួយនឹងកូនៗបួននាក់របស់ពួកគាត់ បានចេញដំណើរជាលើកដំបូងជាមួយក្រុមបេសកជន១៦នាក់ផ្សេងទៀត នៃអង្គការបេសកកម្មចិនដីគោកទៅកាន់ប្រទេសចិន




នៅឆ្នាំ១៨៨២ ផែនទីនៃអង្គការបេសកកម្មចិនដីគោក បង្ហាញ
អំពីទីតាំងបេសកកម្មរបស់ខ្លួន (ចំណុចក្រហម)



ក្រុមខេមប្រ៊ីជ សេវិន នៅឆ្នាំ១៨៨៥



លោក ហ័ដសិន ថេល័រ នៅឆ្នាំ១៨៩០

មានធនធានជាច្រើនទៀតនៅ៖

ផ្លូវពិត
plovpit.com

ហើយទាញយកសៀវភៅជា
ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com